



# ច្បាប់សិទ្ធិមនុស្សកម្ពុជា

## សេចក្តីប្រកាសសិទ្ធិមនុស្សក្នុងរដ្ឋធម្មនុញ្ញកម្ពុជា
## និងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដែលធានាការពារដោយរដ្ឋធម្មនុញ្ញ

អង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ

*កម្ពុជា*

ការិយាល័យឧត្តមស្នងការ

អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

# ច្បាប់សិទ្ធិមនុស្សកម្ពុជា

## សេចក្តីប្រកាសសិទ្ធិមនុស្សក្នុងរដ្ឋធម្មនុញ្ញកម្ពុជា
## និងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដែលធានាការពារដោយរដ្ឋធម្មនុញ្ញ


អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ

*កម្ពុជា*

**២០១២**

OFFICE OF THE UNITED NATIONS HIGH COMMISSIONER
FOR HUMAN RIGHTS

# Cambodian Human Rights Law

The Declaration of Human Rights in the Cambodian Constitution and the international human rights treaties guaranteed by the Constitution

UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER
*Cambodia*

2012

# មាតិកា

បុព្វកថា

## ក. សេចក្ដីប្រកាសអំពីសិទ្ធិមនុស្សក្នុងរដ្ឋធម្មនុញ្ញកម្ពុជា

១- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (សម្រង់) ---------------------------------- ៣

ជំពូកទី២ អំពីព្រះមហាក្សត្រ ----------------------------------------៤

ជំពូកទី៣ អំពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋ --------------------៤

ជំពូកទី៤ អំពីរបបនយោបាយ ------------------------------------១០

ជំពូកទី៦ អំពី អប់រំ វប្បធម៌ និងសង្គមកិច្ច ---------------------១០

ជំពូកទី១១ អំពីអំណាចតុលាការ --------------------------------- ១១

២- កិច្ចព្រមព្រៀងស្ដីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា (សម្រង់) ---- ១៥

៣- កិច្ចព្រមព្រៀងស្ដីពីអធិបតេយ្យភាព ឯករាជ្យ បូរណភាព និងភាពមិនអាច
រំលោភបាននៃទឹកដី អព្យាក្រិត្យភាព និងឯកភាពជាតិរបស់កម្ពុជា ----------១៨

៤- សេចក្ដីថ្លែងការណ៍ស្ដីពីការស្ដារ និងការកសាងប្រទេសកម្ពុជាឡើងវិញ (សម្រង់)---២០

## ខ. សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានា ដែលបានធានាការពារដោយរដ្ឋធម្មនុញ្ញ

៥- ធម្មនុញ្ញសហប្រជាជាតិ (ដកស្រង់ពីបុព្វកថា) ------------------------ ២៥

៦- សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស -----------------------------២៧

៧- កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ -------------៣៧

៧-ក- ពិធីសារបន្ថែមលើកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច
និងវប្បធម៌ពាក់ព័ន្ធនឹងការទទួលយកនីតិវិធីបណ្ដឹងបុគ្គល -------------------- ៥៣

៨- កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ---------------- ៦៥

៨-ក- ពិធីសារបន្ថែមលើកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ
ពាក់ព័ន្ធនឹងការទទួលយកនីតិវិធីបណ្ដឹងបុគ្គល ------------------------- ៨៩

៨-ខ- ពិធីសារបន្ថែមលើកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ
ពាក់ព័ន្ធនឹងការលប់ចោលទោសប្រហារជីវិត ------------------------- ៩៥

៩- អនុសញ្ញាអន្តរជាតិស្ដីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ --------- ៩៩

១០-   អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ---------១១៧
១០-ក-ពិធីសារបន្ថែមលើអនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ-១៣៥
១១-   អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ----------------------- ១៤៣
១១-ក-ពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ---------១៦១
១២-   អនុសញ្ញាស្តីពីសិទ្ធិកុមារ --------------------------------------១៧៧
១២-ក-ពិធីសារបន្ថែមលើអនុសញ្ញាស្តីពីសិទ្ធិកុមារ ពាក់ព័ន្ធនឹងការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ ------------------------------ ២០៧
១២-ខ-ពិធីសារបន្ថែមលើអនុសញ្ញាស្តីពីសិទ្ធិកុមារ ពាក់ព័ន្ធនឹងការលក់កុមារ ពេស្យាកម្មកុមារ និងកាមសាស្ត្រកុមារ ------------------------------២១៧
១២-គ-ពិធីសារបន្ថែមលើអនុសញ្ញាស្តីពីសិទ្ធិកុមារ ពាក់ព័ន្ធនឹងនីតិវិធីបណ្តឹង ----------២២៩
១៣-   អនុសញ្ញាស្តីពីសិទ្ធិជនពិការ ------------------------------------២៤៧
១៣-ក-ពិធីសារបន្ថែមលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ ------------------------២៩៣
១៤-   អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិរបស់ពលករទេសន្តប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ -----------------------------------៣០១
១៥-   អនុសញ្ញាអន្តរជាតិស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ------------៣៧៩
១៦-   អនុសញ្ញាពាក់ព័ន្ធឋានៈនៃជនភៀសខ្លួន ---------------------------- ៤២១
១៦-ក-ពិធីសារពាក់ព័ន្ធឋានៈនៃជនភៀសខ្លួន ---------------------------- ៤៤១
១៧-   អនុសញ្ញាស្តីពីការបង្ការ និងការផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ -----៤៤៥

## គ. <u>ឧបសម្ព័ន្ធ</u>

១៦-   សេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ០៩២/០០៣/២០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ពាក់ព័ន្ធនឹងការអនុវត្តន៍សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានាដោយតុលាការកម្ពុជា ------------------------------------------ ៤៥៣

## Contents


Preface

*A. The Declaration of Human Rights in the Cambodian Constitution*

1. Constitution of the Kingdom of Cambodia (extract) ....3
   Chapter II: The King ....4
   Chapter III: The Rights and Obligations of Citizens ....4
   Chapter IV: Political System ....10
   Chapter VI: Educational, Cultural and Social Affairs ....10
   Chapter XI: The Judiciary ....11
2. Agreement on a comprehensive political settlement to the Cambodia conflict (extract) ....15
3. Agreement concerning the sovereignty, independence, territorial integrity and inviolability, neutrality and national unity of Cambodia ....18
4. Declaration on the rehabilitation and reconstruction of Cambodia (extract) ....20

*B. International human rights treaties guaranteed under the Constitution*

5. Charter of the United Nations (extract from Preamble) ....25
6. Universal Declaration of Human Rights ....27
7. International Covenant on Economic, Social and Cultural Rights ....37

7a. Optional Protocol to the International Covenant on Economic, Social and Cultural Rights regarding the acceptance of the individual complaints procedure ....53

8. International Covenant on Civil and Political Rights ....65

8a. Optional Protocol to the International Covenant on Civil and Political Rights regarding the acceptance of the individual complaints procedure ....89

8b. Optional Protocol to the International Covenant on Civil and Political Rights regarding the abolition of the death penalty ....95

9. International Convention on the Elimination of All Forms of Racial Discrimination ....99

10. Convention on the Elimination of All Forms of Discrimination against Women ....117
10a Optional Protocol to the Convention on the Elimination of All Forms of Discrimination against Women ....135

11. Convention against Torture and Other Cruel Inhuman or Degrading Treatment or Punishment....143

11a. Optional Protocol to the Convention against Torture and Other Cruel Inhuman or Degrading Treatment or Punishment ....161

12. Convention on the Rights of the Child ....177

12a. Optional Protocol to the Convention on the Rights of the Child on the involvement of children in armed conflict....207

12b. Optional Protocol to the Convention on the Rights of the Child on the sale of children, child prostitution and child pornography....217

12c. Optional Protocol to the Convention on the Rights of the Child on the Individual Communication ....229

13. Convention on the Rights of Persons with Disabilities ....247

13a. Optional Protocol to the Convention on the Rights of Persons with Disabilities ....293

14. International Convention on the Protection of the Rights of All Migrant Workers and Members of their Families....301

15. International Convention for the Protection of All Persons from Enforced Disappearance....379

16. Convention relating to the Status of Refugees....421

16a. Protocol relating to the Status of Refugees ....441

17. Convention on the Prevention and Punishment of the Crime of Genocide ....445

*Appendix*

16. Decision of the Constitutional Council No.092/003/2007 of 10 July 2007 regarding the applicability of the international human rights treaties by the courts of Cambodia ....453

# ច្បាប់សិទ្ធិមនុស្សក្នុងរដ្ឋធម្មនុញ្ញកម្ពុជា
# សេចក្តីប្រកាសអំពីសិទ្ធិមនុស្សក្នុងរដ្ឋធម្មនុញ្ញកម្ពុជា
# និងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានា ដែលបានធានាការពារដោយរដ្ឋធម្មនុញ្ញ

## បុព្វកថា

អត្ថបទទាំងឡាយដែលបានដាក់បញ្ចូលក្នុងកម្រងច្បាប់នេះ តំណាងឱ្យឯកសារជាមូលដ្ឋាន នៃច្បាប់សិទ្ធិមនុស្សកម្ពុជាដែលបានធានាការពារដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ការការពារសិទ្ធិមនុស្សក្រោមរដ្ឋធម្មនុញ្ញ ត្រូវបានធ្វើឡើងតាមវិធីពីរយ៉ាងគឺ : ទីមួយអនុលោមតាមកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស រដ្ឋធម្មនុញ្ញបញ្ចូលសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សដែលអាចរកឃើញភាគច្រើននៅក្នុងជំពូកទី៣នៃរដ្ឋធម្មនុញ្ញ ហើយទីពីរគឺ មាត្រា៣១ នៃរដ្ឋធម្មនុញ្ញ ដែលបានបញ្ចូលដោយផ្ទាល់នូវលិខិតុបករណ៍សិទ្ធិមនុស្សសំខាន់ៗមួយចំនួនទៅក្នុងច្បាប់កម្ពុជា ។

*ក- សេចក្តីប្រកាសអំពីសិទ្ធិមនុស្សក្នុងរដ្ឋធម្មនុញ្ញកម្ពុជា*

កិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ ដែលបានបញ្ចប់ជាផ្លូវការនូវជម្លោះកម្ពុជា បានបង្កើតបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ជាមូលដ្ឋានមួយសំរាប់សន្តិភាពជាអមតៈនៅកម្ពុជា ។ មាត្រា១៥ នៃកិច្ចព្រមព្រៀង ស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជាចែងថា :

*"ជនគ្រប់រូបនៅកម្ពុជា និងជនភៀសខ្លួន និងជនផ្លាស់ប្តូរទីកន្លែងកម្ពុជា ត្រូវមានសិទ្ធិ និងសេរីភាពដូចមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិដទៃទៀតដែលពាក់ព័ន្ធ" ។*

ហត្ថលេខីទាំងអស់បានធ្វើការប្តេជ្ញាចិត្តមួយដ៏ជាក់លាក់ ដើម្បីធានាការគោរពសិទ្ធិមនុស្ស នៅកម្ពុជា គាំទ្រសិទ្ធិប្រជាពលរដ្ឋខ្មែរ ក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស ហើយចាត់វិធានការដ៏មានប្រសិទ្ធភាព "ដើម្បីធានាថា នយោបាយ និងការប្រព្រឹត្តពីអតីតកាល មិនអនុញ្ញាតឱ្យវិលត្រឡប់មកវិញឡើយ" ។

កិច្ចព្រមព្រៀងនេះក៏បានចែងអំពីការដាក់បញ្ចូលនូវសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ទៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ។ ឧបសម្ព័ន្ធទី៥ នៃកិច្ចព្រមព្រៀងនេះចែងថា :

" ប្រវត្តិសាស្ត្រថ្មីៗ ប្រកបដោយសោកនាដកម្មនៅកម្ពុជា ទាមទារឱ្យមានវិធានការពិសេស

ដើម្បីធានាការការពារសិទ្ធិមនុស្ស ។ ហេតុដូច្នេះ រដ្ឋធម្មនុញ្ញត្រូវរួមមានសេចក្ដីថ្លែងការណ៍មួយ អំពីសិទ្ធិជាមូលដ្ឋាននៅក្នុងនោះ មានសិទ្ធិមានជីវិតរស់នៅ សេរីភាពរបស់បុគ្គល សន្ដិសុខ សេរីភាពក្នុងការធ្វើដំណើរ សេរីភាពក្នុងជំនឿសាសនា រួមប្រជុំគ្នា និងបង្កើតសមាគមរួមទាំងការបង្កើតគណបក្សនយោបាយ និងសហជីព ដំណើរការតុលាការត្រឹមត្រូវ និងភាពស្មើគ្នាចំពោះមុខច្បាប់ ការការពារកុំឱ្យមានការដកហូតកម្មសិទ្ធិតាមតែទំនើងចិត្ត ឬការដកហូតកម្មសិទ្ធិឯកជនដោយគ្មានការសងជម្ងឺចិត្តដ៏ត្រឹមត្រូវ និងសេរីភាពដោយគ្មានការប្រកាន់រើសអើងពូជសាសន៍ ជនជាតិ ជំនឿ សាសនា ឬភេទឡើយ ។ រដ្ឋធម្មនុញ្ញ ត្រូវហាមឃាត់នូវការអនុវត្តន៍ច្បាប់ឧក្រិដ្ឋ ទៅលើឧក្រិដ្ឋកម្មដែលកើតឡើងក្នុងអតីតកាល ។ សេចក្ដីប្រកាសត្រូវសមស្របទៅនឹងប្រការទាំងឡាយនៃសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស ព្រមទាំងកិច្ចព្រមព្រៀងអន្ដរជាតិដទៃទៀតដែលពាក់ព័ន្ធ ។ បុគ្គលដែលត្រូវគេរំលោភបំពាន មានសិទ្ធិប្ដឹងទៅតុលាការ ដើម្បីកាត់សេចក្ដី និងធ្វើឱ្យគេគោរពសិទ្ធិទាំងអស់នេះ ។”

ស្របតាមបទបញ្ញត្តិនេះ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា បញ្ចូលសេចក្ដីប្រកាសមួយស្ដីពីសិទ្ធិជាមូលដ្ឋាន ក្នុងជំពូកទី៣ អំពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ។ បទបញ្ញត្តិមួយចំនួនទៀតនៃរដ្ឋធម្មនុញ្ញក៏មានចែងផងដែរ អំពីការការពារសិទ្ធិមនុស្ស ហើយត្រូវបានបញ្ចូលក្នុងកម្រងច្បាប់នេះ ។

*ខ- សន្ធិសញ្ញាសិទ្ធិមនុស្សអន្ដរជាតិនានា ដែលបានធានាការពារដោយរដ្ឋធម្មនុញ្ញ*

កិច្ចព្រមព្រៀងទីក្រុងប៉ារីស បានបញ្ចូលការប្ដេជ្ញាចិត្តមួយដ៏ជាក់លាក់ ក្នុងការផ្ដល់សច្ចាប័នសន្ធិសញ្ញាសិទ្ធិមនុស្សអន្ដរជាតិនានា ។ អាស្រ័យហេតុនេះ កម្ពុជាបានក្លាយជាភាគីនៃសន្ធិសញ្ញាទាំងឡាយខាងក្រោមនេះ :

អនុសញ្ញាអន្ដរជាតិស្ដីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (២៨ ធ្នូ ១៩៨៣)
កតិកាសញ្ញាអន្ដរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (២៦ សីហា ១៩៩២)
កតិកាសញ្ញាអន្ដរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (២៦ សីហា ១៩៩២)
អនុសញ្ញាស្ដីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ដ្រីភេទ (១៤ វិច្ឆិកា ១៩៩២)
អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (១៤ វិច្ឆិកា ១៩៩២) និងពិធីសារបន្ថែមនៃអនុសញ្ញានេះ (២៩ មេសា ២០០៧)
អនុសញ្ញាស្ដីពីសិទ្ធិកុមារ (១៤ វិច្ឆិកា ១៩៩២) និងពិធីសារបន្ថែមពីរនៃអនុសញ្ញានេះ ។

ម្យ៉ាងវិញទៀត កម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញាអន្ដរជាតិស្ដីពីការការពារសិទ្ធិកម្មករទេសន្ដរប្រវេសន៍

និងសមាជិកគ្រួសារទាំងអស់របស់ពួកគេ អនុសញ្ញាស្តីពីសិទ្ធិជនពិការនិងពិធីសារបន្ថែមនៃអនុសញ្ញានេះ ព្រមទាំងពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងអនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទពាក់ព័ន្ធនឹងនីតិវិធីបណ្តឹងបុគ្គល ។ ការចុះហត្ថលេខាលើសន្ធិសញ្ញានេះ បង្ហាញអំពីចេតនារបស់រដ្ឋាភិបាល ក្នុងការផ្តល់សច្ចាប័ននៅពេលដ៏ខ្លីខាងមុខ ។

មាត្រា៣១ នៃរដ្ឋធម្មនុញ្ញ ធានាការពារសន្ធិសញ្ញានីមួយៗទាំងនេះថាជាផ្នែកមួយនៃច្បាប់ជាតិ ហើយមាត្រា៤៨ ផ្តល់ការការពារបន្ថែមទៀត ទៅលើអនុសញ្ញាស្តីពីសិទ្ធិកុមារ ។

ក្រុមប្រឹក្សាធម្មនុញ្ញគឺជាស្ថាប័នមួយដែលបានបង្កើតឡើង ដើម្បីធានាការគោរពរដ្ឋធម្មនុញ្ញ ។ នៅក្នុងសេចក្តីសំរេចរបស់ខ្លួន ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ក្រុមប្រឹក្សាធម្មនុញ្ញបានបញ្ជាក់ជាថ្មីអំពីការអនុវត្តន៍សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានានៅក្នុងច្បាប់កម្ពុជា ហើយបានរំលឹកចៅក្រមថា ក្នុងការសំរេចករណីរឿងផ្សេងៗ ចៅក្រមត្រូវយកច្បាប់កម្ពុជាទាំងអស់មកពិចារណា “រួមទាំងរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល និងច្បាប់ឯទៀតដែលនៅជាធរមាន ព្រមទាំងអនុសញ្ញាអន្តរជាតិទាំងអស់ដែលកម្ពុជាបានទទួលស្គាល់.....”

អាស្រ័យហេតុនេះ សិទ្ធិជនគ្រប់រូបនៅកម្ពុជា គួរត្រូវបានគោរពយ៉ាងពេញលេញដោយច្បាប់កម្ពុជា ក្រោមរដ្ឋធម្មនុញ្ញ ស្របតាមគោលការណ៍នីតិរដ្ឋ ។

កិច្ចព្រមព្រៀងទីក្រុងប៉ារីស បានកំណត់ឱ្យអង្គការសហប្រជាជាតិបន្តឃ្លាំមើលស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជា បន្ទាប់ពីសម័យអន្តរកាល ហើយបច្ចុប្បន្ន មុខងារនេះបាននឹងកំពុងបំពេញដោយតំណាងពិសេសរបស់លោកអគ្គលេខាធិការ ស្របតាមអាណត្តិដែលផ្តល់ដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស ។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សបានរក្សាទុកការិយាល័យមួយប្រចាំនៅកម្ពុជាតាំងពីឆ្នាំ១៩៩៣ ដោយមានការយល់ព្រមពីរាជរដ្ឋាភិបាល ។ ការិយាល័យប្រចាំនៅកម្ពុជា គឺជាការិយាល័យមួយក្នុងចំណោមការិយាល័យប្រចាំតំបន់ឯទៀត ដែលការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស បានរក្សាទុកនៅក្នុងប្រទេសនានាជុំវិញពិភពលោក ។

*ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា*

*ខែវិច្ឆិកា ឆ្នាំ២០០៧*

## Cambodian Constitutional Human Rights Law

*The Declaration of Human Rights in the Cambodian Constitution and the International Human Rights Treaties guaranteed under the Constitution*

## Preface

The texts included in this compilation represent the basic documents of Cambodian human rights law as guaranteed by the Constitution of the Kingdom of Cambodia. The protection of human rights under the Constitution is done in two ways: firstly, in accordance with the Paris Peace Accords, the Constitution includes a declaration of human rights, which can be found mainly in Chapter III of the Constitution; secondly, article 31 of the Constitution incorporates certain key international human rights instruments directly into Cambodian law.

### *A. The Declaration of Human Rights in the Cambodian Constitution*

The 1991 Paris Peace Accords, which formally ended the Cambodia conflict, established international human rights norms as a basis for lasting peace in Cambodia. Article 15 of the Agreement on a comprehensive political settlement of the Cambodia conflict states that:

> *All persons in the Cambodia and all Cambodian refugees and displaced persons shall enjoy the rights and freedoms embodied in the Universal Declaration of Human Rights and other relevant international human rights instruments.*

The signatories made a specific commitment to ensure respect for human rights in Cambodia, support the right of Cambodians to promote and protect human rights and take effective measures "to ensure that the policies and practices of the past shall never be allowed to return".

The Agreement provided for the incorporation of a declaration of human rights in the Cambodian Constitution. Annex 5 of the Agreement states:

> *Cambodia's tragic recent history requires special measures to assure protection of human rights. Therefore the constitution will contain a declaration of fundamental rights, including the rights to life, liberty, security, freedom of movement, freedom of religion, assembly and association including political parties and trade unions, due process and equality before the law, protection from arbitrary deprivation of property or deprivation of private property without just compensation, and freedom from racial, ethnic, religious or sexual discrimination. It will prohibit the retroactive application of criminal law. The declaration will be consistent with the Universal Declaration of Human Rights and other relevant instruments. Aggrieved individuals will be entitled to have the courts adjudicate and enforce these rights.*

In accordance with this provision, the 1993 Constitution of the Kingdom of

Cambodia includes a declaration of fundamental rights in Chapter III: The Rights and Obligations of Citizens of Cambodia. Certain other provisions of the Constitution are also relevant to the protection of human rights and are included in this compilation.

*B. International human rights treaties guaranteed under the Constitution*

The Paris Accords included a specific commitment to ratify the international human rights treaties. Accordingly, Cambodia has become party to the following treaties:

International Convention on the Elimination of All Forms of Racial Discrimination (28 December 1983);

International Covenant on Economic, Social and Cultural Rights (26 August 1992);

International Covenant on Civil and Political Rights (26 August 1992);

Convention on the Elimination of All Forms of Discrimination against Women (14 November 1992);

Convention against Torture and Other Cruel Inhuman or Degrading Treatment or Punishment (14 November 1992) and its Optional Protocol (29 April 2007);

Convention on the Rights of the Child (14 November 1992) and its two Optional Protocols.

In addition, Cambodia has signed the International Convention on the Protection of the Rights of All Migrant Workers and Members of their Families, the Convention on the Rights of Persons with Disabilities and its Optional Protocol and the optional protocols to both the International Covenant on Civil and Political Rights and the Convention of the Elimination of Discrimination against Women regarding the individual complaints procedures. Signing a treaty indicates the Government's intention to ratify in the near future.

Article 31 of the Constitution guarantees each of these treaties as part of Cambodian domestic law and article 48 gives additional protection to the Convention on the Rights of the Child.

The Constitutional Council is the body established under the Constitution to safeguard respect for the Constitution. In its decision of 10 July 2007, the Constitutional Council reaffirmed the application of the international human rights treaties in Cambodian law and reminded judges that, in deciding cases, they are obliged to consider all Cambodian law, "including the Constitution, which is the supreme law, and other applicable laws as well as the international conventions that Cambodia has recognized…"

As a result, the human rights of everyone in Cambodia should be fully protected by Cambodian law under the Constitution in accordance with the rule of law.

The Paris Accords provided for the United Nations to continue to monitor the human rights situation in Cambodia after the transitional period, a function currently undertaken by a Special Representative of the Secretary-General in accordance with a mandate given by the Human Rights Council.

The Office of the United Nations High Commissioner for Human Rights (OHCHR) has maintained a country office in Cambodia since 1993 with the agreement of the Royal Government. The Cambodia country office is one of an increasing number of field offices maintained by OHCHR in different countries around the world.

*OHCHR Cambodia, November 2007*

# រដ្ឋធម្មនុញ្ញ
# នៃ
# ព្រះរាជាណាចក្រកម្ពុជា

## ក-សេចក្តីប្រកាសអំពីសិទ្ធិមនុស្សក្នុងរដ្ឋធម្មនុញ្ញកម្ពុជា

### ១- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

**រដ្ឋធម្មនុញ្ញ**

**នៃព្រះរាជាណាចក្រកម្ពុជា**

**សភាធម្មនុញ្ញ**

រដ្ឋធម្មនុញ្ញ/លេខ.../២៤ កញ្ញា ១៩៩៣/រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

**យើង**

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជា

យោងតាមមាត្រាទី១៣៥ និង១៣៦ នៃជំពូក១៤ ស្តីអំពីអន្តរប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា អនុម័តដោយសភាធម្មនុញ្ញនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ។

**ត្រាស់បង្គាប់**

**មាត្រា ១ :** ប្រកាសឱ្យប្រើជាផ្លូវការភ្លាមនូវរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលសភាធម្មនុញ្ញ បានអនុម័តនៅថ្ងៃទី២១ ខែកញ្ញា គ.ស ១៩៩៣ ។

**មាត្រា ២ :** សភាធម្មនុញ្ញបានត្រឡប់ទៅជារដ្ឋសភានៃកម្ពុជាចាប់ពីពេលនេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកញ្ញា គ.ស ១៩៩៣

**នរោត្តម សីហនុ**

# បុព្វកថា
# យើងប្រជារាស្ត្រខ្មែរ

ដែលធ្លាប់មានអារ្យធម៌ឧត្តុងឧត្តម ប្រទេសជាតិស្តុកស្តម្ភ ធំទូលាយថ្កុំថ្កើងរុងរឿង កិត្យានុភាពខ្ពង់ខ្ពស់ ភ្លឺចែងចាំងដូចពេជ្រពណ្ណរាយ

បានធ្លាក់ខ្លួនដ៏សែនរន្ធត់ ក្នុងអំឡុងពីរទសវត្សចុងក្រោយនេះ ឆ្លងកាត់ទុក្ខសោក វិនាសអន្តរាយទ្រុឌទ្រោម ឱនថយមហាសោកស្តាយ

បានភ្ញាក់រលឹក ក្រោកឈរឡើង ចងបាច់ឆន្ទៈមោះមុត ប្តូរផ្តាច់ រួបរួមគ្នាពង្រឹង ឯកភាពជាតិ រក្សាការពារទឹកដីកម្ពុជា អធិបតេយ្យថ្លៃថ្លា និងអារ្យធម៌អង្គរដ៏បវរ កសាងប្រទេសជាតិឱ្យទៅជា "កោះសន្តិភាព" ឡើងវិញ ផ្អែកលើប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស ធានាសិទ្ធិមនុស្ស គោរពច្បាប់ ទទួលខុសត្រូវខ្ពស់ ចំពោះវាសនាអនាគតជាតិ ឱ្យបានឈានឡើង រីកចំរើនលូតលាស់ សម្បូររុងរឿង ជានិច្ចនិរន្តរ៍ ។

## ក្នុងឆន្ទៈមោះមុតនេះ

យើងសរសេរចារឹកក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដូចតទៅ :.......

[នេះគ្រាន់តែជាសម្រង់រដ្ឋធម្មនុញ្ញនៃជំពូក និងមាត្រាដែលចារឹកទុកពីបទប្បញ្ញត្តិទាំងឡាយដែលទាក់ទងនឹងសិទ្ធិមនុស្សប៉ុណ្ណោះ]

## ជំពូកទី២: អំពីព្រះមហាក្សត្រ

មាត្រា ៨ :

ព្រះមហាក្សត្រ ព្រះអង្គទ្រង់ជានិមិត្តរូបនៃឯកភាពជាតិ និងនិរន្តភាពជាតិ ។

ព្រះមហាក្សត្រ ទ្រង់ជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យនិងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ជាអ្នកធានាការគោរពសិទ្ធិនិងសេរីភាពរបស់ប្រជាពលរដ្ឋនិងការគោរពសន្ធិសញ្ញាអន្តរជាតិ។

## ជំពូកទី ៣: អំពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ

មាត្រា ៣១ :

ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ។

ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។

ការប្រើសិទ្ធិ សេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវអោយប៉ះពាល់ដល់សិទ្ធិ សេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមល័ក្ខខ័ណ្ឌកំណត់ក្នុងច្បាប់ ។

មាត្រា ៣២ :

ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន ។

ទោសប្រហារជីវិតមិនត្រូវអោយមានឡើយ ។

មាត្រា ៣៣ :

ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។

ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឯបរទេសត្រូវបានរដ្ឋគាំពារ ។

ការទទួលសញ្ជាតិខ្មែរ ត្រូវកំណត់ក្នុងច្បាប់ ។

មាត្រា ៣៤ : - ថ្មី

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច១៨ឆ្នាំ មានសិទ្ធិបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច ២៥ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច៤០ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា ។

បទប្បញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត ត្រូវចែងក្នុងច្បាប់បោះឆ្នោត ។

មាត្រា ៣៥ :

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ ។

សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ ។

មាត្រា ៣៦ :

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរ សមស្របតាមសមត្ថភាពរបស់ខ្លួន តាមសេចក្តីត្រូវការរបស់សង្គម ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នា ចំពោះការងារដូចគ្នា ។

ការងារមេផ្ទះ មានតំលៃស្មើគ្នានឹងកំរៃដែលបានមកពីការងារដែលធ្វើនៅក្រៅផ្ទះ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ច ដែលមានចែងក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពនេះ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃសហជីព នឹងមានកំណត់ក្នុងច្បាប់ ។

មាត្រា ៣៧ :

សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធី ត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃច្បាប់ ។

មាត្រា ៣៨ :

ច្បាប់រ៉ាប់រង មិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ ។

ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើតលុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។

ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវហាមឃាត់មិនឱ្យធ្វើឡើយ ។ អ្នកដែលដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិត ត្រូវទទួលទោសតាមច្បាប់ ។

ការទទួលសារភាព ដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ ។

វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ។

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។

មាត្រា ៣៩ :

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្ដឹងបរិហារ ប្ដឹងតវ៉ា ឬប្ដឹងទារសំណងជួសជុលការខូចខាតដែលបណ្ដាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ ។ ការដោះស្រាយបណ្ដឹងតវ៉ា និងសំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ ។

មាត្រា ៤០ :

សេរីភាពក្នុងការធ្វើដំណើរឆ្ងាយជិត និងតាំងទីលំនៅក្នុងស្ថានភាពស្របច្បាប់របស់ប្រជាពលរដ្ឋត្រូវបានគោរព ។

ប្រជាពលរដ្ឋខ្មែរ អាចចេញទៅតាំងទីលំនៅនៅប្រទេសក្រៅ ឬវិលត្រឡប់មកវិញបាន ។

ការរក្សាសិទ្ធិមិនឱ្យរំលោភលើលំនៅឋាន និងអាថ៌កំបាំងនៃការឆ្លើយឆ្លងតាមលិខិត តាមសារទូរលេខ ទូរពុម្ព ទូរគមន៍ និងតាមទូរស័ព្ទ ត្រូវបានធានា ។

ការឆែកឆេរលំនៅឋាន សម្ភារៈ វត្ថុ និងលើរូបបុគ្គល ត្រូវធ្វើឱ្យស្របនឹងបញ្ញត្តិច្បាប់ ។

មាត្រា ៤១ :

ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភនាំឱ្យប៉ះពាល់ដល់ កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្ដាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។

របបសារព័ត៌មាន ត្រូវរៀបចំឡើងដោយច្បាប់ ។

មាត្រា ៤២ :

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគមនិងគណបក្សនយោបាយ ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់។

ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជន ជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និងសណ្ដាប់ធ្នាប់សង្គម ។

មាត្រា ៤៣ :

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិពេញទីខាងជំនឿ ។ សេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនា ត្រូវបានរដ្ឋធានាក្នុងលក្ខខណ្ឌ ដែលមិនប៉ះពាល់ដល់ជំនឿ ឬសាសនាដទៃទៀតដល់សណ្ដាប់ធ្នាប់ និងសន្តិសុខសាធារណៈ ។

ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ ។

មាត្រា ៤៤ :

ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តីមានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី ។

កម្មសិទ្ធិឯកជនស្របច្បាប់ ឋិតនៅក្រោមការគាំពារនៃច្បាប់ ។

ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើ ក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុន ដោយសមរម្យ និងយុត្តិធម៌ ។

មាត្រា ៤៥ :

ការរើសអើងគ្រប់ប្រភេទ ប្រឆាំងនឹងស្ត្រីភេទ ត្រូវបំបាត់ចោល ។

ការធ្វើអាជីវកម្ម លើការងាររបស់ស្ត្រី ត្រូវហាមឃាត់ ។

បុរស និងស្ត្រី មានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ ។

អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយ ប្រពន្ធមួយ ។

មាត្រា ៤៦ :

អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាស ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារី ត្រូវហាមឃាត់ ។

ត្រូវហាមឃាត់មិនឱ្យមានការបញ្ឈប់នារីពីការងារ ដោយមូលហេតុមានគភ៌។ នារីមានសិទ្ធិឈប់សំរាក នៅពេលសំរាលកូន ដោយទទួលប្រាក់បៀវត្ស និងដោយមានការធានារក្សាសិទ្ធិអតីតភាពក្នុងការងារ និងអត្ថប្រយោជន៍សង្គមផ្សេងៗទៀត។

រដ្ឋ និងសង្គមយកចិត្តទុកដាក់បង្កលក្ខណៈឱ្យនារី ជាពិសេសនារីនៅជនបទ ដែលគ្មានទីពឹង បានទទួលការឧបត្ថម្ភ ដើម្បីមានមុខរបរ មានលទ្ធភាពព្យាបាលជំងឺ ឱ្យកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ ។

មាត្រា ៤៧ :

មាតាបិតា មានកាតព្វកិច្ចចិញ្ចឹម ថែរក្សា និងអប់រំកូនឱ្យទៅជាពលរដ្ឋល្អ ។

កូនមានករណីយកិច្ចចិញ្ចឹម និងបីបាច់ថែរក្សាមាតាបិតាដែលចាស់ជរាតាមទំនៀមទំលាប់ខ្មែរ ។

មាត្រា ៤៨ :

រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារ ក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច ឬកាមគុណលើកុមារ ។

រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើអោយខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខមាលភាពរបស់កុមារ ។

មាត្រា ៤៩ :

ប្រជាពលករដ្ឋខ្មែរគ្រប់រូប ត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់ ។

ប្រជាពលរដ្ឋខ្មែរគ្រប់រូប មានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ ។

កាតព្វកិច្ចការពារមាតុភូមិ ត្រូវអនុវត្តតាមបញ្ញត្តិច្បាប់ ។

មាត្រា ៥០ :

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ត្រូវគោរពគោលការណ៍អធិបតេយ្យជាតិ និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ត្រូវគោរពព្រទ្យសម្បត្តិសាធារណៈ និងកម្មសិទ្ធស្របច្បាប់របស់ឯកជន ។

## ជំពូកទី ៤: អំពីរបបនយោបាយ

មាត្រា ៥១ : -ថ្មី

ព្រះរាជាណាចក្រកម្ពុជា អនុវត្តរបបនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរ ជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។

អំណាចទាំងអស់ ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួន តាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជំរះក្តី ។

អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។

## ជំពូកទី ៦: អំពី អប់រំ វប្បធម៌ និងសង្គមកិច្ច

មាត្រា ៦៥ :

រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលការអប់រំ ប្រកបដោយគុណភាព នៅគ្រប់កំរិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីអោយការអប់រំនេះ បានទៅដល់ប្រជាពលរដ្ឋគ្រប់រូប ។

រដ្ឋយកចិត្តទុកដាក់ លើវិស័យអប់រំកាយ និងកីឡា ដែលជាសុខុមាលភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ។

មាត្រា ៦៦ :

រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាព នៅទូទាំងប្រទេស ដែលធានាឱ្យបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការ និងគោលការណ៍សមភាពក្នុងការអប់រំ ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូបមានភ័ព្វសំណាងគ្រប់គ្រាន់ ស្មើគ្នា ក្នុងការកសាងជីវិត ។

មាត្រា ៦៨ :

រដ្ឋផ្តល់កិច្ចការអប់រំផ្នែកបឋម និងមធ្យមសិក្សា នៅសាលារៀនសាធារណៈសំរាប់ប្រជាពលរដ្ឋគ្រប់រូប ដោយឥតបង់ថ្លៃ ។

ប្រជាពលរដ្ឋ ត្រូវបានទទួលការអប់រំយ៉ាងតិច ប្រាំបួនឆ្នាំ ។

រដ្ឋជួយផ្សព្វផ្សាយ និងលើកតំកើងសាលាបាលី និងពុទ្ធិកសិក្សា ។

មាត្រា ៧២ :

សុខភាពរបស់ប្រជារាស្ត្រត្រូវបានធានា ។ រដ្ឋយកចិត្តទុកដាក់ដល់ការការពារជម្ងឺ និងព្យាបាលជម្ងឺ ។ ប្រជារាស្ត្រក្រីក្រត្រូវបានទទួលការពិនិត្យរោគ ដោយឥតបង់ថ្លៃនៅតាមមន្ទីរពេទ្យ គិលានដ្ឋាន និងមន្ទីរសម្ភពសាធារណៈ ។

រដ្ឋរៀបចំឱ្យមានគិលានដ្ឋាន និងមន្ទីរសម្ភពដល់ជនបទ ។

មាត្រា ៧៣ :

រដ្ឋយកចិត្តទុកដាក់ចំពោះកុមារ និងមាតា ។ រដ្ឋរៀបចំអោយមានទារកដ្ឋាន និងជួយឧបត្ថម្ភនារីដែលមានកូនច្រើនក្នុងបន្ទុក ហើយឥតទីពឹង ។

មាត្រា ៧៤ :

រដ្ឋជួយឧបត្ថម្ភជនពិការ និងគ្រួសារយុទ្ធជន ដែលបានបូជាជីវិតដើម្បីប្រទេសជាតិ ។

មាត្រា ៧៥ :

រដ្ឋចាត់ចែងអោយមានរបបសន្តិសុខសង្គម ដល់កម្មករ និងនិយោជិក ។

## ជំពូកទី ១១ ថ្មី: អំពី អំណាចតុលាការ

មាត្រា ១២៨ : - ថ្មី (មាត្រា១០៩ ចាស់)

អំណាចតុលាការ ជាអំណាចឯករាជ្យ ។

អំណាចតុលាការ ធានារក្សាអនាគតិ និងការពារសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ ។

អំណាចតុលាការ គ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ។

អំណាចនេះ ត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជំរះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ ។

មាត្រា ១២៩ : -ថ្មី (មាត្រា១១០ ចាស់)

ការជំរះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន ។

មានតែចៅក្រមទេ ដែលមានសិទ្ធិជំរះក្តី ។ ចៅក្រមត្រូវបំពេញភារកិច្ចនេះ ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន ។

មាត្រា ១៣០ : - ថ្មី (មាត្រា១១១ ចាស់)

គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ។

មាត្រា ១៣១ : - ថ្មី (មាត្រា១១២ ចាស់)

មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា ។

មាត្រា ១៣២ : - ថ្មី (មាត្រា១១៣ ចាស់)

ព្រះមហាក្សត្រ ទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ ។

# កិច្ចព្រមព្រៀង
# ស្ដីពី
# ដំណោះស្រាយនយោបាយរួមមួយ
# នៃ
# ជម្លោះកម្ពុជា

## ២- កិច្ចព្រមព្រៀងស្ដីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា

បណ្ដារដ្ឋដែលបានចូលរួមក្នុងសន្និសិទទីក្រុងប៉ារីសស្ដីពីកម្ពុជា គឺអូស្ត្រាលី ប្រ៊ុយណេដារូសាឡាម កម្ពុជា កាណាដា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋបារាំង សាធារណរដ្ឋឥណ្ឌា សាធារណរដ្ឋឥណ្ឌូណេស៊ី ជប៉ុន សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី រាជាណាចក្រថៃឡង់ សហភាពសាធារណរដ្ឋសង្គមនិយមសូវៀត រាជាណាចក្រអង់គ្លេសនិងអៀកឡង់ខាងជើង សហរដ្ឋអាមេរិក សាធារណរដ្ឋសង្គមនិយមវៀតណាម និងសាធារណរដ្ឋសហព័ន្ធសង្គមនិយមយូហ្គោស្លាវី ។

នៅចំពោះវត្តមាននៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ

*ដើម្បីថែរក្សា* និងការពារអធិបតេយ្យភាព-ឯករាជ្យ បូរណភាព និងភាពមិនអាចរំលោភបាននៃដែនដី អព្យាក្រិតភាព និងឯកភាពជាតិរបស់កម្ពុជា។

*ដោយចង់* ស្ដារឡើងវិញ និងថែរក្សាសន្តិភាពនៅកម្ពុជា ជំរុញការបង្រួបបង្រួមជាតិ និងធានាឱ្យប្រជាជនកម្ពុជាប្រើប្រាស់សិទ្ធិស្វ័យសម្រេចតាមរយៈការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ។

*ដោយជឿជាក់ថា* មានតែដំណោះស្រាយនយោបាយរួមមួយសម្រាប់ជម្លោះកម្ពុជាទេ ទើបបានជាដំណោះស្រាយមួយយុត្តិធម៌ និងយូរអង្វែង ហើយនិងរួមវិភាគទានដល់សន្តិភាព និង សន្តិសុខក្នុងតំបន់ និងអន្តរជាតិ។

*ដោយស្វាគមន៍* ឯកសារក្របខ័ណ្ឌ ថ្ងៃទី២៨ សីហា ១៩៩០ ដែលបានព្រមព្រៀងទាំងស្រុងដោយភាគីកម្ពុជាធ្វើជាមូលដ្ឋាន សម្រាប់ដោះស្រាយនៃជម្លោះកម្ពុជា ហើយបន្ទាប់មកត្រូវបានយល់ព្រមជាឯកច្ឆ័ន្ទដោយក្រុមប្រឹក្សាសន្តិសុខតាមសេចក្ដីសម្រេចចិត្តលេខ៦៦៨“១៩៩០” ចុះថ្ងៃទី២០ កញ្ញា ១៩៩០ និងដោយមហាសន្និបាត អ.ស.ប តាមសេចក្ដីសម្រេចចិត្តលេខ៤៥.៣ ចុះថ្ងៃទី១៥ តុលា ១៩៩០។

*ដោយកត់សំគាល់* ការបង្កើតឡើងនូវក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា នៅហ្សាការតា ថ្ងៃទី ១០ កញ្ញា ១៩៩០ ជាអង្គការស្ថាប័នស្របច្បាប់ និងជាប្រភពអំណាចតែមួយគត់នៅកម្ពុជា ដែលនៅក្នុងទូទាំងដំណាក់កាលអន្តរកាល ជាតំណាងតំកល់ អធិបតេយ្យភាព និងឯកភាពជាតិ ហើយដែលតំណាងកម្ពុជានៅបរទេស។

*ដោយស្វាគមន៍* ការជ្រើសតាំងជាឯកច្ឆ័ន្ទនូវសម្ដេច នរោត្តម សីហនុ ជាប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់ នៅប៉េកាំង ថ្ងៃទី១៧ កក្កដា ១៩៩១។

*ដោយទទួលស្គាល់ថា* តួនាទីដ៏ទូលំទូលាយ របស់អង្គការសហប្រជាជាតិ ទាមទារឱ្យបង្កើត អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិមួយនៅកម្ពុជា "អ៊ុនតាក់" ដោយមានផ្នែកយោធា និងផ្នែកស៊ីវិល ដែលនឹងបំពេញភារកិច្ចដោយគោរពទាំងស្រុងដល់អធិបតេយ្យភាពជាតិរបស់កម្ពុជា

*ដោយកត់សម្គាល់* នូវសេចក្តីថ្លែងការណ៍នៅពេលចប់កិច្ចប្រជុំដែលបានប្រព្រឹត្តទៅនៅហ្សាការតា ថ្ងៃទី៩-១០ កញ្ញា ១៩៩០ នៅប៉ារីស ថ្ងៃទី២១-២៣ ធ្នូ ១៩៩០ នៅប៉ាតាយ៉ា ថ្ងៃទី២៤-២៦ មិថុនា ១៩៩១ នៅប៉េកាំង ថ្ងៃទី១៦-១៧ កក្កដា ១៩៩១ នៅប៉ាតាយ៉ា ថ្ងៃទី២៦-២៩ សីហា ១៩៩១ ព្រម ទាំងកិច្ចប្រជុំនៅហ្សាការតា ថ្ងៃទី៤-៦ មិថុនា ១៩៩១ និងនៅញូវយ៉ក ថ្ងៃទី ១៩ កញ្ញា ១៩៩១

*ដោយស្វាគមន៍* សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ៧១៧ "១៩៩១" ចុះថ្ងៃទី១៦ តុលា ១៩៩១ ស្តីពីកម្ពុជា

*ដោយទទួលស្គាល់ថា* ប្រវត្តិសាស្ត្រថ្មីៗ ប្រកបដោយសោកនាដកម្មរបស់កម្ពុជា ទាមទារអោយ មានវិធានការពិសេស ដើម្បីធានាការពារសិទ្ធិមនុស្ស និងការមិនវិលត្រឡប់មកវិញនៃនយោបាយ និង អំពើប្រព្រឹត្តពីអតីតកាល

*បានព្រមព្រៀង* ដូចតទៅនេះ :...

[នេះគ្រាន់តែជាសម្រង់នៃជំពូក និងបទប្បញ្ញត្តិទាំងឡាយដែលទាក់ទងនឹងសិទ្ធិមនុស្ស ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសប៉ុណ្ណោះ]

## ភាគទី ៣
## សិទ្ធិមនុស្ស
## មាត្រាទី ១៥

១- មនុស្សគ្រប់រូបនៅក្នុងប្រទេសកម្ពុជា និងជនភៀសខ្លួន និងជនផ្លាស់ប្តូរទីកន្លែងនៅកម្ពុជា ទាំងអស់ត្រូវមានសិទ្ធិ និងសេរីភាព ដែលមានចែងនៅក្នុងសេចក្តីប្រកាសជាសកលពីសិទ្ធិមនុស្ស និង ក្នុងបណ្តាកិច្ចព្រមព្រៀងអន្តរជាតិទាំងឡាយដែលពាក់ព័ន្ធដល់ ស្តីពីសិទ្ធិមនុស្ស ។

២- ដើម្បីសម្រេចទិសដៅនេះ :

ក- ប្រទេសកម្ពុជាសន្យាថានឹង :

- ធានាគោរព និងប្រតិបត្តិតាមសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាននៅកម្ពុជា
- គាំទ្រសិទ្ធិរបស់ពលរដ្ឋកម្ពុជាទាំងអស់ ក្នុងការធ្វើសកម្មភាពដែលជំរុញ និង ការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន។

- ចាត់បណ្ដាវិធានការដ៏មានប្រសិទ្ធភាព ដើម្បីធានាថា នយោបាយ និងអំពើប្រព្រឹត្តិក្នុងអតីតកាល មិនត្រូវបានអនុញ្ញាតឱ្យវិលត្រឡប់មកវិញដាច់ខាត
- ចូលរួមកិច្ចព្រមព្រៀងជាអន្តរជាតិទាំងឡាយដែលពាក់ព័ន្ធដល់សិទ្ធិមនុស្ស

ខ- ហត្ថលេខីផ្សេងៗទៀតនៃកិច្ចព្រមព្រៀងនេះ សន្យាថាជួយជំរុញ និងលើកទឹកចិត្តដល់ការគោរព និងប្រតិបត្តិតាមសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាននៅក្នុងកម្ពុជា ដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងអន្តរជាតិទាំងឡាយ និងសេចក្ដីសម្រេចចិត្តទាំងឡាយរបស់មហាសន្និបាត អ.ស.ប ដែលទាក់ទងនឹងបញ្ហានេះដើម្បីជាពិសេសការពារទប់ទល់នឹងការកកើតឡើងវិញការរំលោភសិទ្ធិមនុស្សជាថ្មីទៀត។

## មាត្រាទី ១៦

ក្នុងដំណាក់កាលអន្តរកាល អ៊ុនតាក់ "UNTAC" ត្រូវទទួលខុសត្រូវបណ្ដុះបណ្ដាលបរិយាកាសមួយ ធានាដល់ការគោរពសិទ្ធិមនុស្ស ដោយផ្អែកលើប្រការដែលមានចែងក្នុងឧបសម្ព័ន្ធទី១ជំពូក ង ។

## មាត្រាទី ១៧

ក្រោយពីរយៈកាលអន្តរកាលត្រូវបានបញ្ចប់ គណៈកម្មការ អ.ស.ប ស្ដីពីសិទ្ធិមនុស្ស គប្បីបន្តការតាមដានឱ្យបានជិតដល់ពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ហើយបើចាំបាច់ មានរួមទាំងការតែងតាំងអ្នកធ្វើកំណត់ហេតុពិសេសម្នាក់ ដែលត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំ ស្ដីពីលទ្ធផលនៃការរកឃើញរបស់ខ្លួន ទៅជូនគណៈកម្មការ និងមហាសន្និបាត ។

## ភាគទី ៧
## គោលការណ៍សម្រាប់រដ្ឋធម្មនុញ្ញថ្មីមួយរបស់កម្ពុជា
## មាត្រាទី ២៣

បណ្ដាគោលការណ៍ជាមូលដ្ឋាន ដោយរួមទាំងគោលការណ៍ស្ដីពីសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ក៏ដូចជាគោលការណ៍ស្ដីពីលក្ខន្តិកៈរបស់កម្ពុជាជាប្រទេសអព្យាក្រឹតមួយ ហើយដែលត្រូវបញ្ចូលក្នុងរដ្ឋធម្មនុញ្ញកម្ពុជាថ្មីនោះ គឺមានចែងនៅក្នុងឧបម្ព័ន្ធទី៥ ។

## ឧបសម្ព័ន្ធទី ៥
## បណ្ដាគោលការណ៍សម្រាប់រដ្ឋធម្មនុញ្ញថ្មីមួយរបស់កម្ពុជា

១- រដ្ឋធម្មនុញ្ញ គឺជាច្បាប់កំពូលរបស់ប្រទេស ។ គេអាចធ្វើការកែប្រែរដ្ឋធម្មនុញ្ញនេះបានលុះត្រាតែមានរបៀបរបបចាត់តាំងមួយទាក់ទងដល់ការយល់ព្រមពីអង្គការនីតិបញ្ញត្តិ ការធ្វើប្រជាមតិ ឬក៏ដោយវិធីទាំងពីរនេះតែម្ដង ។

២- ប្រវត្តិសាស្ត្រថ្មីៗ ប្រកបដោយសោកនាដកម្មនៅកម្ពុជា ទាមទារឱ្យមានវិធានការពិសេស ដើម្បីធានាការការពារសិទ្ធិមនុស្ស ។ ហេតុដូច្នេះ រដ្ឋធម្មនុញ្ញ ត្រូវរួមមានសេចក្តីថ្លែងការណ៍មួយអំពីសិទ្ធិជាមូលដ្ឋាន នៅក្នុងនោះមាន សិទ្ធិក្នុងការមានជីវិតរស់នៅ សេរីភាពរបស់បុគ្គល សន្តិសុខ សេរីភាពក្នុងការធ្វើដំណើរ សេរីភាពក្នុងជំនឿសាសនា ការរួមប្រជុំគ្នា និងបង្កើតសមាគម រួមមានគណបក្សនយោបាយ និងសហជីព ដំណើរការតុលាការត្រឹមត្រូវ និងភាពស្មើគ្នាចំពោះមុខច្បាប់ ការការពារកុំអោយមានការដកហូតកម្មសិទ្ធិដោយវិធីផ្តាច់ការឬការដកហូតកម្មសិទ្ធិឯកជនដោយគ្មានការសងជម្ងឺចិត្តដ៏ត្រឹមត្រូវ និងសេរីភាពដោយគ្មានការប្រកាន់រើសអើងពូជសាសន៍ ជនជាតិ ជំនឿសាសនាឬភេទឡើយ។ រដ្ឋធម្មនុញ្ញត្រូវហាមឃាត់នូវការអនុវត្តន៍ច្បាប់ឧក្រិដ្ឋទៅលើឧក្រិដ្ឋកម្មដែលកើតឡើងក្នុងអតីតកាល។ សេចក្តីប្រកាសត្រូវសមស្របទៅនឹងប្រការទាំងឡាយ នៃសេចក្តីប្រកាសជាសកលអំពីសិទ្ធិមនុស្ស ព្រមទាំងកិច្ចព្រមព្រៀងអន្តរជាតិដទៃទៀតដែលពាក់ព័ន្ធ ។ បុគ្គលដែលត្រូវគេរំលោភបំពាន មានសិទ្ធិប្តឹងទៅតុលាការ ដើម្បីកាត់សេចក្តី និងធ្វើឱ្យគេគោរពសិទ្ធិទាំងអស់នេះ ។

៣- រដ្ឋធម្មនុញ្ញ ត្រូវប្រកាសអំពីលក្ខន្តិកៈប្រទេសកម្ពុជា ជារដ្ឋអធិបតេយ្យ ឯករាជ និងអព្យាក្រឹតមួយ និងអំពីឯកភាពជាតិរបស់ប្រជាជនកម្ពុជា ។

៤- រដ្ឋធម្មនុញ្ញត្រូវប្រកាសថាកម្ពុជានឹងអនុវត្តប្រព័ន្ធប្រជាធិបតេយ្យសេរីដោយឈរលើមូលដ្ឋានពហុបក្ស ។ រដ្ឋធម្មនុញ្ញ ត្រូវកំណត់ឱ្យមានការបោះឆ្នោតដ៏ត្រឹមត្រូវ និងតាមកាលវេលា ។ រដ្ឋធម្មនុញ្ញត្រូវអនុញ្ញាតសិទ្ធិសម្រាប់បោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោត តាមរបៀបបោះឆ្នោតដោយសកលនិងស្មើភាព ។ រដ្ឋធម្មនុញ្ញត្រូវអនុញ្ញាតឱ្យមានការបោះឆ្នោតដោយសម្ងាត់ ដោយតម្រូវឱ្យទម្រង់បែបបទនៃការបោះឆ្នោត ត្រូវផ្តល់ឱកាសគ្រប់គ្រាន់ និងសមរម្យដើម្បីរៀបចំ និងចូលរួមក្នុងដំណើរការបោះឆ្នោត។

៥- ត្រូវបង្កើតអង្គការតុលាការមួយឯករាជ ដែលត្រូវមានអំណាចដាក់ឱ្យអនុវត្តបណ្តាសិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។

៦- រដ្ឋធម្មនុញ្ញ ត្រូវអនុម័តដោយសម្លេងភាគច្រើន ពីរភាគបីនៃសមាជិករបស់សភាធម្មនុញ្ញ ។

## ៣- កិច្ចព្រមព្រៀងទាក់ទិននៅនឹងអធិបតេយ្យភាព ឯករាជ្យ បូរណភាព និងភាពមិនអាចរំលោភបាន នៃដែនដីអព្យាក្រិតភាព និងឯកភាពជាតិរបស់កម្ពុជា

អូស្ត្រាលី-ប្រ៊ុយណេដារូសាឡាម-កម្ពុជា-កាណាដា-សាធារណរដ្ឋប្រជាមានិតចិន-សាធារណរដ្ឋបារាំង-សាធារណរដ្ឋឥណ្ឌា-សាធារណរដ្ឋឥណ្ឌូណេស៊ី-ជប៉ុន-សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ-ម៉ាឡេស៊ី-សាធារណរដ្ឋហ្វីលីពីន-សាធារណរដ្ឋសិង្ហបុរី-រាជាណាចក្រថៃឡង់-សហភាពសាធារណរដ្ឋសង្គមនិយមសូវៀត-ចក្រភពអង់គ្លេសនិងអៀកឡង់ខាងជើង-សហរដ្ឋអាមេរិក-សាធារណរដ្ឋសង្គមនិយមវៀតណាម និងសាធារណរដ្ឋសហព័ន្ធសង្គមនិយមយូហ្គោស្លាវី ។

ដោយមានវត្តមានរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ

ដោយជឿជាក់ថា ដំណោះស្រាយនយោបាយរួមមួយសម្រាប់កម្ពុជា មានសារសំខាន់សម្រាប់គោលដៅយូរអង្វែងនៃការរក្សាសន្តិភាព និងសន្តិសុខនៅអាស៊ីអគ្នេយ៍ ។

ដោយរំលឹកឡើងវិញ នូវកាតព្វកិច្ចរបស់ខ្លួន ស្របតាមធម្មនុញ្ញអង្គការសហប្រជាជាតិ និងបទប្បញ្ញត្តិនៃច្បាប់អន្តរជាតិដទៃទៀត ។

ដោយចាត់ទុកថា ការគោរពដ៏ពេញលេញនូវគោលការណ៍មិនជ្រៀតជ្រែក និងមិនអន្តរាគមន៍ចូលក្នុងកិច្ចការផ្ទៃក្នុង និងកិច្ចការក្រៅប្រទេសរបស់បណ្តារដ្ឋ គឺមានសារសំខាន់ដ៏ធំបំផុត សម្រាប់ថែរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ ។

ដោយអះអាងឡើងវិញ អំពីសិទ្ធិមិនអាចបាត់បង់បានរបស់បណ្តារដ្ឋ ដើម្បីសម្រេចដោយសេរីនូវប្រព័ន្ធនយោបាយ សេដ្ឋកិច្ច វប្បធម៌ និងសង្គមរបស់ខ្លួន ស្របតាមគោលបំណងរបស់ប្រជាជនខ្លួន ដោយគ្មានការជ្រៀតជ្រែក វិទ្ធង្សនា ការបង្ខិតបង្ខំ ឬគំរាមកំហែងពីខាងក្រៅ ទោះតាមរូបភាពបែបណាមួយក៏ដោយ ។

ដោយចង់ជំរុញ ការគោរព និងអនុវត្តតាមសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ស្របតាមធម្មនុញ្ញអង្គការសហប្រជាជាតិ និងច្បាប់អន្តរជាតិដែលទាក់ទិនដទៃៗទៀត ។

បានព្រមព្រៀងដូចតទៅ :

## មាត្រាទី ៣

១. មនុស្សទាំងអស់នៅកម្ពុជាត្រូវមានសិទ្ធិនិងសេរីភាពដែលបានចែងនៅក្នុងសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស និងច្បាប់អន្តរជាតិទាក់ទិននឹងសិទ្ធិមនុស្សដទៃទៀត ។

២. ក្នុងគោលដៅនេះ

ក. កម្ពុជាសន្យាថា :

- ធានាគោរព និងប្រតិបត្តិតាមសិទ្ធិមនុស្ស ហើយនិងសេរីភាពជាមូលដ្ឋាននៅកម្ពុជា

- គាំទ្រសិទ្ធិពលរដ្ឋកម្ពុជាទាំងអស់ ដើម្បីធ្វើសកម្មភាពដែលជំរុញ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ។

- ចាត់វិធានការដ៏មានប្រសិទ្ធភាព ដើម្បីធានាកុំឱ្យនយោបាយ និងអំពើប្រព្រឹត្តនៅក្នុងអតីតកាលវិលត្រឡប់មកវិញជាដាច់ខាត ។

- ចូលរួមក្នុងកិច្ចព្រមព្រៀងអន្តរជាតិ ស្តីពីសិទ្ធិមនុស្សដែលទាក់ទិន

ខ. ភាគីឯទៀតដែលចូលរួមក្នុងកិច្ចព្រមព្រៀងនេះ សន្យាបង្កើត និងលើកទឹកចិត្តដល់ការគោរព និងការអនុវត្តន៍តាមសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាននៅកម្ពុជាដូចមានចែងក្នុងកិច្ចព្រមព្រៀងអន្តរជាតិដើម្បីជាពិសេសទប់ស្កាត់កុំឱ្យមានការរំលោភសិទ្ធិមនុស្សឡើងវិញ ។

៣. គណៈកម្មការអំពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ត្រូវបន្តតាមដានដោយជិតដល់ពីស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជា រួមទាំងក្នុងករណីចាំបាច់ ចាត់តាំងអ្នករាយការណ៍ពិសេសម្នាក់ ដែលត្រូវរាយការណ៍អំពីលទ្ធផលនៃការរកឃើញរបស់ខ្លួនជារៀងរាល់ឆ្នាំ ជូនទៅគណៈកម្មការ និងទៅមហាសន្និបាតអង្គការសហប្រជាជាតិ ។

## ៤- សេចក្តីថ្លែងការណ៍ស្តីពីការស្តារ និងការកសាងប្រទេសកម្ពុជាឡើងវិញ

១- ទិសដៅជាបឋមនៃការកសាងប្រទេសកម្ពុជាឡើងវិញ គឺជាការរីកចំរើន នៃប្រជាជាតិ និងប្រជាជនកម្ពុជា ដោយគ្មានការប្រកាន់រើសអើង ឬការធ្វើអោយខូចប្រយោជន៍ ហើយដោយគោរពយ៉ាងពេញលេញដល់សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានសម្រាប់ជនគ្រប់រូប ។ ដើម្បីសម្រេចឱ្យបានគោលដៅនេះ គឺត្រូវទាមទារការអនុវត្តន៍ដ៏ពេញលេញ នូវដំណោះស្រាយនយោបាយរួមមួយ ។

២- ការទទួលខុសត្រូវជាសំខាន់ ក្នុងការសម្រេចអំពីសេចក្តីត្រូវការ និងគម្រោងផែនការទាំងឡាយ សម្រាប់ការកសាងប្រទេសកម្ពុជាឡើងវិញ ត្រូវស្ថិតនៅលើប្រជាជន និងរដ្ឋាភិបាលកម្ពុជាដែលត្រូវបង្កើតឡើង តាមរយៈការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ ។ មិនត្រូវមានការប៉ុនប៉ងពីសំណាក់ប្រភពខាងក្រៅណាមួយ ដើម្បីបង្ខិតបង្ខំឱ្យប្រទេសកម្ពុជា ទទួលយកនូវយុទ្ធសាស្រ្តអភិវឌ្ឍន៍មួយ ឬរារាំងទាយក "អ្នកផ្តល់អំណោយ" ទាំងឡាយក្នុងការចូលរួមចំណែកដល់ការកសាងប្រទេសកម្ពុជាឡើងវិញនោះឡើយ

៣- ជំនួយឧបត្ថម្ភជាលក្ខណៈអន្តរជាតិ ជាលក្ខណៈតំបន់ និងជាលក្ខណៈទ្វេភាគីដល់ប្រទេសកម្ពុជា គប្បីត្រូវបានសម្របសម្រួលជាអតិបរិមាតាមការដែលអាចធ្វើទៅបាន ដើម្បីបំពេញបន្ថែមទៅលើធនធានក្នុងប្រទេស ហើយនិង ត្រូវបានផ្តល់ឱ្យដោយឥតលំអៀង និងដោយគិតគូរយ៉ាងពេញលេញដល់អធិបតេយ្យភាព អាទិភាព មធ្យោបាយទាំងឡាយនៃស្ថាប័ននានា ហើយនិងសមត្ថភាពស្រូបយកជំនួយរបស់ប្រទេសកម្ពុជា ។

៤- នៅក្នុងក្របខ័ណ្ឌនៃកិច្ចប្រឹងប្រែងកសាងប្រទេសឡើងវិញនេះ ជំនួយសេដ្ឋកិច្ចត្រូវតែបំរើផលប្រយោជន៍ដល់គ្រប់តំបន់នៃប្រទេសកម្ពុជា ជាពិសេសតំបន់ដែលចាញ់ប្រៀបជាងគេ ហើយត្រូវតែបានទៅដល់គ្រប់ស្រទាប់នៃសង្គម ។

៥- ការអនុវត្តន៏នូវការខំប្រឹងប្រែងផ្តល់ជំនួយជាអន្តរជាតិត្រូវធ្វើឡើងជាកំណត់នៅក្នុងរយៈពេលមួយដែលទទួលស្គាល់ដោយជាក់ស្តែង នូវភាពចាំបាច់ខាងនយោបាយ និងបច្ចេកទេស ។ ការអនុវត្តន៏តម្រូវផងដែរឱ្យមានសហប្រតិបត្តិការដ៏សំខាន់មួយ រវាងអនាគតរដ្ឋាភិបាលកម្ពុជា និងអ្នកចូលរួមវិភាគទានជាទ្វេភាគីក្នុងតំបន់ និងអន្តរជាតិ ។

៦- ប្រពន្ធ័សហប្រជាជាតិ ត្រូវមានតួនាទីដ៏សំខាន់មួយក្នុងការស្តារ និងកសាងឡើងវិញ ។ ការចាប់ផ្តើមលើកផែនការកសាងឡើងវិញ និងការអំពាវនាវជាអន្តរជាតិ ដើម្បីរកវិភាគទាន ត្រូវប្រព្រឹត្តទៅនៅពេលដ៏សមស្រប ដើម្បីធានានូវជោគជ័យរបស់ខ្លួន ។

៧- គេមិនអាចផ្តួចផ្តើមកម្មវិធីដ៏មានប្រសិទ្ធភាព ស្តីពីការកសាងជាតិឡើងវិញបានទេ បើគ្មានការវាយតម្លៃលម្អិតអំពីភោគទ្រព្យខាងកម្លាំងមនុស្ស ខាងធម្មជាតិ និងខាងសេដ្ឋកិច្ចផ្សេងៗទៀតនោះ ។ ជាការចាំបាច់ ត្រូវធ្វើបញ្ជីជំរឿនប្រជាជន ។ ពិនិត្យរកមើលអំពីអាទិភាពផ្នែកខាងការអភិវឌ្ឍន៏ និងការកំណត់ឱ្យបានច្បាស់អំពីធនធាន ដែលមាននៅក្នុងប្រទេស និងក្រៅប្រទេស ។

ដើម្បីសម្រេចគោលបំណងនេះ ត្រូវមានគម្រោងបញ្ជូនទៅកាន់កម្ពុជា នូវបេសកកម្មស្វែងយល់ការពិតរបស់ប្រព័ន្ធអង្គការសហប្រជាជាតិ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងទីភ្នាក់ងារដទៃទៀតដោយមានការយល់ព្រមពីរដ្ឋាភិបាលកម្ពុជាអនាគត ។

៨- អាស្រ័យដោយគេសម្រេចបានដំណោះស្រាយនៃនយោបាយរួមនោះ នាពេលនេះ គេអាចធ្វើហើយគួរតែធ្វើនូវការផ្តួចផ្តើមដំណើរការស្តារឡើងវិញ សំដៅដោះស្រាយសេចក្តីត្រូវការជាបន្ទាន់ និងកសាងលក្ខណសម្បត្តិមូលដ្ឋាន សម្រាប់ការរៀបចំនូវផែនការកសាងឡើងវិញដែលមានរយៈពេលមធ្យម និងរយៈពេលវែង ។

៩- សម្រាប់ដំណាក់កាលនៃការស្តារឡើងវិញនេះ គេស្នើឱ្យអគ្គលេខាធិការអង្គការសហប្រជាជាតិ សម្របសម្រួលកម្មវិធីដឹកនាំដោយមនុស្សម្នាក់ដែលត្រូវបានតែងតាំងឡើងសម្រាប់គោលបំណងនេះ។

១០- នៅក្នុងដំណាក់កាលស្តារឡើងវិញនេះ ត្រូវយកចិត្តទុកដាក់ជាពិសេសទៅលើការផ្គត់ផ្គង់ស្បៀង សុខភាព ទីលំនៅ ការហ្វឹកហ្វឺន ការអប់រំ ប្រព័ន្ធគមនាគមន៏ និងការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន និងមធ្យោបាយ សម្ភារៈប្រើប្រាស់ជាសាធារណៈ ដែលមានស្រាប់របស់កម្ពុជា ។

១១- ការអនុវត្តន៏ផែនការអភិវឌ្ឍន៏ជាអន្តរជាតិ សម្រាប់រយៈពេលវែងស្តីពីការកសាងឡើងវិញ ត្រូវរងចាំដល់ការបង្កើតរដ្ឋាភិបាលមួយ បន្ទាប់ពីការបោះឆ្នោត និងការសម្រេចចិត្ត និងការអនុម័តនូវនយោបាយ និងអាទិភាពផ្ទាល់របស់ខ្លួន ។

១២- ដំណាក់កាលនៃការកសាងឡើងវិញនេះ ត្រូវជំរុញលើកកំពស់ស្មារតីរកស៊ីធ្វើសហគ្រាសរបស់កម្ពុជា ហើយប្រើប្រាស់វិស័យឯកជន ក្នុងចំណោមវិស័យនានាជាច្រើនទៀត ដើម្បីជួយជំរុញការរីកចំរើនសេដ្ឋកិច្ចដោយកម្លាំងខ្លួនផ្ទាល់។ ដំណាក់កាលនេះ ក៏ត្រូវទទួលផលប្រយោជន៍ពីតំបន់ផងដែរដែលក្នុងនោះមានការពាក់ព័ន្ធដល់ស្ថាប័ននានា ដូចជាគណៈកម្មការសេដ្ឋកិច្ច សង្គមកិច្ច សម្រាប់អាស៊ីប៉ាស៊ីហ្វិក "ESCAP" និងគណៈកម្មាធិការទន្លេមេគង្គជាដើម ហើយពីបណ្តារដ្ឋាភិបាលនៅក្នុងតំបន់ និងពីការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាល ។

១៣- ដើម្បីបានស៊ីចង្វាក់គ្នា និងតាមដានការធ្វើវិភាគទាន ដែលត្រូវផ្តល់ឱ្យដោយសហគមន៍អន្តរជាតិ សម្រាប់ការកសាងប្រទេសកម្ពុជាឡើងវិញ ក្រោយការបង្កើតរដ្ឋាភិបាលមួយ បន្ទាប់ពីការបោះឆ្នោត គេត្រូវបង្កើតស្ថាប័នពិគ្រោះយោបល់មួយ ហៅថា គណៈកម្មាធិការអន្តរជាតិស្តីពីការកសាងប្រទេសកម្ពុជាឡើងវិញ "ICORC" នៅពេលវេលាមួយសមស្រប និងបើកចំហចំពោះអ្នកធ្វើអំណោយ និងភាគីផ្សេងទៀតដែលទាក់ទិន ។ គេស្នើលោកអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ឱ្យធ្វើការរៀបចំពិសេសសម្រាប់អោយប្រព័ន្ធអង្គការសហប្រជាជាតិ គាំទ្រគណៈកម្មាធិការអន្តរជាតិស្តីពីការកសាងប្រទេសកម្ពុជាឡើងវិញ "ICORC" ក្នុងការធ្វើការងាររបស់ខ្លួន ដូចជាធ្វើឱ្យមានការផ្ទេរដោយគ្មានការរអាក់រអួលពីដំណាក់កាលស្តារឡើងវិញ ទៅដំណាក់កាលកសាងឡើងវិញ ។

# ធម្មនុញ្ញអង្គការសហប្រជាជាតិ

## ខ-សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានា ដែលបានធានាការពារដោយរដ្ឋធម្មនុញ្ញ

## ៥- ធម្មនុញ្ញអង្គការសហប្រជាជាតិ

**យើងទាំងអស់ជាប្រជារាស្ត្រនៃអង្គការសហប្រជាជាតិ បានសំរេចថា :**

- ការពារមនុស្សជំនាន់ជាបន្តទៅនេះ ពីការរងទុក្ខឈឺចាប់នៃសង្គ្រាម ព្រោះមហាសង្គ្រាមដែលបានកើតមានពីរលើកកន្លងមកនេះ ក្នុងឆាកជីវិតយើងទាំងអស់គ្នា បាននាំមកនូវសេចក្ដីទុក្ខសោកឥតគណនាដល់មនុស្សជាតិ ។
- អះអាងជាថ្មី ពីជំនឿចិត្តរបស់យើង ចំពោះសិទ្ធិមនុស្សជាសារវន្ត សេចក្ដីថ្លៃថ្នូរ នឹងតំលៃជាមនុស្ស សិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី និងរវាងប្រជាជាតិធំ និងប្រជាជាតិតូច ។
- បង្កើតលក្ខខណ្ឌដែលតាមរយៈនេះ យុត្តិធម៌ និងការគោរពកាតព្វកិច្ចដែលកើតចេញពីសន្ធិសញ្ញា និងប្រភពដទៃទៀតនៃច្បាប់អន្តរជាតិ អាចត្រូវបានថែរក្សាទុក ។
- លើកស្ទួយវឌ្ឍនភាពសង្គម និងបង្កើតលក្ខខណ្ឌជីវភាពដ៏ប្រពៃក្នុងសេរីភាពកាន់តែធំទូលាយ។

**ហើយដើម្បីធ្វើអោយបានសំរេចដល់គោលបំណងនេះ**

- អនុវត្តការអត់អោនឱ្យគ្នា ការរស់នៅជាមួយគ្នាក្នុងសន្តិភាពដោយគំនិតជាអ្នកជិតខាងល្អ ។
- រួបរួមកំលាំងគ្នា ដើម្បីរក្សានូវសន្តិភាព និងសន្តិសុខអន្តរជាតិ ។
- អះអាងពីការទទួលយកគោលការណ៍ និងការបង្កើតវិធី ដែលថាកំលាំងអាវុធមិនត្រូវបានយកមកប្រើទេ វៀរលែងតែបំរើអោយប្រយោជន៍រួមគ្នា ។
- ប្រើប្រាស់យន្តការអន្តរជាតិសំរាប់ការលើកស្ទួយវឌ្ឍនភាពសេដ្ឋកិច្ច និងសង្គមដល់ប្រជារាស្ត្រទាំងអស់។

**បានដោះស្រាយចងក្រងពីកិច្ចខិតខំប្រឹងប្រែងរបស់យើងដើម្បីញុំាងបំណងទាំងនេះអោយបានសំរេច**

អាស្រ័យហេតុនេះ រដ្ឋាភិបាលនីមួយៗរបស់យើង តាមរយៈនៃអ្នកតំណាងដែលបានចូលរួមប្រជុំនៅទីក្រុងសាន់ហ្វ្រាន់ស៊ីស្កូ ហើយដែលបានបង្ហាញអំណាចយ៉ាងពេញលេញរបស់ខ្លួន តាមទំរង់ល្អត្រឹមត្រូវ បានអនុម័តធម្មនុញ្ញសហប្រជាជាតិនេះ ហើយតាមរយៈនេះ ត្រូវបង្កើតអង្គការអន្តរជាតិមួយ ដែលត្រូវបានស្គាល់ជាទូទៅថា អង្គការសហប្រជាជាតិ ។ [....]

## មាត្រា ៥៥

ជាមួយនឹងទស្សនៈចំពោះការបង្កើតលក្ខខណ្ឌស្ថេរភាព និងសុខុមាលភាពដែលចាំបាច់ដល់ទំនាក់ទំនងដោយសន្តិវិធី និងមិត្តភាព រវាងប្រជាជាតិនានា ដោយឈរលើលើមូលដ្ឋានគោរពគោលការណ៍សិទ្ធិស្មើគ្នា និងសិទ្ធិស្វ័យសំរេចរបស់របស់ប្រជាជន អង្គការសហប្រជាជាតិ ត្រូវលើកស្ទួយ :

ក. កំរិតជីវភាពរស់នៅកាន់តែខ្ពស់ជាង ការអាស្រ័យផលយ៉ាងពេលលេញ និងលក្ខខណ្ឌនៃការអភិវឌ្ឍន៍ និងវឌ្ឍនភាពសេដ្ឋកិច្ច និងសង្គម ។

ខ. ដំណោះស្រាយបញ្ហាដែលទាក់ទងនឹងសុខភាព សង្គម សេដ្ឋកិច្ចអន្តរជាតិ និងបញ្ហាដែលពាក់ព័ន្ធ ព្រមទាំងកិច្ចសហប្រតិបត្តិការអប់រំ និងវប្បធម៌អន្តរជាតិ ។

គ. ការគោរព និងការប្រតិបត្តិជាសកលនៃសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានសំរាប់អ្នកទាំងអស់គ្នា ដោយគ្មានការបែងចែក ដូចជាជាតិសាសន៍ ភេទ ភាសា ឬសាសនា ។

## មាត្រា ៥៦

សមាជិកទាំងអស់របស់សហប្រជាជាតិ ប្តេជ្ញាដោយខ្លួនឯងថា នឹងចាត់វិធានការរួម និងដោយឡែក ដោយសហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិ ចំពោះសមិទ្ធិផលនៃគោលបំណង ដូចមានចែងនៅក្នុងមាត្រា៥៥ ។

# សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស

# ៦- សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស

សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្សត្រូវបានអនុម័ត និងប្រកាសដោយសេចក្ដីសម្រេចចិត្ត នៃ
មហាសន្និបាតអង្គការសហប្រជាជាតិលេខ២១៧ A(III)
នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨

## បុព្វកថា

*ដោយយល់ឃើញថា* ការទទួលស្គាល់សេចក្ដីថ្លៃថ្នូរជាប់ពីកំណើត និងសិទ្ធិស្មើភាពគ្នា និងសិទ្ធិមិនអាចលក់ដូរ ផ្ទេរ ឬដកហូតបានរបស់សមាជិកទាំងអស់នៃគ្រួសារមនុស្ស គឺជាគ្រឹះនៃសេរីភាពយុត្តិធម៌ និងសន្តិភាពក្នុងពិភពលោក ។

*ដោយយល់ឃើញថា* ការមិនទទួលស្គាល់ និងការប្រមាថមើលងាយសិទ្ធិមនុស្ស នាំឱ្យមានអំពើព្រៃផ្សៃសាហាវយង់ឃ្នង ធ្វើឱ្យក្ដៅក្រហាយដល់សតិសម្បជញ្ញៈមនុស្សជាតិ និង*ថា* ការឈានដល់ពិភពលោកមួយដែលមនុស្សទាំងឡាយមានសេរីភាពក្នុងការនិយាយស្ដី និងជំនឿ និងភាពរួចផុតពីការភ័យខ្លាច និងទុគ៌តភាព ត្រូវបានប្រកាសថាជាសេចក្ដីប្រាថ្នាដ៏ខ្ពស់បំផុតរបស់មនុស្សទូទៅ ។

*ដោយយល់ឃើញថា* ជាការចាំបាច់ដែលសិទ្ធិមនុស្សត្រូវតែបានការពារដោយនីតិរដ្ឋ ដើម្បីជៀសវាងកុំឱ្យមនុស្សបង្ខំចិត្តជាចុងក្រោយបង្អស់ បះបោរប្រឆាំងទល់នឹងអំណាចផ្ដាច់ការនិងការគាបសង្កត់ ។

*ដោយយល់ឃើញថា* ជាការចាំបាច់ ដែលត្រូវលើកស្ទួយការពង្រីកទំនាក់ទំនងជាមិត្តភាព រវាងប្រជាជាតិនានា ។

*ដោយយល់ឃើញថា* ប្រជាជាតិទាំងឡាយនៃសហប្រជាជាតិ បានប្រកាសបញ្ជាក់សារជាថ្មីក្នុងធម្មនុញ្ញសហប្រជាជាតិ នូវជំនឿរបស់ខ្លួន ទៅលើសិទ្ធិមូលដ្ឋាននៃមនុស្ស លើសេចក្ដីថ្លៃថ្នូរ លើតម្លៃរបស់មនុស្ស និងលើសមភាពនៃសិទ្ធិរវាងបុរសនិងស្ត្រី ហើយប្ដេជ្ញាលើកស្ទួយវឌ្ឍនភាពសង្គម និងកម្រិតជីវភាពរស់នៅឱ្យកាន់តែប្រសើរឡើង ក្នុងសេរីភាពកាន់តែទូលំទូលាយ ។

*ដោយយល់ឃើញថា* ដោយសហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិ រដ្ឋជាសមាជិកទាំងអស់ សន្យាធ្វើឱ្យមានការគោរពជាសកល និងការប្រតិបត្តិនូវសិទ្ធិ និងសេរីភាពមូលដ្ឋាន ។

*ដោយយល់ឃើញថា* ការយល់ដូចគ្នាមួយអំពីសិទ្ធិ និងសេរីភាពទាំងនេះ មានសារសំខាន់បំផុតដើម្បីបំពេញនូវការសន្យាខាងលើ ។

*អាស្រ័យហេតុនេះ មហាសន្និបាតប្រកាសថា :*

*សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្សនេះ* ជាឧត្តមគតិរួមដែលប្រជាពលរដ្ឋគ្រប់ៗប្រទេស និងប្រជាជាតិទាំងអស់ត្រូវធ្វើឱ្យបានសម្រេច ដើម្បីឱ្យបុគ្គលគ្រប់ៗរូប និងអង្គការសង្គមទាំងអស់ ដោយរក្សាខ្ជាប់ជានិច្ចក្នុងស្មារតីរបស់ខ្លួន នូវសេចក្ដីប្រកាសនេះ ខិតខំប្រឹងប្រែងបណ្ដុះបណ្ដាលការគោរពសិទ្ធិ និងសេរីភាពទាំងនេះ តាមរយៈការបង្រៀន និងការអប់រំ ហើយនិងខំប្រឹងប្រែងធានាឱ្យមានការទទួលស្គាល់ និងការអនុវត្តន៍ជាសកល និងដោយស័ក្តិសិទ្ធិ នូវសិទ្ធិ និងសេរីភាព ដោយវិធានការជាតិ និងអន្តរជាតិ ដែលមានលក្ខណៈរីកចម្រើនជាលំដាប់ ទាំងក្នុងចំណោមប្រជាពលរដ្ឋនៃរដ្ឋសមាជិក ទាំងក្នុងចំណោមប្រជាពលរដ្ឋដែនដីដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចនៃរដ្ឋទាំងនោះ ។

## មាត្រា ១

មនុស្សទាំងអស់ កើតមកមានសេរីភាព និងសមភាព ក្នុងផ្នែកសេចក្ដីថ្លៃថ្នូរ និងសិទ្ធិ ។ មនុស្សមានវិចារណញ្ញាណ និងសតិសម្បជញ្ញៈជាប់ពីកំណើត ហើយគប្បីប្រព្រឹត្តចំពោះគ្នាទៅវិញទៅមក ក្នុងស្មារតីភាតរភាពជាបងប្អូន ។

## មាត្រា ២

មនុស្សម្នាក់ៗ អាចប្រើប្រាស់សិទ្ធិ និងសេរីភាពទាំងអស់ដែលមានចែងក្នុងសេចក្ដីប្រកាសនេះ ដោយគ្មានការប្រកាន់បែងចែកបែបណាមួយ មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃៗទៀតឡើយ ។

លើសពីនេះ មិនត្រូវធ្វើការប្រកាន់បែងចែកណាមួយ ដោយសំអាងទៅលើឋានៈខាងនយោបាយ ខាងដែនសមត្ថកិច្ច ឬខាងអន្តរជាតិរបស់ប្រទេស ឬដែនដីដែលបុគ្គលណាម្នាក់រស់នៅ ទោះបីជាប្រទេស ឬដែនដីនោះឯករាជ្យក្ដី ស្ថិតក្រោមអាណាព្យាបាលក្ដី ឬ គ្មានស្វ័យគ្រប់គ្រងក្ដី ឬ ស្ថិតក្រោមការដាក់កម្រិតផ្សេងទៀតណាមួយ ដល់អធិបតេយ្យភាពក្ដី ។

## មាត្រា ៣

បុគ្គលម្នាក់ៗ មានសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។

## មាត្រា ៤

គ្មានជនណាម្នាក់ ត្រូវស្ថិតក្នុងទាសភាព ឬស្ថិតក្នុងភាពជាអ្នកបម្រើដាច់ថ្លៃឡើយ ។ ទាសភាព និងទាសពាណិជ្ជកម្ម តាមគ្រប់ទម្រង់ទាំងអស់ ត្រូវហាមឃាត់ ។

## មាត្រា ៥

គ្មានជនណាម្នាក់ ត្រូវទទួលទារុណកម្ម ឬការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបបានឡើយ ។

## មាត្រា ៦

ជនគ្រប់រូប មានសិទ្ធិឱ្យគេទទួលស្គាល់ថាជាមនុស្ស នៅគ្រប់ទីកន្លែង ។

## មាត្រា ៧

ជនគ្រប់រូប មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិទទួលការការពារពីច្បាប់ស្មើៗគ្នា ដោយគ្មានការរើសអើង ។ មនុស្សគ្រប់រូប មានសិទ្ធិទទួលការការពារស្មើៗគ្នា ប្រឆាំងនឹងការរើសអើងណាដែលរំលោភលើសេចក្តីប្រកាសនេះ ព្រមទាំងប្រឆាំងនឹងការញុះញង់ឱ្យមានការរើសអើង ។

## មាត្រា ៨

មនុស្សគ្រប់រូបមានសិទ្ធិរកដំណោះស្រាយស័ក្តិសិទ្ធិមួយ នៅចំពោះមុខសាលាជំរះក្តីជាតិដែលមានសមត្ថកិច្ច ចំពោះអំពើទាំងឡាយណាដែលរំលោភសិទ្ធិមូលដ្ឋានរបស់ខ្លួន ដែលត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ ឬដោយច្បាប់ ។

## មាត្រា ៩

គ្មានជនណាម្នាក់ ត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬនិរទេសខ្លួន តាមអំពើចិត្តឡើយ ។

## មាត្រា ១០

មនុស្សគ្រប់រូប មានសិទ្ធិស្មើគ្នាពេញលេញ សុំឱ្យតុលាការឯករាជ្យ និងមិនលំអៀង ពិនិត្យរឿងក្តីរបស់ខ្លួនជាសាធារណៈ និងដោយសមធម៌ ដើម្បីសម្រេចលើសិទ្ធិ និងកាតព្វកិច្ច និងលើភាពសមហេតុផល នៃការចោទប្រកាន់ទាំងឡាយខាងបទព្រហ្មទណ្ឌមកលើខ្លួន ។

## មាត្រា ១១

១. ជនណាដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ត្រូវសន្មត់ជាជនគ្មានទោសរហូតដល់ពិរុទ្ធភាពត្រូវបានរកឃើញ នៅក្នុងសវនាការជាសាធារណៈដែលមានការធានាចាំបាច់ដើម្បីឱ្យជននោះការពារខ្លួន ។

២. គ្មានជនណាម្នាក់ ត្រូវបានផ្តន្ទាទោសពីបទល្មើសព្រហ្មទណ្ឌ ដោយអំពើ ឬការខកខានមិនបានធ្វើ បើអំពើ ឬការខកខាននេះ មិនបានចែងក្នុងច្បាប់ជាតិ ឬអន្តរជាតិ ថាជាបទល្មើសព្រហ្មទណ្ឌនៅពេលធ្វើអំពើ ឬមានការខកខាននេះ ។ ដូចគ្នានេះដែរ មិនត្រូវមានការផ្តន្ទាទោសឱ្យធ្ងន់ជាងទោសដែលបានកំណត់ឱ្យអនុវត្តក្នុងអំឡុងពេលដែលបទល្មើសបានកើតឡើងឡើយ ។

## មាត្រា ១២

គ្មានមនុស្សណាម្នាក់ ត្រូវរងការរំលោភជ្រៀតជ្រែកតាមអំពើចិត្តក្នុងជីវិតឯកជន គ្រួសារ ទីលំនៅ ឬការឆ្លើយឆ្លង ឬការធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ខ្លួនបានឡើយ ។ ជនគ្រប់រូបមានសិទ្ធិ ទទួលការការពារពីច្បាប់ ប្រឆាំងនឹងការជ្រៀតជ្រែក ឬការប៉ះពាល់បែបនេះ ។

## មាត្រា ១៣

១. មនុស្សគ្រប់រូបមានសិទ្ធិធ្វើដំណើរដោយសេរី និងមានសិទ្ធិជ្រើសរើសនិវេសនដ្ឋានក្នុងរដ្ឋមួយ ។

២. មនុស្សគ្រប់រូបមានសិទ្ធិចាកចេញពីប្រទេសណាមួយ រួមទាំងប្រទេសរបស់ខ្លួនផង និងមានសិទ្ធិវិលត្រឡប់មកប្រទេសរបស់ខ្លួនវិញ ។

## មាត្រា ១៤

១. មនុស្សគ្រប់រូប មានសិទ្ធិស្វែងរក និងទទួលកន្លែងជ្រកកោនក្នុងប្រទេសដទៃទៀត ក្នុងករណីមានការធ្វើទុក្ខបុកម្នេញមកលើខ្លួន ។

២. សិទ្ធិសុំជ្រកកោននេះ មិនអាចលើកមកសំអាងបានទេ ក្នុងករណីមានការចោទប្រកាន់ដែលពិតជាកើតឡើង ពីបទល្មើសមិនមែននយោបាយ ឬពីការប្រព្រឹត្តណា ដែលផ្ទុយពីគោលបំណង និងគោលការណ៍ទាំងឡាយរបស់សហប្រជាជាតិ ។

## មាត្រា ១៥

១. មនុស្សគ្រប់រូប មានសិទ្ធិទទួលបានសញ្ជាតិមួយ ។

២. គ្មានជនណាម្នាក់អាចត្រូវដកហូតសញ្ជាតិ ឬរារាំងសិទ្ធិប្តូរសញ្ជាតិរបស់ខ្លួនតាមអំពើចិត្តបាន។

## មាត្រា ១៦

១. មនុស្សប្រុសស្រីដល់អាយុគ្រប់ការ មានសិទ្ធិរៀបអាពាហ៍ពិពាហ៍ និងកសាងគ្រួសារដោយមិនប្រកាន់ពូជសាសន៍ សញ្ជាតិ ឬសាសនាឡើយ ។ មនុស្សប្រុសស្រីមានសិទ្ធិស្មើគ្នាក្នុងការរៀបអាពាហ៍ពិពាហ៍ ក្នុងចំណងអាពាហ៍ពិពាហ៍ និងក្នុងពេលរំលាយចំណងអាពាហ៍ពិពាហ៍ ។

២. អាពាហ៍ពិពាហ៍នឹងអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការព្រមព្រៀងដោយសេរី និងពេញលេញពីអនាគតប្តីប្រពន្ធ ។

៣. គ្រួសារជាអង្គភាពធម្មជាតិ និងជាអង្គភាពមូលដ្ឋាននៃសង្គម ហើយគ្រួសារមានសិទ្ធិទទួលការការពារពីសង្គមនិងរដ្ឋ ។

## មាត្រា ១៧

១. មនុស្សគ្រប់រូប ទោះតែម្នាក់ឯងក្តី ឬដោយរួមជាមួយអ្នកដទៃក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ។

២. គ្មានជនណាម្នាក់ ត្រូវបានដកហូតកម្មសិទ្ធិ តាមអំពើចិត្តឡើយ ។

## មាត្រា ១៨

ជនគ្រប់រូប មានសិទ្ធិសេរីភាពខាងការគិត សតិសម្បជញ្ញៈ និងសាសនា ។ សិទ្ធិនេះ រាប់បញ្ចូលទាំងសេរីភាពផ្លាស់ប្តូរសាសនា ឬជំនឿ ព្រមទាំងសេរីភាពសម្តែងសាសនា ឬជំនឿរបស់ខ្លួនតែម្នាក់ឯង ឬដោយរួមជាមួយអ្នកដទៃ ជាសាធារណៈ ឬជាឯកជន តាមការបង្ហាត់បង្រៀន ការអនុវត្តន៍ ការគោរពបូជា និងការប្រតិបត្តិតាម ។

## មាត្រា ១៩

មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការមានមតិ និងការសម្តែងមតិ ។ សិទ្ធិនេះ រាប់បញ្ចូលទាំងសេរីភាពក្នុងការប្រកាន់មតិ ដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែងរក ការទទួល និងការផ្សព្វផ្សាយព័ត៌មាន និងគំនិតនានាដោយគ្មានព្រំដែនទឹកដី ទោះតាមរយៈមធ្យោបាយសម្តែងមតិណាមួយក៏ដោយ ។

## មាត្រា ២០

១. មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការប្រជុំ ឬការរួមគ្នាជាសមាគម ដោយសន្តិវិធី ។

២. គ្មានជនណាម្នាក់ ត្រូវបានបង្ខិតបង្ខំ ឱ្យចូលរួមក្នុងសមាគមណាមួយឡើយ ។

## មាត្រា ២១

១. មនុស្សគ្រប់រូប មានសិទ្ធិចូលរួមក្នុងការដឹកនាំកិច្ចការសាធារណៈនៃប្រទេសរបស់ខ្លួន ដោយផ្ទាល់ ឬតាមរយៈតំណាងដែលបានជ្រើសរើសដោយសេរី ។

២. មនុស្សគ្រប់រូប មានសិទ្ធិចូលបម្រើមុខងារសាធារណៈនៃប្រទេសរបស់ខ្លួន ក្នុងលក្ខខណ្ឌសមភាព ។

៣. ឆន្ទៈរបស់ប្រជាពលរដ្ឋ ជាមូលដ្ឋានអំណាចនៃការដឹកនាំកិច្ចការសាធារណៈ ។ ឆន្ទៈនេះត្រូវសម្តែងចេញតាមរយៈការបោះឆ្នោតទៀងទាត់ តាមពេលកំណត់ និងពិតប្រាកដ ដែលមានលក្ខណៈសកល ស្មើភាព និងសម្ងាត់ ឬតាមនីតិវិធីសមមូល ដែលធានាសេរីភាពនៃការបោះឆ្នោត ។

## មាត្រា ២២

ក្នុងឋានៈជាសមាជិកនៃសង្គម មនុស្សគ្រប់រូប មានសិទ្ធិទទួលបានសន្តិសុខសង្គម និងមានបុព្វសិទ្ធិសម្រេចបានសិទ្ធិខាងសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលចាំបាច់សម្រាប់សេចក្តីថ្លៃថ្នូរ និងការរីកចំរើនដោយសេរីនៃបុគ្គលិកលក្ខណៈរបស់ខ្លួន តាមរយៈការខិតខំរបស់ជាតិ និងសហប្រតិបត្តិការអន្តរជាតិ និងដោយយោងទៅតាមការរៀបចំ និងធនធានរបស់ប្រទេសនីមួយៗ ។

## មាត្រា ២៣

១. មនុស្សគ្រប់រូប មានសិទ្ធិមានការងារធ្វើ ជ្រើសរើសការងារដោយសេរី ទទួលលក្ខខណ្ឌការងារត្រឹមត្រូវ និងពេញចិត្ត និងមានការការពារប្រឆាំងនឹងភាពអត់ការងារធ្វើ ។

២. មនុស្សគ្រប់រូប មានសិទ្ធិទទួលប្រាក់បៀវត្សស្មើគ្នា ចំពោះការងារដូចគ្នាដោយគ្មានការរើសអើង ។

៣. អ្នកធ្វើការងារ មានសិទ្ធិទទួលបានលាភការ ដោយសមធម៌ និងពេញចិត្ត ដើម្បីធានាអត្ថិភាពរស់នៅរបស់ខ្លួន និងគ្រួសារ ឱ្យសមស្របនឹងសេចក្តីថ្លៃថ្នូរនៃមនុស្ស និងត្រូវបានបំពេញបន្ថែមទៀត ដោយមធ្យោបាយផ្សេងៗនៃការការពារផ្នែកសង្គម ប្រសិនបើចាំបាច់ ។

៤. មនុស្សគ្រប់រូប មានសិទ្ធិបង្កើតសហជីព និងចូលរួមក្នុងសហជីព ដើម្បីការពារផលប្រយោជន៍របស់ខ្លួន ។

## មាត្រា ២៤

មនុស្សគ្រប់រូប មានសិទ្ធិឈប់សម្រាក និងលំហែកំសាន្ត រួមបញ្ចូលទាំងកម្រិតម៉ោងការងារសមហេតុផល និងការឈប់សម្រាក ដោយបានប្រាក់បៀវត្សតាមពេលកំណត់ទៀងទាត់ ។

## មាត្រា ២៥

១. មនុស្សគ្រប់រូប មានសិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់ ដើម្បីធានាសុខភាព និងសុខុមាលភាពរបស់ខ្លួន និងគ្រួសារ រួមមានចំណីអាហារ សម្លៀកបំពាក់ លំនៅដ្ឋាន ការថែទាំសុខភាព និងសេវាសង្គមកិច្ចចាំបាច់ផ្សេងៗទៀត ។ មនុស្សគ្រប់រូប មានសិទ្ធិទទួលបានការគាំពារ នៅពេលគ្មានការងារធ្វើ មានជំងឺ ពិការ មេម៉ាយ ឬពោះម៉ាយ ចាស់ជរា ឬនៅពេលបាត់បង់មធ្យោបាយធានាជីវភាពដែលបណ្តាលមកពីកាលៈទេសៈផុតពីឆន្ទៈរបស់ខ្លួន ។

២. មាតុភាព និងកុមារភាព មានសិទ្ធិទទួលជំនួយ និងការថែទាំពិសេស ។ កុមារគ្រប់រូប ទោះកើតពីឪពុកម្តាយមានខាន់ស្លាក្តី ឬឥតខាន់ស្លាក្តី ត្រូវបានទទួលការការពារខាងសង្គមកិច្ចដូចគ្នា ។

## មាត្រា ២៦

១. មនុស្សគ្រប់រូប មានសិទ្ធិទទួលបានការអប់រំ ។ ការអប់រំ ត្រូវឥតបង់ថ្លៃយ៉ាងហោចណាស់សម្រាប់ការអប់រំបឋមសិក្សា និងអប់រំមូលដ្ឋាន ។ ការអប់រំបឋមសិក្សា គឺជាកាតព្វកិច្ច ។ ការអប់រំខាងបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវរៀបចំឱ្យមានជាទូទៅ ។ ការអប់រំឧត្តមសិក្សា ត្រូវបើកឱ្យចូលរៀនស្មើភាពគ្នា ដោយឈរលើមូលដ្ឋានសមត្ថភាព ។

២. ការអប់រំ ត្រូវសំដៅទៅរកការរីកលូតលាស់ពេញលេញនៃបុគ្គលិកលក្ខណៈរបស់មនុស្ស និងការពង្រឹងការគោរពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ។ ការអប់រំនេះ ត្រូវលើកកំពស់ការយល់ដឹងការអត់ឱនអធ្យាស្រ័យគ្នា និងមិត្តភាព រវាងប្រជាជាតិ និងក្រុមពូជសាសន៍ ឬក្រុមសាសនាទាំងអស់ព្រមទាំងការអភិវឌ្ឍន៍សកម្មភាពរបស់សហប្រជាជាតិ ក្នុងការថែរក្សាសន្តិភាព ។

៣. មាតាបិតា មានសិទ្ធិជាអាទិភាព ក្នុងការជ្រើសរើសប្រភេទនៃការអប់រំ សម្រាប់បុត្រធីតារបស់ខ្លួន ។

## មាត្រា ២៧

១. មនុស្សគ្រប់រូបមានសិទ្ធិចូលរួមដោយសេរី ក្នុងជីវភាពវប្បធម៌របស់សហគមន៍ អាស្រ័យផលសិល្បៈ និងចូលរួមចំណែកក្នុងវឌ្ឍនភាពវិទ្យាសាស្ត្រ និងក្នុងផលប្រយោជន៍ដែលបានមកពីវឌ្ឍនភាព ។

២. មនុស្សគ្រប់រូប មានសិទ្ធិទទួលបានការការពារផលប្រយោជន៍ ខាងសីលធម៌ និងសម្ភារៈដែលបានមកពីផលិតកម្មខាងវិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬសិល្បៈ ដែលជាស្នាដៃរបស់ខ្លួន ។

## មាត្រា ២៨

មនុស្សគ្រប់រូប មានសិទ្ធិទទួលបាននូវសណ្តាប់ធ្នាប់សង្គម និងអន្តរជាតិ ដែលធ្វើឱ្យសិទ្ធិ និងសេរីភាព ចែងក្នុងសេចក្តីប្រកាសនេះ អាចសម្រេចបានដោយពេញលេញ ។

## មាត្រា ២៩

១. មនុស្សគ្រប់រូប មានករណីយកិច្ច ចំពោះសហគមន៍ ដែលជាកន្លែងតែមួយគត់ ដែលអាចបង្កើតបានការរីកចម្រើនដោយសេរី និងពេញបរិបូរណ៍ នូវបុគ្គលិកលក្ខណៈរបស់ខ្លួន ។

២. ក្នុងការប្រើប្រាស់សិទ្ធិ និងសេរីភាពរបស់ខ្លួន មនុស្សគ្រប់រូប ត្រូវស្ថិតនៅត្រឹមតែកម្រិតព្រំដែនដែលច្បាប់បានកំណត់ សំរាប់ធានាការទទួលស្គាល់ និងការគោរពសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ និងបំពេញសេចក្តីត្រូវការយ៉ាងត្រឹមត្រូវ ខាងសីលធម៌ សណ្តាប់ធ្នាប់សាធារណៈ និងសុខុមាលភាពទូទៅនៅក្នុងសង្គមប្រជាធិបតេយ្យតែប៉ុណ្ណោះ ។

៣. តែយ៉ាងណាក៏ដោយ សិទ្ធិ និងសេរីភាពទាំងនេះ មិនអាចយកទៅប្រើប្រាស់ផ្ទុយនឹងគោលបំណង និងគោលការណ៍ទាំងឡាយរបស់សហប្រជាជាតិឡើយ ។

## មាត្រា ៣០

គ្មានបទបញ្ញត្តិណាមួយ នៃសេចក្តីប្រកាសនេះ អាចត្រូវបានបកស្រាយតម្រូវថា រដ្ឋណាមួយ ក្រុមណាមួយ ឬបុគ្គលណាម្នាក់ មានសិទ្ធិបែបណាមួយ ក្នុងការធ្វើសកម្មភាព ឬការប្រព្រឹត្តអំពើអ្វីមួយ ដែលសំដៅទៅបំផ្លិចបំផ្លាញនូវសិទ្ធិ និងសេរីភាពទាំងឡាយ ដែលមានចែងនៅក្នុងសេចក្តីប្រកាសនេះឡើយ ។

# កតិកាសញ្ញាអន្តរជាតិ

# ស្តីពី

# សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច

# និងវប្បធម៌

# ៧- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦
និងចូលជាធរមាននៅថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៦ ស្របតាមបទប្បញ្ញត្តិនៃមាត្រា២៧
កម្ពុជាក្លាយជារដ្ឋភាគីនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២

## បុព្វកថា

*រដ្ឋភាគីនៃកតិកាសញ្ញានេះ :*

*យល់ឃើញថា* ស្របតាមគោលការណ៍ដែលបានចែងក្នុងធម្មនុញ្ញសហប្រជាជាតិ ការទទួលស្គាល់សេចក្តីថ្លៃថ្នូរជាប់ពីកំណើត និងការទទួលស្គាល់សិទ្ធិស្មើគ្នា និងមិនអាចលក់ដូរ ផ្ទេរ ឬដកហូតបានរបស់សមាជិកទាំងអស់នៃគ្រួសារមនុស្ស គឺជាគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពក្នុងពិភពលោក។

*ទទួលស្គាល់ថា*សិទ្ធិទាំងនេះកើតចេញមកពីសេចក្តីថ្លៃថ្នូរជាប់ពីកំណើតរបស់មនុស្ស។

*ទទួលស្គាល់ថា* ស្របតាមសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ឧត្តមគតិនៃមនុស្ស សេរីភាពរួចផុតពីការភ័យខ្លាច និងទុគ៌តភាព អាចសម្រេចជោគជ័យទៅបាន លុះត្រាតែបង្កើតបានលក្ខខណ្ឌ ដែលឱ្យមនុស្សម្នាក់ៗ អាចប្រើប្រាស់បាននូវសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ព្រមទាំងសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់ខ្លួន។

*យល់ឃើញថា* ធម្មនុញ្ញសហប្រជាជាតិ តម្រូវឱ្យរដ្ឋនានានូវកាតព្វកិច្ចលើកស្ទួយការគោរពជាសកល និងការប្រតិបត្តិនូវសិទ្ធិ និងសេរីភាពរបស់មនុស្ស ។

*យល់ថា* បុគ្គលម្នាក់ៗ មានករណីយកិច្ចចំពោះអ្នកដទៃ និងសហគមន៍ដែលខ្លួនរស់នៅ មានការទទួលខុសត្រូវក្នុងការខិតខំលើកស្ទួយ និងធ្វើឱ្យមានការប្រតិបត្តិសិទ្ធិដែលទទួលស្គាល់ក្នុងកតិកាសញ្ញានេះ ។

*ព្រមព្រៀងលើមាត្រាទាំងឡាយដូចតទៅ:*

## ផ្នែកទី ១

## មាត្រា ១

១. ប្រជាជាតិទាំងអស់ មានសិទ្ធិស្វ័យសម្រេច។ ដោយអាស្រ័យនូវសិទ្ធិនេះ ប្រជាជាតិទាំងនោះ កំណត់ដោយសេរីនូវឋានៈនយោបាយ និងខិតខំអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ខ្លួនដោយសេរី។

២. ដើម្បីសម្រេចគោលដៅរបស់ខ្លួន ប្រជាជាតិទាំងអស់អាចចាត់ចែងដោយសេរីនូវភោគទ្រព្យ និងធនធានធម្មជាតិរបស់ខ្លួន ដោយមិនធ្វើឱ្យប៉ះពាល់ដល់កាតព្វកិច្ចដែលចេញមកពីសហប្រតិបត្តិការសេដ្ឋកិច្ចអន្តរជាតិ ដែលផ្អែកលើគោលការណ៍នៃផលប្រយោជន៍ទៅវិញទៅមក និងគោលការណ៍នៃច្បាប់អន្តរជាតិ។ តែក្នុងករណីណាក៏ដោយ ក៏ប្រជាជាតិនីមួយៗ មិនត្រូវបានដកហូតមធ្យោបាយផ្ទាល់របស់ខ្លួន សម្រាប់ចិញ្ចឹមជីវិតឡើយ។

៣. រដ្ឋភាគីនៃកតិកាសញ្ញានេះ រួមទាំងរដ្ឋនានាដែលមានការទទួលខុសត្រូវគ្រប់គ្រងទឹកដីអស្វយ័ត និងទឹកដីអាណាព្យាបាល ត្រូវលើកស្ទួយធ្វើឱ្យបានសម្រេចនូវសិទ្ធិស្វ័យសម្រេច និងត្រូវគោរពសិទ្ធិនេះ ស្របតាមបទបញ្ញត្តិទាំងឡាយនៃធម្មនុញ្ញសហប្រជាជាតិ។

## ផ្នែកទី ២

## មាត្រា ២

១. រដ្ឋភាគីនីមួយៗនៃកតិកាសញ្ញានេះ ដោយការប្រឹងប្រែងរបស់ខ្លួនឯងផ្ទាល់ និងតាមរយៈជំនួយ និងសហប្រតិបត្តិការអន្តរជាតិ ជាពិសេសខាងសេដ្ឋកិច្ច និងបច្ចេកទេស សន្យាចាត់វិធានការ ប្រើប្រាស់ជាអតិបរមានូវធនធានដែលខ្លួនមាន សម្រាប់ការធ្វើឱ្យមានការរីកចម្រើនជាលំដាប់នូវការសម្រេចបានដោយពេញលេញនូវសិទ្ធិទាំងអស់ដែលទទួលស្គាល់ក្នុងកតិកាសញ្ញានេះ តាមគ្រប់មធ្យោបាយសមស្រប រួមមាន ជាពិសេសការអនុម័តវិធានការខាងច្បាប់ផង។

២. រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាធានាថា សិទ្ធិទាំងឡាយដែលចែងក្នុងកតិកាសញ្ញានេះ នឹងត្រូវប្រើប្រាស់ដោយគ្មានការរើសអើងណាមួយ ផ្អែកលើពូជសាសន៍ ពណ៌សម្បុរ ភេទ សាសនា ភាសា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃទៀតឡើយ។

៣. ប្រទេសកំពុងអភិវឌ្ឍន៍ទាំងឡាយ ដោយគិតគូរឱ្យបានត្រឹមត្រូវដល់សិទ្ធិមនុស្ស និងសេដ្ឋកិច្ចជាតិរបស់ខ្លួនអាចកំណត់ដល់កម្រិតត្រឹមណាមួយដែលខ្លួនធានាសិទ្ធិសេដ្ឋកិច្ចដែលទទួលស្គាល់ក្នុងកតិកាសញ្ញានេះ ដល់អ្នកដែលពុំមែនជាប្រជាពលរដ្ឋខ្លួន។

## មាត្រា ៣

រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាធានានូវសិទ្ធិស្មើគ្នារវាងបុរសនិងស្ត្រី ក្នុងការអាស្រ័យផលសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ទាំងអស់ដែលមានចែងនៅក្នុងកតិកាសញ្ញានេះ។

## មាត្រា ៤

រដ្ឋភាគីនៃកតិកាសញ្ញានេះទទួលស្គាល់ថា ក្នុងការទទួលបានសិទ្ធិទាំងឡាយដែលធានាដោយរដ្ឋ ស្របតាមកតិកាសញ្ញានេះ រដ្ឋអាចដាក់សិទ្ធិទាំងនេះឱ្យមានព្រំដែន ដែលកំណត់ដោយច្បាប់តែប៉ុណ្ណោះ ដោយឱ្យស្របទៅនឹងប្រភេទនៃសិទ្ធិទាំងនេះ និងសម្រាប់តែដើម្បីលើកស្ទួយសុខុមាលភាពទូទៅប៉ុណ្ណោះ នៅក្នុងសង្គមប្រជាធិបតេយ្យ។

## មាត្រា ៥

១. គ្មានបទបញ្ញត្តិណាមួយនៃកតិកាសញ្ញានេះ អាចត្រូវបានគេបកស្រាយតម្រូវថា រដ្ឋណាមួយ ក្រុមណាមួយ បុគ្គលណាម្នាក់ មានសិទ្ធិណាមួយ ធ្វើសកម្មភាពណាមួយ ឬប្រព្រឹត្តិអំពើណាមួយសំដៅទៅបំផ្លិចបំផ្លាញសិទ្ធិ ឬសេរីភាព ដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ ឬសំដៅទៅដាក់កម្រិតដែលមានវិសាលភាពធំជាងកម្រិតដែលបានចែងនៅក្នុងកតិកាសញ្ញានេះ។

២. មិនត្រូវធ្វើការរិតត្បិតឬធ្វើបដិបញ្ញត្តិណាមួយទៅលើសិទ្ធិមនុស្សមូលដ្ឋានដែលត្រូវបានទទួលស្គាល់ ឬនៅជាធរមាននៅក្នុងរដ្ឋភាគីទាំងឡាយនៃកតិកាសញ្ញានេះ ដោយអនុលោមទៅតាមច្បាប់ អនុសញ្ញា បទបញ្ជា ឬទំនៀមទំលាប់ទាំងឡាយ ដោយយកលេសថា កតិកាសញ្ញានេះ មិនទទួលស្គាល់ ឬទទួលស្គាល់សិទ្ធិទាំងនោះនៅក្នុងកម្រិតតិចជាង។

# ផ្នែកទី ៣

## មាត្រា ៦

១. រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិធ្វើការងារ រួមមាន សិទ្ធិរបស់មនុស្សគ្រប់រូប មានលទ្ធភាពចិញ្ចឹមជីវិតដោយការងារដែលជ្រើសរើស ឬព្រមទទួលយកដោយសេរី និងចាត់វិធានការសមស្រប ដើម្បីការពារសិទ្ធិនេះ។

២. វិធានការដែលរដ្ឋភាគីនៃកតិកាសញ្ញានេះ ប្រកាន់យកដើម្បីធានាការប្រើប្រាស់ពេញលេញ នូវសិទ្ធិនេះ ត្រូវរួមបញ្ចូល ការតម្រង់ទិសខាងបច្ចេកទេស និងវិជ្ជាជីវៈ និងកម្មវិធីបណ្ដុះបណ្ដាលគោលនយោបាយ និងបច្ចេកទេស ដើម្បីធានាឱ្យមានការអភិវឌ្ឍន៍ថេរខាងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងការងារពេញលេញដែលមានផលប្រយោជន៍ ក្នុងលក្ខខណ្ឌការពារសេរីភាពមូលដ្ឋាន ខាងនយោបាយ និងសេដ្ឋកិច្ចចំពោះបុគ្គលគ្រប់រូប។

## មាត្រា ៧

រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិរបស់បុគ្គលគ្រប់រូប ដើម្បីទទួលបាននូវលក្ខខណ្ឌការងារត្រឹមត្រូវ និងប្រកបដោយអំណោយផល ដែលធានាជាពិសេសនូវ ៖

(ក) ប្រាក់កម្រៃដែលផ្ដល់ជាអប្បបរមាឱ្យអ្នកធ្វើការ នូវៈ

១. បៀវត្សរ៍ប្រកបដោយសមធម៌ និងប្រាក់កម្រៃស្មើគ្នាចំពោះការងារដែលមានតម្លៃស្មើគ្នា ដោយមិនមានការបែងចែកណាមួយ ជាពិសេស ស្ត្រីត្រូវតែមានការធានានូវលក្ខខណ្ឌការងារដែលផ្ដល់ឱ្យពួកគេ មិនតិចជាងលក្ខខណ្ឌដែលបុរសបានទទួល ដោយត្រូវបានប្រាក់កម្រៃស្មើគ្នាចំពោះការងារដូចគ្នា។

២. ជីវភាពរស់នៅសមរម្យសម្រាប់ខ្លួនគេផ្ទាល់ និងគ្រួសារ ស្របតាមបទបញ្ញត្តិនៃកតិកាសញ្ញានេះ។

(ខ) ល័ក្ខខ័ណ្ឌការងារប្រកបដោយសុវត្ថិភាព និងអនាម័យ។

(គ) ឱកាសដូចគ្នាសម្រាប់បុគ្គលគ្រប់រូប ដើម្បីបានឡើងឋានៈក្នុងការងារទៅកម្រិតខ្ពស់សមស្រប ដោយមិនពិចារណាទៅលើអ្វីផ្សេងពីអតីតភាពការងារ និងសមត្ថភាព។

(ឃ) ការសម្រាក ការលំហែ ការកម្រិតម៉ោងធ្វើការសមរម្យ និងការឈប់សម្រាកតាមកាលកំណត់ទៀងទាត់ ដោយមានប្រាក់បៀវត្សរ៍ និងប្រាក់កម្រៃសម្រាប់ថ្ងៃបុណ្យជាតិ។

## មាត្រា ៨

១. រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាធានាឱ្យបាននូវ ៖

(ក) សិទ្ធិសម្រាប់ជនគ្រប់រូប បង្កើតសហជីព និងចូលរួមសហជីព តាមការជ្រើសរើសរបស់ខ្លួន ដោយស្ថិតក្រោមវិធានទាំងឡាយ ដែលកំណត់ដោយអង្គការពាក់ព័ន្ធ ដើម្បីលើកស្ទួយ

និងការពារផលប្រយោជន៍សេដ្ឋកិច្ច និងសង្គមកិច្ចរបស់ខ្លួន ។ ការប្រើប្រាស់សិទ្ធិនេះ មិនអាចរឹតត្បិតបានទេ លើកលែងតែការរឹតត្បិតនោះ មានចែងនៅក្នុងច្បាប់ និងជាវិធានការចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ ជាផលប្រយោជន៍ដល់សន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ ឬដើម្បីការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ ។

(ខ) សិទ្ធិរបស់សហជីពបង្កើតសហព័ន្ធ ឬសម្ព័ន្ធជាតិ និងសិទ្ធិរបស់សហព័ន្ធ និងសម្ព័ន្ធជាតិ បង្កើត ឬចូលរួមក្នុងអង្គការសហជីពអន្តរជាតិ។

(គ) សិទ្ធិរបស់សហជីព ធ្វើសកម្មភាពដោយសេរីដោយគ្មានកម្រិតព្រំដែន លើកលែងតែកម្រិតព្រំដែននោះ មានចែងក្នុងច្បាប់ និងជាវិធានការចាំបាច់ ក្នុងសង្គមប្រជាធិបតេយ្យ សម្រាប់ជាផលប្រយោជន៍ដល់សន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ ឬដើម្បីការពារសិទ្ធិនិងសេរីភាពរបស់អ្នកដទៃ។

(ឃ) សិទ្ធិធ្វើកូដកម្ម ដែលត្រូវប្រើប្រាស់ឱ្យស្របតាមច្បាប់របស់ប្រទេសនីមួយៗ។

២. មាត្រានេះ មិនរារាំងដល់ការដាក់ការរឹតត្បិតស្របច្បាប់លើការប្រើប្រាស់សិទ្ធិទាំងនេះ ដោយសមាជិកកងកម្លាំងប្រដាប់អាវុធ ឬនគរបាល ឬមុខងារសាធារណៈឡើយ។

៣. គ្មានបទបញ្ញត្តិណាមួយនៃមាត្រានេះ អនុញ្ញាតឱ្យរដ្ឋភាគីទាំងអស់នៃអនុសញ្ញា ឆ្នាំ ១៩៤៨ នៃអង្គការពលកម្មអន្តរជាតិស្តីពីសេរីភាពខាងសហជីព និងការការពារសិទ្ធិសហជីព ចាត់វិធានការខាងផ្លូវច្បាប់ដែលប៉ះពាល់ ឬអនុវត្តច្បាប់តាមបែបដែលធ្វើឱ្យប៉ះពាល់ដល់ការធានាទាំងឡាយ ដែលមានចែងក្នុងអនុសញ្ញានោះ។

## មាត្រា ៩

រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិរបស់ជនគ្រប់រូប ទទួលបានសន្តិសុខសង្គម រួមទាំងការធានារ៉ាប់រងសង្គមផង។

## មាត្រា ១០

រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់ថា :

១. កិច្ចគាំពារ និងជំនួយដ៏ទូលំទូលាយបំផុតដែលអាចធ្វើទៅបាន ត្រូវតែផ្តល់ឱ្យគ្រួសារ

ដែលជាអង្គភាពធម្មជាតិ និងជាអង្គភាពមូលដ្ឋានរបស់សង្គម ជាពិសេសសម្រាប់ការកសាងគ្រួសារ និងនៅពេលដែលគ្រួសារ មានការទទួលខុសត្រូវ ចំពោះការថែរក្សា និងការអប់រំបុត្រធីតាក្នុងបន្ទុក។ អាពាហ៍ពិពាហ៍ ត្រូវតែធ្វើឡើងដោយមានការយល់ព្រមដោយសេរីពីអនាគតប្តីប្រពន្ធ។

២. កិច្ចគាំពារពិសេសមួយ ត្រូវផ្តល់ឱ្យម្តាយទាំងឡាយ សម្រាប់រយៈពេលសមរម្យមួយនៅមុន និងក្រោយពេលសម្រាលកូន។ ក្នុងរយៈពេលនេះ ម្តាយជានិយោជិក ត្រូវបានទទួលនូវការសម្រាក មានប្រាក់ខែ ឬការសម្រាកដែលមានការផ្តល់សន្តិសុខសង្គមគ្រប់គ្រាន់។

៣. វិធានការការពារ និងជំនួយពិសេស ត្រូវធ្វើឡើងជាគុណប្រយោជន៍ដល់កុមារ និងយុវជនទាំងអស់ ដោយគ្មានការរើសអើងណាមួយ ដោយមូលហេតុខ្សែលោហិត ឬលក្ខខណ្ឌអ្វីផ្សេងទៀតឡើយ។ កុមារ និងយុវជនទាំងអស់ ត្រូវទទួលបាននូវការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច និងសង្គមកិច្ច។ ការជួលកុមារ និងយុវជនឱ្យធ្វើការ ដែលធ្វើឱ្យប៉ះពាល់ដល់សីលធម៌ ឬសុខភាពរបស់ពួកគេ ឬធ្វើឱ្យមានគ្រោះថ្នាក់ដល់ជីវិត ឬដែលអាចធ្វើឱ្យខូចដល់ការលូតលាស់ធម្មតារបស់ពួកគេ ត្រូវផ្តន្ទាទោសតាមច្បាប់។ រដ្ឋត្រូវកំណត់អាយុជួលឱ្យធ្វើការងារ ហើយការជួលកុមារឱ្យធ្វើការងារ ក្រោមអាយុកំណត់នេះ ត្រូវហាមឃាត់ និងផ្តន្ទាទោសតាមច្បាប់។

## មាត្រា ១១

១. រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិរបស់ជនគ្រប់រូបក្នុងការទទួលបានកម្រិតជីវភាពគ្រប់គ្រាន់ សម្រាប់ខ្លួនផ្ទាល់ និងសម្រាប់គ្រួសារខ្លួន រួមមានចំណីអាហារ សំលៀកបំពាក់ និងទីលំនៅគ្រប់គ្រាន់ ព្រមទាំងការរីកចម្រើនជាលំដាប់នៃលក្ខខណ្ឌរស់នៅរបស់គេ។ រដ្ឋភាគីត្រូវចាត់វិធានការសមស្រប ដើម្បីធានាឱ្យសម្រេចបាននូវសិទ្ធិនេះ និងទទួលស្គាល់សារៈសំខាន់ចាំបាច់នៃសហប្រតិបត្តិការអន្តរជាតិ តាមការយល់ព្រមគ្នាដោយសេរី។

២. ដោយទទួលស្គាល់សិទ្ធិមូលដ្ឋានរបស់មនុស្សគ្រប់រូប រួចចាកផុតពីសេចក្តីស្រេកឃ្លាន រដ្ឋភាគីនៃកតិកាសញ្ញានេះ ដោយម្នាក់ៗឯង និងតាមរយៈសហការអន្តរជាតិ ត្រូវចាត់វិធានការរួមមានកម្មវិធីពិសេសៗជាក់លាក់ ដែលចាំបាច់ដូចតទៅ :

(ក) ដើម្បីធ្វើឱ្យប្រសើរដល់វិធីនៃការផលិត ការរក្សាទុក និងការចែកចាយម្ហូបអាហារ ដោយការប្រើប្រាស់ពេញលេញ នូវចំណេះដឹងខាងបច្ចេកទេស និងវិទ្យាសាស្ត្រ ដោយការផ្សព្វ

ផ្សាយគោលការណ៍នៃការអប់រំស្តីពីអាហារូបត្ថម្ភ និងដោយការអភិវឌ្ឍន៍ ឬការកែទម្រង់របបដីធ្លី ដើម្បីសម្រេចបាននូវការអភិវឌ្ឍន៍ និងការប្រើប្រាស់ធនធានធម្មជាតិ ប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត។

(ខ) ដើម្បីធានាការបែងចែកដោយសមធម៌ នូវធនធានស្បៀងអាហារពិភពលោកទៅតាមសេចក្តីត្រូវការ ដោយគិតទៅដល់បញ្ហាទាំងឡាយដែលចោទឡើងចំពោះប្រទេសនាំចូល ក៏ដូចជាប្រទេសនាំចេញស្បៀងអាហារ។

## មាត្រា ១២

១. រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិរបស់បុគ្គលគ្រប់រូប មានកម្រិតសុខភាពទាំងខាងរាងកាយ និងខាងស្មារតីខ្ពស់បំផុត តាមដែលអាចធ្វើទៅបាន។

២. វិធានការនានា ដែលរដ្ឋភាគីនៃកតិកាសញ្ញានេះចាត់ ដើម្បីធានាការប្រើសិទ្ធិនេះឱ្យបានពេញលេញ ត្រូវរាប់បញ្ចូលនូវវិធានការដែលចាំបាច់ដើម្បីធានា:

(ក) វិធានការសម្រាប់ការកាត់បន្ថយអត្រាមរណៈនៃទារកក្នុងពោះម្តាយ និងមរណៈនៃកុមារ និងសម្រាប់ការរីកលូតលាស់ប្រកបដោយសុខភាពល្អរបស់កុមារ។

(ខ) ការធ្វើឱ្យប្រសើរគ្រប់ទិដ្ឋភាពនៃអនាម័យខាងផ្នែកបរិស្ថាន និងឧស្សាហកម្ម។

(គ) វិធីបង្ការ ការព្យាបាល និងការត្រួតពិនិត្យជំងឺឆ្លង ជំងឺរាតត្បាតជំងឺបណ្តាលមកពីវិជ្ជាជីវៈ និងជំងឺដទៃទៀត ព្រមទាំងប្រយុទ្ធប្រឆាំងនឹងជំងឺទាំងនេះផង។

(ឃ) ការបង្កើតលក្ខខណ្ឌសម្រាប់ធានាដល់ជនគ្រប់រូបនូវសេវាសុខាភិបាលគ្រប់ផ្នែក និងជំនួយផ្នែកសុខាភិបាលក្នុងពេលមានជំងឺ។

## មាត្រា ១៣

១. រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិបុគ្គលគ្រប់រូប ដើម្បីទទួលបានការអប់រំ។ រដ្ឋភាគីព្រមព្រៀងគ្នាថា ការអប់រំត្រូវនាំឆ្ពោះទៅរកការរីកចម្រើនពេញលេញនៃបុគ្គលិកលក្ខណៈរបស់មនុស្ស និងអត្ថន័យនៃសេចក្តីថ្លៃថ្នូររបស់មនុស្ស និងពង្រឹងការគោរពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន។ រដ្ឋភាគីព្រមព្រៀងគ្នាបន្ថែមទៀតថា ការអប់រំត្រូវធ្វើឱ្យមនុស្សគ្រប់រូប អាច

ដើរតួនាទីមានប្រយោជន៍ ក្នុងសង្គមសេរី លើកស្ទួយការយោគយល់ ការអត់ឱន និងមិត្តភាព រវាងប្រជាជាតិ និងរវាងក្រុមពូជសាសន៍ ក្រុមជាតិពន្ធ ឬក្រុមសាសនាទាំងអស់ ព្រមទាំងជ្រោមជ្រែងសកម្មភាពរបស់អង្គការសហប្រជាជាតិ ដើម្បីរក្សាសន្តិភាព។

២. រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់ថា ដើម្បីសម្រេចបានការប្រើប្រាស់ពេញលេញនូវសិទ្ធិនេះ :

(ក) ការអប់រំកម្រិតបឋមសិក្សាត្រូវតែជាកាតព្វកិច្ចហើយឥតគិតថ្លៃសម្រាប់ទាំងអស់គ្នា។

(ខ) ការអប់រំកម្រិតមធ្យមសិក្សាតាមទ្រង់ទ្រាយផ្សេងៗ រួមទាំងការអប់រំបច្ចេកទេស និងវិជ្ជាជីវៈកម្រិតមធ្យម ត្រូវតែបើកឱ្យមានជាទូទៅ និងឱ្យមនុស្សគ្រប់គ្នាអាចចូលរៀនបាន តាមគ្រប់មធ្យោបាយសមស្របទាំងអស់ និងជាពិសេស តាមការដាក់ឱ្យមានជាលំដាប់នូវការសិក្សាដោយឥតបង់ថ្លៃ។

(គ) ការអប់រំកម្រិតឧត្តមសិក្សា ត្រូវតែបើកចំហដល់មនុស្សគ្រប់រូបដោយស្មើភាព តាមសមត្ថភាពរបស់មនុស្សម្នាក់ៗ តាមគ្រប់មធ្យោបាយសមស្របទាំងអស់ និងជាពិសេស តាមការដាក់ឱ្យមានជាលំដាប់នូវការសិក្សាដោយឥតបង់ថ្លៃ។

(ឃ) ការអប់រំមូលដ្ឋាន ត្រូវតែជំរុញ ឬពង្រឹងតាមគ្រប់មធ្យោបាយដែលអាចធ្វើទៅបាន សម្រាប់អ្នកដែលមិនបានទទួល ឬមិនបានបញ្ចប់កម្រិតបឋមសិក្សារបស់ខ្លួន។

(ង) ត្រូវតែបន្តយ៉ាងសកម្មលើការអភិវឌ្ឍន៍បណ្តាញសិក្សាធិការគ្រប់លំដាប់ បង្កើតប្រព័ន្ធអាហារូបករណ៍ឱ្យបានគ្រប់គ្រាន់ និងបង្កើនជាលំដាប់នូវលក្ខខណ្ឌសម្ភារៈរបស់បុគ្គលិកសិក្សា។

៣. រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាគោរពសេរីភាពរបស់មាតាបិតា និងអាណាព្យាបាលស្របច្បាប់បើសមស្រប ដើម្បីជ្រើសរើសសាលារៀន ក្រៅពីសាលារៀនសាធារណៈឱ្យកូនរបស់ខ្លួន ប៉ុន្តែត្រូវស្របតាមវិធានអប្បបរមាដែលរដ្ឋអាចកំណត់ ឬអនុម័តក្នុងវិស័យអប់រំ និងរ៉ាប់រងការអប់រំ សាសនា និងសីលធម៌របស់កូន ស្របតាមជំនឿផ្ទាល់របស់ពួកគេ។

៤. គ្មានបទបញ្ញត្តិណាមួយនៃមាត្រានេះ ត្រូវយកមកបកស្រាយថា ប៉ះពាល់ដល់សេរីភាពនៃរូបវន្តបុគ្គល និងនីតិបុគ្គល ក្នុងការបង្កើត និងដឹកនាំគ្រឹះស្ថានសិក្សា លើកលែងតែគោលការណ៍ដែលបានចែងក្នុងកថាខណ្ឌ១ នៃមាត្រានេះ ត្រូវបានគោរព និងឱ្យតែការអប់រំដែលផ្តល់ឱ្យនៅក្នុងគ្រឹះស្ថានទាំងនោះ ស្របទៅនឹងបទដ្ឋានអប្បបរមាដែលអាចកំណត់ដោយរដ្ឋ។

## មាត្រា ១៤

នៅពេលក្លាយជាភាគីនៃកតិកាសញ្ញានេះ រដ្ឋភាគីដែលមិនទាន់អាចធានាការអប់រំកម្រិតបឋម ជាកាតព្វកិច្ច និងដោយឥតបង់ថ្លៃ នៅក្នុងដែនដីចំណុះនៃប្រទេសខ្លួន ឬដែនដីដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន សន្យាបង្កើត និងអនុម័តក្នុងរយៈពេល២ឆ្នាំ នូវផែនការលំអិតនៃវិធានការចាំបាច់ ដើម្បីធ្វើឱ្យបានសម្រេចជាលំដាប់តាមចំនួនឆ្នាំសមរម្យដែលកំណត់ក្នុងផែនការនេះ នូវការអនុវត្តន៍ពេញលេញនៃគោលការណ៍អប់រំកម្រិតបឋមជាកាតព្វកិច្ច និងដោយឥតបង់ថ្លៃសម្រាប់ទាំងអស់គ្នា។

## មាត្រា ១៥

១. រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិនៃបុគ្គលគ្រប់រូប ដើម្បី ៖

(ក) ចូលរួមក្នុងជីវភាពវប្បធម៌។

(ខ) ទទួលអត្ថប្រយោជន៍ពីវឌ្ឍនភាព និងការអនុវត្តន៍វិទ្យាសាស្ត្រ។

(គ) ទទួលអត្ថប្រយោជន៍ពីការការពារផលប្រយោជន៍ខាងសីលធម៌ និងខាងសម្ភារៈដែលកើតពីផលិតកម្មខាងវិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬសិល្បៈដែលខ្លួនជាអ្នកបង្កើត។

២. វិធានការដែលរដ្ឋភាគីនៃកតិកាសញ្ញានេះប្រកាន់យក ដើម្បីធានាដល់ការប្រើប្រាស់ពេញលេញនូវសិទ្ធនេះ ត្រូវរួមបញ្ចូលវិធានការចាំបាច់សម្រាប់ធានាដល់ការថែរក្សា ការអភិវឌ្ឍន៍ និងការផ្សព្វផ្សាយខាងវិទ្យាសាស្ត្រ និងវប្បធម៌។

៣. រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាគោរពសេរីភាពដែលមិនអាចខ្វះបានសម្រាប់ការស្រាវជ្រាវខាងវិទ្យាសាស្ត្រ និងសកម្មភាពប្រឌិតញាណ។

៤. រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់អត្ថប្រយោជន៍ដែលបានមកពីការលើកទឹកចិត្ត និង ការអភិវឌ្ឍន៍នៃសហប្រតិបត្តិការ និងការទាក់ទងជាអន្តរជាតិក្នុងវិស័យវិទ្យាសាស្ត្រ និងវប្បធម៌។

## ផ្នែកទី ៤

## មាត្រា ១៦

១. រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាដាក់ជូន ដោយអនុលោមទៅតាមបទបញ្ញត្តិនានានៃ

ផ្នែកនេះនៃកតិកាសញ្ញានេះ នូវរបាយការណ៍ស្ដីពីវិធានការដែលខ្លួនបានអនុម័ត និងស្ដីពីការរីកចម្រើនដែលសម្រេចបាន ដើម្បីធានាការគោរពសិទ្ធិដែលត្រូវបានទទួលស្គាល់ ដោយកតិកាសញ្ញានេះ។

២. (ក) របាយការណ៍ទាំងអស់ ត្រូវដាក់ជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយអគ្គលេខាធិការ ត្រូវបញ្ជូនច្បាប់ចម្លងនៃរបាយការណ៍ទាំងនេះ ទៅក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គម ដើម្បីពិនិត្យ ស្របតាមបទបញ្ញត្តិនៃកតិកាសញ្ញានេះ។

(ខ) អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវបញ្ជូនផងដែរនូវច្បាប់ចម្លងនៃរបាយការណ៍ទាំងនេះ ទៅឱ្យស្ថាប័នឯកទេស ឬផ្នែកពាក់ព័ន្ធខ្លះនៃរបាយការណ៍ ដែលផ្ញើមកដោយរដ្ឋភាគីនៃកតិកាសញ្ញានេះ ដែលជាសមាជិកនៃស្ថាប័នឯកទេសតាមដែលរបាយការណ៍ ឬផ្នែកនៃរបាយការណ៍មានទាក់ទងនឹងបញ្ហាដែលស្ថិតក្រោមសមត្ថកិច្ចរបស់ស្ថាប័នខាងលើ ស្របតាមសារលិខិតជាបតិដ្ឋាប័នរៀងៗខ្លួន។

## មាត្រា ១៧

១. រដ្ឋភាគីនៃកតិកាសញ្ញានេះ ត្រូវបង្ហាញរបាយការណ៍របស់ខ្លួនជាដំណាក់ៗ ស្របតាមកម្មវិធី ដែលក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម នឹងកំណត់ក្នុងរយៈពេល១ឆ្នាំ គិតពីកាលបរិច្ឆេទដែលកតិកាសញ្ញានេះចូលជាធរមាន បន្ទាប់ពីបានពិគ្រោះប្ដូរយោបល់ជាមួយរដ្ឋភាគី និងស្ថាប័នឯកទេសពាក់ព័ន្ធ។

២. របាយការណ៍អាចប្រាប់ពីកត្តា និងការលំបាកដែលរារាំងរដ្ឋទាំងនោះ ក្នុងការបំពេញកាតព្វកិច្ចក្រោមកតិកាសញ្ញានេះ។

៣. ក្នុងករណីដែលព័ត៌មានពាក់ព័ន្ធ ត្រូវបានដាក់ជូនអង្គការសហប្រជាជាតិ ឬស្ថាប័នឯកទេសណាមួយ ដោយរដ្ឋភាគីណាមួយនៃកតិកាសញ្ញានេះហើយ នោះមិនចាំបាច់បង្ហាញព័ត៌មាននោះឡើងវិញទៀតទេគឺគ្រាន់តែយោងឱ្យច្បាស់លាស់លើព័ត៌មាននោះទៅជាការគ្រប់គ្រាន់ហើយ។

## មាត្រា ១៨

ស្របតាមការទទួលខុសត្រូវរបស់ខ្លួន នៅក្រោមធម្មនុញ្ញសហប្រជាជាតិ ក្នុងវិស័យសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម អាចធ្វើការសម្របសម្រួលជា

មួយស្ថាប័នឯកទេសនានា ពាក់ព័ន្ធនឹងការធ្វើរបាយការណ៍ ដែលស្ថាប័នទាំងនេះ ត្រូវដាក់ជូនក្រុមប្រឹក្សា ហើយដែលទាក់ទងនឹងការរីកចម្រើនដែលសម្រេចបាន ក្នុងការអនុវត្តន៍បទបញ្ញត្តិនៃកតិកាសញ្ញានេះ ដែលស្ថិតក្នុងក្របខ័ណ្ឌនៃសកម្មភាពរបស់ខ្លួន។ របាយការណ៍ទាំងនេះអាចបញ្ចូលទិន្នន័យនៃសេចក្តីសម្រេច និងអនុសាសន៍លើការអនុវត្តន៍ដែលបានអនុម័តដោយអង្គការមានសមត្ថកិច្ចនៃស្ថាប័នឯកទេស។

## មាត្រា ១៩

ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម អាចផ្ញើជូនគណៈកម្មការសិទ្ធិមនុស្ស ដើម្បីធ្វើការសិក្សា និងផ្តល់អនុសាសន៍ទូទៅ ឬដើម្បីជាព័ត៌មាន បើសិនជាមាន នូវរបាយការណ៍ស្តីពីសិទ្ធិមនុស្ស ដែលរដ្ឋនានាបានដាក់ជូន ស្របតាមមាត្រា១៦ និងមាត្រា១៧ និងរបាយការណ៍ស្តីពីសិទ្ធិមនុស្ស ដែលស្ថាប័នឯកទេសបាន ដាក់ជូនស្របតាមមាត្រា១៨។

## មាត្រា ២០

រដ្ឋភាគីនៃកតិកាសញ្ញានេះ និងស្ថាប័នឯកទេសពាក់ព័ន្ធនានា អាចជូនយោបល់ទៅក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម លើកអនុសាសន៍ទូទៅស្របតាមមាត្រា១៩ ឬយោងតាមអនុសាសន៍ទូទៅដែលមាន ក្នុងរបាយការណ៍របស់គណៈកម្មការសិទ្ធិមនុស្ស ឬក្នុងឯកសារដែលមានចែងក្នុងរបាយការណ៍នោះ។

## មាត្រា ២១

ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម អាចដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិ ម្តងម្កាល នូវរបាយការណ៍ភ្ជាប់ជាមួយអនុសាសន៍ដែលមានលក្ខណៈទូទៅ និងសេចក្តីសង្ខេបព័ត៌មានដែលទទួលបានពីរដ្ឋភាគីនៃកតិកាសញ្ញានេះ និងស្ថាប័នឯកទេសស្តីពីវិធានការដែលបានដាក់ចេញ និងការរីកចម្រើនដែលសម្រេចបាន ដើម្បីធានាការគោរពជាទូទៅនូវសិទ្ធិដែលបានទទួលស្គាល់ក្នុងកតិកាសញ្ញានេះ។

## មាត្រា ២២

ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម អាចជំរាបជូនអង្គការដទៃទៀតនៃអង្គការសហប្រជាជាតិ អង្គការជាសាខា និងស្ថាប័នឯកទេសពាក់ព័ន្ធ ដែលផ្តល់ជំនួយខាងបច្ចេកទេស នូវបញ្ហាទាំងឡាយ

ដូចបានលើកឡើងក្នុងរបាយការណ៍ ដែលបានបញ្ជាក់ក្នុងផ្នែកនេះនៃកតិកាសញ្ញានេះ ហើយអាចជួយអង្គការទាំងនេះ ធ្វើការសម្រេចក្នុងវង្វង់សមត្ថកិច្ចផ្ទាល់រៀងៗខ្លួន នូវការគួរឱ្យមានវិធានការអន្តរជាតិសម្រាប់រួមចំណែកក្នុងការអនុវត្តន៍កតិកាសញ្ញានេះ ឱ្យបានស័ក្តិសិទ្ធិ និងជាលំដាប់។

## មាត្រា ២៣

រដ្ឋភាគីនៃកតិកាសញ្ញានេះព្រមព្រៀងគ្នាថា វិធានការលំដាប់អន្តរជាតិ ដើម្បីសម្រេចបាននូវសិទ្ធិ ដែលមានចែងក្នុងកតិកាសញ្ញានេះ មានជាអាទិ៍ ការធ្វើអនុសញ្ញា ការអនុម័តអនុសាសន៍ ការឧបត្ថម្ភ ជំនួយបច្ចេកទេស និងការរៀបចំការប្រជុំថ្នាក់តំបន់ និងការប្រជុំផ្នែកបច្ចេកទេសសម្រាប់ពិគ្រោះយោបល់ និងសិក្សាជាមួយរដ្ឋាភិបាលពាក់ព័ន្ធ។

## មាត្រា ២៤

គ្មានបទបញ្ញត្តិណាមួយក្នុងកតិកាសញ្ញានេះ ត្រូវយកមកបកស្រាយ ធ្វើឱ្យប៉ះពាល់ដល់បទបញ្ញត្តិទាំងឡាយនៃធម្មនុញ្ញសហប្រជាជាតិ និងធម្មនុញ្ញនៃស្ថាប័នឯកទេសដែលកំណត់ការទទួលខុសត្រូវរៀងៗខ្លួន របស់ស្ថាប័ននានានៃអង្គការសហប្រជាជាតិ និងស្ថាប័នឯកទេសដែលពាក់ព័ន្ធនឹងបញ្ហាដែលដោះស្រាយក្នុងកតិកាសញ្ញានេះឡើយ។

## មាត្រា ២៥

គ្មានបទបញ្ញត្តិណាមួយ ត្រូវយកមកបកស្រាយធ្វើឱ្យប៉ះពាល់ដល់សិទ្ធិពីកំណើតរបស់ប្រជាជាតិ ក្នុងការអាស្រ័យផល និងប្រើប្រាស់ដោយពេញលេញ និងដោយសេរីនូវភោគទ្រព្យ និងធនធានធម្មជាតិរបស់ខ្លួនឡើយ។

# ផ្នែកទី ៥

## មាត្រា ២៦

១. កតិកាសញ្ញានេះ ត្រូវបើកចំហឱ្យចុះហត្ថលេខា សម្រាប់រដ្ឋសមាជិកសហប្រជាជាតិ ឬសមាជិកនៃស្ថាប័នឯកទេសណាមួយ ឬជាភាគីនៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ ឬជារដ្ឋផ្សេងទៀត ដែលត្រូវបានអញ្ជើញដោយមហាសន្និបាតសហប្រជាជាតិ ឱ្យក្លាយជាភាគីនៃកតិកាសញ្ញានេះ។

២. កតិកាសញ្ញានេះ ជាកម្មវត្ថុនៃការឱ្យសច្ចាប័ន។ លិខិតុបករណ៍ឱ្យសច្ចាប័នត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ។

៣. កតិកាសញ្ញានេះ ត្រូវបើកចំហឱ្យចូលជាសមាជិកដោយរដ្ឋណាមួយ ដែលមានយោងក្នុងកថាខណ្ឌ១ នៃមាត្រានេះ។

៤. ការចូលជាសមាជិក ត្រូវធ្វើឡើងដោយការតំកល់លិខិតុបករណ៍សុំចូលជាសមាជិកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ។

៥. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវជូនដំណឹងដល់រដ្ឋទាំងអស់ដែលបានចុះហត្ថលេខាលើកតិកាសញ្ញានេះ ឬដែលបានចូលជាសមាជិកនៃកតិកាសញ្ញានេះ អំពីការតំកល់លិខិតុបករណ៍ ឱ្យសច្ចាប័ន ឬលិខិតុបករណ៍សុំចូលជាសមាជិក។

## មាត្រា ២៧

១. កតិកាសញ្ញានេះចូលជាធរមានក្នុងរយៈពេល៣ខែ ក្រោយពីកាលបរិច្ឆេទនៃការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬលិខិតុបករណ៍សុំចូលជាសមាជិកទី៣៥ នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ។

២. ចំពោះរដ្ឋណាមួយដែលឱ្យសច្ចាប័ន ឬសុំចូលជាសមាជិកនៃកតិកាសញ្ញានេះ បន្ទាប់ពីសមាជិកទី៣៥ កតិកាសញ្ញានេះនឹងចូលជាធរមានក្នុងរយៈពេល ៣ខែ ក្រោយពីកាលបរិច្ឆេទនៃការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬលិខិតុបករណ៍សុំចូលជាសមាជិករបស់រដ្ឋនោះ។

## មាត្រា ២៨

បទបញ្ញត្តិនៃកតិកាសញ្ញានេះ ត្រូវអនុវត្តលើគ្រប់ផ្នែកទាំងអស់នៃរដ្ឋសហព័ន្ធ ដោយគ្មានការដាក់កម្រិតព្រំដែន ឬការលើកលែងឡើយ។

## មាត្រា ២៩

១. រដ្ឋភាគីណាមួយនៃកតិកាសញ្ញានេះ អាចស្នើសុំធ្វើវិសោធនកម្ម និងដាក់សេចក្តីស្នើនោះ ជូនទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនសេចក្តីស្នើធ្វើវិសោធនកម្មនេះ ទៅរដ្ឋភាគីនៃកតិកាសញ្ញានេះ ដោយសុំឱ្យរដ្ឋភាគីបញ្ជាក់ថាតើយល់ព្រមឱ្យមានសន្និសីទនៃរដ្ឋភាគីទាំងអស់ ដើម្បីពិនិត្យ និងបោះឆ្នោតលើសេចក្តីស្នើសុំធ្វើ

វិសោធនកម្មឬទេ។ ក្នុងករណីមានសម្លេង១ភាគ៣យ៉ាងតិចនៃរដ្ឋភាគីទាំងអស់ ប្រកាសយល់ព្រមឱ្យមានសន្និសីទ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវកោះប្រជុំសន្និសីទ ក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ។ គ្រប់វិសោធនកម្មដែលបានអនុម័តដោយមតិភាគច្រើននៃរដ្ឋភាគីវត្តមាន និងបោះឆ្នោតក្នុងសន្និសីទ ត្រូវដាក់ជូនមហាសន្និបាតនៃអង្គការសហប្រជាជាតិ ដើម្បីសុំការយល់ព្រម។

២. វិសោធនកម្មទាំងនេះនឹងចូលជាធរមាននៅពេលទទួលបានការយល់ព្រមពីមហាសន្និបាតអង្គការសហប្រជាជាតិ និងទទួលបានការអនុម័តដោយមតិភាគច្រើន២ភាគ៣ នៃរដ្ឋភាគីនៃកតិកាសញ្ញានេះ ស្របតាមបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញរបស់រដ្ឋនីមួយៗ។

៣. នៅពេលដែលវិសោធនកម្មទាំងនោះចូលជាធរមានហើយ វិសោធនកម្មទាំងនោះ នឹងក្លាយជាកាតព្វកិច្ច សម្រាប់រដ្ឋភាគីដែលបានទទួលយល់ព្រមយកវិសោធនកម្មទាំងនោះ ឯរដ្ឋភាគីផ្សេងទៀត ដែលមិនបានទទួលយល់ព្រម ត្រូវស្ថិតនៅក្រោមបទបញ្ញត្តិនៃកតិកាសញ្ញានេះ និងវិសោធនកម្មមុនៗ ដែលខ្លួនបានយល់ព្រមរួចហើយ។

## មាត្រា ៣០

ក្រៅពីការជូនដំណឹងទាំងឡាយដែលមានចែងនៅក្នុងកថាខណ្ឌ៥ នៃមាត្រា២៦ អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវជូនដំណឹងដល់រដ្ឋទាំងឡាយ ស្របតាមកថាខណ្ឌ១នៃមាត្រានេះនូវ :

(ក) ការចុះហត្ថលេខា ការឱ្យសច្ចាប័ន និងការសុំចូលជាសមាជិក យោងតាមមាត្រា២៦។

(ខ) កាលបរិច្ឆេទនៃការចូលជាធរមាននៃកតិកាសញ្ញានេះ យោងតាមមាត្រា២៧ និងកាលបរិច្ឆេទនៃការចូលជាធរមាននៃវិសោធនកម្មទាំងឡាយ យោងតាមមាត្រា២៩។

## មាត្រា ៣១

១. កតិកាសញ្ញានេះដែលមានអត្ថបទជាភាសាចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញមានតម្លៃស្មើគ្នា និងត្រូវតំកល់ទុកនៅបណ្ណសារដ្ឋានរបស់អង្គការសហប្រជាជាតិ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនច្បាប់ចម្លងនៃកតិកាសញ្ញានេះដោយមានបញ្ជាក់ការចម្លងតាមច្បាប់ដើម ទៅរដ្ឋទាំងឡាយ យោងតាមមាត្រា២៦។

## ៧-គ. ពិធីសារបន្ថែមលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី១០ ធ្នូ ឆ្នាំ២០០៨
និងយោងតាមមាត្រា១៨ ពិធីសារបន្ថែមនេះ មិនទាន់ចូលជាធរមាននៅឡើយ
កម្ពុជាមិនទាន់ទាំងចុះហត្ថលេខានៅឡើយ

*រដ្ឋភាគីនៃពិធីសារនេះ :*

*យល់ឃើញថា* ស្របតាមគោលការណ៍ដែលបានចែងក្នុងធម្មនុញ្ញសហប្រជាជាតិ ការទទួលស្គាល់សេចក្តីថ្លៃថ្នូរជាប់ពីកំណើត និងការទទួលស្គាល់សិទ្ធិស្មើគ្នា និងមិនអាចលក់ ដូរ ផ្ទេរ ឬដកហូតបានរបស់សមាជិកទាំងអស់នៃគ្រួសារមនុស្ស គឺជាគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពក្នុងពិភពលោក ។

*កត់សំគាល់ថា* សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ប្រកាសថា មនុស្សទាំងអស់កើតមក មានសេរីភាព និងសមភាពក្នុងសេចក្តីថ្លៃថ្នូរ និងសិទ្ធិ ហើយថាមនុស្សម្នាក់ៗ អាចប្រើប្រាស់សិទ្ធិ និងសេរីភាពទាំងអស់ដែលមានចែងក្នុងសេចក្តីប្រកាសនេះ ដោយគ្មានការប្រកាន់បែងចែកបែបណាមួយ មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃៗទៀតឡើយ ។

*រំលឹកឡើងវិញថា* សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិនានាស្តីពីសិទ្ធិមនុស្ស ដែលទទួលស្គាល់ថា ឧត្តមគតិមនុស្ស រួចផុតពីការភ័យខ្លាច និងទុគ៌តភាព អាចសម្រេចជោគជ័យទៅបាន លុះត្រាតែបង្កើតបានលក្ខខណ្ឌដែលឱ្យមនុស្សម្នាក់ៗ អាចប្រើប្រាស់បាននូវសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ព្រមទាំងសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់ខ្លួន ។

*អះអាងជាថ្មី* អំពីសកលភាព អវិភាគីយភាព ការពឹងពាក់អាស្រ័យគ្នា ភាពទាក់ទងគ្នាទៅវិញទៅមកនៃសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ។

*រំលឹកឡើងវិញថា* រដ្ឋភាគីនីមួយៗនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ដែលក្នុងឯកសារនេះហៅថាកតិកាសញ្ញា) ត្រូវចាត់វិធានការដោយខ្លួនឯងផ្ទាល់ និងតាមរយៈជំនួយ និងសហប្រតិបត្តិការអន្តរជាតិ ជាពិសេសលើផ្នែកសេដ្ឋកិច្ច និងបច្ចេកទេស សន្យាប្រើជាអតិបរមាធនធានរបស់ខ្លួនដែលមាន ដើម្បីរាប់រងនូវការរីកចម្រើនជាលំដាប់ នៃការប្រតិបត្តិពេញលេញនូវសិទ្ធិទាំងអស់ ដែលទទួលស្គាល់ក្នុងកតិកាសញ្ញានេះ តាមគ្រប់មធ្យោបាយសមស្រប ជាពិសេស រួមទាំងការអនុម័តវិធានការច្បាប់ផង ។

*យល់ឃើញថា* ដើម្បីសំរេចគោលបំណងនៃកតិកាសញ្ញានេះ និងការអនុវត្តន៍បទបញ្ញត្តិនៃកតិកាសញ្ញានេះ វាជាការសមស្រប ដែលត្រូវផ្តល់លទ្ធភាពឱ្យគណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ដែលក្នុងឯកសារនេះ ហៅថាគណៈកម្មាធិការ) ក្នុងការបំពេញមុខងារទាំងឡាយ ដូចមានចែងក្នុងពិធីសារនេះ ។

*បានព្រមព្រៀងគ្នាតទៅ ៖*

## មាត្រា ១
## សមត្ថកិច្ចរបស់គណៈកម្មាធិការក្នុងការទទួល និងពិនិត្យបណ្តឹង

១. រដ្ឋភាគីនៃកតិកាសញ្ញានេះ ដែលក្លាយជាភាគីមួយនៃពិធីសារនេះ ទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការក្នុងការទទួល និងពិនិត្យបណ្តឹង ដូចមានចែងក្នុងបទបញ្ញត្តិនៃពិធីសារនេះ ។

២. គណៈកម្មាធិការ នឹងមិនទទួលពិនិត្យបណ្តឹងរបស់រដ្ឋភាគីនៃកតិកាសញ្ញានេះ ដែលមិនមែនជាភាគីនៃពិធីសារនេះឡើយ ។

## មាត្រា ២
## បណ្តឹង

បុគ្គលអាចដាក់ពាក្យបណ្តឹងរបស់ខ្លួន ឬក្នុងនាមបុគ្គល ឬក្រុមបុគ្គលផ្សេងទៀត ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋភាគី ដោយធ្វើការអះអាងថា ជាជនរងគ្រោះពីការរំលោភបំពានដោយរដ្ឋភាគីទៅលើសិទ្ធិណាមួយនៃសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលមានចែងនៅក្នុងកតិកាសញ្ញានេះ។ ប្រសិនបើបណ្តឹងមួយធ្វើឡើងក្នុងនាមបុគ្គល ឬក្រុមបុគ្គល បណ្តឹងនេះ ត្រូវតែមានការយល់ព្រមពីបុគ្គលទាំងនោះ បើពុំនោះទេ អ្នកប្តឹងអាចបញ្ជាក់អះអាងលើពាក្យបណ្តឹងក្នុងនាមពួកគេ ដោយមិនចាំបាច់មានការយល់ព្រមបែបនេះក៏បាន ។

## មាត្រា ៣
## ការទទួលបណ្តឹង

១. គណៈកម្មាធិការមិនទទួលពិនិត្យបណ្តឹងទេ លើកលែងតែមានការបញ្ជាក់ច្បាស់ថា បានប្រើប្រាស់អស់ នូវដំណោះស្រាយទាំងប៉ុន្មានដែលមាននៅក្នុងស្រុក បើពុំនោះទេ ការប្រើប្រាស់ដំណោះស្រាយទាំងនេះ បានអូសបន្លាយរយៈពេលយូរហួសហេតុពេក ។

២. គណៈកម្មាធិការត្រូវប្រកាសថាមិនទទួលដោះស្រាយបណ្តឹងទេ ប្រសិនបើ៖

ក-បណ្តឹងនោះ មិនបានដាក់ក្នុងអំឡុងពេលមួយឆ្នាំ ក្រោយពីបានប្រើប្រាស់អស់នូវដំណោះស្រាយ ទាំងប៉ុន្មានដែលមាននៅក្នុងស្រុក លើកលែងតែក្នុងករណីដែលអ្នកប្តឹង បង្ហាញថា ខ្លួនមិនអាចបញ្ជូនបណ្តឹងនោះនៅក្នុងអំឡុងពេលដែលបានកំណត់ ។

ខ- អង្គហេតុដែលជាកម្មវត្ថុនៃបណ្តឹងបានកើតមាននៅមុនថ្ងៃចូលជាធរមាននៃពិធីសារនេះ សំរាប់រដ្ឋភាគីពាក់ព័ន្ធ បើពុំនោះទេ លុះត្រាតែអង្គហេតុនោះ បានបន្តរហូតដល់ក្រោយកាលបរិច្ឆេទនៃពិធីសារនេះ ។

គ- បញ្ហាដដែលនេះ ត្រូវបានគណៈកម្មាធិការពិនិត្យរួចហើយ ឬត្រូវបាន ឬកំពុងពិនិត្យ ស្របតាមនីតិវិធីមួយផ្សេងទៀតនៃការស៊ើបអង្កេត ឬការដោះស្រាយជាអន្តរជាតិ ។

ឃ- ជាប្រការផ្ទុយនឹងបទបញ្ញត្តិនៃកតិកាសញ្ញានេះ ។

ង- មិនបានបញ្ជាក់មូលហេតុច្បាស់លាស់ ឬគ្មានភស្តុតាងគ្រប់គ្រាន់ ឬផ្អែកតែលើរបាយការណ៍ផ្សព្វផ្សាយដោយប្រព័ន្ធសារព័ត៌មាន ។

ច- ជាការរំលោភសិទ្ធិដាក់ពាក្យបណ្តឹង ឬនៅពេលដែល

ឆ- បណ្តឹងអានាមិក ឬមិនមានសរសេរជាលក្ខណ៍អក្សរ ។

## មាត្រា ៤
## បណ្តឹងមិនបង្ហាញថាពិតជាមានការខូចប្រយោជន៍

ប្រសិនជាចាំបាច់ គណៈកម្មាធិការអាចមិនទទួលពិនិត្យបណ្តឹងណាដែលមិនបង្ហាញថា អ្នកប្តឹងពិតជាទទួលរងនូវការខូចប្រយោជន៍ បើពុំនោះទេ គណៈកម្មាធិការយល់ថា បណ្តឹងនោះ ចោទជាបញ្ហាធ្ងន់ធ្ងរដល់កិត្យានុភាពទូទៅ ។

## មាត្រា ៥
## វិធានការបណ្តោះអាសន្ន

១. នៅគ្រប់ពេលបន្ទាប់ពីការទទួលបណ្តឹង និងនៅមុនពេលឈានដល់ការសំរេចលើអង្គសេចក្តី គណៈកម្មាធិការអាចបញ្ជូនទៅរដ្ឋភាគីពាក់ព័ន្ធ ដើម្បីពិនិត្យជាបន្ទាន់លើសំណើ ដែលរដ្ឋភាគីចាត់វិធានការបណ្តោះអាសន្នតាមការចាំបាច់ ដើម្បីជៀសវាងការអាចកើតមាន នូវការគេចវេះមិនជួសជុលសំណងការខូចខាតដល់ជនរងគ្រោះម្នាក់ ឬច្រើននាក់ ដែលអះអាងថាបានទទួលរងការរំលោភ ។

២. ប្រសិនបើគណៈកម្មាធិការ ប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ស្របតាមកថាខ័ណ្ឌទី១ នៃមាត្រានេះ នេះមិនមានន័យថា ជាការសំរេចទទួលយក ឬការសំរេចលើអង្គសេចក្តីនៃបណ្តឹងឡើយ ។

## មាត្រា ៦
## ការបញ្ជូនពាក្យបណ្តឹង

១. ប្រសិនបើគណៈកម្មាធិការយល់ថា មិនអាចទទួលពាក្យបណ្តឹង ដោយមិនបញ្ជូនបណ្តឹងនោះ ទៅរដ្ឋភាគីពាក់ព័ន្ធ គណៈកម្មាធិការ ត្រូវផ្តល់ដំណឹងជាសំងាត់ដល់រដ្ឋភាគីពាក់ព័ន្ធអំពីបណ្តឹងដែលបានបញ្ជូនមកឱ្យខ្លួន ។

២. ក្នុងរយៈពេល ៦ (ប្រាំមួយ) ខែ រដ្ឋចុងចំលើយត្រូវបញ្ជូនការពន្យល់ជាលាយល័ក្ខណ៍អក្សរ ឬសេចក្តីថ្លែងការណ៍បំភ្លឺបញ្ហា និងការដោះស្រាយរបស់រដ្ឋនោះ ប្រសិនជាមាន ទៅគណៈកម្មាធិការ ។

## មាត្រា ៧
## ការដោះស្រាយដោយមេត្រីភាព

១. គណៈកម្មាធិការ ត្រូវផ្តល់សេវាដោះស្រាយដល់រដ្ឋភាគីពាក់ព័ន្ធតាមរយៈការដើរតួជាអាជ្ញាកណ្តាលអព្យាក្រិត និងមិនលំអៀង (Good Offices) ក្នុងគោលបំណងស្វែងរកការដោះស្រាយមួយ ដោយមេត្រីភាព ដោយផ្អែកលើគោលការណ៍នៃការគោរពកាតព្វកិច្ចដែលបានកំណត់ក្នុងកតិកាសញ្ញានេះ ។

២. កិច្ចព្រមព្រៀងលើការដោះស្រាយដោយមេត្រីភាពនេះបិទការពិនិត្យបណ្តឹង ស្របតាមពិធីសារនេះ។

## មាត្រា ៨
## ការពិនិត្យបណ្តឹង

១. គណៈកម្មាធិការ ត្រូវពិនិត្យបណ្តឹងដែលទទួលបានស្របតាមមាត្រា២ នៃពិធីសារនេះ នូវរាល់សំណុំឯកសារដែលបានផ្តល់មកឱ្យខ្លួន ហើយត្រូវបញ្ជូនសំណុំឯកសារនោះ ទៅភាគីពាក់ព័ន្ធដទៃទៀត ។

២. គណៈកម្មាធិការ ត្រូវប្រជុំជាសម្ងាត់ នៅពេលពិនិត្យបណ្តឹង ស្របតាមពិធីសារនេះ ។

៣. នៅពេលពិនិត្យបណ្តឹងស្របតាមពិធីសារនេះ គណៈកម្មាធិការអាចពិគ្រោះយោបល់ តាមការសមស្របនូវសំណុំឯកសារពាក់ព័ន្ធដែលចេញពីស្ថាប័ន ទីភ្នាក់ងារ មូលនិធិ កម្មវិធី និងយន្តការសហប្រជាជាតិ និងអង្គការអន្តរជាតិនានា រួមទាំងពីប្រព័ន្ធសិទ្ធិមនុស្សក្នុងតំបន់ និងសេចក្តីសង្កេត ឬសេចក្តីផ្តល់មតិរបស់រដ្ឋភាគីពាក់ព័ន្ធ។

៤. នៅពេលពិនិត្យបណ្តឹងស្របតាមពិធីសារនេះ គណៈកម្មាធិការ ត្រូវពិចារណាអំពីភាពសមហេតុសមផលនៃវិធានការដែលរដ្ឋភាគីបានចាត់ឡើង ស្របតាមផ្នែកទី២ នៃកតិកាសញ្ញានេះ។ ក្នុងការធ្វើបែបនេះ គណៈកម្មាធិការ ត្រូវចងចាំថា រដ្ឋភាគីអាចអនុម័តវិធានការស្តីពីគោលនយោបាយផ្សេងៗ សំរាប់អនុវត្តសិទ្ធិទាំងឡាយ ដែលមានចែងក្នុងកតិកាសញ្ញានេះ ។

## មាត្រា ៩
## ការឆ្លើយតបទៅនឹងការយល់ឃើញរបស់គណៈកម្មាធិការ

១. បន្ទាប់ពីពិនិត្យបណ្តឹងរួច គណៈកម្មាធិការត្រូវបញ្ជូនការយល់ឃើញរបស់ខ្លួន អំពីបណ្តឹងនោះ រួមជាមួយអនុសាសន៍របស់ខ្លួន ប្រសិនជាមាន ទៅភាគីពាក់ព័ន្ធ ។

២. រដ្ឋភាគីត្រូវពិនិត្យឱ្យបានត្រឹមត្រូវចំពោះការយល់ឃើញ និងអនុសាសន៍របស់គណៈកម្មាធិការ ប្រសិនជាមាន ហើយត្រូវបញ្ជូនចំលើយជាលាយល័ក្ខណ៍អក្សរទៅគណៈកម្មាធិការ ក្នុងរយៈពេល៦ខែ រួមទាំងព័ត៌មានស្តីពីវិធានការផ្សេងៗដែលបានចាត់ឡើង ទាក់ទងនឹងការយល់ឃើញ និងអនុសាសន៍របស់គណៈកម្មាធិការ ។

៣. គណៈកម្មាធិការអាចអញ្ជើញរដ្ឋភាគីឱ្យផ្តល់ព័ត៌មានបន្ថែមស្តីពីវិធានការនានា ដែលរដ្ឋភាគីបានចាត់ឡើង ឆ្លើយតបទៅនឹងការយល់ឃើញនិងអនុសាសន៍របស់ខ្លួន ប្រសិនជាមាន តាមដែលគណៈកម្មាធិការយល់ថា សមស្រប នៅក្នុងរបាយការណ៍បន្តបន្ទាប់មកទៀតរបស់រដ្ឋភាគី ស្របតាមមាត្រា១៦ និងមាត្រា១៧ នៃកតិកាសញ្ញានេះ។

## មាត្រា ១០
## បណ្តឹងរវាងរដ្ឋ និងរដ្ឋ

១. រដ្ឋភាគីនៃពិធីសារនេះ អាចប្រកាសគ្រប់ពេល ស្របតាមមាត្រានេះថា ខ្លួនទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការក្នុងការទទួលនិងពិនិត្យបណ្តឹង អាស្រ័យដោយរដ្ឋភាគីមួយអះអាងថា រដ្ឋភាគីមួយទៀត មិនបំពេញកាតព្វកិច្ចរបស់ខ្លួន ស្របតាមកតិកាសញ្ញានេះ។ បណ្តឹងនេះអាចទទួលយកមកពិនិត្យ ស្របតាមនីតិវិធី ដូចមានចែងក្នុងមាត្រានេះបាន លុះត្រាតែបណ្តឹងនេះ ធ្វើឡើងដោយរដ្ឋភាគីដែលបានប្រកាសទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការ។ គណៈកម្មាធិការមិនទទួលយកបណ្តឹងរបស់រដ្ឋភាគីដែលមិនបានធ្វើសេចក្តីប្រកាស ស្របតាមមាត្រានេះ មកដោះស្រាយឡើយ។ បណ្តឹងដែលបានទទួលស្របតាមមាត្រានេះ ត្រូវដោះស្រាយតាមនីតិវិធីដូចខាងក្រោមៈ

ក- បើរដ្ឋភាគីណាមួយនៃពិធីសារនេះ ពិនិត្យឃើញថា រដ្ឋភាគីមួយទៀត មិនអនុវត្តបទបញ្ញត្តិនៃកតិកាសញ្ញានេះ រដ្ឋភាគីនោះអាចលើកយកបញ្ហា តាមរយៈបណ្តឹងជាលាយល័ក្ខណ៍អក្សរ ទៅជូនរដ្ឋភាគីម្ខាងទៀត។ រដ្ឋភាគី ក៏អាចជូនដំណឹងទៅគណៈកម្មាធិការ អំពីបញ្ហានេះបានដែរ។ ក្នុងរយៈពេល ៣ខែ ចាប់ពីកាលបរិច្ឆេទនៃការទទួលបណ្តឹង រដ្ឋភាគី ចុងបណ្តឹង ត្រូវផ្ញើលិខិតឆ្លើយតបទៅរដ្ឋភាគីដើមបណ្តឹងនូវការពន្យល់ ឬសេចក្តីថ្លែងការណ៍ជាលាយល័ក្ខណ៍អក្សរណាមួយ បំភ្លឺអំពីបញ្ហានៃបណ្តឹងនេះ ដោយរួមទាំងការបញ្ជាក់អំពីនីតិវិធី និងការដោះស្រាយក្នុងស្រុកដែលរដ្ឋភាគីនោះមានចំណាត់ការរួច ឬមិនទាន់បានចាត់ការរួច តាមលទ្ធភាពដែលអាចធ្វើទៅបាន និងសមហេតុផល ។

ខ- បើបញ្ហាមិនត្រូវបានដោះស្រាយដាច់ស្រេចរវាងរដ្ឋភាគីពាក់ព័ន្ធទាំងពីរ ក្នុងរយៈពេល ៦ខែ គិតចាប់ពីកាលបរិច្ឆេទដែលរដ្ឋចុងបណ្តឹងទទួលបណ្តឹងទី១នោះ រដ្ឋភាគីណាមួយនៃរដ្ឋភាគីទាំងពីរ អាចមានសិទ្ធិលើកបញ្ហាទៅគណៈកម្មាធិការ ដោយការជូនដំណឹងជាលាយល័ក្ខណ៍អក្សរដល់គណៈកម្មាធិការ និងរដ្ឋភាគីពាក់ព័ន្ធ ។

គ- គណៈកម្មាធិការត្រូវដោះស្រាយបញ្ហាមួយដែលបញ្ជូនមកឱ្យខ្លួនបាន លុះត្រាតែគណៈកម្មាធិការ រកឃើញថា ដំណោះស្រាយបញ្ហាតាមផ្លូវច្បាប់ទាំងអស់នៅក្នុងស្រុក បានយកមកប្រើអស់ហើយ ។ វិធាននេះ នឹងមិនត្រូវយកមកអនុវត្តទេ បើនីតិវិធីនៃការដោះស្រាយ បន្តយូរហួសហេតុពេក ។

ឃ- តាមបទបញ្ញត្តិនៃអនុកថាខណ្ឌ (គ) នៃពិធីសារនេះ គណៈកម្មាធិការត្រូវផ្តល់ឱ្យរដ្ឋភាគីពាក់ព័ន្ធតាមរយៈការដើរតួជាអាជ្ញាកណ្តាលអព្យាក្រិត និងមិនលំអៀង (Good Offices) នូវការដោះស្រាយបញ្ហាមួយប្រកបដោយមេត្រីភាព ដោយផ្អែកលើគោលការណ៍នៃការគោរពកាតព្វកិច្ចដែលបានកំណត់ក្នុងកតិកាសញ្ញានេះ ។

ង-   គណៈកម្មាធិការ ត្រូវប្រជុំជាសម្ងាត់ នៅពេលគណៈកម្មាធិការពិនិត្យបណ្តឹងស្របតាមមាត្រានេះ។

ច-   គ្រប់បញ្ហាដែលបានដាក់ជូនគណៈកម្មាធិការ ស្របតាមអនុកថាខ័ណ្ឌ (ខ) នៃកថាខណ្ឌនេះ គណៈកម្មាធិការ អាចស្នើសុំឱ្យរដ្ឋភាគីពាក់ព័ន្ធ ដូចមានចែងក្នុងអនុកថាខ័ណ្ឌ (ខ) ផ្តល់ព័ត៌មានពាក់ព័ន្ធទាំងអស់ដល់គណៈកម្មាធិការ ។

ឆ-   រដ្ឋភាគីពាក់ព័ន្ធ ដូចមានចែងក្នុងអនុកថាខ័ណ្ឌ (ខ)នៃកថាខ័ណ្ឌនេះ មានសិទ្ធិដាក់វត្តមានតំណាងរបស់ខ្លួន នៅពេលគណៈកម្មាធិការកំពុងពិនិត្យបញ្ហា និងមានសិទ្ធិសុំយោបល់ដោយផ្ទាល់មាត់ និង/ ឬជាលាយល័ក្ខណ៍អក្សរ ។

ជ-   ក្នុងរយៈពេលមួយសមស្រប គិតចាប់ពីថ្ងៃទទួលការជូនដំណឹង ដូចចែងក្នុងអនុកថាខ័ណ្ឌ (ខ) នៃកថាខ័ណ្ឌនេះ គណៈកម្មាធិការត្រូវបង្ហាញរបាយការណ៍ដូចខាងក្រោមនេះ   :

(i)  បើដំណោះស្រាយមួយត្រូវបានរកឃើញ ក្នុងក្របខ័ណ្ឌនៃបទបញ្ញត្តិក្នុងអនុកថាខ័ណ្ឌ (ឃ) គណៈកម្មាធិការ ត្រូវកម្រិតរបាយការណ៍របស់ខ្លួន មកត្រឹមតែជាសេចក្តីថ្លែងការណ៍សង្ខេបអំពីអង្គហេតុ និងដំណោះស្រាយដែលសម្រេចបាន ។

(ii) បើដំណោះស្រាយមួយ មិនបានសម្រេចក្នុងក្របខ័ណ្ឌនៃអនុកថាខ័ណ្ឌ (ឃ)ទេ គណៈកម្មាធិការ ត្រូវសរសេរក្នុងរបាយការណ៍របស់ខ្លួនអំពីអង្គហេតុពាក់ព័ន្ធស្តីពីបញ្ហាដែលកើតមានរវាងរដ្ឋភាគីពាក់ព័ន្ធ ។ សេចក្តីស្នើសុំយោបល់ជាលាយល័ក្ខណ៍អក្សរ និងកំណត់ហេតុលើសេចក្តីស្នើសុំយោបល់ផ្ទាល់មាត់របស់រដ្ឋភាគីពាក់ព័ន្ធ ត្រូវភ្ជាប់ទៅជាមួយរបាយការណ៍នេះ។ គណៈកម្មាធិការ ក៏អាចផ្ញើទៅរដ្ឋភាគីពាក់ព័ន្ធនានា នូវការយល់ឃើញដែលខ្លួន អាចគិតថា  ពាក់ព័ន្ធនឹងបញ្ហារវាងរដ្ឋភាគីទាំងនោះ ។

ក្នុងករណីនីមួយៗ គណៈកម្មាធិការ ត្រូវផ្ញើរបាយការណ៍ទៅរដ្ឋភាគីពាក់ព័ន្ធ ។

២.   សេចក្តីប្រកាសណាមួយ ស្របតាមកថាខ័ណ្ឌទី១នៃមាត្រានេះ ត្រូវបានដាក់ដំកល់ដោយរដ្ឋភាគី នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលត្រូវបញ្ជូនច្បាប់ចម្លងនៃសេចក្តីប្រកាសទាំងនោះ ទៅរដ្ឋភាគីផ្សេងទៀត ។ សេចក្តីប្រកាសអាចដកហូតមកវិញបានគ្រប់ពេល ដោយការជូនដំណឹងជាលាយល័ក្ខណ៍អក្សរ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ការដកហូតនេះ មិនប៉ះពាល់ដល់ការពិនិត្យលើបញ្ហាទាំងឡាយក្នុងបណ្តឹង ដែលបានផ្ញើរួចហើយ ស្របតាមមាត្រានេះទេ ។ បណ្តឹងបន្ថែមរបស់រដ្ឋភាគី នឹងមិនទទួលយកមកពិនិត្យតាមមាត្រានេះឡើយ បន្ទាប់ពីអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបានការជូនដំណឹងស្តីពីការដកហូតសេចក្តីប្រកាសនេះ លើកលែងតែរដ្ឋភាគីពាក់ព័ន្ធធ្វើសេចក្តីប្រកាសថ្មី ។

## មាត្រា ១១
## នីតិវិធីស៊ើបសួរ

១. រដ្ឋភាគីនីមួយៗនៃពិធីសារនេះ ត្រូវប្រកាសគ្រប់ពេលវេលាថា ខ្លួនទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការ ដូចមានចែងក្នុងមាត្រានេះ ។

២. ប្រសិនបើគណៈកម្មាធិការទទួលព័ត៌មានគួរឱ្យទុកចិត្តដែលបង្ហាញឱ្យឃើញពី ការរំលោភធ្ងន់ធ្ងរ ឬជាប្រព័ន្ធ ដោយរដ្ឋភាគីទៅលើសិទ្ធិណាមួយនៃសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដូចមានចែងកតិកាសញ្ញានេះ គណៈកម្មាធិការត្រូវអញ្ជើញរដ្ឋភាគីនោះឱ្យសហការពិនិត្យព័ត៌មាន និងផ្តល់សេចក្តីសង្កេត ចំពោះព័ត៌មានពាក់ព័ន្ធ។

៣. តាមការពិនិត្យសេចក្តីសង្កេត ដែលរដ្ឋភាគីពាក់ព័ន្ធបញ្ជូនមក ព្រមទាំងព័ត៌មានពាក់ព័ន្ធដែលគួរឱ្យជឿបានផ្សេងទៀត គណៈកម្មាធិការ អាចចាត់តាំងសមាជិកម្នាក់ ឬច្រើននាក់ឱ្យធ្វើការស៊ើបសួរ និងរាយការណ៍ជាបន្ទាន់ទៅគណៈកម្មាធិការ។ ប្រសិនជាចាំបាច់ និងដោយមានការយល់ព្រមពីរដ្ឋភាគី ការស៊ើបសួរនេះ អាចរួមទាំងការធ្វើទស្សនកិច្ចទៅកាន់ទឹកដីនៃរដ្ឋនោះផង ។

៤. ការស៊ើបសួរនេះត្រូវធ្វើជាសំងាត់ និងត្រូវស្វែងរកកិច្ចសហការពីរដ្ឋភាគីនៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនេះ ។

៥. ក្រោយពីការពិនិត្យសេចក្តីសន្និដ្ឋាននៃការស៊ើបសួរនេះ គណៈកម្មាធិការត្រូវបញ្ជូនសេចក្តីសន្និដ្ឋានទាំងនេះ ទៅរដ្ឋភាគីពាក់ព័ន្ធ រួមជាមួយនឹងការផ្តល់យោបល់ ឬអនុសាសន៍ ។

៦. ក្នុងរយៈពេល៦ខែ នៃការទទួលសេចក្តីសន្និដ្ឋាន ការផ្តល់យោបល់ និងអនុសាសន៍ដែលគណៈកម្មាធិការបានបញ្ជូន រដ្ឋភាគីពាក់ព័ន្ធត្រូវបញ្ជូនសេចក្តីសង្កេតរបស់ខ្លួន ទៅគណៈកម្មាធិការ ។

៧. ក្រោយពីកិច្ចដំណើរការនេះបានធ្វើចប់សព្វគ្រប់ ទាក់ទងនឹងការស៊ើបសួរដែលបានធ្វើឡើង ស្របតាមកថាខ័ណ្ឌទី២នៃមាត្រានេះ និងក្រោយពីមានការពិគ្រោះយោបល់ជាមួយរដ្ឋភាគីពាក់ព័ន្ធ គណៈកម្មាធិការ អាចសំរេចបញ្ចូលសេចក្តីសង្កេតអំពីលទ្ធផលនៃកិច្ចដំណើរការ ទៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន ដូចមានចែងក្នុងមាត្រា១៥ នៃពិធីសារនេះ ។

៨. រដ្ឋភាគីណាមួយដែលបានធ្វើសេចក្តីប្រកាស ស្របតាមកថាខ័ណ្ឌទី១ នៃមាត្រានេះ អាចដកសេចក្តីប្រកាសនេះវិញ បានគ្រប់ពេលវេលា តាមរយៈការជូនដំណឹងទៅអគ្គលេខាធិការ ។

## មាត្រា ១២
## ការបន្តតាមនីតិវិធីស៊ើបសួរ

១. គណៈកម្មាធិការ អាចអញ្ជើញរដ្ឋភាគីពាក់ព័ន្ធឱ្យបញ្ចូលទៅក្នុងរបាយការណ៍របស់ខ្លួន ស្របតាមមាត្រា១៦ និងមាត្រា១៧ នៃកតិកាសញ្ញានេះ នូវព័ត៌មានស្តីពីវិធានការដែលខ្លួនបានអនុម័ត ដើម្បីឆ្លើយតបទៅនឹងការស៊ើបសួរដែលបានធ្វើឡើងស្របតាមមាត្រា១១ នៃពិធីសារនេះ ។

២. ប្រសិនជាចាំបាច់ បន្ទាប់ពីផុតរយៈពេល៦ខែ ដូចមានចែងក្នុងមាត្រា១១ កថាខណ្ឌទី៦ គណៈកម្មាធិការ អាចអញ្ជើញរដ្ឋភាគីពាក់ព័ន្ធឱ្យផ្តល់ព័ត៌មានមកខ្លួន អំពីវិធានការដែលបានចាត់ឡើង ដើម្បីឆ្លើយតបទៅនឹងការស៊ើបសួរនេះ ។

## មាត្រា ១៣
## វិធានការការពារ

រដ្ឋភាគីនីមួយៗ ត្រូវចាត់រាល់វិធានការសមស្រប ដើម្បីធានាថា ឯកត្តបុគ្គលទាំងឡាយ ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន មិនមែនជាកម្មវត្ថុនៃការប្រព្រឹត្តអំពើឃោរឃៅ អមនុស្សធម៌ ឬការបំភិតបំភ័យ ដោយសារតែការប្ដឹងទៅគណៈកម្មាធិការ ស្របតាមពិធីសារនេះឡើយ ។

## មាត្រា ១៤
## កិច្ចសហប្រតិបត្តិការ និងជំនួយអន្តរជាតិ

១. ប្រសិនជាយល់ឃើញថាសមស្រប និងដោយមានការយល់ព្រមពីរដ្ឋភាគីពាក់ព័ន្ធ គណៈកម្មាធិការត្រូវបញ្ជូនទៅឱ្យទីភ្នាក់ងារ មូលនិធិ និងកម្មវិធីឯកទេសរបស់អង្គការសហប្រជាជាតិ និងស្ថាប័នមានសមត្ថកិច្ចដទៃទៀតនូវការយល់ឃើញ ឬអនុសាសន៍របស់ខ្លួន ចំពោះបណ្ដឹង និងការស៊ើបសួរមួយចំនួន ដែលបង្ហាញពីសេចក្ដី ត្រូវការផ្នែកជំនួយ ឬប្រឹក្សាបច្ចេកទេស ព្រមទាំងសេចក្ដីសន្និដ្ឋាន និងសំណើរបស់រដ្ឋភាគី ប្រសិនជាមាន អំពីការយល់ឃើញ ឬអនុសាសន៍ទាំងនេះ ។

២. គណៈកម្មាធិការ ក៏អាចជូនដំណឹងទៅស្ថាប័នទាំងនេះ ដោយមានការយល់ព្រមពីរដ្ឋភាគីពាក់ព័ន្ធនូវបញ្ហាណាមួយដែលកើតចេញពីបណ្ដឹងដែលចាត់ទុកថា ស្ថិតក្នុងដែនសមត្ថកិច្ចនៃពិធីសារនេះ ដែលអាចជួយដល់ស្ថាប័នទាំងនេះ ក្នុងការសំរេចលើបញ្ហានីមួយៗ ដែលស្ថិតក្នុងវិស័យនៃសមត្ថកិច្ចរបស់ខ្លួន អំពីភាពសមស្របនៃវិធានការអន្តរជាតិ ដែលទំនងជាអាចរួមចំណែកជួយដល់រដ្ឋភាគីនានា ក្នុងការធ្វើឱ្យសំរេចការរីកចំរើន ក្នុងការអនុវត្តន៍សិទ្ធិទាំងឡាយដែលបានទទួលស្គាល់នៅក្នុងកតិកាសញ្ញា ។

៣. ត្រូវបង្កើតមូលនិធិទំនុកចិត្តមួយ ស្របតាមនីតិវិធីពាក់ព័ន្ធរបស់មហាសន្និបាត ដែលនឹងត្រូវគ្រប់គ្រងស្របតាមវិធាន និងបទបញ្ជាហិរញ្ញវត្ថុរបស់អង្គការសហប្រជាជាតិ ក្នុងគោលដៅផ្ដល់អ្នកជំនាញ និងជំនួយបច្ចេកទេសដល់រដ្ឋភាគីនានា ដោយមានការយល់ព្រមពីរដ្ឋភាគីពាក់ព័ន្ធ ដើម្បីសំរួលដល់ការអនុវត្តន៍សិទ្ធិទាំងឡាយដែលមានចែងក្នុងកតិកាសញ្ញានេះ ដើម្បីរួមចំណែកកសាងសមត្ថភាពជាតិ ក្នុងវិស័យសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ស្ថិតក្នុងបរិបទនៃពិធីសារនេះ ។

៤. បទបញ្ញត្តិនៃមាត្រានេះ មិនប៉ះពាល់ដល់កាតព្វកិច្ចរបស់រដ្ឋនីមួយៗ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនក្រោមកតិកាសញ្ញានេះឡើយ ។

## មាត្រា ១៥
## របាយការណ៍ប្រចាំឆ្នាំ

គណៈកម្មាធិការត្រូវបញ្ចូលទៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន នូវសេចក្តីសង្ខេបស្តីពីសកម្មភាពរបស់ខ្លួន ស្របតាមពិធីសារនេះ ។

## មាត្រា ១៦
## ការផ្សព្វផ្សាយ និងព័ត៌មាន

រដ្ឋភាគីនីមួយៗមានភារៈកិច្ចផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងជាសាធារណៈ អំពីកតិកាសញ្ញា និងពិធីសារនេះ និងដើម្បីជួយសំរួលដល់ការទទួលបានព័ត៌មានអំពីការយល់ឃើញ និងអនុសាសន៍របស់គណៈកម្មាធិការ ជាពិសេស អំពីបញ្ហាដែលពាក់ព័ន្ធនឹងរដ្ឋភាគីនោះ ហើយត្រូវធ្វើក្នុងទម្រង់ផ្សេងៗ ដែលងាយស្រួលឱ្យជនពិការអាចទទួលយកបាន ។

## មាត្រា ១៧
## ការចុះហត្ថលេខា ការផ្តល់សច្ចាប័ន និងការចូលជាសមាជិក

១. ពិធីសារនេះ ត្រូវបើកចំហឱ្យចុះហត្ថលេខាដោយរដ្ឋសមាជិកណាមួយ ដែលបានចុះហត្ថលេខាផ្តល់សច្ចាប័ន ឬចូលជាសមាជិកនៃកតិកាសញ្ញានេះ ។

២. ពិធីសារនេះជាកម្មវត្ថុនៃការផ្តល់សច្ចាប័នដោយរដ្ឋសមាជិកណាមួយ ដែលបានផ្តល់សច្ចាប័ន ឬចូលជាសមាជិកនៃកតិកាសញ្ញានេះ។ លិខិតុបករណ៍ផ្តល់សច្ចាប័នត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ។

៣. ពិធីសារនេះ ត្រូវបើកចំហឱ្យចូលជាសមាជិកដោយរដ្ឋណាមួយ ដែលបានផ្តល់សច្ចាប័ន ឬចូលជាសមាជិកនៃកតិកាសញ្ញានេះ ។

៤. ការចូលជាសមាជិកត្រូវធ្វើឡើងដោយការតំកល់លិខិតុបករណ៍ចូលជាសមាជិក នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

## មាត្រា ១៨
## ការចូលជាធរមាន

១. ពិធីសារនេះ ចូលជាធរមានក្នុងរយៈពេលបីខែ ក្រោយពីកាលបរិច្ឆេទនៃការតំកល់លិខិតុបករណ៍ផ្តល់សច្ចាប័ន ឬលិខិតុបករណ៍ចូលជាសមាជិកទីដប់ នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

២. ចំពោះរដ្ឋណាមួយដែលផ្តល់សច្ចាប័ន ឬចូលជាសមាជិកនៃពិធីសារនេះ បន្ទាប់ពីការដំកល់លិខិតុបករណ៍ផ្តល់សច្ចាប័ន ឬលិខិតុបករណ៍ចូលជាសមាជិកទីដប់ ពិធីសារនេះត្រូវចូលជាធរមានក្នុងរយៈពេលបីខែ ក្រោយកាលបរិច្ឆេទនៃការតំកល់លិខិតុបករណ៍ផ្តល់សច្ចាប័ន ឬលិខិតុបករណ៍ចូលជាសមាជិករបស់រដ្ឋខ្លួន ។

## មាត្រា ១៩
## ការធ្វើវិសោធនកម្ម

១. រដ្ឋភាគីណាមួយ អាចស្នើសុំធ្វើវិសោធនកម្មកតិកាសញ្ញានេះ រួចដាក់សំណើនោះជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវជូនព័ត៌មានអំពីសំណើធ្វើវិសោធនកម្មនេះ ទៅរដ្ឋភាគីដោយស្នើសុំឱ្យរដ្ឋទាំងនោះ បញ្ជាក់ថាតើខ្លួនគាំទ្រឱ្យមានសន្និសិទនៃរដ្ឋភាគី ចំពោះគោលបំណងនៃការពិចារណា និងការសំរេចលើសំណើទាំងនោះឬទេ។ ក្នុងរយៈពេល៤ ខែ គិតចាប់ពីថ្ងៃជូនដំណឹងនោះមក ក្នុងករណីដែលរដ្ឋភាគីយ៉ាងតិចមួយភាគបី គាំទ្រអោយមានសន្និសិទបែបនេះ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវកោះប្រជុំសន្និសិទនេះ ក្រោមកិច្ចឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ។ ការធ្វើវិសោធនកម្មណាមួយដែលអនុម័តដោយសំលេងភាគច្រើនពីរភាគបីនៃរដ្ឋភាគីដែលមានវត្តមានបោះឆ្នោត ត្រូវបានអគ្គលេខាធិការអង្គការសហប្រជាជាតិ ដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិសំរាប់ការអនុម័តយល់ព្រម រួចហើយបញ្ជូនទៅគ្រប់រដ្ឋភាគីសំរាប់ការទទួលយល់ព្រម។

២. ការធ្វើវិសោធនកម្មដែលបានយល់ព្រម និងអនុម័ត អនុលោមទៅតាមកថាខ័ណ្ឌទី១ នៃមាត្រានេះ ត្រូវចូលជាធរមាននៅទីសាមសិប បន្ទាប់ពីមានចំនួនលិខិតុបករណ៍នៃការទទួលយល់ព្រម ត្រូវបានតំកល់ទុកឡើងដល់ពីរភាគបីនៃរដ្ឋភាគី នាឱកាសនៃការអនុម័តវិសោធនកម្មនេះ។ បន្ទាប់មក វិសោធនកម្មនេះ ត្រូវចូលជាធរមានសំរាប់រដ្ឋភាគីទាំងអស់ នៅថ្ងៃទីសាមសិប ក្រោយពីការតំកល់ទុកលិខិតុបករណ៍នៃការទទួលយល់ព្រមរបស់ខ្លួន។ វិសោធនកម្ម អនុវត្តបានតែចំពោះរដ្ឋភាគីណាដែលបានទទួលយល់ព្រមលើការធ្វើវិសោធនកម្មនោះតែប៉ុណ្ណោះ ។

## មាត្រា ២០
## ការប្រកាសដកខ្លួនចេញ

១. រដ្ឋភាគី អាចប្រកាសដកខ្លួនចេញពីពិធីសារនេះ បានគ្រប់ពេលវេលា ដោយការជូនដំណឹងជាលាយល័ក្ខណ៍អក្សរ ដល់អគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ការប្រកាសដកខ្លួនចេញ ត្រូវចូលជាធរមានប្រាំមួយខែបន្ទាប់ពីកាលបរិច្ឆេទដែលអគ្គលេខាធិការបានទទួលការជូនដំណឹងនេះ ។

២. ការប្រកាសដកខ្លួនចេញ មិនត្រូវឱ្យប៉ះពាល់ដល់ការបន្តអនុវត្តបទបញ្ញត្តិនៃពិធីសារនេះ ចំពោះបណ្ដឹងណាមួយដែលបានដាក់ស្នើ ស្របតាមមាត្រា២ និងមាត្រា១០ ឬចំពោះនីតិវិធីណាមួយដែលបានផ្ដើមធ្វើ ស្របតាមមាត្រា១១ នៅមុនកាលបរិច្ឆេទចូលជាធរមាននៃការប្រកាសដកខ្លួនចេញនេះឡើយ ។

## មាត្រា ២១
## ការជូនដំណឹងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ

អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវជូនដំណឹងដល់រដ្ឋទាំងអស់ ដូចមានចែងក្នុងមាត្រា២៦ កថាខ័ណ្ឌទី១ នៃកតិកាសញ្ញានេះ នូវចំណុចដូចខាងក្រោមនេះ :

ក-  ការចុះហត្ថលេខា  ការផ្តល់សច្ចាប័ន  និងការចូលជាសមាជិក  ស្របតាមពិធីសារនេះ ។

ខ-  កាលបរិច្ឆេទចូលជាធរមាននៃពិធីសារនេះ  និងកាលបរិច្ឆេទចូលជាធរមាននៃវិសោធនកម្មណាមួយ ស្របតាមមាត្រា១៩ ។

គ-  ការប្រកាសដកខ្លួនចេញ  ស្របតាមមាត្រា២០ ។

## មាត្រា ២២

## ភាសាផ្លូវការ

១.  ពិធីសារនេះដែលមានអត្ថបទជាភាសាអារ៉ាប់  ចិន  អង់គ្លេស  បារាំង  រុស្ស៊ី  និងអេស្ប៉ាញ៉ុល មានតម្លៃយថាភូតស្មើគ្នា  និងត្រូវតំកល់ទុកនៅបណ្ណសារដ្ឋានរបស់អង្គការសហប្រជាជាតិ ។

២.  អគ្គលេខាធិការអង្គការសហប្រជាជាតិ  ត្រូវបញ្ជូនច្បាប់ចម្លងនៃពិធីសារនេះ  ដោយមានបញ្ជាក់ការចម្លងតាមច្បាប់ដើម  ទៅរដ្ឋភាគីទាំងឡាយ  ស្របតាមមាត្រា២៦ នៃកតិកាសញ្ញានេះ ។

# កតិកាសញ្ញាអន្តរជាតិ
# ស្តីពី
# សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

# ៨- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦
និងចូលជាធរមាននៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦ ស្របតាមមាត្រា៤៩
កម្ពុជាក្លាយជារដ្ឋភាគីនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២

## បុព្វកថា

*រដ្ឋភាគីនៃកតិកាសញ្ញានេះ*

*យល់ឃើញថា* ស្របតាមគោលការណ៍នានា ដែលបានប្រកាសនៅក្នុងធម្មនុញ្ញសហប្រជាជាតិ ការទទួលស្គាល់សេចក្តីថ្លៃថ្នូរជាប់ពីកំណើត សិទ្ធិស្មើភាពគ្នា និងសិទ្ធិដែលមិនអាចលក់ដូរ ផ្ទេរ ដកហូតបាន របស់សមាជិកគ្រួសារមនុស្ស គឺជាគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពក្នុងពិភពលោក ។

*ទទួលស្គាល់ថា* សិទ្ធិទាំងនេះកើតមកពីសេចក្តីថ្លៃថ្នូរជាប់ពីកំណើតរបស់មនុស្ស ។

*ទទួលស្គាល់ថា* ស្របតាមសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ឧត្តមគតិរបស់មនុស្សសេរីដែលអាស្រ័យផលសេរីភាពពលរដ្ឋ និងនយោបាយ និងភាពរួចផុតពីការភ័យខ្លាច និងទុគ៌តភាព អាចសម្រេចជោគជ័យទៅបាន លុះត្រាតែបង្កើតបានលក្ខខណ្ឌដែលឱ្យមនុស្សម្នាក់ៗ អាចប្រើប្រាស់បាននូវសិទ្ធិពលរដ្ឋ និងនយោបាយ ព្រមទាំងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ខ្លួន ។

*យល់ឃើញថា* ធម្មនុញ្ញសហប្រជាជាតិ តម្រូវឱ្យរដ្ឋនូវកាតព្វកិច្ចជំរុញឱ្យមានការគោរពជាសកល និងការអនុវត្តន៍នូវសិទ្ធិ និងសេរីភាពរបស់មនុស្ស ។

*យល់ឃើញថា* បុគ្គលគ្រប់រូបមានករណីយកិច្ចចំពោះអ្នកដទៃ និងចំពោះសហគមន៍ដែលខ្លួនរស់នៅ ហើយត្រូវខិតខំលើកស្ទួយ និងគោរពសិទ្ធិទាំងឡាយដែលទទួលស្គាល់ក្នុងកតិកាសញ្ញានេះ ។

*ព្រមព្រៀងលើមាត្រាទាំងឡាយដូចតទៅ :*

### ផ្នែកទី ១

### មាត្រា ១

១. ប្រជាជាតិទាំងអស់មានសិទ្ធិស្វ័យសម្រេច ។ អាស្រ័យដោយសិទ្ធិនេះ ប្រជាជាតិទាំងនេះសម្រេចដោយសេរីនូវឋានៈនយោបាយនិងខិតខំអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌របស់ខ្លួនដោយសេរី។

២. ដើម្បីសម្រេចគោលដៅរបស់ខ្លួន ប្រជាជាតិទាំងអស់ អាចចាត់ចែងដោយសេរីនូវភោគទ្រព្យ និងធនធានធម្មជាតិរបស់ខ្លួន ដោយមិនធ្វើឱ្យប៉ះពាល់ដល់កាតព្វកិច្ច ដែលចេញមកពីសហប្រតិបត្តិការសេដ្ឋកិច្ចអន្តរជាតិ ដែលផ្អែកលើគោលការណ៍នៃផលប្រយោជន៍ទៅវិញទៅមក និងគោលការណ៍នៃច្បាប់អន្តរជាតិ។ តែយ៉ាងណាក៏ដោយ ប្រជាជាតិនីមួយៗមិនត្រូវបានដកហូតមធ្យោបាយចិញ្ចឹមជីវិតផ្ទាល់ខ្លួនឡើយ ។

៣. រដ្ឋភាគីនៃកតិកាសញ្ញានេះរួមទាំងរដ្ឋនានាដែលមានការទទួលខុសត្រូវគ្រប់គ្រងទឹកដីអស្វយ័ត និងទឹកដីអាណាព្យាបាល ត្រូវលើកស្ទួយធ្វើឱ្យបានសម្រេចនូវសិទ្ធិស្វ័យសម្រេច និងត្រូវគោរពសិទ្ធិនេះ ស្របតាមបទបញ្ញត្តិទាំងឡាយនៃធម្មនុញ្ញសហប្រជាជាតិ ។

## ផ្នែកទី ២

## មាត្រា ២

១. រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាគោរព និងធានាជូនបុគ្គលគ្រប់រូបដែលរស់នៅលើទឹកដី និងស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន នូវសិទ្ធិដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ ដោយគ្មានការបែងចែកណាមួយ មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃៗទៀតឡើយ ។

២. បើមិនទាន់មានចែងក្នុងច្បាប់ដែលមានស្រាប់ ឬក្នុងវិធានការដទៃទៀតទេ រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាចាត់វិធានការចាំបាច់ ស្របតាមនីតិវិធីនៃរដ្ឋធម្មនុញ្ញរបស់ខ្លួន និងស្របតាមបទបញ្ញត្តិទាំងឡាយនៃកតិកាសញ្ញានេះ ដោយសម្រួលដល់ការអនុម័តវិធានការច្បាប់ ឬវិធានការផ្សេងទៀតដែលចាំបាច់ ដើម្បីធ្វើឱ្យសម្រេចបាននូវសិទ្ធិទាំងឡាយ ដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ ។

៣. រដ្ឋភាគីនៃកាតិកាសញ្ញានេះ សន្យា :

(ក) ធានាថា ជនណាដែលត្រូវគេរំលោភសិទ្ធិ និងសេរីភាពរបស់ខ្លួន ដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ ជននោះមានសិទ្ធិឱ្យមានការដោះស្រាយដោយស័ក្តិសិទ្ធិ ទោះបីការរំលោភនោះ បានប្រព្រឹត្តដោយជនដែលបំពេញមុខនាទីរាជការក៏ដោយ ។

(ខ) ធានាថា ជនណាដែលប្តឹងឱ្យមានការដោះស្រាយបែបនេះ ត្រូវមានសិទ្ធិឱ្យអាជ្ញាធរមានសមត្ថកិច្ចខាងយុត្តិធម៌ ខាងរដ្ឋបាល ឬខាងនីតិបញ្ញត្តិ ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀត សម្រេចឱ្យខ្លួន ដោយយោងតាមច្បាប់របស់រដ្ឋនោះ និងត្រូវបង្កើតលទ្ធភាពនៃការប្តឹងទៅតុលាការផង ។

(គ) ធានាថា អាជ្ញាធរមានសមត្ថកិច្ចត្រូវអនុវត្តឱ្យបាននូវដំណោះស្រាយដែលបានសម្រេចហើយ។

## មាត្រា ៣

រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាធានា សិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី ក្នុងការប្រើប្រាស់សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដូចមានចែងក្នុងកតិកាសញ្ញានេះ ។

## មាត្រា ៤

១. ក្នុងករណីមានភាពអាសន្នសាធារណៈពិសេស ដែលគំរាមកំហែងដល់អត្ថិភាពជាតិ និងដែលត្រូវបានប្រកាសជាផ្លូវការ រដ្ឋភាគីនៃកតិកាសញ្ញានេះ អាចចាត់វិធានការបដិប្បញ្ញត្តិនឹងកាតព្វកិច្ចដែលមានចែងក្នុងកតិកាសញ្ញានេះ ក្នុងកម្រិតដែលស្ថានភាពតម្រូវតែប៉ុណ្ណោះ កុំឱ្យតែវិធានការទាំងនេះ មានវិសមិតភាពទៅនឹងកាតព្វកិច្ចដទៃទៀត ដែលច្បាប់អន្តរជាតិតម្រូវ ហើយមិនពាក់ព័ន្ធនឹងការរើសអើងដែលផ្អែកលើពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ឬដើមកំណើតសង្គម ។

២. បទបញ្ញត្តិខាងលើនេះ មិនអនុញ្ញាតឱ្យមាន បដិប្បញ្ញត្តិនឹងមាត្រា៦ មាត្រា៧ មាត្រា៨ (កថាខណ្ឌ១ និង២) មាត្រា១១ មាត្រា១៥ មាត្រា១៦ និងមាត្រា១៨ ។

៣. រដ្ឋភាគីណាមួយនៃកតិកាសញ្ញានេះ ដែលប្រើប្រាស់សិទ្ធិបដិប្បញ្ញត្តិ ត្រូវផ្តល់ព័ត៌មានដល់រដ្ឋភាគីឯទៀតជាបន្ទាន់ តាមរយៈអន្តរការីនៃអគ្គលេខាធិការអង្គការសហប្រជាជាតិ នូវបទបញ្ញត្តិ និងមូលហេតុ ដែលខ្លួនបានធ្វើបដិប្បញ្ញត្តិនេះ ។ ការផ្តល់ព័ត៌មានបន្ថែម ស្តីពីកាលបរិច្ឆេទនៃការបញ្ចប់បដិប្បញ្ញត្តិរបស់ខ្លួន ត្រូវធ្វើឡើងតាមរយៈអន្តរការីនៃអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

## មាត្រា ៥

១. គ្មានបទបញ្ញត្តិណាមួយនៃកតិកាសញ្ញានេះ អាចត្រូវបានបកស្រាយតម្រូវថា រដ្ឋមួយ ក្រុមមួយ បុគ្គលម្នាក់ មានសិទ្ធិធ្វើសកម្មភាព ឬប្រព្រឹត្តអំពើអ្វីមួយ ដែលសំដៅទៅបំផ្លិចបំផ្លាញសិទ្ធិ និងសេរីភាពដែលទទួលស្គាល់ក្នុងកតិកាសញ្ញានេះ ឬសំដៅទៅដាក់កម្រិត ដែលមានវិសាលភាពធំជាងកម្រិតដែលបានចែងនៅក្នុងកតិកាសញ្ញានេះ ។

២. មិនត្រូវធ្វើការរឹតត្បិត ឬធ្វើបដិប្បញ្ញត្តិណាមួយឡើយទៅលើសិទ្ធិមូលដ្ឋានរបស់មនុស្សដែលត្រូវបានទទួលស្គាល់ ឬដែលនៅជាធរមានក្នុងរដ្ឋភាគីនៃកតិកាសញ្ញានេះ ដោយអនុលោមទៅតាមច្បាប់ អនុសញ្ញា បទបញ្ជា ឬទំនៀមទំលាប់ ដោយយកលេសថា កតិកាសញ្ញានេះ មិនទទួលស្គាល់សិទ្ធិទាំងនោះ ឬទទួលស្គាល់សិទ្ធិទាំងនោះក្នុងកម្រិតតិចជាង ។

# ផ្នែកទី ៣

## មាត្រា ៦

១. ជនគ្រប់រូប មានសិទ្ធិមានជីវិតជាប់ពីកំណើត ។ សិទ្ធិនេះ ត្រូវការពារដោយច្បាប់ ។ គ្មានជនណាម្នាក់ ត្រូវគេប្រហារជីវិតតាមអំពើចិត្តបានឡើយ ។

២. ក្នុងប្រទេសទាំងឡាយណាដែលមិនទាន់បានលប់ចោលទោសប្រហារជីវិត សាលក្រមកាត់ទោសប្រហារជីវិត អាចប្រកាសបានចំពោះតែបទឧក្រិដ្ឋណាដែលធ្ងន់ធ្ងរបំផុតស្របតាមច្បាប់ជាធរមានក្នុងពេលដែលបទឧក្រិដ្ឋនោះកើតឡើង ហើយមិនផ្ទុយនឹងបទបញ្ញត្តិនៃកតិកាសញ្ញានេះ និងអនុសញ្ញាស្តីពីការបង្ការ និងការផ្តន្ទាទោសបទឧក្រិដ្ឋប្រល័យពូជសាសន៍ ។ ទណ្ឌកម្មនេះអាចអនុវត្តបាន ដោយអនុលោមតែតាមសាលក្រមស្ថាពរ ដែលចេញដោយតុលាការមានសមត្ថកិច្ចប៉ុណ្ណោះ ។

៣. នៅពេលដែលការប្រហារជីវិតជាបទឧក្រិដ្ឋប្រល័យពូជសាសន៍ត្រូវយល់ថាគ្មានបទបញ្ញត្តិណាមួយនៃមាត្រានេះ ដែលអនុញ្ញាតឱ្យរដ្ឋភាគីនៃកតិកាសញ្ញានេះ ធ្វើបដិប្បញ្ញត្តិតាមបែបណាមួយពីកាតព្វកិច្ចណា ដែលបានសន្មត់ ស្របតាមបទបញ្ញត្តិនៃអនុសញ្ញាស្តីពីការបង្ការ និងការផ្តន្ទាទោសបទឧក្រិដ្ឋប្រល័យពូជសាសន៍នោះបានឡើយ ។

៤. ជនដែលទទួលទោសប្រហារជីវិត មានសិទ្ធិសុំអភ័យទោស ឬបន្ធូរបន្ថយទោស ។ ការលើកលែងទោស ការអភ័យទោស ឬការបន្ធូរបន្ថយទោសប្រហារជីវិត អាចផ្តល់ឱ្យបានគ្រប់ករណីទាំងអស់ ។

៥. ទោសប្រហារជីវិត មិនត្រូវអនុវត្តចំពោះបទឧក្រិដ្ឋទាំងឡាយណា ដែលប្រព្រឹត្តដោយជនមានអាយុក្រោម១៨ឆ្នាំ និងមិនត្រូវអនុវត្តចំពោះស្ត្រីមានផ្ទៃពោះឡើយ ។

៦. គ្មានបទបញ្ញត្តិណាមួយក្នុងមាត្រានេះ អាចយកមកសំអាង ដើម្បីធ្វើឱ្យយឺតយ៉ាវ ឬរារាំងដល់ការលុបចោលទោសប្រហារជីវិត ដោយរដ្ឋភាគីនៃកតិកាសញ្ញានេះឡើយ ។

## មាត្រា ៧

គ្មានជនណាម្នាក់ត្រូវរងទារុណកម្ម ឬប្រព្រឹត្តកម្ម ឬទណ្ឌកម្ម ដែលឃោរឃៅ អមនុស្សធម៌ ឬធ្វើឱ្យថោកទាបឡើយ ។ ជាពិសេស ហាមយកជនណាម្នាក់ មកធ្វើការពិសោធន៍ខាងវេជ្ជសាស្ត្រ ឬវិទ្យាសាស្ត្រ ដោយគ្មានការយល់ព្រមដោយសេរីពីសាមីខ្លួនឡើយ ។

## មាត្រា ៨

១. គ្មានជនណាម្នាក់ ត្រូវជាប់ក្នុងទាសភាពឡើយ ។ ទាសភាព និងទាសពាណិជ្ជកម្ម តាមគ្រប់ទម្រង់ទាំងអស់ ត្រូវហាមឃាត់ ។

២. គ្មានជនណាម្នាក់ ត្រូវជាប់ក្នុងភាពជាខ្ញុំបម្រើដាច់ថ្លៃឡើយ ។

៣. (ក) គ្មានជនណាម្នាក់ តម្រូវឱ្យធ្វើការដោយបង្ខំ ឬខានមិនបានឡើយ ។

(ខ) កថាខណ្ឌ៣ (ក) មិនត្រូវយកមកបកស្រាយថា ហាមឃាត់ការអនុវត្តន៍ទោសឱ្យធ្វើការដោយបង្ខំ ស្របតាមការវិនិច្ឆ័យទោស ដោយតុលាការមានសមត្ថកិច្ចក្នុងប្រទេស ដែលបទឧក្រិដ្ឋខ្លះ អាចមានទោសជាប់គុកឱ្យធ្វើការដោយបង្ខំ ។

(គ) បំណងនៃកថាខណ្ឌនេះ ពាក្យថា "ការងារដោយបង្ខំ ឬដោយខានមិនបាន" មិនត្រូវរាប់បញ្ចូល :

(i) ការងារ ឬសេវាដែលគ្មានចែងក្នុងអនុកថាខណ្ឌ (ខ) និងដែលតម្រូវជាធម្មតា ចំពោះជនជាប់ឃុំ តាមបទបញ្ជាស្របច្បាប់របស់តុលាការ ឬចំពោះជនដែលតុលាការសម្រេចដោះលែងឱ្យមានសេរីភាពដោយលក្ខខណ្ឌ ។

(ii) សេវាដែលមានលក្ខណៈយោធា និងកិច្ចការបំរើជាតិ ដែលតម្រូវតាមច្បាប់សម្រាប់អ្នកប្រឆាំងសង្គ្រាម នៅក្នុងប្រទេសដែលទទួលស្គាល់សិទ្ធិប្រឆាំងសង្គ្រាម ។

(iii) សេវា ដែលតម្រូវក្នុងករណីមានអាសន្ន ឬគ្រោះមហន្តរាយ ដែលគំរាមកំហែងដល់អាយុជីវិត និងសុខមាលភាពសហគមន៍ ។

(iv) ការងារ ឬសេវា ដែលជាផ្នែកនៃកាតព្វកិច្ចធម្មតារបស់ប្រជាពលរដ្ឋ ។

## មាត្រា ៩

១. ជនគ្រប់រូប មានសិទ្ធិមានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន ។ គ្មានជនណាម្នាក់ ត្រូវចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្តបានឡើយ ។ គ្មានជនណាម្នាក់ ត្រូវដកហូតសេរីភាពបានឡើយ លើកលែងតែមានហេតុផល និងស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់ ។

២. ជនណាដែលត្រូវបានចាប់ខ្លួន ត្រូវមានសិទ្ធិឱ្យគេប្រាប់ឱ្យដឹងនៅពេលចាប់ខ្លួន អំពីមូលហេតុនៃការចាប់ខ្លួន និងត្រូវប្រាប់ឱ្យដឹងភ្លាមអំពីការចោទប្រកាន់ ។

៣. បុគ្គលណាដែលបានចាប់ខ្លួន ឬឃុំខ្លួនពីបទព្រហ្មទណ្ឌ នឹងត្រូវបាននាំខ្លួនទៅចំពោះមុខចៅក្រម ឬអាជ្ញាធរណាមួយផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់ឱ្យបំពេញមុខងារតុលាការ ក្នុងរយៈពេលយ៉ាងខ្លីបំផុត និងត្រូវបានជំនុំជំរះក្នុងរយៈពេលសមស្រប ឬត្រូវដោះលែង ។ ការឃុំខ្លួនមនុស្ស ដើម្បីរង់ចាំការជំនុំជំរះ គឺមិនមែនជាវិធានទូទៅទេ ប៉ុន្តែការឱ្យនៅក្រៅឃុំ ត្រូវតែមានការធានាការចូលខ្លួនរបស់ជននោះនៅពេលសវនាការ ឬនៅគ្រប់ដំណាក់ការដទៃទៀតនៃនីតិវិធី ហើយត្រូវមានមុខក្នុងការអនុវត្តន៍សាលក្រម។

៤. ជនណាដែលត្រូវដកហូតសេរីភាព ដោយការឃាត់ខ្លួន ឬឃុំខ្លួន ត្រូវតែមានសិទ្ធិដាក់ពាក្យបណ្តឹង ដើម្បីឱ្យតុលាការអាចសម្រេចដោយមិនពន្យារពេល អំពីនីត្យានុកូលភាពនៃការឃុំខ្លួន និងបង្គាប់ឱ្យនៅក្រៅឃុំ បើការឃុំខ្លួននោះមិនស្របច្បាប់ ។

៥. ជនណាដែលបានរងគ្រោះដោយសារការឃាត់ខ្លួនឬឃុំខ្លួនខុសច្បាប់មានសិទ្ធិទាមទារសំណង។

### មាត្រា ១០

១. ជនណាដែលត្រូវបានដកហូតសេរីភាព ត្រូវទទួលបានការប្រព្រឹត្តមកលើខ្លួន តាមលក្ខណៈមនុស្សធម៌ និងការគោរពចំពោះសេចក្តីថ្លៃថ្នូរពីកំណើតរបស់មនុស្ស ។

២. (ក) ជនជាប់ចោទ ត្រូវដាក់ឱ្យនៅផ្សេងពីទណ្ឌិត លើកលែងតែក្នុងកាលៈទេសៈពិសេស ។ ជនជាប់ចោទ ត្រូវស្ថិតនៅក្រោមរបបដាច់ដោយឡែក ដែលសមស្របទៅតាមលក្ខខណ្ឌរបស់ជនពុំទាន់មានទោស ។

(ខ) ជនជាប់ចោទជាអនីតិជន ត្រូវដាក់ផ្សេងពីនីតិជន ហើយត្រូវទទួលការជំនុំជំរះឱ្យបានឆាប់តាមដែលអាចធ្វើបាន ។

៣. ប្រព័ន្ធគ្រប់គ្រងពន្ធនាគារ ត្រូវមានការប្រព្រឹត្តទៅលើទណ្ឌិត ដែលមានគោលបំណងជាសារវ័ន្ត ដើម្បីស្តារនីតិសម្បទា និងបញ្ចូលពួកគេទៅក្នុងសង្គមវិញ ។ ទណ្ឌិតជាអនីតិជន ត្រូវបំបែកចេញពីនីតិជន ហើយត្រូវស្ថិតនៅក្នុងការប្រព្រឹត្តទៅលើពួកគេ សមស្របតាមអាយុ និងស្ថានភាពនីត្យានុកូលភាពរបស់គេ ។

### មាត្រា ១១

គ្មានជនណាម្នាក់ ត្រូវជាប់ពន្ធនាគារ ដោយសារតែខ្លួនពុំអាចបំពេញតាមកាតព្វកិច្ចនៃកិច្ចសន្យានោះឡើយ ។

### មាត្រា ១២

១. ជនណាដែលរស់នៅត្រឹមត្រូវតាមលក្ខណៈច្បាប់ ក្នុងប្រទេសណាមួយ មានសិទ្ធិធ្វើដំណើរ និងជ្រើសរើសនិវេសនដ្ឋានរបស់ខ្លួនដោយសេរី ។

២. ជនគ្រប់រូប មានសេរីភាពចាកចេញពីប្រទេសណាមួយ រួមទាំងប្រទេសរបស់ខ្លួនផង ។

៣. សិទ្ធិដែលបានចែងខាងលើនេះ មិនត្រូវមានការរិតត្បិតឡើយ លើកលែងតែការការរិតត្បិតនេះមានចែងក្នុងច្បាប់ ចាំបាច់ដើម្បីការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាពសាធារណៈ ឬសីលធម៌ ឬសិទ្ធិ និងសេរីភាពអ្នកដទៃ ហើយមិនទំនាស់ជាមួយសិទ្ធិដទៃទៀត ដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ ។

៤. គ្មានជនណាម្នាក់ ត្រូវបានដកសិទ្ធិតាមអំពើចិត្ត មិនឱ្យចូលក្នុងប្រទេសរបស់ខ្លួនឡើយ ។

## មាត្រា ១៣

ជនបរទេស ឋិតនៅដោយស្របច្បាប់ លើដែនដីរដ្ឋភាគីនៃកតិកាសញ្ញានេះ នឹងអាចត្រូវបានបណ្តេញចេញពីរដ្ឋនោះបាន លុះត្រាតែធ្វើឡើងដោយអនុលោមតាមសេចក្តីសម្រេចស្របតាមច្បាប់ លើកលែងការបណ្តេញចេញ ដោយហេតុផលបង្ខំ សម្រាប់រក្សាសន្តិសុខជាតិ ហើយជនបរទេសនេះត្រូវបានអនុញ្ញាតឱ្យដាក់ហេតុផលជំទាស់នឹងការបណ្តេញចេញនេះ និងសុំឱ្យអាជ្ញាធរមានសមត្ថកិច្ច ឬមនុស្សម្នាក់ ឬច្រើននាក់ ដែលអាជ្ញាធរបានតែងតាំងជាពិសេស ពិនិត្យករណីរបស់ខ្លួនឡើងវិញ រួមទាំងឱ្យមានអ្នកការពារសិទ្ធិផងដែរ ។

## មាត្រា ១៤

១. ជនគ្រប់រូប ត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជំរះក្តី ។ ជនគ្រប់រូបត្រូវមានសិទ្ធិឱ្យសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង ដែលបង្កើតឡើងដោយច្បាប់ ជំនុំជំរះរឿងក្តីរបស់ខ្លួន ដោយសមធម៌ និងជាសាធារណៈ ដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួន ក្នុងវិស័យព្រហ្មទណ្ឌ ឬលើសិទ្ធិ និងករណីយកិច្ច ក្នុងវិស័យរដ្ឋប្បវេណី ។ សារព័ត៌មាន និងសាធារណៈជន អាចមិនឱ្យចូលរួមទាំងស្រុង ឬផ្នែកមួយនៃសវនាការ សម្រាប់ផលប្រយោជន៍នៃទំនៀមទំលាប់ល្អ សណ្តាប់ធ្នាប់សាធារណៈ ឬសន្តិសុខជាតិក្នុងសង្គមប្រជាធិបតេយ្យ ឬនៅពេលផលប្រយោជន៍នៃជីវិតឯកជនរបស់គូភាគីតម្រូវឱ្យធ្វើដូច្នេះ ឬក្នុងកម្រិតដែលចាំបាច់បំផុត តាមការយល់ឃើញរបស់តុលាការ ក្នុងស្ថានភាពពិសេសដែលថា ការធ្វើជាសាធារណៈ នឹងនាំឱ្យខូចដល់ផលប្រយោជន៍យុត្តិធម៌ ។ ប៉ុន្តែការចេញសាលក្រមទាំងអស់ អំពីរឿងព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី ត្រូវប្រកាសជាសាធារណៈ លើកលែងតែផលប្រយោជន៍អនីតិជន តម្រូវផ្សេងពីនេះ ឬរឿងក្តីអំពីទំនាស់គ្រួសារ ឬអាណាព្យាបាលរបស់កុមារ ។

២. ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌ ត្រូវបានសន្មត់ជាមុនថាជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួន ត្រូវបានកំណត់ស្របតាមច្បាប់ ។

៣. ក្នុងការសម្រេចសេចក្តី ចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរិមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ដូចខាងក្រោម ៖

(ក) ត្រូវបានព័ត៌មានភ្លាមៗ និងដោយលំអិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួន ជាភាសាដែលជននោះចេះ ។

(ខ) ត្រូវមានពេលវេលា និងសម្ភារៈរូបវ័ន្តគ្រប់គ្រាន់ សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លងជាមួយមេធាវីដែលជ្រើសរើសដោយខ្លួនឯង ។

(គ) ត្រូវបានជំនុំជំរះដោយឥតពន្យារពេលយូរហួស ។

(ឃ) ត្រូវបានជំនុំជំរះដោយមានវត្តមានរបស់ខ្លួន និងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់ តាមការជ្រើសរើសរបស់ខ្លួន និងត្រូវបានប្រាប់ឱ្យដឹង អំពីសិទ្ធិនេះ ប្រសិនបើខ្លួនគ្មានជំនួយការច្បាប់ ហើយត្រូវទទួលបានជំនួយការច្បាប់សម្រាប់ខ្លួន ក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើដូច្នេះ និងដោយឥតបង់ថ្លៃ នៅគ្រប់ករណីបែបនេះ បើជនជាប់ចោទ គ្មានមធ្យោបាយគ្រប់គ្រាន់ ដើម្បីចំណាយទៅលើជំនួយការច្បាប់ទេ ។

(ង) ត្រូវមានការសួរចម្លើយ ឬសុំឱ្យសួរចម្លើយ ទៅលើសាក្សីដាក់បន្ទុក និងសុំឱ្យសាក្សីដោះបន្ទុកចូលខ្លួន ដើម្បីសួរចម្លើយក្នុងនាមខ្លួន ក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក ។

(ច) ត្រូវទទួលបានអ្នកបកប្រែភាសាដោយឥតគិតឈ្នួល បើជនជាប់ចោទមិនយល់ ឬមិនចេះភាសាដែលប្រើប្រាស់ក្នុងសវនាការ ។

(ឆ) មិនត្រូវបានបង្ខិតបង្ខំឱ្យឆ្លើយដាក់កំហុសលើខ្លួនឯង ឬសារភាពថាមានពិរុទ្ធ ។

៤. នីតិវិធីអនុវត្តចំពោះយុវជន-យុវនារី ដែលមិនទាន់មាននីតិភាពតាមច្បាប់កំណត់ ត្រូវគិតដល់អាយុ និងអត្ថប្រយោជន៍នៃការអប់រំរបស់ពួកគេឡើងវិញ ។

៥. ជនគ្រប់រូបដែលជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ត្រូវមានសិទ្ធិសុំឱ្យសាលាក្តីជាន់ខ្ពស់ ពិនិត្យទៅលើការប្រកាសពិរុទ្ធភាព និងការផ្តន្ទាទោសឡើងវិញស្របតាមច្បាប់ ។

៦. នៅពេលជនណាម្នាក់ ត្រូវបានប្រកាសឱ្យជាប់ពិរុទ្ធបទព្រហ្មទណ្ឌជាស្ថាពរ ហើយក្រោយមកការប្រកាសឱ្យជាប់ពិរុទ្ធនេះ ត្រូវបានបដិសេធ ឬត្រូវបានលើកលែងទោសដោយហេតុថា អង្គហេតុថ្មី ឬដែលបានរកឃើញថ្មី បញ្ជាក់យ៉ាងច្បាស់ថា មានការខុសឆ្គងពីសំណាក់តុលាការ ជនដែលទទួលរងគ្រោះដោយសារការដាក់ទោសនេះ ត្រូវទទួលសំណងស្របតាមច្បាប់ លើកលែងតែមានការកំណត់បង្ហាញថាការមិនលាតត្រដាងអាថ៌កំបាំងនៃការពិតទាន់ពេលបណ្តាលមកពីជននោះ ទាំងស្រុង ឬមួយផ្នែក ។

៧. គ្មានជនណាម្នាក់ ត្រូវយកមកចោទប្រកាន់ ឬយកមកផ្តន្ទាទោសសារជាថ្មីឡើយ ចំពោះបទល្មើស ដែលបានផ្តន្ទាទោសជាស្ថាពរ ឬបានលើកលែងទោសស្របតាមច្បាប់ និងនិតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនីមួយៗរួចហើយ ។

## មាត្រា ១៥

១. គ្មានជនណាម្នាក់ ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ចំពោះអំពើ ឬការខកខានណាមួយដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ ក្នុងខណៈពេលប្រព្រឹត្តនោះឡើយ ។ ដូចគ្នានេះ មិនត្រូវដាក់ទោស ឱ្យធ្ងន់ជាងទោសដែលអនុវត្តក្នុងខណៈពេលប្រព្រឹត្តបទល្មើសឡើយ ។ ប្រសិនបើក្រោយពីការប្រព្រឹត្តបទល្មើសហើយ ច្បាប់បានបញ្ញត្តិឱ្យមានការដាក់ទោសស្រាលជាងមុន ជនល្មើសត្រូវទទួលអត្ថប្រយោជន៍ពីការដាក់ទោសស្រាលជាងនេះ ។

២. គ្មានបញ្ញត្តិណាមួយក្នុងមាត្រានេះ ប្រឆាំងនឹងការជំនុំជំរះក្តី ឬការផ្តន្ទាទោសដល់ជនណាម្នាក់ ចំពោះអំពើ ឬការខកខានណាមួយដែលជននោះបានប្រព្រឹត្ត ក្នុងខណៈពេលដែលអំពើ ឬការខកខាននោះ ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមគោលការណ៍ទូទៅនៃច្បាប់ដែលទទួលស្គាល់ដោយសហគមន៍នៃប្រជាជាតិ ។

## មាត្រា ១៦

ជនគ្រប់រូប មានសិទ្ធិឱ្យគេទទួលស្គាល់បុគ្គលិកលក្ខណៈគតិយុត្តិរបស់ខ្លួន នៅគ្រប់ទីកន្លែង ។

## មាត្រា ១៧

១. គ្មានជនណាម្នាក់ ត្រូវទទួលរងការជ្រៀតជ្រែកតាមអំពើចិត្ត ឬដោយខុសច្បាប់ ក្នុងជីវិតឯកជន គ្រួសារ លំនៅដ្ឋាន សំបុត្រឆ្លើយឆ្លងរបស់ខ្លួន ឬត្រូវរងការប៉ះពាល់ដោយខុសច្បាប់ ទៅលើកិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ខ្លួនឡើយ ។

២. ជនគ្រប់រូប មានសិទ្ធិឱ្យច្បាប់ការពារប្រឆាំងនឹងការជ្រៀតជ្រែក ឬការប៉ះពាល់បែបនេះ ។

## មាត្រា ១៨

១. ជនគ្រប់រូប មានសិទ្ធិសេរីភាពខាងការគិត សតិសម្បជញ្ញៈ និងសាសនា ។ សិទ្ធិនេះ ត្រូវរាប់បញ្ចូលទាំងសេរីភាពក្នុងការកាន់ ឬគោរពសាសនា ឬជំនឿណាមួយតាមការជ្រើសរើសរបស់ខ្លួន និងសេរីភាពក្នុងការសម្តែងសាសនា ឬជំនឿរបស់ខ្លួន ដោយម្នាក់ៗឯង ឬដោយរួមជាមួយអ្នកដទៃ និងជាសាធារណៈ ឬជាឯកជន តាមការគោរពបូជា ការប្រតិបត្តិតាម ការអនុវត្តន៍ និងការបង្ហាត់បង្រៀន ។

២. គ្មានជនណាម្នាក់ត្រូវរងការបង្ខិតបង្ខំឱ្យកាន់ ឬគោរពសាសនា ដែលបំពារបំពានធ្វើឱ្យខូចខាតដល់សេរីភាពនៃការកាន់ ឬកាគោរពសាសនា ឬជំនឿតាមការជ្រើសរើសរបស់ខ្លួនឡើយ ។

៣. សេរីភាពសម្តែងការគោរពសាសនា ឬជំនឿរបស់ខ្លួន នឹងអាចដាក់កម្រិតព្រំដែនបាន លុះត្រាតែមានបញ្ញត្តិដោយច្បាប់ និងចាំបាច់ដល់ការការពារ សន្តិសុខសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ សុខភាពសាធារណៈ ឬសីលធម៌ ឬសិទ្ធិ និងសេរីភាពមូលដ្ឋានរបស់អ្នកដទៃ ។

៤. រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាគោរពសេរីភាពរបស់ឪពុកម្តាយ និងអ្នកអាណាព្យាបាលស្របច្បាប់ ប្រសិនជាមាន ក្នុងការធានាដល់ការអប់រំខាងសាសនា និងសីលធម៌ដល់បុត្រធីតារបស់គេស្របតាមជំនឿរបស់គេ ។

## មាត្រា ១៩

១. ជនគ្រប់រូប មានសិទ្ធិប្រកាន់យកមតិយោបល់ ដោយគ្មានការជ្រៀតជ្រែក ។

២. ជនគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ។ សិទ្ធិនេះ ត្រូវរាប់បញ្ចូលទាំងសេរីភាពស្រាវជ្រាវព័ត៌មាន ទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាង ដោយមិនគិតពីព្រំដែន ដោយផ្ទាល់មាត់ សរសេរ ឬបោះពុម្ព តាមទម្រង់សិល្បៈក្តី ឬក៏ដោយមធ្យោបាយផ្សព្វផ្សាយដទៃទៀតក្តី តាមការជ្រើសរើសរបស់ខ្លួន ។

៣. ការប្រើប្រាស់សិទ្ធិដែលចែងក្នុងកថាខណ្ឌ២ នៃមាត្រានេះ តម្រូវឱ្យមានករណីយកិច្ច និងការទទួលខុសត្រូវពិសេស ។ ដូច្នេះ ការប្រើប្រាស់សិទ្ធិនេះ អាចមានការរិតត្បិតមួយចំនួន ដែលត្រូវកំណត់ដាច់ខាតដោយច្បាប់ និងដែលចាំបាច់ដើម្បី :

(ក) គោរពសិទ្ធិ និងកិត្តិសព្ទរបស់អ្នកដទៃ ។

(ខ) ការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាព ឬសីលធម៌សាធារណៈ ។

## មាត្រា ២០

១. ការឃោសនាណាជាគុណប្រយោជន៍ដល់សង្គ្រាម ត្រូវហាមឃាត់ដោយច្បាប់ ។

២. ការអំពាវនាវណាឱ្យមានការស្អប់ខ្ពើមជាតិ ពូជសាសន៍ ឬសាសនា ដែលជាការញុះញង់នាំឱ្យកើតមានការរើសអើង ការប្រទូស្តរាយ ឬហិង្សា ត្រូវហាមឃាត់ដោយច្បាប់ ។

## មាត្រា ២១

សិទ្ធិប្រជុំដោយសន្តិវិធីត្រូវតែទទួលស្គាល់ ។ ការប្រើប្រាស់សិទ្ធិនេះ អាចមានការរិតត្បិតដែលកំណត់ដោយច្បាប់តែប៉ុណ្ណោះ និងដែលចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ ក្នុងផលប្រយោជន៍នៃសន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខភាពសាធារណៈ ឬសីលធម៌ ឬការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ ។

## មាត្រា ២២

១. ជនគ្រប់រូប មានសិទ្ធិចូលរួមជាសមាគមដោយសេរីជាមួយអ្នកដទៃ រាប់បញ្ចូលទាំងសិទ្ធិបង្កើតសហជីព និងសិទ្ធិចូលជាសមាជិកសហជីព ដើម្បីការពារផលប្រយោជន៍របស់ខ្លួន ។

២. ការប្រើប្រាស់សិទ្ធិនេះ អាចមានការរិតត្បិតដែលកំណត់ដោយច្បាប់តែប៉ុណ្ណោះ និងដែលចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ ក្នុងផលប្រយោជន៍នៃសន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខភាពសាធារណៈ ឬសីលធម៌ ឬការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ ។ មាត្រានេះ មិនរារាំងដល់ការរិតត្បិតខាងផ្លូវច្បាប់ លើសមាជិកយោធា និងនគរបាល ក្នុងការប្រើប្រាស់សិទ្ធិនេះទេ ។

៣. គ្មានបទបញ្ញត្តិណាមួយនៃមាត្រានេះអនុញ្ញាតឱ្យរដ្ឋភាគីនៃអនុសញ្ញាឆ្នាំ១៩៤៨ របស់អង្គការការងារអន្តរជាតិស្តីពីសេរីភាពខាងសហជីព និងការការពារសិទ្ធិខាងសហជីព ចាត់វិធានការខាងផ្លូវច្បាប់ ឬអនុវត្តច្បាប់ តាមរបៀបដែលធ្វើឱ្យប៉ះពាល់ដល់ការធានា ដែលមានចែងក្នុងអនុសញ្ញានោះឡើយ ។

## មាត្រា ២៣

១. គ្រួសារជាអង្គភាពធម្មជាតិ និងជាអង្គភាពមូលដ្ឋានរបស់សង្គម ហើយគ្រួសារ មានសិទ្ធិទទួលការការពារពីសង្គម និងរដ្ឋ ។

២. សិទ្ធិរបស់មនុស្សប្រុសស្រីពេញវ័យ ក្នុងការរៀបអាពាហ៍ពិពាហ៍ និងក្នុងការកសាងគ្រួសារ ត្រូវតែទទួលស្គាល់ ។

៣. គ្មានអាពាហ៍ពិពាហ៍ណាអាចធ្វើឡើងដោយគ្មានការយល់ព្រមដោយសេរី និងពេញលេញពីអនាគតប្តីប្រពន្ធឡើយ ។

៤. រដ្ឋភាគីនៃកតិកាសញ្ញានេះ ត្រូវចាត់វិធានការសមស្រប ដើម្បីធានាសមភាពខាងសិទ្ធិ និងការទទួលខុសត្រូវរបស់ប្តីប្រពន្ធ ចំពោះការរៀបអាពាហ៍ពិពាហ៍ ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ និងនៅពេលរំលាយអាពាហ៍ពិពាហ៍ ។ ក្នុងគ្រាដែលមានការរំលាយអាពាហ៍ពិពាហ៍ ត្រូវមានបទបញ្ញត្តិសម្រាប់ការការពារជាចាំបាច់ចំពោះកូន ។

## មាត្រា ២៤

១. កុមារគ្រប់រូប មានសិទ្ធិទទួលបានវិធានការការពារ តម្រូវនឹងស្ថានភាពរបស់ខ្លួនជាអនីតិជនពីសំណាក់គ្រួសាររបស់ខ្លួន សង្គម និងរដ្ឋ ដោយគ្មានការរើសអើងលើពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ ឬកំណើតឡើយ ។

២. កុមារគ្រប់រូប ត្រូវបានចុះឈ្មោះក្នុងបញ្ជីជាបន្ទាន់ បន្ទាប់ពីពេលកើត និងត្រូវមានឈ្មោះ ។

៣. កុមារគ្រប់រូប មានសិទ្ធិបានសញ្ជាតិមួយ ។

## មាត្រា ២៥

ដោយគ្មានការបែងចែក ដូចដែលបានចែងក្នុងមាត្រា២ និងដោយគ្មានការរិតត្បិត ដែលមិនសមហេតុផល ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិ និងមានឱកាស :

(ក) រួមចំណែកក្នុងការដឹកនាំកិច្ចការសាធារណៈ ដោយផ្ទាល់ ឬតាមរយៈតំណាង ដែលខ្លួនជ្រើសរើសដោយសេរី ។

(ខ) បោះឆ្នោត និងឈរឈ្មោះបោះឆ្នោត នៅក្នុងការបោះឆ្នោតពិតប្រាកដតាមកាលកំណត់ទៀងទាត់ជាសកល ស្មើភាព និងដោយសម្ងាត់ដែលធានាការបញ្ចេញមតិដោយសេរីពីឆន្ទៈអ្នកបោះឆ្នោត។

(គ) ចូលបម្រើមុខងារសាធារណៈក្នុងប្រទេសរបស់ខ្លួន ក្នុងលក្ខខណ្ឌទូទៅដោយសមភាព ។

## មាត្រា ២៦

ជនគ្រប់រូប មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិការពារពីច្បាប់ស្មើគ្នា ដោយឥតរើសអើង ។ ក្នុងប្រការនេះ ច្បាប់ត្រូវហាមការរើសអើង និងត្រូវធានាឱ្យជនគ្រប់រូបនូវការការពារស័ក្តិសិទ្ធិស្មើគ្នាប្រឆាំងការរើសអើងទាំងឡាយ មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃទៀត ។

## មាត្រា ២៧

ក្នុងរដ្ឋដែលមានក្រុមជនភាគតិចខាងជាតិពន្ធុ សាសនា ឬភាសា ជនដែលជាសមាជិកជនភាគតិចទាំងនេះ ដោយរួមនឹងសមាជិកដទៃទៀតនៃក្រុមរបស់ខ្លួន មិនត្រូវទទួលរងការរារាំងសិទ្ធិអាស្រ័យផលវប្បធម៌របស់ពួកគេ សិទ្ធិកាន់ និងប្រតិបត្តិសាសនាតាមទម្លាប់ពួកគេ ឬសិទ្ធិប្រើប្រាស់ភាសារបស់ពួកគេឡើយ។

## ផ្នែកទី ៤

## មាត្រា ២៨

១. គណៈកម្មាធិការសិទ្ធិមនុស្សមួយ (បន្ទាប់ពីនេះទៅហៅថា គណៈកម្មាធិការ) ត្រូវបង្កើតឡើង ។ គណៈកម្មាធិការមានសមាជិក ១៨រូប និងបំពេញមុខងារតាមការកំណត់ខាងក្រោម ។

២. គណៈកម្មាធិការ ត្រូវមានសមាជិកជាប្រជាពលរដ្ឋនៃរដ្ឋសមាជិកកតិកាសញ្ញានេះ ដែលជាមនុស្សមានអត្តចរិតសីលធម៌ខ្ពស់ និងសមត្ថភាពដែលគេទទួលស្គាល់ក្នុងវិស័យសិទ្ធិមនុស្ស ដោយការគិតដល់ប្រយោជន៍ ដែលបានមកពីការចូលរួមពីមនុស្សមួយចំនួន ដែលមានបទពិសោធន៍ខាងវិស័យច្បាប់ ។

៣. សមាជិកគណៈកម្មាធិការ ត្រូវជ្រើសរើសតាមការបោះឆ្នោត ហើយត្រូវធ្វើការក្នុងឋានៈជាបុគ្គល ។

## មាត្រា ២៩

១. សមាជិកគណៈកម្មាធិការ ត្រូវជ្រើសរើសតាមការបោះឆ្នោតជាសម្ងាត់ ពីបញ្ជីឈ្មោះបេក្ខជនដែលមានគុណសម្បត្តិ តាមលក្ខខណ្ឌបញ្ញត្តិក្នុងមាត្រា២៨ ហើយដែលជ្រើសតាំងដោយរដ្ឋភាគីនៃកតិកាសញ្ញានេះ ។

២. រដ្ឋភាគីនីមួយៗនៃកតិកាសញ្ញានេះ អាចជ្រើសតាំងបេក្ខជន ២រូប យ៉ាងច្រើន ។ បេក្ខជនទាំងនេះ ត្រូវតែជាជនជាតិនៃរដ្ឋដែលជ្រើសតាំងបេក្ខជន ។

៣. បេក្ខជនដដែល អាចមានសិទ្ធិជ្រើសតាំងជាថ្មីទៀតបាន ។

## មាត្រា ៣០

១. ការបោះឆ្នោតលើកដំបូង ត្រូវធ្វើយ៉ាងយូរបំផុត ៦ខែ ក្រោយពីកាលបរិច្ឆេទនៃការចូលជាធរមាននៃកតិកាសញ្ញានេះ ។

២. យ៉ាងតិច៤ខែ មុនកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសសមាជិកសម្រាប់គណៈកម្មាធិការ ក្រៅពីការជ្រើសរើសឱ្យបំពេញមុខងារទំនេរស្របតាមមាត្រា៣៤ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវចេញលិខិតអញ្ជើញឱ្យរដ្ឋភាគីនៃកតិកាសញ្ញានេះ បញ្ជូនបញ្ជីបេក្ខជនរបស់ខ្លួន ក្នុងរយៈពេល ៣ខែ សម្រាប់ធ្វើជាសមាជិកគណៈកម្មាធិការ ។

៣. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវធ្វើបញ្ជីឈ្មោះបេក្ខជនទាំងអស់ តាមឈ្មោះលំដាប់អក្ខរៈក្រម ដោយបញ្ជាក់ឈ្មោះរដ្ឋភាគីដែលបានជ្រើសតាំងបេក្ខជន ហើយផ្ញើបញ្ជីនេះទៅរដ្ឋភាគីទាំងអស់នៃកតិកាសញ្ញានេះ យ៉ាងហោច ១ខែ មុនកាលបរិច្ឆេទនៃការបោះឆ្នោតនីមួយៗ ។

៤. ការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការត្រូវធ្វើក្នុងពេលប្រជុំរដ្ឋភាគីនៃកតិកាសញ្ញានេះ ដែលកោះអញ្ជើញដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ នៅទីស្នាក់ការនៃអង្គការនេះ ។ កូរ៉ុមសម្រាប់កិច្ចប្រជុំ គឺពីរភាគបីនៃរដ្ឋភាគីនៃកតិកាសញ្ញានេះ ។ បេក្ខជនដែលជាប់ជាសមាជិកគណៈកម្មាធិការ ត្រូវតែជាបេក្ខជនដែលទទួលបានសម្លេងច្រើនបំផុត និងសម្លេងភាគច្រើនដាច់ខាតពីតំណាងរបស់រដ្ឋភាគីដែលមានវត្តមាន និងបានបោះឆ្នោត ។

## មាត្រា ៣១

១. គណៈកម្មាធិការ មិនអាចមានសមាជិកលើសពី ១រូប ដែលជាជនជាតិនៃរដ្ឋដដែលឡើយ ។

២. ក្នុងការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការ ត្រូវធ្វើការពិចារណាបែងចែកសមាជិកភាព ទៅតាមភូមិសាស្ត្រដោយសមធម៌ និងឱ្យមានតំណាងទម្រង់ផ្សេងៗនៃអារ្យធម៌ ព្រមទាំងទៅតាមប្រព័ន្ធច្បាប់ធំៗផង ។

## មាត្រា ៣២

១. សមាជិកគណៈកម្មាធិការ ត្រូវជ្រើសរើសតាមការបោះឆ្នោត សម្រាប់រយៈពេល ៤ឆ្នាំ ។ សមាជិកគណៈកម្មាធិការ អាចមានសិទ្ធិឈរឈ្មោះបោះឆ្នោតឡើងវិញ ប្រសិនបើមានការជ្រើសតាំងជាថ្មី ។ ប៉ុន្តែអាណត្តិសមាជិក ៩រូប ដែលជាប់ឆ្នោតលើកទី១ ត្រូវផុតកំណត់ក្នុងរយៈពេល ២ឆ្នាំ ហើយក្រោយពីការបោះឆ្នោតលើកទី១ ឈ្មោះសមាជិកទាំង ៩រូបនេះ ត្រូវចាប់ឆ្នោតជ្រើសរើសជាបន្ទាន់ ដោយប្រធានអង្គប្រជុំ ដែលមានចែងក្នុងកថាខណ្ឌ៤ នៃមាត្រា៣០ ។

២. ពេលផុតអាណត្តិការងារ ការបោះឆ្នោតត្រូវធ្វើឡើងឱ្យស្របតាមបទបញ្ញត្តិនៃមាត្រាមុនៗ នៅក្នុងផ្នែកទី៤ នៃកតិកាសញ្ញានេះ ។

## មាត្រា ៣៣

១. ប្រសិនបើមានសមាជិកណាមួយនៃគណៈកម្មាធិការ បានឈប់ធ្វើការងាររបស់ខ្លួន ក្រៅពីមូលហេតុអវត្តមានជាលក្ខណៈបណ្តោះអាសន្ន ប្រធានគណៈកម្មាធិការ តាមមតិឯកច្ឆ័ន្ទពីសមាជិកឯទៀត ត្រូវជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយអគ្គលេខាធិការត្រូវប្រកាសពីអាសនៈទំនេររបស់សមាជិកនោះ ។

២. ក្នុងគ្រាមានមរណភាព ឬការលាឈប់ពីតំណែងរបស់សមាជិកណាម្នាក់ ប្រធានគណៈកម្មាធិការ ត្រូវជូនដំណឹងភ្លាម ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយអគ្គលេខាធិការ ត្រូវប្រកាសពីអាសនៈទំនេរ ចាប់ពីកាលបរិច្ឆេទមរណភាព ឬការសុំលាលែង មានអានុភាព ។

## មាត្រា ៣៤

១. នៅពេលអាសនៈទំនេរ ត្រូវបានប្រកាសស្របតាមមាត្រា៣៣ និងបើអាណត្តិរបស់សមាជិកដែលត្រូវដាក់ជំនួស មិនទាន់ផុតកំណត់ក្នុងរយៈពេល ៦ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការប្រកាសអាសនៈទំនេរ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវជូនដំណឹងឱ្យរដ្ឋភាគីទាំងអស់នៃកតិកាសញ្ញានេះ ក្នុងរយៈពេល ២ខែ ឱ្យជ្រើសតាំងបេក្ខជន ស្របតាមបទបញ្ញត្តិនៃមាត្រា២៩ ដើម្បីបំពេញអាសនៈទំនេរនេះ ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវរៀបចំបញ្ជីឈ្មោះបេក្ខជនជ្រើសតាំងតាមលំដាប់អក្ខរក្រម ហើយត្រូវផ្ញើបញ្ជីនេះទៅរដ្ឋភាគីនៃកតិកាសញ្ញានេះ ។ ការបោះឆ្នោតបំពេញអាសនៈទំនេរត្រូវធ្វើស្របតាមបទបញ្ញត្តិពាក់ព័ន្ធនៃផ្នែកទី៤ នៃកតិកាសញ្ញានេះ ។

៣. សមាជិកគណៈកម្មាធិការ ដែលជាប់ឆ្នោតបំពេញអាសនៈទំនេរ ដូចបានប្រកាសស្របតាមមាត្រា៣៣ ត្រូវបំពេញភារកិច្ច រហូតដល់ចប់អាណត្តិរបស់សមាជិក ដែលទុកអាសនៈឱ្យទំនេរនៅក្នុងគណៈកម្មាធិការ ស្របតាមបទបញ្ញត្តិនៃមាត្រានោះ ។

## មាត្រា ៣៥

សមាជិកគណៈកម្មាធិការ ទទួលបរិលាភពីធនធានរបស់អង្គការសហប្រជាជាតិ តាមការយល់ព្រមពីមហាសន្និបាតអង្គការសហប្រជាជាតិ ក្នុងលក្ខខណ្ឌកំណត់ដោយមហាសន្និបាតអង្គការសហប្រជាជាតិ ទៅតាមសារសំខាន់នៃមុខងាររបស់គណៈកម្មាធិការ ។

## មាត្រា ៣៦

អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវផ្តល់បុគ្គលិក និងសម្ភារៈរូបវ័ន្តចាំបាច់ ដើម្បីឱ្យគណៈកម្មាធិការបំពេញមុខងារឱ្យបានស័ក្តិសិទ្ធិ ស្របតាមកតិកាសញ្ញានេះ ។

## មាត្រា ៣៧

១. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវកោះសមាជិកគណៈកម្មាធិការឱ្យមកប្រជុំជាលើកទី១ នៅទីស្នាក់ការអង្គការសហប្រជាជាតិ ។

២. ក្រោយពីកិច្ចប្រជុំលើកទី១ គណៈកម្មាធិការត្រូវរៀបចំសម័យប្រជុំគ្រប់ពេល ដូចបានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

៣. តាមធម្មតា គណៈកម្មាធិការ ត្រូវប្រជុំនៅទីស្នាក់ការអង្គការសហប្រជាជាតិ ឬនៅការិយាល័យអង្គការសហប្រជាជាតិ នៅទីក្រុងហ្សឺណែវ ។

## មាត្រា ៣៨

មុននឹងទទួលតំណែង សមាជិកគណៈកម្មាធិការទាំងអស់ ត្រូវប្រកាសជាឧឡារិកនៅចំពោះមុខអង្គប្រជុំថា នឹងបំពេញមុខងាររបស់ខ្លួន ដោយគ្មានលំអៀង និងដោយសតិសម្បជញ្ញៈ ។

## មាត្រា ៣៩

១. គណៈកម្មាធិការ ត្រូវបោះឆ្នោតជ្រើសរើសមន្ត្រីការិយាល័យរបស់ខ្លួនសម្រាប់រយៈពេល២ឆ្នាំ ។ មន្ត្រីការិយាល័យទាំងអស់ អាចត្រូវបានបោះឆ្នោតជ្រើសរើសជាថ្មីទៀតបាន ។

២. គណៈកម្មាធិការ ត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។ ប៉ុន្តែ បទបញ្ជាផ្ទៃក្នុងនេះ ត្រូវមានបទបញ្ញត្តិដូចខាងក្រោមនេះ បន្ថែមលើបទបញ្ញត្តិដទៃទៀត ៖

(ក) កូរ៉ុមត្រូវមានសមាជិក ១២នាក់

(ខ) សេចក្តីសម្រេចរបស់គណៈកម្មាធិការត្រូវធ្វើឡើងដោយសម្លេងភាគច្រើននៃសមាជិកវត្តមាន

## មាត្រា ៤០

១. រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាបង្ហាញរបាយការណ៍ស្តីពីវិធានការដែលបានអនុម័ត អនុវត្តសិទ្ធិដែលទទួលស្គាល់ក្នុងកតិកាសញ្ញានេះ និងរបាយការណ៍ស្តីពីការរីកចម្រើនដែលសម្រេចបាន ក្នុងការអាស្រ័យផលនៃសិទ្ធិទាំងនេះ ៖

(ក) ក្នុងរយៈពេល ១ឆ្នាំ គិតពីថ្ងៃចូលជាធរមាននៃកតិកាសញ្ញានេះ ចំពោះរដ្ឋភាគីពាក់ព័ន្ធ ។

(ខ) រាល់លើកដែលគណៈកម្មាធិការធ្វើសំណើ ។

២. របាយការណ៍ទាំងអស់ ត្រូវដាក់ជូនទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយអគ្គលេខាធិការ ត្រូវបញ្ជូនរបាយការណ៍ទាំងនោះ ទៅគណៈកម្មាធិការដើម្បីពិនិត្យ ។ របាយការណ៍ត្រូវបញ្ជាក់ ប្រសិនបើមានកត្តា និងឧបសគ្គ ដែលនាំឱ្យប៉ះពាល់ដល់ការអនុវត្តន៍នៃកតិកាសញ្ញានេះ ។

៣. ក្រោយពីការពិគ្រោះជាមួយគណៈកម្មាធិការ អគ្គលេខាធិការអង្គការសហប្រជាជាតិ អាច បញ្ជូនទៅស្ថាប័នឯកទេសពាក់ព័ន្ធ នូវសេចក្តីចម្លងគ្រប់ភាគនៃរបាយការណ៍ ដែលអាចស្ថិតក្នុងវិស័យនៃ សមត្ថកិច្ចរបស់ស្ថាប័នទាំងនោះ ។

៤. គណៈកម្មាធិការ ត្រូវសិក្សារបាយការណ៍ដែលដាក់ជូនដោយរដ្ឋភាគីនៃកតិកាសញ្ញានេះ ។ គណៈកម្មាធិការ ត្រូវបញ្ជូនរបាយការណ៍របស់ខ្លួន ព្រមទាំងយោបល់ទូទៅដែលគណៈកម្មាធិការពិនិត្យ ឃើញថាសមស្រប ទៅឱ្យរដ្ឋភាគីទាំងអស់ ។ គណៈកម្មាធិការ អាចបញ្ជូនយោបល់ទាំងនេះទៅក្រុម ប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ចដោយភ្ជាប់ជាមួយច្បាប់ចម្លងនៃរបាយការណ៍នានាដែលគណៈកម្មាធិការបាន ទទួលពីរដ្ឋភាគីនៃកតិកាសញ្ញានេះ ។

៥. រដ្ឋភាគីនៃកតិកាសញ្ញានេះ អាចដាក់ជូនគណៈកម្មាធិការ នូវសេចក្តីសង្កេត លើការផ្តល់ យោបល់ ដែលអាចត្រូវធ្វើឡើង ស្របតាមកថាខណ្ឌ៤ នៃមាត្រានេះ ។

## មាត្រា ៤១

១. រដ្ឋភាគីណាមួយនៃកតិកាសញ្ញានេះ អាចប្រកាសនៅគ្រប់ពេលវេលា ស្របតាមមាត្រានេះថា ខ្លួនទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការ ក្នុងការទទួល និងពិនិត្យបណ្តឹងពីរដ្ឋភាគី ដែលអះអាងថា រដ្ឋភាគីមួយទៀត មិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន ស្របតាមកតិកាសញ្ញានេះ ។ បណ្តឹងនេះ អាចទទួល និងពិនិត្យបាន លុះត្រាតែរដ្ឋភាគី បានធ្វើសេចក្តីប្រកាសទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការចំពោះ រដ្ឋនេះ ។ គណៈកម្មាធិការ មិនត្រូវទទួលបណ្តឹងរបស់រដ្ឋភាគី ដែលមិនបានធ្វើសេចក្តីប្រកាសទទួលស្គាល់ ឡើយ ។ បណ្តឹងស្របតាមមាត្រានេះ ត្រូវដោះស្រាយ ស្របតាមនីតិវិធីខាងក្រោម :

(ក) បើរដ្ឋភាគីមួយនៃកតិកាសញ្ញានេះយល់ឃើញថា រដ្ឋភាគីមួយទៀតមិនអនុវត្តបទបញ្ញត្តិនៃ កតិកាសញ្ញានេះ រដ្ឋភាគីម្ខាងអាចនាំយកបញ្ហា តាមរយៈបណ្តឹងជាលាយល័ក្ខអក្សរ មកបង្ហាញឱ្យរដ្ឋ ភាគីម្ខាងទៀតពិនិត្យពិចារណា ។ ក្នុងរយៈពេល ៣ខែ ក្រោយពីបានទទួលបណ្តឹង រដ្ឋចុងបណ្តឹង ត្រូវ ផ្តល់ការពន្យល់ ឬសេចក្តីប្រកាសជាលាយល័ក្ខអក្សរ បំភ្លឺបញ្ហាតាមកម្រិត ដែលអាចធ្វើបាននិងដោយចំៗ ជូនរដ្ឋដើមបណ្តឹង ដែលមានយោងនីតិវិធី និងដំណោះស្រាយនៅក្នុងប្រទេសដែលបានធ្វើហើយ ដែលមិន ទាន់សម្រេច ឬដែលនៅបើកចំហ ។

(ខ) បើបញ្ហាមិនត្រូវបានដោះស្រាយឱ្យពេញចិត្តរវាងរដ្ឋជាប់ពាក់ព័ន្ធទាំងពីរ ក្នុងរយៈពេល៦ខែ ចាប់ពីថ្ងៃទទួលបណ្តឹងដំបូងដោយរដ្ឋចុងបណ្តឹង រដ្ឋណាមួយក៏បាន មានសិទ្ធិបញ្ជូនបញ្ហាទៅគណៈកម្មា ធិការ ដោយជូនដំណឹងទៅគណៈកម្មាធិការ និងរដ្ឋម្ខាងទៀត ។

(គ) គណៈកម្មាធិការ អាចដោះស្រាយបញ្ហាដែលបញ្ជូនឱ្យមកខ្លួនបាន លុះត្រាតែគណៈកម្មា ធិការ បានរកឃើញថា មធ្យោបាយខាងផ្លូវច្បាប់ទាំងអស់ដែលមាននៅក្នុងប្រទេសនោះ ត្រូវបានយក

មកប្រើអស់លទ្ធភាព ស្របតាមគោលការណ៍នៃច្បាប់អន្តរជាតិ ដែលទទួលស្គាល់ជាទូទៅ ។ វិធាននេះនឹងមិនត្រូវយកមកអនុវត្តទេ បើនីតិវិធីនៃការដោះស្រាយបន្តយូរហួសហេតុ ។

(ឃ) គណៈកម្មាធិការ ត្រូវរៀបចំសម័យប្រជុំរបស់ខ្លួនដោយសម្ងាត់ នៅពេលពិនិត្យបណ្ដឹងស្របតាមមាត្រានេះ ។

(ង) យោងតាមបទបញ្ញត្តិក្នុងអនុកថាខណ្ឌ (គ) គណៈកម្មាធិការ ត្រូវដាក់សេវារបស់ខ្លួនឱ្យរដ្ឋភាគីពាក់ព័ន្ធប្រើប្រាស់ ដើម្បីឈានទៅដល់ដំណោះស្រាយស្រុះស្រួលលើបញ្ហា ផ្អែកលើមូលដ្ឋាននៃការគោរពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ដែលទទួលស្គាល់ក្នុងកតិកាសញ្ញានេះ ។

(ច) បញ្ហាណាដែលបញ្ជូនមកគណៈកម្មាធិការ ស្របតាមអនុកថាខណ្ឌ (ខ) គណៈកម្មាធិការអាចសុំឱ្យរដ្ឋភាគីពាក់ព័ន្ធផ្ដល់ព័ត៌មានពាក់ព័ន្ធបន្ថែមមកគណៈកម្មាធិការ ។

(ឆ) រដ្ឋភាគីពាក់ព័ន្ធ យោងតាមអនុកថាខណ្ឌ (ខ) មានសិទ្ធិមានវត្តមានតំណាងរបស់ខ្លួន នៅពេលគណៈកម្មាធិការកំពុងពិនិត្យបញ្ហា និងមានសិទ្ធិស្នើយោបល់ដោយផ្ទាល់មាត់ និង/ ឬជាលាយល័ក្ខអក្សរ ។

(ជ) ក្នុងរយៈពេល ១២ខែ ក្រោយពីកាលបរិច្ឆេទទទួលដំណឹង ដូចចែងក្នុងអនុកថាខណ្ឌ (ខ) គណៈកម្មាធិការ ត្រូវដាក់ជូនរបាយការណ៍មួយ :

(i) ប្រសិនបើដំណោះស្រាយមួយ ត្រូវបានរកឃើញ ស្របតាមបទបញ្ញត្តិនៅក្នុងអនុកថាខណ្ឌ (ង) គណៈកម្មាធិការ ត្រូវកម្រិតរបាយការណ៍របស់ខ្លួន ត្រឹមតែជាសេចក្ដីថ្លែងការណ៍សង្ខេបស្ដីពីអង្គហេតុ និងដំណោះស្រាយ ដែលបានរកឃើញ ។

(ii) ប្រសិនបើដំណោះស្រាយណាមួយមិនអាចរកឃើញ ស្របតាមបទបញ្ញត្តិនៃអនុកថាខណ្ឌ (ង) ទេ គណៈកម្មាធិការ ត្រូវកម្រិតរបាយការណ៍របស់ខ្លួន ត្រឹមតែជាសេចក្ដីថ្លែងការណ៍សង្ខេបស្ដីពីអង្គហេតុ ។ ការស្នើយោបល់ជាលាយល័ក្ខអក្សរ និងកំណត់ត្រានៃការស្នើយោបល់ផ្ទាល់មាត់ដោយរដ្ឋភាគីពាក់ព័ន្ធ ត្រូវភ្ជាប់ទៅនឹងរបាយការណ៍ ។ នៅគ្រប់បញ្ហាទាំងអស់ របាយការណ៍ ត្រូវផ្សាយឱ្យរដ្ឋភាគីពាក់ព័ន្ធបានដឹង ។

២. បទបញ្ញត្តិនៃមាត្រានេះ នឹងចូលជាធរមាន នៅពេលដែលរដ្ឋភាគីចំនួន១០នៃកតិកាសញ្ញានេះ បានធ្វើសេចក្ដីប្រកាសស្របតាមកថាខណ្ឌ១នៃមាត្រានេះ ។ សេចក្ដីប្រកាសនេះត្រូវតំកល់ទុកដោយរដ្ឋភាគី នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយអគ្គលេខាធិការ ត្រូវធ្វើច្បាប់ចម្លងទៅឱ្យរដ្ឋភាគីទាំងអស់ ។ សេចក្ដីប្រកាសអាចដកទៅវិញបានគ្រប់ពេល ដោយជូនដំណឹងទៅអគ្គលេខាធិការ ។ ការដកទៅវិញនេះ មិនត្រូវធ្វើឱ្យប៉ះពាល់ដល់ការពិនិត្យបញ្ហាណាដែលជាកម្មវត្ថុនៃបណ្ដឹងដែលផ្ញើរួចហើយស្របតាមមាត្រានេះឡើយ ហើយបណ្ដឹងបន្ថែមពីរដ្ឋភាគី នឹងឈប់ទទួល ក្រោយពីអគ្គលេខាធិការ បានទទួលការជូនដំណឹងពីការដក លើកលែងតែ រដ្ឋភាគីពាក់ព័ន្ធបានធ្វើសេចក្ដីប្រកាសជាថ្មី ។

## មាត្រា ៤២

១.(ក) បើបញ្ហាដែលដាក់ជូនគណៈកម្មាធិការ ស្របតាមមាត្រា៤១ មិនត្រូវបានដោះស្រាយជាទីពេញចិត្តដល់រដ្ឋភាគីពាក់ព័ន្ធទេ គណៈកម្មាធិការ ដោយមានការយល់ព្រមជាមុនពីរដ្ឋភាគីពាក់ព័ន្ធ អាចចាត់តាំងគណៈកម្មការផ្សះផ្សាចំពោះកិច្ចមួយ (បន្ទាប់ពីនេះទៅហៅថា គណៈកម្មការ)។ គណៈកម្មការត្រូវដាក់សេវារបស់ខ្លួនឱ្យរដ្ឋភាគីពាក់ព័ន្ធប្រើប្រាស់ ដើម្បីរកដំណោះស្រាយសម្រុះសម្រួល លើបញ្ហានោះដោយគោរពតាមកតិកាសញ្ញានេះ ។

(ខ) គណៈកម្មការ ត្រូវមានសមាជិក ៥រូប ដែលមានការយល់ព្រមពីរដ្ឋភាគីពាក់ព័ន្ធ ។ បើរដ្ឋភាគីពាក់ព័ន្ធ មិនឈានដល់ការព្រមព្រៀងគ្នាទាំងស្រុង ឬផ្នែកខ្លះ លើសមាសភាពគណៈកម្មការ ក្នុងរយៈពេល ៣ខែទេ សមាជិកគណៈកម្មការណាដែលមិនបានទទួលការយល់ព្រម ត្រូវដាក់ឱ្យជ្រើសរើសដោយការបោះឆ្នោតជាសម្ងាត់ ដោយយកសម្លេងភាគច្រើនពីរភាគបី នៃចំណោមសមាជិកគណៈកម្មាធិការ ។

២. សមាជិកគណៈកម្មការ ត្រូវបំពេញតួនាទីជាបុគ្គល ។ សមាជិកគណៈកម្មការ មិនត្រូវជាជនជាតិនៃរដ្ឋភាគីពាក់ព័ន្ធ ឬនៃរដ្ឋដែលមិនមែនជាភាគីនៃកតិកាសញ្ញានេះ ឬនៃរដ្ឋភាគីដែលមិនបានធ្វើសេចក្តីប្រកាសដូចចែងក្នុងមាត្រា៤១ ។

៣. គណៈកម្មការ ត្រូវបោះឆ្នោតជ្រើសរើសប្រធាន និងអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

៤. គណៈកម្មការ ត្រូវប្រជុំជាធម្មតានៅទីស្នាក់ការអង្គការសហប្រជាជាតិ ឬនៅការិយាល័យអង្គការសហប្រជាជាតិនៅទីក្រុងហ្សឺណែវ ។ ប៉ុន្តែ កិច្ចប្រជុំអាចធ្វើទៅបាន នៅកន្លែងសមស្របដទៃទៀត ដែលគណៈកម្មការអាចកំណត់ដោយពិគ្រោះយោបល់ជាមួយអគ្គលេខាធិការអង្គការសហប្រជាជាតិ និងរដ្ឋភាគីពាក់ព័ន្ធ ។

៥. លេខាធិការដ្ឋាន ដែលមានចែងក្នុងមាត្រា៣៦ ត្រូវជួយគណៈកម្មការ ដែលបានចាត់តាំងស្របតាមមាត្រានេះ ។

៦. ព័ត៌មានដែលគណៈកម្មាធិការ ទទួល និងប្រមូលបាន ត្រូវទុកឱ្យគណៈកម្មការប្រើប្រាស់ ហើយគណៈកម្មការ អាចសុំឱ្យរដ្ឋភាគីពាក់ព័ន្ធផ្តល់ព័ត៌មានពាក់ព័ន្ធផ្សេងទៀត ។

៧. នៅពេលដែលគណៈកម្មការបានពិនិត្យបញ្ហាសព្វគ្រប់ហើយ យ៉ាងយូរ ១២ខែ ក្រោយពីការសិក្សាបញ្ហាចប់ គណៈកម្មការ ត្រូវធ្វើរបាយការណ៍ទៅប្រធានគណៈកម្មាធិការ ដើម្បីឆ្លើយឆ្លងទៅរដ្ឋភាគីពាក់ព័ន្ធ :

(ក) បើគណៈកម្មការ មិនអាចបញ្ចប់ការពិនិត្យបញ្ហា ក្នុងពេល១២ខែទេ គណៈកម្មការត្រូវកម្រិតរបាយការណ៍ ត្រឹមតែជាសេចក្តីថ្លែងការណ៍សង្ខេបស្តីពីស្ថានភាពនៃការពិនិត្យបញ្ហាតែប៉ុណ្ណោះ ។

(ខ) ផ្អែកលើការគោរពសិទ្ធិមនុស្ស ដូចបានទទួលស្គាល់នៅក្នុងកតិកាសញ្ញានេះ បើដំណោះស្រាយស្រុះស្រួលគ្នាលើបញ្ហា អាចធ្វើបានសម្រេចហើយ នោះគណៈកម្មការ ត្រូវកម្រិតរបាយការណ៍របស់ខ្លួន ត្រឹមតែជាសេចក្តីថ្លែងការណ៍សង្ខេបលើអង្គហេតុ និងដំណោះស្រាយដែលសម្រេចបាន ។

(គ) បើដំណោះស្រាយតាមលក្ខខណ្ឌនៃអនុកថាខណ្ឌ (ខ) មិនអាចសម្រេចបានទេ របាយការណ៍របស់គណៈកម្មការ ត្រូវបង្ហាញសេចក្តីសន្និដ្ឋានលើគ្រប់ចំណុចនៃអង្គហេតុ ទាក់ទងនឹងបញ្ហានានា រវាងរដ្ឋភាគីពាក់ព័ន្ធ និងបង្ហាញយោបល់ស្តីពីលទ្ធភាពនៃដំណោះស្រាយស្រុះស្រួលគ្នាលើបញ្ហា ។ របាយការណ៍នេះ ត្រូវមានផងដែរនូវការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ និងសំណុំរឿងទាំងមូលនៃការផ្តល់យោបល់ផ្ទាល់មាត់ដោយភាគីពាក់ព័ន្ធ ។

(ឃ) បើរបាយការណ៍របស់គណៈកម្មការ បានដាក់ជូនស្របតាមអនុកថាខណ្ឌ (គ)ខាងលើនោះ រដ្ឋភាគីពាក់ព័ន្ធត្រូវជំរាបទៅប្រធាននៃគណៈកម្មាធិការក្នុងរយៈពេល៣ខែចាប់ពីថ្ងៃបានទទួលរបាយការណ៍ ថាតើព្រមទទួល ឬមិនព្រមទទួលអត្ថន័យនៃរបាយការណ៍របស់គណៈកម្មការ ។

៨. បទបញ្ញត្តិនៃមាត្រានេះ មិនប៉ះពាល់ដល់មុខការរបស់គណៈកម្មាធិការ ដូចមានចែងក្នុងមាត្រា៤១ ឡើយ ។

៩. ចំណាយទាំងអស់របស់សមាជិកគណៈកម្មការ ត្រូវបែងចែកស្មើគ្នា រវាងរដ្ឋភាគីពាក់ព័ន្ធស្របតាមការប៉ាន់ស្មានដែលកំណត់ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

១០. ប្រសិនបើចាំបាច់ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវមានសិទ្ធិចំណាយជួសទៅលើសមាជិកគណៈកម្មការ មុនមានសំណងពីរដ្ឋភាគីពាក់ព័ន្ធ ស្របតាមកថាខណ្ឌ៩ នៃមាត្រានេះ ។

## មាត្រា ៤៣

សមាជិកនៃគណៈកម្មាធិកា និងគណៈកម្មការសម្រុះសម្រួលចំពោះកិច្ចដែលតែងតាំង ស្របតាមមាត្រា៤២ មានសិទ្ធិប្រើប្រាស់សម្ភារៈរូបវ័ន្ត មានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ នៃអ្នកជំនាញការ ក្នុងបេសកកម្មរបស់អង្គការសហប្រជាជាតិ ដូចមានចែងក្នុងផ្នែកពាក់ព័ន្ធ នៃ អនុសញ្ញាស្តីអំពីបុព្វសិទ្ធ និងអភ័យឯកសិទ្ធរបស់សហប្រជាជាតិ ។

## មាត្រា ៤៤

បទបញ្ញត្តិសម្រាប់អនុវត្តអនុសញ្ញានេះ ត្រូវអនុវត្តដោយមិនត្រូវធ្វើឱ្យប៉ះពាល់ដល់នីតិវិធីដែលបានចែងក្នុងវិស័យសិទ្ធិមនុស្ស ស្របតាមលិខិតុបករណ៍ផ្សេងៗ និងអនុសញ្ញារបស់សហប្រជាជាតិ និងស្ថាប័នឯកទេសឡើយ ហើយមិនត្រូវរារាំងរដ្ឋភាគីនៃអនុសញ្ញានេះ ក្នុងការប្រើនីតិវិធីដទៃទៀត ដើម្បីដោះស្រាយជម្លោះ ស្របតាមកិច្ចព្រមព្រៀងអន្តរជាតិទូទៅ ឬពិសេសដែលចងរដ្ឋភាគីឡើយ ។

## មាត្រា ៤៥

គណៈកម្មាធិការ ត្រូវបញ្ជូនរបាយការណ៍ប្រចាំឆ្នាំ ស្តីពីសកម្មភាពរបស់ខ្លួនទៅឱ្យមហាសន្និបាតអង្គការសហប្រជាជាតិ តាមរយៈក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច ។

## ផ្នែកទី ៥

## មាត្រា ៤៦

គ្មានបទបញ្ញត្តិណាមួយក្នុងកតិកាសញ្ញានេះត្រូវយកមកបកស្រាយធ្វើឱ្យប៉ះពាល់ដល់បទបញ្ញត្តិទាំងឡាយនៃធម្មនុញ្ញសហប្រជាជាតិ និងរដ្ឋធម្មនុញ្ញនៃស្ថាប័នឯកទេសនានា ដែលកំណត់ការទទួលខុសត្រូវរបស់អង្គការនានានៃសហប្រជាជាតិ និងស្ថាប័នឯកទេស ចំពោះបញ្ហាពាក់ព័ន្ធនឹងកតិកាសញ្ញានេះឡើយ។

## មាត្រា ៤៧

គ្មានបទបញ្ញត្តិណាមួយនៃកតិកាសញ្ញានេះ ត្រូវយកមកបកស្រាយ ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិពីកំណើតរបស់ប្រជាជាតិទាំងអស់ ក្នុងការអាស្រ័យផល និងប្រើប្រាស់ពេញលេញ និងដោយសេរីនូវភោគទ្រព្យ និងធនធានធម្មជាតិរបស់ខ្លួនឡើយ ។

## ផ្នែកទី ៦

## មាត្រា ៤៨

១. កតិកាសញ្ញានេះត្រូវបើកចំហឱ្យចុះហត្ថលេខាសម្រាប់រដ្ឋសមាជិកសហប្រជាជាតិ ឬសមាជិកនៃស្ថាប័នឯកទេសណាមួយ ឬ ជាភាគីនៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ ឬ ជារដ្ឋផ្សេងទៀតដែលត្រូវបានអញ្ជើញដោយមហាសន្និបាតសហប្រជាជាតិ ដើម្បីក្លាយជាភាគីនៃកតិកាសញ្ញានេះ ។

២. កតិកាសញ្ញានេះ ជាកម្មវត្ថុនៃការឱ្យសច្ចាប័ន ។ លិខិតុបករណ៍ឱ្យសច្ចាប័ន ត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៣. កតិកាសញ្ញានេះ ត្រូវបើកចំហឱ្យរដ្ឋទាំងអស់ចូលជាសមាជិក ដូចចែងក្នុងកថាខណ្ឌ១ នៃមាត្រានេះ ។

៤. ការចូលជាសមាជិក ត្រូវធ្វើឡើងដោយការតំកល់លិខិតុបករណ៍សុំចូលជាសមាជិក នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៥. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវជូនដំណឹងដល់រដ្ឋទាំងអស់ ដែលបានចុះហត្ថលេខាលើកតិកាសញ្ញានេះ ឬដែលបានចូលជាសមាជិកនៃកតិកាសញ្ញានេះអំពីការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬលិខិតុបករណ៍សុំចូលជាសមាជិក ។

## មាត្រា ៤៩

១. កតិកាសញ្ញានេះ ចូលជាធរមានក្នុងរយៈពេល ៣ខែ ក្រោយពីកាលបរិច្ឆេទនៃការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬលិខិតុបករណ៍សុំចូលជាសមាជិកទី៣៥ នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

២. ចំពោះរដ្ឋដែលឱ្យសច្ចាប័ន ឬសុំចូលជាសមាជិកនៃកតិកាសញ្ញានេះ បន្ទាប់ពីសមាជិកទី៣៥ កតិកាសញ្ញានេះ នឹងចូលជាធរមានក្នុងរយៈពេល៣ខែ ក្រោយពីកាលបរិច្ឆេទនៃការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬលិខិតុបករណ៍សុំចូលជាសមាជិករបស់រដ្ឋនោះ ។

## មាត្រា ៥០

បទបញ្ញត្តិនៃកតិកាសញ្ញានេះ ត្រូវអនុវត្តលើគ្រប់ផ្នែកទាំងអស់នៃរដ្ឋសហព័ន្ធ ដោយគ្មានការកម្រិត ឬលើកលែងឡើយ ។

## មាត្រា ៥១

១. រដ្ឋភាគីណាមួយនៃកតិកាសញ្ញានេះ អាចស្នើធ្វើវិសោធនកម្ម និងដាក់សេចក្តីស្នើនោះជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនសេចក្តីស្នើវិសោធនកម្មនេះទៅរដ្ឋភាគីនៃកតិកាសញ្ញានេះ ដោយសុំឱ្យរដ្ឋភាគីបញ្ជាក់ថាតើយល់ព្រមឱ្យមានសន្និសីទនៃរដ្ឋភាគីទាំងអស់ ដើម្បីពិនិត្យ និងបោះឆ្នោតលើសេចក្តីស្នើវិសោធនកម្មឬទេ ។ ក្នុងករណីមានសម្លេង១ភាគ៣យ៉ាងតិចនៃរដ្ឋភាគីទាំងអស់ ប្រកាសយល់ព្រមឱ្យមានសន្និសីទ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវកោះប្រជុំសន្និសីទ ក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ ។ គ្រប់វិសោធនកម្មដែលអនុម័តដោយមតិភាគច្រើននៃរដ្ឋភាគីវត្តមាន និងបោះឆ្នោតក្នុងសន្និសីទ ត្រូវដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិ ដើម្បីសុំការយល់ព្រម ។

២. វិសោធនកម្មទាំងនេះ នឹងចូលជាធរមាន នៅពេលទទួលបានការយល់ព្រមពីមហាសន្និបាតអង្គការសហប្រជាជាតិ និងទទួលបានការអនុម័តដោយមតិភាគច្រើន២ភាគ៣ នៃរដ្ឋភាគីនៃកតិកាសញ្ញានេះ ស្របតាមបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញរបស់រដ្ឋនីមួយៗ ។

៣. នៅពេលដែលវិសោធនកម្មទាំងនោះ ចូលជាធរមានហើយ វិសោធនកម្មទាំងនោះ នឹងក្លាយជាកាតព្វកិច្ចសម្រាប់រដ្ឋភាគី ដែលព្រមទទួលយកវិសោធនកម្មទាំងនោះ ឯរដ្ឋភាគីផ្សេងទៀតដែលមិនបានទទួលយល់ព្រម ត្រូវស្ថិតនៅក្រោមបទបញ្ញត្តិនៃកតិកាសញ្ញានេះ និងវិសោធនកម្មមុនៗ ដែលខ្លួនបានព្រមទទួលយករួចហើយ ។

## មាត្រា ៥២

ក្រៅពីការជូនដំណឹងទាំងឡាយដែលមានចែងនៅក្នុងកថាខណ្ឌ៥ នៃមាត្រា៤៨ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវជម្រាបជូនរដ្ឋទាំងឡាយ ស្របតាមកថាខណ្ឌ១ នៃមាត្រានេះនូវ :

(ក) ការចុះហត្ថលេខា ការឱ្យសច្ចាប័ន និងការសុំចូលជាសមាជិក យោងតាមមាត្រា៤៨ ។

(ខ) កាលបរិច្ឆេទនៃការចូលជាធរមាននៃកតិកាសញ្ញានេះ យោងតាមមាត្រា៤៩ និងកាលបរិច្ឆេទនៃការចូលជាធរមាននៃវិសោធនកម្មទាំងឡាយ យោងតាមមាត្រា៥១ ។

## មាត្រា ៥៣

១. កតិកាសញ្ញានេះដែលមានអត្ថបទជាភាសាចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ មានតម្លៃស្មើគ្នា និងត្រូវតំកល់ទុកនៅបណ្ណសារដ្ឋានរបស់អង្គការសហប្រជាជាតិ ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនច្បាប់ចម្លងនៃកតិកាសញ្ញានេះ ដោយមានបញ្ជាក់ការចម្លងតាមច្បាប់ដើម ជូនដល់រដ្ឋទាំងឡាយ យោងតាមមាត្រា៤៨ ។

# ៨-ឥ. ពិធីសារបន្ថែមទី១ លើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦
និងចូលជាធរមានថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦ ស្របតាមមាត្រា៩
កម្ពុជាបានចុះហត្ថលេខាលើពិធីសារបន្ថែមនេះ កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៤

*រដ្ឋភាគីនៃពិធីសារនេះ*

*យល់ឃើញថា* ដើម្បីធ្វើឱ្យប្រសើរឡើងទៀត នូវការសម្រេចទិសដៅនៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ពីនេះតទៅហៅត្រឹមថា កតិកាសញ្ញា)និងការអនុវត្តន៍បទបញ្ញត្តិនៃកតិកាសញ្ញា វាជាការសមស្របក្នុងការធ្វើឱ្យគណៈកម្មាធិការសិទ្ធិមនុស្ស ដែលបង្កើតឡើង ស្របតាមផ្នែកទី៤ នៃកតិកាសញ្ញា (ពីនេះតទៅហៅត្រឹមថា គណៈកម្មាធិការ) អាចទទួល និងពិនិត្យបណ្តឹងដូចចែងក្នុងពិធីសារនេះ ពីបុគ្គលទាំងឡាយដែលអះអាងថា ជាជនរងគ្រោះនៃការរំលោភសិទ្ធិណាមួយ ដូចចែងក្នុងកតិកាសញ្ញា ។

*បានព្រមព្រៀងគ្នាដូចតទៅ :*

## មាត្រា ១

រដ្ឋភាគីនៃកតិកាសញ្ញាដែលក្លាយជាភាគីនៃពិធីសារនេះ ទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការ ក្នុងការទទួល និងពិនិត្យបណ្តឹង ពីបុគ្គលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ដែលអះអាងថាជាជនរងគ្រោះនៃការរំលោភពីរដ្ឋភាគីនោះ ទៅលើសិទ្ធិណាមួយដូចចែងនៅក្នុងកតិកាសញ្ញា ។ គ្មានបណ្តឹងណាមួយត្រូវទទួលដោយគណៈកម្មាធិការទេ បើបណ្តឹងនោះទាក់ទងនឹងរដ្ឋភាគីនៃកតិកាសញ្ញា ដែលមិនមែនជាភាគីនៃពិធីសារនេះ ។

## មាត្រា ២

ស្របតាមបទបញ្ញត្តិនៃមាត្រា១ បុគ្គលទាំងឡាយដែលអះអាងថា សិទ្ធិណាមួយរបស់ពួកគេដូចបានរៀបរាប់នៅក្នុងកតិកាសញ្ញា ត្រូវរងការរំលោភ និងបានប្រើអស់នូវការដោះស្រាយ ដែលមាននៅក្នុងប្រទេស អាចដាក់បណ្តឹងជាលាយលក្ខណ៍អក្សរជូនគណៈកម្មាធិការដើម្បីពិនិត្យ ។

## មាត្រា ៣

គណៈកម្មាធិការ ត្រូវចាត់ទុកមិនអាចទទួលយកនូវរាល់បណ្តឹងក្រោមពិធីសារនេះដែលជាបណ្តឹងអនាមិក ឬដែលគណៈកម្មាធិការចាត់ទុកថា ជាការរំលោភសិទ្ធិដាក់ពាក្យបណ្តឹង ឬចាត់ទុកថាមានវិសមិតភាពនឹងបទបញ្ញត្តិនៃកតិកាសញ្ញា ។

## មាត្រា ៤

១. ពាក់ព័ន្ធនឹងបទបញ្ញត្តិនៃមាត្រា៣ គណៈកម្មាធិការត្រូវផ្ដល់ព័ត៌មានអំពីបណ្ដឹងណាមួយដែលដាក់ជូនខ្លួនស្របតាមពិធីសារនេះ ដល់រដ្ឋភាគីនៃពិធីសារនេះ ដែលជាប់ចោទពីការរំលោភបទបញ្ញត្តិណាមួយនៃកតិកាសញ្ញា ។

២. ក្នុងរយៈពេល៦ខែ រដ្ឋដែលទទួលព័ត៌មាននេះត្រូវដាក់ជូនគណៈកម្មាធិការនូវការពន្យល់ជាលាយលក្ខណ៍អក្សរ ឬសេចក្ដីថ្លែងការណ៍បំភ្លឺអំពីបញ្ហា និងការដោះស្រាយ ប្រសិនជាមាន ដែលរដ្ឋនោះអាចធ្វើ។

## មាត្រា ៥

១. គណៈកម្មាធិការ ត្រូវពិនិត្យបណ្ដឹងដែលទទួលបានស្របតាមពិធីសារនេះ ដោយយកមកគិតនូវរាល់ព័ត៌មានជាលាយលក្ខណ៍អក្សរ ដែលផ្ដល់មកឱ្យខ្លួនដោយបុគ្គល និងដោយរដ្ឋភាគីពាក់ព័ន្ធ ។

២. គណៈកម្មាធិការ មិនត្រូវពិនិត្យបណ្ដឹងណាមួយពីបុគ្គលណាម្នាក់ លើកលែងតែគណៈកម្មាធិការប្រាកដថា :

(ក) បញ្ហាដដែលនោះ មិនមានការពិនិត្យតាមនីតិវិធី នៃការស៊ើបអង្កេត ឬការដោះស្រាយអន្តរជាតិផ្សេងទៀត ។

(ខ) បុគ្គលនោះ បានប្រើអស់នូវការដោះស្រាយដែលមាននៅក្នុងប្រទេស ។ វិធាននេះ នឹងមិនត្រូវយកមកអនុវត្តទេ បើនីតិវិធីនៃការដោះស្រាយបន្ដយូរហួសហេតុ ។

៣. គណៈកម្មាធិការ ត្រូវរៀបចំសម័យប្រជុំរបស់ខ្លួនដោយសម្ងាត់ នៅពេលពិនិត្យបណ្ដឹងស្របតាមពិធីសារនេះ ។

៤. គណៈកម្មាធិការ ត្រូវបញ្ជូនការយល់ឃើញរបស់ខ្លួនទៅរដ្ឋភាគី និងបុគ្គលពាក់ព័ន្ធ ។

## មាត្រា ៦

គណៈកម្មាធិការ ត្រូវបញ្ចូលទៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន ស្របតាមមាត្រា៤៥ នៃកតិកាសញ្ញា នូវសេចក្ដីសង្ខេបនៃសកម្មភាពរបស់ខ្លួនក្រោមពិធីសារនេះ ។

## មាត្រា ៧

ទំរាំដល់ការសម្រេចបាននូវទិសដៅនៃសេចក្ដីសម្រេចចិត្តលេខ ១៥១៤ (XV) អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៦០ ស្ដីពីសេចក្ដីប្រកាសផ្ដល់ឯករាជ្យដល់ប្រទេស និងប្រជាជាតិក្រោមអាណានិគម បទបញ្ញត្តិនៃពិធីសារនេះ ជាដាច់ខាតមិនអាចកម្រិតសិទ្ធិប្ដឹងទាមទារដែលផ្ដល់ឱ្យដល់ប្រជាជាតិទាំងនេះ ដោយធម្មនុញ្ញសហប្រជាជាតិ និងអនុសញ្ញានិងលិខិតុបករណ៍អន្តរជាតិផ្សេងទៀតក្រោមអង្គការសហប្រជាជាតិ និងស្ថាប័នឯកទេសរបស់អង្គការសហប្រជាជាតិឡើយ ។

## មាត្រា ៨

១. ពិធីសារនេះ បើកចំហឱ្យរដ្ឋហត្ថលេខីនៃកតិកាសញ្ញាចុះហត្ថលេខា ។

២. ពិធីសារនេះ ត្រូវជាកម្មវត្ថុនៃការឱ្យសច្ចាប័នដោយរដ្ឋ ដែលបានឱ្យសច្ចាប័ន ឬបានចូលជាសមាជិកនៃកតិកាសញ្ញា ។ លិខិតុបករណ៍ឱ្យសច្ចាប័ន ត្រូវតំកល់ទុកនៅនឹង អគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៣. ពិធីសារនេះ ត្រូវបើកឱ្យចូលជាសមាជិកដោយរដ្ឋដែលបានឱ្យសច្ចាប័ន ឬបានចូលជាសមាជិកនៃកតិកាសញ្ញា ។

៤. ការសុំចូលជាសមាជិក មានអនុភាព ដោយការដាក់តំកល់លិខិតុបករណ៍សុំចូលជាសមាជិកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៥. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវផ្ដល់ព័ត៌មានដល់រដ្ឋហត្ថលេខីនៃពិធីសារនេះ ឬរដ្ឋសមាជិកនៃពិធីសារនេះ អំពីការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬចូលជាសមាជិក ។

## មាត្រា ៩

១. ស្របតាមការចូលជាធរមាននៃកតិកាសញ្ញា ពិធីសារនេះត្រូវចូលជាធរមានក្នុងរយៈពេល៣ខែ បន្ទាប់ពីកាលបរិច្ឆេទ នៃការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬចូលជាសមាជិកទី១០ នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

២. ចំពោះរដ្ឋនីមួយៗ ដែលឱ្យសច្ចាប័នលើពិធីសារនេះ ឬចូលជាសមាជិកនៃពិធីសារនេះ បន្ទាប់ពីការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬលិខិតុបករណ៍ចូលជាសមាជិកទី១០ ពិធីសារនេះ ត្រូវចូលជាធរមានក្នុងរយៈពេល៣ខែ បន្ទាប់ពីកាលបរិច្ឆេទដែលរដ្ឋនីមួយៗ ដាក់តំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬលិខិតុបករណ៍ចូលជាសមាជិករបស់ខ្លួន ។

## មាត្រា ១០

បទបញ្ញត្តិទាំងឡាយនៃពិធីសារនេះ ត្រូវអនុវត្តលើគ្រប់ផ្នែកនៃរដ្ឋសហព័ន្ធ ដោយគ្មានការដាក់កម្រិតព្រំដែន ឬការលើកលែងឡើយ ។

## មាត្រា ១១

១. រដ្ឋភាគីនៃពិធីសារនេះ អាចស្នើសុំធ្វើវិសោធនកម្ម និងបញ្ជូនសេចក្ដីស្នើសុំធ្វើវិសោធនកម្មនេះជូនទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ នៅពេលនោះ អគ្គលេខាធិការត្រូវបញ្ជូនសេចក្ដីស្នើសុំធ្វើវិសោធនកម្ម ជូនទៅរដ្ឋភាគីនៃពិធីសារនេះ ដោយសុំឱ្យរដ្ឋភាគីបញ្ជាក់ថា តើយល់ព្រមឱ្យមានសន្និសីទនៃរដ្ឋភាគីទាំងអស់ ដើម្បីពិនិត្យ និងបោះឆ្នោតលើសេចក្ដីស្នើសុំធ្វើវិសោធនកម្មឬទេ ។ ក្នុងករណីមាន

សម្លេង១ភាគ៣ យ៉ាងតិចនៃរដ្ឋភាគីទាំងអស់ ប្រកាសយល់ព្រមឱ្យមានសន្និសីទ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវកោះប្រជុំសន្និសីទក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ ។ គ្រប់វិសោធនកម្ម ដែលអនុម័តដោយមតិភាគច្រើននៃរដ្ឋភាគីវត្តមាន និងបោះឆ្នោតក្នុងសន្និសីទ ត្រូវដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិ ដើម្បីសុំការយល់ព្រម ។

២. វិសោធនកម្មទាំងនេះ នឹងចូលជាធរមាន នៅពេលទទួលបានការយល់ព្រមពីមហាសន្និបាតអង្គការសហប្រជាជាតិ និងទទួលបានការអនុម័តដោយមតិភាគច្រើន២ភាគ៣ នៃរដ្ឋភាគីនៃពិធីសារនេះ ស្របតាមបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញរបស់រដ្ឋនីមួយៗ ។

៣. នៅពេលវិសោធនកម្មទាំងនោះ ចូលជាធរមានហើយ វិសោធនកម្មទាំងនោះនឹងក្លាយជាកាតព្វកិច្ចសម្រាប់រដ្ឋភាគី ដែលព្រមទទួលយកវិសោធនកម្មទាំងនោះ រីឯរដ្ឋភាគីផ្សេងទៀត ដែលមិនបានទទួលយល់ព្រម ត្រូវស្ថិតនៅក្រោមបទបញ្ញត្តិនៃកតិកាសញ្ញានេះ និងវិសោធនកម្មមុនៗ ដែលខ្លួនបានព្រមទទួលយករួចហើយ ។

## មាត្រា ១២

១. រដ្ឋភាគី អាចប្រកាសដកខ្លួនចេញពីពិធីសារនេះបានគ្រប់ពេល ដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ការប្រកាសដកខ្លួននេះចូលជាធរមានក្នុងរយៈពេល៣ខែ បន្ទាប់ពីកាលបរិច្ឆេទ ដែលអគ្គលេខាធិការទទួលការជូនដំណឹង ។

២. ការប្រកាសដកខ្លួន មិនប៉ះពាល់ដល់ការបន្តអនុវត្តបទបញ្ញត្តិនៃពិធីសារនេះ លើបណ្តឹងដែលដាក់ជូនស្របតាមមាត្រា២ មុនកាលបរិច្ឆេទចូលជាធរមាននៃការប្រកាសដកខ្លួនឡើយ ។

## មាត្រា ១៣

ដោយមិនគិតដល់ការជូនដំណឹង ដែលធ្វើឡើងស្របតាមមាត្រា៨ កថាខណ្ឌ៥ នៃពិធីសារនេះ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវជូនដំណឹងដល់រដ្ឋទាំងអស់ ដូចមានចែងក្នុងមាត្រា៤៨កថាខណ្ឌ១ នៃកតិកាសញ្ញា អំពីព័ត៌មានលំអិតខាងក្រោម :

(ក) ហត្ថលេខា ការឱ្យសច្ចាប័ន និងការចូលជាសមាជិក ស្រមតាមមាត្រា៨ ។

(ខ) កាលបរិច្ឆេទនៃការចូលជាធរមាននៃពិធីសារនេះ ស្របតាមមាត្រា៩ និងកាលបរិច្ឆេទនៃការចូលជាធរមាននៃវិសោធនកម្ម ស្របតាមមាត្រា១១ ។

(គ) ការប្រកាសដកខ្លួន ស្របតាមមាត្រា១២ ។

## មាត្រា ១៤

១. ពិធីសារនេះដែលមានអត្ថបទជាភាសាចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ មានតម្លៃស្មើគ្នា ត្រូវតំកល់ទុកនៅបណ្ណសារដ្ឋាននៃអង្គការសហប្រជាជាតិ ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនច្បាប់ចម្លងនៃកតិកាសញ្ញានេះដោយមានបញ្ជាក់ការចម្លងតាមច្បាប់ដើម ទៅរដ្ឋទាំងឡាយដែលមានយោងក្នុងមាត្រា៤៨ នៃកតិកាសញ្ញា ។

## ៨-ខ. ពិធីសារបន្ថែមទីពីរ លើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សំដៅលុបបំបាត់ទោសប្រហារជីវិត

ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិកាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៨៩
និងចូលជាធរមានកាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៩១
កម្ពុជាមិនទាន់ទាំងបានចុះហត្ថលេខានៅឡើយផង

*រដ្ឋភាគីនៃពិធីសារនេះ*

*ជឿថា* ការលុបបំបាត់ទោសប្រហារជីវិត នាំឱ្យសេចក្តីថ្លៃថ្នូររបស់មនុស្ស កាន់តែប្រសើរឡើង និងនាំឱ្យសិទ្ធិមនុស្ស មានការអភិវឌ្ឍន៍ជាលំដាប់ ។

*រំលឹកឡើងវិញ* នូវមាត្រា៣ នៃសេចក្តីប្រកាសជាសកល ស្តីពីសិទ្ធិមនុស្ស ដែលអនុម័តនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ និងមាត្រា៦ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលអនុម័តនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ។

*កត់សំគាល់ថា* មាត្រា៦ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បាននិយាយយោងអំពីការលុបបំបាត់ទោសប្រហារជីវិត ដោយពាក្យសំដីសង្កត់ធ្ងន់លើការប៉ងប្រាថ្នា ឱ្យមានការលប់ចោលនេះ ។

*ជឿជាក់ថា* រាល់វិធានការលុបបំបាត់ទោសប្រហារជីវិត ត្រូវចាត់ទុកថាជាការរីកចម្រើននៃការអាស្រ័យផលនៃសិទ្ធិរស់រានមានជីវិត ។

*មានបំណងយ៉ាងខ្លាំង* ធ្វើការសន្យាជាអន្តរជាតិតាមរយៈនេះ ដើម្បីលុបបំបាត់ទោសប្រហារជីវិត។

*បានព្រមព្រៀងគ្នាដូចតទៅ :*

### មាត្រា ១

១. គ្មានជនណាម្នាក់ ស្ថិតក្រោមដែនសមត្ថកិច្ចរដ្ឋភាគីនៃពិធីសារនេះ ត្រូវប្រហារជីវិតឡើយ ។

២. រដ្ឋភាគីនីមួយៗ ត្រូវចាត់រាល់វិធានការចាំបាច់ ដើម្បីលុបបំបាត់ទោសប្រហារជីវិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

### មាត្រា ២

១. ពិធីសារនេះ មិនអនុញ្ញាតឱ្យមានលក្ខខណ្ឌណាមួយឡើយ លើកលែងតែលក្ខខណ្ឌលើកឡើងនៅពេលឱ្យសច្ចាប័ន ឬចូលជាសមាជិក ដែលមានចែងអំពីការដាក់ទោសប្រហារជីវិតក្នុងពេលមានសង្គ្រាមចំពោះទោសឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតខាងយោធា ដែលប្រព្រឹត្តឡើងក្នុងពេលមានសង្គ្រាម ។

២. រដ្ឋភាគីដែលស្នើលក្ខខណ្ឌបែបនេះនៅពេលឱ្យសច្ចាប័នឬចូលជាសមាជិកត្រូវផ្ញើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ នូវបទបញ្ញត្តិពាក់ព័ន្ធក្នុងច្បាប់ជាតិរបស់ខ្លួនដែលអនុវត្តក្នុងពេលសង្គ្រាម ។

៣. រដ្ឋភាគីដែលដាក់លក្ខខណ្ឌបែបនេះ ត្រូវជំរាបជូនអគ្គលេខាធិការអង្គការសហប្រជាជាតិអំពីការចាប់ផ្តើម និងការបញ្ចប់ស្ថានភាពសង្គ្រាមនៅលើទឹកដីរបស់ខ្លួន ។

## មាត្រា ៣

រដ្ឋភាគីនៃពិធីសារនេះ ត្រូវបញ្ចូលទៅក្នុងរបាយការណ៍ ដែលដាក់ជូនគណៈកម្មាធិការសិទ្ធិមនុស្សស្របតាមមាត្រា៤០ នៃកតិកាសញ្ញា នូវព័ត៌មានស្តីពីវិធានការដែលខ្លួនបានអនុម័ត ដើម្បីផ្តល់អនុភាពដល់ពិធីសារនេះ ។

## មាត្រា ៤

ចំពោះរដ្ឋភាគីនៃកតិកាសញ្ញា ដែលបានធ្វើសេចក្តីថ្លែងការណ៍ស្របតាមមាត្រា៤១ សមត្ថកិច្ចគណៈកម្មាធិការសិទ្ធិមនុស្សក្នុងការទទួល និងពិនិត្យបណ្តឹង ត្រូវពង្រីកដល់បទបញ្ញត្តិ នៃពិធីសារនេះ នៅពេលរដ្ឋភាគីមួយអះអាងថា រដ្ឋភាគីមួយទៀតមិនបំពេញកាតព្វកិច្ចរបស់ខ្លួន លើកលែងតែរដ្ឋភាគីពាក់ព័ន្ធបានធ្វើសេចក្តីថ្លែងការណ៍ផ្ទុយ នៅពេលឱ្យសច្ចាប័ន ឬចូលជាសមាជិក ។

## មាត្រា ៥

ចំពោះរដ្ឋភាគីនៃពិធីសារបន្ថែមទី១លើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលអនុម័តនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ សមត្ថកិច្ចរបស់គណៈកម្មាធិការសិទ្ធិមនុស្ស ក្នុងការទទួលនិងពិនិត្យបណ្តឹងពីបុគ្គល ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់រដ្ឋភាគី ត្រូវពង្រីកដល់បទបញ្ញត្តិនៃពិធីសារនេះ លើកលែងតែរដ្ឋភាគីពាក់ព័ន្ធបានធ្វើសេចក្តីថ្លែងការណ៍ផ្ទុយ នៅពេលផ្តល់សច្ចាប័នឬចូលជាសមាជិក។

## មាត្រា ៦

១. បទបញ្ញត្តិនៃពិធីសារនេះ ត្រូវអនុវត្តជាបទបញ្ញត្តិបន្ថែមលើកតិកាសញ្ញា ។

២. ដោយមិនធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពនៃការដាក់លក្ខខណ្ឌស្របតាមមាត្រា២ នៃពិធីសារនេះ សិទ្ធិដែលធានាក្នុងមាត្រា១ កថាខណ្ឌ១ នៃពិធីសារនេះ មិនត្រូវជាកម្មវត្ថុនៃការធ្វើបដិប្បញ្ញត្តិណាមួយក្រោមមាត្រា៤ នៃកតិកាសញ្ញាឡើយ ។

## មាត្រា ៧

១. ពិធីសារនេះ ត្រូវបើកចំហឱ្យរដ្ឋហត្ថលេខីនៃកតិកាសញ្ញា ចុះហត្ថលេខា ។

២. ពិធីសារនេះ គឺជាកម្មវត្ថុនៃការឱ្យសច្ចាប័នដោយរដ្ឋ ដែលបានឱ្យសច្ចាប័នដល់កតិកាសញ្ញា ឬបានចូលជាសមាជិកនៃកតិកាសញ្ញា ។ លិខិតុបករណ៍ឱ្យសច្ចាប័ន ត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៣. ពិធីសារនេះ ត្រូវបើកឱ្យចូលជាសមាជិកដោយរដ្ឋ ដែលបានឱ្យសច្ចាប័នដល់កតិកាសញ្ញា ឬបានចូលជាសមាជិកនៃកតិកាសញ្ញា ។

៤. ការចូលជាសមាជិក ត្រូវធ្វើតាមរយៈការតំកល់លិខិតុបករណ៍ចូលជាសមាជិក នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៥. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវជូនព័ត៌មានទៅរដ្ឋទាំងអស់ដែលចុះហត្ថលេខាលើពិធីសារនេះ ឬចូលជាសមាជិកនៃពិធីសារនេះ អំពីការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬការចូលជាសមាជិក ។

## មាត្រា ៨

១. ពិធីសារនេះ ត្រូវចូលជាធរមានក្នុងរយៈពេល៣ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការតំកល់ទុកលិខិតុបករណ៍ឱ្យសច្ចាប័ន និងចូលជាសមាជិកទី១០ នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

២. ចំពោះរដ្ឋនីមួយៗ ដែលឱ្យសច្ចាប័នដល់ពិធីសារនេះ ឬចូលជាសមាជិកនៃពិធីសារនេះ បន្ទាប់ពីការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬលិខិតុបករណ៍ចូលជាសមាជិកទី១០នៃពិធីសារនេះ ត្រូវចូលជាធរមាន ក្នុងរយៈពេល៣ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬលិខិតុបករណ៍ចូលជាសមាជិករបស់ខ្លួន ។

## មាត្រា ៩

បទបញ្ញត្តិនៃពិធីសារនេះ ត្រូវអនុវត្តលើគ្រប់ផ្នែកនៃរដ្ឋសហព័ន្ធ ដោយគ្មានការដាក់កម្រិតព្រំដែន ឬការលើកលែងឡើយ ។

## មាត្រា ១០

អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវជូនដំណឹងទៅរដ្ឋទាំងអស់ ដូចចែងក្នុងមាត្រា៤៨ កថាខណ្ឌ១ នៃកតិកាសញ្ញា នូវព័ត៌មានលំអិតខាងក្រោម :

(ក) លក្ខខណ្ឌ បណ្តឹង និងការជូនដំណឹង ស្របតាមមាត្រា២ នៃពិធីសារនេះ ។

(ខ) សេចក្តីថ្លែងការណ៍ដែលធ្វើស្របតាមមាត្រា៤ ឬ៥ នៃពិធីសារនេះ ។

(គ) ការចុះហត្ថលេខា ការឱ្យសច្ចាប័ន និងការចូលជាសមាជិក ស្របតាមមាត្រា៧ នៃពិធីសារនេះ ។

(ឃ) កាលបរិច្ឆេទនៃការចូលជាធរមាននៃពិធីសារនេះ ស្របតាមមាត្រា៨ ។

## មាត្រា ១១

១. ពិធីសារនេះដែលមានអត្ថបទជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ មានតម្លៃស្មើគ្នា ត្រូវតំកល់ទុកក្នុងបណ្ណសារដ្ឋាននៃអង្គការសហប្រជាជាតិ ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនច្បាប់ចម្លងនៃកតិកាសញ្ញានេះ ដោយមានបញ្ជាក់ការចម្លងតាមច្បាប់ដើម ទៅរដ្ឋទាំងឡាយដែលមានយោងក្នុងមាត្រា៤៨ នៃកតិកាសញ្ញា ។

# អនុសញ្ញាអន្តរជាតិ
# ស្តីពី
# ការបំបាត់រាល់ទម្រង់ នៃ
# ការរើសអើងពូជសាសន៍

# ៩- អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍

ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ កាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៦៥
និងចូលជាធរមាននៅថ្ងៃទី៤ ខែមករា ឆ្នាំ១៩៦៩ ស្របតាមបទបញ្ញត្តិនៃមាត្រា១៩
កម្ពុជាក្លាយជារដ្ឋភាគី នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៨៣

*រដ្ឋភាគីនៃអនុសញ្ញានេះ*

*យល់ឃើញថា* ធម្មនុញ្ញសហប្រជាជាតិ ផ្អែកលើគោលការណ៍នៃសេចក្តីថ្លៃថ្នូរ និងសមភាពដែលជាប់ពីកំណើតមនុស្សគ្រប់រូប *និងថា* រដ្ឋភាគីទាំងអស់បានសន្យាចាត់វិធានការរួមគ្នា និងដោយឡែកពីគ្នា ដោយសហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិ ដើម្បីសម្រេចទិសដៅមួយរបស់សហប្រជាជាតិក្នុងការលើកស្ទួយ និងជំរុញឱ្យមានការគោរព និងការអនុវត្តន៍ជាសកលនូវសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានសម្រាប់ទាំងអស់គ្នា ដោយគ្មានការប្រកាន់បែងចែក មានជាអាទិ៍ ពូជសាសន៍ ភេទ ភាសា ឬសាសនា ។

*យល់ឃើញថា* សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ប្រកាសថា មនុស្សគ្រប់រូបកើតមកមានសេរីភាព និងស្មើភាពខាងសេចក្តីថ្លៃថ្នូរ និងសិទ្ធិ និងថា ជនគ្រប់រូបមានសិទ្ធិ និងសេរីភាពទាំងអស់ដែលមានចែងក្នុងសេចក្តីប្រកាស ដោយគ្មានការប្រកាន់បែងចែកណាមួយ ពិសេសខាង ពូជសាសន៍ ពណ៌សម្បុរ ឬដើមកំណើតជាតិ ។

*យល់ឃើញថា* មនុស្សជាតិគ្រប់រូបមានភាពស្មើគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិទទួលការការពារដោយច្បាប់ដូចគ្នាប្រឆាំងនឹងការរើសអើង និងការញុះញង់ទាំងឡាយណាដែលនាំឱ្យមានការរើសអើង ។

*យល់ឃើញថា* សហប្រជាជាតិបានផ្តន្ទាទោសអាណានិគមនិយម និងការអនុវត្តន៍ការផាត់ចេញ និងការរើសអើងអមជាមួយ ទោះតាមទម្រង់និងមាននៅទីណាក៏ដោយ និង*យល់ឃើញថា* សេចក្តីប្រកាសនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៦០ ស្តីពីការផ្តល់ឯករាជ្យដល់ប្រទេស និងប្រជាពលរដ្ឋស្ថិតក្រោមអាណានិគម (សេចក្តីសម្រេចចិត្តរបស់មហាសន្និបាតលេខ១៥១៤(XV)) បានអះអាង និងប្រកាសយ៉ាងឧឡារិក ពីភាពចាំបាច់នៃការនាំយកបញ្ហាទាំងនេះ ទៅកាន់ទីបញ្ចប់យ៉ាងឆាប់ និងដោយឥតល័ក្ខខ័ណ្ឌ ។

*យល់ឃើញថា* សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិ ស្តីអំពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៦៣ (សេចក្តីសម្រេចចិត្តរបស់មហាសន្និបាតលេខ១៩០៤ (XVIII)) អះអាងយ៉ាងឧឡារិកអំពីភាពចាំបាច់នៃការបំបាត់ឱ្យបានឆាប់ នូវរាល់ទម្រង់និងរាល់ការសម្តែងការរើសអើងពូជសាសន៍ទូទាំងពិភពលោក និងធានាឱ្យមានការយល់ដឹង និងការគោរពដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ។

*ជឿជាក់ថា* រាល់លទ្ធិនៃឧត្តមភាពដែលផ្អែកលើការបែងចែកពូជសាសន៍ គឺខុសឆ្គងខាងវិទ្យាសាស្ត្រ អាចត្រូវផ្តន្ទាទោសខាងសីលធម៌ នាំឱ្យមានអយុត្តិធម៌ និងគ្រោះថ្នាក់ដល់សង្គម និង *ជឿជាក់ថា* ពុំមានយុត្តិកម្មសម្រាប់ការរើសអើងពូជសាសន៍ ក្នុងទ្រឹស្តី ឬការអនុវត្តន៍ឡើយ ។

*អះអាងជាថ្មីថា* ការរើសអើងរវាងមនុស្សនិងមនុស្ស ផ្អែកលើពូជសាសន៍ ពណ៌សម្បុរ ឬដើមកំណើតជាតិ គឺជាឧបសគ្គដល់ការទាក់ទងជាមិត្តភាព និងសន្តិភាព រវាងប្រជាជាតិនានា និងអាចរំខានដល់សន្តិភាព និងសន្តិសុខរវាងប្រជាជាតិ និងភាពចុះសម្រុងគ្នា រវាងមនុស្សរស់នៅក្នុងរដ្ឋជាមួយគ្នា ។

*ជឿជាក់ថា* អត្ថិភាពនៃរបាំងពូជសាសន៍ មិនអាចចុះសម្រុងជាមួយនឹងឧត្តមគតិនៃសង្គមមនុស្សបានឡើយ ។

*ភ្ញាក់ផ្អើល* ចំពោះការសម្តែងការរើសអើងពូជសាសន៍ នៅមានជាភស្តុតាងក្នុងតំបន់ខ្លះនៃពិភពលោក និងចំពោះនយោបាយរបស់រដ្ឋាភិបាល ដែលឈរលើឧត្តមភាពខាងពូជសាសន៍ ឬការស្អប់ខ្ពើមខាងពូជសាសន៍ ដូចជានយោបាយ *អាប៉ាថេត* ការផាត់ចេញ ឬការបែងចែក។

*ប្តេជ្ញាចិត្ត* អនុម័តយកវិធានការចាំបាច់ទាំងអស់ ដើម្បីបំបាត់ឱ្យបានឆាប់ នូវរាល់ទម្រង់ និងរាល់ការសម្តែងការរើសអើងពូជសាសន៍ និងទប់ស្កាត់ និងប្រយុទ្ធប្រឆាំងទ្រឹស្តី និងការអនុវត្តន៍បែបពូជសាសន៍និយម ដើម្បីបង្កការយោគយល់រវាងពូជសាសន៍និងពូជសាសន៍ និងស្ថាបនាសហគមន៍អន្តរជាតិមួយរួចផុតពីគ្រប់ទម្រង់នៃការផាត់ចេញ និងការរើសអើងពូជសាសន៍ ។

*ចងចាំនូវ* អនុសញ្ញាស្តីពីការរើសអើងក្នុងការជួលឱ្យធ្វើការ និងការប្រកបមុខរបរ អនុម័តដោយអង្គការពលកម្មអន្តរជាតិក្នុងឆ្នាំ១៩៥៨ និងអនុសញ្ញាប្រឆាំងនឹងការរើសអើងក្នុងវិស័យអប់រំ អនុម័តដោយអង្គការសម្រាប់ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ក្នុងឆ្នាំ១៩៦០ ។

*ប្រាថ្នា* អនុវត្តគោលការណ៍នានា ដែលចែងក្នុងសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ និងធានាអនុម័តយ៉ាងឆាប់បំផុត នូវវិធានការអនុវត្តន៍សម្រាប់ទិសដៅនេះ ។

*បានព្រមព្រៀងគ្នាដូចតទៅ :*

### ផ្នែកទី ១

### មាត្រា ១

១. ក្នុងអនុសញ្ញានេះ ពាក្យ "ការរើសអើងពូជសាសន៍" មានន័យថា ការប្រកាន់បែងចែក ការផាត់ចេញ ការរឹតត្បិត ឬការនិយម ផ្អែកលើពូជសាសន៍ ពណ៌សម្បុរ បុព្វញាតិ ឬដើមកំណើតជាតិ ឬជាតិពន្ធ ដែលមានទិសដៅ ឬអានុភាពបំផ្លាញ ឬបន្ថយការទទួលស្គាល់ ការមាន ឬការប្រើប្រាស់ក្នុងល័ក្ខខ័ណ្ឌសមភាព នូវសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ខាងវិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ឬវិស័យដទៃទៀតនៃជីវភាពសាធារណៈ ។

២. អនុសញ្ញានេះ មិនអនុវត្តទៅលើការបែងចែក ការផាត់ចេញ ការរឹតត្បិត ឬការនិយមរវាងប្រជាពលរដ្ឋខ្លួន និងមិនមែនជាប្រជាពលរដ្ឋខ្លួន ដែលធ្វើឡើងដោយរដ្ឋភាគីនៃអនុសញ្ញានេះឡើយ ។

៣. គ្មានបទបញ្ញត្តិណាមួយនៃអនុសញ្ញានេះ អាចត្រូវបានបកស្រាយ ទោះតាមវិធីណាក៏ដោយ ថាប៉ះពាល់ដល់បទបញ្ញត្តិច្បាប់របស់រដ្ឋភាគីនៃអនុសញ្ញានេះ ស្តីពីសញ្ជាតិ ភាពជាប្រជាពលរដ្ឋ ឬការចូលសញ្ជាតិ ឱ្យតែបទបញ្ញត្តិច្បាប់ទាំងនោះ មិនរើសអើងចំពោះសញ្ជាតិពិសេសណាមួយ ។

៤. វិធានការពិសេសនានាដែលបានធ្វើឡើងក្នុងគោលបំណងធានាតែម្យ៉ាងគត់ដល់ការរីកចម្រើនសមស្របរបស់ក្រុម ឬបុគ្គលជនជាតិ ឬពូជសាសន៍ខ្លះ ដែលត្រូវការនូវការការពារជាចាំបាច់ ដើម្បីធានាឱ្យក្រុម ឬបុគ្គលទាំងនោះ បានទទួល ឬប្រើប្រាស់សិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ក្នុងលក្ខខណ្ឌស្មើភាព ដោយមិនត្រូវចាត់ទុកជាវិធានការរើសអើងពូជសាសន៍ឡើយ ឱ្យតែវិធានការទាំងនោះ មិនបង្កឱ្យមានការរក្សាសិទ្ធិដាច់ដោយឡែក សម្រាប់ក្រុមពូជសាសន៍ផ្សេងគ្នា និងឱ្យតែវិធានការទាំងនោះ មិនត្រូវបានបន្តធ្វើបន្ទាប់ពីទិសដៅនៃវិធានការត្រូវបានសម្រេចហើយ ។

## មាត្រា ២

១. រដ្ឋភាគី ផ្តន្ទាទោសការរើសអើងពូជសាសន៍ និងសន្យាធ្វើតាមគ្រប់វិធីសមស្រប និងដោយមិនពន្យារពេល នូវនយោបាយលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ និងបង្កការយោគយល់រវាងពូជសាសន៍ទាំងអស់ ហើយដើម្បីសំរេចទិសដៅនេះ :

(ក) រដ្ឋភាគីនីមួយៗ សន្យាមិនធ្វើអំពើ ឬការអនុវត្តណ៍ណាមួយនៃការរើសអើងពូជសាសន៍ប្រឆាំងនឹងមនុស្ស ក្រុមមនុស្ស ឬស្ថាប័ន និងធានាថា អាជ្ញាធរ និងស្ថាប័នសាធារណៈទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ធ្វើស្របតាមកាតព្វកិច្ចនេះ ។

(ខ) រដ្ឋភាគីនីមួយៗ សន្យាមិនលើកទឹកចិត្ត ការពារ ឬគាំទ្រដល់ការរើសអើងពូជសាសន៍ ដែលធ្វើដោយមនុស្សម្នាក់ ឬអង្គការណាមួយឡើយ ។

(គ) រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការស័ក្តិសិទ្ធិ ដើម្បីពិនិត្យឡើងវិញ នូវនយោបាយរបស់រដ្ឋាភិបាល ទាំងថ្នាក់ជាតិ និងមូលដ្ឋាន និងដើម្បីកែប្រែ និរាករណ៍ ឬដាក់ឱ្យមោឃៈនូវច្បាប់ និងបទបញ្ញត្តិណាដែលមានអានុភាពបង្កើត ឬបន្តការរើសអើងពូជសាសន៍ ទោះមាននៅទីណាក៏ដោយ ។

(ឃ) រដ្ឋភាគីនីមួយៗ តាមគ្រប់មធ្យោបាយសមស្រប រួមមាន វិធានការខាងផ្លូវច្បាប់ផង តាមដែលស្ថានភាពតម្រូវ ត្រូវហាមឃាត់ និងបញ្ចប់ការរើសអើងពូជសាសន៍ ដែលធ្វើដោយមនុស្ស ក្រុមមនុស្ស ឬអង្គការណាក៏ដោយ ។

(ង) រដ្ឋភាគីនីមួយៗ សន្យា បង្កលក្ខណៈតាមករណីសមស្រប ឱ្យមានអង្គការ និងចលនាសមាហរណកម្មពហុពូជសាសន៍ និងមធ្យោបាយដទៃទៀត សម្រាប់ការលុបបំបាត់របាំងរវាងពូជសាសន៍ និងបន្ទុចបង្អាក់អ្វីដែលមានទំនោរពង្រឹងការបែងចែកពូជសាសន៍ ។

២. រដ្ឋភាគី បើកាលៈទេសៈតម្រូវ ក្នុងវិស័យសង្គមកិច្ច សេដ្ឋកិច្ច វប្បធម៌ និងវិស័យដទៃទៀត ត្រូវចាត់វិធានការពិសេស និងជាក់ស្តែង ដើម្បីធានា ការអភិវឌ្ឍន៍ និងការការពារគ្រប់គ្រាន់ដល់ក្រុមពូជសាសន៍ខ្លះ ឬបុគ្គលក្នុងក្រុមទាំងនោះ ក្នុងគោលបំណងធានាឱ្យពួកគេ ទទួលបានពេញលេញ និងស្មើភាព នូវសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ។ វិធានការទាំងនេះ ទោះក្នុងករណីណាក៏ដោយ មិនតម្រូវឱ្យរក្សាទុកសិទ្ធិមិនស្មើភាព និងដាច់ដោយឡែក សម្រាប់ក្រុមពូជសាសន៍ផ្សេងគ្នា បន្ទាប់ពីទិសដៅនៃវិធានការ ត្រូវបានសម្រេចហើយ ។

មាត្រា ៣

រដ្ឋភាគី ផ្តន្ទាទោសជាពិសេសដល់ការផាត់ចេញខាងពូជសាសន៍ និងអាផាថេត និងសន្យាបង្ការ ហាមឃាត់ និងលុបបំបាត់ការអនុវត្តន៍ប្រភេទនេះ លើទឹកដីដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ។

មាត្រា ៤

រដ្ឋភាគីផ្តន្ទាទោសការឃោសនាទាំងអស់ និងអង្គការទាំងអស់ដែលយកគំនិត ឬទ្រឹស្តីផ្អែកលើឧត្តមភាពពូជសាសន៍មួយ ឬក្រុមមួយនៃមនុស្សដែលមានពណ៌សម្បុរមួយ ឬដើមកំណើត ជនជាតិមួយ ឬដែលប៉ុនប៉ងការពារ ឬលើកស្ទួយការស្អប់ខ្ពើម និងការរើសអើងពូជសាសន៍ក្នុងទម្រង់ណាមួយ ។ រដ្ឋភាគីសន្យាអនុម័តជាបន្ទាន់នូវវិធានការជាវិជ្ជមាន សំដៅលុបបំបាត់រាល់ការញុះញង់ ឬរាល់អំពើឱ្យមានការរើសអើងពូជសាសន៍ ហើយដើម្បីទិសដៅនេះ ត្រូវឈរលើគោលការណ៍ ដែលបានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងសិទ្ធិដែលមានចែងច្បាស់លាស់ក្នុងមាត្រា៥ នៃអនុសញ្ញានេះ ។ រដ្ឋភាគី សន្យាជាពិសេស :

(ក) ប្រកាសពីបទល្មើសដែលត្រូវផ្តន្ទាទោសដោយច្បាប់ ការសាបព្រោះផ្សព្វផ្សាយទាំងអស់នូវគំនិតទាំងឡាយដែលផ្អែកលើឧត្តមភាព ឬការស្អប់ខ្ពើម ការញុះញង់ទាំងអស់ ដែលនាំឱ្យមានការរើសអើងពូជសាសន៍ ក៏ដូចជារាល់អំពើហិង្សា ឬការញុះញុងឱ្យមានអំពើបែបនេះ ប្រឆាំងពូជសាសន៍ ឬក្រុមមនុស្សណាមួយ ដែលមានពណ៌សម្បុរផ្សេង ឬដើមកំណើតជាតិផ្សេង និងការជួយដល់សកម្មភាពខាងពូជសាសន៍និយម រួមមានហិរញ្ញប្បទានផង ។

(ខ) ប្រកាសថាខុសច្បាប់ និងហាមឃាត់អង្គការ សកម្មភាពមានការចាត់តាំង និងរាល់សកម្មភាពឃោសនា ដែលលើកស្ទួយ និងញុះញង់ឱ្យមាន ការរើសអើងពូជសាសន៍ និងប្រកាសថាការចូលរួមជាមួយអង្គការ ឬសកម្មភាពបែបនេះ គឺជាបទល្មើសដែលត្រូវផ្តន្ទាទោសដោយច្បាប់ ។

(គ) មិនអនុញ្ញាតឱ្យអាជ្ញាធរ ឬស្ថាប័នសាធារណៈទាំងថ្នាក់ជាតិ ឬថ្នាក់មូលដ្ឋាន លើកស្ទួយ ឬញុះញង់ឱ្យមានការរើសអើងពូជសាសន៍ ។

## មាត្រា ៥

ស្របតាមកាតព្វកិច្ចជាមូលដ្ឋានដែលបានចែងក្នុងមាត្រា២ នៃអនុសញ្ញានេះ រដ្ឋភាគីសន្យាហាមឃាត់ និងលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ និងសន្យាធានាឱ្យមនុស្សម្នាក់ៗ មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ដោយគ្មានការប្រកាន់បែងចែក មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ឬដើមកំណើតជាតិ ឬជនជាតិ ជាពិសេសក្នុងការអាស្រ័យផលសិទ្ធិដូចខាងក្រោម :

(ក) សិទ្ធិទទួលបានការប្រព្រឹត្តិមកលើខ្លួនស្មើគ្នាចំពោះមុខសាលាជំរះក្តី និងស្ថាប័នទាំងឡាយដែលផ្តល់យុត្តិធម៌ ។

(ខ) សិទ្ធិមានសន្តិសុខបុគ្គល និងការការពារដោយរដ្ឋ ប្រឆាំងនឹងការរំលោភ ឬការបំពារបំពានរាងកាយពីសំណាក់មន្ត្រីរាជការរបស់រដ្ឋាភិបាល ឬពីសំណាក់ក្រុមបុគ្គល ឬស្ថាប័នណាមួយ ។

(គ) សិទ្ធិនយោបាយ ជាពិសេសសិទ្ធិចូលរួមការបោះឆ្នោត សិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះបោះឆ្នោត តាមប្រព័ន្ធនៃការបោះឆ្នោតជាសកល និងស្មើភាព សិទ្ធិចូលរួមក្នុងរដ្ឋាភិបាល ក៏ដូចជាក្នុងការដឹកនាំការងារសាធារណៈនៅគ្រប់ជាន់ថ្នាក់ និងមានលទ្ធភាពស្មើគ្នាក្នុងការចូលបំរើការងារសាធារណៈ ។

(ឃ) សិទ្ធិពលរដ្ឋដទៃទៀត ជាពិសេស :

(i) សិទ្ធិដើរហើរ និងមាននិវេសនដ្ឋានដោយសេរីនៅក្នុងព្រំដែននៃរដ្ឋមួយ ។

(ii) សិទ្ធិចាកចេញពីប្រទេសណាមួយ រួមទាំងប្រទេសរបស់ខ្លួនផង និងវិលត្រឡប់មកប្រទេសខ្លួនវិញ ។

(iii) សិទ្ធិមានសញ្ជាតិមួយ ។

(iv) សិទ្ធិរៀបអាពាហ៍ពិពាហ៍ និងជ្រើសរើសគូស្រករ ។

(v) សិទ្ធិមានកម្មសិទ្ធិតែម្នាក់ឯង ក៏ដូចជារួមជាមួយអ្នកដទៃ ។

(vi) សិទ្ធិជាទាយាទ ។

(vii) សិទ្ធិក្នុងការគិត មានសម្បជញ្ញៈ និងមានជំនឿសាសនាដោយសេរី ។

(viii) សិទ្ធិមានមតិ និងបញ្ចេញមតិដោយសេរី ។

(ix) សិទ្ធិមានសេរីភាពក្នុងការប្រជុំ និងធ្វើសមាគមដោយសន្តិវិធី ។

(ង) សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ជាពិសេសៈ

(i) សិទ្ធិធ្វើការងារ សិទ្ធិជ្រើសរើសការងារដោយសេរី សិទ្ធិទទួលបានល័ក្ខខ័ណ្ឌធ្វើការត្រឹមត្រូវ និងប្រកបដោយអំណោយផល សិទ្ធិទទួលបានការការពារប្រឆាំងការគ្មានការងារធ្វើ សិទ្ធិទទួលប្រាក់ឈ្នួលស្មើគ្នាចំពោះការងារដូចគ្នា សិទ្ធិទទួលបានប្រាក់បំណាច់សមស្រប និងជាទីពេញចិត្ត ។

(ii) សិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីព ។

(iii) សិទ្ធិមានផ្ទះជ្រកកោណ ។

(iv) សិទ្ធិមានសុខភាព ការព្យាបាលជំងឺ សន្តិសុខសង្គម និងសេវាសង្គមកិច្ច ។

(v) សិទ្ធិទទួលបានការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ។

(vi) សិទ្ធិចូលរួមក្នុងសកម្មភាពវប្បធម៌ ក្នុងល័ក្ខខ័ណ្ឌសមភាព ។

**(ច)** សិទ្ធិចេញចូលទីកន្លែង ឬទទួលសេវាដែលដាក់ឱ្យប្រើប្រាស់ដោយសាធារណៈជនទូទៅ ដូចជាការដឹកជញ្ជូន សណ្ឋាគារ ភោជនីយដ្ឋាន កន្លែងលក់កាហ្វេ រោងល្ខោន និងសួនច្បារ ។

## មាត្រា ៦

រដ្ឋភាគីត្រូវធានាថា មនុស្សគ្រប់រូបដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ទទួលបានការការពារ និងការដោះស្រាយសំណុំសិទ្ធិ តាមរយៈតុលាការជាតិ និងស្ថាប័នរដ្ឋមានសមត្ថកិច្ចផ្សេងទៀត ប្រឆាំងនឹងអំពើរើសអើងពូជសាសន៍ ដែលរំលោភសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ផ្ទុយនឹងអនុសញ្ញានេះ និងមានសិទ្ធិសុំឱ្យតុលាការទាំងនេះ ផ្តល់សំណង ឬការជួសជុលត្រឹមត្រូវ និងគ្រប់គ្រាន់ ចំពោះការខូចខាតដែលបណ្តាលមកពីការរើសអើងពូជសាសន៍ ។

## មាត្រា ៧

រដ្ឋភាគីសន្យាចាត់វិធានការជាបន្ទាន់ និងស័ក្តិសិទ្ធិ ពិសេសក្នុងវិស័យសិក្សាអប់រំ វប្បធម៌ និងព័ត៌មាន ដើម្បីប្រយុទ្ធប្រឆាំងនឹងទស្សនៈលំអៀង ដែលនាំឱ្យមានការរើសអើងពូជសាសន៍ និងដើម្បីបង្កអំណោយផលដល់ការយោគយល់គ្នា ការអត់ឱនឱ្យគ្នា និងមិត្តភាពរវាងប្រជាជាតិ និងក្រុមពូជសាសន៍ ឬក្រុមជនជាតិ ក៏ដូចជា ដើម្បីផ្សព្វផ្សាយគោលបំណង និងគោលការណ៍នៃធម្មនុញ្ញសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ហើយនិងអនុសញ្ញានេះ ។

## ផ្នែកទី ២

## មាត្រា ៨

១. គណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍ (ចាប់ពីនេះទៅហៅថាគណៈកម្មាធិការ) ត្រូវបង្កើតឡើង ។ គណៈកម្មាធិការនេះ មានអ្នកជំនាញ១៨រូប ដែលមានជំហរសីលធម៌ខ្ពស់ និងមិនលំអៀង និងដែលជ្រើសរើសក្នុងការបោះឆ្នោតដោយរដ្ឋភាគី ក្នុងចំណោមជនជាតិរបស់ខ្លួន និងត្រូវធ្វើការក្នុងឋានៈជាបុគ្គលឯកជន ដោយត្រូវធ្វើការពិចារណាបែងចែក តាមភូមិសាស្ត្រដោយសមធម៌ និងឱ្យមានតំណាងទម្រង់ផ្សេងៗនៃអារ្យធម៌ ព្រមទាំងទៅតាមប្រព័ន្ធច្បាប់ធំៗផង ។

២. សមាជិកគណៈកម្មាធិការ ត្រូវជ្រើសរើសតាមការបោះឆ្នោតដោយសម្ងាត់ ពីបញ្ជីរាយនាមបេក្ខជនដែលជ្រើសតាំងដោយរដ្ឋភាគី ។ រដ្ឋភាគីនីមួយៗ អាចជ្រើសតាំងបេក្ខជនម្នាក់ ក្នុងចំណោមជនជាតិរបស់ខ្លួន ។

៣. ការបោះឆ្នោតលើកដំបូង ត្រូវធ្វើឡើង៦ខែ ក្រោយកាលបរិច្ឆេទនៃការចូលជាធរមាននៃអនុសញ្ញានេះ ។ យ៉ាងតិច៣ខែ មុនកាលបរិច្ឆេទនៃការបោះឆ្នោតនីមួយៗ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវចេញលិខិតអញ្ជើញរដ្ឋភាគី ឱ្យដាក់ស្នើនាមបេក្ខជនរបស់ខ្លួនក្នុងរយៈពេល២ខែ ។ អគ្គលេខាធិការ ត្រូវរៀបចំបញ្ជីឈ្មោះតាមលំដាប់អក្ខរក្រម នៃបេក្ខជនទាំងអស់ ដែលបានដាក់ស្នើដោយរដ្ឋភាគី ដោយបញ្ជាក់ឈ្មោះរដ្ឋភាគី ដែលបានជ្រើសតាំងបេក្ខជន ហើយផ្ញើបញ្ជីនេះទៅគ្រប់រដ្ឋភាគីទាំងអស់ ។

៤. ការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការ ត្រូវធ្វើក្នុងសម័យប្រជុំនៃរដ្ឋភាគី តាមការកោះអញ្ជើញដោយអគ្គលេខាធិការ នៅទីស្នាក់ការអង្គការសហប្រជាជាតិ ។ កូរ៉ុមសម្រាប់កិច្ចប្រជុំ គឺពីរភាគបីនៃរដ្ឋភាគី។ បេក្ខជនដែលជាប់ជាសមាជិកគណៈកម្មាធិការ ត្រូវតែជាបេក្ខជនដែលទទួលបានសម្លេងច្រើនបំផុត និងសម្លេងភាគច្រើនដាច់ខាតពីតំណាងរបស់រដ្ឋភាគីដែលមានវត្តមាន និងបានបោះឆ្នោត ។

៥. (ក) សមាជិកគណៈកម្មាធិការ ត្រូវជ្រើសរើសតាមការបោះឆ្នោត សម្រាប់រយៈពេល៤ឆ្នាំ ។ ប៉ុន្តែអាណត្តិសមាជិក៩រូប ដែលជាប់នៅពេលបោះឆ្នោតលើកទី១ ត្រូវផុតកំណត់ក្នុងរយៈពេល២ឆ្នាំ ហើយឈ្មោះសមាជិកទាំង៩រូបនេះ ត្រូវចាប់ឆ្នោតជ្រើសរើសដោយប្រធានអង្គប្រជុំភ្លាមៗ បន្ទាប់ពីការបោះឆ្នោតលើកទី១ ។

(ខ) ដើម្បីបំពេញកន្លែងទំនេរដោយចៃដន្យ រដ្ឋភាគីដែលមានអ្នកជំនាញការឈប់បំពេញមុខងាររបស់ខ្លួនជាសមាជិកគណៈកម្មាធិការ ត្រូវតែងតាំងអ្នកជំនាញម្នាក់ទៀត ក្នុងចំណោមជនជាតិរបស់ខ្លួន ដោយមានការយល់ព្រមពីគណៈកម្មាធិការ ។

(៦) រដ្ឋភាគី ត្រូវទទួលបន្ទុកខ្លួនឯងលើចំណាយរបស់សមាជិកគណៈកម្មាធិការ សម្រាប់រយៈពេលសមាជិកគណៈកម្មាធិការបំពេញការងារ ។

## មាត្រា ៩

១. រដ្ឋភាគី សន្យាដាក់ជូនទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ដើម្បីគណៈកម្មាធិការពិនិត្យនូវរបាយការណ៍ ស្តីពី វិធានការខាងនីតិកម្ម តុលាការ រដ្ឋបាល ឬវិធានការផ្សេងទៀតដែលបានអនុម័ត និងផ្តល់អានុភាពដល់បទបញ្ញត្តិនៃអនុសញ្ញានេះ : (ក) នៅក្នុងរយៈពេល១ឆ្នាំ គិតចាប់ពីការចូលជាធរមាននៃអនុសញ្ញា សម្រាប់រដ្ឋពាក់ព័ន្ធ និង (ខ) បន្ទាប់មកទៀត រាល់២ឆ្នាំម្តង និងនៅគ្រប់ពេលដែលគណៈកម្មាធិការសុំឱ្យធ្វើ ។ គណៈកម្មាធិការអាចសុំព័ត៌មានបន្ថែមពីរដ្ឋភាគីបាន ។

២. គណៈកម្មាធិការ ត្រូវដាក់របាយការណ៍ប្រចាំឆ្នាំស្តីពីសកម្មភាពរបស់ខ្លួន តាមរយៈអគ្គលេខាធិការ ជូនទៅមហាសន្និបាតអង្គការសហប្រជាជាតិ និងអាចផ្តល់យោបល់ និងអនុសាសន៍ទូទៅ ផ្អែកលើការពិនិត្យរបាយការណ៍ និងព័ត៌មានទទួលបានពីរដ្ឋភាគី ។ ការផ្តល់យោបល់ និងអនុសាសន៍ទូទៅទាំងនេះ ត្រូវដាក់ជូនមហាសន្និបាត ព្រមជាមួយមូលវិចាររបស់រដ្ឋជាភាគី បើសិនជាមាន ។

## មាត្រា ១០

១. គណៈកម្មាធិការ ត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

២. គណៈកម្មាធិការត្រូវបោះឆ្នោតជ្រើសរើសមន្ត្រីការិយាល័យរបស់ខ្លួនសម្រាប់រយៈពេល២ឆ្នាំ ។

៣. លេខាធិការដ្ឋានរបស់គណៈកម្មាធិការ ត្រូវបានផ្តល់ឱ្យដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៤. ការប្រជុំគណៈកម្មាធិការ ជាធម្មតា ធ្វើនៅទីស្នាក់ការអង្គការសហប្រជាជាតិ ។

## មាត្រា ១១

១. បើរដ្ឋភាគីណាមួយយល់ឃើញថា រដ្ឋភាគីមួយទៀត មិនអនុវត្តបទបញ្ញត្តិនៃអនុសញ្ញានេះ រដ្ឋនោះ អាចលើកយកបញ្ហានេះដាក់ជូនគណៈកម្មាធិការ ។ គណៈកម្មាធិការ ត្រូវបញ្ជូនបណ្តឹងនេះទៅរដ្ឋភាគីពាក់ព័ន្ធ ។ ក្នុងរយៈពេល៣ខែ រដ្ឋចុងបណ្តឹងត្រូវដាក់ជូនគណៈកម្មាធិការ នូវការពន្យល់ ឬសេចក្តីថ្លែងការណ៍ជាលាយល័ក្ខណ៍អក្សរ ដោយបំភ្លឺបញ្ហា រួមទាំងការដោះស្រាយ បើសិនជាមាន ដែលរដ្ឋចុងបណ្តឹងបានធ្វើ ។

២. បើបញ្ហា មិនត្រូវបានដោះស្រាយឱ្យពេញចិត្តសម្រាប់រដ្ឋពាក់ព័ន្ធទាំងពីរ តាមការចរចារទ្វេភាគី ឬតាមនីតិវិធីណាមួយបានទេ ក្នុងរយៈពេល៦ខែ បន្ទាប់ពីរដ្ឋចុងបណ្តឹងបានទទួលបណ្តឹងទីមួយ ហើយរដ្ឋភាគីណាមួយក៏បាន មានសិទ្ធិលើកយកបញ្ហានោះដាក់ជូនគណៈកម្មាធិការជាថ្មី ដោយការជូនដំណឹងទៅគណៈកម្មាធិការ និងដល់រដ្ឋម្ខាងទៀត ។

៣. គណៈកម្មាធិការ ត្រូវដោះស្រាយបញ្ហាដែលដាក់ជូនមកខ្លួន ស្របតាមកថាខណ្ឌ២ នៃមាត្រានេះ ក្រោយពីខ្លួនបានដឹងច្បាស់ថា វិធីដោះស្រាយទាំងអស់ដែលមាននៅក្នុងស្រុក បានយកមកប្រើអស់ហើយក្នុងករណីនេះ ស្របតាមគោលការណ៍នៃច្បាប់អន្តរជាតិ ដែលត្រូវបានទទួលស្គាល់ជាទូទៅ ។ វិធាននេះ នឹងមិនត្រូវយកមកអនុវត្តទេ បើនីតិវិធីនៃការដោះស្រាយបន្តយូរហួសហេតុ ។

៤. ចំពោះគ្រប់សំណុំរឿងដែលបញ្ជូនមក គណៈកម្មាធិការ អាចសុំរដ្ឋភាគីពាក់ព័ន្ធ ឱ្យផ្តល់ព័ត៌មានពាក់ព័ន្ធផ្សេងទៀត ។

៥. នៅពេលគណៈកម្មាធិការពិនិត្យសំណុំរឿងណាមួយ ស្របតាមមាត្រានេះ រដ្ឋភាគីពាក់ព័ន្ធមានសិទ្ធិចាត់តំណាងម្នាក់ឱ្យចូលរួម តែពុំមានសិទ្ធិបោះឆ្នោតក្នុងការងាររបស់គណៈកម្មាធិការ នៅគ្រប់ពេលនៃការពិនិត្យពិភាក្សាលើករណីនេះ ។

## មាត្រា ១២

១.(ក) បន្ទាប់ពីគណៈកម្មាធិការ បានទទួល និងប្រមូលផ្តុំតាមលំដាប់លំដោយ នូវព័ត៌មានទាំងអស់ដែលខ្លួនយល់ថាចាំបាច់ហើយ ប្រធានគណៈកម្មាធិការ ត្រូវតែងតាំងគណៈកម្មការចំពោះកិច្ចមួយ (ដែលពីនេះតទៅហៅថា គណៈកម្មការ)ដែលមានសមាសភាព៥រូប ដែលអាចជាសមាជិក ឬអាចមិនមែនជាសមាជិកគណៈកម្មាធិការ ។ សមាជិកគណៈកម្មការ ត្រូវតែងតាំងដោយមានការយល់ព្រមជាឯកច្ឆ័ន្ទពីភាគីមានទំនាស់ និងត្រូវដាក់សេវារបស់ខ្លួនឱ្យរដ្ឋភាគីពាក់ព័ន្ធប្រើប្រាស់ ដើម្បីរកដំណោះស្រាយស្រុះស្រួលលើបញ្ហា ដោយគោរពតាមអនុសញ្ញានេះ ។

ខ. បើរដ្ឋភាគីមានទំនាស់ មិនឈានដល់ការកិច្ចព្រមព្រៀងទាំងស្រុង ឬផ្នែកខ្លះលើសមាសភាពគណៈកម្មការក្នុងរយៈពេល៣ខែទេ សមាជិកគណៈកម្មការណាដែលមិនបានទទួលការយល់ព្រមពីរដ្ឋភាគីមានទំនាស់ ត្រូវដាក់ឱ្យជ្រើសរើសតាមការបោះឆ្នោតជាសម្ងាត់ ដោយយកសម្លេងភាគច្រើនពីរភាគបីនៃចំណោមសមាជិកគណៈកម្មាធិការ ។

២. សមាជិកគណៈកម្មការ ត្រូវធ្វើការក្នុងឋានៈជាបុគ្គលឯកជន ។ សមាជិកគណៈកម្មការមិនត្រូវជាជនជាតិនៃរដ្ឋភាគីមានទំនាស់ ឬនៃរដ្ឋមិនមែនភាគីនៃអនុសញ្ញានេះឡើយ ។

៣. គណៈកម្មការ ត្រូវបោះឆ្នោតរើសប្រធាន និងត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

៤. ការប្រជុំគណៈកម្មការ ត្រូវធ្វើជាធម្មតានៅទីស្នាក់ការអង្គការសហប្រជាជាតិ ឬនៅកន្លែងសមស្របផ្សេងទៀត កំណត់ដោយគណៈកម្មការ ។

៥. លេខាធិការដ្ឋានដែលកំណត់ស្របតាមមាត្រា១០ កថាខណ្ឌ៣ នៃអនុសញ្ញានេះ ត្រូវជួយគណៈកម្មការ នៅពេលទំនាស់រវាងរដ្ឋភាគី ឈានដល់ការបង្កើតឱ្យមានគណៈកម្មការ ។

៦. រដ្ឋភាគីមានទំនាស់ ត្រូវបែងចែកស្មើគ្នាលើចំណាយសម្រាប់សមាជិកគណៈកម្មការ ស្របតាមការប៉ាន់ស្មានកំណត់ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៧. បើចាំបាច់ អគ្គលេខាធិការ មានសិទ្ធិចេញចំណាយជួសសមាជិកគណៈកម្មការ មុនពេលសងមកវិញដោយរដ្ឋភាគីមានទំនាស់ ស្របតាមកថាខណ្ឌ៦ នៃមាត្រានេះ ។

៨. ព័ត៌មានដែលគណៈកម្មាធិការទទួល និងប្រមូលបាន ត្រូវដាក់ឱ្យគណៈកម្មការប្រើប្រាស់ ហើយគណៈកម្មការ អាចសុំឱ្យរដ្ឋភាគីពាក់ព័ន្ធ ផ្តល់ព័ត៌មានពាក់ព័ន្ធផ្សេងទៀត ។

## មាត្រា ១៣

១. នៅពេលគណៈកម្មការបានសិក្សាបញ្ហាសព្វគ្រប់ហើយ គណៈកម្មាការត្រូវរៀបចំ និងដាក់ជូនប្រធានគណៈកម្មាធិការ នូវរបាយការណ៍មួយដែលបង្ហាញសេចក្ដីសន្និដ្ឋានលើបញ្ហាអង្គហេតុទាក់ទងនឹងចំណុចវិវាទរវាងភាគី និងកំណត់អនុសាសន៍ ដែលគណៈកម្មាធិការយល់ឃើញថា សមស្របសម្រាប់ដោះស្រាយទំនាស់ដោយស្រុះស្រួលគ្នា ។

២. ប្រធានគណៈកម្មាធិការ ត្រូវផ្ញើរបាយការណ៍របស់គណៈកម្មការ ជូនទៅភាគីមានទំនាស់ ។ រដ្ឋភាគីទាំងនេះ ត្រូវជូនដំណឹងទៅប្រធានគណៈកម្មាធិការក្នុងរយៈពេល៣ខែ ថាខ្លួនព្រមទទួល ឬមិនព្រមទទួលយកអនុសាសន៍ ដែលកំណត់ក្នុងរបាយការណ៍របស់គណៈកម្មការ ។

៣. បើផុតរយៈពេល ដែលបានកំណត់ក្នុងកថាខណ្ឌ២ នៃមាត្រានេះ ប្រធានគណៈកម្មាធិការត្រូវផ្ញើរបាយការណ៍របស់គណៈកម្មការ និងសេចក្ដីប្រកាសរបស់រដ្ឋភាគីពាក់ព័ន្ធ ជូនទៅរដ្ឋភាគីផ្សេងទៀតនៃអនុសញ្ញានេះ ។

## មាត្រា ១៤

១. រដ្ឋភាគី អាចប្រកាសគ្រប់ពេលវេលា ថាខ្លួនទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការក្នុងការទទួល និងពិនិត្យបណ្ដឹងរបស់បុគ្គល ឬក្រុមបុគ្គលដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងដែលអះអាងថាជាជនរងគ្រោះពីការរំលោភដោយរដ្ឋភាគីទៅលើសិទ្ធិណាមួយ ដែលមានចែងនៅក្នុងអនុសញ្ញានេះ ។ គណៈកម្មាធិការ នឹងមិនទទួលយកបណ្ដឹងពាក់ព័ន្ធនឹងរដ្ឋភាគី ដែលមិនបានធ្វើសេចក្ដីប្រកាសនេះឡើយ ។

២. រដ្ឋភាគីណាដែលធ្វើសេចក្ដីប្រកាស ស្របតាមកថាខណ្ឌ១ នៃមាត្រានេះ អាចបង្កើត ឬបង្ហាញឈ្មោះស្ថាប័នមួយ ក្នុងលំដាប់គតិយុត្តិថ្នាក់ជាតិរបស់ខ្លួន ដែលមានសមត្ថកិច្ចទទួល និងពិនិត្យបណ្ដឹងទាមទាររបស់បុគ្គល ឬក្រុមបុគ្គល ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងដែលអះអាងថា ជាជនរងគ្រោះដោយការរំលោភសិទ្ធិណាមួយ ដែលមានចែងក្នុងអនុសញ្ញានេះ ហើយដែលបានប្រើអស់ដំណោះស្រាយក្នុងស្រុកដែលមាន ។

៣. សេចក្ដីប្រកាសដែលធ្វើស្របតាមកថាខណ្ឌ១នៃមាត្រានេះនិងឈ្មោះស្ថាប័នណាមួយដែលបានបង្កើត ឬបង្ហាញស្របតាមកថាខណ្ឌ២ នៃមាត្រានេះ ត្រូវដំកល់ទុកដោយរដ្ឋភាគីពាក់ព័ន្ធ នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនច្បាប់ចម្លងនៃសេចក្ដីប្រកាស និងឈ្មោះស្ថាប័នទៅជូនរដ្ឋភាគីផ្សេងទៀត ។ សេចក្ដីប្រកាសអាចដកវិញបានគ្រប់ពេល ដោយការជូនដំណឹងទៅអគ្គលេខាធិការ ប៉ុន្តែការដកនេះ មិនប៉ះពាល់បញ្ហាដែលគណៈកម្មាធិការបានទទួលរួចហើយឡើយ ។

៤. ស្ថាប័នដែលបានបង្កើត ឬបង្ហាញស្របតាមកថាខណ្ឌ២ នៃមាត្រានេះ ត្រូវរក្សាសៀវភៅចុះបញ្ជីបណ្តឹងទាមទារ ហើយច្បាប់ចម្លងនៃសៀវភៅចុះបញ្ជី ដែលមានការបញ្ជាក់ស្របតាមច្បាប់ដើម ត្រូវដំកល់ទុករៀងរាល់ឆ្នាំ នៅនឹងអគ្គលេខាធិការតាមរយៈខ្សែបណ្តាញសមស្រប ក្នុងន័យថា ខ្លឹមសារនៃច្បាប់ចម្លង មិនត្រូវឱ្យដឹងជាសាធារណៈឡើយ ។

៥. បើមិនពេញចិត្តនឹងស្ថាប័នដែលបង្កើត ឬបង្ហាញស្របតាមកថាខណ្ឌ២នៃមាត្រានេះទេ អ្នកដាក់បណ្តឹងទាមទារ មានសិទ្ធិក្នុងរយៈពេល៦ខែ ប្តឹងអំពីបញ្ហានេះទៅគណៈកម្មាធិការ ។

៦. (ក) គណៈកម្មាធិការ ត្រូវបញ្ជូនជាសម្ងាត់នូវបណ្តឹងណាដែលផ្ញើមកឱ្យខ្លួន ទៅរដ្ឋភាគីដែលជាប់ចោទ ថាបានរំលោភបទបញ្ញត្តិណាមួយនៃអនុសញ្ញានេះ ប៉ុន្តែអត្តសញ្ញាណរបស់បុគ្គល ឬក្រុមបុគ្គលពាក់ព័ន្ធ មិនត្រូវប្រាប់ឱ្យដឹងឡើយ បើគ្មានការយល់ព្រមជាក់លាក់ពីបុគ្គលនេះ ឬក្រុមបុគ្គលនេះ ។ គណៈកម្មាធិការ មិនទទួលបណ្តឹងអនាមិកទេ ។

(ខ) ក្នុងរយៈពេល ៣ ខែ រដ្ឋចុងចោទត្រូវដាក់ការពន្យល់ ឬសេចក្តីថ្លែងការណ៍ជាលាយល័ក្ខអក្សរ បំភ្លឺអំពីបញ្ហានិងការដោះស្រាយ ប្រសិនជាមាន ដែលរដ្ឋចុងចោទបានធ្វើឡើងហើយ ។

៧. (ក) គណៈកម្មាធិការ ត្រូវពិនិត្យបណ្តឹងទាំងឡាយ ស្របតាមព័ត៌មានដែលខ្លួនបានទទួលពីរដ្ឋភាគីពាក់ព័ន្ធ និងពីអ្នកប្តឹងទាមទារ ។ គណៈកម្មាធិការ មិនពិនិត្យបណ្តឹងពីអ្នកប្តឹងទាមទារណាដែលមិនបានធានាអះអាង ថាខ្លួនបានប្រើអស់នូវការដោះស្រាយក្នុងស្រុកដែលមាន ។ ប៉ុន្តែវិធាននេះនឹងមិនត្រូវយកមកអនុវត្តទេ បើនីតិវិធីនៃការដោះស្រាយ បន្តយូរហួសហេតុ ។

(ខ) គណៈកម្មាធិការ ត្រូវបញ្ជូនការផ្តល់យោបល់ និងអនុសាសន៍ បើសិនជាមាន ទៅជូនរដ្ឋភាគីពាក់ព័ន្ធ និងអ្នកប្តឹងទាមទារ ។

៨. គណៈកម្មាធិការ ត្រូវបញ្ចូលទៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន នូវសេចក្តីសង្ខេបនៃបណ្តឹង និងបើសមស្រប សង្ខេបការពន្យល់ និងសេចក្តីថ្លែងការណ៍របស់រដ្ឋភាគីពាក់ព័ន្ធ ព្រមទាំងសង្ខេបការផ្តល់យោបល់ និងអនុសាសន៍របស់គណៈកម្មាធិការ ។

៩. គណៈកម្មាធិការ មានសមត្ថកិច្ចបំពេញមុខងារដែលបានចែងក្នុងមាត្រានេះបាន លុះត្រាតែយ៉ាងតិចបំផុត រដ្ឋភាគីចំនួន១០នៃអនុសញ្ញានេះ ជាប់កាតព្វកិច្ចដោយសេចក្តីប្រកាស ដែលធ្វើឡើងស្របតាមកថាខណ្ឌ១ នៃមាត្រានេះ ។

## មាត្រា ១៥

១. ក្នុងពេលរង់ចាំការសម្រេចបាននូវគោលបំណង នៃសេចក្តីប្រកាស ស្តីពីការផ្តល់ឯករាជ្យដល់ប្រទេស និងប្រជាជាតិអាណានិគម ដែលកំណត់នៅក្នុងសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតលេខ១៥១៤ (XV) ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៦០ បទបញ្ញត្តិនានានៃអនុសញ្ញានេះ នឹងមិនដាក់កម្រិតព្រំដែនដោយ

ប្រការណាមួយ លើសិទ្ធិប្ដឹងទាមទារដែលផ្ដល់ដល់ប្រជាជាតិទាំងនេះដោយលិខិតុបករណ៍អន្តរជាតិផ្សេងៗ ឬដោយអង្គការសហប្រជាជាតិ និងស្ថាប័នឯកទេសនានា នៃអង្គការសហប្រជាជាតិឡើយ ។

២. (ក) គណៈកម្មាធិការ ដែលបានបង្កើតស្របតាមកថាខណ្ឌ១ នៃមាត្រា៨ នៃអនុសញ្ញានេះ ត្រូវទទួលច្បាប់ចម្លងនៃបណ្ដឹងទាមទារ និងដាក់បង្ហាញមតិ និងអនុសាសន៍ស្ដីពីបណ្ដឹងទាមទារទាំងនេះ ទៅស្ថាប័ននានារបស់អង្គការសហប្រជាជាតិ ដែលទទួលបន្ទុកដោះស្រាយដោយផ្ទាល់នូវបញ្ហាពាក់ព័ន្ធនឹង គោលការណ៍ និងគោលបំណងនៃអនុសញ្ញានេះ ដើម្បីពិនិត្យបណ្ដឹងទាមទាររបស់ប្រជាពលរដ្ឋ នៃដែនដី ស្ថិតក្រោមអាណាព្យាបាល ដែនដីគ្មានស្វ័យភាពគ្រប់គ្រង និងដែនដីផ្សេងទៀតទាំងអស់ដែលកំណត់ឱ្យ អនុវត្តតាមសេចក្ដីសម្រេចចិត្តរបស់មហាសន្និបាតលេខ១៥១៤ (XV) ទាក់ទងនឹងបញ្ហាដែលបានចែងក្នុង អនុសញ្ញានេះ និងដែលស្ថិតនៅចំពោះមុខស្ថាប័នទាំងនេះ ។

(ខ) គណៈកម្មាធិការត្រូវទទួលពីស្ថាប័នមានសមត្ថកិច្ចរបស់អង្គការសហប្រជាជាតិ នូវច្បាប់ ចម្លងនៃរបាយការណ៍ស្ដីពីវិធានការខាងនីតិបញ្ញត្តិ តុលាការ រដ្ឋបាល ឬវិធានការផ្សេងទៀត ដែល ពាក់ព័ន្ធផ្ទាល់នឹងគោលការណ៍ និងគោលបំណងនៃអនុសញ្ញានេះ ដែលត្រូវបានអនុវត្តដោយអាជ្ញាធរ គ្រប់គ្រងលើដែនដី ដែលមានចែងក្នុងអនុកថាខណ្ឌ (ក) នៃកថាខណ្ឌនេះ និងត្រូវបង្ហាញមតិ និង ផ្ដល់អនុសាសន៍ដល់ស្ថាប័នទាំងនេះ ។

៣. គណៈកម្មាធិការ ត្រូវបញ្ចូលទៅក្នុងរបាយការណ៍របស់ខ្លួន ជូនមហាសន្និបាត នូវសេចក្ដី សង្ខេបនៃបណ្ដឹងទាមទារ និងរបាយការណ៍ដែលខ្លួនបានទទួលពីស្ថាប័ននានារបស់អង្គការសហប្រជាជាតិ ព្រមទាំងការបង្ហាញមតិ និងអនុសាសន៍នៃគណៈកម្មាធិការ ទាក់ទងនឹងបណ្ដឹងទាមទារ និងរបាយការណ៍ ដែលលើកឡើងខាងលើ ។

៤. គណៈកម្មាធិការ ត្រូវស្នើសុំអគ្គលេខាធិការអង្គការសហប្រជាជាតិ ឱ្យផ្ដល់មកឱ្យខ្លួននូវព័ត៌មាន ទាំងអស់ ដែលទាក់ទងនឹងគោលបំណងនៃអនុសញ្ញានេះ និងព័ត៌មានដែលអគ្គលេខាធិការ អាចមាន ស្ដីពីដែនដី ដែលមានចែងក្នុងកថាខណ្ឌ២ (ក) នៃមាត្រានេះ ។

## មាត្រា ១៦

បទបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ ស្ដីពីវិធានសម្រាប់ការដោះស្រាយទំនាស់ ឬបណ្ដឹង ត្រូវ អនុវត្តដោយមិនធ្វើឱ្យប៉ះពាល់ដល់នីតិវិធីផ្សេងទៀត សម្រាប់ដោះស្រាយទំនាស់ ឬបណ្ដឹង ក្នុងវិស័យនៃ ការរើសអើង ដែលមានបញ្ញត្តិក្នុងលិខិតុបករណ៍មូលដ្ឋាន ឬអនុសញ្ញានានាដែលអនុម័តដោយអង្គការ សហប្រជាជាតិ និងស្ថាប័នឯកទេសនានានៃអង្គការសហប្រជាជាតិ និងមិនត្រូវរារាំងរដ្ឋភាគីក្នុងការប្រើ នីតិវិធីផ្សេង ដើម្បីដោះស្រាយទំនាស់ណាមួយ ស្របតាមកិច្ចព្រមព្រៀងអន្តរជាតិ មានលក្ខណៈទូទៅ ឬមានលក្ខណៈពិសេស ដែលមានជាធរមានរវាងរដ្ឋទាំងនោះឡើយ ។

## វគ្គទី ៣

### មាត្រា ១៧

១. អនុសញ្ញានេះ ត្រូវបើកចំហឱ្យចុះហត្ថលេខាសម្រាប់រដ្ឋសមាជិកសហប្រជាជាតិ ឬសមាជិកនៃស្ថាប័នឯកទេសណាមួយ ឬជាភាគីនៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ ឬជារដ្ឋផ្សេងទៀតដែលត្រូវបានអញ្ជើញដោយមហាសន្និបាតសហប្រជាជាតិ ឱ្យក្លាយជាភាគីនៃអនុសញ្ញានេះ ។

២. អនុសញ្ញានេះ ជាកម្មវត្ថុនៃការឱ្យសច្ចាប័ន ។ លិខិតុបករណ៍ឱ្យសច្ចាប័ន ត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

### មាត្រា ១៨

១. អនុសញ្ញានេះ ត្រូវបើកចំហឱ្យរដ្ឋណាមួយ ដូចមានយោងក្នុងមាត្រា១៧ កថាខណ្ឌ១ នៃអនុសញ្ញានេះចូលជាសមាជិក ។

២. ការចូលជាសមាជិក ត្រូវធ្វើឡើងដោយការតំកល់លិខិតុបករណ៍សុំចូលជាសមាជិកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

### មាត្រា ១៩

១. អនុសញ្ញានេះ ចូលជាធរមាននៅថ្ងៃទី៣០ បន្ទាប់ពីកាលបរិច្ឆេទនៃការដំកល់លិខិតុបករណ៍ទី២៧ នៃការឱ្យសច្ចាប័ន ឬការសុំចូលជាសមាជិក នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

២. រដ្ឋណាដែលបានផ្តល់សច្ចាប័ន ឬចូលជាសមាជិកនៃអនុសញ្ញានេះ បន្ទាប់ពីការដំកល់លិខិតុបករណ៍ទី២៧ នៃការឱ្យសច្ចាប័ន ឬការសុំចូលជាសមាជិកអនុសញ្ញានេះ នឹងត្រូវចូលជាធរមាននៅថ្ងៃទី៣០ បន្ទាប់ពីកាលបរិច្ឆេទដែលរដ្ឋនេះ ដំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬការសុំចូលជាសមាជិករបស់ខ្លួន ។

### មាត្រា ២០

១. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវទទួល និងជូនដំណឹងទៅរដ្ឋទាំងអស់ដែលជាភាគី ឬអាចនឹងក្លាយជាភាគីនៃអនុសញ្ញានេះ នូវល័ក្ខខ័ណ្ឌទាំងឡាយ ដែលរដ្ឋបានដាក់នៅពេលឱ្យសច្ចាប័ន ឬសុំចូលជាសមាជិក ។ រដ្ឋណាដែលជំទាស់នឹងល័ក្ខខ័ណ្ឌណាមួយ ត្រូវជូនដំណឹង ទៅអគ្គលេខាធិការក្នុងរយៈពេល៩០ថ្ងៃ ចាប់ពីកាលបរិច្ឆេទនៃឆ្លើយឆ្លងខាងលើ ថាខ្លួនមិនទទួលយកល័ក្ខខ័ណ្ឌនោះទេ ។

២. ល័ក្ខខ័ណ្ឌដែលវិសមិតនឹងកម្មវត្ថុ និងគោលបំណងនៃអនុសញ្ញានេះ មិនត្រូវបានអនុញ្ញាតទេ ហើយក៏មិនត្រូវអនុញ្ញាតដែរ នូវល័ក្ខខ័ណ្ឌណាដែលមានអានុភាពបង្អាក់ដំណើរនៃអង្គការណាមួយ ដែលបង្កើតឡើងដោយអនុសញ្ញានេះ ។ ល័ក្ខខ័ណ្ឌត្រូវចាត់ថាមានវិសមិតភាព និងបន្ទុចបង្អាក់ បើ២ភាគ៣យ៉ាងតិចនៃរដ្ឋភាគីនៃអនុសញ្ញានេះ លើកការជំទាស់ ។

៣. ល័ក្ខខ័ណ្ឌអាចដកចេញវិញបានគ្រប់ពេល ដោយការជូនដំណឹងទៅអគ្គលេខាធិការ ។ ការជូនដំណឹងនេះ មានអានុភាពនៅកាលបរិច្ឆេទនៃការបានទទួលដំណឹង ។

## មាត្រា ២១

រដ្ឋភាគី អាចប្រកាសដកខ្លួនចេញពីអនុសញ្ញានេះ ដោយការជូនដំណឹងជាលាយល័ក្ខណ៍អក្សរទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ការប្រកាសដកខ្លួន មានអានុភាព១ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទដែលអគ្គលេខាធិការបានទទួលការជូនដំណឹងនេះ ។

## មាត្រា ២២

ទំនាស់រវាងរដ្ឋភាគីពីរ ឬច្រើនជាងនេះ ដែលពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តន៍អនុសញ្ញានេះ ហើយដែលមិនអាចដោះស្រាយតាមការចរចារបាន ឬតាមនីតិវិធីដែលមានកំណត់ច្បាស់លាស់ក្នុងអនុសញ្ញានេះ ត្រូវបញ្ជូនទៅតុលាការយុត្តិធម៌អន្តរជាតិ តាមការស្នើសុំរបស់ភាគីទំនាស់ណាមួយ ដើម្បីជំនុំជំរះ លើកលែងតែរដ្ឋភាគីទំនាស់ណាមួយ សុខចិត្តទទួលយកវិធីដោះស្រាយណាមួយផ្សេងទៀត ។

## មាត្រា ២៣

១. សំណើរសុំពិនិត្យឡើងវិញនូវអនុសញ្ញានេះ អាចធ្វើទៅបានគ្រប់ពេល ដោយរដ្ឋភាគីណាមួយ តាមការជូនដំណឹងជាលាយល័ក្ខណ៍អក្សរទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

២. មហាសន្និបាតអង្គការសហប្រជាជាតិ ត្រូវសម្រេចពីវិធានការនានាបើមាន ចំពោះការស្នើសុំនេះ ។

## មាត្រា ២៤

អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវជូនព័ត៌មានដល់រដ្ឋទាំងអស់ ស្របតាមមាត្រា១៧ កថាខណ្ឌ១ នៃអនុសញ្ញានេះ នូវចំណុចខាងក្រោម :

ក. ការចុះហត្ថលេខា ការឱ្យសច្ចាប័ន និងការចូលជាសមាជិក ស្របតាមមាត្រា១៧ និង១៨ ។

ខ. កាលបរិច្ឆេទដែលអនុសញ្ញានេះចូលជាធរមាន ស្របតាមមាត្រា១៩ ។

គ. បណ្ដឹងនិងសេចក្ដីប្រកាសដែលទទួលបាន ស្របតាមមាត្រា១៤ មាត្រា២០ និងមាត្រា២៣ ។

ឃ. ការប្រកាសដកខ្លួន ស្របតាមមាត្រា២១ ។

## មាត្រា ២៥

១. អនុសញ្ញានេះ ដែលមានអត្ថបទជាភាសាចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ៉ុល មានតម្លៃស្មើគ្នា នឹងតម្កល់ទុកនៅបណ្ណសារដ្ឋានរបស់អង្គការសហប្រជាជាតិ ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនច្បាប់ចម្លងនៃអនុសញ្ញានេះ ដោយមានបញ្ជាក់ការចម្លងត្រឹមត្រូវតាមច្បាប់ដើម ទៅរដ្ឋទាំងអស់ដែលជាសមាជិក តាមប្រភេទដូចមានចែងក្នុងមាត្រា១៧ កថាខណ្ឌ១ នៃអនុសញ្ញានេះ ។

# អនុសញ្ញា
# ស្តីពី
# ការបំបាត់រាល់ទម្រង់
# នៃការរើសអើង
# ប្រឆាំងនឹងស្ត្រីភេទ

# ១០ - អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ

ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ កាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៩
និងចូលជាធរមាននៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៨១ ស្របតាមបទបញ្ញត្តិមាត្រា២៧ (១)
កម្ពុជាក្លាយជារដ្ឋភាគីនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២

## បុព្វកថា

រដ្ឋភាគីនៃអនុសញ្ញានេះ

*កត់សំគាល់ឃើញថា* ធម្មនុញ្ញសហប្រជាជាតិអះអាងជាថ្មី នូវជំនឿលើសិទ្ធិមូលដ្ឋានរបស់មនុស្ស លើសេចក្តីថ្លៃថ្នូរ និងតម្លៃមនុស្ស និងលើសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី ។

*កត់សំគាល់ឃើញថា* សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស បញ្ជាក់នូវគោលការណ៍មិនរើសអើង និងបានប្រកាសថា មនុស្សគ្រប់រូបកើតមកមានសេរីភាព និងសមភាពក្នុងផ្នែកសេចក្តីថ្លៃថ្នូរ និងសិទ្ធិ ហើយថាមនុស្សគ្រប់រូប ត្រូវទទួលបានសិទ្ធិ និងសេរីភាពទាំងអស់ ដែលមានចែងក្នុងសេចក្តីប្រកាសនោះ ដោយគ្មានការប្រកាន់បែងចែកណាមួយ រួមមានការបែងចែកខាងផ្លូវភេទផង ។

*កត់សំគាល់ឃើញថា* រដ្ឋភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស មានកាតព្វកិច្ចធានាសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី ក្នុងការអាស្រ័យផលសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ពលរដ្ឋ និងនយោបាយ ។

*យល់ឃើញថា* អនុសញ្ញាអន្តរជាតិ ដែលបានអនុម័តក្រោមកិច្ចឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ និងស្ថាប័នឯកទេសនានា ក្នុងការលើកស្ទួយសមភាពនៃសិទ្ធិរវាងបុរស និងស្ត្រី ។

*កត់សំគាល់ឃើញពី* សេចក្តីសម្រេចចិត្ត សេចក្តីប្រកាស និងអនុសាសន៍នានា ដែលបានអនុម័តដោយអង្គការសហប្រជាជាតិ និងស្ថាប័នឯកទេសនានា ក្នុងគោលបំណងលើកស្ទួយសមភាពនៃសិទ្ធិរវាងបុរស និងស្ត្រី ។

*មានកង្វល់ថា* ទោះបីមានលិខិតុបករណ៍ទាំងនេះហើយក្តី ក៏ការរើសអើងដ៏រីករាលដាលប្រឆាំងនឹងស្ត្រីភេទ នៅតែបន្តកើតមាន ។

*រំលឹកឡើងវិញថា* ការរើសអើងប្រឆាំងនឹងស្ត្រីភេទ រំលោភលើគោលការណ៍សមភាពនៃសិទ្ធិ និងការគោរពសេចក្តីថ្លៃថ្នូររបស់មនុស្ស ជាឧបសគ្គដល់ការចូលរួមរបស់ស្ត្រី ក្នុងល័ក្ខខ័ណ្ឌស្មើភាពគ្នាជាមួយបុរសក្នុងជីវភាពនយោបាយ សង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌នៃប្រទេសរបស់ខ្លួន ធ្វើឱ្យរាំងស្ទះដល់ការរីកចម្រើននៃភាពសំបូណ៌រុងរឿងរបស់សង្គម និងគ្រួសារ ហើយបង្កឧបសគ្គដល់ការអភិវឌ្ឍន៍ពេញលេញនៃសក្តានុភាពរបស់ស្ត្រី ក្នុងការបម្រើប្រទេសរបស់ខ្លួន និងមនុស្សជាតិ ។

*មានកង្វល់ថា* ក្នុងស្ថានភាពក្រីក្រ ស្ត្រីភេទបានទទួលតិចបំផុតនូវម្ហូបអាហារ សេវាសុខាភិបាល ការអប់រំ ការហ្វឹកហ្វឺន និងឱកាសរកការងារធ្វើ ហើយនិងសេចក្តីត្រូវការដទៃទៀត ។

*ជឿជាក់ថា* ការបង្កើតប្រព័ន្ធសេដ្ឋកិច្ចអន្តរជាតិថ្មី ផ្អែកលើមូលដ្ឋានសមភាព និងយុត្តិធម៌ នឹងរួមចំណែកយ៉ាងសំខាន់ដល់ការលើកស្ទួយសមភាពរវាងបុរស និងស្ត្រី ។

*គូសបញ្ជាក់ថា* ការលប់បំបាត់ចោលរបបអាប៉ាថេត គ្រប់ទម្រង់ពូជសាសន៍និយម ការរើសអើងពូជសាសន៍ អាណានិគមនិយម អាណានិគមនិយមបែបថ្មី ការឈ្លានពាន ការកាន់កាប់ និងជិះជាន់ដោយបរទេស និងការជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋ គឺជាការចាំបាច់ដល់ការអាស្រ័យផលពេញលេញ ពីសិទ្ធិរបស់បុរស និងស្ត្រី ។

*អះអាងថា* ការពង្រឹងសន្តិភាព និងសន្តិសុខអន្តរជាតិ ការបន្ធូរភាពតានតឹងអន្តរជាតិ សហប្រតិបត្តិការទៅវិញទៅមករវាងរដ្ឋទាំងអស់ ដោយមិនគិតដល់ប្រព័ន្ធសេដ្ឋកិច្ច និងសង្គមកិច្ចរបស់រដ្ឋទាំងនោះ ការដកហូតអាវុធជាទូទៅ និងទាំងស្រុង ជាពិសេសការដកហូតអាវុធនុយក្លេអ៊ែរ ក្រោមការត្រួតពិនិត្យហ្មត់ចត់ និងដោយប្រសិទ្ធភាពពីអន្តរជាតិ ការអះអាងនូវគោលការណ៍យុត្តិធម៌ សមភាពនិងអត្ថប្រយោជន៍ទៅវិញទៅមក ក្នុងទំនាក់ទំនងរវាងប្រទេសទាំងឡាយ និងការសម្រេចបាននូវសិទ្ធិស្វ័យសម្រេច និងឯករាជ្យភាពរបស់ប្រជាជាតិក្រោមការជិះជាន់ និងអាណានិគមបរទេស និងការកាន់កាប់ដោយបរទេស ហើយនិងការគោរពអធិបតេយ្យភាពជាតិ និងបូរណភាពទឹកដី នឹងលើកស្ទួយវឌ្ឍនភាព និងការអភិវឌ្ឍន៍សង្គម ហើយផលនេះ នឹងរួមចំណែកដល់ការធ្វើឱ្យសម្រេចបាននូវសមភាពពេញលេញរវាងបុរសនិងស្ត្រី ។

*ជឿជាក់ថា* ការអភិវឌ្ឍន៍យ៉ាងពេញលេញរបស់ប្រទេសមួយ សុខមាលភាពរបស់ពិភពលោក និងបុព្វហេតុសន្តិភាព ត្រូវការឱ្យមានការចូលរួមជាអតិបរិមារបស់ស្ត្រី ដោយសមភាពជាមួយបុរសនៅក្នុងវិស័យទាំងអស់ ។

*ចងចាំថា* វិភាគទានធំធេងរបស់ស្ត្រី ចំពោះសុខមាលភាព គ្រួសារ និងការអភិវឌ្ឍន៍នៃសង្គម ដែលមិនបានទទួលស្គាល់ពេញលេញមកទល់ពេលនេះ សារសំខាន់ខាងសង្គមនៃមាតុភាព និងតួនាទីរបស់ឪពុកម្តាយក្នុងគ្រួសារ និងក្នុងការអប់រំកូន និង*ដឹងថា* តួនាទីរបស់ស្ត្រីក្នុងការបង្កើតកូនមិនគួរជាមូលហេតុនៃការរើសអើងទេ ប៉ុន្តែការអប់រំកូន តម្រូវឱ្យចែករំលែកការទទួលខុសត្រូវរវាងបុរស និងស្ត្រី និងសង្គមទាំងមូល ។

*ដឹងថា* តួនាទីជាប្រពៃណីរបស់បុរស និងស្ត្រីនៅក្នុងសង្គម និងគ្រួសារ ចាំបាច់ត្រូវមានការផ្លាស់ប្តូរ ដើម្បីធ្វើឱ្យសម្រេចបាននូវសមភាពពេញលេញរវាងបុរស និងស្ត្រី ។

*ប្តេជ្ញាចិត្ត* អនុវត្តគោលការណ៍ទាំងឡាយ ដែលមានចែងក្នុងសេចក្តីប្រកាសស្តីពីការបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ ហើយដើម្បីគោលបំណងនោះ អនុម័តវិធានការចាំបាច់នានា ដើម្បីលប់បំបាត់ចោលការរើសអើងគ្រប់ទម្រង់ និងគ្រប់ការសម្តែងចេញ។

បានព្រមព្រៀងគ្នាតទៅ :

## ផ្នែកទី ១

### មាត្រា ១

ដើម្បីបម្រើគោលដៅនៃអនុសញ្ញានេះ ពាក្យ "ការរើសអើងប្រឆាំងស្ត្រីភេទ" សំដៅដល់ការប្រកាន់បែងចែក ការផាត់ចេញ ឬការរឹតត្បិតផ្អែកលើភេទ ដែលមានអានុភាព ឬមានបំណងធ្វើឱ្យខូចខាត ឬធ្វើឱ្យមោឃៈនូវការទទួលស្គាល់ ការអាស្រ័យផល ឬការប្រើប្រាស់ដោយស្ត្រី ដោយឥតគិតដល់ស្ថានភាពអាពាហ៍ពិពាហ៍របស់ស្ត្រី ផ្អែកលើមូលដ្ឋានសមភាពរវាងបុរស និងស្ត្រី នូវសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងពលរដ្ឋ ឬក្នុងវិស័យដទៃទៀត ។

### មាត្រា ២

រដ្ឋភាគី ផ្តន្ទាទោសការរើសអើងប្រឆាំងស្ត្រីភេទក្នុងគ្រប់ទម្រង់ ព្រមព្រៀងគ្នាអនុវត្តគោលនយោបាយ តាមមធ្យោបាយសមស្រប និងដោយឥតពន្យាពេល ដើម្បីឈានទៅលប់បំបាត់ការរើសអើងប្រឆាំងស្ត្រីភេទ ហើយក្នុងទិសដៅនេះ សន្យាថា :

(ក) បញ្ចូលគោលការណ៍សមភាពរវាងបុរស និងស្ត្រី ទៅក្នុងរដ្ឋធម្មនុញ្ញ ឬច្បាប់ជាតិសមស្របឯទៀត ប្រសិនបើមិនទាន់បានបញ្ចូលនៅឡើយ និងធានាតាមផ្លូវច្បាប់ ឬមធ្យោបាយសមស្របដទៃទៀត ដើម្បីធ្វើឱ្យគោលការណ៍នេះ បានសម្រេចជាក់ស្តែង ។

(ខ) អនុម័តបទបញ្ញត្តិ និងវិធានការច្បាប់ និងវិធានការសមស្របផ្សេងៗ រួមមានទណ្ឌកម្មផងបើចាំបាច់ ដើម្បីហាមឃាត់ការរើសអើងទាំងអស់ប្រឆាំងនឹងស្ត្រី។

(គ) បង្កើតកិច្ចការពារសិទ្ធិរបស់ស្ត្រីតាមផ្លូវច្បាប់ ផ្អែកលើមូលដ្ឋានសមភាពជាមួយបុរស និងធានាការពារដោយស័ក្តិសិទ្ធិដល់ស្ត្រី ប្រឆាំងនឹងអំពើរើសអើង តាមរយៈសាលាជំរះក្តីជាតិដែលមានសមត្ថកិច្ច និងស្ថាប័នសាធារណៈដទៃទៀត។

(ឃ) ទប់មិនឱ្យធ្វើអំពើ ឬការអនុវត្តន៍ដែលមានលក្ខណៈរើសអើងប្រឆាំងនឹងស្ត្រី និងធានាថាអាជ្ញាធរ និងស្ថាប័នសាធារណៈ ធ្វើសកម្មភាពស្របតាមកាតព្វកិច្ចនេះ ។

(ង) ចាត់វិធានការសមស្របទាំងអស់ ដើម្បីលប់បំបាត់ចោលការរើសអើងប្រឆាំងនឹងស្ត្រីដែលធ្វើឡើងដោយបុគ្គល អង្គការ ឬសហគ្រាសណាមួយ។

(ច) ចាត់វិធានការសមស្របទាំងអស់ រួមទាំងការធ្វើច្បាប់ផង ដើម្បីកែប្រែ ឬដាក់ឱ្យនិរាករណ៍ច្បាប់ បទបញ្ញា ទម្លាប់ និងការអនុវត្តន៍ណាដែលបង្កើតការរើសអើងប្រឆាំងនឹងស្ត្រី។

(ឆ) ដាក់ឱ្យនិរាករណ៍បទបញ្ញត្តិព្រហ្មទណ្ឌណា ដែលបង្កើតជាការរើសអើងប្រឆាំងនឹងស្ត្រី ។

## មាត្រា ៣

ក្នុងគ្រប់វិស័យ ជាពិសេស វិស័យនយោបាយ សង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌ រដ្ឋត្រូវចាត់វិធានការសមស្របទាំងអស់ រួមមានការធ្វើច្បាប់ផង ដើម្បីធានាការអភិវឌ្ឍន៍ និងការរីកចំរើនពេញលេញរបស់ស្ត្រី ដើម្បីធានាឱ្យស្ត្រីប្រើប្រាស់ និងអាស្រ័យផលសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានដោយសមភាពជាមួយបុរស ។

## មាត្រា ៤

១. ការអនុម័តដោយរដ្ឋភាគី នូវវិធានការពិសេសបណ្តោះអាសន្ន ដើម្បីពន្លឿនការកសាងសមភាពរវាងបុរស និងស្ត្រី មិនត្រូវចាត់ទុកជាការរើសអើងដូចបានចែងក្នុងអនុសញ្ញានេះទេ ប៉ុន្តែទោះតាមបែបណាមួយក៏ដោយ មិនត្រូវមានន័យថា រក្សាទុកបទដ្ឋានវិសមភាព ឬដាច់ដោយឡែកឡើយ វិធានការទាំងនេះ ត្រូវដាក់ឱ្យនិរាករណ៍នៅពេលគោលដៅខាងសមភាពនៃឱកាស និងនៃការប្រព្រឹត្តមកលើស្ត្រីបានសម្រេចហើយ ។

២. ការអនុម័តដោយរដ្ឋភាគីនូវវិធានការពិសេស រួមមានវិធានការទាំងឡាយ ដែលមានក្នុងអនុសញ្ញានេះផង ដើម្បីការពារមាតុភាព មិនត្រូវចាត់ទុកជាការរើសអើងឡើយ ។

## មាត្រា ៥

រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ ដើម្បីៈ

(ក) កែប្រែផ្នត់គំនិតឥរិយាបថសង្គម និងវប្បធម៌របស់បុរស និងស្ត្រី ដើម្បីសម្រេចបាននូវការលប់បំបាត់ចោលសេចក្តីលំអៀង និងទំលាប់ និងការអនុវត្តជាទម្លាប់ផ្សេងៗទៀត ផ្អែកលើគំនិតស្តីពីភាពទាបជាង ឬខ្ពស់ជាងរបស់ភេទណាមួយ ឬលើតួនាទីជាទំលាប់សម្រាប់បុរស និងស្ត្រី ។

(ខ) ធានាថា ការអប់រំគ្រួសារ មានរាប់បញ្ចូលការយល់ដឹងត្រឹមត្រូវអំពីមាតុភាព ដែលជាមុខងាររបស់សង្គម និងការទទួលស្គាល់ការទទួលខុសត្រូវរួមរបស់បុរស និងស្ត្រី ក្នុងការចិញ្ចឹមកូន និងការអភិវឌ្ឍន៍របស់កូន ហើយប្រការនេះ ក៏ត្រូវមានការយល់ថា ប្រយោជន៍របស់កុមារ គឺជាល័ក្ខខ័ណ្ឌចម្បងក្នុងគ្រប់ករណីទាំងអស់ ។

## មាត្រា ៦

រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ រួមមានការធ្វើច្បាប់ផង ដើម្បីបង្ក្រាបគ្រប់ទម្រង់នៃការជួញដូរស្ត្រី និងអាជីវកម្មពេស្យាកម្មលើស្ត្រី ។

## ផ្នែកទី ២

### មាត្រា ៧

រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្រប ដើម្បីលុបបំបាត់ចោលការរើសអើងប្រឆាំងនឹងស្ត្រី ក្នុងជីវភាពនយោបាយ និងសាធារណៈរបស់ប្រទេស និងជាពិសេស ត្រូវធានាដល់ស្ត្រីនូវលក្ខខណ្ឌស្មើភាពជាមួយបុរសនូវសិទ្ធិ :

(ក) បោះឆ្នោតនៅគ្រប់ការបោះឆ្នោត និងការធ្វើប្រជាមតិសាធារណៈ និងមានសិទ្ធិឈរឈ្មោះបោះឆ្នោតសម្រាប់អង្គការសាធារណៈ ដែលជ្រើសរើសដោយបោះឆ្នោត ។

(ខ) ចូលរួមតាក់តែងគោលនយោបាយរបស់រដ្ឋ និងការអនុវត្តន៍គោលនយោបាយ កាន់មុខការសាធារណៈ និងបំពេញមុខងារសាធារណៈ នៅគ្រប់កម្រិតជាន់ថ្នាក់របស់រដ្ឋាភិបាល ។

(គ) ចូលរួមក្នុងអង្គការ និងសមាគមក្រៅរដ្ឋាភិបាល ដែលពាក់ព័ន្ធនឹងជីវភាពសាធារណៈ និងនយោបាយរបស់ប្រទេសជាតិ ។

### មាត្រា ៨

រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ ដើម្បីធានាឱ្យស្ត្រីមានឱកាសធ្វើជាតំណាងរដ្ឋាភិបាលនៅថ្នាក់អន្តរជាតិ និងចូលរួមក្នុងកិច្ចការរបស់អង្គការអន្តរជាតិ ដោយផ្អែកលើលក្ខខណ្ឌស្មើភាពជាមួយបុរស និងដោយគ្មានការរើសអើង ។

### មាត្រា ៩

១. រដ្ឋភាគី ត្រូវផ្តល់ឱ្យស្ត្រីនូវសិទ្ធិស្មើគ្នានឹងបុរស ក្នុងការទទួលផ្លាស់ប្តូរ ឬរក្សាទុកសញ្ជាតិរបស់ខ្លួន ។ រដ្ឋភាគី ត្រូវធានាជាពិសេសថា ការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ឬការផ្លាស់ប្តូរសញ្ជាតិរបស់ប្តីក្នុងពេលអាពាហ៍ពិពាហ៍ មិនធ្វើឱ្យផ្លាស់ប្តូរជាស្វ័យប្រវត្តិនូវសញ្ជាតិរបស់ប្រពន្ធ មិនធ្វើឱ្យប្រពន្ធគ្មានសញ្ជាតិ ឬបង្ខំឱ្យប្រពន្ធយកសញ្ជាតិរបស់ប្តីឡើយ ។

២. រដ្ឋភាគី ត្រូវផ្តល់ឱ្យស្ត្រីនូវសិទ្ធិស្មើគ្នានឹងបុរស ក្នុងការសម្រេចពីសញ្ជាតិរបស់កូនផងដែរ ។

## ផ្នែកទី ៣

### មាត្រា ១០

រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ ដើម្បីលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី ដើម្បីធានាឱ្យស្ត្រីមានសិទ្ធិស្មើគ្នានឹងបុរសក្នុងវិស័យអប់រំ និងជាពិសេស ដើម្បីធានាដល់ស្ត្រី ដោយផ្អែកលើមូលដ្ឋាននៃសមភាពរវាងបុរស និងស្ត្រី នូវ :

(ក) លក្ខខណ្ឌដូចគ្នាសម្រាប់មុខរបរ និងការណែនាំខាងវិជ្ជាជីវៈ សម្រាប់ការទទួលការសិក្សា និងសម្រាប់ការទទួលបាននូវសញ្ញាប័ត្រក្នុងគ្រឹះស្ថានអប់រំគ្រប់ប្រភេទ ទាំងនៅជនបទទាំងនៅទីក្រុង ។ សមភាពនេះ ត្រូវធានាឱ្យមានក្នុងការអប់រំមុនបឋមសិក្សា ការអប់រំចំណេះទូទៅ បច្ចេកទេសវិជ្ជាជីវៈ និងបច្ចេកទេសជាន់ខ្ពស់ និងការបណ្តុះបណ្តាលវិជ្ជាជីវៈមធ្យមគ្រប់ផ្នែកផងដែរ ។

(ខ) សិទ្ធិទទួលកម្មវិធីសិក្សាអប់រំដូចគ្នា ការប្រឡងដូចគ្នា បុគ្គលិកបង្រៀនដែលមានគុណសម្បត្តិដូចគ្នា និងបរិវេណ និងសម្ភារៈសិក្សាដែលមានគុណភាពដូចគ្នា ។

(គ) ការលុបបំបាត់រាល់ទស្សនៈជាទំលាប់ស្តីពីតួនាទីរបស់បុរស និងស្ត្រី នៅគ្រប់កម្រិត និងគ្រប់ទម្រង់នៃការអប់រំ ដោយលើកទឹកចិត្តដល់ការអប់រំរួមគ្នា និងប្រភេទផ្សេងៗទៀតនៃការអប់រំ ដែលជួយឱ្យសម្រេចគោលបំណងនេះ និងជាពិសេស ដោយពិនិត្យកែប្រែឡើងវិញនូវអត្ថបទសិក្សា និងកម្មវិធីសិក្សា និងសម្របសម្រួលវិធីសាស្ត្របង្រៀន ។

(ឃ) ឱកាសដូចគ្នា ក្នុងការទទួលអាហារូបករណ៍ និងប្រាក់សម្រាប់ការសិក្សាផ្សេងៗ ។

(ង) ឱកាសដូចគ្នា ក្នុងការទទួលកម្មវិធីអប់រំអចិន្ត្រៃយ៍ រួមមានកម្មវិធីអក្ខរកម្មសំរាប់នីតិជន និងអនក្ខរៈជនផង ជាពិសេស កម្មវិធីទាំងឡាយសំដៅកាត់បន្ថយឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាននូវគម្លាតណាមួយខាងការអប់រំដែលមានរវាងបុរស និងស្ត្រី ។

(ច) ការបន្ថយអត្រាបោះបង់ការសិក្សារបស់សិស្សស្រី និងការរៀបចំកម្មវិធីសម្រាប់យុវនារី និងស្ត្រីដែលឆាប់បោះបង់ការសិក្សា ។

(ឆ) ឱកាសដូចគ្នា ក្នុងការចូលរួមយ៉ាងសកម្មក្នុងកីឡា និងកាយសិក្សា ។

(ជ) ការទទួលបានព័ត៌មានអប់រំពិសេសជាក់លាក់ ដើម្បីជួយធានាសុខភាព និងសុខមាលភាពគ្រួសារ រួមមានព័ត៌មាន និងដំបូន្មានស្តីពីផែនការគ្រួសារផង ។

## មាត្រា ១១

១. រដ្ឋភាគីត្រូវចាត់វិធានការសមស្របទាំងអស់ ដើម្បីបំបាត់ការរើសអើងប្រឆាំងស្ត្រីក្នុងវិស័យការងារ ដើម្បីធានា ដោយផ្អែកលើមូលដ្ឋានសមភាពរវាងបុរស និងស្ត្រីនូវសិទ្ធិដូចគ្នា និងជាពិសេស :

(ក) សិទ្ធិធ្វើការងារដែលជាសិទ្ធិមិនអាចលក់ ដូរ ផ្ទេរ ឬដកហូតបានរបស់មនុស្សជាតិគ្រប់រូប ។

(ខ) សិទ្ធិមានឱកាសធ្វើការងារដូចគ្នា រួមមានការអនុវត្តនូវលក្ខណៈវិនិច្ឆ័យដូចគ្នាផង ក្នុងការជ្រើសរើសឱ្យធ្វើការងារ ។

(គ) សិទ្ធិជ្រើសរើសដោយសេរីនូវវិជ្ជាជីវៈ និងការងារ សិទ្ធិឡើងស័ក្តិ សិទ្ធិមានស្ថិរភាពការងារ ទទួលប្រាក់បំណាច់ និងល័ក្ខខ័ណ្ឌការងារ សិទ្ធិទទួលការបណ្តុះបណ្តាល និងវិក្រិតការវិជ្ជាជីវៈ រួមមានការហ្វឹកហាត់ការងារ សុក្រឹតការខាងវិជ្ជាជីវៈ និងការបណ្តុះបណ្តាលជាអចិន្ត្រៃយ៍ផង ។

(ឃ) សិទ្ធិក្នុងការទទួលប្រាក់បំណាច់ស្មើគ្នា រួមទាំងផលប្រយោជន៍ និងសិទ្ធិទទួលបានការគិតគូរស្មើគ្នាចំពោះការងារដែលមានតម្លៃស្មើគ្នា និងសិទ្ធិទទួលបានការគិតគូរស្មើគ្នា លើការវាយតម្លៃគុណភាពការងារ ។

(ង) សិទ្ធិទទួលបានសន្តិសុខសង្គម ជាពិសេស ផលប្រយោជន៍សម្រាប់ការចូលនិវត្តន៍ ការគ្មានការងារធ្វើ ការមានជំងឺ ការគ្មានសុពលភាព និងជរាពាធិ ឬបាត់បង់សមត្ថភាពការងារដទៃទៀត ព្រមទាំងសិទ្ធិឈប់សម្រាកដោយមានប្រាក់ឈ្នួល ។

(ច) សិទ្ធិទទួលបានការការពារសុខភាព និងសុវត្ថិភាពក្នុងល័ក្ខខ័ណ្ឌការងារ រួមមានការការពារមុខងារបន្តពូជផង ។

២. ដើម្បីបង្ការការរើសអើងប្រឆាំងនឹងស្ត្រីផ្អែកលើអាពាហ៍ពិពាហ៍ ឬមាតុភាព និងដើម្បីធានាសិទ្ធិធ្វើការងាររបស់ស្ត្រីឱ្យបានស័ក្តិសិទ្ធិ រដ្ឋភាគីសន្យាចាត់វិធានការសមស្រប ដើម្បី ៖

(ក) ហាមឃាត់ ដោយដាក់ទណ្ឌកម្មនូវការបណ្តេញចេញពីការងារ ដោយមូលហេតុមានគភ៌ ឬការឈប់សម្រាកមាតុភាព និងការរើសអើងក្នុងការបណ្តេញចេញពីការងារ ដោយផ្អែកលើស្ថានភាពរៀបអាពាហ៍ពិពាហ៍ ។

(ខ) ផ្តល់ការឈប់សម្រាកមាតុភាព ដោយមានប្រាក់ឈ្នួល ឬប្រាក់បំណាច់សង្គមកិច្ចស្មើគ្នា ដោយគ្មានការបាត់បង់ការងារ អតីតភាពការងារ ឬជំនួយសង្គមកិច្ច ។

(គ) ជំរុញការផ្តល់សេវាគាំពារសង្គមកិច្ចចាំបាច់ ដើម្បីឱ្យឪពុកម្តាយ អាចបញ្ចូលកាតព្វកិច្ចគ្រួសារ ជាមួយនឹងការទទួលខុសត្រូវខាងវិជ្ជាជីវៈ និងការចូលរួមក្នុងជីវភាពសាធារណៈ ជាពិសេសដោយសម្រួលដល់ការបង្កើត និងការអភិវឌ្ឍន៍បណ្តាញនៃសម្ភារៈរូបវន្តសម្រាប់ថែទាំកុមារ ។

(ឃ) ផ្តល់ការការពារពិសេសដល់ស្ត្រីកំពុងមានគភ៌ ពីប្រភេទការងារទាំងឡាយណា ដែលបញ្ជាក់ឱ្យឃើញថាមានគ្រោះថ្នាក់ដល់ពួកគេ ។

៣. ច្បាប់ការពារស្ត្រីទាក់ទងនឹងបញ្ហាដែលបានចែងក្នុងមាត្រានេះ ត្រូវលើកយកមកពិនិត្យឡើងវិញជាទៀងទាត់ ទៅតាមចំណេះដឹងផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេស និងត្រូវសើរើ ធ្វើនិរាករណ៍ ឬអនុវត្តបន្តទៅតាមការចាំបាច់ ។

## មាត្រា ១២

១. រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ ដើម្បីបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី ក្នុងវិស័យថែទាំសុខភាព ដើម្បីធានានូវសិទ្ធិទទួលសេវាសុខាភិបាល រួមមានមធ្យោបាយទាក់ទងនឹងផែនការគ្រួសារផង ដោយផ្អែកលើមូលដ្ឋានសមភាពរវាងបុរស និងស្ត្រី ។

២. ក្រៅពីបទបញ្ញត្តិដែលចែងក្នុងកថាខណ្ឌ១ នៃមាត្រានេះ រដ្ឋភាគីត្រូវធានាដល់ស្ត្រីកំពុងមានគភ៌ កំពុងសំរាលកូន និងក្រោយពេលសំរាលកូន នូវការផ្តល់សេវាសមស្រប បើចាំបាច់ ដោយឥតគិតថ្លៃ ព្រមទាំងអាហាររូបត្ថម្ភគ្រប់គ្រាន់ក្នុងរយៈពេលមានគភ៌ និងពេលបំបៅកូន ។

## មាត្រា ១៣

រដ្ឋភាគី ត្រូវចាត់វិធានការសមស្របនានា ដើម្បីបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី ក្នុងវិស័យជីវភាព សេដ្ឋកិច្ច និងសង្គមកិច្ចផ្សេងទៀត ដើម្បីធានានូវសិទ្ធិដូចគ្នា ដោយផ្អែកលើមូលដ្ឋានសមភាពរវាងបុរស និងស្ត្រី ជាពិសេស :

(ក) សិទ្ធិទទួលបានផលប្រយោជន៍សម្រាប់គ្រួសារ

(ខ) សិទ្ធិខ្ចីប្រាក់ពីធនាគារ អ៊ីប៉ូតែក និងទម្រង់ផ្សេងៗទៀតនៃឥណទានហិរញ្ញវត្ថុ

(គ) សិទ្ធិចូលរួមក្នុងសកម្មភាពកំសាន្ត កីឡា និងគ្រប់ទិដ្ឋភាពនៃជីវភាពវប្បធម៌ ។

## មាត្រា ១៤

១. រដ្ឋភាគី ត្រូវគិតគូរដល់បញ្ហាពិសេសដែលស្ត្រីនៅជនបទប្រឈមមុខ និងតួនាទីសំខាន់របស់ស្ត្រីជនបទ ក្នុងការរក្សាភាពគង់វង្សសេដ្ឋកិច្ចគ្រួសាររបស់ខ្លួន រួមមានការងាររបស់ពួកគេ ក្នុងផ្នែកគ្មានចំណូលសេដ្ឋកិច្ចផង ។ រដ្ឋភាគី ត្រូវចាត់វិធានការសមស្របទាំងអស់ ដើម្បីធានាការអនុវត្តន៍បទបញ្ញត្តិនៃអនុសញ្ញានេះ ចំពោះស្ត្រីនៅជនបទ ។

២. រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ ដើម្បីបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីនៅជនបទ ដើម្បីធានានូវការចូលរួមរបស់ស្ត្រីក្នុងការអភិវឌ្ឍន៍ជនបទ និងទទួលអត្ថប្រយោជន៍ពីការអភិវឌ្ឍន៍ជនបទ ដោយផ្អែកលើមូលដ្ឋានសមភាពរវាងបុរស និងស្ត្រី និងជាពិសេស ត្រូវធានាឱ្យស្ត្រីជនបទទាំងនោះនូវសិទ្ធិ :

(ក) ចូលរួមពេញលេញក្នុងការតាក់តែង និងអនុវត្តផែនការអភិវឌ្ឍន៍នៅគ្រប់លំដាប់ថ្នាក់ ។

(ខ) មានសិទ្ធិទទួលបានសេវាគ្រប់គ្រាន់ខាងវិស័យសុខាភិបាល រួមទាំងព័ត៌មាន ដំបូន្មាន និងសេវាខាងផែនការគ្រួសារ ។

(គ) ទទួលអត្ថប្រយោជន៍ដោយផ្ទាល់ពីកម្មវិធីសន្តិសុខសង្គម ។

(ឃ) ទទួលបានការបណ្តុះបណ្តាល និងការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធគ្រប់ប្រភេទ រួមមានការអប់រំអក្ខរកម្មបង្កើតមុខរបរផង ព្រមទាំងជាពិសេសអត្ថប្រយោជន៍ខាងសេវាសហគមន៍ និងការពន្យល់ផ្សព្វផ្សាយរបស់ថ្មី ដើម្បីបង្កើនសមត្ថភាពបច្ចេកទេសរបស់ស្ត្រី ។

(ង) រៀបចំក្រុម និងសហករណ៍ ជួយគ្នាទៅវិញទៅមក ដើម្បីឱ្យមានសិទ្ធិមានឱកាសខាងសេដ្ឋកិច្ចស្មើគ្នា តាមរយៈការងារមានប្រាក់ឈ្នួល ឬការងារឯករាជ្យ ។

(ច) ចូលរួមក្នុងគ្រប់សកម្មភាពរបស់សហគមន៍ ។

(ឆ) មានសិទ្ធិទទួលបានឥណទាន និងប្រាក់កម្ចីខាងកសិកម្ម សេវារកទីផ្សារ បច្ចេកវិជ្ជាសមស្រប និងការគិតគូរស្មើគ្នាក្នុងការកែទម្រង់ដីធ្លី និងកសិកម្ម ព្រមទាំងក្នុងគម្រោងបែងចែកដីធ្លី ។

(ជ) អាស្រ័យផលលក្ខខណ្ឌរស់នៅគ្រប់គ្រាន់ ជាពិសេស ទាក់ទងនឹងការមានផ្ទះសម្បែង អនាម័យ ការផ្គត់ផ្គង់អគ្គិសនី និងទឹក ការដឹកជញ្ជូន និងគមនាគមន៍ ។

## ផ្នែកទី ៤

### មាត្រា ១៥

១. រដ្ឋភាគី ត្រូវផ្តល់ឱ្យស្ត្រីនូវសមភាពជាមួយបុរសនៅចំពោះមុខច្បាប់ ។

២. រដ្ឋភាគី ត្រូវផ្តល់ឱ្យស្ត្រីក្នុងបញ្ហារដ្ឋប្បវេណី នូវឋានៈនីត្យានុកូលដូចគ្នានឹងបុរស និងមានឱកាសដូចគ្នាដើម្បីប្រើប្រាស់ឋានៈនេះ ។ ជាពិសេស រដ្ឋភាគី ត្រូវផ្តល់ឱ្យស្ត្រីនូវសិទ្ធិស្មើគ្នា ក្នុងការចុះកិច្ចសន្យា និងការគ្រប់គ្រងទ្រព្យ និងត្រូវឱ្យមានការប្រព្រឹត្តមកលើស្ត្រីដូចគ្នា ក្នុងគ្រប់ដំណាក់កាលនៃនីតិវិធីរបស់តុលាការ និងសាលាជំរះក្តី ។

៣. រដ្ឋភាគីព្រមព្រៀងគ្នាថា កិច្ចសន្យាទាំងអស់ និងលិខិតុបករណ៍ឯកជនដទៃទៀតគ្រប់ប្រភេទ ដែលមានអានុភាពនីត្យានុកូល សំដៅរឹតត្បិតឋានៈនីត្យានុកូលរបស់ស្ត្រី ត្រូវទុកជាមោឃៈ ។

៤. រដ្ឋភាគី ត្រូវឱ្យបុរស និងស្ត្រី មានសិទ្ធិដូចគ្នាចំពោះច្បាប់ ដែលទាក់ទងដល់សិទ្ធិដើរហើររបស់បុគ្គល និងសេរីភាពជ្រើសរើសនិវេសនដ្ឋាន និងលំនៅដ្ឋាន ។

### មាត្រា ១៦

១. រដ្ឋភាគី ត្រូវចាត់វិធានការសមស្របទាំងអស់ ដើម្បីបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីលើរាល់បញ្ហាដែលទាក់ទងនឹងអាពាហ៍ពិពាហ៍ និងទំនាក់ទំនងគ្រួសារ និងជាពិសេស ដោយផ្អែកលើមូលដ្ឋានសមភាពរវាងបុរស និងស្ត្រី ត្រូវធានាឱ្យស្ត្រីនូវ :

(ក) សិទ្ធិដូចគ្នាក្នុងការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ។

(ខ) សិទ្ធិដូចគ្នាក្នុងការជ្រើសរើសសហព័ទ្ធរបស់ខ្លួនដោយសេរី និងក្នុងការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ តែនៅពេលណាដែលពួកគេព្រមព្រៀងគ្នាដោយសេរី និងដោយពេញលេញប៉ុណ្ណោះ ។

(គ) សិទ្ធិ និងការទទួលខុសត្រូវដូចគ្នា នៅពេលមានចំណងអាពាហ៍ពិពាហ៍ និងនៅពេលរំលាយអាពាហ៍ពិពាហ៍ ។

(ឃ) សិទ្ធិ និងការទទួលខុសត្រូវដូចគ្នា ក្នុងនាទីជាឪពុកម្តាយលើបញ្ហាទាក់ទងនឹងកូន ដោយឥតគិតពីស្ថានភាពគ្រួសារ ហើយអត្ថប្រយោជន៍របស់កូន ត្រូវស្ថិតជាចម្បងនៅគ្រប់ករណីទាំងអស់ ។

(ង) សិទ្ធិដូចគ្នាក្នុងការសម្រេចចិត្តដោយសេរី និងដោយស្មារតីទទួលខុសត្រូវ ក្នុងការសម្រេចអំពីចំនួន និងការពន្យារកំណើតកូន និងក្នុងការទទួលបានព័ត៌មាន ការអប់រំ និងមធ្យោបាយដើម្បីឱ្យស្ត្រីអាចប្រើប្រាស់សិទ្ធិទាំងនេះ ។

(ច) សិទ្ធិ និងការទទួលខុសត្រូវដូចគ្នា ចំពោះអាណាព្យាបាលភាព ការការពារ ការគ្រប់គ្រង និងការទទួលចិញ្ចឹមកូនអ្នកដទៃ ឬក្នុងការអនុវត្តន៍ស្រដៀងគ្នានេះ បើគំនិតទាំងនេះមានស្រាប់នៅក្នុងច្បាប់ជាតិ ។ នៅគ្រប់ករណីទាំងអស់ អត្ថប្រយោជន៍របស់កូនត្រូវចាត់ទុកជាចម្បង ។

(ឆ) សិទ្ធិបុគ្គលដូចគ្នារវាងប្តី និងប្រពន្ធ រួមមានសិទ្ធិជ្រើសរើសនាមត្រកូល វិជ្ជាជីវៈ និងមុខរបរផង ។

(ជ) សិទ្ធិដូចគ្នា សម្រាប់ទាំងពីរនាក់ប្តី និងប្រពន្ធ ចំពោះកម្មសិទ្ធិ ការទិញ ការចាត់ចែង ការគ្រប់គ្រង ការអាស្រ័យផល និងការប្រគល់ទ្រព្យសម្បត្តិ ទោះដោយមិនគិតថ្លៃក្តី ឬគិតថ្លៃក្តី ។

២. ការភ្ជាប់ពាក្យ និងការរៀបអាពាហ៍ពិពាហ៍កូន មិនត្រូវមានអានុភាពផ្លូវច្បាប់ទេ ហើយគេត្រូវចាត់វិធានការចាំបាច់ទាំងអស់ រួមមានការធ្វើច្បាប់ផង ដើម្បីកំណត់អាយុអប្បបរមា សម្រាប់រៀបអាពាហ៍ពិពាហ៍ ហើយចាំបាច់ត្រូវចុះបញ្ជីអាពាហ៍ពិពាហ៍នៅក្នុងបញ្ជីជាផ្លូវការ ។

## ផ្នែកទី ៥

## មាត្រា ១៧

១. ក្នុងគោលបំណងពិនិត្យការវិវឌ្ឍន៍ទៅមុខនៃការអនុវត្តន៍អនុសញ្ញានេះ គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីមួយ ត្រូវបានបង្កើតឡើង (ចាប់ពីនេះទៅ ប្រើត្រឹមពាក្យ “គណៈកម្មាធិការ”)។ គណៈកម្មាធិការនេះមានអ្នកជំនាញការ១៨រូប នៅពេលដែលអនុសញ្ញានេះ ចូលជាធរមាន។ បន្ទាប់ពីរដ្ឋភាគីទី៣៥ បានឱ្យសច្ចាប័ន ឬបានចូលជាសមាជិកនៃអនុសញ្ញានេះ គណៈកម្មាធិការនេះ នឹងមានអ្នកជំនាញការចំនួន២៣រូប ដែលមានសីលធម៌ និងមានសមត្ថកិច្ចខ្ពស់ ក្នុងវិស័យដែលត្រូវអនុវត្តអនុសញ្ញានេះ។ អ្នកជំនាញការ ត្រូវបោះឆ្នោតជ្រើសរើសដោយរដ្ឋភាគី ពីក្នុងចំណោមជនជាតិរបស់ខ្លួន និងត្រូវធ្វើការក្នុងឋានៈជាបុគ្គលឯកជន ដោយធ្វើការពិចារណាបែងចែក ទៅតាមភូមិសាស្ត្រដោយសមធម៌ និងឱ្យមានតំណាងទម្រង់ផ្សេងៗនៃអារ្យធម៌ ព្រមទាំងទៅតាមប្រព័ន្ធច្បាប់ធំៗផង ។

២. សមាជិករបស់គណៈកម្មាធិការ ត្រូវជ្រើសរើសតាមការបោះឆ្នោតសម្ងាត់ ពីបញ្ជីបេក្ខជន ដែលស្នើដោយរដ្ឋភាគី ។ រដ្ឋភាគីនីមួយៗ អាចដាក់ស្នើបេក្ខជនម្នាក់ក្នុងចំណោមជនជាតិរបស់ខ្លួន ។

៣. ការបោះឆ្នោតដំបូងបង្អស់ ត្រូវធ្វើឡើង៦ខែ ក្រោយពីកាលបរិច្ឆេទចូលជាធរមាននៃអនុសញ្ញានេះ ។ យ៉ាងតិច៣ខែ មុនកាលបរិច្ឆេទនៃការបោះឆ្នោតនីមួយៗ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវចេញលិខិតអញ្ជើញរដ្ឋភាគី ឱ្យដាក់ស្នើនាមបេក្ខជនរបស់ខ្លួនក្នុងរយៈពេល២ខែ ។ អគ្គលេខាធិការ ត្រូវរៀបចំតាមលំដាប់អក្ខរក្រម នូវបញ្ជីឈ្មោះបេក្ខជន ដែលស្នើដោយរដ្ឋភាគី ដោយបញ្ជាក់ឈ្មោះរដ្ឋភាគីដែលបានជ្រើសតាំងបេក្ខជនទាំងនោះ ហើយផ្ញើបញ្ជីនេះទៅគ្រប់រដ្ឋភាគី ។

៤. ការបោះឆ្នោតជ្រើសរើស ត្រូវធ្វើឡើងក្នុងសម័យប្រជុំរបស់រដ្ឋភាគី តាមការកោះអញ្ជើញដោយអគ្គលេខាធិការ នៅទីស្នាក់ការអង្គការសហប្រជាជាតិ ។ កូរ៉ុមសម្រាប់កិច្ចប្រជុំ គឺពីរភាគបីនៃរដ្ឋភាគី ។ បេក្ខជនដែលជាប់ជាសមាជិកគណៈកម្មាធិការ ត្រូវតែជាបេក្ខជនទទួលបានសម្លេងច្រើនបំផុត និងសម្លេងភាគច្រើនដាច់ខាត ពីតំណាងរបស់រដ្ឋភាគីដែលមានវត្តមាន និងបានបោះឆ្នោត ។

៥. សមាជិកគណៈកម្មាធិការ ត្រូវជ្រើសរើសតាមការបោះឆ្នោតសម្រាប់រយៈពេល៤ឆ្នាំ ។ ប៉ុន្តែអាណត្តិសមាជិក៩រូប ដែលជាប់នៅពេលបោះឆ្នោតលើកទី១ ត្រូវផុតកំណត់ក្នុងរយៈពេល២ឆ្នាំ ហើយឈ្មោះសមាជិកទាំង៩រូបនេះ ត្រូវចាប់ឆ្នោតជ្រើសរើសដោយប្រធានអង្គប្រជុំភ្លាមៗ បន្ទាប់ពីការបោះឆ្នោតលើកទី១ ។

៦. ការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការបន្ថែម៥រូប នឹងត្រូវធ្វើឡើងស្របតាមបទបញ្ញត្តិច្បាប់ក្នុងកថាខណ្ឌ២ កថាខណ្ឌ៣ និងកថាខណ្ឌ៤ នៃមាត្រានេះ បន្ទាប់ពីមានការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកលើកទី៣៥ ។ អាណត្តិសមាជិក២រូប នៃសមាជិកបន្ថែមដែលជាប់ឆ្នោត នឹងត្រូវផុតកំណត់ក្នុងរយៈពេល២ឆ្នាំ ហើយឈ្មោះសមាជិកទាំង២រូបនេះ ត្រូវជ្រើសរើសតាមការចាប់ឆ្នោតដោយប្រធានគណៈកម្មាធិការ ។

៧. ដើម្បីបំពេញកន្លែងទំនេរដោយចៃដន្យ រដ្ឋភាគីណាដែលមានអ្នកជំនាញការរបស់ខ្លួនឈប់បំពេញមុខងារជាសមាជិកគណៈកម្មាធិការ ត្រូវតែងតាំងអ្នកជំនាញការម្នាក់ទៀត ពីចំណោមជនជាតិខ្លួន ដោយមានការយល់ព្រមពីគណៈកម្មាធិការ ។

៨. សមាជិកគណៈកម្មាធិការត្រូវទទួលថវិកាពីធនធានរបស់អង្គការសហប្រជាជាតិ តាមចំណែក និងល័ក្ខខ័ណ្ឌដែលកំណត់ដោយមហាសន្និបាត អាស្រ័យលើសារសំខាន់នៃការងាររបស់គណៈកម្មាធិការ ។

៩. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវផ្តល់បុគ្គលិក និងសម្ភារៈរូបវន្តដែលចាំបាច់សម្រាប់គណៈកម្មាធិការបំពេញមុខងារឱ្យបានស័ក្តិសិទ្ធិ ស្របតាមអនុសញ្ញានេះ ។

## មាត្រា ១៨

១. រដ្ឋភាគី សន្យាដាក់ជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ ដើម្បីគណៈកម្មាធិការពិនិត្យនូវរបាយការណ៍ស្ដីពីវិធានការខាងនីតិកម្ម តុលាការ រដ្ឋបាល ឬវិធានការផ្សេងៗ ដែលបានអនុម័តផ្ដល់អានុភាពដល់បទបញ្ញត្តិនៃអនុសញ្ញានេះ ព្រមទាំងការរីកចម្រើនដែលសម្រេចបាន :

(ក) ក្នុងរយៈពេល១ឆ្នាំ ក្រោយពីការចូលជាធរមាននៃអនុសញ្ញា ចំពោះរដ្ឋដែលពាក់ព័ន្ធ ។

(ខ) បន្ទាប់មក យ៉ាងហោចណាស់រៀងរាល់៤ឆ្នាំម្ដង និងរបាយការណ៍បន្ថែម បើមានសេចក្ដីស្នើសុំរបស់គណៈកម្មាធិការ ។

២. របាយការណ៍ អាចបញ្ជាក់ពីកត្តា និងការលំបាក ដែលនាំឱ្យប៉ះពាល់ដល់ការបំពេញកាតព្វកិច្ចស្របតាមអនុសញ្ញានេះ ។

## មាត្រា ១៩

១. គណៈកម្មាធិការ ត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

២. គណៈកម្មាធិការត្រូវបោះឆ្នោតជ្រើសរើសមន្ត្រីការិយាល័យរបស់ខ្លួនសម្រាប់រយៈពេល២ឆ្នាំ ។

## មាត្រា ២០

១. គណៈកម្មាធិការ ត្រូវជួបប្រជុំជាធម្មតាមិនលើសពី ២សប្ដាហ៍ក្នុងមួយឆ្នាំៗ ដើម្បីពិនិត្យរបាយការណ៍ដែលស្នើឡើង ស្របតាមមាត្រា១៨ នៃអនុសញ្ញានេះ ។

២. សម័យប្រជុំគណៈកម្មាធិការ ត្រូវប្រារព្ធធ្វើជាធម្មតានៅទីស្នាក់ការនៃអង្គការសហប្រជាជាតិ ឬនៅកន្លែងសមស្របមួយផ្សេងពីនេះ អាស្រ័យដោយការកំណត់របស់គណៈកម្មាធិការ ។

## មាត្រា ២១

១. តាមរយៈក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម គណៈកម្មាធិការ ត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំជូនមហាសន្និបាតអង្គការសហប្រជាជាតិ អំពីសកម្មភាពរបស់ខ្លួន និងអាចផ្ដល់យោបល់ និងផ្ដល់អនុសាសន៍ទូទៅ ផ្អែកលើការពិនិត្យរបាយការណ៍ និងព័ត៌មានដែលទទួលបានពីរដ្ឋភាគី ។ ការផ្ដល់យោបល់ និងអនុសាសន៍ ត្រូវដាក់បញ្ចូលក្នុងរបាយការណ៍របស់គណៈកម្មាធិការ អមដោយមូលវិចារណ៍របស់រដ្ឋភាគីប្រសិនបើមាន ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនរបាយការណ៍របស់គណៈកម្មាធិការទៅគណៈកម្មការទទួលបន្ទុកស្ថានភាពស្ត្រី ដើម្បីជ្រាបជាព័ត៌មាន ។

## មាត្រា ២២

អង្គការឯកទេស មានសិទ្ធិមានជាតំណាងនៅពេលពិនិត្យ ការអនុវត្តន៍បទបញ្ញត្តិនៃអនុសញ្ញានេះ ដែលស្ថិតក្នុងក្របខ័ណ្ឌនៃសកម្មភាពរបស់ខ្លួន ។ គណៈកម្មាធិការ អាចអញ្ជើញអង្គការឯកទេសនានាឱ្យដាក់របាយការណ៍ស្តីពីការអនុវត្តន៍អនុសញ្ញានេះ ក្នុងវិស័យដែលស្ថិតក្នុងក្របខ័ណ្ឌនៃសកម្មភាពរបស់ខ្លួន ។

## ផ្នែកទី ៦

## មាត្រា ២៣

គ្មានចំណុចណាមួយក្នុងអនុសញ្ញានេះ ធ្វើឱ្យប៉ះពាល់ដល់បទបញ្ញត្តិ ដែលនាំឱ្យសម្រេចបាននូវអត្ថប្រយោជន៍ខាងសមភាពរវាងបុរស និងស្ត្រី ដែលអាចមានច្រើនជាងនេះ នៅក្នុង :

(ក) ច្បាប់របស់រដ្ឋភាគី ឬ

(ខ) អនុសញ្ញា សន្ធិសញ្ញា ឬកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀតដែលនៅជាធរមានក្នុងរដ្ឋនោះ។

## មាត្រា ២៤

រដ្ឋភាគី សន្យាអនុម័តគ្រប់វិធានការចាំបាច់ថ្នាក់ជាតិ ដើម្បីធ្វើឱ្យសម្រេចបាននូវការប្រើប្រាស់ឱ្យបានពេញលេញ នូវសិទ្ធិទាំងឡាយដែលទទួលស្គាល់ក្នុងអនុសញ្ញានេះ ។

## មាត្រា ២៥

១. អនុសញ្ញានេះ ត្រូវបើកចំហឱ្យរដ្ឋទាំងអស់ចុះហត្ថលេខា ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវចាត់តាំងជាអ្នកទទួលដំកល់ទុកអនុសញ្ញានេះ ។

៣. អនុសញ្ញានេះ ជាកម្មវត្ថុនៃការឱ្យសច្ចាប័ន ។ លិខិតុបករណ៍នៃការឱ្យសច្ចាប័នត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៤. អនុសញ្ញានេះ ត្រូវបើកចំហឱ្យរដ្ឋទាំងអស់សុំចូលជាសមាជិក ។ ការសុំចូលជាសមាជិកត្រូវធ្វើឡើងដោយការតំកល់លិខិតុបករណ៍សុំចូលជាសមាជិក នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

## មាត្រា ២៦

១. រដ្ឋភាគី អាចសុំសើរើអនុសញ្ញានេះបាននៅគ្រប់ពេលវេលា ដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

២. មហាសន្និបាតអង្គការសហប្រជាជាតិ ត្រូវសម្រេចលើវិធានការដែលត្រូវចាត់ ប្រសិនជាមានតាមសេចក្តីសុំនោះ ។

## មាត្រា ២៧

១. អនុសញ្ញានេះ ត្រូវចូលជាធរមាននៅថ្ងៃទីសាមសិប ក្រោយកាលបរិច្ឆេទនៃការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬការសុំចូលជាសមាជិកទី២០ នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

២. សម្រាប់រដ្ឋនីមួយៗដែលឱ្យសច្ចាប័នលើអនុសញ្ញានេះ ឬសុំចូលជាសមាជិកក្រោយពីការតំកល់លិខិតុបករណ៍នៃការឱ្យសច្ចាប័ន ឬការសុំចូលជាសមាជិកទី២០ អនុសញ្ញានេះនឹងត្រូវចូលជាធរមាននៅថ្ងៃទីសាមសិប ក្រោយកាលបរិច្ឆេទនៃការដាក់តំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬការសុំចូលជាសមាជិករបស់ខ្លួន ។

## មាត្រា ២៨

១. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវទទួល និងផ្សព្វផ្សាយដល់រដ្ឋទាំងអស់នូវអត្ថបទល័ក្ខខ័ណ្ឌដែលរដ្ឋបានធ្វើ នៅខណៈពេលឱ្យសច្ចាប័ន ឬសុំចូលជាសមាជិក ។

២. ល័ក្ខខ័ណ្ឌដែលមិនស្របតាមកម្មវត្ថុ និងគោលបំណងនៃអនុសញ្ញានេះ មិនត្រូវបានអនុញ្ញាតឱ្យធ្វើឡើយ ។

៣. ល័ក្ខខ័ណ្ឌទាំងឡាយអាចដកចេញទៅវិញបាននៅគ្រប់ពេលវេលា ដោយការជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលត្រូវជូនដំណឹងនេះបន្តដល់រដ្ឋទាំងអស់ ។ ការជូនដំណឹងជាលាយលក្ខណ៍អក្សរ ត្រូវមានប្រសិទ្ធភាពនៅថ្ងៃដែលបានទទួល ។

## មាត្រា ២៩

១. រាល់វិវាទរវាងរដ្ឋភាគីពីរ ឬច្រើនជាងនេះ ស្តីពីការបកស្រាយ ឬការអនុវត្តន៍អនុសញ្ញានេះ ដែលមិនអាចដោះស្រាយតាមរយៈការចរចារបាន ត្រូវដាក់ឱ្យមានការសម្រេចដោយអាជ្ញាកណ្តាល តាមសំណើរបស់ភាគីណាមួយនៃគូវិវាទនេះ ។ បើក្នុងរយៈពេល៦ខែ គិតចាប់ពីថ្ងៃស្នើឱ្យមានអាជ្ញាកណ្តាល ភាគីវិវាទមិនឯកភាពលើការរៀបចំអាជ្ញាកណ្តាលទេ ភាគីណាមួយនៃភាគីវិវាទទាំងនោះ អាចលើករឿងវិវាទទៅតុលាការយុត្តិធម៌អន្តរជាតិ តាមសេចក្តីស្នើសុំ ស្របតាមលក្ខន្តិកៈរបស់តុលាការ ។

២. រដ្ឋភាគីនីមួយៗ នៅពេលចុះហត្ថលេខា ឬឱ្យសច្ចាប័ន ឬសុំចូលជាសមាជិកនៃអនុសញ្ញានេះ អាចប្រកាសថា ខ្លួនមិនជាប់កាតព្វកិច្ចនឹងកថាខណ្ឌ១ នៃមាត្រានេះទេ ។ រដ្ឋភាគីឯទៀតនឹងមិនជាប់កាតព្វកិច្ចក្នុងកថាខណ្ឌ១ នេះ ជាមួយរដ្ឋភាគីណាដែលបានធ្វើល័ក្ខខ័ណ្ឌនេះឡើយ ។

៣. រដ្ឋភាគីណា ដែលធ្វើល័ក្ខខ័ណ្ឌស្របតាមកថាខណ្ឌ២ នៃមាត្រានេះ អាចដកល័ក្ខខ័ណ្ឌរបស់ខ្លួនវិញគ្រប់ពេល ដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

### មាត្រា ៣០

អនុសញ្ញានេះ ដែលមានអត្ថបទជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ មានតម្លៃស្មើគ្នា នឹងត្រូវតំកល់ទុកនៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

ជាបន្ទាល់នៃអនុសញ្ញានេះ បុណ្ណទូតដែលមានហត្ថលេខាខាងក្រោម ហើយដែលបានទទួលនូវការអនុញ្ញាតយ៉ាងត្រឹមត្រូវ បានចុះហត្ថលេខាលើអនុសញ្ញានេះ ។

# ១០-ឥ. ពិធីសារបន្ថែមលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ

ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ កាលពីថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៩៩
និងចូលជាធរមាននៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០០
កម្ពុជាក្លាយរដ្ឋភាគីនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០

រដ្ឋភាគីនៃពិធីសារនេះ

*កត់សំគាល់ឃើញថា* ធម្មនុញ្ញសហប្រជាជាតិអះអាងជាថ្មី នូវជំនឿលើសិទ្ធិមូលដ្ឋានរបស់មនុស្ស លើសេចក្តីថ្លៃថ្នូរ និងតម្លៃមនុស្ស និងលើសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី ។

*កត់សំគាល់ឃើញផងដែរថា* សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សប្រកាសថា មនុស្សគ្រប់រូបកើតមកមានសេរីភាព និងសមភាពក្នុងផ្នែកសេចក្តីថ្លៃថ្នូរ និងសិទ្ធិ ហើយថាមនុស្សគ្រប់រូបត្រូវទទួលបានសិទ្ធិ និងសេរីភាពទាំងអស់ ដែលមានចែងក្នុងសេចក្តីប្រកាសនោះ ដោយគ្មានការប្រកាន់បែងចែកណាមួយ រួមមានការបែងចែកខាងផ្លូវភេទផង ។

*រំលឹកឡើងវិញថា* កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស សេចក្តីសំរេចចិត្តលេខ២២០០A(XXI) ឧបសម្ព័ន្ធ និងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិដទៃទៀត ហាមឃាត់ការរើសអើងខាងផ្លូវភេទ ។

*រំលឹកឡើងវិញផងដែរថា* អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (“អនុសញ្ញា”) ដែលរដ្ឋភាគីទាំងឡាយនៃអនុសញ្ញានេះ ផ្តន្ទាទោសការរើសអើងប្រឆាំងស្ត្រីភេទ ក្នុងគ្រប់ទម្រង់ និងការព្រមព្រៀងគ្នាអនុវត្តគោលនយោបាយ តាមមធ្យោបាយសមស្រប និងដោយគ្មានការពន្យាពេល ដើម្បីឈានទៅលុបបំបាត់ការរើសអើងប្រឆាំងស្ត្រីភេទ ។

*អះអាងជាថ្មី* ការប្តេជ្ញាចិត្តរបស់ខ្លួន ដើម្បីធានាឱ្យស្ត្រីទទួលបានយ៉ាងពេញលេញ និងស្មើភាពគ្នានូវសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានទាំងអស់ និងចាត់វិធានការដ៏មានប្រសិទ្ធភាព ដើម្បីទប់ស្កាត់ការរំលោភលើសិទ្ធិសេរីភាពទាំងនេះ ។

បានព្រមព្រៀងគ្នាតទៅ :

## មាត្រា ១

រដ្ឋភាគីនៃពិធីសារនេះ (“រដ្ឋភាគី”) អាចប្រកាសទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ (គណៈកម្មាធិការ) ក្នុងការទទួល និងពិនិត្យបណ្តឹងដែលបានបញ្ជូនស្របតាមមាត្រា២ ។

## មាត្រា ២

បុគ្គលអាចដាក់ពាក្យបណ្ដឹងរបស់ខ្លួន ឬក្នុងនាមបុគ្គល ឬក្រុមបុគ្គលផ្សេងទៀត ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋភាគី ដែលបុគ្គលអះអាងថា ជាជនរងគ្រោះពីការរំលោភដោយរដ្ឋភាគីទៅលើសិទ្ធិណាមួយដែលមានចែងនៅក្នុងអនុសញ្ញានេះ ។ ប្រសិនបើបណ្ដឹងមួយ ធ្វើឡើងក្នុងនាមបុគ្គល ឬក្រុមបុគ្គល បណ្ដឹងនេះ ត្រូវតែមានការយល់ព្រមពីបុគ្គលទាំងនោះ បើពុំនោះទេ អ្នកប្ដឹងអាចបញ្ជាក់ អះអាងលើពាក្យបណ្ដឹងក្នុងនាមពួកគេ ដោយមិនចាំបាច់មានការយល់ព្រមឡើយ ។

## មាត្រា ៣

បណ្ដឹងត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ហើយមិនត្រូវជាបណ្ដឹងអនាមិកឡើយ ។ គណៈកម្មាធិការមិនទទួលបណ្ដឹងមកពិនិត្យទេ បើបណ្ដឹងនោះ ពាក់ព័ន្ធនឹងរដ្ឋភាគីនៃអនុសញ្ញា ដែលមិនមែនជាភាគីនៃពិធីសារនេះ ។

## មាត្រា ៤

១. គណៈកម្មាធិការមិនទទួលពិនិត្យបណ្ដឹងទេ លើកលែងតែមានការបញ្ជាក់ច្បាស់ថាបានប្រើប្រាស់អស់នូវដំណោះស្រាយទាំងប៉ុន្មានដែលមាននៅក្នុងស្រុក បើពុំនោះទេការប្រើប្រាស់ដំណោះស្រាយនេះបានអូសបន្លាយរយៈពេលយូរហួសហេតុ ឬមិនទំនងជានាំមកនូវការជួយឱ្យធូរស្បើយបានស័ក្តិសិទ្ធិ ។

២. គណៈកម្មាធិការត្រូវប្រកាសថាមិនទទួលដោះបណ្ដឹងទេ ប្រសិនបើ :

ក. បញ្ហាដដែលនេះ ត្រូវបានគណៈកម្មាធិការពិនិត្យរួចហើយ ឬត្រូវបាន និងកំពុងពិនិត្យ ស្របតាមនីតិវិធីនៃការស៊ើបអង្កេត ឬការដោះស្រាយជាអន្តរជាតិ ។

ខ. ជាប្រការផ្ទុយនឹងបទបញ្ញត្តិនៃអនុសញ្ញានេះ ។

គ. មិនបានបញ្ជាក់មូលហេតុច្បាស់លាស់ ឬគ្មានភស្តុតាងគ្រប់គ្រាន់សំរាប់ធ្វើជាអំណះអំណាង ។

ឃ. ជាការរំលោភសិទ្ធិដាក់ពាក្យបណ្ដឹង ។

ង. អង្គហេតុដែលជាកម្មវត្ថុនៃបណ្ដឹងបានកើតមាន នៅមុនថ្ងៃចូលជាធរមាននៃពិធីសារនេះសំរាប់រដ្ឋភាគីពាក់ព័ន្ធ បើពុំនោះទេលុះត្រាតែអង្គហេតុនោះបានបន្តរហូតដល់ក្រោយកាលបរិច្ឆេទនៃពិធីសារនេះ។

## មាត្រា ៥

១. នៅគ្រប់ពេល បន្ទាប់ពីការទទួលបណ្ដឹង និងនៅមុនពេលឈានដល់ការសំរេចលើអង្គសេចក្ដី គណៈកម្មាធិការអាចបញ្ជូនទៅរដ្ឋភាគីពាក់ព័ន្ធ ដើម្បីពិនិត្យជាបន្ទាន់លើសំណើដែលរដ្ឋភាគីចាត់វិធានការបណ្ដោះអាសន្នតាមការចាំបាច់ ដើម្បីជៀសវាងការអាចកើតមាននូវការគេចវេះ មិនជួសជុលសំណងការខូចខាតដល់ជនរងគ្រោះម្នាក់ ឬច្រើននាក់ ដែលអះអាងថាបានទទួលរងការរំលោភ ។

២. ប្រសិនបើគណៈកម្មាធិការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ស្របតាមកថាខណ្ឌទី១ នៃមាត្រានេះ នោះមិនបានបញ្ជាក់ថាជាការសំរេចទទួលយក ឬការសំរេចលើអង្គសេចក្តីនៃបណ្តឹងឡើយ ។

## មាត្រា ៦

១. ប្រសិនបើគណៈកម្មាធិការយល់ថាមិនអាចទទួលពាក្យបណ្តឹង ដោយមិនបញ្ជូនបណ្តឹងនោះទៅរដ្ឋភាគីពាក់ព័ន្ធ ហើយបុគ្គលម្នាក់ ឬច្រើននាក់យល់ព្រមបង្ហាញអត្តសញ្ញាណរបស់ខ្លួនដល់រដ្ឋភាគីនោះ គណៈកម្មាធិការ ត្រូវផ្តល់ដំណឹងជាសំងាត់ ដល់រដ្ឋភាគីពាក់ព័ន្ធអំពីបណ្តឹងដែលបានបញ្ជូនមកឱ្យខ្លួន ស្របតាមពិធីសារនេះ ។

២. ក្នុងរយៈពេល៦ខែ រដ្ឋចុងចំលើយត្រូវបញ្ជូនការពន្យល់ជាលាយលក្ខណ៍អក្សរ ឬសេចក្តីថ្លែងការណ៍បំភ្លឺបញ្ហា និងការដោះស្រាយរបស់រដ្ឋនោះ ប្រសិនជាមាន ទៅគណៈកម្មាធិការ ។

## មាត្រា ៧

១. គណៈកម្មាធិការ ត្រូវពិនិត្យបណ្តឹងដែលទទួលបានស្របតាមពិធីសារនេះ ចំពោះព័ត៌មានដែលផ្តល់មកឱ្យខ្លួនដោយបុគ្គល ឬក្នុងនាមបុគ្គល ឬក្រុមបុគ្គល និងដោយរដ្ឋភាគីពាក់ព័ន្ធ ហើយព័ត៌មាននេះ ត្រូវបានបញ្ជូនទៅភាគីពាក់ព័ន្ធដទៃទៀត ។

២. គណៈកម្មាធិការ ត្រូវប្រជុំជាសម្ងាត់ នៅពេលពិនិត្យបណ្តឹង ស្របតាមពិធីសារនេះ ។

៣. បន្ទាប់ពីពិនិត្យបណ្តឹងរួច គណៈកម្មាធិការត្រូវបញ្ជូនការយល់ឃើញអំពីបណ្តឹងនោះ រួមជាមួយអនុសាសន៍របស់ខ្លួន ទៅភាគីពាក់ព័ន្ធ ប្រសិនជាមាន ។

៤. រដ្ឋភាគីត្រូវធ្វើការពិនិត្យឱ្យបានត្រឹមត្រូវចំពោះការយល់ឃើញរបស់គណៈកម្មាធិការ រួមជាមួយអនុសាសន៍របស់ខ្លួន ប្រសិនជាមាន ហើយត្រូវបញ្ជូនចំលើយជាលាយលក្ខណ៍អក្សរទៅគណៈកម្មាធិការ ក្នុងរយៈពេល៦ខែ រួមទាំងព័ត៌មានស្តីពីវិធានការដែលបានចាត់ឡើង ទាក់ទងនឹងការយល់ឃើញ និងអនុសាសន៍របស់គណៈកម្មាធិការ ។

៥. គណៈកម្មាធិការ អាចអញ្ជើញរដ្ឋភាគី ឱ្យផ្តល់ព័ត៌មានបន្ថែមស្តីពីវិធានការនានា ដែលរដ្ឋភាគីបានចាត់ឡើង ឆ្លើយតបទៅនឹងការយល់ឃើញ និងអនុសាសន៍របស់ខ្លួន ប្រសិនជាមាន តាមដែលគណៈកម្មាធិការយល់ថា សមស្រប នៅក្នុងរបាយការណ៍បន្តបន្ទាប់មកទៀតរបស់រដ្ឋភាគី ស្របតាមមាត្រា១៨ នៃអនុសញ្ញានេះ ។

## មាត្រា ៨

១. ប្រសិនបើគណៈកម្មាធិការ ទទួលព័ត៌មានគួរឱ្យទុកចិត្ត ដែលបង្ហាញឱ្យឃើញពីការរំលោភធ្ងន់ធ្ងរ ឬជាប្រព័ន្ធ ដោយរដ្ឋភាគីទៅលើសិទ្ធិទាំងឡាយ ដែលមានចែងក្នុងអនុសញ្ញានេះ គណៈកម្មាធិការត្រូវអញ្ជើញរដ្ឋភាគីនោះ ឱ្យសហការពិនិត្យព័ត៌មាន និងផ្តល់សេចក្តីសង្កេតចំពោះព័ត៌មានពាក់ព័ន្ធ ។

២. តាមការពិនិត្យសេចក្តីសង្កេត ដែលរដ្ឋភាគីពាក់ព័ន្ធបញ្ជូនមក រួមមានព័ត៌មានពាក់ព័ន្ធសមស្របផ្សេងទៀតផង គណៈកម្មាធិការ អាចចាត់តាំងសមាជិកម្នាក់ ឬច្រើននាក់ ឱ្យស៊ើបអង្កេត និងរាយការណ៍ជាបន្ទាន់ទៅគណៈកម្មាធិការ ។ ប្រសិនជាចាំបាច់ និងដោយមានការយល់ព្រមពីរដ្ឋភាគី ការស៊ើបអង្កេតនេះអាចរួមទាំងការធ្វើទស្សនកិច្ចទៅកាន់ទឹកដីនៃរដ្ឋនោះ ។

៣. ក្រោយពីការពិនិត្យសេចក្តីសន្និដ្ឋាននៃការស៊ើបអង្កេតនេះ គណៈកម្មាធិការត្រូវបញ្ជូនសេចក្តីសន្និដ្ឋានទាំងនេះទៅរដ្ឋភាគីពាក់ព័ន្ធ រួមជាមួយនឹងការផ្តល់យោបល់ ឬអនុសាសន៍ ។

៤. ក្នុងរយៈពេល៦ខែ នៃការទទួលសេចក្តីសន្និដ្ឋាន ការផ្តល់យោបល់ និងអនុសាសន៍ ដែលគណៈកម្មាធិការបានបញ្ជូន រដ្ឋភាគីពាក់ព័ន្ធត្រូវបញ្ជូនសេចក្តីសង្កេតរបស់ខ្លួនទៅគណៈកម្មាធិការ ។

៥. ការស៊ើបអង្កេតនេះ ត្រូវធ្វើជាសំងាត់ និងត្រូវស្វែងរកកិច្ចសហការពីរដ្ឋភាគី នៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនេះ ។

## មាត្រា ៩

១. គណៈកម្មាធិការ អាចអញ្ជើញរដ្ឋភាគីពាក់ព័ន្ធ ឱ្យបញ្ចូលទៅក្នុងរបាយការណ៍របស់ខ្លួនស្របតាមមាត្រា១៨ នៃអនុសញ្ញានេះ នូវព័ត៌មានស្តីពីវិធានការ ដែលខ្លួនបានអនុម័ត ដើម្បីឆ្លើយតបទៅនឹងការស៊ើបអង្កេតដែលបានធ្វើឡើង ស្របតាមមាត្រា៨ នៃពិធីសារនេះ ។

២. ប្រសិនជាចាំបាច់ បន្ទាប់ពីផុតរយៈពេល៦ខែ ដូចមានចែងក្នុងមាត្រា៨.៤ គណៈកម្មាធិការអាចអញ្ជើញរដ្ឋភាគីពាក់ព័ន្ធ ឱ្យផ្តល់ព័ត៌មានមកខ្លួនអំពីវិធានការដែលបានចាត់ឡើង ឆ្លើយតបទៅនឹងការស៊ើបអង្កេតនេះ ។

## មាត្រា ១០

១. នៅពេលចុះហត្ថលេខា ឬឱ្យសច្ចាប័ន ឬចូលជាសមាជិកនៃពិធីសារនេះ រដ្ឋភាគីនីមួយៗអាចប្រកាសថា ខ្លួនមិនទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការ ដូចមានចែងក្នុងមាត្រា៨ និងមាត្រា៩ ។

២. រដ្ឋភាគីណាមួយដែលបានធ្វើសេចក្តីប្រកាស ស្របតាមកថាខ័ណ្ឌទី១ នៃមាត្រានេះ អាចដកសេចក្តីប្រកាសនេះវិញបានគ្រប់ពេលវេលា តាមរយៈការជូនដំណឹងទៅអគ្គលេខាធិការ ។

## មាត្រា ១១

រដ្ឋភាគីនីមួយៗ ត្រូវចាត់រាល់វិធានការសមស្រប ដើម្បីធានាថាបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន មិនមែនជាកម្មវត្ថុនៃការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ ឬការបំភិតបំភ័យ ដោយសារតែខ្លួនបានប្តឹងទៅគណៈកម្មាធិការ ស្របតាមពិធីសារនេះ ។

## មាត្រា ១២

គណៈកម្មាធិការ ត្រូវបញ្ចូលទៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន ក្រោមមាត្រា២១ នៃអនុសញ្ញានេះ នូវសេចក្តីសង្ខេបស្តីពីសកម្មភាពរបស់ខ្លួន ស្របតាមពិធីសារនេះ ។

## មាត្រា ១៣

រដ្ឋភាគីនីមួយៗ មានភារៈកិច្ចផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងជាសាធារណៈអំពីអនុសញ្ញា និងពិធីសារនេះ និងដើម្បីជួយសំរួលដល់ការទទួលបានព័ត៌មានអំពីការយល់ឃើញ និងអនុសាសន៍របស់គណៈកម្មាធិការ ជាពិសេស អំពីបញ្ហាដែលពាក់ព័ន្ធនឹងរដ្ឋភាគីនោះ ។

## មាត្រា ១៤

គណៈកម្មាធិការ ត្រូវបង្កើតបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន សំរាប់អនុវត្ត នៅពេលបំពេញតួនាទីដែលពិធីសារនេះបានប្រគល់ឱ្យខ្លួន ។

## មាត្រា ១៥

១. ពិធីសារនេះ បើកឱ្យចុះហត្ថលេខា ដោយរដ្ឋភាគីដែលបានចុះហត្ថលេខា ឱ្យសច្ចាប័ន ឬចូលជាសមាជិកនៃអនុសញ្ញានេះ ។

២. ពិធីសារនេះ ជាកម្មវត្ថុនៃការឱ្យសច្ចាប័នដោយរដ្ឋណាមួយដែលបានឱ្យសច្ចាប័ន ឬចូលជាសមាជិកនៃអនុសញ្ញានេះ ។ លិខិតុបករណ៍ឱ្យសច្ចាប័ន ត្រូវតំកល់នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៣. ពិធីសារនេះ បើកឱ្យចូលជាសមាជិកដោយរដ្ឋភាគីណាមួយ ដែលបានឱ្យសច្ចាប័ន ឬចូលជាសមាជិកនៃអនុសញ្ញានេះ ។

៤. ការចូលជាសមាជិក ត្រូវចូលជាធរមាន ដោយការតំកល់លិខិតុបករណ៍ចូលជាសមាជិកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

## មាត្រា ១៦

១. ពិធីសារនេះចូលជាធរមានក្នុងរយៈពេល៣ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬចូលជាសមាជិកទី១០ នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

២. ចំពោះរដ្ឋនីមួយៗ ដែលឱ្យសច្ចាប័ន ឬចូលជាសមាជិក បន្ទាប់ពីពិធីសារនេះចូលជាធរមាន ពិធីសារនេះ ត្រូវចូលជាធរមានក្នុងរយៈពេល៣ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬចូលជាសមាជិករបស់រដ្ឋនោះ ។

## មាត្រា ១៧

មិនអនុញ្ញាតឱ្យមានលក្ខខណ្ឌណាមួយ ចំពោះពិធីសារនេះឡើយ ។

## មាត្រា ១៨

១. រដ្ឋភាគីអាចស្នើសុំធ្វើវិសោធនកម្មពិធីសារនេះ និងដាក់សេចក្តីស្នើសុំនេះ ជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ អគ្គលេខាធិការ ត្រូវបញ្ជូនសេចក្តីស្នើវិសោធនកម្មទៅរដ្ឋភាគីទាំងអស់ ដោយស្នើសុំឱ្យរដ្ឋភាគីទាំងនោះបញ្ជាក់ប្រាប់ខ្លួនថាតើរដ្ឋភាគីយល់ព្រមឱ្យមានសន្និសីទនៃរដ្ឋភាគីទាំងអស់ ដើម្បីពិនិត្យ និងបោះឆ្នោតលើសេចក្តីស្នើសុំឬទេ ។ ក្នុងករណីមានសំលេង១ភាគ៣ យ៉ាងតិចនៃរដ្ឋភាគីប្រកាសយល់ព្រមឱ្យមានសន្និសីទ អគ្គលេខាធិការត្រូវកោះធ្វើសន្និសីទក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ ។ វិសោធនកម្មដែលបានអនុម័តដោយមតិភាគច្រើននៃរដ្ឋភាគីវត្តមាន និងបានបោះឆ្នោតក្នុងសន្និសីទត្រូវដាក់ជូនមហាសន្និបាតសហប្រជាជាតិ ដើម្បីសុំការយល់ព្រម ។

២. វិសោធនកម្មត្រូវចូលជាធរមាន នៅពេលវិសោធនកម្មនេះ ទទួលបានការយល់ព្រមពីមហាសន្និបាត និងបានទទួលយកដោយសំលេងភាគច្រើន២ភាគ៣ នៃរដ្ឋភាគីនៃពិធីសារនេះ អាស្រ័យតាមនីតិវិធីនៃរដ្ឋធម្មនុញ្ញរបស់រដ្ឋនីមួយៗ ។

៣. នៅពេលវិសោធនកម្មចូលជាធរមានហើយ វិសោធនកម្មនោះ នឹងក្លាយជាកាតព្វកិច្ចសំរាប់រដ្ឋភាគីដែលយល់ព្រមទទួលយកវិសោធនកម្មនោះ រដ្ឋភាគីក្រៅពីនេះ នៅតែចងភ្ជាប់ដោយបទបញ្ញត្តិនៃពិធីសារនេះ និងវិសោធនកម្មមុនៗ ដែលរដ្ឋភាគីនោះបានយល់ព្រមទទួលយក ។

## មាត្រា ១៩

១. រដ្ឋភាគី អាចប្រកាសដកខ្លួនចេញពីពិធីសារនេះបានគ្រប់ពេល ដោយការជូនដំណឹងជាលាយល័ក្ខអក្សរទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ការប្រកាសដកខ្លួនមានអានុភាពក្នុងរយៈពេល៦ខែ បន្ទាប់ពីកាលបរិច្ឆេទ ដែលអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបានការជូនដំណឹង ។

២. ការប្រកាសដកខ្លួននេះ មិនត្រូវឱ្យប៉ះពាល់ដល់ការបន្តអនុវត្តបទបញ្ញត្តិនៃពិធីសារនេះចំពោះបណ្តឹងណាមួយដែលបានស្នើឡើងក្រោមមាត្រា២ ឬការស៊ើបអង្កេតណាមួយដែលបានផ្តើមធ្វើ ស្របតាមមាត្រា៨ នៅមុនកាលបរិច្ឆេទចូលជាធរមាន នៃការប្រកាសដកខ្លួននេះឡើយ ។

## មាត្រា ២០

អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវជូនដំណឹងទៅរដ្ឋទាំងអស់អំពី :

ក. ការចុះហត្ថលេខា ការឱ្យសច្ចាប័ន និងការចូលជាសមាជិក ស្របតាមពិធីសារនេះ ។

ខ. កាលបរិច្ឆេទចូលជាធរមាននៃពិធីសារនេះ និងកាលបរិច្ឆេទចូលជាធរមាននៃវិសោធនកម្ម នានា ស្របតាមមាត្រា១៨ ។

គ. ការប្រកាសដកខ្លួន ស្របតាមមាត្រា១៩ ។

## មាត្រា ២១

១. ពិធីសារនេះ ដែលមានអត្ថបទជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ មានតម្លៃស្មើគ្នា និងត្រូវដំកល់ទុកនៅបណ្ណសារដ្ឋាននៃអង្គការសហប្រជាជាតិ ។

២. អគ្គលេខាធិការសហប្រជាជាតិ ត្រូវបញ្ជូនសេចក្តីចម្លងនៃពិធីសារនេះ ដោយមានបញ្ជាក់ការចម្លងស្របតាមច្បាប់ដើម ជូនរដ្ឋភាគីទាំងអស់ ដូចមានចែងក្នុងមាត្រា២៥ នៃអនុសញ្ញានេះ ។

# អនុសញ្ញាប្រឆាំងនឹងទារុណកម្ម

# និងការប្រព្រឹត្តមកលើខ្លួន

# ឬទណ្ឌកម្មឯទៀត

# ដែលឃោរឃៅ

# អមនុស្សធម៌

# ឬបន្ថោកបន្ទាប

# និងពិធីសារបន្ថែម

# ១១- អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប

ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤
និងចូលជាធរមាននៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៨៧ ស្របតាមបទបញ្ញត្តិនៃមាត្រា២៧ (១)
កម្ពុជាក្លាយជារដ្ឋភាគីនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២

*រដ្ឋភាគីនៃអនុសញ្ញានេះ*

*យល់ឃើញថា* ស្របតាមគោលការណ៍ដែលមានប្រកាសក្នុងធម្មនុញ្ញសហប្រជាជាតិ ការទទួលស្គាល់សិទ្ធិស្មើភាព និងមិនអាចលក់ ដូរ ផ្ទេរ ឬដកហូតបានរបស់សមាជិកនៃគ្រួសារមនុស្ស គឺជាគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពក្នុងពិភពលោក ។

*ទទួលស្គាល់ថា* សិទ្ធិទាំងនេះ កើតមកពីសេចក្តីថ្លៃថ្នូរជាប់ពីកំណើតរបស់មនុស្ស ។

*យល់ឃើញថា* រដ្ឋមានកាតព្វកិច្ចក្រោមធម្មនុញ្ញសហប្រជាជាតិ ជាពិសេសមាត្រា៥៥ ក្នុងការលើកស្ទួយការគោរព និងប្រតិបត្តិជាសកលនូវសិទ្ធិ និងសេរីភាពមូលដ្ឋានរបស់មនុស្ស ។

*ចងចាំថា* មាត្រា៥ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងមាត្រា៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ដែលឯកសារទាំងពីរ បានចែងថា គ្មានជនណាម្នាក់ត្រូវទទួលទារុណកម្ម ឬការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបឡើយ ។

*គិតផងដែរដល់* សេចក្តីប្រកាសស្តីពីកិច្ចការពារមនុស្សគ្រប់រូបពីទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មដែលឃោរឃៅ អមនុស្សធម៌ និងបន្ថោកបន្ទាប ដែលបានអនុម័តដោយមហាសន្និបាតនៅថ្ងៃ៩ ខែធ្នូ ឆ្នាំ១៩៧៥ ។

*មានបំណងឱ្យ*ធ្វើការតស៊ូរឹតតែប្រសិទ្ធភាពថែមទៀតប្រឆាំងនឹងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួនឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ និងបន្ថោកបន្ទាបដែលមាននៅពាសពេញពិភពលោក។

*បានព្រមព្រៀងគ្នាដូចតទៅ :*

## ផ្នែកទី ១

## មាត្រា ១

១. ដើម្បីគោលបំណងនៃអនុសញ្ញានេះ ពាក្យ "ទារុណកម្ម" មានន័យថា អំពើទាំងឡាយណាដែលនាំឱ្យមានការឈឺចាប់ ឬរងទុក្ខយ៉ាងខ្លាំង ទោះផ្លូវកាយក្តី ឬផ្លូវចិត្តក្តី ដែលត្រូវបានបង្កឡើងដោយចេតនាទៅលើជនណាម្នាក់ ក្នុងគោលបំណងទាំងឡាយដូចជាទាញយកព័ត៌មានពីជននោះ ឬតតិយ

ជនណាម្នាក់ ដាក់ទណ្ឌកម្មជននោះ ចំពោះអំពើណាមួយដែលជននោះ ឬតតិយជនណាម្នាក់បានប្រព្រឹត្ត ឬសង្ស័យថាបានប្រព្រឹត្ត ឬបំភិតបំភ័យ ឬបង្ខិតបង្ខំជននោះ ឬតតិយជនណាម្នាក់ ឬដើម្បីមូលហេតុណាផ្សេងទៀត ដែលផ្អែកលើការរើសអើងណាមួយ បើការឈឺចាប់ ឬការរងទុក្ខ បង្កដោយមន្ត្រីសាធារណៈ ឬជនផ្សេងទៀត តាមការញុះញង់ ឬការព្រមព្រៀង ឬធ្វើមិនដឹងមិនលឺ ឬផ្ដើមគំនិតរបស់មន្ត្រីសាធារណៈ ឬជនផ្សេងទៀតដែលបំពេញតួនាទីជាផ្លូវការ ។ ពាក្យទារុណកម្ម មិនរាប់បញ្ចូលនូវការឈឺចាប់ ឬការរងទុក្ខដែលកើតជាប់ ឬម្ដងម្កាលពីទណ្ឌកម្មត្រឹមត្រូវតាមច្បាប់ឡើយ ។

២. មាត្រានេះ មិនប៉ះពាល់ដល់លិខិតុបករណ៍អន្តរជាតិ ឬច្បាប់ជាតិទាំងឡាយ ដែលមាន ឬអាចមានបទបញ្ញត្តិទូលំទូលាយជាងនេះឡើយ ។

### មាត្រា ២

១. រដ្ឋភាគី ត្រូវចាត់វិធានការខាងផ្លូវច្បាប់ រដ្ឋបាល តុលាការ និងវិធានការផ្សេងទៀត ដើម្បីបង្ការកុំឱ្យមានទារុណកម្មនៅលើដែនដីក្រោមសមត្ថកិច្ចរបស់ខ្លួន ។

២. មិនមានស្ថានភាពពិសេសដោយឡែកណាមួយ ទោះស្ថានភាពសង្គ្រាម ឬស្ថានភាពគំរាមកំហែងដោយសង្គ្រាម អស្ថិរភាពនយោបាយផ្ទៃក្នុង ឬភាពអាសន្នជាសាធារណៈផ្សេងទៀតក៏ដោយ ដែលអាចយកមកសំអាងដោះសារទារុណកម្មឡើយ ។

៣. បញ្ជាពីមន្ត្រីថ្នាក់លើ ឬអាជ្ញាធរសាធារណៈ មិនអាចយកមកសំអាងដោះសារទារុណកម្មឡើយ ។

### មាត្រា ៣

១. គ្មានរដ្ឋភាគីណាមួយត្រូវបណ្ដេញ បញ្ជូនទៅវិញ និងធ្វើបត្យាប័នជនណាម្នាក់ទៅកាន់រដ្ឋមួយទៀត បើមានមូលហេតុល្មមនឹងជឿបានថា ជននោះនឹងធ្លាក់ក្នុងគ្រោះថ្នាក់នៃការធ្វើទារុណកម្ម ។

២. ដើម្បីកំណត់ថាតើមានមូលហេតុបែបនោះឬទេ អាជ្ញាធរមានសមត្ថកិច្ច ត្រូវគិតពីបញ្ហាពាក់ព័ន្ធទាំងអស់ ដោយរាប់បញ្ចូលការកើតមាននូវការរំលោភសិទ្ធិមនុស្ស ជាលក្ខណៈប្រចាំធ្ងន់ធ្ងរជាក់ស្ដែង ឬជាក្រុមនៅក្នុងរដ្ឋពាក់ព័ន្ធ ។

### មាត្រា ៤

១. រដ្ឋភាគី ត្រូវធានាថា ទារុណកម្មជាបទល្មើសក្រោមច្បាប់ព្រហ្មទណ្ឌរបស់ខ្លួន ។ ច្បាប់នេះត្រូវអនុវត្តចំពោះការប៉ុនប៉ង ការប្រព្រឹត្តទារុណកម្ម ឬអំពើប្រព្រឹត្តដោយជនណាម្នាក់ ដែលចាត់ជាការសមគំនិត ឬការចូលរួមប្រព្រឹត្តទារុណកម្ម ។

២. រដ្ឋភាគី ត្រូវផ្ដន្ទាទោសចំពោះបទល្មើសទាំងនេះ ឱ្យបានសមស្របតាមប្រភេទធ្ងន់ធ្ងរ នៃបទល្មើសទាំងឡាយ ។

## មាត្រា ៥

១. រដ្ឋភាគី ត្រូវចាត់វិធានការចាំបាច់ ដើម្បីបង្កើតដែនសមត្ថកិច្ចរបស់ខ្លួន លើបទល្មើស ស្របតាមមាត្រា៤ ក្នុងករណីដូចតទៅ :

(ក) បើបទល្មើស ត្រូវបានប្រព្រឹត្តលើដែនដីស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ឬនៅលើអាកាសយាន ឬនាវាដែលចុះបញ្ជីការក្នុងរដ្ឋនោះ ។

(ខ) បើជនជាប់សង្ស័យនៃបទល្មើសជាជនជាតិនៃរដ្ឋនោះ ។

(គ) បើជនរងគ្រោះជាជនជាតិនៃរដ្ឋនោះ បើរដ្ឋនោះយល់ថា សមស្រប ។

២. រដ្ឋភាគីនីមួយៗ ក៏ត្រូវចាត់វិធានការចាំបាច់បង្កើតដែនសមត្ថកិច្ចរបស់ខ្លួន លើបទល្មើសទាំងនោះ ក្នុងករណីដែលជនជាប់សង្ស័យនៃបទល្មើសស្ថិតក្នុងដែនដីក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ហើយរដ្ឋនោះមិនធ្វើបត្យាប័នជននោះស្របតាមមាត្រា៨ទៅកាន់រដ្ឋណាមួយដែលមានចែងក្នុងកថាខណ្ឌ១នៃមាត្រានេះ។

៣. អនុសញ្ញានេះ មិនផាត់ចោលដែនសមត្ថកិច្ចព្រហ្មទណ្ឌណាមួយ ដែលត្រូវបានអនុវត្ត ស្របតាមច្បាប់ជាតិឡើយ ។

## មាត្រា ៦

១. យោងតាមស្ថានភាពចាំបាច់ ក្រោយពីពិនិត្យព័ត៌មាន ដែលទទួលបានរួចហើយ រដ្ឋភាគីដែលដែនដីរបស់ខ្លួន មានវត្តមានជនសង្ស័យនៃបទល្មើស ដូចមានចែងក្នុងមាត្រា៤ ត្រូវឃុំខ្លួនជននោះ ឬត្រូវចាត់វិធានការតាមផ្លូវច្បាប់នានា ដើម្បីធានាវត្តមានរបស់ជននោះ ។ ការឃុំខ្លួន និងវិធានការតាមផ្លូវច្បាប់នានា ត្រូវធ្វើឱ្យស្របតាមច្បាប់រដ្ឋនោះ ប៉ុន្តែការឃុំខ្លួន និងវិធានការទាំងនេះ អាចបន្តធ្វើបានតែក្នុងរយៈពេលចាំបាច់ ដើម្បីផ្តើមអនុវត្តការចោទប្រកាន់ព្រហ្មទណ្ឌ ឬនីតិវិធីធ្វើបត្យាប័ន ។

២. រដ្ឋនោះ ត្រូវចាត់ជាបន្ទាន់នូវការស៊ើបអង្កេតបឋមមួយ ដើម្បីកសាងអង្គហេតុ ។

៣. ជនណាដែលត្រូវឃុំខ្លួន ស្របតាមកថាខណ្ឌ១ នៃមាត្រានេះ អាចទាក់ទងជាបន្ទាន់ជាមួយតំណាងសមស្របដែលនៅជិតបំផុតនៃប្រទេសដែលជននោះមានសញ្ជាតិ ឬបើជននោះជាជនគ្មានសញ្ជាតិ ត្រូវទាក់ទងជាមួយតំណាងនៃប្រទេសណាដែលជននោះស្នាក់នៅជាប្រក្រតី ។

៤. បើរដ្ឋណាមួយ បានឃុំខ្លួនជនណាម្នាក់ ស្របតាមបទបញ្ញត្តិមាត្រានេះ រដ្ឋនោះ ត្រូវជូនដំណឹងភ្លាមអំពីហេតុផលនៃការឃុំខ្លួន និងស្ថានភាពតម្រូវដល់ការឃុំខ្លួន ទៅដល់រដ្ឋទាំងឡាយ ដូចមានចែងក្នុងមាត្រា៥ កថាខណ្ឌ១ ។ រដ្ឋដែលចាត់ការស៊ើបអង្កេតបឋម ដូចមានចែងក្នុងកថាខណ្ឌ២ នៃមាត្រានេះ ត្រូវរាយការណ៍អំពីសេចក្តីសន្និដ្ឋានរបស់ខ្លួនទៅរដ្ឋទាំងឡាយនោះ និងត្រូវបញ្ជាក់ថាតើ ខ្លួននឹងប្រើប្រាស់សាលាក្តីឬទេ ។

## មាត្រា ៧

១. រដ្ឋភាគីដែលរកឃើញជនជាប់សង្ស័យនៃបទល្មើស ដូចមានចែងក្នុងមាត្រា៤ ក្នុងដែនដីស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន បើមិនធ្វើបត្យាប័នជននេះ តាមករណីដូចមានចែងក្នុងមាត្រា៥ ត្រូវដាក់សំណុំរឿងនេះទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីធ្វើការចោទប្រកាន់ ។

២. អាជ្ញាធរទាំងនេះត្រូវធ្វើសេចក្តីសម្រេចរបស់ខ្លួនក្នុងលក្ខខណ្ឌដូចគ្នានឹងបទល្មើសធម្មតាដែលមានលក្ខណៈធ្ងន់ធ្ងរ ស្របតាមច្បាប់រដ្ឋនោះ ។ ក្នុងករណីដូចមានចែងក្នុងមាត្រា៥ កថាខណ្ឌ២ វិធាននៃភស្តុតាងសម្រាប់អនុវត្តលើការចោទប្រកាន់ និងការផ្តន្ទាទោស មិនត្រូវមានបែបណាមួយ ដែលតឹងរឹងតិចជាងទណ្ឌកម្ម ដែលអនុវត្តក្នុងករណីដូចមានចែងក្នុងមាត្រា៥ កថាខណ្ឌ១ ឡើយ ។

៣. ជនណាដែលត្រូវចោទប្រកាន់ពីបទល្មើសណាមួយ ដូចមានចែងក្នុងមាត្រា៤ ត្រូវទទួលបានការគិតគូដោយឥតលំអៀង នៅគ្រប់ដំណាក់ការនៃនីតិវិធី ។

## មាត្រា ៨

១. បទល្មើសដូចមានចែងក្នុងមាត្រា៤ ត្រូវចាត់បញ្ចូលជាបទល្មើសចំណុះបត្យាប័ន នៅគ្រប់សន្ធិសញ្ញាបត្យាប័នដែលមានស្រាប់រវាងរដ្ឋភាគី ។ រដ្ឋភាគីសន្យាបញ្ចូលបទល្មើសទាំងនោះ ជាបទល្មើសចំណុះបត្យាប័ន នៅគ្រប់សន្ធិសញ្ញាបត្យាប័ន ដែលសម្រេចអនុម័តរវាងរដ្ឋភាគី ។

២. បើរដ្ឋភាគីណាមួយ ដែលធ្វើបត្យាប័នផ្អែកលើលក្ខខណ្ឌអត្ថិភាពនៃសន្ធិសញ្ញាមួយ ទទួលសេចក្តីស្នើសុំធ្វើបត្យាប័នពីរដ្ឋភាគីមួយផ្សេងទៀត ដែលរដ្ឋភាគីនោះ មិនមានសន្ធិសញ្ញាបត្យាប័នជាមួយខ្លួន រដ្ឋនោះអាចចាត់ទុកអនុសញ្ញានេះជាមូលដ្ឋានច្បាប់សម្រាប់ធ្វើបត្យាប័ន ចំពោះបទល្មើសទាំងនោះ ។ បត្យាប័នត្រូវចំណុះទៅនឹងលក្ខខណ្ឌផ្សេងទៀត ដូចមានកំណត់ក្នុងច្បាប់របស់រដ្ឋដែលទទួលសេចក្តីស្នើសុំ ។

៣. រដ្ឋភាគីដែលមិនធ្វើបត្យាប័នផ្អែកលើលក្ខខណ្ឌអត្ថិភាពនៃសន្ធិសញ្ញាត្រូវទទួលស្គាល់បទល្មើសទាំងនេះ ជាបទល្មើសចំណុះបត្យាប័នរវាងរដ្ឋភាគី ស្របតាមលក្ខខណ្ឌ ដែលមានចែងក្នុងច្បាប់រដ្ឋដែលទទួលសេចក្តីស្នើសុំ ។

៤. ដើម្បីឱ្យមានបត្យាប័នរវាងរដ្ឋភាគី បទល្មើសបែបនេះ ត្រូវចាត់ទុកថាដូចជាបានប្រព្រឹត្តទាំងនៅកន្លែងកើតហេតុ ទាំងក្នុងដែនដីនៃរដ្ឋ ដែលតម្រូវឱ្យបង្កើតសាលាក្តី ស្របតាមមាត្រា៥ កថាខណ្ឌ១ ។

## មាត្រា ៩

១. រដ្ឋភាគី ត្រូវទទួលជួយគ្នាទៅវិញទៅមក ខាងវិស័យតុលាការឱ្យបានទូលំទូលាយ តាមអាចធ្វើទៅបាន ក្នុងនីតិវិធីព្រហ្មទណ្ឌទាក់ទិននឹងបទល្មើស ដូចមានចែងក្នុងមាត្រា៤ រួមមានការផ្តល់ភស្តុតាងទាំងអស់ ដែលខ្លួនមានតាមដែលចាំបាច់ សម្រាប់នីតិវិធីផង ។

២. រដ្ឋភាគី ត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្រោមកថាខណ្ឌ១ នៃមាត្រានេះ ដោយអនុលោមតាមសន្ធិសញ្ញាទាំងឡាយ ស្តីពីកិច្ចការទៅវិញទៅមកខាងតុលាការ ដែលអាចមានរវាងរដ្ឋភាគី ។

## មាត្រា ១០

១. រដ្ឋភាគី ត្រូវធានាថា ការអប់រំ និងព័ត៌មានស្តីពីការហាមប្រាមទារុណកម្ម ត្រូវបានដាក់បញ្ចូលយ៉ាងពេញលេញក្នុងការបណ្តុះបណ្តាលមន្ត្រីប្រតិបត្តិច្បាប់ បុគ្គលិកស៊ីវិល ឬយោធា បុគ្គលិកពេទ្យ មន្ត្រីសាធារណៈ និងជនផ្សេងទៀតដែលអាចដាក់ឱ្យអន្តរាគមន៍ការឃុំខ្លួន ការសួរចម្លើយ ឬការប្រព្រឹត្តទៅលើបុគ្គលណាដែលស្ថិតក្រោមការចាប់ខ្លួន ឃុំខ្លួន ឬការដាក់ពន្ធនាគារ តាមបែបណាមួយ ។

២. រដ្ឋភាគី ត្រូវបញ្ចូលការហាមប្រាមនេះ ទៅក្នុងបទបញ្ជា ឬសេចក្តីបង្គាប់ ដែលដាក់ចេញឱ្យអនុវត្ត អាស្រ័យតាមភារកិច្ច និងមុខតំណែងរបស់អ្នកទាំងនោះ ។

## មាត្រា ១១

រដ្ឋភាគី ត្រូវដាក់វិធាននៃការសួរចម្លើយ សេចក្តីបង្គាប់ឱ្យសួរចម្លើយ វិធី និងការអនុវត្តន៍ការសួរចម្លើយ រួមមានរបបឃុំ និងការប្រព្រឹត្តទៅលើជនដែលត្រូវចាប់ខ្លួន ឃុំខ្លួន ឬជាប់ពន្ធនាគារក្នុងដែនដីក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ក្រោមការពិនិត្យឡើងវិញហ្មត់ចត់ ដើម្បីជៀសវាងរាល់ករណីទារុណកម្ម ។

## មាត្រា ១២

រដ្ឋភាគី ត្រូវធានាថា អាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ធ្វើជាបន្ទាន់នូវការស៊ើបអង្កេតមិនលំអៀងរៀងរាល់លើក នៅពេលមានមូលហេតុសមស្របគួរឱ្យជឿបានថា អំពើទារុណកម្ម ត្រូវបានប្រព្រឹត្តក្នុងដែនដីស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ។

## មាត្រា ១៣

រដ្ឋភាគី ត្រូវធានាថា បុគ្គលណាដែលអះអាងថាបានរងទារុណកម្ម ក្នុងដែនដីស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន មានសិទ្ធិប្តឹង និងដាក់ករណីរបស់ខ្លួន ទៅអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីនេះ ឱ្យចាត់ការពិនិត្យជាបន្ទាន់ និងឥតលំអៀងនូវរឿងហេតុរបស់ជននេះ ។ វិធានការនានា ត្រូវធ្វើឡើងដើម្បីធានាការការពារអ្នកប្តឹង និងសាក្សីទាំងឡាយប្រឆាំងនឹងការធ្វើបាប ឬការបំភិតបំភ័យ ដោយសារការដាក់ពាក្យប្តឹង ឬការធ្វើសាក្សី ។

## មាត្រា ១៤

១. រដ្ឋភាគី ត្រូវធានាក្នុងប្រព័ន្ធច្បាប់របស់ខ្លួនថា ជនរងគ្រោះពីអំពើទារុណកម្ម មានសិទ្ធិទទួលបានការជួសជុល និងសិទ្ធិបង្គាប់សំណងខូចខាតសមរម្យ និងគ្រប់គ្រាន់ រួមមានមធ្យោបាយស្តារនីតិសម្បទាឱ្យបានពេញលេញ តាមដែលអាចធ្វើទៅបានផង ។ ក្នុងករណីជនរងគ្រោះស្លាប់ ដោយអំពើទារុណកម្ម សិទ្ធិវន្តនៃជនរងគ្រោះមានសិទ្ធិទទួលសំណង ។

២. គ្មានបទបញ្ញត្តិណាមួយក្នុងមាត្រានេះ ប៉ះពាល់ដល់សិទ្ធិណាមួយនៃជនរងគ្រោះ ឬជនផ្សេងទៀត ដើម្បីទទួលសំណងដែលអាចមានក្នុងច្បាប់ជាតិឡើយ ។

## មាត្រា ១៥

រដ្ឋភាគី ត្រូវធានាថា ឯកសាររាយការណ៍ទាំងឡាយ ដែលបង្កើតឡើងបានមកពីអំពើទារុណកម្ម មិនត្រូវយកមកសំអាងជាធាតុនៃភស្តុតាងក្នុងនីតិវិធីណាមួយឡើយ លើកលែងតែឯកសាររាយការណ៍នោះត្រូវបានធ្វើសម្រាប់ជាភស្តុតាងប្រឆាំងនឹងជនជាប់ចោទនៃអំពើទារុណកម្ម ។

## មាត្រា ១៦

១. រដ្ឋភាគី ត្រូវសន្យាហាមឃាត់ក្នុងដែនដីស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន នូវអំពើផ្សេងទៀតនៃការប្រព្រឹត្តទៅលើបុគ្គល ឬទណ្ឌកម្មឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ដែលមិនចាត់ជាទារុណកម្ម ដូចមានចែងក្នុងមាត្រា១ បើអំពើទាំងនេះ ត្រូវបានប្រព្រឹត្តតាមការញុះញង់ ឬការព្រមព្រៀង ឬការធ្វើមគំនិតរបស់មន្ត្រីសាធារណៈ ឬជនផ្សេងទៀតដែលបំពេញមុខងារជាផ្លូវការ ។ ជាពិសេស កាតព្វកិច្ចដែលមានចែងក្នុងមាត្រា១០ មាត្រា១១ មាត្រា១២ និងមាត្រា១៣ ត្រូវអនុវត្ត ដោយយកសេចក្តីយោងពាក់ព័ន្ធនឹងទម្រង់ផ្សេងទៀតនៃការប្រព្រឹត្តទៅលើបុគ្គល ឬទណ្ឌកម្មឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបទៅជំនួសសេចក្តីយោងពាក់ព័ន្ធនឹងទារុណកម្ម ។

២. បទបញ្ញត្តិនានានៃអនុសញ្ញានេះ មិនប៉ះពាល់ដល់បទបញ្ញត្តិក្នុងលិខិតុបករណ៍អន្តរជាតិផ្សេងទៀត ឬច្បាប់ជាតិ ដែលហាមប្រាមការប្រព្រឹត្តទៅលើបុគ្គល ឬទណ្ឌកម្មឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ឬដែលទាក់ទងនឹងបត្យាប័ន ឬការបណ្តេញចេញឡើយ ។

## ផ្នែកទី ២

## មាត្រា ១៧

១. គណៈកម្មាធិការប្រឆាំងទារុណកម្ម (ដែលចាប់ពីនេះទៅហៅថា គណៈកម្មាធិការ) ត្រូវបង្កើតឡើង ។ គណៈកម្មាធិការមានមុខងារ ដូចមានកំណត់ដូចតទៅ : គណៈកម្មាធិការត្រូវមានសមាសភាពអ្នកជំនាញការចំនួន១០រូប ដែលមានសីលធម៌ខ្ពស់ និងសមត្ថកិច្ចដែលគេទទួលស្គាល់ក្នុងវិស័យសិទ្ធិមនុស្ស និងត្រូវបំពេញការងារក្នុងឋានៈជាបុគ្គលឯកជន ។ អ្នកជំនាញការ ត្រូវបោះឆ្នោតជ្រើសរើសដោយរដ្ឋភាគី ដោយធ្វើការពិចារណាបែងចែកសមាជិកភាព ទៅតាមភូមិសាស្ត្រ ដោយសមធម៌ និងទៅតាមប្រយោជន៍នៃការចូលរួមពីបេក្ខជន ពីមនុស្សមួយចំនួន ដែលមានបទពិសោធន៍ខាងច្បាប់ ។

២. សមាជិកគណៈកម្មាធិការ ត្រូវជ្រើសរើសតាមការបោះឆ្នោតដោយសម្ងាត់ លើបញ្ជីរាយនាមបេក្ខជន ដែលជ្រើសតាំងដោយរដ្ឋភាគី ។ រដ្ឋភាគីនីមួយៗ អាចជ្រើសតាំងបេក្ខជនម្នាក់ ក្នុងចំណោមជនជាតិរបស់ខ្លួន ។ រដ្ឋភាគី ត្រូវគិតដល់សារប្រយោជន៍ នៃការជ្រើសតាំងបេក្ខជន ដែលជាសមាជិកនៃ

គណៈកម្មាធិការសិទ្ធិមនុស្សផង ដែលបង្កើតឡើងក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងដែលស្ម័គ្រចិត្តបម្រើការងារក្នុងគណៈកម្មាធិការប្រឆាំងទារុណកម្មផងដែរ ។

៣. ការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការ ត្រូវធ្វើក្នុងកិច្ចប្រជុំ២ឆ្នាំម្តងនៃរដ្ឋភាគីតាមការកោះអញ្ជើញដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ កូរ៉ុមសម្រាប់កិច្ចប្រជុំ គឺ២ភាគ៣នៃរដ្ឋភាគី ។ បេក្ខជនដែលជាប់ជាសមាជិកគណៈកម្មាធិការ ត្រូវតែជាបេក្ខជនទទួលបានសំឡេងច្រើនបំផុត និងសំឡេងភាគច្រើនដាច់ខាត ពីតំណាងរបស់រដ្ឋភាគីដែលមានវត្តមាន និងបានបោះឆ្នោត ។

៤. ការបោះឆ្នោតជាលើកដំបូង ត្រូវធ្វើឡើងយ៉ាងយូរបំផុត៦ខែ ក្រោយកាលបរិច្ឆេទចូលជាធរមាននៃអនុសញ្ញានេះ ។ យ៉ាងតិច៤ខែ មុនកាលបរិច្ឆេទនៃការបោះឆ្នោតនីមួយៗ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវចេញលិខិតអញ្ជើញ ឱ្យរដ្ឋភាគីបញ្ជូនឈ្មោះបេក្ខជនរបស់ខ្លួន ក្នុងរយៈពេល ៣ខែ ។ អគ្គលេខាធិការត្រូវរៀបចំបញ្ជីឈ្មោះបេក្ខជនតាមលំដាប់អក្ខរក្រម ដោយបញ្ជាក់ឈ្មោះរដ្ឋភាគី ដែលបានជ្រើសតាំងបេក្ខជន និងត្រូវបញ្ជូនបញ្ជីនេះទៅរដ្ឋភាគី ។

៥. សមាជិកគណៈកម្មាធិការត្រូវជ្រើសរើសតាមការបោះឆ្នោតសម្រាប់រយៈពេល៤ឆ្នាំ។ សមាជិកអាចមានសិទ្ធិឈរឈ្មោះជាថ្មី បើខ្លួនត្រូវបានជ្រើសតាំងឡើងវិញ ។ ប៉ុន្តែ អាណត្តិរបស់សមាជិក ៥រូបដែលជាប់ឆ្នោតក្នុងពេលបោះឆ្នោតលើកទី១ ត្រូវផុតកំណត់ក្នុងរយៈពេល២ឆ្នាំ ។ ក្រោយការបោះឆ្នោតលើកទីមួយភ្លាម ឈ្មោះសមាជិកទាំង៥រូបនេះ ត្រូវចាប់ឆ្នោតជ្រើសរើសដោយប្រធានអង្គប្រជុំ ដូចមានចែងក្នុងកថាខណ្ឌ៣ នៃមាត្រានេះ ។

៦. បើសមាជិកគណៈកម្មាធិការណាម្នាក់ទទួលមរណភាព ឬសុំលាលែងពីមុខងារ ឬដោយបុព្វហេតុផ្សេងដែលមិនអាចបំពេញមុខការឱ្យគណៈកម្មាធិការនោះ រដ្ឋភាគីដែលជ្រើសតាំងសមាជិករូបនោះ ត្រូវតែងតាំងអ្នកជំនាញការម្នាក់ទៀត ក្នុងចំណោមជនជាតិរបស់ខ្លួនឱ្យបន្តអាណត្តិដែលនៅសល់អាស្រ័យតាមការយល់ព្រមភាគច្រើននៃរដ្ឋភាគី ។ ការយល់ព្រមនេះ ត្រូវចាត់ទុកជាបានការ ដរាបណាចំនួនពាក់កណ្តាល ឬលើសពីពាក់កណ្តាលនៃរដ្ឋភាគី មិនបញ្ចេញយោបល់ជំទាស់ក្នុងរយៈពេល៦សប្តាហ៍បន្ទាប់ពីរដ្ឋភាគី ទទួលដំណឹងស្តីពីសេចក្តីស្នើសុំតែងតាំងពីអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៧. រដ្ឋភាគី ត្រូវទទួលបន្ទុកខ្លួនឯងលើចំណាយសម្រាប់សមាជិកគណៈកម្មាធិការ ក្នុងរយៈពេលដែលសមាជិកបំពេញមុខងារគណៈកម្មាធិការ ។

## មាត្រា ១៨

១. គណៈកម្មាធិការ ត្រូវបោះឆ្នោតជ្រើសរើសមន្ត្រីការិយាល័យរបស់ខ្លួន សម្រាប់អាណត្តិ២ឆ្នាំ។ មន្ត្រីការិយាល័យទាំងអស់ អាចត្រូវបានបោះឆ្នោតជ្រើសរើសសារជាថ្មីឡើងវិញ ។

២. គណៈកម្មាធិការបង្កើតបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។ ប៉ុន្តែបទបញ្ជាផ្ទៃក្នុងនេះ ត្រូវមានបទបញ្ញត្តិខាងក្រោមបន្ថែមលើបទបញ្ញត្តិផ្សេងទៀត :

(ក) កូរ៉ុមត្រូវមានសមាជិក៦រូប ។

(ខ) សេចក្តីសម្រេចរបស់គណៈកម្មាធិការ ត្រូវយកតាមសំឡេងភាគច្រើននៃសមាជិកវត្តមាន ។

៣. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវផ្តល់បុគ្គលិក និងសម្ភារៈរូបវ័ន្តចាំបាច់ សម្រាប់ការបំពេញឱ្យបាននូវមុខងាររបស់គណៈកម្មាធិការក្រោមអនុសញ្ញានេះ ។

៤. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវកោះប្រជុំសមាជិកគណៈកម្មាធិការលើកដំបូង ។ បន្ទាប់ពីកិច្ចប្រជុំលើកដំបូង គណៈកម្មធិការត្រូវប្រជុំទៅតាមពេលវេលា ដូចបានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

៥. រដ្ឋភាគី ត្រូវទទួលខុសត្រូវលើការចំណាយចំពោះកិច្ចប្រជុំនៃរដ្ឋភាគី និងកិច្ចប្រជុំគណៈកម្មាធិការ រួមទាំងសងទៅអង្គការសហប្រជាជាតិ នូវថ្លៃចំណាយដូចជាថ្លៃបុគ្គលិក និងសម្ភារៈរូបវ័ន្ត ដែលអង្គការសហប្រជាជាតិបានចំណាយ ស្របតាមកថាខណ្ឌ៣ នៃមាត្រានេះ ។

## មាត្រា ១៩

១. រដ្ឋភាគី ត្រូវបញ្ជូនតាមរយៈអគ្គលេខាធិការអង្គការសហប្រជាជាតិ នូវរបាយការណ៍ស្តីពីវិធានការ ដែលរដ្ឋភាគីបានដាក់ចេញ ដើម្បីអនុវត្តការសន្យារបស់ខ្លួន ក្រោមអនុសញ្ញានេះ ក្នុងរយៈពេល ១ឆ្នាំ គិតចាប់ពីការចូលជាធរមាន នៃអនុសញ្ញាសម្រាប់រដ្ឋពាក់ព័ន្ធ ។ បន្ទាប់មកទៀត រដ្ឋភាគី ត្រូវធ្វើរបាយការណ៍បន្ថែម រៀងរាល់៤ឆ្នាំម្តង ស្តីពីវិធានការថ្មីៗដែលបានដាក់ចេញ និងរបាយការណ៍ផ្សេងទៀតតាមការស្នើសុំរបស់គណៈកម្មាធិការ ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនរបាយការណ៍ទៅគ្រប់រដ្ឋភាគី ។

៣. គណៈកម្មាធិការ ត្រូវសិក្សារបាយការណ៍នីមួយៗ និងផ្តល់យោបល់ទូទៅលើរបាយការណ៍តាមដែលគណៈកម្មាធិការយល់ថាសមស្រប ហើយត្រូវបញ្ជូនយោបល់ទាំងនេះ ទៅរដ្ឋភាគីពាក់ព័ន្ធ ។ រដ្ឋភាគីនោះ អាចផ្ញើតបទៅគណៈកម្មាធិការវិញ នូវសេចក្តីសង្កេតនានា ដែលខ្លួនយល់ឃើញថា មានប្រយោជន៍សម្រាប់គណៈកម្មាធិការ ។

៤. គណៈកម្មាធិការ អាស្រ័យការយល់ឃើញរបស់ខ្លួន អាចសម្រេចបញ្ចូលទៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន ដូចបានកំណត់ក្នុងមាត្រា២៤ នូវយោបល់របស់ខ្លួន ស្របតាមកថាខណ្ឌ៣ នៃមាត្រានេះ ដោយភ្ជាប់ជាមួយនូវសេចក្តីសង្កេតរបស់រដ្ឋភាគីពាក់ព័ន្ធ ។ បើមានសេចក្តីស្នើសុំពីរដ្ឋភាគី គណៈកម្មាធិការ អាចបញ្ចូលច្បាប់ចម្លងនៃរបាយការណ៍ដែលបានផ្ញើមកខ្លួន ក្រោមកថាខណ្ឌ១ នៃមាត្រានេះ ។

## មាត្រា ២០

១. បើគណៈកម្មាធិការ ទទួលព័ត៌មានគួរឱ្យទុកចិត្ត ដែលបង្ហាញឱ្យឃើញនូវមូលដ្ឋានសមហេតុផលថា មានការប្រព្រឹត្តទារុណកម្មដោយមានការរៀបចំហ្មត់ចត់ ក្នុងដែនដីនៃរដ្ឋភាគីមួយ គណៈកម្មាធិការត្រូវអញ្ជើញរដ្ឋភាគីនោះ ឱ្យសហការពិនិត្យព័ត៌មាន និងផ្តល់សេចក្តីសង្កេតចំពោះព័ត៌មានពាក់ព័ន្ធ ។

២. តាមការពិនិត្យសេចក្តីសង្កេត ដែលរដ្ឋភាគីពាក់ព័ន្ធបញ្ជូនមក រួមមានព័ត៌មានពាក់ព័ន្ធសមស្របផ្សេងទៀតផង បើសម្រេចថាត្រឹមត្រូវហើយ គណៈកម្មាធិការ អាចចាត់តាំងសមាជិកម្នាក់ ឬច្រើននាក់ ឱ្យស៊ើបអង្កេតជាសម្ងាត់ និងរាយការណ៍ជាបន្ទាន់ទៅគណៈកម្មាធិការ ។

៣. បើការស៊ើបអង្កេត ត្រូវបានធ្វើ ស្របតាមកថាខណ្ឌ២ នៃមាត្រានេះ ហើយគណៈកម្មាធិការត្រូវស្វែងរកសហប្រតិបត្តិការពីរដ្ឋភាគីពាក់ព័ន្ធ ។ ដោយមានការព្រមព្រៀងជាមួយរដ្ឋភាគីនោះ ការស៊ើបអង្កេតបែបនេះ អាចរាប់បញ្ចូលទស្សនកិច្ចទៅកាន់ដែនដីនៃរដ្ឋភាគីនោះផងដែរ ។

៤. ក្រោយពីការពិនិត្យសេចក្តីសន្និដ្ឋានរបស់សមាជិកម្នាក់ ឬច្រើននាក់ស្របតាមកថាខណ្ឌ២ នៃមាត្រានេះ គណៈកម្មាធិការត្រូវបញ្ជូនសេចក្តីសន្និដ្ឋានទាំងនេះ ទៅរដ្ឋភាគីពាក់ព័ន្ធ រួមជាមួយនឹងការផ្តល់យោបល់ ឬការណែនាំដែលសមស្របនឹងសភាពការណ៍ ។

៥. ចំណាត់ការទាំងអស់របស់គណៈកម្មាធិការ ដូចមានចែងក្នុងកថាខណ្ឌ១ ដល់៤ នៃមាត្រានេះត្រូវរក្សាជាសម្ងាត់ ហើយគ្រប់ដំណាក់កាលនៃចំណាត់ការ ត្រូវតែខំឱ្យបានទទួលសហប្រតិបត្តិការពីរដ្ឋភាគី ។ ក្រោយពីបញ្ចប់ចំណាត់ការស៊ើបអង្កេត ស្របតាមកថាខណ្ឌ២ និងបន្ទាប់ពីពិគ្រោះយោបល់ជាមួយរដ្ឋភាគីពាក់ព័ន្ធ គណៈកម្មាធិការ អាចសម្រេចដាក់បញ្ចូលដំណើររឿងសង្ខេបស្តីពីលទ្ធផលនៃការងារក្នុងរបាយការណ៍ប្រចាំឆ្នាំ ស្របតាមមាត្រា២៤ ។

## មាត្រា ២១

១. រដ្ឋភាគីនៃអនុសញ្ញានេះ អាចប្រកាសស្របតាមមាត្រានេះគ្រប់ពេលថា ខ្លួនទទួលស្គាល់សមត្ថកិច្ចនៃគណៈកម្មាធិការ ដើម្បីទទួល និងពិនិត្យបណ្តឹង អាស្រ័យដោយរដ្ឋភាគីមួយ អះអាងថារដ្ឋភាគីមួយទៀត មិនបំពេញកាតព្វកិច្ចរបស់ខ្លួន ស្របតាមអនុសញ្ញានេះ ។ បណ្តឹងនេះ អាចទទួលយកមកពិនិត្យ ស្របតាមនីតិវិធី ដូចមានចែងក្នុងមាត្រានេះបាន លុះត្រាតែបណ្តឹងនេះធ្វើឡើងដោយរដ្ឋភាគី ដែលបានប្រកាសទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការ ។ គណៈកម្មាធិការ មិនទទួលយកបណ្តឹងរបស់រដ្ឋភាគី ដែលមិនបានធ្វើសេចក្តីប្រកាសស្របតាមមាត្រានេះមកដោះស្រាយឡើយ ។ បណ្តឹងដែលបានទទួលស្របតាមមាត្រានេះ ត្រូវដោះស្រាយតាមនីតិវិធីខាងក្រោម :

(ក) បើរដ្ឋភាគីណាមួយពិនិត្យឃើញថា រដ្ឋភាគីមួយទៀត មិនអនុវត្តបទបញ្ញត្តិនៃអនុសញ្ញានេះ រដ្ឋភាគីនោះអាចលើកយកបញ្ហាតាមរយៈបណ្តឹងជាលាយល័ក្ខណ៍អក្សរ ទៅជូនរដ្ឋភាគីម្ខាងទៀត ។ ក្នុងរយៈពេល៣ខែ ចាប់ពីកាលបរិច្ឆេទនៃការទទួលបណ្តឹង រដ្ឋភាគីចុងបណ្តឹង ត្រូវផ្ញើតបទៅរដ្ឋភាគីដើមបណ្តឹងនូវការពន្យល់ ឬសេចក្តីថ្លែងការណ៍ជាលាយល័ក្ខណ៍អក្សរណាមួយ បំភ្លឺអំពីបញ្ហាដែលសមល្មមតាមកម្រិតអាចយល់បាន និងដែលមានប្រយោជន៍ ដោយបញ្ជាក់អំពីនីតិវិធី និងការដោះស្រាយរបស់រដ្ឋភាគី ដែលមិនទាន់សម្រេច ឬដែលសម្រេចហើយចំពោះបញ្ហានោះ ។

(ខ) បើបញ្ហាមិនត្រូវបានដោះស្រាយដាច់ស្រេចរវាងរដ្ឋភាគីពាក់ព័ន្ធទាំងពីរ ក្នុងរយៈពេល៦ខែ គិតចាប់ពីកាលបរិច្ឆេទដែលរដ្ឋចុងបណ្តឹងទទួលបណ្តឹងទី១នោះ រដ្ឋភាគីណាមួយនៃរដ្ឋភាគីទាំងពីរ អាចមានសិទ្ធិលើកបញ្ហាទៅគណៈកម្មាធិការ ដោយការជូនដំណឹងជាលាយល័ក្ខណ៍អក្សរដល់គណៈកម្មាធិការ និងរដ្ឋភាគីពាក់ព័ន្ធ ។

(គ) គណៈកម្មាធិការ អាចដោះស្រាយបញ្ហាមួយដែលបញ្ជូនមកឱ្យខ្លួនស្របតាមមាត្រានេះបាន លុះត្រាតែគណៈកម្មាធិការរកឃើញថា ដំណោះស្រាយបញ្ហាតាមផ្លូវច្បាប់ទាំងអស់នៅក្នុងស្រុកបានយកមកប្រើអស់ហើយ ស្របតាមគោលការណ៍ច្បាប់អន្តរជាតិដែលទទួលស្គាល់ជាទូទៅ ។ វិធាននេះ នឹងមិនត្រូវយកមកអនុវត្តទេ បើនីតិវិធីនៃការដោះស្រាយបន្តយូររហូសហេតុ ឬមិនទំនងជានាំមកនូវការជួយឱ្យធូរស្បើយ បានស័ក្តិសិទ្ធិដល់ជនរងគ្រោះនៃការរំលោភអនុសញ្ញានេះទេ ។

(ឃ) គណៈកម្មាធិការ ត្រូវប្រជុំជាសម្ងាត់ នៅពេលគណៈកម្មាធិការ ពិនិត្យបណ្តឹង ស្របតាមមាត្រានេះ ។

(ង) តាមបទបញ្ញត្តិនៃអនុកថាខណ្ឌ (គ) គណៈកម្មាធិការ ត្រូវដាក់សេវារបស់ខ្លួនឱ្យរដ្ឋភាគីពាក់ព័ន្ធប្រើប្រាស់ ដើម្បីទៅដល់ដំណោះស្រាយជានាគ្គាលើបញ្ហា ដោយគោរពតាមកាតព្វកិច្ច ដូចមានចែងក្នុងអនុសញ្ញានេះ ។ ក្នុងទិសដៅនេះ គណៈកម្មាធិការ អាចបង្កើតគណៈកម្មការចំពោះកិច្ចមួយ បើយល់ថាសមស្រប ។

(ច) គ្រប់បញ្ហាដែលបានដាក់ជូនគណៈកម្មាធិការស្របតាមមាត្រានេះ គណៈកម្មាធិការ អាចស្នើសុំឱ្យរដ្ឋភាគីពាក់ព័ន្ធ ដូចមានចែងក្នុងអនុកថាខណ្ឌ (ខ) ផ្តល់ព័ត៌មានពាក់ព័ន្ធទាំងអស់ដល់គណៈកម្មាធិការ ។

(ឆ) រដ្ឋភាគីពាក់ព័ន្ធ ដូចមានចែងក្នុងអនុកថាខណ្ឌ (ខ) មានសិទ្ធិដាក់វត្តមានតំណាងរបស់ខ្លួននៅពេលគណៈកម្មាធិការកំពុងពិនិត្យបញ្ហា និងមានសិទ្ធិសុំយោបល់ដោយផ្ទាល់មាត់ និង/ឬជាលាយល័ក្ខណ៍អក្សរ ។

(ជ) ក្នុងរយៈពេល១២ខែ គិតចាប់ពីថ្ងៃទទួលការជូនដំណឹង ដូចចែងក្នុងអនុកថាខណ្ឌ (ខ) គណៈកម្មាធិការ ត្រូវបង្ហាញរបាយការណ៍ ៖

(i) បើដំណោះស្រាយមួយ ត្រូវបានរកឃើញ ក្នុងក្របខ័ណ្ឌនៃបទបញ្ញត្តិក្នុងអនុកថាខណ្ឌ (ង) គណៈកម្មាធិការ ត្រូវកម្រិតរបាយការណ៍របស់ខ្លួន មកត្រឹមតែជាសេចក្តីថ្លែងការណ៍សង្ខេបអំពីអង្គហេតុ និងដំណោះស្រាយដែលសម្រេចបាន ។

(ii) បើដំណោះស្រាយមួយមិនបានសម្រេច ក្នុងក្របខ័ណ្ឌនៃអនុកថាខណ្ឌ (ង) ទេ គណៈកម្មាធិការ ត្រូវកម្រិតរបាយការណ៍របស់ខ្លួន ត្រឹមតែជាសេចក្តីថ្លែងការណ៍សង្ខេបអំពីអង្គហេតុ ។ សេចក្តីស្នើសុំយោបល់ជាលាយល័ក្ខណ៍អក្សរ និងកំណត់ហេតុលើសេចក្តីស្នើសុំយោបល់ផ្ទាល់មាត់របស់រដ្ឋភាគីពាក់ព័ន្ធ ត្រូវភ្ជាប់ទៅជាមួយរបាយការណ៍នេះ ។ ក្នុងករណីនីមួយៗ គណៈកម្មាធិការត្រូវផ្ញើរបាយការណ៍ទៅរដ្ឋភាគីពាក់ព័ន្ធ ។

២. បទបញ្ញត្តិនៃមាត្រានេះ ត្រូវចូលជាធរមាន បើរដ្ឋភាគីចំនួន៥នៃអនុសញ្ញានេះ បានធ្វើសេចក្តីប្រកាសស្របតាមកថាខណ្ឌ១ នៃមាត្រានេះ ។ រដ្ឋភាគី ត្រូវតំកល់ទុកសេចក្តីប្រកាសទាំងនោះនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយអគ្គលេខាធិការ ត្រូវបញ្ជូនច្បាប់ចម្លងនៃសេចក្តីប្រកាសទាំងនោះទៅរដ្ឋភាគីផ្សេងទៀត ។ សេចក្តីប្រកាស អាចដកហូតមកវិញបានគ្រប់ពេល ដោយការជូនដំណឹងជាលាយល័ក្ខណ៍អក្សរទៅអគ្គលេខាធិការ ។ ការដកហូតនេះ មិនប៉ះពាល់ដល់ការពិនិត្យលើបញ្ហាទាំងឡាយក្នុងបណ្តឹង ដែលបានផ្ញើរួចហើយស្របតាមមាត្រានេះទេ ។ បណ្តឹងបន្ថែមរបស់រដ្ឋភាគី នឹងមិនទទួលយកមកពិនិត្យក្រោមមាត្រានេះឡើយ បន្ទាប់ពីអគ្គលេខាធិការទទួលបានការជូនដំណឹងស្តីពីការដកហូតនូវសេចក្តីប្រកាសនេះ លើកលែងតែរដ្ឋភាគីពាក់ព័ន្ធ ធ្វើសេចក្តីប្រកាសថ្មី ។

## មាត្រា ២២

១. រដ្ឋភាគីនៃអនុសញ្ញានេះអាចប្រកាសគ្រប់ពេលក្រោមមាត្រានេះថា ខ្លួនទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការ ក្នុងការទទួល និងពិនិត្យបណ្តឹង ដែលធ្វើដោយបុគ្គល ឬក្នុងនាមបុគ្គលដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដែលបុគ្គលនោះអះអាងថា ខ្លួនបានរងគ្រោះដោយសារការរំលោភរបស់រដ្ឋភាគីលើបទបញ្ញត្តិនៃអនុសញ្ញានេះ ។ គណៈកម្មាធិការ មិនទទួលបណ្តឹងមកពិនិត្យទេ បើបណ្តឹងនោះពាក់ព័ន្ធនឹងរដ្ឋភាគី ដែលមិនបានធ្វើសេចក្តីប្រកាស ។

២. គណៈកម្មាធិការ ចាត់ទុកថាមិនអាចទទួលយកនូវបណ្តឹងអនាមិក ដែលប្តឹងក្រោមមាត្រានេះ ឬដែលគណៈកម្មាធិការចាត់ទុកថា ជាការរំលោភសិទ្ធិដាក់ពាក្យបណ្តឹង ឬជាប្រការផ្ទុយនឹងបទបញ្ញត្តិនៃអនុសញ្ញានេះ ។

៣. តាមបទបញ្ញត្តិនៃកថាខណ្ឌ២ គណៈកម្មាធិការ ត្រូវបញ្ជូនបណ្តឹងដែលខ្លួនបានទទួល ស្របតាមមាត្រានេះ ទៅរដ្ឋភាគីនៃអនុសញ្ញានេះ ដែលបានធ្វើសេចក្តីប្រកាសស្របតាមកថាខណ្ឌ១ និងដែលជាប់ការចោទប្រកាន់ថា បានរំលោភបំពាន លើបទបញ្ញត្តិណាមួយនៃអនុសញ្ញានេះ ។ ក្នុងរយៈពេល ៦ខែ រដ្ឋចុងបណ្តឹងត្រូវបញ្ជូនការពន្យល់ជាលាយល័ក្ខណ៍អក្សរ ឬសេចក្តីថ្លែងការណ៍បំភ្លឺបញ្ហា និងការដោះស្រាយរបស់រដ្ឋនោះ ប្រសិនជាមាន ជូនទៅគណៈកម្មាធិការ ។

៤. គណៈកម្មាធិការ ត្រូវពិនិត្យបណ្តឹងដែលទទួលបានស្របតាមមាត្រានេះ ដោយសំអាងព័ត៌មានរបស់ខ្លួន បានទទួលពីបុគ្គល ឬក្នុងនាមបុគ្គល និងពីរដ្ឋភាគីពាក់ព័ន្ធ ។

៥. គណៈកម្មាធិការ មិនពិនិត្យបណ្តឹងរបស់បុគ្គលណាម្នាក់ ស្របតាមមាត្រានេះទេ លើកលែងតែគណៈកម្មាធិការបានដឹងច្បាស់ថា :

(ក) បញ្ហាដដែលនោះ មិនដែលបានពិនិត្យ និងមិនកំពុងពិនិត្យ ស្របតាមនីតិវិធីនៃការស៊ើបអង្កេតជាអន្តរជាតិ ឬការដោះស្រាយជាអន្តរជាតិផ្សេងទៀត ។

(ខ) បុគ្គលនោះ បានប្រើប្រាស់អស់នូវដំណោះស្រាយទាំងប៉ុន្មានដែលមាននៅក្នុងស្រុក ។ វិធាននេះ មិនត្រូវយកមកអនុវត្តទេ បើនីតិវិធីនៃការដោះស្រាយបន្តយូរហួសហេតុ ឬមិនទំនងជានាំមកនូវការជួយឱ្យធូរស្បើយបានស័ក្តិសិទ្ធិដល់ជនរងគ្រោះ ពីការរំលោភអនុសញ្ញានេះ ។

៦. គណៈកម្មាធិការត្រូវបើកសម័យប្រជុំជាសម្ងាត់ នៅពេលពិនិត្យបណ្តឹងស្របតាមមាត្រានេះ។

៧. គណៈកម្មាធិការ ត្រូវបញ្ជូនការសង្កេតរបស់ខ្លួនទៅរដ្ឋភាគីពាក់ព័ន្ធ និងទៅបុគ្គលនោះ ។

៨. បទបញ្ញត្តិនៃមាត្រានេះត្រូវចូលជាធរមាន នៅពេលដែលរដ្ឋភាគីនៃអនុសញ្ញានេះចំនួន៥ បានធ្វើសេចក្តីប្រកាសស្របតាមកថាខណ្ឌ១នៃមាត្រានេះ ។ រដ្ឋភាគី ត្រូវតំកល់ទុកសេចក្តីប្រកាសនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ អគ្គលេខាធិការ ត្រូវចម្លងសេចក្តីប្រកាសទាំងនោះ បញ្ជូនទៅរដ្ឋភាគីផ្សេងទៀត ។ សេចក្តីប្រកាសអាចដកហូតទៅវិញគ្រប់ពេលដោយការជូនដំណឹងទៅអគ្គលេខាធិការ។ ការដកហូតនេះ មិនប៉ះពាល់ដល់ការត្រួតពិនិត្យបញ្ហាទាំងឡាយនៃបណ្តឹងដែលបានដាក់ជូនគណៈកម្មាធិការស្របតាមមាត្រានេះរួចហើយ ។ បណ្តឹងផ្សេងទៀតរបស់បុគ្គល ឬក្នុងនាមបុគ្គល នឹងមិនទទួលយកទេស្របតាមមាត្រានេះ បន្ទាប់ពីអគ្គលេខាធិការ បានទទួលការជូនដំណឹងអំពីការសុំដកសេចក្តីប្រកាស លើកលែងតែរដ្ឋភាគីពាក់ព័ន្ធធ្វើសេចក្តីប្រកាសជាថ្មី ។

## មាត្រា ២៣

សមាជិកគណៈកម្មាធិការ និងសមាជិកគណៈកម្មការចំពោះកិច្ច ដែលទទួលការតែងតាំង ស្របតាមមាត្រា២១ កថាខណ្ឌ១ (ង) មានសិទ្ធិទទួលសម្ភារៈរូបវ័ន្តឯកសិទ្ធិ និងអភ័យឯកសិទ្ធិក្នុងមុខងារជាអ្នកជំនាញការ បំពេញបេសកកម្មជូនអង្គការសហប្រជាជាតិ ដូចមានចែងក្នុងផ្នែកពាក់ព័ន្ធនៃអនុសញ្ញាស្តីពីឯកសិទ្ធិ និងអភ័យឯកសិទ្ធិ របស់អង្គការសហប្រជាជាតិ ។

## មាត្រា ២៤

គណៈកម្មាធិការ ត្រូវបញ្ជូនរបាយការណ៍ប្រចាំឆ្នាំស្តីពីសកម្មភាពរបស់ខ្លួន ស្របតាមអនុសញ្ញានេះ ទៅរដ្ឋភាគី និងមហាសន្និបាតអង្គការសហប្រជាជាតិ ។

## ផ្នែកទី ៣

## មាត្រា ២៥

១. អនុសញ្ញានេះ បើកចំហរឱ្យរដ្ឋទាំងអស់ចុះហត្ថលេខា ។

២. អនុសញ្ញានេះ ជាកម្មវត្ថុនៃការឱ្យសច្ចាប័ន ។ លិខិតុបករណ៍ឱ្យសច្ចាប័ន ត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

## មាត្រា ២៦

អនុសញ្ញានេះ បើកចំហឱ្យប្រទេសទាំងអស់ចូលជាសមាជិក ។ ការចូលជាសមាជិកចូលជាធរមានដោយការដាក់លិខិតុបករណ៍សុំចូលជាសមាជិក នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

## មាត្រា ២៧

១. អនុសញ្ញានេះ ចូលជាធរមាននៅថ្ងៃទី៣០ បន្ទាប់ពីកាលបរិច្ឆេទនៃការតំកល់ទុកជាមួយអគ្គលេខាធិការអង្គការសហប្រជាជាតិ នូវលិខិតុបករណ៍ទី២០ នៃការឱ្យសច្ចាប័ន ឬការសុំចូលជាសមាជិក ។

២. ចំពោះរដ្ឋដែលឱ្យសច្ចាប័ន ឬចូលជាសមាជិកនៃអនុសញ្ញានេះ ក្រោយពីការតំកល់ទុកលិខិតុបករណ៍ឱ្យសច្ចាប័ន ឬសុំចូលជាសមាជិកទី២០ អនុសញ្ញានេះនឹងចូលជាធរមាននៅថ្ងៃទី៣០ បន្ទាប់ពីកាលបរិច្ឆេទនៃការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬលិខិតុបករណ៍សុំចូលជាសមាជិករបស់រដ្ឋនោះ ។

## មាត្រា ២៨

១. នៅពេលចុះហត្ថលេខា ឬឱ្យសច្ចាប័ន ឬសុំចូលជាសមាជិកនៃអនុសញ្ញានេះ រដ្ឋនីមួយៗអាចប្រកាសថា ខ្លួនមិនទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការ ដែលមានចែងក្នុងមាត្រា២០ទេ ។

២. រដ្ឋភាគី ដែលប្រកាសនូវល័ក្ខខ័ណ្ឌស្របតាមបទបញ្ញត្តិនៃកថាខណ្ឌ១ នៃមាត្រានេះ អាចដកល័ក្ខខ័ណ្ឌចេញវិញបានគ្រប់ពេល ដោយការជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

## មាត្រា ២៩

១. រដ្ឋភាគីណាមួយនៃអនុសញ្ញានេះ អាចសុំធ្វើវិសោធនកម្ម និងអាចដាក់សេចក្តីស្នើសុំនេះទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ អគ្គលេខាធិការ ត្រូវបញ្ជូនសេចក្តីស្នើសុំធ្វើវិសោធកម្មនេះ ទៅ

រដ្ឋភាគីនានា ដោយសុំឱ្យរដ្ឋភាគីបញ្ជាក់ប្រាប់មកអគ្គលេខាធិការវិញថា តើយល់ព្រមឱ្យមានសន្និសីទនៃរដ្ឋភាគីដើម្បីពិនិត្យ និងបោះឆ្នោតគាំទ្រសេចក្តីស្នើសុំនោះឬទេ ។ ក្នុងរយៈពេល៤ខែ គិតចាប់ពីកាលបរិច្ឆេទនៃការជូនព័ត៌មានទៅរដ្ឋភាគី បើមានសម្លេង១ភាគ៣យ៉ាងតិចនៃរដ្ឋភាគីគាំទ្រឱ្យមានកិច្ចប្រជុំនេះ អគ្គលេខាធិការ ត្រូវកោះប្រជុំក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ។ អគ្គលេខាធិការ ត្រូវបញ្ជូនរាល់វិសោធនកម្ម ដែលបានអនុម័តដោយសំឡេងភាគច្រើននៃរដ្ឋភាគីវត្តមាន និងបានបោះឆ្នោតនៅឯកិច្ចប្រជុំ ជូនទៅរដ្ឋភាគីទាំងអស់ ដើម្បីសុំការទទួលយក ។

២. វិសោធនកម្មដែលបានអនុម័ត ស្របតាមបទបញ្ញត្តិកថាខណ្ឌ១ នៃមាត្រានេះ ត្រូវចូលជាធរមាន នៅពេលរដ្ឋភាគីនៃអនុសញ្ញានេះចំនួន២ភាគ៣ បានជូនដំណឹងដល់អគ្គលេខាធិការអង្គការសហប្រជាជាតិថាព្រមទទួលយកវិសោធនកម្ម អាស្រ័យតាមនីតិវិធីនៃរដ្ឋធម្មនុញ្ញរបស់រដ្ឋនីមួយៗ ។

៣. ពេលវិសោធនកម្មចូលជាធរមាន រដ្ឋភាគីដែលព្រមទទួលយកវិសោធនកម្មទាំងនេះ ត្រូវជាប់កាតព្វកិច្ចក្រោមវិសោធនកម្មទាំងនោះ ចំពោះរដ្ឋភាគីផ្សេងពីនេះ នៅតែជាប់កាតព្វកិច្ចក្រោមបទបញ្ញត្តិនៃអនុសញ្ញានេះ និងវិសោធនកម្មមុនៗ ដែលខ្លួនបានយល់ព្រមទទួលយក ។

## មាត្រា ៣០

១. ទំនាស់រវាងរដ្ឋភាគីពីរ ឬច្រើនជាងនេះ លើការបកស្រាយ ឬការអនុវត្តន៍អនុសញ្ញានេះ ដែលមិនអាចដោះស្រាយបានតាមការចរចា ត្រូវដាក់ឱ្យមានមជ្ឈត្តកម្ម វិនិច្ឆ័យតាមការស្នើសុំពីរដ្ឋភាគីណាមួយ ។ បើក្នុងរយៈពេល៦ខែ បន្ទាប់ពីកាលបរិច្ឆេទ នៃការស្នើសុំឱ្យមានមជ្ឈត្តកម្មវិនិច្ឆ័យ គូភាគីមិនអាចទៅដល់ការយល់ព្រមលើការរៀបចំមជ្ឈត្តកម្មវិនិច្ឆ័យទេ ភាគីណាមួយក្នុងរឿងនេះ អាចបញ្ជូនទំនាស់នេះទៅតុលាការយុត្តិធម៌អន្តរជាតិ ដោយការដាក់ពាក្យប្តឹង ស្របតាមលក្ខន្តិកៈរបស់តុលាការ ។

២. នៅពេលចុះហត្ថលេខា ឬឱ្យសច្ចាប័នលើអនុសញ្ញានេះ ឬពេលសុំចូលជាសមាជិកនៃអនុសញ្ញានេះ រដ្ឋនីមួយៗ អាចប្រកាសថា ខ្លួនមិនចំណុះឱ្យបទបញ្ញត្តិក្នុងកថាខណ្ឌ១ នៃមាត្រានេះទេ ។ រដ្ឋភាគីផ្សេងពីនេះមិនជាប់កាតព្វកិច្ចក្រោមបទបញ្ញត្តិក្នុងកថាខណ្ឌ១នៃមាត្រានេះ ជាមួយរដ្ឋភាគីណាមួយដែលបានដាក់ល័ក្ខខ័ណ្ឌខាងលើនេះឡើយ ។

៣. រដ្ឋភាគីណាដែលបានដាក់ល័ក្ខខ័ណ្ឌ ស្របតាមកថាខណ្ឌ២នៃមាត្រានេះ អាចដកល័ក្ខខ័ណ្ឌរបស់ខ្លួនវិញបានគ្រប់ពេល ដោយការជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

## មាត្រា ៣១

១. រដ្ឋភាគី អាចដកខ្លួនចេញពីអនុសញ្ញានេះ ដោយការជូនដំណឹងជាលាយល័ក្ខណ៍អក្សរដល់អគ្គលេខាធិការអង្គការសហប្រជាជាតិ។ ការដកខ្លួន នឹងចូលជាធរមាន១ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទដែលអគ្គលេខាធិការបានទទួលការជូនដំណឹងនេះ ។

២. ការដកខ្លួននេះ នឹងមិនដោះលែងឱ្យរដ្ឋភាគីរួចផុតពីកាតព្វកិច្ចរបស់ខ្លួន ក្រោមអនុសញ្ញានេះ ចំពោះអំពើឬការខកខានណាមួយ ដែលកើតមុនកាលបរិច្ឆេទ នៃការសុំដកខ្លួនបានចូលជាធរមានឡើយ ។ ការសុំដកខ្លួននេះ ទោះជាយ៉ាងណាក៏ដោយ ក៏មិនប៉ះពាល់ដល់ការបន្តពិនិត្យបញ្ហា ដែលស្ថិតក្រោមការពិនិត្យរបស់គណៈកម្មាធិការ មុនកាលបរិច្ឆេទនៃការសុំដកខ្លួន បានចូលជាធរមានឡើយ ។

៣. បន្ទាប់ពីកាលបរិច្ឆេទ នៃការសុំដកខ្លួនរបស់រដ្ឋភាគីចូលជាធរមាន គណៈកម្មាធិការនឹងមិនពិនិត្យបញ្ហាថ្មីណាមួយ ទាក់ទងនឹងរដ្ឋនោះឡើយ ។

## មាត្រា ៣២

អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវជូនដំណឹងដល់រដ្ឋសមាជិកនៃអង្គការសហប្រជាជាតិ និងរដ្ឋដែលបានចុះហត្ថលេខា ឬបានសុំចូលជាសមាជិកនៃអនុសញ្ញានេះ នូវប្រការដូចខាងក្រោម :

(ក) ការចុះហត្ថលេខា ការឱ្យសច្ចាប័ន និងការចូលជាសមាជិក ស្របតាមមាត្រា២៥ និង២៦។

(ខ) កាលបរិច្ឆេទចូលជាធរមាននៃអនុសញ្ញានេះ ស្របមាត្រា២៧ និងកាលបរិច្ឆេទចូលជាធរមាននៃវិសោធនកម្មនានា ស្របតាមមាត្រា២៩ ។

(គ) ការសុំដកខ្លួន ស្របតាមមាត្រា៣១ ។

## មាត្រា ៣៣

១. អនុសញ្ញានេះ ដែលមានអត្ថបទជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រូស្ស៊ី និងអេស្ប៉ាញ៉ុល មានតម្លៃស្មើគ្នា នឹងត្រូវតំកល់ទុកជាមួយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនច្បាប់ចម្លងនៃកតិកាសញ្ញានេះ ដោយមានបញ្ជាក់ការចម្លងតាមច្បាប់ដើមទៅរដ្ឋទាំងអស់ ។

# ១១-គ. ពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប

ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិកាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២
និងចូលជាធរមាននៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៦
កម្ពុជាក្លាយជារដ្ឋភាគី នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៧

## បុព្វកថា

រដ្ឋភាគីនៃពិធីសារនេះ

*អះអាងជាថ្មីថា* ការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ត្រូវបានហាមឃាត់ និងចាត់ទុកជាការរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិមនុស្ស ។

*ជឿជាក់ថា* ត្រូវចាត់វិធានការចាំបាច់ថែមទៀត ដើម្បីសំរេចគោលបំណងនៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (ពីនេះតទៅហៅត្រឹមថា អនុសញ្ញា) និងដើម្បីពង្រឹងការការពារ ជនទាំងឡាយដែលត្រូវបានដកហូតសេរីភាព ឱ្យរួចផុតពីការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ។

*រំលឹកឡើងវិញថា* មាត្រា២ និងមាត្រា១៦ នៃអនុសញ្ញាតម្រូវឱ្យរដ្ឋភាគីនីមួយៗ ចាត់វិធានការដ៏មានប្រសិទ្ធភាព ដើម្បីបង្ការការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប នៅលើទឹកដីណាមួយក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ។

*ទទួលស្គាល់ថា* រដ្ឋទាំងឡាយមានការទទួលខុសត្រូវចម្បងក្នុងការអនុវត្តន៍មាត្រាទាំងនេះដែលត្រូវពង្រឹងការការពារជនទាំងឡាយដែលត្រូវបានដកហូតសេរីភាពរបស់ខ្លួន និងការគោរពឱ្យបានពេញលេញនូវសិទ្ធិមនុស្ស គឺជាការទទួលខុសត្រូវរួមមួយ ដែលមនុស្សគ្រប់រូបត្រូវរួមគ្នាអនុវត្ត ហើយស្ថាប័នអន្តរជាតិនានា ដែលមានភារកិច្ចប្រតិបត្តិ ត្រូវជួយបំពេញបន្ថែម និងពង្រឹងវិធានការជាតិ ។

*រំលឹកឡើងវិញថា* ការបង្ការប្រកបដោយប្រសិទ្ធភាពប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ទាមទារការអប់រំ និងសមាយោគនៃវិធានការផ្សេងៗ ដូចជាវិធានការផ្លូវច្បាប់ រដ្ឋបាល តុលាការ និងវិធានការដទៃទៀត ។

*រំលឹកឡើងវិញផងដែរថា* សន្និសិទពិភពលោកស្តីពីសិទ្ធិមនុស្ស បានប្រកាសជាឧឡារិកថា ការខិតខំប្រឹងលុបបំបាត់ការធ្វើទារុណកម្ម គួរផ្តោតការយកចិត្តទុកដាក់ជាសំខាន់ និងជាដំបូងគេបង្អស់លើការបង្ការ ហើយអំពាវនាវឱ្យមានការអនុម័តពិធីសារបន្ថែមលើអនុសញ្ញានេះ ដែលមានគោលបំណងបង្កើតប្រព័ន្ធបង្ការ តាមរយៈការចូលពិនិត្យកន្លែងឃុំឃាំងនានា ។

*ជឿជាក់ថា* ការការពារជនទាំងឡាយដែលត្រូវបានដកហូតសិទ្ធិសេរីភាពឱ្យរួចផុតពីការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប អាចត្រូវពង្រឹងដោយវិធានការក្រៅផ្លូវតុលាការ ដែលមានចរិតជាការបង្ការ ដោយផ្អែកលើការចូលពិនិត្យជាទៀងទាត់ នៅកន្លែងឃុំឃាំងនានា

ដោយមានការព្រមព្រៀងដូចតទៅ :

## ផ្នែកទី ១
## គោលការណ៍ទូទៅ

### មាត្រា ១

ពិធីសារនេះមានគោលបំណងបង្កើតប្រព័ន្ធត្រួតពិនិត្យជាទៀតទាត់មួយដោយស្ថាប័នជាតិ និងអន្តរជាតិនានាដែលឯករាជ្យ នៅកន្លែងឃុំឃាំងជនទាំងឡាយដែលត្រូវបានដកហូតសេរីភាព ដើម្បីបង្ការការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ។

### មាត្រា ២

១. អនុគណៈកម្មាធិការបង្ការអំពើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប នៃគណៈកម្មាធិការប្រឆាំងទារុណកម្ម (ពីនេះតទៅហៅត្រឹមថា អនុគណៈកម្មាធិការបង្ការ) ត្រូវបានបង្កើតឡើង និងត្រូវអនុវត្តមុខងាររបស់ខ្លួន ដូចមានចែងនៅក្នុងពិធីសារនេះ ។

២. អនុគណៈកម្មាធិការបង្ការត្រូវបំពេញការងាររបស់ខ្លួនក្នុងក្របខ័ណ្ឌនៃធម្មនុញ្ញសហប្រជាជាតិ ហើយត្រូវអនុវត្តស្របតាមគោលបំណងនិងគោលការណ៍ផ្សេងៗនៃធម្មនុញ្ញនេះក៏ដូចជាលិខិតបទដ្ឋាននានារបស់អង្គការសហប្រជាជាតិ ស្តីពីការប្រព្រឹត្តលើជនទាំងឡាយដែលត្រូវបានដកហូតសេរីភាពរបស់ខ្លួន ។

៣. ដូចគ្នានេះដែរ អនុគណៈកម្មាធិការបង្ការ ត្រូវអនុវត្តតាមគោលការណ៍រក្សាការសំងាត់ ភាពឥតលំអៀង ភាពមិនប្រកាន់និន្នាការសកលភាព និងគោលការណ៍សត្យានុម័ត ។

៤. អនុគណៈកម្មាធិការបង្ការ និងរដ្ឋភាគីទាំងអស់ ត្រូវសហការគ្នាអនុវត្តពិធីសារនេះ ។

### មាត្រា ៣

រដ្ឋភាគីនីមួយៗ ត្រូវបង្កើតចាត់តាំង ឬរក្សាឱ្យមាននៅថ្នាក់ជាតិ នូវស្ថាប័នត្រួតពិនិត្យមួយ ឬច្រើនដើម្បីបង្ការទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (ពីនេះតទៅហៅត្រឹមថា យន្តការបង្ការថ្នាក់ជាតិ) ។

## មាត្រា ៤

១. អនុលោមតាមពិធីសារនេះ រដ្ឋភាគីនីមួយៗត្រូវអនុញ្ញាតឱ្យយន្តការត្រួតពិនិត្យនានា ដូចមានចែងក្នុងមាត្រា២ និងមាត្រា៣ ទៅមើលកន្លែងឃុំឃាំងណាមួយ ស្ថិតក្រោមដែនសមត្ថកិច្ច និងការគ្រប់គ្រងរបស់ខ្លួន ដែលជនទាំងឡាយត្រូវបាន ឬអាចត្រូវបានដកហូតសេរីភាព ទោះជាដោយតាមបញ្ជារបស់អាជ្ញាធរសាធារណៈ ឬតាមការផ្តួចផ្តើម ឬការយល់ព្រម ឬការស្រុះស្រួលគ្នាក៏ដោយ (ពីនេះតទៅហៅត្រឹមថា កន្លែងឃុំឃាំង) ។ ប្រសិនជាចាំបាច់ ការត្រួតពិនិត្យទាំងនេះ ត្រូវមានគោលដៅ ដើម្បីពង្រឹងការការពារជនទាំងឡាយពីអំពើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប ។

២. សំរាប់គោលបំណងនៃពិធីសារនេះ ការដកហូតសេរីភាព មានន័យថារាល់ទម្រង់នៃការឃុំខ្លួន ឬការដាក់ពន្ធនាគារ ឬការដាក់ជនណាម្នាក់នៅក្នុងកន្លែងឃុំឃាំងឯកជន ឬសាធារណៈដែលគេមិនអនុញ្ញាតឱ្យជននោះ ចាកចេញតាមចិត្ត ដោយធ្វើតាមបញ្ជារបស់អាជ្ញាធររដ្ឋបាល អាជ្ញាធរតុលាការ ឬអាជ្ញាធរដទៃទៀត ។

## ផ្នែកទី ២

## អនុគណៈកម្មាធិការបង្ការ

## មាត្រា ៥

១. អនុគណៈកម្មាធិការបង្ការនេះ ត្រូវមានសមាជិក១០រូប ។ បន្ទាប់ពីការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកទី៥០នៃពិធីសារនេះ ចំនួនសមាជិកអនុគណៈកម្មាធិការបង្ការត្រូវកើនឡើងដល់២៥រូប ។

២. សមាជិកនៃអនុគណៈកម្មាធិការបង្ការ ត្រូវបានជ្រើសរើស ពីក្នុងចំណោមបុគ្គលដែលមានអាកប្បកិរិយាសីលធម៌ខ្ពស់ មានបទពិសោធន៍ខាងវិជ្ជាជីវៈក្នុងវិស័យគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ ជាពិសេសក្នុងការគ្រប់គ្រងតាមច្បាប់ព្រហ្មទណ្ឌ ពន្ធនាគារ ឬនគរបាល ឬក្នុងវិស័យផ្សេងទៀតពាក់ព័ន្ធនឹងការប្រព្រឹត្តទៅលើជនទាំងឡាយ ដែលត្រូវបានដកហូតសេរីភាពរបស់ខ្លួន ។

៣. ក្នុងសមាសភាពនៃអនុគណៈកម្មាធិការបង្ការ គេត្រូវធ្វើការពិចារណាឱ្យបានត្រឹមត្រូវ ដោយផ្អែកលើការបែងចែកប្រកបដោយសមភាព តាមភូមិសាស្ត្រ និងភាពជាអ្នកតំណាងមកពីទំរង់ផ្សេងៗគ្នានៃអារ្យធម៌ និងតាមប្រព័ន្ធច្បាប់នៃរដ្ឋជាភាគីនានា ។

៤. នៅក្នុងសមាសភាពនេះ គេក៏ត្រូវពិចារណាផងដែរ អំពីតុល្យភាពនៃភាពជាតំណាងខាងយេនឌ័រ ដោយផ្អែកលើមូលដ្ឋាននៃគោលការណ៍សមភាព និងការមិនរើសអើង ។

៥. អនុគណៈកម្មាធិការបង្ការនេះ មិនអាចមានសមាជិកពីររូប ជាជនជាតិនៃរដ្ឋតែមួយឡើយ ។

៦. សមាជិកអនុគណៈកម្មាធិការបង្ការ ត្រូវធ្វើការក្នុងឋានៈជាបុគ្គលឯកជន ត្រូវប្រកាន់ភាពឯករាជ្យ និងមិនលំអៀង ហើយត្រូវបំរើការជូនអនុគណៈកម្មាធិការបង្ការឱ្យមានប្រសិទ្ធភាព ។

## មាត្រា ៦

១. រដ្ឋភាគីនីមួយៗ អាចបញ្ជូនឈ្មោះបេក្ខជន ស្របតាមកថាខ័ណ្ឌទី២នៃមាត្រានេះ មិនឱ្យលើសពី២រូប ដែលមានគុណវុឌ្ឍិ និងបំពេញតាមការទាមទារទាំងឡាយដែលមានចែងក្នុងមាត្រា៥ ហើយត្រូវផ្ដល់ព័ត៌មានលំអិតស្ដីពីគុណវុឌ្ឍិ នៃបេក្ខជនទាំងនោះផង ។

២. បេក្ខជនដែលទទួលការតែងតាំងត្រូវមានសញ្ជាតិរបស់រដ្ឋភាគី នៃពិធីសារនេះ :

(ក) យ៉ាងហោចណាស់មានបេក្ខជន១រូប ត្រូវមានសញ្ជាតិរបស់រដ្ឋភាគីដែលតែងតាំង ។

(ខ) រដ្ឋភាគីមិនអាចតែងតាំងបេក្ខជននៃជាតិខ្លួនលើសពី២រូបបានឡើយ ។

(គ) មុនពេលដែលរដ្ឋភាគីមួយ តែងតាំងបេក្ខជនជាជនជាតិនៃរដ្ឋភាគីមួយទៀត រដ្ឋនេះត្រូវស្វែងរក និងទទួលកាយល់ព្រមពីរដ្ឋភាគីនោះសិន ។

៣. យ៉ាងហោចណាស់៥ខែ មុនកាលបរិច្ឆេទនៃការប្រជុំរបស់រដ្ឋភាគីទាំងឡាយ បើការបោះឆ្នោតនឹងត្រូវរៀបចំធ្វើនៅក្នុងរយៈពេលនោះ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវធ្វើលិខិតអញ្ជើញរដ្ឋភាគីទាំងអស់ ឱ្យបញ្ជូនឈ្មោះបេក្ខជនរបស់ខ្លួនមកក្នុងរយៈពេល៣ខែ ។ អគ្គលេខាធិការ ត្រូវរៀបចំបញ្ជីឈ្មោះបេក្ខជន ដែលទទួលការតែងតាំងទាំងនោះ តាមលំដាប់អក្ខរក្រម ដោយបញ្ជាក់ពីឈ្មោះរដ្ឋភាគី ដែលបានបញ្ជូនឈ្មោះបេក្ខជនទាំងនោះមកផង ។

## មាត្រា ៧

១. សមាជិកអនុគណៈកម្មាធិការបង្ការ ត្រូវបានបោះឆ្នោតជ្រើសរើសតាមរបៀបខាងក្រោមនេះ:

(ក) ការពិចារណាជាបឋម ត្រូវផ្ដល់ជូនចំពោះការបំពេញបានតាមលក្ខណៈវិនិច្ឆ័យ និងការទាមទារដូចមានចែងក្នុងមាត្រា៥ នៃពិធីសារបន្ថែមនេះ ។

(ខ) ការបោះឆ្នោតលើកដំបូង ត្រូវធ្វើឡើងមិនឱ្យហួសពីរយៈពេល៦ខែ ក្រោយពីកាលបរិច្ឆេទនៃការចូលជាធរមាននៃពិធីសារនេះទេ ។

(គ) រដ្ឋភាគីទាំងឡាយ ត្រូវបោះឆ្នោតជ្រើសរើសសមាជិកអនុគណៈកម្មាធិការបង្ការ តាមរយៈការបោះឆ្នោតជាសម្ងាត់ ។

(ឃ) ការបោះឆ្នោតជ្រើសរើសសមាជិកអនុគណៈកម្មាធិការបង្ការ ត្រូវធ្វើក្នុងសម័យប្រជុំនៃរដ្ឋភាគី រយៈពេល២ឆ្នាំម្ដង តាមការកោះអញ្ជើញ របស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ កូរ៉ុមសម្រាប់កិច្ចប្រជុំបែបនេះ គឺ២ភាគ៣នៃរដ្ឋភាគីទាំងអស់ ។ បេក្ខជនដែលជាប់ជាសមាជិកនៃអនុគណៈ

កម្មាធិការបង្ការ ត្រូវតែជាបេក្ខជនដែលទទួលបានសន្លឹកឆ្នោតច្រើនបំផុត និងសម្លេងភាគច្រើនដាច់ខាត ពីតំណាងរបស់រដ្ឋភាគីដែលមានវត្តមាន និងបានបោះឆ្នោត ។

២. ប្រសិនបើក្នុងកិច្ចដំណើរការបោះឆ្នោតនេះ បេក្ខជន២រូប មានសញ្ជាតិនៃរដ្ឋភាគីតែមួយ មានសិទ្ធិធ្វើជាសមាជិកអនុគណៈកម្មាធិការបង្ការ បេក្ខជនម្នាក់ដែលទទួលបានសំលេងច្រើនជាង ត្រូវធ្វើជាសមាជិកអនុគណៈកម្មាធិការបង្ការ ។ ប្រសិនបើបេក្ខជនទាំង២រូបនេះ ទទួលបានសំលេងស្មើគ្នា ត្រូវអនុវត្តតាមនីតិវិធី ដូចខាងក្រោមនេះ :

(ក) ប្រសិនបើមានតែបេក្ខជនម្នាក់ ត្រូវបានតែងតាំងដោយរដ្ឋភាគីដែលបេក្ខជននោះ ជាជនជាតិនៃរដ្ឋនោះ បេក្ខជននោះត្រូវធ្វើជាសមាជិកអនុគណៈកម្មាធិការបង្ការ ។

(ខ) ប្រសិនបើបេក្ខជនទាំង២រូប ត្រូវបានតែងតាំងដោយរដ្ឋភាគី ដែលបេក្ខជនទាំងនោះ ជាជនជាតិនៃរដ្ឋនោះ ការបោះឆ្នោតដាច់ដោយឡែក និងជាសំងាត់មួយ ត្រូវរៀបចំធ្វើឡើង ដើម្បីកំណត់ថាតើបេក្ខជនណាត្រូវធ្វើជាសមាជិក ។

(គ) ប្រសិនជាគ្មានបេក្ខជនណាម្នាក់ ត្រូវបានតែងតាំងដោយរដ្ឋភាគី ដែលបេក្ខជននោះ ជាជនជាតិនៃរដ្ឋនោះ ការបោះឆ្នោតដាច់ដោយឡែក និងជាសំងាត់ ត្រូវរៀបចំធ្វើឡើង ដើម្បីកំណត់ថាតើបេក្ខជនណាត្រូវធ្វើជាសមាជិក ។

## មាត្រា ៨

ប្រសិនបើ សមាជិកអនុគណៈកម្មាធិការបង្ការណាម្នាក់ ទទួលមរណភាព ឬសុំលាឈប់ពីមុខតំណែង ឬដោយបុព្វហេតុផ្សេង ដែលមិនអាចបំពេញមុខងារឱ្យអនុគណៈកម្មាធិការបង្ការនោះបាន រដ្ឋភាគី ត្រូវតែងតាំងសមាជិកមួយរូបទៀត ដែលមានគុណសម្បត្តិគ្រប់គ្រាន់ និងបំពេញតាមសេចក្តីតម្រូវដូចមានចែងក្នុងមាត្រា៥ ដោយគិតគូរពីសេចក្តីត្រូវការឱ្យមានតុល្យភាពត្រឹមត្រូវ ក្នុងចំណោមវិស័យផ្សេងទៀតនៃសមត្ថកិច្ច ដើម្បីបំរើការងាររហូតដល់សម័យប្រជុំលើកក្រោយនៃរដ្ឋភាគី ដោយមានការយល់ព្រមពីរដ្ឋភាគីភាគច្រើន ។ ការយល់ព្រមនេះត្រូវចាត់ទុកជាបានការ ប្រសិនបើរដ្ឋភាគីចំនួនពាក់កណ្តាល ឬច្រើនជាងនេះ មិនបញ្ចេញយោបល់ជំទាស់ក្នុងរយៈពេល៦សប្តាហ៍ បន្ទាប់ពីបានទទួលដំណឹង ស្តីពីការស្នើសុំតែងតាំងនេះ ពីអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

## មាត្រា ៩

សមាជិកអនុគណៈកម្មាធិការបង្ការ ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោត សំរាប់មួយអាណត្តិ ៤ឆ្នាំ ។ សមាជិកទាំងនេះ មានសិទ្ធិឈរឈ្មោះបោះឆ្នោតបានតែម្តងទៀតប៉ុណ្ណោះ ប្រសិនបើត្រូវបានតែងតាំងជាថ្មី។ អាណត្តិនៃសមាជិកពាក់កណ្តាលដែលជាប់ឆ្នោតនៅពេលបោះឆ្នោតលើកទី១ ត្រូវផុតកំណត់ក្នុងរយៈពេល២ឆ្នាំ ។ បន្ទាប់ពីការបោះឆ្នោតលើកទី១ភ្លាម ឈ្មោះសមាជិកទាំងនោះ ត្រូវចាប់ឆ្នោតជ្រើសរើសដោយប្រធានអង្គប្រជុំ ដូចមានចែងក្នុងមាត្រា៧ កថាខណ្ឌទី១ (ឃ) ។

### មាត្រា ១០

១. អនុគណៈកម្មាធិការបង្ការ ត្រូវបោះឆ្នោតជ្រើសរើសមន្ត្រីរបស់ខ្លួន សំរាប់អាណត្តិ២ឆ្នាំ ។ មន្ត្រីទាំងនេះ អាចឈរឈ្មោះអោយគេបោះឆ្នោតសាជាថ្មីបាន ។

២. អនុគណៈកម្មាធិការបង្ការ ត្រូវបង្កើតវិធាននីតិវិធីរបស់ខ្លួន ។ វិធានទាំងនេះ ត្រូវចែងពីលក្ខខណ្ឌមួយចំនួនដូចជា :

(ក) សមាជិកពាក់កណ្តាលបូកមួយ (50+1) បង្កើតបានជាកូរ៉ុម ។

(ខ) សេចក្តីសំរេចរបស់អនុគណៈកម្មាធិការបង្ការ ត្រូវធ្វើឡើងដោយសម្លេងភាគច្រើនដាច់ខាត នៃសមាជិកដែលមានវត្តមាន ។

(គ) អនុគណៈកម្មាធិការបង្ការ ត្រូវប្រជុំជាសំងាត់ ។

៣. អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវកោះប្រជុំដំបូងរបស់អនុគណៈកម្មាធិការបង្ការ ។ បន្ទាប់ពីការប្រជុំដំបូងរបស់ខ្លួន អនុគណៈកម្មាធិការបង្ការ ត្រូវប្រជុំទៅតាមពេលវេលាដែលបានកំណត់នៅក្នុងវិធាននីតិវិធីរបស់ខ្លួន ។ អនុគណៈកម្មាធិការបង្ការ និងគណៈកម្មាធិការប្រឆាំងទារុណកម្ម ត្រូវរៀបចំបើកសម័យប្រជុំរបស់ខ្លួន នៅពេលជាមួយគ្នាយ៉ាងតិចម្តងក្នុង១ឆ្នាំ ។

## ផ្នែកទី ៣
## អាណត្តិរបស់អនុគណៈកម្មាធិការបង្ការ

### មាត្រា ១១

អនុគណៈកម្មាធិការបង្ការត្រូវ :

(ក) ពិនិត្យកន្លែងឃុំឃាំងទាំងឡាយ ដូចមានចែងក្នុងមាត្រា៤ និងធ្វើអនុសាសន៍ទៅរដ្ឋភាគីអំពីការការពារជនទាំងឡាយដែលត្រូវបានដកហូតសេរីភាពរបស់ខ្លួន ពីការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ។

(ខ) ចំពោះយន្តការទប់ស្កាត់ថ្នាក់ជាតិ អនុគណៈកម្មាធិការត្រូវ :

(១) ផ្តល់យោបល់ និងជួយរដ្ឋភាគី តាមការចាំបាច់ ក្នុងការបង្កើតយន្តការរបស់ខ្លួន ។

(២) រក្សាទំនាក់ទំនងផ្ទាល់ ហើយប្រសិនជាចាំបាច់ ជាសំងាត់ជាមួយយន្តការបង្ការថ្នាក់ជាតិ និងផ្តល់ការបណ្តុះបណ្តាល និងជំនួយបច្ចេកទេស ក្នុងគោលបំណងពង្រឹងសមត្ថភាពពួកគេ ។

(៣) ណែនាំ និងជួយពួកគេក្នុងការវាយតំលៃពីសេចក្តីត្រូវការ និងមធ្យោបាយចាំបាច់ ដើម្បីពង្រឹងការការពារជនទាំងឡាយដែលត្រូវបានដកហូតសេរីភាពរបស់ខ្លួន ពីការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ។

(ឃ) ធ្វើអនុសាសន៍ និងសេចក្តីសង្កេតទៅរដ្ឋភាគី ក្នុងគោលដៅពង្រឹងសមត្ថភាព និងអាណត្តិនៃយន្តការបង្ការថ្នាក់ជាតិ ដើម្បីបង្ការអំពើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ។

(ង) សហការដើម្បីបង្ការអំពើទារុណកម្មជាទូទៅ ជាមួយស្ថាប័ន និងយន្តការអង្គការសហប្រជាជាតិពាក់ព័ន្ធនានា ព្រមទាំងជាមួយស្ថាប័ន ឬអង្គការអន្តរជាតិតំបន់ និងជាតិនានាដែលធ្វើការក្នុងគោលដៅពង្រឹងការការពារជនគ្រប់រូប ពីការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ។

## មាត្រា ១២

ដើម្បីឱ្យអនុគណៈកម្មាធិការបង្ការអាចបំពេញអាណត្តិរបស់ខ្លួនដូចមានចែងក្នុងមាត្រា១១ រដ្ឋភាគីត្រូវអនុវត្តដូចតទៅនេះ :

(ក) ទទួលអនុគណៈកម្មាធិការបង្ការនៅលើទឹកដីរបស់ខ្លួន និងអនុញ្ញាតឱ្យអនុគណៈកម្មាធិការបង្ការ ចូលពិនិត្យកន្លែងឃុំឃាំង ដូចមានចែងក្នុងមាត្រា៤ នៃពិធីសារនេះ ។

(ខ) ផ្តល់ព័ត៌មានពាក់ព័ន្ធទាំងឡាយដែលអនុគណៈកម្មាធិការបង្ការអាចស្នើសុំ ដើម្បីវាយតំលៃពីសេចក្តីត្រូវការ និងវិធានការនានាដែលគួរត្រូវបានអនុម័ត ដើម្បីពង្រឹងការការពារជនទាំងឡាយដែលត្រូវបានដកហូតសេរីភាពរបស់ខ្លួន ពីការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ។

(គ) ជំរុញលើកទឹកចិត្ត និងសំរួលដល់ទំនាក់ទំនងរវាងអនុគណៈកម្មាធិការបង្ការ និងយន្តការបង្ការថ្នាក់ជាតិ ។

(ឃ) ពិនិត្យអនុសាសន៍របស់អនុគណៈកម្មាធិការបង្ការ ហើយជួបប្រជុំពិភាក្សាលើអនុសាសន៍នោះ អំពីវិធានការពង្រឹងការអនុវត្តន៍មួយចំនួនដែលអាចមាន ។

## មាត្រា ១៣

១. អនុគណៈកម្មាធិការបង្ការ ត្រូវបង្កើតជាដំបូងដោយការចាប់ឆ្នោត នូវកម្មវិធីទស្សនកិច្ចជាទៀងទាត់ ទៅកាន់រដ្ឋភាគីនានា ដើម្បីបំពេញអាណត្តិរបស់ខ្លួន ដូចមានចែងក្នុងមាត្រា១១ ។

២. បន្ទាប់ពីមានការពិគ្រោះយោបល់ អនុគណៈកម្មាធិការបង្ការ ត្រូវជូនដំណឹងទៅរដ្ឋភាគីអំពីកម្មវិធីរបស់ខ្លួន ដើម្បីអោយរដ្ឋនោះ អាចធ្វើការរៀបចំចាំបាច់ជាក់ស្តែង ដោយមិនមានការពន្យាពេល ដើម្បីសំរួលដល់ដំណើរទស្សនកិច្ចនេះ ។

៣. ទស្សនកិច្ចនេះ ត្រូវធ្វើឡើងដោយសមាជិកយ៉ាងតិច២រូប នៃអនុគណៈកម្មាធិការបង្ការ ។ ប្រសិនជាចាំបាច់ សមាជិកទាំងនេះ អាចត្រូវបានអមដំណើរដោយអ្នកជំនាញការទាំងឡាយដែលមានបទពិសោធន៍ផ្នែកវិជ្ជាជីវៈ និងចំណេះដឹងក្នុងវិស័យផ្សេងៗ ដែលគ្របដណ្តប់ដោយពិធីសារនេះ ហើយត្រូវបានជ្រើសរើសចេញពីបញ្ជីឈ្មោះអ្នកជំនាញការ ដែលបានរៀបចំឡើងដោយ ផ្អែកលើសំណើររបស់រដ្ឋភាគី ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនិងមជ្ឈមណ្ឌលអង្គការសហប្រជាជាតិទទួលបន្ទុកការបង្ការឧក្រិដ្ឋកម្ម ។ ក្នុងការរៀបចំបញ្ជីឈ្មោះនេះ រដ្ឋភាគីពាក់ព័ន្ធ ត្រូវស្នើឈ្មោះអ្នកជំនាញការជាតិមិនឱ្យលើសពី៥នាក់ឡើយ ។ រដ្ឋភាគីសាម៉ី អាចធ្វើការបដិសេធ ពីការដាក់បញ្ចូលអ្នកជំនាញការឯកទេសណាមួយ ទៅក្នុងដំណើរទស្សនៈកិច្ចនោះ ហើយក្នុងករណីនេះ អនុគណៈកម្មាធិការបង្ការ ត្រូវដាក់សំណើសុំអ្នកជំនាញការម្នាក់ផ្សេងទៀត ។

៤. ប្រសិនបើអនុគណៈកម្មាធិការបង្ការ យល់ថាសមស្រប អនុគណៈកម្មាធិការបង្ការ អាចរៀបចំឱ្យមានទស្សនកិច្ចតាមដានរយៈពេលខ្លីមួយបាន បន្ទាប់ពីទស្សនកិច្ចទៀងទាត់នោះ ។

## មាត្រា ១៤

១. ដើម្បីឱ្យអនុគណៈកម្មាធិការបង្ការអាចបំពេញអាណត្តិរបស់ខ្លួនបាន រដ្ឋភាគីនៃពិធីសារនេះ ត្រូវផ្តល់ឱ្យអនុគណៈកម្មាធិការបង្ការ ៖

(ក) ដោយគ្មានការរិតត្បិត នូវព័ត៌មានទាំងអស់ដែលទាក់ទងនឹងចំនួនជនដែលត្រូវបានដកហូតសេរីភាពនៅក្នុងកន្លែងឃុំឃាំង ដូចមានចែងក្នុងមាត្រា៤ ព្រមទាំងចំនួនទីកន្លែង និងទីតាំងរបស់ពួកគេ ។

(ខ) ដោយគ្មានការរិតត្បិត នូវសិទ្ធិក្នុងការទទួលបានព័ត៌មានទាំងអស់ដែលទាក់ទងនឹងប្រព្រឹត្តកម្មលើជនទាំងនោះ ព្រមទាំងលក្ខខណ្ឌនៃការឃុំខ្លួនផង ។

(គ) ដោយអនុលោមតាមកថាខ័ណ្ឌទី២ សិទ្ធិចេញចូលដោយគ្មានការរិតត្បិត ក្នុងការពិនិត្យកន្លែងឃុំឃាំងទាំងអស់ គ្រឿងឧបករណ៍ និងអាគារនានានៃកន្លែងឃុំឃាំង ។

(ឃ) ឱកាសជួបសម្ភាសន៍ជាឯកជនជាមួយជនដែលត្រូវបានដកហូតសេរីភាព ដោយគ្មានសាក្សីដោយផ្ទាល់ ឬដោយមានអ្នកបកប្រែភាសាម្នាក់ ប្រសិនបើចាំបាច់ ក៏ដូចជាជាមួយជនផ្សេងទៀតដែលអនុគណៈកម្មាធិការបង្ការ ជឿជាក់ថា អាចផ្តល់ព័ត៌មានពាក់ព័ន្ធបាន ។

(ង) សេរីភាពក្នុងការជ្រើសរើសទីកន្លែង ដែលអនុគណៈកម្មាធិការបង្ការ ចង់ទៅទស្សនកិច្ច និងជនដែលអនុគណៈកម្មាធិការបង្ការចង់ជួបសម្ភាសន៍ ។

២. ការជំទាស់ទៅនឹងទស្សនៈកិច្ចក្នុងមន្ទីរឃុំឃាំងណាមួយអាចធ្វើទៅបាន តែក្នុងករណីបន្ទាន់បង្ខំដោយមូលហេតុនៃការការពារជាតិ សុវត្ថិភាពសាធារណៈ គ្រោះមហន្តរាយធម្មជាតិ ឬចលាចលធ្ងន់

ធូរនៅកន្លែងដែលត្រូវធ្វើទស្សនកិច្ច ដែលរារាំងជាបណ្ដោះអាសន្នដល់ការធ្វើទស្សនកិច្ចនេះ ។ អត្ថិភាពនៃការប្រកាសភាពមានអាសន្នបែបនេះ មិនអាចលើកជាសំអាងដោយរដ្ឋភាគីណាមួយ ថាជាហេតុផលដើម្បីជំទាស់ទៅនឹងការធ្វើទស្សនកិច្ចនេះឡើយ ។

## មាត្រា ១៥

គ្មានអាជ្ញាធរ ឬមន្ត្រីណាអាចបញ្ជា អនុវត្ត អនុញ្ញាត ឬបណ្ដោយឱ្យមានការដាក់ទណ្ឌកម្មទៅលើបុគ្គល ឬអង្គការណាមួយ ដែលបានទំនាក់ទំនងទៅអនុគណៈកម្មាធិការបង្ការ ឬទៅប្រតិភូរបស់ខ្លួននូវព័ត៌មានណាមួយ ទោះជាព័ត៌មាននោះពិត ឬមិនពិតក្ដី ហើយបុគ្គល ឬអង្គការនោះ មិនត្រូវបានទទួលការរើសអើងដោយវិធីនេះឡើយ ។

## មាត្រា ១៦

១. អនុគណៈកម្មាធិការបង្ការ ត្រូវបញ្ជូនអនុសាសន៍ និងសេចក្ដីសង្កេតរបស់ខ្លួន ជាសំងាត់ទៅរដ្ឋភាគី ហើយប្រសិនជាមានការពាក់ព័ន្ធ ត្រូវបញ្ជូនទៅយន្តការបង្ការថ្នាក់ជាតិ ។

២. អនុគណៈកម្មាធិការបង្ការ បោះពុម្ពផ្សាយរបាយការណ៍របស់ខ្លួន រួមជាមួយសេចក្ដីផ្ដល់មតិរបស់រដ្ឋភាគីពាក់ព័ន្ធ នៅពេលដែលមានការស្នើសុំដោយរដ្ឋភាគីនោះ ។ ប្រសិនបើរដ្ឋភាគី ធ្វើការផ្សព្វផ្សាយតែផ្នែកមួយនៃរបាយការណ៍នេះ អនុគណៈកម្មាធិការបង្ការ អាចបោះពុម្ពផ្សាយរបាយការណ៍នេះទាំងស្រុង ឬមួយផ្នែកក៏បាន ។ ទោះជាយ៉ាងណាក៏ដោយ អនុគណៈកម្មាធិការបង្ការ មិនត្រូវធ្វើការចុះផ្សាយនូវទិន្នន័យផ្ទាល់ខ្លួនរបស់បុគ្គល ដោយគ្មានការយល់ព្រមពីសាមីជននោះឡើយ ។

៣. អនុគណៈកម្មាធិការបង្ការ ត្រូវបង្ហាញរបាយការណ៍ប្រចាំឆ្នាំជាសាធារណៈស្ដីពីសកម្មភាពរបស់ខ្លួន ទៅគណៈកម្មាធិការប្រឆាំងទារុណកម្ម ។

៤. ប្រសិនបើរដ្ឋភាគី បដិសេធមិនព្រមសហការជាមួយអនុគណៈកម្មាធិការបង្ការ ស្របតាមមាត្រា១២ និងមាត្រា១៤ ឬមិនព្រមចាត់វិធានការដើម្បីកែលំអស្ថានភាព តាមស្មារតីនៃអនុសាសន៍របស់អនុគណៈកម្មាធិការបង្ការ គណៈកម្មាធិការប្រឆាំងទារុណកម្ម អាចផ្អែកតាមការស្នើសុំរបស់គណៈកម្មាធិការទប់ស្កាត់ សំរេចដោយសម្លេងភាគច្រើននៃសមាជិករបស់ខ្លួន បន្ទាប់ពីរដ្ឋភាគីមានឱកាសបញ្ចេញពីការយល់ឃើញរបស់ខ្លួន ធ្វើសេចក្ដីថ្លែងការណ៍ជាសាធារណៈអំពីបញ្ហានោះ ឬបោះពុម្ពផ្សាយរបាយការណ៍របស់អនុគណៈកម្មាធិការបង្ការ ។

## ផ្នែកទី ៤
## យន្តការបង្ការថ្នាក់ជាតិ
### មាត្រា ១៧

រដ្ឋភាគីនីមួយៗ ត្រូវរក្សាចាត់តាំង ឬបង្កើតយន្តការបង្ការឯករាជថ្នាក់ជាតិមួយ ឬច្រើន ដើម្បីបង្ការការធ្វើទារុណកម្មនៅថ្នាក់ជាតិ យ៉ាងយូរបំផុតរយៈពេល១ឆ្នាំ បន្ទាប់ពីថ្ងៃចូលជាធរមាននៃពិធីសារនេះ ឬនៃការឱ្យសច្ចាប័ន ឬនៃការចូលជាសមាជិករបស់ខ្លួន ។ យន្តការដែលបានបង្កើតដោយអង្គភាពវិមជ្ឈការនានា អាចត្រូវបានចាត់តាំងជាយន្តការបង្ការថ្នាក់ជាតិ ដើម្បីគោលបំណងនៃពិធីសារនេះ ប្រសិនបើយន្តការទាំងនេះ ស្របទៅនឹងបទបញ្ញត្តិនៃពិធីសារនេះ ។

### មាត្រា ១៨

១. រដ្ឋភាគី ត្រូវធានាការពារឯករាជ្យភាពមុខងាររបស់យន្តការបង្ការថ្នាក់ជាតិ ក៏ដូចជាឯករាជ្យភាពនៃបុគ្គលិករបស់ខ្លួន ។

២. រដ្ឋភាគីត្រូវចាត់វិធានការចាំបាច់ ដើម្បីធានាថា អ្នកជំនាញការនៃយន្តការបង្ការថ្នាក់ជាតិមានចំណេះដឹងវិជ្ជាជីវៈ និងសមត្ថភាពដូចដែលបានទាមទារ ។ រដ្ឋភាគី ត្រូវខិតខំរក្សាឱ្យបានតុល្យភាពខាងយេនឌ័រ និងភាពជាតំណាងគ្រប់គ្រាន់ នៃក្រុមជាតិពន្ធុ និងក្រុមជនជាតិភាគតិចនៅក្នុងប្រទេស ។

៣. រដ្ឋភាគី ត្រូវផ្តល់ធនធានដែលចាំបាច់សំរាប់ការប្រព្រឹត្តទៅនៃយន្តការបង្ការថ្នាក់ជាតិ ។

៤. នៅពេលបង្កើតយន្តការបង្ការថ្នាក់ជាតិ រដ្ឋភាគីត្រូវធ្វើការពិចារណាឱ្យបានត្រឹមត្រូវចំពោះគោលការណ៍ទាក់ទងនឹងឋានៈ និងការប្រព្រឹត្តទៅនៃស្ថាប័នជាតិ ទទួលបន្ទុកការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស ។

### មាត្រា ១៩

យ៉ាងហោចណាស់ យន្តការបង្ការថ្នាក់ជាតិ ត្រូវមានអំណាចដូចខាងក្រោម :

(ក) ពិនិត្យយ៉ាងទៀងទាត់ អំពីការប្រព្រឹត្តទៅលើជនដែលត្រូវបានដកហូតសេរីភាព នៅក្នុងទីកន្លែងទាំងឡាយ ដូចមានចែងក្នុងមាត្រា៤ ប្រសិនជាចាំបាច់ ក្នុងគោលដៅពង្រឹងការការពារដល់ពួកគេពីការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ។

(ខ) ផ្តល់អនុសាសន៍ដល់អាជ្ញាធរពាក់ព័ន្ធ ក្នុងគោលបំណងកែលំអការប្រព្រឹត្ត និងលក្ខខណ្ឌនៃជនដែលត្រូវបានដកហូតសេរីភាព និងដើម្បីបង្ការការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ដោយពិនិត្យទៅលើលិខិតបទដ្ឋានពាក់ព័ន្ធរបស់អង្គការសហប្រជាជាតិ ។

(គ) លើកសំណើ និងសេចក្ដីសង្កេតពាក់ព័ន្ធនឹងច្បាប់ដែលកំពុងមានជាធរមាន និងសេចក្ដីព្រាងច្បាប់នានា ។

### មាត្រា ២០

ដើម្បីឱ្យយន្តការបង្ការថ្នាក់ជាតិ អាចបំពេញអាណត្តិរបស់ខ្លួនបាន រដ្ឋភាគីនៃពិធីសារនេះ ត្រូវអនុញ្ញាតឱ្យយន្តការនេះនូវ :

(ក) សិទ្ធិទទួលបានរាល់ព័ត៌មានពាក់ព័ន្ធនឹងចំនួនជនដែលត្រូវបានដកហូតសេរីភាពនៅក្នុងកន្លែងឃុំឃាំង ដូចមានចែងក្នុងមាត្រា៤ ក៏ដូចជាចំនួនកន្លែង និងទីតាំងរបស់ពួកគេ ។

(ខ) សិទ្ធិទទួលបានរាល់ព័ត៌មាន ដែលនិយាយពីការប្រព្រឹត្តទៅលើជនទាំងនេះ ក៏ដូចជាស្ថានភាព នៃការឃុំខ្លួនរបស់ពួកគេផងដែរ ។

(គ) សិទ្ធិចេញចូលពិនិត្យរាល់ទីកន្លែងឃុំឃាំង រចនាសម្ពន្ធនានា នៃទីកន្លែងឃុំឃាំង និងគ្រឿងឧបករណ៍ ។

(ឃ) ឱកាសជួបសម្ភាសន៍ជាឯកជនជាមួយជនដែលត្រូវបានដកហូតសេរីភាពដោយគ្មានសាក្សី ទោះជាដោយផ្ទាល់ ឬដោយមានអ្នកបកប្រែភាសាម្នាក់ ប្រសិនបើចាំបាច់ ព្រមទាំងជាមួយជនផ្សេងទៀត ដែលយន្តការបង្ការថ្នាក់ជាតិយល់ថា អាចផ្ដល់ព័ត៌មានពាក់ព័ន្ធបាន ។

(ង) សេរីភាពក្នុងការជ្រើសរើសទីកន្លែង ដែលខ្លួនចង់ទៅទស្សនកិច្ច និងជនដែលខ្លួនចង់ជួបសម្ភាសន៍ ។

(ច) សិទ្ធិមានទំនាក់ទំនងជាមួយអនុគណៈកម្មាធិការបង្ការ ដើម្បីផ្ដល់ព័ត៌មាន និងជួបប្រជុំជាមួយអនុគណៈកម្មាធិការបង្ការនេះ ។

### មាត្រា ២១

១. គ្មានអាជ្ញាធរ ឬមន្ត្រីណាអាចបញ្ជា អនុវត្ត អនុញ្ញាត ឬបណ្ដោយឱ្យមានការដាក់ទណ្ឌកម្មទៅលើបុគ្គល ឬអង្គការណាមួយ ពីការបានធ្វើទំនាក់ទំនងផ្ដល់ព័ត៌មាន ដល់យន្តការទប់ស្កាត់ថ្នាក់ជាតិ ទោះជាព័ត៌មាននោះពិត ឬមិនពិតក្ដី ហើយបុគ្គល ឬអង្គការទាំងនេះ មិនត្រូវទទួលរងការរើសអើងតាមវិធីណាមួយឡើយ ។

២. ព័ត៌មានសំងាត់ដែលប្រមូលបានដោយយន្តការបង្ការថ្នាក់ជាតិ ត្រូវបានផ្ដល់បុព្វសិទ្ធិ ។ គ្មានព័ត៌មានផ្ទាល់ខ្លួនត្រូវបានចុះផ្សាយដោយគ្មានការយល់ព្រមពីសាម៉ីជននោះឡើយ ។

### មាត្រា ២២

អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីពាក់ព័ន្ធ ត្រូវពិនិត្យមើលអនុសាសន៍របស់យន្តការបង្ការថ្នាក់ជាតិ ហើយត្រូវធ្វើការពិភាក្សាជាមួយយន្តការនេះ អំពីវិធានការអនុវត្តដែលអាចមាន ។

## មាត្រា ២៣

រដ្ឋភាគីនៃពិធីសារនេះ មានភារកិច្ចបោះពុម្ព និងផ្សព្វផ្សាយរបាយការណ៍ប្រចាំឆ្នាំរបស់យន្តការបង្ការថ្នាក់ជាតិ ។

# ផ្នែកទី ៥

# សេចក្តីប្រកាស

## មាត្រា ២៤

១. នៅពេលផ្តល់សច្ចាប័ន រដ្ឋភាគីអាចប្រកាសលើកពេលអនុវត្តកាតព្វកិច្ចរបស់ខ្លួន ស្របតាមផ្នែកទី៣ ឬផ្នែកទី៤ នៃពិធីសារនេះបាន ។

២. ការពន្យាពេលនេះ ត្រូវមានសុពលភាពរយៈពេលអតិបរមា៣ឆ្នាំ ។ បន្ទាប់ពីរដ្ឋភាគីបានធ្វើសេចក្តីថ្លែងការណ៍យ៉ាងត្រឹមត្រូវ និងបន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយអនុគណៈកម្មាធិការបង្ការគណៈកម្មាធិការប្រឆាំងទារុណកម្ម អាចពន្យាពេលដែលបានកំណត់នេះ រយៈពេល២ឆ្នាំបន្ថែមទៀត ។

# ផ្នែកទី ៦

# បទប្បញ្ញត្តិហិរញ្ញវត្ថុ

## មាត្រា ២៥

១. ការចំណាយរបស់អនុគណៈកម្មាធិការបង្ការ ក្នុងការអនុវត្តន៍ពិធីសារនេះ គឺជាបន្ទុករបស់អង្គការសហប្រជាជាតិ ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវផ្តល់បុគ្គលិកចាំបាច់ និងអាគារសំរាប់ឱ្យអនុគណៈកម្មាធិការបង្ការ បំពេញមុខងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ស្របតាមពិធីសារនេះ ។

## មាត្រា ២៦

១. មូលនិធិពិសេសមួយ ត្រូវបានបង្កើតឡើង ស្របតាមនីតិវិធីពាក់ព័ន្ធរបស់មហាសន្និបាតដែលមូលនិធិនេះ ត្រូវចាត់ចែងស្របតាមវិធាន និងបទបញ្ញត្តិហិរញ្ញវត្ថុរបស់អង្គការសហប្រជាជាតិ ដើម្បីជួយជាហិរញ្ញវត្ថុដល់ការអនុវត្តន៍អនុសាសន៍ទាំងឡាយដែលបានធ្វើឡើងដោយអនុគណៈកម្មាធិការបង្ការចំពោះរដ្ឋភាគីមួយ បន្ទាប់ពីការធ្វើទស្សនកិច្ចទៅកាន់រដ្ឋភាគីនោះ ព្រមទាំងជួយ ក្នុងកម្មវិធីអប់រំរបស់យន្តការបង្ការថ្នាក់ជាតិ ។

២. មូលនិធិពិសេសនេះ អាចត្រូវផ្តល់ តាមរយៈវិភាគទានស្ម័គ្រចិត្ត ដោយរដ្ឋាភិបាលនានា អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តររដ្ឋាភិបាល និងអង្គភាពសាធារណៈ ឬឯកជនដទៃទៀត ។

## ផ្នែកទី ៧
## អវសានប្បញ្ញត្តិ
### មាត្រា ២៧

១. ពិធីសារនេះ បើកឱ្យចុះហត្ថលេខា ដោយរដ្ឋភាគីដែលបានចុះហត្ថលេខាលើអនុសញ្ញានេះ ។

២. ពិធីសារនេះ ជាកម្មវត្ថុនៃការផ្តល់សច្ចាប័នដោយរដ្ឋណាក៏ដោយ ដែលបានឱ្យសច្ចាប័ន ឬចូលជាសមាជិកនៃអនុសញ្ញានេះ ។ លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ត្រូវតំកល់ទុកនៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៣. ពិធីសារនេះ បើកឱ្យចូលជាសមាជិកដោយរដ្ឋណាក៏ដោយ ដែលបានផ្តល់សច្ចាប័ន ឬចូលជាសមាជិកនៃអនុសញ្ញានេះ ។

៤. ការចូលជាសមាជិក ត្រូវមានជាធរមានបញ្ញត្តិ គិតចាប់ពីការតំកល់លិខិតុបករណ៍នៃការចូលជាសមាជិក នៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៥. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវជូនដំណឹងដល់រដ្ឋទាំងអស់ដែលបានចុះហត្ថលេខាលើពិធីសារនេះ ឬដែលបានចូលជាសមាជិកនៃពិធីសារនេះ អំពីលិខិតុបករណ៍នីមួយៗនៃការឱ្យសច្ចាប័ន ឬការចូលជាសមាជិក ។

### មាត្រា ២៨

១. ពិធីសារនេះត្រូវចូលជាធរមាននៅថ្ងៃទី៣០ ក្រោយពីកាលបរិច្ឆេទនៃការតំកល់លិខិតុបករណ៍ទី២០ នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិក នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

២. ចំពោះរដ្ឋនីមួយៗ ដែលនឹងផ្តល់សច្ចាប័ន ឬនឹងចូលជាសមាជិកនៃពិធីសារនេះ បន្ទាប់ពីការតំកល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកទី២០ នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ពិធីសារនេះ នឹងចូលជាធរមានសំរាប់រដ្ឋនោះនៅ៣០ថ្ងៃ ក្រោយពីកាលបរិច្ឆេទនៃការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬចូលជាសមាជិករបស់ខ្លួន ។

### មាត្រា ២៩

បទបញ្ញត្តិនៃពិធីសារនេះ ត្រូវអនុវត្តលើគ្រប់ផ្នែកទាំងអស់នៃរដ្ឋសហព័ន្ធ ដោយគ្មានការកម្រិតព្រំដែន ឬការលើកលែងឡើយ ។

### មាត្រា ៣០

មិនអនុញ្ញាតឱ្យដាក់ខលក្ខខណ្ឌណាមួយ ចំពោះពិធីសារនេះឡើយ ។

## មាត្រា ៣១

បទបញ្ញត្តិនៃពិធីសារនេះ មិនបានធ្វើឱ្យប៉ះពាល់ដល់កាតព្វកិច្ចរបស់រដ្ឋភាគី ក្រោមអនុសញ្ញាតំបន់ដែលបង្កើតប្រព័ន្ធពិនិត្យកន្លែងឃុំឃាំងនានានោះទេ ។ អនុគណៈកម្មាធិការបង្ការ និងស្ថាប័នដទៃទៀតដែលបានបង្កើតឡើងក្រោមអនុសញ្ញាតំបន់ទាំងនោះ ត្រូវបានជំរុញលើកទឹកចិត្តឱ្យពិគ្រោះយោបល់ និងសហការក្នុងគោលបំណងជៀសវាងការងារត្រួតគ្នា និងដើម្បីលើកស្ទួយដល់គោលដៅនៃពិធីសារនេះឱ្យមានប្រសិទ្ធភាព ។

## មាត្រា ៣២

បទបញ្ញត្តិនៃពិធីសារនេះ មិនបានធ្វើអោយប៉ះពាល់ ដល់កាតព្វកិច្ចនៃរដ្ឋភាគី ចំពោះអនុសញ្ញាទីក្រុងហ្សឺណែវទាំង៤ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងពិធីសារបន្ថែមនានានៃអនុសញ្ញាទាំងនោះ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៧៧ទេ ឬឱកាសដែលមានចំពោះរដ្ឋភាគីណាមួយ ដើម្បីអនុញ្ញាតឱ្យគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ ចូលទៅពិនិត្យកន្លែងឃុំឃាំង ក្នុងស្ថានភាពដែលមិនស្ថិតក្រោមច្បាប់មនុស្សធម៌អន្តរជាតិនោះក៏ទេដែរ ។

## មាត្រា ៣៣

១. រដ្ឋភាគីណាក៏ដោយ ក៏អាចដកខ្លួនចេញពីពិធីសារនេះបានគ្រប់ពេលវេលា ដោយការជូនដំណឹងជាលាយល័ក្ខណ៍អក្សរ ដល់អគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលជាអ្នកត្រូវជូនដំណឹងនេះទៅរដ្ឋភាគីដទៃទៀតនៃពិធីសារ និងអនុសញ្ញានេះ ។ ការដកខ្លួននឹងចូលជាធរមាន១ឆ្នាំ ក្រោយពីកាលបរិច្ឆេទ នៃការទទួលបានលិខិតជូនដំណឹងនេះពីលោកអគ្គលេខាធិការ ។

២. ការដកខ្លួននេះ នឹងមិនលើកលែងឱ្យរដ្ឋភាគីរួចកាតព្វកិច្ចរបស់ខ្លួនពីពិធីសារនេះទេ ចំពោះអំពើ ឬស្ថានការណ៍ណាមួយ ដែលកើតមុនកាលបរិច្ឆេទនៃការសុំដកខ្លួនបានចូលជាធរមាន ឬសកម្មភាពទាំងឡាយដែលអនុគណៈកម្មាធិការបង្ការបានសំរេច ឬអាចសំរេចអនុម័តយកមកចាត់ការចំពោះរដ្ឋភាគីពាក់ព័ន្ធ ហើយការសុំដកខ្លួននេះ ក៏មិនធ្វើឱ្យខូចខាតដល់ការពិចារណាលើបញ្ហាកំពុងបន្ត ដែលស្ថិតក្រោមការពិនិត្យរបស់អនុគណៈកម្មាធិការបង្ការ មុនកាលបរិច្ឆេទនៃការសុំដកខ្លួនបានចូលជាធរមាននោះឡើយ ។

៣. បន្ទាប់ពីកាលបរិច្ឆេទនៃការសុំដកខ្លួនរបស់រដ្ឋភាគីចូលជាធរមាន អនុគណៈកម្មាធិការបង្ការមិនត្រូវចាប់ផ្តើមពិនិត្យបញ្ហាថ្មីណាមួយទាក់ទងនឹងរដ្ឋនោះទៀតទេ ។

## មាត្រា ៣៤

១. រដ្ឋភាគីណាមួយនៃពិធីសារនេះ អាចស្នើសុំធ្វើវិសោធនកម្ម និងដាក់សេចក្តីស្នើសុំនេះទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ អគ្គលេខាធិការ ត្រូវបញ្ជូនសេចក្តីស្នើធ្វើវិសោធកម្មនេះទៅរដ្ឋភាគីនៃពិធីសារនេះ ដោយសុំឱ្យរដ្ឋភាគីបញ្ជាក់ប្រាប់មកលោកវិញថា តើខ្លួនយល់ព្រមឱ្យមានសន្និសីទនៃរដ្ឋភាគី

ដើម្បីពិនិត្យ និងបោះឆ្នោតគាំទ្រសេចក្តីស្នើសុំនោះឬទេ ។ ក្នុងរយៈពេល៤ខែ គិតចាប់ពីកាលបរិច្ឆេទនៃការជូនព័ត៌មានទៅរដ្ឋភាគី បើមានសម្លេង១ភាគ៣យ៉ាងតិចនៃរដ្ឋភាគី គាំទ្រឱ្យមានកិច្ចប្រជុំ លោកត្រូវកោះប្រជុំសន្និសិទ្ធនេះ ក្រោមការជួយឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ។ រាល់វិសោធនកម្មត្រូវអនុម័តដោយសម្លេងភាគច្រើន២ភាគ៣ នៃរដ្ឋភាគីដែលមានវត្តមាន និងបានបោះឆ្នោតនៅឯកិច្ចប្រជុំ ហើយអគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនវិសោធនកម្មនេះទៅរដ្ឋភាគីទាំងអស់ ដើម្បីសុំការទទួលយក ។

២. វិសោធនកម្ម ដែលបានអនុម័តស្របតាមបទបញ្ញត្តិកថាខ័ណ្ឌទី១ នៃមាត្រានេះ ត្រូវចូលជា ធរមាននៅពេលដែលវិសោធនកម្មនេះ ត្រូវបានទទួលយកដោយសម្លេងភាគច្រើន ២ភាគ៣ នៃរដ្ឋសមាជិក ពិធីសារនេះ ដោយអនុលោមតាមនីតិវិធីនៃរដ្ឋធម្មនុញ្ញរបស់រដ្ឋនីមួយៗ ។

៣. នៅពេលវិសោធនកម្មចូលជាធរមាន រដ្ឋភាគីដែលព្រមទទួលយកវិសោធនកម្មនេះ ត្រូវជាប់កាតព្វកិច្ចក្រោមវិសោធនកម្មនេះ ចំពោះរដ្ឋភាគីដទៃទៀត នៅតែជាប់កាតព្វកិច្ចក្រោមបទបញ្ញត្តិនៃពិធីសារនេះ និងវិសោធនកម្មមុនៗ ដែលខ្លួនបានយល់ព្រមទទួលយក ។

## មាត្រា ៣៥

សមាជិកអនុគណៈកម្មាធិការបង្ការ និងសមាជិកយន្តការបង្ការថ្នាក់ជាតិ ត្រូវទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិទាំងឡាយតាមការចាំបាច់ សំរាប់អនុវត្តមុខងាររបស់ខ្លួន ប្រកបដោយឯករាជ្យភាព ។ សមាជិកគណៈកម្មាធិការបង្ការ ត្រូវទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិទាំងឡាយ ដូចមានចែងក្នុងផ្នែកទី២២ នៃអនុសញ្ញាស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់អង្គការសហប្រជាជាតិ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៤៦ ដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃផ្នែកទី២៣ នៃអនុសញ្ញានោះ ។

## មាត្រា ៣៦

នៅពេលធ្វើទស្សនកិច្ចនៅរដ្ឋភាគីមួយ ដោយមិនធ្វើឱ្យប៉ះពាល់ដល់បទបញ្ញត្តិ និងគោលបំណងនៃពិធីសារនេះ ជាមួយបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិដែលមាន សមាជិកអនុគណៈកម្មាធិការបង្ការត្រូវ :

(ក) គោរពច្បាប់ និងបទបញ្ជារបស់រដ្ឋម្ចាស់ផ្ទះ ។

(ខ) ប្រាសចាកពីអំពើ ឬសកម្មភាពណាមួយ ដែលមិនស្របទៅនឹងចរិតអន្តរជាតិ និងភាពឥតលំអៀងនៃភារកិច្ចរបស់ខ្លួនឡើយ ។

## មាត្រា ៣៧

១. ពិធីសារនេះ ដែលតាក់តែងឡើងជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ មានតម្លៃគតិយុត្តិស្មើគ្នា ហើយត្រូវតំកល់ទុកជាមួយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនច្បាប់ចម្លងនៃពិធីសារនេះ ដោយមានបញ្ជាក់ពីការថតចម្លងតាមច្បាប់ដើមផងទៅរដ្ឋភាគីទាំងអស់ ។

# អនុសញ្ញាស្តីពីសិទ្ធិកុមារ

# និង

# ពិធីសារបន្ថែម

# ១២-អនុសញ្ញាស្ដីពីសិទ្ធិកុមារ

ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩
ចូលជាធរមាននៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩០ ស្របតាមមាត្រា៤៩
កម្ពុជាក្លាយជារដ្ឋភាគីនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២

# បុព្វកថា

## *រដ្ឋភាគីទាំងអស់នៃអនុសញ្ញានេះ*

*យល់ឃើញថា* យោងតាមគោលការណ៍នានាដែលប្រកាសក្នុងធម្មនុញ្ញសហប្រជាជាតិ ការទទួលស្គាល់សេចក្ដីថ្លៃថ្នូរជាប់ពីកំណើតនិងសិទ្ធិស្មើភាព និងមិនអាចលក់ ដូរ ផ្ទេរ ឬដកហូតបានរបស់សមាជិកទាំងអស់នៃគ្រួសារមនុស្សជាគ្រឹះនៃសេរីភាព យុត្តិធម៌និងសន្តិភាពក្នុងពិភពលោក។

*ចងចាំថា* ប្រជាជាតិនៃសហប្រជាជាតិ បានប្រកាសបញ្ជាក់សារជាថ្មីក្នុងធម្មនុញ្ញសហប្រជាជាតិនូវជំនឿរបស់ខ្លួនទៅលើសិទ្ធិមូលដ្ឋានរបស់មនុស្ស លើសេចក្ដីថ្លៃថ្នូរនិងតម្លៃរបស់មនុស្ស ហើយប្ដេជ្ញាលើកស្ទួយវឌ្ឍនភាពសង្គម និងកម្រិតជីវភាពរស់នៅឱ្យកាន់តែប្រសើរឡើងក្នុងសេរីភាពកាន់តែទូលំទូលាយ។

*ទទួលស្គាល់ថា* ក្នុងសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិនានាស្ដីពីសិទ្ធិមនុស្ស សហប្រជាជាតិបានប្រកាស និងយល់ស្របថា មនុស្សគ្រប់រូបត្រូវមានសិទ្ធិ និងសេរីភាពទាំងអស់ ដូចមានចែងនៅក្នុងសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិមនុស្ស ដោយគ្មានការប្រកាន់បែងចែកបែបណាមួយ មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពផ្សេងទៀតឡើយ។

*រំលឹកឡើងវិញថា* ក្នុងសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស សហប្រជាជាតិបានប្រកាសថា កុមារមានសិទ្ធិទទួលជំនួយ និងការថែទាំពិសេស។

*ជឿជាក់ថា* គ្រួសារជាអង្គភាពគ្រឹះនៃសង្គម និងជាមជ្ឈដ្ឋានធម្មជាតិសម្រាប់ការរីកលូតលាស់ និងសុខុមាលភាពនៃសមាជិកទាំងអស់របស់សង្គម និងជាពិសេស កុមារត្រូវទទួលនូវការការពារ និងជំនួយឧបត្ថម្ភចាំបាច់ ដើម្បីឱ្យគ្រួសារអាចរ៉ាប់រងការទទួលខុសត្រូវរបស់ខ្លួនពេញលេញនៅក្នុងសហគមន៍។

*ទទួលស្គាល់ថា* ដើម្បីឱ្យមានការអភិវឌ្ឍន៍ពេញលេញ និងសមស្របតាមបុគ្គលិកលក្ខណៈរបស់កុមារ កុមារត្រូវធំលូតលាស់ក្នុងមជ្ឈដ្ឋានគ្រួសារ ក្នុងបរិយាកាសសុភមង្គល សេចក្តីស្រឡាញ់ និងការយោគយល់។

*យល់ឃើញថា* កុមារ គួរត្រូវបានគេរៀបចំឱ្យមានជីវភាពជាឯកត្តជនក្នុងសង្គម និងធំលូតលាស់ក្នុងស្មារតីនៃឧត្តមគតិ ដូចមានចែងក្នុងធម្មនុញ្ញសហប្រជាជាតិ និងជាពិសេស ក្នុងស្មារតីនៃសន្តិភាព សេចក្តីថ្លៃថ្នូរ ការអត់ឱនឱ្យគ្នា សេរីភាព សមភាព និងសាមគ្គីភាព។

*ចងចាំថា* ភាពចាំបាច់ដើម្បីផ្តល់ការការពារពិសេសដល់កុមារត្រូវបានថ្លែងក្នុងសេចក្តីប្រកាសនាទីក្រុងហ្សឺណែវ ឆ្នាំ១៩២៤ ស្តីពីសិទ្ធិកុមារ និងក្នុងសេចក្តីប្រកាសស្តីពីសិទ្ធិកុមារដែលបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៥៩ ហើយភាពចាំបាច់នេះត្រូវបានទទួលស្គាល់ នៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ជាពិសេសក្នុងមាត្រា២៣ និងមាត្រា២៤) ក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ជាពិសេសក្នុងមាត្រា១០) និងក្នុងលក្ខន្តិកៈ និងលិខិតុបករណ៍ពាក់ព័ន្ធនានារបស់ស្ថាប័នឯកទេស និងអង្គការអន្តរជាតិ ដែលមានកិច្ចការទាក់ទិននឹងសុខុមាលភាពរបស់កុមារ ។

*ចងចាំថា* ដូចបានបញ្ជាក់ក្នុងសេចក្តីប្រកាសស្តីពីសិទ្ធិកុមារ "ដោយសារភាពខ្ចីខាងផ្នែករាងកាយ និងសតិបញ្ញា កុមារត្រូវការនូវកិច្ចការពារ និងការថែទាំជាពិសេស រួមទាំងការការពារសមស្របតាមផ្លូវច្បាប់ទាំងមុន និងបន្ទាប់ពីកំណើត"។

*រំលឹកឡើងវិញថា* បទប្បញ្ញត្តិនៃសេចក្តីប្រកាសស្តីពីគោលការណ៍ខាងសង្គមកិច្ច និងខាងផ្លូវច្បាប់ទាក់ទងនឹងកិច្ចការពារ និងសុខុមាលភាពរបស់កុមារ សំដៅជាពិសេសទៅរកការទុកដាក់ជាមួយឪពុក-ម្តាយធម៌ និងសុំកូនក្នុងប្រទេសនិងអន្តរជាតិ វិធានជាបទដ្ឋានអប្បបរមារបស់សហប្រជាជាតិ ដើម្បីគ្រប់គ្រងវិស័យយុត្តិធម៌សម្រាប់កុមារ (វិធានក្រុងប៉េកាំង) និងសេចក្តីប្រកាសស្តីពីការការពារស្ត្រី និងកុមារក្នុងពេលមានអាសន្ន និងជម្លោះប្រដាប់អាវុធ។

*ទទួលស្គាល់ថា* នៅក្នុងប្រទេសទាំងអស់លើពិភពលោកមានកុមារកំពុងរស់នៅក្នុងស្ថានភាពដ៏សែនលំបាក ហើយកុមារទាំងនោះ ត្រូវការនូវការយកចិត្តទុកដាក់ពិសេស។

*យកមកគិតនូវ* សារសំខាន់នៃប្រពៃណី និងតម្លៃវប្បធម៌របស់ប្រជាជាតិនីមួយៗ ក្នុងការការពារ និងការរីកចម្រើនដោយសុខដុមរបស់កុមារ។

*ទទួលស្គាល់* សារសំខាន់នៃកិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីលើកកំពស់លក្ខខណ្ឌជីវភាពរបស់កុមារនៅគ្រប់ប្រទេស ជាពិសេសក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

*បានព្រមព្រៀងគ្នាដូចតទៅ :*

## *ផ្នែកទី ១*

### មាត្រា ១

សម្រាប់គោលបំណងនៃអនុសញ្ញានេះ កុមារគឺជាមនុស្សមានអាយុក្រោម១៨ឆ្នាំ លើកលែងតែក្រោមច្បាប់ដែលត្រូវអនុវត្តចំពោះកុមារ នីតិភាពត្រូវបានកំណត់ទាបជាងនេះ។

### មាត្រា ២

១. រដ្ឋភាគី ត្រូវគោរព និងធានាសិទ្ធិដូចចែងក្នុងអនុសញ្ញានេះដល់កុមារដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយគ្មានការរើសអើងណាមួយ ដោយឥតគិតពីពូជសាសន៍ ពណ៌សម្បុរ ភេទ សាសនា មតិនយោបាយ ឬមតិផ្សេងទៀត ដើមកំណើតជាតិ ដើមកំណើតជនជាតិ ឬសង្គម ទ្រព្យសម្បត្តិ អសមត្ថភាព កំណើត ឬស្ថានភាពផ្សេងទៀតរបស់កុមារ របស់ឪពុក-ម្ដាយកុមារឬអ្នកអាណាព្យាបាលស្របច្បាប់របស់កុមារ។

២. រដ្ឋភាគីត្រូវចាត់វិធានការសមស្របទាំងឡាយ ដើម្បីធានាឱ្យកុមារបានទទួលនូវការការពារប្រឆាំងនឹងរាល់ទម្រង់នៃការរើសអើង ឬទណ្ឌកម្មដែលផ្អែកលើមូលដ្ឋានស្ថានភាព សកម្មភាព ការបញ្ចេញមតិ ឬជំនឿរបស់ឪពុក-ម្ដាយ របស់អ្នកអាណាព្យាបាលស្របច្បាប់ ឬសមាជិកគ្រួសាររបស់កុមារ។

### មាត្រា ៣

១. នៅក្នុងវិធានការទាំងអស់ដែលពាក់ព័ន្ធនឹងកុមារ ទោះធ្វើឡើងដោយស្ថាប័នឯកជន ឬសាធារណៈ ទទួលភារៈខាងសុខុមាលភាពសង្គម ឬដោយតុលាការ ឬអាជ្ញាធររដ្ឋបាល ឬអង្គការនីតិបញ្ញត្តិក៏ដោយ ឧត្តមប្រយោជន៍របស់កុមារ ត្រូវតែយកចិត្តទុកដាក់ជាចម្បង។

២. រដ្ឋភាគីសន្យាធានាដល់កុមារនូវការការពារនិងការថែទាំចាំបាច់ដើម្បីសុខុមាលភាពរបស់កុមារ ដោយយកមកគិតនូវសិទ្ធិ និងករណីយកិច្ចរបស់ឪពុក-ម្ដាយ អ្នកអាណាព្យាបាល ឬបុគ្គលផ្សេងទៀត ដែលទទួលខុសត្រូវតាមផ្លូវច្បាប់ចំពោះកុមារ និងដើម្បីសម្រេចទិសដៅនេះ រដ្ឋភាគីត្រូវចាត់វិធានការ ខាងនីតិបញ្ញត្តិ និងរដ្ឋបាលដែលសមស្របទាំងអស់។

៣. រដ្ឋភាគីត្រូវធានាថា ស្ថាប័ន សេវាកម្ម និងគ្រឹះស្ថានដែលមានបន្ទុកថែទាំ ឬការពារកុមារ ត្រូវធ្វើតាមបទដ្ឋានកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ជាពិសេស នៅក្នុងវិស័យនៃសុវត្ថិភាព សុខភាព អំពីចំនួន និងភាពសមស្របនៃបុគ្គលិក ព្រមទាំងសមត្ថកិច្ចគ្រប់គ្រង។

មាត្រា ៤

រដ្ឋភាគីសន្យាចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីអនុវត្តសិទ្ធិទាំងឡាយដែលទទួលស្គាល់ក្នុងអនុសញ្ញានេះ។ ចំពោះសិទ្ធិខាងសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ រដ្ឋភាគី ត្រូវចាត់វិធានការក្នុងកម្រិតអតិបរមានៃធនធានដែលខ្លួនមាន និងបើចាំបាច់ ក្នុងក្របខ័ណ្ឌនៃសហប្រតិបត្តិការអន្តរជាតិ។

មាត្រា ៥

រដ្ឋភាគី ត្រូវគោរពតួនាទី សិទ្ធិ និងករណីយកិច្ចរបស់ឪពុកម្ដាយ ឬបើសមស្រប ត្រូវគោរពតួនាទី សិទ្ធិនិងករណីយកិច្ចរបស់សមាជិកគ្រួសារជាសាខាញាតិឬសហគមន៍ អាស្រ័យតាមទំនៀមទម្លាប់នៅមូលដ្ឋាន អ្នកអាណាព្យាបាលស្របច្បាប់ ឬជនផ្សេងទៀតដែលមាននាទីតាមផ្លូវច្បាប់លើកុមារ ក្នុងការតម្រង់ទិស និងការណែនាំសមស្របតាមសមត្ថភាពរបស់កុមារ ដើម្បីឱ្យកុមារប្រើប្រាស់សិទ្ធិទាំងឡាយដែលទទួលស្គាល់ក្នុងអនុសញ្ញានេះ។

មាត្រា ៦

១. រដ្ឋភាគីទទួលស្គាល់ថា កុមារគ្រប់រូប មានសិទ្ធិមានជីវិតជាប់ពីកំណើត។

២. រដ្ឋភាគី ត្រូវធានាក្នុងកម្រិតអតិបរមា តាមដែលអាចធ្វើទៅបាន ចំពោះការរស់រាន និងការលូតលាស់របស់កុមារ ។

## មាត្រា ៧

១. កុមារ ត្រូវបានចុះក្នុងសៀវភៅអត្រានុកូលដ្ឋានភ្លាម បន្ទាប់ពីពេលកើត និងត្រូវមានសិទ្ធិមានឈ្មោះមួយពីពេលកើតមក មានសិទ្ធិទទួលបានសញ្ជាតិមួយ និងតាមដែលអាចធ្វើទៅបាន កុមារត្រូវមានសិទ្ធិស្គាល់ឪពុក-ម្តាយ និងទទួលការថែទាំពីឪពុក-ម្តាយ។

២. រដ្ឋភាគីត្រូវធានាការអនុវត្តសិទ្ធិទាំងនេះ ស្របតាមច្បាប់ជាតិ និងកាតព្វកិច្ចក្រោមលិខិតុបករណ៍អន្តរជាតិក្នុងវិស័យនេះ ពិសេសក្នុងករណីដែលកុមារនឹងក្លាយជាជនឥតស្រុកទេស បើគ្មានការអនុវត្តនោះទេ ។

## មាត្រា ៨

១. រដ្ឋភាគីសន្យាគោរពសិទ្ធិរក្សាអត្តសញ្ញាណរបស់កុមារ រួមមានសញ្ជាតិ ឈ្មោះ និងទំនាក់ទំនងគ្រួសារផង ដូចបានទទួលស្គាល់ក្នុងច្បាប់ ដោយគ្មានការជ្រៀតជ្រែកដោយខុសច្បាប់ឡើយ។

២. បើកុមារម្នាក់ត្រូវរងការដកហូតដោយខុសច្បាប់នូវធាតុមួយចំនួន ឬទាំងអស់នៃអត្តសញ្ញាណរបស់ខ្លួននោះ រដ្ឋភាគី ត្រូវផ្តល់ជំនួយ និងការការពារសមស្រប ដើម្បីស្តារអត្តសញ្ញាណរបស់កុមារឡើងវិញឱ្យបានឆាប់រហ័ស។

## មាត្រា ៩

១. រដ្ឋភាគីត្រូវធានាថា កុមារមិនត្រូវបានបំបែកចេញពីឪពុក-ម្តាយ ផ្ទុយពីឆន្ទៈរបស់កុមារឡើយ លើកលែងតែអាជ្ញាធរមានសមត្ថកិច្ច ដែលស្ថិតក្រោមការពិនិត្យរបស់តុលាការ សម្រេចស្របតាមច្បាប់ និងនីតិវិធី ថាការបំបែកនេះ គឺចាំបាច់សម្រាប់ឧត្តមប្រយោជន៍របស់កុមារ។ សេចក្តីសម្រេចនេះអាចចាំបាច់តែក្នុងករណីពិសេស មានជាអាទិ៍ ឪពុក-ម្តាយធ្វើបាប ឬទុកចោលមិនយកចិត្តទុកដាក់ ឬឪពុក-ម្តាយមិនរស់នៅជាមួយគ្នា ហើយសេចក្តីសម្រេចនេះ ត្រូវធ្វើដោយគិតពីកន្លែងស្នាក់នៅរបស់កុមារ ។

២. នៅគ្រប់នីតិវិធីស្របតាមកថាខណ្ឌ១នៃមាត្រានេះ ភាគីពាក់ព័ន្ធទាំងអស់ត្រូវបានផ្តល់ឱកាសឱ្យចូលរួមក្នុងនីតិវិធីទាំងនោះ និងឱ្យបង្ហាញពីទស្សនៈរបស់ខ្លួន។

៣. រដ្ឋភាគី ត្រូវគោរពសិទ្ធិរបស់កុមារដែលត្រូវបំបែកពីឪពុកឬម្តាយ ឬឪពុក-ម្តាយទាំងពីរ ក្នុងការរក្សាជាទៀងទាត់ នូវទំនាក់ទំនងផ្ទាល់ខ្លួន និងការទាក់ទងដោយផ្ទាល់ជាមួយឪពុក-ម្តាយ លើកលែងតែប្រការនេះផ្ទុយនឹងឧត្តមប្រយោជន៍របស់កុមារ។

៤. បើការរស់នៅបែកគ្នាបណ្ដាលមកពីវិធានការណាមួយផ្ដើមដោយរដ្ឋភាគី មានជាអាទិ៍ការឃាត់ ឬការឃុំខ្លួន ការដាក់ពន្ធនាគារ ការនិរទេស ការបំបរបង់ ឬមរណភាព (រួមទាំងមរណភាពបណ្ដាលមកពីបុព្វហេតុណាមួយក្នុងខណៈពេលដែលបុគ្គលនោះ ត្រូវបានឃាត់ ឬឃុំខ្លួនដោយរដ្ឋ) ឪពុក ឬម្ដាយ ឬឪពុក-ម្ដាយទាំងពីរ ឬកុមារ នោះរដ្ឋភាគី ដោយយោងតាមការស្នើសុំ ត្រូវជូនដំណឹងទៅឪពុក-ម្ដាយ ឬកុមារ ឬបើសមស្រប ត្រូវជូនដំណឹងទៅសមាជិកគ្រួសារណាម្នាក់ផ្សេងទៀតនូវព័ត៌មានសំខាន់អំពីទីកន្លែងនៃសមាជិកគ្រួសារណាម្នាក់ ឬច្រើននាក់ដែលអវត្តមាន លើកលែងតែការជូនដំណឹងនេះ ប៉ះពាល់ដល់ផាសុខភាពរបស់កុមារ។ ម្យ៉ាងទៀត រដ្ឋភាគីត្រូវធានាថាការដាក់សេចក្ដីស្នើសុំមួយបែបនេះ នឹងមិននាំឱ្យមានផលជាអវិភូតសម្រាប់បុគ្គលពាក់ព័ន្ធឡើយ។

មាត្រា ១០

១. ស្របតាមកាតព្វកិច្ចរបស់រដ្ឋភាគី ក្រោមមាត្រា៩ កថាខណ្ឌ១ គ្រប់សេចក្ដីស្នើសុំរបស់កុមារ ឬឪពុក ឬម្ដាយរបស់កុមារ ដើម្បីចូល ឬចាកចេញពីរដ្ឋភាគី ក្នុងគោលបំណងជួបជុំគ្រួសារ ត្រូវតែដោះស្រាយក្នុងស្មារតីវិជ្ជមាន មនុស្សធម៌ និងឱ្យបានឆាប់រហ័ស។ ក្រៅពីនេះ រដ្ឋភាគីត្រូវធានាថា ការដាក់សេចក្ដីស្នើសុំនេះ នឹងមិនបង្កឱ្យមានផលអវិភូតដល់អ្នកសុំ និងដល់សមាជិកគ្រួសាររបស់អ្នកសុំឡើយ ។

២. កុមារដែលមានឪពុក-ម្ដាយរស់នៅក្នុងរដ្ឋផ្សេង មានសិទ្ធិរក្សាជាទៀងទាត់នូវទំនាក់ទំនងផ្ទាល់ និងការទាក់ទងដោយផ្ទាល់ ជាមួយឪពុក-ម្ដាយទាំងពីរ លើកលែងតែក្នុងកាលៈទេសៈពិសេស។ ក្នុងទិសដៅនេះ និងស្របតាមកាតព្វកិច្ចរបស់រដ្ឋភាគី ក្រោមមាត្រា៩ កថាខណ្ឌ១ រដ្ឋភាគី ត្រូវគោរពសិទ្ធិរបស់កុមារ និងសិទ្ធិឪពុក-ម្ដាយរបស់កុមារ ក្នុងការចាកចេញពីប្រទេស រួមមាន ប្រទេសរបស់ខ្លួនផង និងវិលចូលមកក្នុងប្រទេសរបស់ខ្លួនវិញ។ សិទ្ធិចាកចេញពីប្រទេសណាមួយ អាចស្ថិតក្រោមការរិតត្បិតបាន លុះត្រាតែការរិតត្បិតនោះ បញ្ញត្តិដោយច្បាប់ និងចាំបាច់ដើម្បីការពារសន្តិសុខជាតិ សណ្ដាប់ធ្នាប់សាធារណៈ សុខភាព ឬសីលធម៌សាធារណៈ ឬសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ ហើយស្របនឹងសិទ្ធិផ្សេងទៀតដែលទទួលស្គាល់ដោយអនុសញ្ញានេះ។

មាត្រា ១១

១. រដ្ឋភាគី ត្រូវចាត់វិធានការប្រយុទ្ធប្រឆាំងនឹងការផ្ទេរកុមារចេញក្រៅប្រទេស ដោយខុសច្បាប់ និងការមិនប្រគល់កុមារពីក្រៅប្រទេសមកវិញ។

២. ក្នុងទិសដៅនេះ រដ្ឋភាគី ត្រូវសម្រួលដល់ការចុះកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគី ឬចូលជាសមាជិកក្នុងកិច្ចព្រមព្រៀងដែលមានស្រាប់។

### មាត្រា ១២

១. រដ្ឋភាគី ត្រូវធានាអះអាងដល់កុមារដែលមានសមត្ថភាពបង្កើតទស្សនៈផ្ទាល់ខ្លួន នូវសិទ្ធិបញ្ចេញទស្សនៈទាំងនោះដោយសេរី លើគ្រប់បញ្ហាពាក់ព័ន្ធនឹងកុមារ។ ទស្សនៈទាំងនេះរបស់កុមារ ត្រូវបានយកទៅពិចារណាថ្លឹងថ្លែង ដោយគិតទៅតាមវ័យ និងភាពចាស់ទុំរបស់កុមារ។

២. ក្នុងទិសដៅនេះ កុមារត្រូវបានផ្តល់ជាពិសេសនូវឱកាសត្រូវបានគេស្តាប់នៅក្នុងនីតិវិធីតុលាការ និងរដ្ឋបាលដែលពាក់ព័ន្ធនឹងកុមារ ទោះដោយផ្ទាល់ ឬតាមរយៈអ្នកតំណាង ឬស្ថាប័នសមស្របណាមួយ ស្របតាមបទប្បញ្ញត្តិនីតិវិធីនៃច្បាប់ជាតិ។

### មាត្រា ១៣

១. កុមារមានសិទ្ធិសម្តែងមតិដោយសេរី។ សិទ្ធិនេះ រាប់បញ្ចូលទាំងសេរីភាព ស្រាវជ្រាវ ទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតគ្រប់ប្រភេទ ដោយគ្មានគិតពីព្រំដែន ទោះជាតាមទម្រង់ផ្ទាល់មាត់ សរសេរ ឬបោះពុម្ព ទម្រង់សិល្បៈ ឬតាមគ្រប់គ្រឿងផ្សាយព័ត៌មានផ្សេងទៀត តាមការជ្រើសរើសរបស់កុមារ។

២. ការប្រើប្រាស់សិទ្ធិនេះ អាចស្ថិតក្រោមការរិតត្បិតខ្លះបាន លុះត្រាតែការរិតត្បិតទាំងនេះ ត្រូវបានអនុញ្ញាតដោយច្បាប់ និងមានលក្ខណៈចាំបាច់ ដូចខាងក្រោម:

(ក) ដើម្បីគោរពសិទ្ធិ និងកិត្តិនាមរបស់អ្នកដទៃ ឬ

(ខ) ដើម្បីការពារសន្តិសុខជាតិ ឬសណ្តាប់ធ្នាប់ សុខភាព ឬសីលធម៌សាធារណៈ។

### មាត្រា ១៤

១. រដ្ឋភាគី ត្រូវគោរពសិទ្ធិកុមារក្នុងការមានសេរីភាពគិតគូរ សេរីភាពខាងសតិសម្បជញ្ញៈ និងសេរីភាពខាងសាសនា។

២. រដ្ឋភាគីត្រូវគោរពសិទ្ធិ និងករណីយកិច្ចរបស់ឪពុក-ម្តាយ និងបើសមស្រប អ្នកអាណាព្យាបាលស្របច្បាប់របស់កុមារ ក្នុងការនាំផ្លូវកុមារឱ្យប្រើប្រាស់សិទ្ធិកុមារ ស្របតាមសមត្ថភាពវិវត្តទៅមុខរបស់កុមារ។

៣. សេរីភាពសម្តែងសាសនា ឬជំនឿរបស់កុមារ អាចស្ថិតក្រោមការរិតត្បិតបាន ដរាបណាមានបញ្ញត្តិដោយច្បាប់ និងចាំបាច់ដើម្បីការពារសុវត្ថិភាព សណ្តាប់ធ្នាប់ សុខភាព និងសីលធម៌សាធារណៈ ឬសិទ្ធិ និងសេរីភាពមូលដ្ឋានរបស់អ្នកដទៃ។

### មាត្រា ១៥

១. រដ្ឋភាគី ទទួលស្គាល់សិទ្ធិកុមារមានសេរីភាពខាងសមាគម និងមានសេរីភាពប្រជុំដោយសន្តិវិធី។

២. ការប្រើប្រាស់សិទ្ធិទាំងនេះ អាចស្ថិតក្រោមការរិតត្បិតបាន លុះត្រាតែមានបញ្ញត្តិដោយច្បាប់ និងចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ ដើម្បីអត្ថប្រយោជន៍នៃសន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ ឬសណ្តាប់ធ្នាប់សាធារណៈ ឬដើម្បីការពារសុខភាព ឬសីលធម៌សាធារណៈ ឬដើម្បីការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ។

### មាត្រា ១៦

១. គ្មានកុមារណាម្នាក់ ត្រូវស្ថិតក្រោមការជ្រៀតជ្រែកតាមអំពើចិត្ត ឬដោយខុសច្បាប់ ក្នុងជីវិតឯកជន គ្រួសារ លំនៅដ្ឋាន ឬការឆ្លើយឆ្លងរបស់កុមារ និងគ្មានកុមារណាម្នាក់ ត្រូវស្ថិតក្រោមការបំពារបំពានដោយខុសច្បាប់លើកិត្តិយស និងកិត្តិនាមរបស់ខ្លួនឡើយ។

២. កុមារមានសិទ្ធិទទួលបានការការពារដោយច្បាប់ ប្រឆាំងនឹងការជ្រៀតជ្រែក ឬការបំពារបំពានទាំងនេះ។

### មាត្រា ១៧

រដ្ឋភាគី ទទួលស្គាល់សារសំខាន់នៃមុខងារផ្សព្វផ្សាយតាមប្រព័ន្ធឃោសនា និងត្រូវធានាឱ្យកុមារមានសិទ្ធិទទួលបានព័ត៌មាន និងឯកសារ ឬសម្ភារៈពីប្រភពផ្សេងៗរបស់ជាតិ និងអន្តរជាតិជាពិសេស ព័ត៌មាន និងទិន្នន័យដែលសំដៅលើកស្ទួយសុខុមាលភាព ខាងសង្គម ស្មារតី និងសីលធម៌របស់កុមារ ព្រមទាំងសុខភាពផ្នែករាងកាយ និងសតិបញ្ញារបស់កុមារ។ ក្នុងទិសដៅនេះ រដ្ឋភាគីត្រូវ:

(ក) ជំរុញប្រព័ន្ធឃោសនា ឱ្យផ្សព្វផ្សាយព័ត៌មាន និងឯកសារ ឬសម្ភារៈ បង្ហាញពីអត្ថប្រយោជន៍ខាងសង្គម និងវប្បធម៌ដល់កុមារ និងស្របតាមស្មារតីនៃមាត្រា២៩។

(ខ) ជំរុញសហប្រតិបត្តិការអន្តរជាតិ ដើម្បីផលិត ផ្លាស់ប្តូរ និងផ្សាយព័ត៌មាន និងឯកសារ ឬសម្ភារៈដែលចេញមកពីប្រភពប្លែកៗគ្នា ខាងវប្បធម៌ជាតិ និងអន្តរជាតិ។

(គ) ជំរុញការផលិត និងការផ្សព្វផ្សាយសៀវភៅសម្រាប់កុមារ។

(ឃ) ជំរុញប្រព័ន្ធឃោសនា ឱ្យគិតគូរជាពិសេសដល់សេចក្តីត្រូវការផ្នែកភាសារបស់កុមារ ដែលជាសមាជិកក្រុមជនជាតិភាគតិច ឬជាសមាជិកជនអន្តោគ្រាម។

(ង) ជំរុញការកសាងគោលការណ៍ដឹកនាំសមស្រប សំដៅការពារកុមារឱ្យផុតពីព័ត៌មាន និងឯកសារ ឬសម្ភារៈដែលបំផ្លាញសុខុមាលភាពកុមារ ដោយយោងទៅលើបទប្បញ្ញត្តិនៃមាត្រា ១៣ និងមាត្រា១៨។

### មាត្រា ១៨

១. រដ្ឋភាគីត្រូវប្រឹងប្រែងឱ្យអស់ពីលទ្ធភាព ដើម្បីធានាការទទួលស្គាល់គោលការណ៍ដែលថា ឪពុក-ម្តាយទាំងពីរ មានការទទួលខុសត្រូវរួម ក្នុងការចិញ្ចឹមបីបាច់ និងធ្វើឱ្យកុមារមានការអភិវឌ្ឍន៍។ ការទទួលខុសត្រូវបឋមក្នុងការចិញ្ចឹមបីបាច់កុមារ និងធ្វើឱ្យកុមារមានការអភិវឌ្ឍន៍ ត្រូវស្ថិតនៅលើឪពុក-ម្តាយ ឬបើពុំនោះទេ អ្នកអាណាព្យាបាលស្របច្បាប់របស់កុមារ។ ពួកគេនេះ ត្រូវគិតមុនបង្អស់ដល់ឧត្តមប្រយោជន៍របស់កុមារ។

២. ដើម្បីធានា និងលើកស្ទួយសិទ្ធិដូចចែងក្នុងអនុសញ្ញានេះ រដ្ឋភាគីត្រូវផ្តល់ជំនួយសមស្រប ដល់ឪពុក-ម្តាយ និងអ្នកអាណាព្យាបាលស្របច្បាប់របស់កុមារ ដើម្បីបំពេញតួនាទីចិញ្ចឹម អប់រំកុមារ និងធានាដល់ការបង្កើតឱ្យមានស្ថាប័ន គ្រឹះស្ថាន និងសេវាកម្មទទួលបន្ទុកថែទាំកុមារ។

៣. រដ្ឋភាគីត្រូវចាត់វិធានការសមស្របទាំងអស់ ធានាដល់កុមារដែលមានឪពុក-ម្តាយ ជាអ្នកធ្វើការនូវសិទ្ធិទទួលអត្ថប្រយោជន៍ពីសេវាកម្ម និងគ្រឹះស្ថានគាំពារកុមារដែលកុមារមានលក្ខណៈសម្បត្តិអាចទទួលបាន។

### មាត្រា ១៩

១. រដ្ឋភាគី ត្រូវចាត់វិធានការសមស្របខាងនីតិបញ្ញត្តិ រដ្ឋបាល សង្គមកិច្ច និងខាងអប់រំ ដើម្បីការពារកុមារពីគ្រប់ទម្រង់នៃអំពើហិង្សា ការធ្វើឱ្យរបួស ឬការរំលោភបំពានលើរាងកាយ ឬលើផ្លូវចិត្ត ការទុកចោលមិនយកចិត្តទុកដាក់ ឬការមិនអើពើ ការធ្វើបាប ឬការកេងប្រវ័ញ្ច រួមទាំងការរំលោភបំពានផ្លូវភេទ ក្នុងកំឡុងពេលដែលកុមារ ស្ថិតនៅក្រោមការចិញ្ចឹមបីបាច់របស់ឪពុក-ម្តាយ

ទាំងពីរ ឬឪពុក ឬម្ដាយ ឬអ្នកអាណាព្យាបាលស្របច្បាប់ ឬបុគ្គលផ្សេងទៀតដែលមានភារៈថែទាំកុមារ។

២. វិធានការការពារទាំងនេះ បើសមស្រប គួរបញ្ចូលនីតិវិធីដែលមានប្រសិទ្ធភាព ដើម្បីស្ថាបនាកម្មវិធីសង្គម ដែលផ្ដល់ការគាំទ្រចាំបាច់ដល់កុមារ និងអ្នកដែលមានភារៈថែទាំកុមារ និងដើម្បីបង្ការតាមទម្រង់ផ្សេងៗ និងដើម្បីកំណត់អត្តសញ្ញាណ រាយការណ៍ បញ្ជូន ស៊ើបអង្កេត ព្យាបាល និងតាមដានលើរាល់ករណីនៃការធ្វើបាបកុមារ ដូចលើកឡើងខាងលើ និងបើសមស្រប ដើម្បីកិច្ចអន្តរាគមន៍ពីតុលាការ។

## មាត្រា ២០

១. កុមារដែលត្រូវបានដកចេញជាបណ្ដោះអាសន្ន ឬជាអចិន្ត្រៃយ៍ពីមជ្ឈដ្ឋានគ្រួសាររបស់ខ្លួន ឬដែលឧត្ដមប្រយោជន៍របស់កុមារ មិនអាចបណ្ដោយឱ្យរស់នៅក្នុងមជ្ឈដ្ឋាននេះបាន មានសិទ្ធិទទួលការការពារ និងជំនួយឧបត្ថម្ភពិសេសពីរដ្ឋ។

២. រដ្ឋភាគីត្រូវធានាថែទាំកុមារខាងលើនេះ តាមការថែទាំជំនួស ស្របតាមច្បាប់ជាតិរបស់ខ្លួន។

៣. ការថែទាំនេះ អាចរាប់បញ្ចូលជាអាទិ៍ ការទុកដាក់ជាមួយឪពុក-ម្ដាយធម៌ កាហ្វាឡានៃច្បាប់អ៊ីស្លាម ស្មុំកូន ឬបើសិនជាចាំបាច់ ការដាក់កុមារក្នុងស្ថាប័នសមស្រប ដើម្បីថែទាំកុមារ។ នៅក្នុងការជ្រើសរើសដំណោះស្រាយនេះ ត្រូវយកចិត្តទុកដាក់លើអត្ថប្រយោជន៍នៃការបន្តថែទាំកុមារ ដូចពេលកន្លងមក ហើយត្រូវយកចិត្តទុកដាក់លើប្រភពជាតិសាសន៍ សាសនា វប្បធម៌ និងភាសារបស់កុមារ។

## មាត្រា ២១

១. រដ្ឋភាគី ដែលទទួលស្គាល់ និង/ឬអនុញ្ញាតឱ្យមានប្រព័ន្ធស្មុំកូន ត្រូវធានាថា ឧត្ដមប្រយោជន៍របស់កុមារ ត្រូវស្ថិតក្នុងការពិចារណាខ្ពស់បំផុត ក្នុងវិស័យនេះ ហើយរដ្ឋភាគីត្រូវ :

(ក) ធានាថា ស្មុំកូនអនុញ្ញាតបានតែដោយអាជ្ញាធរមានសមត្ថកិច្ចជាអ្នកសម្រេច ស្របតាមច្បាប់ និងនីតិវិធីជាធរមាន និងផ្អែកលើមូលដ្ឋានព័ត៌មានពាក់ព័ន្ធ និងគួរជឿទុកចិត្ត ទាក់ទងនឹងករណីនេះ និងធានាថា ស្មុំកូនអាចអនុញ្ញាតឱ្យធ្វើដោយគិតពីស្ថានភាពកុមារទាក់ទងនឹងឪពុក-ម្ដាយ

ញាតិសន្តានឬអ្នកអាណាព្យាបាលស្របច្បាប់ និងបើចាំបាច់ ត្រូវធានាថា ជនពាក់ព័ន្ធបានដឹង និងបាន ផ្តល់ការយល់ព្រម បន្ទាប់ពីបានទទួលដំណឹងពីផលប៉ះពាល់នានាចំពោះសុំកូន ដោយផ្អែកលើការ ផ្តល់ការពិគ្រោះយោបល់តាមការចាំបាច់។

(ខ) ទទួលស្គាល់ថា សុំកូនអន្តរប្រទេស អាចចាត់ទុកជាមធ្យោបាយជំនួសមួយនៃការ ថែទាំកុមារបាន បើសិនជានៅក្នុងប្រទេសដើមកំណើតរបស់ខ្លួន កុមារមិនអាចរស់នៅតាមគ្រួសារ ធម៌ ឬក្នុងគ្រួសារចិញ្ចឹម ឬមិនអាចទទួលបាននូវការថែទាំឱ្យសមស្របទេនោះ។

(គ) ធានាថា កុមារពាក់ព័ន្ធនឹងសុំកូនអន្តរប្រទេស បានទទួលការធានា និងបទដ្ឋានដូចគ្នានឹងការ ធានា និងបទដ្ឋានដែលមានស្រាប់ក្នុងករណីសុំកូនក្នុងប្រទេស។

(ឃ) ចាត់វិធានការសមស្របនានាដើម្បីធានាក្នុងករណីសុំកូនអន្តរប្រទេស ថាការផ្តល់កូននេះ ពុំបណ្តាលឱ្យមានផលចំណេញផ្នែកហិរញ្ញវត្ថុដោយមិនត្រឹមត្រូវ ដល់រាល់បុគ្គលដែលមានការទាក់ទិន ក្នុងរឿងនេះឡើយ ។

(ង) ត្រូវលើកស្ទួយទិសដៅនៃមាត្រានេះតាមការធ្វើកិច្ចសម្រុះសម្រួល ឬចុះកិច្ចព្រមព្រៀង ទ្វេភាគី ឬពហុភាគី តាមករណីនីមួយៗ និងប្រឹងប្រែងក្នុងក្របខ័ណ្ឌនេះ ដើម្បីធានាថា ការទុកដាក់ នៅក្រៅប្រទេសនេះ ត្រូវបានអនុវត្ត ដោយអាជ្ញាធរ ឬអង្គការមានសមត្ថកិច្ច។

### មាត្រា ២២

១. រដ្ឋភាគីត្រូវចាត់វិធានការសមស្របដើម្បីធានាថា កុមារដែលស្វះស្វែងរកឋានៈជាជនភៀស ខ្លួន ឬដែលត្រូវបានចាត់ទុកជាជនភៀសខ្លួន ស្របតាមច្បាប់ និងនីតិវិធីអន្តរជាតិ ឬជាតិជាធរមាន ទោះដោយម្នាក់ឯងក្តី ឬរួមដំណើរដោយឪពុក-ម្តាយ ឬជនផ្សេងទៀតក្តី ត្រូវទទួលបានការការពារ និងជំនួយមនុស្សធម៌សមស្រប ដើម្បីអាស្រ័យផលពីសិទ្ធិពាក់ព័ន្ធ ដូចមានចែងក្នុងអនុសញ្ញានេះ និងក្នុងលិខិតុបករណ៍អន្តរជាតិស្តីពីសិទ្ធិមនុស្ស ឬមនុស្សធម៌ ដែលរដ្ឋទាំងនោះជាភាគី។

២. ក្នុងទិសដៅនេះ រដ្ឋភាគីត្រូវផ្តល់កិច្ចសហប្រតិបត្តិការដល់ការប្រឹងប្រែងទាំងអស់ដែល ធ្វើឡើងដោយអង្គការសហប្រជាជាតិ និងអង្គការអន្តររដ្ឋាភិបាល ឬអង្គការក្រៅរដ្ឋាភិបាលដែល មានសមត្ថកិច្ចសហការជាមួយអង្គការសហប្រជាជាតិ ដើម្បីការពារ និងជួយឧបត្ថម្ភកុមារដែល ស្ថិតនៅក្នុងស្ថានភាពដូចគ្នានេះ និងដើម្បីស្វែងរកឪពុក-ម្តាយ ឬសមាជិកគ្រួសារផ្សេងទៀតរបស់

កុមារភៀសខ្លួន ដើម្បីបានមកនូវព័ត៌មានចាំបាច់សម្រាប់កុមារ បានជួបជុំគ្រួសារខ្លួនឡើងវិញ។ បើរកមិនឃើញឪពុក-ម្តាយ ឬសមាជិកណាម្នាក់នៃគ្រួសាររបស់កុមារទេ កុមារត្រូវបានទទួលការការពារដូចគ្នានឹងកុមារផ្សេងទៀត ដែលបាត់បង់មជ្ឈដ្ឋានគ្រួសាររបស់ខ្លួនជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្ន ដោយហេតុផលណាមួយ ដូចចែងក្នុងអនុសញ្ញានេះ។

### មាត្រា ២៣

១. រដ្ឋភាគីទទួលស្គាល់ថា កុមារពិការខាងសតិបញ្ញា ឬរាងកាយ ត្រូវមានជីវភាពពេញលេញ និងសមរម្យ ក្នុងល័ក្ខខ័ណ្ឌដែលធានាដល់សេចក្តីថ្លៃថ្នូររបស់កុមារ លើកស្ទួយសេចក្តីទុកចិត្តលើខ្លួនឯងរបស់កុមារ និងសម្រួលឱ្យកុមារចូលរួមយ៉ាងសកម្មក្នុងសហគមន៍។

២. រដ្ឋភាគីទទួលស្គាល់សិទ្ធិទទួលបានការថែទាំពិសេសរបស់កុមារពិការ និងត្រូវជំរុញ និងធានាផ្តល់តាមធនធានដែលមានឱ្យដល់កុមារពិការ ដែលមានលក្ខណៈសម្បត្តិសមស្រប និងអ្នកដែលមានភារៈថែទាំកុមារ នូវជំនួយឧបត្ថម្ភ តាមការស្នើសុំ និងសមស្របទៅនឹងស្ថានភាពកុមារ និងស្ថានភាពឪពុក-ម្តាយកុមារ ឬអ្នកផ្សេងទៀតដែលថែទាំកុមារ។

៣. ដោយទទួលស្គាល់ នូវសេចក្តីត្រូវការពិសេសរបស់កុមារពិការ ជំនួយឧបត្ថម្ភដែលផ្តល់ស្របតាមកថាខណ្ឌ២ នៃមាត្រានេះ ត្រូវធ្វើដោយឥតគិតថ្លៃ រៀងរាល់លើកដែលអាចធ្វើទៅបាន ដោយយោងទៅលើប្រភពធនធាន ហិរញ្ញវត្ថុរបស់ឪពុក-ម្តាយកុមារ ឬអ្នកដែលថែទាំកុមារ។ ជំនួយឧបត្ថម្ភ ត្រូវគ្រោងដើម្បីធានាថា កុមារពិការមានសិទ្ធិទទួល និងទទួលប្រកបដោយប្រសិទ្ធភាព នូវការអប់រំ ការបណ្តុះបណ្តាល សេវាថែទាំសុខភាព សេវាស្តារនីតិសម្បទា ការរៀបចំចាត់ចែង ដើម្បីរកការងារធ្វើ និងឱកាសលំហែកាយ ដែលមានអត្ថប្រយោជន៍ឱ្យកុមារសម្រេចបាននូវសមាហរណកម្មដ៏ពេញលេញបំផុត តាមដែលអាចធ្វើបាន និងសម្រេចបានការអភិវឌ្ឍន៍ជាបុគ្គល រួមមាន ការអភិវឌ្ឍន៍ខាងវប្បធម៌ និងស្មារតីរបស់កុមារផង។

៤. ក្នុងស្មារតីនៃសហប្រតិបត្តិការអន្តរជាតិ រដ្ឋភាគី ត្រូវជំរុញឱ្យមានការផ្លាស់ប្តូរព័ត៌មានសមស្របស្តីពីការថែទាំ បង្ការសុខភាព និងការព្យាបាលតាមបែបវេជ្ជសាស្ត្រ ចិត្តសាស្ត្រ និងមុខងារនៃសរីរាង្គនៃកុមារពិការនោះ រួមមានការផ្សព្វផ្សាយ និងទទួលព័ត៌មានស្តីពីវិធីនៃការស្តារនីតិសម្បទា ការអប់រំ និងសេវាខាងវិជ្ជាជីវៈផង ក្នុងទិសដៅឱ្យរដ្ឋភាគីអាចបង្កើនសមត្ថភាព និង

ការប៉ិនប្រសប់របស់ខ្លួន និងពង្រីកបទពិសោធន៍របស់ខ្លួនក្នុងវិស័យនេះ។ ក្នុងចំណុចនេះ ត្រូវយកចិត្តទុកដាក់ជាពិសេសលើសេចក្ដីត្រូវការនៃប្រទេសដែលកំពុងអភិវឌ្ឍន៍។

### មាត្រា ២៤

១. រដ្ឋភាគីទទួលស្គាល់សិទ្ធិកុមារ ក្នុងការទទួលបានកម្រិតខ្ពស់បំផុតនៃសុខភាពតាមដែលអាចធ្វើទៅបាន ព្រមទាំងសម្ភារៈរូបវ័ន្តសម្រាប់ការព្យាបាលជំងឺ និងស្ដារសុខភាព។ រដ្ឋភាគី ត្រូវប្រឹងប្រែងធានាឱ្យបានថា គ្មានកុមារណាម្នាក់ ត្រូវបានដកសិទ្ធិទទួលបានសេវាថែទាំសុខភាពទាំងនេះឡើយ។

២. រដ្ឋភាគីត្រូវចាត់ចែងអនុវត្តឱ្យបានពេញលេញនូវសិទ្ធិនេះ និងជាពិសេស ត្រូវចាត់វិធានការសមស្រប ដើម្បីៈ

(ក) បន្ថយមរណភាពនៃទារក និងកុមារ។

(ខ) ធានាផ្ដល់ដល់កុមារទាំងអស់នូវជំនួយសុខាភិបាល និងការថែទាំសុខភាពចាំបាច់នានា ដោយផ្ដោតជាពិសេសលើការអភិវឌ្ឍន៍ការថែទាំសុខភាពបឋម។

(គ) កំចាត់រោគនិងកង្វះអាហារបំប៉នសុខភាព រួមទាំងក្នុងក្របខ័ណ្ឌថែទាំសុខភាពបឋមផងជាអាទិ៍ តាមរយៈការប្រើប្រាស់បច្ចេកវិជ្ជាដែលមានស្រាប់ និងតាមរយៈការផ្គត់ផ្គង់អាហារបំប៉នគ្រប់គ្រាន់ និងទឹកទទួលទានស្អាត ដោយគិតពីគ្រោះថ្នាក់ និងភ័យន្តរាយនៃភាពកខ្វក់ផ្នែកបរិស្ថាន។

(ឃ) ធានាឱ្យមាតាទាំងឡាយទទួលបានការថែទាំសុខភាពសមស្រប មុនពេល និងក្រោយពេលសម្រាលកូន។

(ង) ធានាឱ្យគ្រប់ផ្នែកនៃសង្គម ជាពិសេសឪពុក-ម្ដាយ និងកុមារ បានទទួលព័ត៌មាន មានសិទ្ធិទទួលការអប់រំ និងទទួលបានការឧបត្ថម្ភក្នុងការប្រើប្រាស់ចំណេះដឹងមូលដ្ឋានស្ដីពីសុខភាព និងអាហារបំប៉នកុមារ ប្រយោជន៍នៃការបំបៅកូនដោយទឹកដោះម្ដាយ អនាម័យរាងកាយ និងអនាម័យបរិស្ថាន និងការបង្ការគ្រោះថ្នាក់។

(ច) បង្កើតការថែទាំសុខភាព ដោយការបង្ការផ្ដល់ការណែនាំដល់ឪពុក-ម្ដាយ ការអប់រំ និងសេវាស្ដីពីផែនការគ្រួសារ។

៣. រដ្ឋភាគី ត្រូវចាត់គ្រប់វិធានការប្រកបដោយប្រសិទ្ធភាព និងសមស្រប ដើម្បីលុបបំបាត់រាល់ការអនុវត្តជាប្រពៃណីដែលប៉ះពាល់ដល់សុខភាពកុមារ។

៤. រដ្ឋភាគីរ៉ាប់រងលើកស្ទួយ និងលើកទឹកចិត្តដល់សហប្រតិបត្តិការអន្តរជាតិ ដើម្បីធ្វើឱ្យសម្រេចបានពេញលេញជាលំដាប់នូវសិទ្ធិ ដែលត្រូវបានទទួលស្គាល់ក្នុងមាត្រានេះ។ ចំពោះបញ្ហានេះ ត្រូវយកចិត្តទុកដាក់ជាពិសេស លើសេចក្ដីត្រូវការនៃប្រទេសកំពុងអភិវឌ្ឍន៍។

មាត្រា ២៥

រដ្ឋភាគី ទទួលស្គាល់ថា កុមារដែលត្រូវបានទុកដាក់ដោយអាជ្ញាធរមានសមត្ថកិច្ច ក្នុងគោលបំណង ដើម្បីថែទាំ ការពារ ឬព្យាបាលសុខភាពរាងកាយ ឬសតិបញ្ញា មានសិទ្ធិទទួលបានការពិនិត្យមើលជាទៀងទាត់នូវការថែទាំខ្លួន និងគ្រប់ស្ថានភាពផ្សេងទៀតពាក់ព័ន្ធនឹងការទុកដាក់នោះ។

មាត្រា ២៦

១. រដ្ឋភាគីត្រូវទទួលស្គាល់សិទ្ធិរបស់កុមារគ្រប់រូប ក្នុងការទទួលអត្ថប្រយោជន៍ពីសន្តិសុខសង្គម រួមមានកិច្ចធានារ៉ាប់រងសង្គមផង និងត្រូវចាត់វិធានការចាំបាច់ ដើម្បីធ្វើឱ្យសម្រេចបាននូវការប្រើប្រាស់ពេញលេញនូវសិទ្ធិនេះ ស្របតាមច្បាប់ជាតិរបស់ខ្លួន។

២. ផលប្រយោជន៍ទាំងនេះ បើសមស្រប ត្រូវតែផ្ដល់ឱ្យដោយគិតតាមធនធាន និងស្ថានភាពរបស់កុមារ និងអ្នកដែលមានភារកិច្ចថែទាំកុមារ ព្រមទាំងការពិចារណាផ្សេងទៀតពាក់ព័ន្ធនឹងការស្នើសុំផលប្រយោជន៍ ដែលធ្វើឡើងដោយកុមារ ឬក្នុងនាមកុមារ។

មាត្រា ២៧

១. រដ្ឋភាគី ទទួលស្គាល់សិទ្ធិរបស់កុមារគ្រប់រូបក្នុងការមានកម្រិតជីវភាពគ្រប់គ្រាន់សម្រាប់ការអភិវឌ្ឍន៍រាងកាយ សតិបញ្ញា ស្មារតី សីលធម៌ និងសង្គមរបស់កុមារ។

២. ឪពុក-ម្ដាយ ឬអ្នកផ្សេងទៀតដែលទទួលបន្ទុកលើកុមារ គឺជាអ្នកទទួលខុសត្រូវបឋមក្នុងការធានាឱ្យមានតាមលទ្ធភាព និងសមត្ថភាពហិរញ្ញវត្ថុរបស់ខ្លួននូវល័ក្ខខ័ណ្ឌនៃការរស់នៅដែលចាំបាច់ សម្រាប់ការរីកលូតលាស់របស់កុមារ។

៣. រដ្ឋភាគី ដោយយោងតាមស្ថានភាពជាតិ និងក្នុងកម្រិតមធ្យោបាយរបស់ខ្លួន ត្រូវចាត់វិធានការសមស្របនានា ដើម្បីជួយឧបត្ថម្ភដល់ឪពុក-ម្តាយ និងអ្នកផ្សេងទៀតដែលទទួលបន្ទុកលើកុមារ ដើម្បីអនុវត្តសិទ្ធិនេះ ហើយក្នុងករណីចាំបាច់ ត្រូវឧបត្ថម្ភសម្ភារៈ និងផ្តល់កម្មវិធីគាំទ្រនានា ជាពិសេសទាក់ទងនឹងចំណីអាហារ សំលៀកបំពាក់ និងកន្លែងស្នាក់នៅ។

៤. រដ្ឋភាគីត្រូវចាត់វិធានការសមស្រប ដើម្បីធ្វើឱ្យកុមារទទួលបាននូវ អាហារកិច្ចពីឪពុក-ម្តាយ ឬពីបុគ្គលផ្សេងទៀតដែលទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ សម្រាប់កុមារទាំងនៅក្នុងប្រទេស ទាំងនៅក្រៅប្រទេស។ ជាពិសេស បើអ្នកទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ សម្រាប់កុមាររស់នៅក្នុងប្រទេសផ្សេងពីប្រទេសរបស់កុមារ រដ្ឋភាគីត្រូវជំរុញឱ្យមានការចូលជាសមាជិកនៃកិច្ចព្រមព្រៀងអន្តរជាតិ ឬការចុះកិច្ចព្រមព្រៀងបែបនេះ ព្រមទាំងការរៀបចំសមស្របផ្សេងៗទៀត។

## មាត្រា ២៨

១. រដ្ឋភាគី ទទួលស្គាល់សិទ្ធិកុមារក្នុងការទទួលបានការអប់រំ ហើយដើម្បីអនុវត្តសិទ្ធិនេះឱ្យកាន់តែប្រសើរឡើងជាលំដាប់ និងផ្អែកលើមូលដ្ឋាននៃឱកាសស្មើភាព ជាពិសេស រដ្ឋភាគីត្រូវ៖

(ក) ធ្វើឱ្យការអប់រំកម្រិតបឋមមានលក្ខណៈជាកាតព្វកិច្ច និងឥតបង់ថ្លៃសម្រាប់គ្រប់គ្នា។

(ខ) ជំរុញការអភិវឌ្ឍន៍ទម្រង់ផ្សេងៗនៃការអប់រំកម្រិតមធ្យម រួមមាន ការអប់រំចំណេះទូទៅ និងវិជ្ជាជីវៈផង បើកឱ្យមាន និងទទួលបានដល់កុមារគ្រប់រូប និងចាត់វិធានការសមស្របនានា មានជាអាទិ៍ ការបង្កើតការអប់រំឥតបង់ថ្លៃ និងការផ្តល់ជំនួយហិរញ្ញវត្ថុក្នុងករណីចាំបាច់។

(គ) ធានាតាមគ្រប់មធ្យោបាយសមស្រប ឱ្យមានការអប់រំថ្នាក់ឧត្តម សម្រាប់ជនគ្រប់រូបដោយយកសមត្ថភាពជាមូលដ្ឋាន។

(ឃ) បើកឱ្យមាន និងធ្វើឱ្យកុមារទាំងអស់បានទទួលព័ត៌មាន និងការណែនាំស្តីពីការអប់រំ និងវិជ្ជាជីវៈ។

(ង) ចាត់វិធានការជំរុញឱ្យមានការចូលរៀនទៀងទាត់ និងកាត់បន្ថយអត្រាបោះបង់ចោលការសិក្សា។

២. រដ្ឋភាគីត្រូវចាត់វិធានការសមស្រប ដើម្បីធានាថា វិន័យសាលា ត្រូវបានអនុវត្តក្នុងបែបផែន ស្របនឹងសេចក្តីថ្លៃថ្នូរជាមនុស្សរបស់កុមារ និងស្របតាមអនុសញ្ញានេះ។

៣. រដ្ឋភាគី ត្រូវលើកស្ទួយ និងលើកទឹកចិត្តដល់សហប្រតិបត្តិការអន្តរជាតិក្នុងវិស័យអប់រំជាពិសេស ដើម្បីរួមចំណែកលុបបំបាត់ភាពអវិជ្ជា និងអនក្ខរភាពទូទាំងពិភពលោក និងដើម្បីសម្រួលសិទ្ធិទទួលបាននូវចំណេះដឹងផ្នែកវិទ្យាសាស្ត្រនិងបច្ចេកទេស និងវិធីបង្រៀនបែបទំនើប។ ក្នុងបញ្ហានេះត្រូវយកចិត្តទុកដាក់ជាពិសេសលើសេចក្ដីត្រូវការរបស់ប្រទេសដែលកំពុងអភិវឌ្ឍន៍។

មាត្រា ២៩

១. រដ្ឋភាគី យល់ស្របថា ការអប់រំកុមារត្រូវតែឆ្ពោះទៅរកៈ

(ក) ការអភិវឌ្ឍន៍បុគ្គលិកលក្ខណៈ ទេពកោលសល្យ សមត្ថភាព កាយនិងសតិបញ្ញារបស់កុមារ ឱ្យដល់សក្ដានុពលភាពពេញទំហឹងបំផុតរបស់កុមារ។

(ខ) ការបណ្ដុះគំនិតដល់កុមារឱ្យគោរពសិទ្ធិមនុស្សនិងសេរីភាពមូលដ្ឋាននិងគោលការណ៍ទាំងឡាយដែលមានចែងនៅក្នុងធម្មនុញ្ញសហប្រជាជាតិ។

(គ) ការបណ្ដុះគំនិតដល់កុមារ ឱ្យចេះគោរពឪពុក-ម្ដាយ អត្តសញ្ញាណ វប្បធម៌ ភាសា និងតម្លៃរបស់ខ្លួន ការគោរពតម្លៃជាតិនៃប្រទេសដែលកុមារកំពុងរស់នៅ ការគោរពតម្លៃជាតិនៃប្រទេសដែលអាចជាដើមកំណើតរបស់កុមារ និងគោរពអារ្យធម៌នានា ដែលខុសពីអារ្យធម៌ផ្ទាល់ខ្លួនរបស់កុមារ។

(ឃ) ការរៀបចំចាត់ចែងឱ្យកុមាររស់នៅ ប្រកបដោយការទទួលខុសត្រូវក្នុងសង្គមសេរីក្នុងស្មារតីយោគយល់គ្នា សន្តិភាព អត់ឱនឱ្យគ្នា សមភាព ភេទ និងមិត្តភាពរវាងប្រជាជាតិទាំងអស់ ក្រុមជាតិពន្ធ ជនជាតិ និងសាសនា និងជនអន្តោប្រាណ។

(ង) ការបណ្ដុះគំនិតដល់កុមារ ឱ្យគោរពបរិស្ថានធម្មជាតិ។

២. គ្មានផ្នែកណាមួយនៃមាត្រានេះ ឬមាត្រា២៨ ត្រូវបានយកមកបកស្រាយ ធ្វើឱ្យប៉ះពាល់ដល់សេរីភាពរបស់រូបវន្តបុគ្គលឬនីតិបុគ្គល ក្នុងការបង្កើត និងដឹកនាំគ្រឹះស្ថានសិក្សាឡើយ ជានិច្ចកាល ត្រូវតែគោរពតាមគោលការណ៍ដែលមានចែងក្នុងកថាខណ្ឌ១ នៃមាត្រានេះ ត្រូវតែបំពេញទៅតាមលក្ខខណ្ឌតំរូវដែលថា ការអប់រំដែលផ្ដល់ក្នុងគ្រឹះស្ថានទាំងនោះ ស្របតាមបទដ្ឋានអប្បបរមាតាមការកំណត់របស់រដ្ឋ។

### មាត្រា ៣០

នៅក្នុងរដ្ឋដែលមានជនភាគតិចខាងជាតិពន្ធុ សាសនា ឬភាសា ឬជនអន្តោប្រវេសន៍ កុមារជាសមាជិកនៃជនភាគតិច ឬជនអន្តោប្រវេសន៍នេះ មិនត្រូវទទួលរងនូវការបដិសេធសិទ្ធិមានជីវភាពវប្បធម៌ សិទ្ធិសំដែង និងប្រតិបត្តិសាសនា ឬប្រើភាសាផ្ទាល់ខ្លួន ដោយរួមជាមួយសមាជិកផ្សេងទៀតនៃក្រុមរបស់ខ្លួនឡើយ។

### មាត្រា ៣១

១. រដ្ឋភាគីទទួលស្គាល់សិទ្ធិរបស់កុមារ ក្នុងការសម្រាក និងលំហែកាយ ចូលរួមក្នុងការលេង និងក្នុងសកម្មភាពកំសាន្តផ្សេងៗ សមស្របតាមអាយុរបស់កុមារ និងចូលរួមដោយសេរីក្នុងជីវភាពវប្បធម៌ និងសិល្បៈ។

២. រដ្ឋភាគីត្រូវគោរព និងលើកស្ទួយសិទ្ធិរបស់កុមារ ក្នុងការចូលរួមយ៉ាងពេញលេញក្នុងជីវភាពវប្បធម៌ និងសិល្បៈ និងត្រូវជំរុញឱ្យមានការផ្តល់ឱកាសសមស្រប និងស្មើភាពសម្រាប់សកម្មភាពវប្បធម៌ សិល្បៈ លេងកំសាន្ត និងលំហែកាយ។

### មាត្រា ៣២

១. រដ្ឋភាគី ទទួលស្គាល់សិទ្ធិការពារកុមារ ប្រឆាំងការកេងប្រវ័ញ្ចសេដ្ឋកិច្ច និងការឱ្យធ្វើការងារប្រកបដោយគ្រោះថ្នាក់ ឬដែលអាចប៉ះពាល់ដល់ការសិក្សារបស់កុមារ ឬដែលអាចបំផ្លាញសុខភាព ឬការអភិវឌ្ឍន៍រាងកាយ សតិបញ្ញា ស្មារតី សីលធម៌ ឬសង្គមរបស់កុមារ។

២. រដ្ឋភាគីត្រូវចាត់វិធានការខាងផ្លូវច្បាប់ រដ្ឋបាល សង្គម និងការអប់រំ ដើម្បីធានាដល់ការអនុវត្តមាត្រានេះ។ ក្នុងទិសដៅនេះ និងយោងតាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងលិខិតុបករណ៍អន្តរជាតិផ្សេងទៀត រដ្ឋភាគី ជាពិសេស:

(ក) ត្រូវកំណត់អាយុអប្បបរមាមួយ ឬអាយុអប្បបរមាច្រើន សម្រាប់ចូលធ្វើការ។

(ខ) ត្រូវចែងបទបញ្ជាសមស្របស្តីពីម៉ោងពេល និងល័ក្ខខ័ណ្ឌការងារ។

(គ) ត្រូវកំណត់ទោស ឬទណ្ឌកម្មសមស្របផ្សេងទៀត ដើម្បីធានាដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវមាត្រានេះ។

មាត្រា ៣៣

រដ្ឋភាគី ត្រូវចាត់វិធានការសមស្រប រួមបញ្ចូលទាំងវិធានការខាងផ្លូវច្បាប់ រដ្ឋបាល សង្គម និងការអប់រំ ដើម្បីការពារកុមារឱ្យផុតពីការប្រើប្រាស់ខុសច្បាប់ នូវថ្នាំញៀន និងសារជាតិសណ្ដំស្មារតី ដូចមានកំណត់ក្នុងសន្ធិសញ្ញាអន្តរជាតិពាក់ព័ន្ធ និងដើម្បីទប់ស្កាត់ការប្រើប្រាស់កុមារក្នុងការផលិត និងការជួញដូរខុសច្បាប់នូវសារជាតិទាំងនេះ។

មាត្រា ៣៤

រដ្ឋភាគី រ៉ាប់រងការពារកុមារ ឱ្យផុតពីគ្រប់ទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ។ ក្នុងទិសដៅនេះ រដ្ឋភាគី ជាពិសេស ត្រូវចាត់វិធានការសមស្របនានា ក្នុងក្របខ័ណ្ឌជាតិ ក្របខ័ណ្ឌទ្វេភាគី និងពហុភាគី ដើម្បីទប់ស្កាត់ :

(ក) ការអូសទាញ ឬការបង្ខិតបង្ខំកុមារ ឱ្យចូលរួមក្នុងសកម្មភាពខាងផ្លូវភេទខុសច្បាប់។

(ខ) ការប្រើប្រាស់កុមារក្នុងពេស្យាកម្មកេងប្រវ័ញ្ច ឬប្រព្រឹត្តដោយខុសច្បាប់ខាងផ្លូវភេទផ្សេងទៀត។

(គ) ការប្រើប្រាស់កុមារដោយកេងប្រវ័ញ្ច នៅក្នុងការសម្ដែងអាសអាភាស និងផលិតសម្ភារៈ ឬរូបភាពអាសអាភាស។

មាត្រា ៣៥

រដ្ឋភាគី ត្រូវចាត់វិធានការសមស្របក្នុងក្របខ័ណ្ឌជាតិ ទ្វេភាគី និងពហុភាគី ដើម្បីទប់ស្កាត់ការចាប់ពង្រត់ ការលក់ ឬការជួញដូរកុមារ ទោះក្នុងគោលបំណងអ្វី ឬទម្រង់ណាក៏ដោយ។

មាត្រា ៣៦

រដ្ឋភាគី ត្រូវការពារកុមារប្រឆាំងនឹងទម្រង់ផ្សេងទៀតទាំងអស់នៃការកេងប្រវ័ញ្ច ដែលប៉ះពាល់ដល់គ្រប់ទិដ្ឋភាពណាមួយនៃសុខុមាលភាពរបស់កុមារ។

មាត្រា ៣៧

រដ្ឋភាគី ត្រូវធានាថា :

(ក) គ្មានកុមារណាម្នាក់ត្រូវទទួលរងទារុណកម្ម ឬការប្រព្រឹត្តទៅលើខ្លួន ឬការផ្ដន្ទាទោសឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបឡើយ។ ទោសប្រហារជីវិត ឬដាក់គុកអស់មួយជីវិតដោយគ្មានលទ្ធភាពដោះលែង មិនត្រូវដាក់ចំពោះបទល្មើសដែលប្រព្រឹត្តដោយមនុស្សមានអាយុក្រោម១៨ឆ្នាំឡើយ។

(ខ) គ្មានកុមារណាម្នាក់ ត្រូវបានដកហូតសេរីភាពដោយខុសច្បាប់ ឬតាមអំពើចិត្តឡើយ។ ការចាប់ខ្លួន ការឃាត់ ឬការឃុំខ្លួន ឬការដាក់ពន្ធនាគារកុមារ ត្រូវធ្វើស្របតាមច្បាប់ និងត្រូវប្រើសម្រាប់តែវិធានការចុងក្រោយ និងសម្រាប់រយៈពេលខ្លីបំផុត។

(គ) កុមារណា ដែលត្រូវបានដកហូតសេរីភាព ត្រូវទទួលបានការប្រព្រឹត្តមកលើខ្លួន ប្រកបដោយមនុស្សធម៌ ដោយការគោរពចំពោះសេចក្តីថ្លៃថ្នូរជាប់ពីកំណើតរបស់មនុស្ស និងគិតដល់សេចក្តីត្រូវការរបស់មនុស្សក្នុងវ័យរបស់ខ្លួន។ ជាពិសេស រាល់កុមារដែលត្រូវបានដកហូតសេរីភាព ត្រូវដាក់ឱ្យនៅដោយឡែកពីមនុស្សពេញវ័យ លើកលែងតែឧត្តមប្រយោជន៍របស់កុមារមិនតម្រូវឱ្យធ្វើដូច្នេះ ហើយកុមារទាំងនេះ ត្រូវមានសិទ្ធិទាក់ទងជាមួយគ្រួសារខ្លួន តាមរយៈការឆ្លើយឆ្លង និងការជួបសួរសុខទុក្ខ លើកលែងតែក្នុងកាលៈទេសៈពិសេសចេញ។

(ឃ) កុមារដែលត្រូវបានដកហូតសេរីភាព មានសិទ្ធិទទួលបានភ្លាមៗ នូវជំនួយផ្នែកច្បាប់ និងជំនួយសមស្របផ្សេងៗទៀត និងមានសិទ្ធិជំទាស់ភាពស្របច្បាប់នៃការដកហូតសេរីភាពខ្លួននៅចំពោះមុខតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង និងមានសិទ្ធិទទួលបានសេចក្តីសម្រេចយ៉ាងឆាប់ លើចំណាត់ការបែបនេះ។

### មាត្រា ៣៨

១. រដ្ឋភាគីរ៉ាប់រង និងធានាឱ្យមានការគោរពវិធាននៃច្បាប់មនុស្សធម៌អន្តរជាតិដែលអនុវត្តទៅលើរដ្ឋភាគីដែលមានជម្លោះប្រដាប់អាវុធ ហើយពាក់ព័ន្ធនឹងកុមារ។

២. រដ្ឋភាគីត្រូវចាត់វាល់វិធានការដែលអាចធ្វើទៅបាន ដើម្បីធានាថា មនុស្សដែលមិនទាន់ដល់អាយុ១៥ឆ្នាំ មិនត្រូវចូលរួមដោយផ្ទាល់ក្នុងអរិភាពឡើយ។

៣. រដ្ឋភាគី ត្រូវជៀសវាងរើសមនុស្សដែលមានអាយុមិនទាន់ដល់១៥ឆ្នាំ ឱ្យចូលបំរើក្នុងកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន។ ក្នុងការរើសទ័ព ក្នុងចំណោមមនុស្សដែលមានអាយុចាប់ពី១៥ឆ្នាំឡើង ប៉ុន្តែមិនទាន់ដល់អាយុ១៨ឆ្នាំ រដ្ឋភាគីត្រូវខំប្រឹងប្រែងជ្រើសរើសមនុស្ស ដែលមានអាយុច្រើនជាងគេបំផុតជាអាទិភាព។

៤. ស្របទៅតាមកាតព្វកិច្ចរបស់រដ្ឋ ក្រោមច្បាប់មនុស្សធម៌អន្តរជាតិ ដើម្បីការពារជនស៊ីវិលក្នុងជម្លោះប្រដាប់អាវុធ រដ្ឋភាគី ត្រូវចាត់វាល់វិធានការ ដែលអាចធ្វើទៅបាន ដើម្បីធានាការពារ និងថែទាំកុមារដែលប៉ះពាល់ដោយជម្លោះប្រដាប់អាវុធ។

មាត្រា ៣៩

រដ្ឋភាគី ត្រូវចាត់វាល់វិធានការសមស្រប ដើម្បីជំរុញការស្តារកាយសម្បទា និងចិត្តសាស្ត្រ ឱ្យមានដូចដើមវិញ និងសមាហរណកម្មសង្គមកុមាររងគ្រោះ ពីទម្រង់ណាមួយនៃការទុកចោល មិនយកចិត្តទុកដាក់ ការកេងប្រវ័ញ្ច ឬការរំលោភបំពាន ការធ្វើទារុណកម្ម ឬទម្រង់ណាមួយនៃការប្រព្រឹត្តទៅលើខ្លួន ឬទណ្ឌកម្មដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ឬដោយសារជម្លោះប្រដាប់អាវុធ។ ការស្តារ និងសមាហរណកម្មទាំងនេះ ត្រូវប្រព្រឹត្តក្នុងបរិយាកាសមួយ ដែលលើកស្ទួយសុខភាព ការគោរពតម្លៃខ្លួនឯង និងសេចក្តីថ្លៃថ្នូររបស់កុមារ។

មាត្រា ៤០

១. រដ្ឋភាគីទទួលស្គាល់ថា កុមារដែលជាប់សង្ស័យ ជាប់ចោទឬដែលគេស្គាល់ថា បានល្មើសនឹងច្បាប់ព្រហ្មទ័ណ្ឌ មានសិទ្ធិទទួលបាននូវការប្រព្រឹត្តមកលើខ្លួន តាមលក្ខណៈមួយដែលលើកស្ទួយសេចក្តីថ្លៃថ្នូរ និងតម្លៃរបស់កុមារ ដែលពង្រឹងកុមារ ឱ្យចេះគោរពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានរបស់អ្នកដទៃ ដោយគិតពីអាយុរបស់កុមារ ព្រមទាំងពីអត្ថប្រយោជន៍នៃការលើកស្ទួយការធ្វើសមាហរណកម្មកុមារមកក្នុងសង្គមវិញ និងឱ្យកុមារបំពេញតួនាទីស្ថាបនានៅក្នុងសង្គម។

២. ក្នុងទិសដៅនេះ និងដោយគិតទៅនឹងបទប្បញ្ញត្តិនៃលិខិតុបករណ៍អន្តរជាតិដែលពាក់ព័ន្ធ រដ្ឋភាគីត្រូវធានា ជាពិសេសថា :

(ក) គ្មានកុមារណាម្នាក់ ត្រូវជាប់សង្ស័យ ជាប់ចោទ ឬទទួលស្គាល់ថា បានល្មើសនឹងច្បាប់ព្រហ្មទណ្ឌដោយសារអំពើ ឬការខកខានដែលច្បាប់ជាតិ ឬច្បាប់អន្តរជាតិ មិនបានហាមឃាត់នៅពេលអំពើ ឬការខកខាននោះត្រូវបានប្រព្រឹត្ត។

(ខ) កុមារដែលជាប់សង្ស័យ ឬជាប់ចោទថា បានរំលោភច្បាប់ព្រហ្មទណ្ឌ យ៉ាងហោចណាស់ ត្រូវទទួលបាននូវការធានាដូចតទៅ :

(i) ចាត់ទុកកុមារថា ឥតទោសរហូតទាល់តែពិរុទ្ធភាព ត្រូវបានបង្ហាញស្របតាមច្បាប់។

(ii) ប្រាប់កុមារភ្លាមៗ និងដោយផ្ទាល់ អំពីបទចោទមកលើខ្លួន ឬបើសមស្រប ប្រាប់តាមរយៈឪពុក-ម្ដាយ ឬអ្នកអាណាព្យាបាលស្របច្បាប់របស់កុមារ និងផ្ដល់ជំនួយផ្នែកច្បាប់ ឬជំនួយសមស្របផ្សេងទៀត សម្រាប់ការរៀបចំ និងដាក់ចេញនូវមធ្យោបាយការពារខ្លួន។

(iii) ទទួលបានការដោះស្រាយបញ្ហា ដោយគ្មានការយឺតយ៉ាវពីសំណាក់អាជ្ញាធរ ឬស្ថាប័នតុលាការដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង នៅក្នុងការជំនុំជំរះដ៏យុត្តិធម៌មួយ ដែលសមស្របទៅតាមច្បាប់ និងដោយមានជំនួយផ្នែកច្បាប់ ឬជំនួយសមស្របផ្សេងៗទៀត ហើយប្រសិនបើមិនផ្ទុយនឹងឧត្តមប្រយោជន៍របស់កុមារនោះ ជាពិសេស ដោយយោងទៅលើអាយុ ឬស្ថានភាពរបស់កុមារ ដោយមានវត្តមានរបស់ឪពុក-ម្ដាយ ឬអ្នកអាណាព្យាបាលស្របច្បាប់របស់កុមារផង។

(iv) មិនត្រូវទទួលរងការបង្ខិតបង្ខំឱ្យផ្ដល់សក្ខីកម្ម ឬសារភាពកំហុសឡើយ។ ត្រូវសួរចម្លើយ ឬឱ្យមានការសួរចម្លើយសាក្សីដាក់បន្ទុក និងត្រូវឱ្យមានការចូលរួម និងការសួរចម្លើយសាក្សីដោះបន្ទុកក្នុងនាមកុមារ ក្រោមល័ក្ខខ័ណ្ឌសមភាព ។

(v) បើយល់ឃើញថា បានរំលោភច្បាប់ព្រហ្មទណ្ឌ កុមារអាចសុំឱ្យអាជ្ញាធរ ដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង ឬតុលាការថ្នាក់លើ ពិនិត្យឡើងវិញលើសេចក្ដីសម្រេចនេះ និងលើវិធានការណាមួយដែលដាក់បង្ខំ តាមសេចក្ដីសម្រេចនេះ ដោយស្របតាមច្បាប់។

(vi) ទទួលបានដោយឥតគិតថ្លៃនូវជំនួយពីអ្នកបកប្រែ បើកុមារមិនអាចយល់ ឬនិយាយភាសាដែលត្រូវបានប្រើនោះទេ។

(vii) ត្រូវគោរពយ៉ាងពេញលេញនូវសិទ្ធិនៃជីវិតឯកជនរបស់កុមារនៅក្នុងគ្រប់ដំណាក់កាលនៃនីតិវិធី។

៣. រដ្ឋភាគី ត្រូវខិតខំលើកស្ទួយការបង្កើតច្បាប់នីតិវិធី អាជ្ញាធរ និងស្ថាប័នសម្រាប់អនុវត្តជាពិសេស ទៅលើកុមារដែលជាប់សង្ស័យ ជាប់ចោទ ឬទទួលស្គាល់ថា បានរំលោភច្បាប់ព្រហ្មទណ្ឌ និងជាពិសេស :

(ក) ត្រូវកំណត់អាយុអប្បបរមាដែលក្រោមអាយុអប្បបរមានេះ កុមារត្រូវបានសន្មត់ជាមុនថា ពុំមានសមត្ថភាពរំលោភច្បាប់ព្រហ្មទ័ណ្ឌឡើយ។

(ខ) ក្នុងករណីសមស្រប និងចាំបាច់ វិធានការសម្រាប់ដោះស្រាយចំពោះកុមារទាំងនេះ មិនចាំបាច់ឆ្លងកាត់នីតិវិធីតុលាការឡើយ ឱ្យតែធានា និងគោរពបានពេញលេញនូវសិទ្ធិមនុស្ស និងការធានាខាងផ្លូវច្បាប់។

៤. ចំណាត់ការមួយចំនួន ដូចជា ការថែទាំ របៀបណែនាំ និងដឹកាតាមដាន ការពិគ្រោះយោបល់ ការសាកល្បងឱ្យនៅក្រៅឃុំ ការថែទាំដោយឪពុក-ម្តាយធម៌ កម្មវិធីអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមធ្យោបាយផ្សេងៗទៀត ជំនួសការថែទាំតាមស្ថាប័ន ត្រូវធ្វើឱ្យមាន ដើម្បីធានាថា កុមារទទួលបាននូវចំណាត់ការដែលសមស្រប ចំពោះសុខុមាលភាពរបស់ខ្លួន និងមានសមាមាត្រទៅនឹងស្ថានភាពរបស់កុមារ និងបទល្មើស។

### មាត្រា ៤១

គ្មានបទប្បញ្ញត្តិណាមួយនៃអនុសញ្ញានេះ ធ្វើឱ្យប៉ះពាល់ដល់បទប្បបញ្ញត្តិណាមួយដែលមានអំណោយផលល្អជាង ក្នុងការធ្វើឱ្យសម្រេចដល់សិទ្ធិទាំងឡាយរបស់កុមារ ហើយដែលអាចមានចែងក្នុង :

(ក) ច្បាប់របស់រដ្ឋភាគី ឬ

(ខ) ច្បាប់អន្តរជាតិដែលចូលធរមានសម្រាប់រដ្ឋនោះ។

## *ផ្នែកទី ២*

### មាត្រា ៤២

រដ្ឋភាគី រ៉ាប់រងផ្សព្វផ្សាយយ៉ាងទូលំទូលាយនូវគោលការណ៍ និងបទប្បញ្ញត្តិនៃអនុសញ្ញានេះតាមមធ្យោបាយសមស្រប និងដ៏សកម្ម ដល់មនុស្សពេញវ័យ ក៏ដូចជាកុមារផងដែរ។

### មាត្រា ៤៣

១. ក្នុងគោលបំណងពិនិត្យ ការវិវត្តទៅមុខនៃការសម្រេចបាននូវការបំពេញកាតព្វកិច្ច ក្នុងអនុសញ្ញានេះ ដែលរ៉ាប់រងដោយរដ្ឋភាគី គណៈកម្មាធិការស្តីពីសិទ្ធិកុមារមួយ ត្រូវបានបង្កើតឡើង។ គណៈកម្មាធិការ មានមុខងារកំណត់ ដូចតទៅនេះ។

២. គណៈកម្មាធិការ ត្រូវមានអ្នកជំនាញការចំនួន១០រូប ដែលមានសីលធម៌ខ្ពស់ និងមានសមត្ថកិច្ច ដែលគេទទួលស្គាល់ក្នុងវិស័យដូចចែងក្នុងអនុសញ្ញានេះ។ សមាជិកនៃគណៈកម្មាធិការ

ត្រូវជ្រើសរើសតាមការបោះឆ្នោតដោយរដ្ឋភាគី ពីក្នុងចំណោមជនជាតិរបស់ខ្លួន និងត្រូវធ្វើការក្នុងសមត្ថកិច្ចជាបុគ្គល ដោយធ្វើការពិចារណាបែងចែកទៅតាមភូមិសាស្ត្រ ដោយសមធម៌ ព្រមទាំងទៅតាមប្រព័ន្ធច្បាប់ធំៗ។

៣. សមាជិកគណៈកម្មាធិការ ត្រូវជ្រើសរើសតាមការបោះឆ្នោតជាសម្ងាត់ ពីបញ្ជីឈ្មោះបេក្ខជនដែលជ្រើសតាំងដោយរដ្ឋភាគី។ រដ្ឋភាគីនីមួយៗ អាចជ្រើសតាំងបេក្ខជន១រូបពីក្នុងចំណោមជនជាតិរបស់ខ្លួន។

៤. ការបោះឆ្នោតលើកដំបូង ត្រូវរៀបចំឡើងក្នុងរយៈពេលមិនឱ្យលើសពី៦ខែ បន្ទាប់ពីកាលបរិច្ឆេទដែលអនុសញ្ញានេះ ចូលជាធរមាន និងបន្ទាប់មក ការបោះឆ្នោត ត្រូវរៀបចំឡើងរៀងរាល់ពីរឆ្នាំម្តង។ យ៉ាងតិច៤ខែ មុនដល់កាលបរិច្ឆេទកំណត់នៃការបោះឆ្នោតនីមួយៗ អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវចេញលិខិតអញ្ជើញ ឱ្យរដ្ឋភាគីដាក់បញ្ជីឈ្មោះបេក្ខជនរបស់ខ្លួនក្នុងរយៈពេល២ខែ។ បន្ទាប់មក អគ្គលេខាធិការ ត្រូវរៀបចំបញ្ជីឈ្មោះបេក្ខជនទាំងអស់តាមលំដាប់អក្សរក្រម ដោយបញ្ជាក់ឈ្មោះរដ្ឋភាគី ដែលបានជ្រើសតាំងបេក្ខជនទាំងនោះ ហើយត្រូវបញ្ជូនបញ្ជីឈ្មោះនេះ ទៅរដ្ឋភាគីនៃអនុសញ្ញានេះ។

៥. ការបោះឆ្នោតត្រូវរៀបចំឡើងក្នុងសម័យប្រជុំនៃរដ្ឋភាគី នៅទីស្នាក់ការអង្គការសហប្រជាជាតិ តាមការកោះអញ្ជើញដោយអគ្គលេខាធិការ។ កូរ៉ុមសម្រាប់កិច្ចប្រជុំ គឺពីរភាគបីនៃរដ្ឋភាគីនៃអនុសញ្ញានេះ បេក្ខជនដែលជាប់ជាសមាជិកគណៈកម្មាធិការ ត្រូវតែជាបេក្ខជនទទួលបានសម្លេងច្រើនបំផុត និងសម្លេងភាគច្រើនដាច់ខាត ពីតំណាងរបស់រដ្ឋភាគី ដែលមានវត្តមាន និងបានបោះឆ្នោត។

៦. សមាជិកនៃគណៈកម្មាធិការ ត្រូវជ្រើសរើសតាមការបោះឆ្នោត សម្រាប់រយៈពេល៤ឆ្នាំ។ សមាជិកគណៈកម្មាធិការ អាចមានសិទ្ធិឈរឈ្មោះបោះឆ្នោតឡើងវិញ ប្រសិនបើមានការជ្រើសតាំងជាថ្មី។ អាណត្តិសមាជិក៥រូប ក្នុងចំណោមសមាជិកជាប់ឆ្នោតលើកទី១ ត្រូវផុតកំណត់ក្នុងរយៈពេល២ឆ្នាំ ហើយឈ្មោះរបស់សមាជិកទាំង៥រូបនេះ ត្រូវចាប់ឆ្នោតជាបន្ទាន់ដោយប្រធានអង្គប្រជុំ ក្រោយពីការបោះឆ្នោតលើកទី១។

៧. ក្នុងគ្រាមានមរណភាព ឬការសុំលាឈប់ពីតំណែង ឬប្រកាសដោយបុព្វហេតុណាមួយថា មិនអាចបំពេញមុខងាររបស់ខ្លួនក្នុងគណៈកម្មាធិការនោះ រដ្ឋភាគីដែលបានជ្រើសតាំងសមាជិកនេះ ត្រូវតែងតាំងអ្នកជំនាញម្នាក់ផ្សេងទៀត ពីក្នុងចំណោមជនជាតិរបស់ខ្លួន ឱ្យបន្តបំពេញរយៈពេលនៃអាណត្តិដែលនៅសល់ ដោយមានការយល់ព្រមពីគណៈកម្មាធិការ។

៨. គណៈកម្មាធិការ ត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

៩. គណៈកម្មាធិការ ត្រូវជ្រើសរើសមន្ត្រីការិយាល័យរបស់ខ្លួន សម្រាប់រយៈពេល២ឆ្នាំ។

១០. សម័យប្រជុំណៈកម្មាធិការ ត្រូវធ្វើជាធម្មតានៅទីស្នាក់ការអង្គការសហប្រជាជាតិ ឬនៅកន្លែងសមស្របណាមួយផ្សេងទៀត ដែលកំណត់ដោយគណៈកម្មាធិការ។ គណៈកម្មាធិការត្រូវរៀបចំសម័យប្រជុំប្រចាំឆ្នាំជាធម្មតា។ រយៈពេលនៃសម័យប្រជុំគណៈកម្មាធិការ ត្រូវកំណត់ ឬកែប្រែឡើងវិញ បើចាំបាច់ ក្នុងសម័យប្រជុំមួយរបស់រដ្ឋភាគីនៃអនុសញ្ញានេះ ដោយមានការយល់ព្រមពីមហាសន្និបាតអង្គការសហប្រជាជាតិ។

១១. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវផ្តល់បុគ្គលិក និងសម្ភារៈរូបវ័ន្តចាំបាច់ ដើម្បីឱ្យគណៈកម្មាធិការបំពេញមុខងារ ប្រកបដោយប្រសិទ្ធភាព ស្របតាមអនុសញ្ញានេះ។

១២. ដោយមានការយល់ព្រមពីមហាសន្និបាតអង្គការសហប្រជាជាតិ សមាជិកគណៈកម្មាធិការដែលបានបង្កើតឡើង ស្របតាមអនុសញ្ញានេះ ត្រូវទទួលបរិលាភពីធនធានរបស់អង្គការសហប្រជាជាតិ តាមលក្ខខណ្ឌ និងខទាំងឡាយដែលកំណត់ដោយមហាសន្និបាត។

### មាត្រា ៤៤

១. រដ្ឋភាគីរ៉ាប់រងដាក់ជូនគណៈកម្មាធិការ តាមរយៈអគ្គលេខាធិការអង្គការសហប្រជាជាតិ នូវរបាយការណ៍ស្តីពីវិធានការដែលបានប្រកាន់យក ដើម្បីធ្វើឱ្យសម្រេចនូវសិទ្ធិទាំងឡាយ ដែលបានទទួលស្គាល់ក្នុងអនុសញ្ញានេះ និងរបាយការណ៍ស្តីពីវឌ្ឍនភាពក្នុងការអាស្រ័យផលពីសិទ្ធិទាំងនេះ:

(ក) ក្នុងរយៈពេល២ឆ្នាំ ពីពេលដែលអនុសញ្ញានេះចូលជាធរមានសម្រាប់រដ្ឋភាគីពាក់ព័ន្ធ។

(ខ) បន្ទាប់មក រៀងរាល់៥ឆ្នាំម្តង។

២. របាយការណ៍ដែលធ្វើស្របតាមមាត្រានេះ ត្រូវបញ្ជាក់ពីកត្តា និងការលំបាក បើមាន ដែលនាំឱ្យប៉ះពាល់ដល់កម្រិតនៃការបំពេញកាតព្វកិច្ចក្រោមអនុសញ្ញានេះ។ របាយការណ៍ ត្រូវបញ្ចូលព័ត៌មានឱ្យបានគ្រប់គ្រាន់ផងដែរ ដើម្បីផ្តល់ឱ្យគណៈកម្មាធិការ នូវការពន្យល់សព្វគ្រប់អំពីការអនុវត្តអនុសញ្ញា ក្នុងប្រទេសពាក់ព័ន្ធ។

៣. រដ្ឋភាគី ដែលដាក់របាយការណ៍ពេញលេញលើកដំបូងជូនគណៈកម្មាធិការ មិនចាំបាច់សរសេរឡើងវិញ ក្នុងរបាយការណ៍បន្តបន្ទាប់របស់ខ្លួន ដែលដាក់ជូនគណៈកម្មាធិការ ស្របតាមកថាខណ្ឌ១(ខ) នៃមាត្រានេះ នូវព័ត៌មានជាមូលដ្ឋានដែលមានក្នុងរបាយការណ៍មុនៗទេ។

៤. គណៈកម្មាធិការអាចស្នើសុំព័ត៌មានបន្ថែមពីរដ្ឋភាគី ទាក់ទងនឹងការអនុវត្តអនុសញ្ញានេះ។

៥. គណៈកម្មាធិការ ត្រូវបញ្ជូនរបាយការណ៍ស្តីពីសកម្មភាពរបស់ខ្លួន តាមរយៈក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម ទៅមហាសន្និបាតរៀងរាល់២ឆ្នាំម្តង។

៦. រដ្ឋភាគី ត្រូវធានាឱ្យមានការផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់សាធារណជន នូវរបាយការណ៍របស់ខ្លួន នៅក្នុងប្រទេសខ្លួនផ្ទាល់។

### មាត្រា ៤៥

ដើម្បីជំរុញឱ្យមានប្រសិទ្ធភាព ក្នុងការអនុវត្តអនុសញ្ញានេះ និងដើម្បីលើកទឹកចិត្តដល់កិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងវិស័យដូចចែងក្នុងអនុសញ្ញានេះ ៖

(ក) ទីភ្នាក់ងារឯកទេស មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ និងស្ថាប័នផ្សេងទៀតនៃអង្គការសហប្រជាជាតិ មានសិទ្ធិតែងតាំងតំណាង ដើម្បីត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិ នៃអនុសញ្ញានេះក្នុងក្របខ័ណ្ឌនៃអាណត្តិរបស់ខ្លួន។ គណៈកម្មាធិការអាចអញ្ជើញទីភ្នាក់ងារឯកទេស មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ ឬស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត ដែលគណៈកម្មាធិការ អាចនឹងយល់ថាសមស្រប ដើម្បីផ្តល់មតិឯកទេសស្តីពីការអនុវត្តអនុសញ្ញានេះ ក្នុងវិស័យដែលស្ថិតក្នុងក្របខ័ណ្ឌនៃអាណត្តិរបស់ខ្លួនរៀងៗខ្លួន។ គណៈកម្មាធិការ អាចអញ្ជើញទីភ្នាក់ងារឯកទេស មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ ឬស្ថាប័នផ្សេងទៀតរបស់អង្គការសហប្រជាជាតិ បញ្ជូនរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញានេះ ក្នុងវិស័យដែលស្ថិតក្នុងក្របខ័ណ្ឌនៃសកម្មភាពរបស់ខ្លួន។

(ខ) បើយល់ថាចាំបាច់ គណៈកម្មាធិការត្រូវបញ្ជូនទៅទីភ្នាក់ងារឯកទេស មូលនិធិសហប្រជាជាតិដើម្បីកុមារ និងស្ថាប័នមានសមត្ថកិច្ចឯទៀត នូវរបាយការណ៍ណាមួយរបស់រដ្ឋភាគី ដែលមានភ្ជាប់នូវសេចក្តីស្នើសុំ ឬដែលបង្ហាញនូវសេចក្តីត្រូវការ ដើម្បីសុំជំនួយ ឬការណែនាំខាងបច្ចេកទេស ដោយភ្ជាប់ជាមួយនូវសេចក្តីសង្កេត និងការជូនយោបល់របស់គណៈកម្មាធិការ បើមានទៅលើការស្នើសុំ ឬការបង្ហាញខាងលើនេះ។

(គ) គណៈកម្មាធិការអាចផ្តល់អនុសាសន៍ទៅមហាសន្និបាត ដើម្បីសុំឱ្យអគ្គលេខាធិការចាត់ចែងក្នុងនាមគណៈកម្មាធិការ ឱ្យមានការសិក្សាលើបញ្ហាពិសេសជាក់លាក់ពាក់ព័ន្ធនឹងសិទ្ធិកុមារ។

(ឃ) គណៈកម្មាធិការអាចធ្វើការលើកសំណើ និងផ្តល់អនុសាសន៍ទូទៅ ដោយផ្អែកលើមូលដ្ឋានព័ត៌មានដែលបានទទួល ស្របតាមមាត្រា៤៤ និងមាត្រា៤៥ នៃអនុសញ្ញានេះ។ សំណើ និងអនុសាសន៍ទូទៅទាំងនេះ ត្រូវបញ្ជូនទៅរដ្ឋភាគីពាក់ព័ន្ធ និងត្រូវរាយការណ៍ជូនមហាសន្និបាត ដោយភ្ជាប់ជាមួយនូវយោបល់របស់រដ្ឋភាគី ប្រសិនជាមាន។

## *ផ្នែកទី ៣*

### មាត្រា ៤៦

អនុសញ្ញានេះ ត្រូវបានបើកចំហឱ្យរដ្ឋទាំងអស់ចុះហត្ថលេខា។

### មាត្រា ៤៧

អនុសញ្ញានេះជាកម្មវត្ថុនៃការឱ្យសច្ចាប័ន។ លិខិតុបករណ៍នៃការឱ្យសច្ចាប័ន ត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ។

### មាត្រា ៤៨

អនុសញ្ញានេះ នៅទុកបើកចំហឱ្យរដ្ឋទាំងអស់ សុំចូលជាសមាជិក។ លិខិតុបករណ៍សុំចូលជាសមាជិក ត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ។

### មាត្រា ៤៩

១. អនុសញ្ញានេះ ត្រូវចូលជាធរមាន នៅថ្ងៃទី៣០ បន្ទាប់ពីកាលបរិច្ឆេទ នៃការតំកល់លិខិតុបករណ៍ទី២០ នៃការឱ្យសច្ចាប័ន ឬការសុំចូលជាសមាជិក នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ។

២. ចំពោះរដ្ឋនីមួយៗដែលឱ្យសច្ចាប័ន ឬសុំចូលជាសមាជិកនៃអនុសញ្ញានេះ ក្រោយពីការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬសុំចូលជាសមាជិកទី២០ អនុសញ្ញានេះ នឹងចូលជាធរមាន នៅថ្ងៃទី៣០ គិតចាប់ពីពេលដែលរដ្ឋនោះ តំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬសុំចូលជាសមាជិករបស់ខ្លួន។

### មាត្រា ៥០

១. រដ្ឋភាគីណាមួយ អាចស្នើសុំធ្វើវិសោធនកម្ម និងដាក់សេចក្តីស្នើសុំធ្វើវិសោធនកម្មនេះទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។ បន្ទាប់មក អគ្គលេខាធិការ ត្រូវបញ្ជូនសំណើធ្វើវិសោធនកម្ម ទៅរដ្ឋភាគីនានា ដោយសុំឱ្យរដ្ឋភាគីទាំងនោះ បញ្ជាក់ថាតើ គាំទ្រឱ្យមានសន្និសីទនៃរដ្ឋភាគី ដើម្បីពិនិត្យ និងបោះឆ្នោតលើសេចក្តីស្នើសុំនោះដែរឬទេ។ បើក្នុងរយៈពេល ៤ខែបន្ទាប់ពីកាលបរិច្ឆេទនៃការឆ្លើយឆ្លងមាន១ ភាគ ៣ យ៉ាងតិចនៃរដ្ឋភាគីគាំទ្រឱ្យមានសន្និសីទបែបនេះ អគ្គលេខាធិការ ត្រូវកោះធ្វើសន្និសីទ ក្រោមជំនួយឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ។ វិសោធនកម្ម ដែលអនុម័តដោយសម្លេងភាគច្រើននៃរដ្ឋភាគីវត្តមាន និងបានបោះឆ្នោតនៅក្នុងសន្និសីទ ត្រូវដាក់ជូនទៅមហាសន្និបាត ដើម្បីសុំការយល់ព្រម។

២. វិសោធនកម្មដែលបានអនុម័ត ស្របតាមកថាខណ្ឌ១ នៃមាត្រានេះ ត្រូវចូលជាធរមាននៅពេលបានទទួលការយល់ព្រមពីមហាសន្និបាតអង្គការសហប្រជាជាតិ និងទទួលបានការអនុម័តដោយសម្លេងភាគច្រើន ២ ភាគ ៣ នៃរដ្ឋភាគី។

៣. ពេលវិសោធនកម្ម ចូលជាធរមាន វិសោធនកម្មនេះ នឹងក្លាយជាកាតព្វកិច្ចសម្រាប់រដ្ឋភាគីដែលព្រមទទួលយក រដ្ឋភាគីដទៃទៀត ត្រូវស្ថិតនៅក្រោមបទ្បញ្ញត្តិនៃអនុសញ្ញានេះ និងវិសោធនកម្មលើកមុន ដែលខ្លួនបានទទួលយក។

### មាត្រា ៥១

១. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវទទួល និងផ្សព្វផ្សាយទៅកាន់រដ្ឋទាំងអស់នូវអត្ថបទនៃការដាក់លក្ខខណ្ឌរបស់រដ្ឋដែលធ្វើនៅពេលឱ្យសច្ចាប័ន ឬសុំចូលជាសមាជិក។

២. ការដាក់លក្ខខណ្ឌណាដែលវិសមភាពនឹងកម្មវត្ថុ និងគោលបំណងនៃអនុសញ្ញានេះ មិនត្រូវបានអនុញ្ញាតឡើយ។

៣. ការដាក់លក្ខខណ្ឌ អាចដកវិញបានគ្រប់ពេលវេលា ដោយការជូនដំណឹងអំពីការដកខ្លួននេះ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយបន្ទាប់មក អគ្គលេខាធិការ ត្រូវជូនដំណឹងទៅរដ្ឋទាំងអស់។ ការជូនដំណឹងនេះ មានអានុភាព ចាប់ពីកាលបរិច្ឆេទដែលអគ្គលេខាធិការបានទទួលការជូនដំណឹង។

### មាត្រា ៥២

១. រដ្ឋភាគី អាចប្រកាសដកខ្លួនចេញពីអនុសញ្ញានេះដោយការជូនដំណឹងជាលាយល័ក្ខអក្សរទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។ ការប្រកាសដកខ្លួន មានអានុភាព១ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទ ដែលអគ្គលេខាធិការបានទទួលការជូនដំណឹង។

### មាត្រា ៥៣

អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបានតែងតាំងជាអ្នកទទួលរក្សាទុកអនុសញ្ញានេះ។

### មាត្រា ៥៤

ច្បាប់ដើមនៃអនុសញ្ញានេះ ដែលមានជាភាសាអារ៉ាប់ អង់គ្លេស បារាំង ចិន រុស្ស៊ី និងអេស្ប៉ាញ៉ុល មានតម្លៃយថាភូតស្មើគ្នា និងត្រូវតំកល់ទុកនៅអគ្គលេខាធិការសហប្រជាជាតិ។

ជាបន្ទាល់នៃអនុសញ្ញានេះ អ្នកតំណាងពេញសមត្ថភាព ដែលចុះហត្ថលេខាខាងក្រោម ដោយបានទទួលនូវការអនុញ្ញាតយ៉ាងត្រឹមត្រូវ បានចុះហត្ថលេខាលើអនុសញ្ញានេះ។

# ១២_ក. ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ

ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ
កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០០
និងចូលជាធរមាននៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០២ ស្របតាមមាត្រា១០
កម្ពុជាក្លាយជារដ្ឋភាគីនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៤

*រដ្ឋភាគីនៃពិធីសារនេះ :*

*ត្រូវបានលើកទឹកចិត្ត* ដោយការគាំទ្រដ៏ច្រើនលើសលប់ចំពោះអនុសញ្ញាស្តីពីសិទ្ធិកុមារដែលបង្ហាញឱ្យឃើញនូវការប្តេជ្ញាចិត្តកាន់តែច្រើនឡើងៗក្នុងការខិតខំលើកស្ទួយ និងការពារសិទ្ធិកុមារ។

*ប្រកាសបញ្ជាក់ជាថ្មីថា* សិទ្ធិកុមារត្រូវការនូវការការពារពិសេស និង*អំពាវនាវសុំឱ្យ* បន្តលើកកំពស់ស្ថានភាពកុមារ ដោយគ្មានការប្រកាន់បែងចែក និងឱ្យមានការអភិវឌ្ឍន៍ និងការអប់រំដល់កុមារក្នុងលក្ខខណ្ឌសន្តិភាព និងសន្តិសុខ។

*ត្រូវបានរំខាន* ដោយផលប៉ះពាល់នៃជម្លោះប្រដាប់អាវុធដែលរាលដាល និងធ្វើឱ្យខូចខាតដល់កុមារ និងដោយផលវិបាករយៈពេលវែង សម្រាប់សន្តិភាព សន្តិសុខ និងការអភិវឌ្ឍន៍ស្ថិតស្ថេរ។

*ផ្តន្ទាទោស* ចំពោះការដាក់កុមារជាមុខសញ្ញា ក្នុងស្ថានភាពនៃជម្លោះប្រដាប់អាវុធ និងការវាយប្រហារដោយផ្ទាល់ ទៅលើវត្ថុដែលត្រូវទទួលបានការការពារក្រោមច្បាប់អន្តរជាតិ រាប់ទាំងទីកន្លែងដែលជាទូទៅមានវត្តមានកុមារ មានជាអាទិ៍ សាលារៀន និងមន្ទីរពេទ្យ។

*កត់សំគាល់* ការអនុម័តលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការឧក្រិដ្ឋកម្មអន្តរជាតិ និងជាពិសេសការរាប់បញ្ចូលជាបទឧក្រិដ្ឋសង្គ្រាម នៅក្នុងលក្ខន្តិកៈនូវការកេណ្ឌ ឬចុះបញ្ជី ជ្រើសរើសកុមារក្រោមអាយុ១៥ឆ្នាំ ឱ្យធ្វើទាហាន ឬឱ្យចូលរួមយ៉ាងសកម្មក្នុងអរិភាព ក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិ និងមិនមែនអន្តរជាតិ។

*យល់ឃើញថា* ដើម្បីពង្រឹងបន្ថែមនូវការអនុវត្តសិទ្ធិ ដែលទទួលស្គាល់ក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ គឺចាំបាច់ត្រូវបង្កើនការការពារកុមារ មិនឱ្យចូលពាក់ព័ន្ធក្នុងជម្លោះប្រដាប់អាវុធ។

*កត់សំគាល់ឃើញថា* មាត្រា១ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ បញ្ជាក់ច្បាស់លាស់ថា សម្រាប់គោលបំណងនៃអនុសញ្ញានេះ កុមារគឺជាមនុស្សមានអាយុក្រោម១៨ឆ្នាំ លើកលែងតែច្បាប់ដែលអនុវត្តចំពោះកុមារ កំណត់អំពីនីតិភាពទាបជាងនេះ។

*ជឿជាក់ថា* ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលតម្លើងអាយុបុគ្គល ដែលអាចជ្រើសរើសឱ្យចូលបម្រើក្នុងកងកម្លាំងប្រដាប់អាវុធ និងចូលរួមក្នុងអរិភាព នឹងរួមចំណែកយ៉ាងមានប្រសិទ្ធភាព ដល់ការអនុវត្តគោលការណ៍ ដែលត្រូវគិតគូរជាចម្បងដល់ឧត្តមប្រយោជន៍របស់កុមារ នៅគ្រប់សកម្មភាពដែលពាក់ព័ន្ធនឹងកុមារ។

*កត់សំគាល់ឃើញថា* សន្និសីទអន្តរជាតិលើកទី២៦ នៃកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម ក្នុងខែធ្នូ ឆ្នាំ១៩៩៥ បានធ្វើអនុសាសន៍ ដែលមានជាអាទិ៍ថា ភាគីនៃជម្លោះ ត្រូវចាត់វាល់វិធានការដែលអាចធ្វើទៅបាន ដើម្បីធានាមិនឱ្យកុមារអាយុក្រោម ១៨ឆ្នាំ ចូលរួមក្នុងអរិភាព។

*ស្វាគមន៍* ការអនុម័តជាឯកច្ឆ័ន្ទក្នុងខែមិថុនា ឆ្នាំ១៩៩៩ ដោយអង្គការពលកម្មអន្តរជាតិ(ILO) នូវអនុសញ្ញាលេខ១៨២ ស្តីពីការហាមប្រាម និងការចាត់វិធានការបន្ទាន់ ដើម្បីលប់បំបាត់ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ ដែលមានជាអាទិ៍ ការហាមឃាត់ការជ្រើសរើសកុមារដោយការបង្ខិតបង្ខំ ឬជាកាតព្វកិច្ច ដើម្បីប្រើប្រាស់ក្នុងជម្លោះប្រដាប់អាវុធ។

*ថ្កោលទោសយ៉ាងធ្ងន់ធ្ងរបំផុត* ចំពោះការជ្រើសរើស ការហ្វឹកហ្វឺន និងការប្រើប្រាស់កុមារក្នុងដែនដីជាតិ ឬឆ្លងដែនដីជាតិនៅក្នុងអរិភាព ដោយក្រុមប្រដាប់អាវុធ ផ្សេងពីកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋ និង*ទទួលស្គាល់* ការទទួលខុសត្រូវរបស់ជនដែលជ្រើសរើស ហ្វឹកហ្វឺន និងប្រើប្រាស់កុមារនៅក្នុងគោលដៅខាងលើនេះ។

*រំលឹកឡើងវិញ* អំពីកាតព្វកិច្ចរបស់ភាគីនីមួយៗនៃជម្លោះប្រដាប់អាវុធ ក្នុងការអនុវត្តបទប្បញ្ញត្តិនៃច្បាប់មនុស្សធម៌អន្តរជាតិ។

*សង្កត់ធ្ងន់ថា* ពិធីសារនេះមិនប៉ះពាល់ដល់គោលបំណង និងគោលការណ៍ដូចមានកំណត់ក្នុងធម្មនុញ្ញសហប្រជាជាតិរួមមានមាត្រា៥១ផង និងបទដ្ឋាននានានៃច្បាប់មនុស្សធម៌អន្តរជាតិឡើយ។

*ចងចាំថា* លក្ខខណ្ឌសន្តិភាព និងសន្តិសុខ ដែលផ្អែកលើការគោរពទាំងស្រុង នូវគោលបំណង និងគោលការណ៍ ដូចបានកំណត់ក្នុងធម្មនុញ្ញសហប្រជាជាតិ និង *ចងចាំថា* ការប្រតិបត្តិតាមលិខិតុបករណ៍សិទ្ធិមនុស្សជាធរមាន គឺមិនអាចខ្វះបានឡើយ ដើម្បីការពារកុមារឱ្យបានទាំងស្រុង ជាពិសេស អំឡុងពេលមានជម្លោះប្រដាប់អាវុធ និងការកាន់កាប់ដោយបរទេស។

*ទទួលស្គាល់* សេចក្តីត្រូវការពិសេសរបស់កុមារដែលជាពិសេសងាយទទួលរងគ្រោះដោយសារការជ្រើសរើស ឬប្រើប្រាស់នៅក្នុងអរិភាព ផ្ទុយនឹងពិធីសារនេះ ដោយហេតុមកពីស្ថានភាពសេដ្ឋកិច្ច ឬស្ថានភាពសង្គម ឬភេទ។

*កត់សំគាល់អំពី* ភាពចាំបាច់ ដើម្បីពិនិត្យពិចារណារកមូលហេតុ ជាឫសគល់ខាងសេដ្ឋកិច្ច សង្គមកិច្ច និងនយោបាយ ក្នុងការធ្វើឱ្យកុមារពាក់ព័ន្ធក្នុងជម្លោះប្រដាប់អាវុធ។

*មានជំនឿ* លើភាពចាំបាច់ដើម្បីពង្រឹងសហប្រតិបត្តិការអន្តរជាតិ ក្នុងការអនុវត្តពិធីសារនេះ ព្រមទាំងការស្តារសម្បទាខាងផ្លូវកាយ និងផ្លូវចិត្ត និងការធ្វើសមាហរណកម្មកុមាររងគ្រោះនៃជម្លោះប្រដាប់អាវុធ ទៅក្នុងសង្គម។

*លើកទឹកចិត្ត* ដល់ការចូលរួមរបស់សហគមន៍ ជាពិសេសកុមារ និងកុមាររងគ្រោះ ក្នុងការផ្សព្វផ្សាយកម្មវិធីអប់រំ និងកម្មវិធីព័ត៌មានស្តីពីការអនុវត្តពិធីសារនេះ។

*បានព្រមព្រៀងគ្នាដូចតទៅ :*

### មាត្រា ១

រដ្ឋភាគី ត្រូវចាត់វាល់វិធានការទាំងអស់ តាមដែលអាចធ្វើបាន ដើម្បីធានាថា សមាជិកកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន ដែលអាយុមិនគ្រប់១៨ឆ្នាំ មិនចូលរួមដោយផ្ទាល់ក្នុងអរិភាពឡើយ។

### មាត្រា ២

រដ្ឋភាគី ត្រូវធានាថា បុគ្គលមិនគ្រប់អាយុ១៨ឆ្នាំ មិនត្រូវបានជ្រើសរើសឱ្យចូលក្នុងកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋជាដាច់ខាត។

មាត្រា ៣

១. រដ្ឋភាគី ត្រូវតំឡើងអាយុអប្បបរមា សម្រាប់ការជ្រើសរើសអ្នកស្ម័គ្រចិត្តចូលបម្រើកងកម្លាំងប្រដាប់អាវុធជាតិរបស់ខ្លួន ឱ្យខ្ពស់ជាងអាយុដែលមានចែងក្នុងកថាខណ្ឌទី៣ នៃមាត្រា៣៨ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ដោយគិតដល់គោលការណ៍ដែលមានកំណត់ក្នុងមាត្រានោះ និងដោយទទួលស្គាល់ថា យោងតាមអនុសញ្ញានោះ បុគ្គលដែលមានអាយុក្រោម ១៨ឆ្នាំ មានសិទ្ធិទទួលបាននូវការការពារពិសេស។

២. រដ្ឋភាគីនីមួយៗនៅពេលឱ្យសច្ចាប័ន ឬសុំចូលជាសមាជិកនៃពិធីសារនេះ ត្រូវតំកល់សេចក្តីប្រកាសខ្ជាប់មួយ ស្តីពីការកំណត់អាយុអប្បបរមា ដែលអនុញ្ញាតឱ្យជ្រើសរើសដោយស្ម័គ្រចិត្ត ចូលបម្រើក្នុងកងកម្លាំងប្រដាប់អាវុធជាតិរបស់ខ្លួន និងត្រូវតំកល់សេចក្តីពណ៌នាពីវិធានការការពារដែលរដ្ឋភាគីបានអនុម័ត ដើម្បីធានាថា មិនមានការជ្រើសរើសដោយបង្ខិតបង្ខំ ឬដោយប្រើកំលាំង។

៣. រដ្ឋភាគី ដែលអនុញ្ញាតឱ្យជ្រើសរើសបុគ្គល មានអាយុក្រោម ១៨ឆ្នាំ ឱ្យចូលបម្រើដោយស្ម័គ្រចិត្តក្នុងកងកម្លាំងប្រដាប់អាវុធជាតិរបស់ខ្លួន ត្រូវធានាឱ្យបានជាអប្បបរមាថា :

(ក) ការជ្រើសរើស ធ្វើតាមការស្ម័គ្រចិត្តពិតប្រាកដ។

(ខ) ការជ្រើសរើសធ្វើឡើងដោយមានការយល់ព្រមពីឪពុក-ម្តាយ ឬអ្នកអាណាព្យាបាលស្របច្បាប់របស់ជននោះ បន្ទាប់ពីបានទទួលដំណឹងពីផលប៉ះពាល់នានា។

(គ) បុគ្គលនោះ ត្រូវទទួលបានព័ត៌មានពេញលេញស្តីពីករណីយកិច្ចចូលរួមបម្រើកងទ័ព។

(ឃ) បុគ្គលនោះ ត្រូវផ្តល់ភស្តុតាងសមស្របអំពីអាយុរបស់ខ្លួន មុនទទួលឱ្យចូលបម្រើកងទ័ពជាតិ។

៤. រដ្ឋភាគីនីមួយៗ អាចពង្រឹងសេចក្តីប្រកាសរបស់ខ្លួនបានគ្រប់ពេល ដោយជូនដំណឹងអំពីកិច្ចការនេះ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយអគ្គលេខាធិការ ត្រូវជូនដំណឹងអំពីការពង្រឹងនេះ ទៅរដ្ឋភាគីទាំងអស់។ ការជូនដំណឹងនេះ មានអនុភាពចាប់ពីកាលបរិច្ឆេទដែលអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបាននូវសេចក្តីជូនដំណឹងនោះ។

៥. ការតម្រូវឱ្យតំឡើងអាយុក្នុងកថាខ័ណ្ឌទី១ នៃមាត្រានេះ មិនអនុវត្តចំពោះសាលារៀន ដែលដំណើរការ ឬត្រួតពិនិត្យដោយកងកម្លាំងប្រដាប់អាវុធនៃរដ្ឋភាគីឡើយ ដោយប្រកាន់ខ្ជាប់តាមមាត្រា២៨ និងមាត្រា២៩ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

មាត្រា ៤

១. ក្រុមប្រដាប់អាវុធ ក្រៅពីកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋ ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយ មិនត្រូវជ្រើសរើស ឬប្រើប្រាស់បុគ្គលអាយុក្រោម ១៨ឆ្នាំ ក្នុងអរិភាពឡើយ។

២. រដ្ឋភាគី ត្រូវចាត់វាល់វិធានការតាមដែលអាចធ្វើបាន ដើម្បីទប់ស្កាត់ការជ្រើសរើស និងការប្រើបែបនេះ រួមមានការអនុម័តវិធានការច្បាប់ដែលចាំបាច់ ដើម្បីហាមឃាត់ និងដាក់ជាបទព្រហ្មទណ្ឌចំពោះការប្រព្រឹត្តបែបនេះ។

៣. ការអនុវត្តមាត្រានេះ មិនប៉ះពាល់ឋានៈខាងផ្លូវច្បាប់នៃភាគីណាមួយ ក្នុងជម្លោះប្រដាប់អាវុធឡើយ។

មាត្រា ៥

គ្មានបទប្បញ្ញត្តិណាមួយឡើយនៃពិធីសារនេះ អាចយកមកបកស្រាយថា ជាការរារាំងដល់ការអនុវត្តបទប្បញ្ញត្តិនៃច្បាប់របស់រដ្ឋភាគី ឬលិខិតុបករណ៍អន្តរជាតិ និងច្បាប់មនុស្សធម៌អន្តរជាតិ ដែលអាចមានប្រយោជន៍ប្រសើរជាងនេះ ក្នុងការធ្វើឱ្យសម្រេចបាននូវសិទ្ធិកុមារ។

មាត្រា ៦

១. រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការចាំបាច់តាមផ្លូវច្បាប់ តាមផ្លូវរដ្ឋបាល និងវិធានការផ្សេងៗទៀត ដើម្បីធានាដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាព នូវបទប្បញ្ញត្តិនៃពិធីសារនេះ ក្នុងយុត្តាធិការរបស់ខ្លួន។

២. រដ្ឋភាគីរ៉ាប់រងផ្សព្វផ្សាយគោលការណ៍ និងបទប្បញ្ញត្តិនៃពិធីសារនេះដល់មនុស្សពេញវ័យ និងកុមារឱ្យបានយល់ដឹងទូលំទូលាយ និងជំរុញឱ្យអ្នកទាំងនោះអនុវត្តតាមមធ្យោបាយសមស្របនានា។

៣. រដ្ឋភាគី ត្រូវចាត់រាល់វិធានការដែលអាចធ្វើបាន ដើម្បីធានាថា បុគ្គលរស់នៅក្នុងយុត្តាធិការរបស់ខ្លួនដែលបានជ្រើសរើស ឬប្រើក្នុងអរិភាពដែលផ្ទុយពីខ្លឹមសារនៃពិធីសារនេះ ត្រូវបានរំសាយ ឬឱ្យរួចផុតពីការបម្រើទ័ព។ ករណីចាំបាច់ រដ្ឋភាគីត្រូវផ្តល់ជំនួយឧបត្ថម្ភសមស្របដល់អ្នកទាំងនោះ ដើម្បីស្តារសម្បទាខាងផ្លូវកាយ និងផ្លូវចិត្ត និងធ្វើសមាហរណកម្មទៅក្នុងសង្គម។

មាត្រា ៧

១. រដ្ឋភាគី ត្រូវធ្វើសហប្រតិបត្តិការជាមួយគ្នាដែលក្នុងនោះ រួមមាន សហប្រតិបត្តិការបច្ចេកទេស និងជំនួយឧបត្ថម្ភខាងហិរញ្ញវត្ថុផងក្នុងការអនុវត្តពិធីសារនេះ ក្នុងនោះមានការបង្ការសកម្មភាពផ្ទុយពីពិធីសារនេះ និងការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មក្នុងសង្គម នូវជនរងគ្រោះពីអំពើផ្ទុយពីពិធីសារនេះ។ ជំនួយឧបត្ថម្ភ និងសហប្រតិបត្តិការនេះ នឹងត្រូវអនុម័តតាមរយៈការពិគ្រោះយោបល់ជាមួយរដ្ឋភាគី និងអង្គការអន្តរជាតិពាក់ព័ន្ធ។

២. រដ្ឋភាគីដែលស្ថិតក្នុងនាទីផ្តល់ជំនួយឧបត្ថម្ភ ត្រូវផ្តល់ជំនួយនេះតាមរយៈកម្មវិធីពហុភាគីទ្វេភាគី ឬកម្មវិធីផ្សេងទៀតដែលមានស្រាប់ ឬពុំនោះទេ តាមរយៈមូលនិធិនៃវិភាគទានស្ម័គ្រចិត្តដែលបង្កើតស្របតាមបែបបទនៃមហាសន្និបាតអង្គការសហប្រជាជាតិជាអាទិ៍។

មាត្រា ៨

១. រដ្ឋភាគីនីមួយៗ ក្នុងរយៈពេល ២ឆ្នាំ ក្រោយពីពិធីសារនេះចូលជា ធរមានចំពោះខ្លួនត្រូវដាក់របាយការណ៍មួយ ជូនគណៈកម្មាធិការសិទ្ធិកុមារ ដោយផ្តល់ព័ត៌មានលំអិតស្តីពីវិធានការរបស់រដ្ឋភាគី ក្នុងការអនុវត្តបទប្បញ្ញត្តិនៃពិធីសារនេះ រួមមាន វិធានការអនុវត្តបទប្បញ្ញត្តិស្តីពីការចូលបម្រើទ័ព និងការជ្រើសរើសទ័ពផង។

២. បន្ទាប់ពីដាក់របាយការណ៍លំអិត រដ្ឋភាគីនីមួយៗត្រូវបញ្ចូលព័ត៌មានបន្ថែមស្តីពីការអនុវត្តពិធីសារនេះ ក្នុងរបាយការណ៍ ជូនទៅគណៈកម្មាធិការសិទ្ធិកុមារ ដូចមានចែងក្នុងមាត្រា៤៤ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។ រដ្ឋភាគីឯទៀតនៃពិធីសារនេះ ត្រូវដាក់របាយការណ៍រៀងរាល់៥ឆ្នាំម្តង។

៣. គណៈកម្មាធិការសិទ្ធិកុមារ អាចស្នើសុំឱ្យរដ្ឋភាគីផ្តល់ព័ត៌មានបន្ថែម ទាក់ទងនឹងការអនុវត្តពិធីសារនេះ។

### មាត្រា ៩

១. ពិធីសារនេះ បើកចំហឱ្យចុះហត្ថលេខា សម្រាប់រដ្ឋដែលជាភាគីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ឬដែលបានចុះហត្ថលេខាលើអនុសញ្ញាស្តីពីសិទ្ធិកុមារ។

២. ពិធីសារនេះ ជាកម្មវត្ថុនៃការឱ្យសច្ចាប័ន និងបើកចំហឱ្យរដ្ឋ សុំចូលជាសមាជិក។ លិខិតុបករណ៍ឱ្យសច្ចាប័ន ឬសុំចូលជាសមាជិក ត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ។

៣. អគ្គលេខាធិការអង្គការសហប្រជាជាតិ ក្នុងឋានៈជាអ្នកទទួលទុកអនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារ ត្រូវជូនដំណឹងដល់រដ្ឋភាគីទាំងអស់ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ និងរដ្ឋទាំងអស់ ដែលបានចុះហត្ថលេខាលើអនុសញ្ញាស្តីពីសិទ្ធិកុមារ អំពីលិខិតុបករណ៍នៃសេចក្តីប្រកាសនីមួយៗ ស្របតាមមាត្រា៣។

### មាត្រា ១០

១. ពិធីសារនេះ ចូលជាធរមាន ក្នុងរយៈពេល៣ខែ បន្ទាប់ពីកាលបរិច្ឆេទ នៃការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬសុំចូលជាសមាជិកទី១០។

២. ចំពោះរដ្ឋនីមួយៗដែលឱ្យសច្ចាប័ន ឬសុំចូលជាសមាជិក បន្ទាប់ពីពិធីសារនេះចូលជាធរមាន ពិធីសារនេះត្រូវចូលជាធរមានក្នុងរយៈពេល១ខែ បន្ទាប់ពីកាលបរិច្ឆេទ នៃការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬសុំចូលជាសមាជិករបស់រដ្ឋនោះ។

### មាត្រា ១១

១. រដ្ឋភាគី អាចប្រកាសដកខ្លួនចេញពីពិធីសារនេះបានគ្រប់ពេល ដោយការជូនដំណឹងជាលាយល័ក្ខអក្សរ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយអគ្គលេខាធិការត្រូវជូនដំណឹងពីការប្រកាសដកខ្លួននេះ ទៅរដ្ឋភាគីផ្សេងទៀត នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ និងរដ្ឋទាំងអស់ដែលបានចុះហត្ថលេខាលើអនុសញ្ញាស្តីពីសិទ្ធិកុមារ។ ការប្រកាសដកខ្លួន មានអនុភាពក្នុងរយៈពេល ១ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទដែលអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបានការជូនដំណឹង។ ប៉ុន្តែបើផុតកំណត់រយៈពេល១ឆ្នាំនេះ រដ្ឋភាគីដែលប្រកាសដកខ្លួននោះ ជាប់ពាក់ព័ន្ធក្នុងជម្លោះប្រដាប់អាវុធនោះ ការប្រកាសរំសាយនេះ មិនចូលជាធរមានមុនចប់ជម្លោះប្រដាប់អាវុធឡើយ។

២. ការប្រកាសដកខ្លួននេះ ពុំមានអានុភាពឱ្យរដ្ឋភាគីរួចផុតពីកាតព្វកិច្ចរបស់ខ្លួន ក្រោមពិធីសារនេះ ចំពោះបទល្មើសណាដែលកើតមុនកាលបរិច្ឆេទនៃការប្រកាសដកខ្លួន ចូលជាធរមានឡើយ។ ទោះតាមមធ្យោបាយណាក៏ដោយ ការប្រកាសដកខ្លួននេះ មិនប៉ះពាល់ដល់ការបន្តពិនិត្យបញ្ហាទាំងឡាយ ដែលគណៈកម្មាធិការសិទ្ធិកុមារ កំពុងពិនិត្យ មុនកាលបរិច្ឆេទប្រកាសដកខ្លួនចូលជាធរមានឡើយ។

មាត្រា ១២

១. រដ្ឋភាគី អាចសុំធ្វើវិសោធនកម្ម និងដាក់សេចក្តីស្នើសុំនេះជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ។ អគ្គលេខាធិការ ត្រូវបញ្ជូនសេចក្តីស្នើវិសោធនកម្មទៅរដ្ឋភាគី ដោយស្នើសុំឱ្យរដ្ឋភាគីបញ្ជាក់ថាតើ រដ្ឋភាគីយល់ព្រម ឱ្យមានសន្និសីទនៃរដ្ឋភាគីទាំងអស់ ដើម្បីពិនិត្យ និងបោះឆ្នោតលើសេចក្តីស្នើសុំឬទេ។ ក្នុងរយៈពេល៤ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការឆ្លើយឆ្លងនោះ ក្នុងករណីមានសំឡេង១ភាគ៣យ៉ាងតិចនៃរដ្ឋភាគី គាំទ្រឱ្យមានសន្និសីទបែបនេះ អគ្គលេខាធិការត្រូវកោះធ្វើសន្និសីទ ក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ។ វិសោធនកម្ម ដែលបានអនុម័តដោយមតិភាគច្រើននៃរដ្ឋភាគីវត្តមាន និងបានបោះឆ្នោតក្នុងសន្និសីទ ត្រូវដាក់ជូនមហាសន្និបាតសហប្រជាជាតិ ដើម្បីសុំការយល់ព្រម។

២. វិសោធនកម្មដែលបានអនុម័ត ស្របតាមកថាខណ្ឌទី១ នៃមាត្រានេះ ត្រូវចូលជាធរមាននៅពេលវិសោធនកម្មនេះ ទទួលបានការយល់ព្រមពីមហាសន្និបាត និងបានទទួលយក ដោយមតិភាគច្រើន ២ភាគ៣ នៃរដ្ឋភាគី។

៣. នៅពេលវិសោធនកម្មចូលជាធរមានហើយ វិសោធនកម្មនោះ នឹងក្លាយជាកាតព្វកិច្ចសម្រាប់រដ្ឋភាគីដែលយល់ព្រមទទួលយកវិសោធនកម្មនោះ រដ្ឋភាគីក្រៅពីនេះ នៅតែជាប់កាតព្វកិច្ចចំពោះបទប្បញ្ញត្តិនៃពិធីសារនេះ និងវិសោធនកម្មមុនៗដែលរដ្ឋភាគីនោះបានយល់ព្រមទទួលយក។

មាត្រា ១៣

១. ពិធីសារនេះដែលមានអត្ថបទជាភាសាអារ៉ាប់ អង់គ្លេស បារាំង ចិន រុស្ស៊ី និងអេស្ប៉ាញ៉ុល មានតម្លៃយថាភូតស្មើគ្នា និងត្រូវដកល់ទុកនៅបណ្ណសារដ្ឋាននៃអង្គការសហប្រជាជាតិ។

២. អគ្គលេខាធិការសហប្រជាជាតិត្រូវបញ្ជូនសេចក្តីចម្លងនៃពិធីសារនេះ ដោយមានបញ្ជាក់ការចម្លងស្របតាមច្បាប់ដើម ជូនរដ្ឋភាគីទាំងអស់នៃអនុសញ្ញា និងរដ្ឋទាំងអស់ដែលបានចុះហត្ថលេខាលើអនុសញ្ញាស្តីពីសិទ្ធិកុមារ។

## ១២-ខ. ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារពាក់ព័ន្ធនឹងការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសកុមារ

ត្រូវបានអនុម័តដោយមហាសន្និបាតនៃអង្គការសហប្រជាជាតិ កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០០
និងចូលជាធរមាននៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០០២ ស្របតាមមាត្រា១៤
កម្ពុជាក្លាយជារដ្ឋភាគីនៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០២

*រដ្ឋភាគីនៃពិធីសារនេះ*

*យល់ឃើញថា* ដើម្បីធ្វើឱ្យសម្រេចគោលបំណងនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ *និង*ការអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ពិសេសមាត្រា១ មាត្រា១១ មាត្រា២១ មាត្រា៣២ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ និងមាត្រា៣៦ ឱ្យកាន់តែបានច្រើនការពង្រីកវិធានការ គឺជាការសមស្របនឹងការសន្យារបស់រដ្ឋភាគី ដើម្បីធានាការពារកុមារប្រឆាំងនឹងការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសកុមារ។

*យល់ឃើញផងដែរថា* អនុសញ្ញាស្តីពីសិទ្ធិកុមារទទួលស្គាល់សិទ្ធិកុមារ ទទួលការការពារប្រឆាំងនឹងការកេងប្រវ័ញ្ចសេដ្ឋកិច្ច និងការឱ្យធ្វើការងារដែលគ្រោះថ្នាក់ ឬការងារដែលប៉ះពាល់ដល់ការសិក្សារបស់កុមារ ឬធ្វើឱ្យខូចសុខភាពកុមារ ឬការអភិវឌ្ឍន៍ខាងផ្លូវកាយ ផ្លូវចិត្ត ស្មារតី សីលធម៌ ឬសង្គម។

*មានកង្វល់យ៉ាងខ្លាំង* ចំពោះកំណើនច្រើនឡើងគួរឱ្យកត់សំគាល់នៃការជួញដូរកុមារជាអន្តរជាតិ ដើម្បីលក់កុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសកុមារ។

*មានការបារម្ភយ៉ាងជ្រាលជ្រៅ* ចំពោះការអនុវត្តយ៉ាងរីករាលដាល និងជាបន្តនៃទេសចរណ៍ផ្លូវភេទដែលកុមារងាយរងគ្រោះច្រើនជាងគេដោយហេតុថា ទេសចរណ៍ផ្លូវភេទជំរុញដោយផ្ទាល់ឱ្យមានការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសកុមារ។

*ទទួលស្គាល់ថា* ក្រុមជាច្រើនដែលងាយរងគ្រោះជាពិសេស ដែលក្នុងនោះរួមមានកុមារី គឺស្ថិតក្នុងចំណុចគ្រោះថ្នាក់នៃការកេងប្រវ័ញ្ចផ្លូវភេទខ្លាំងជាងគេ និង*ទទួលស្គាល់ថា* កុមារីស្ថិតក្នុងតួលេខខ្ពស់ហួសហេតុ ក្នុងចំណោមអ្នករងគ្រោះនៃការកេងប្រវ័ញ្ចផ្លូវភេទ។

*មានកង្វល់* ចំពោះភាពងាយរកបានច្រើនឡើងនៃរូបភាពអាសអាភាសកុមារតាមអ៊ីនធឺណែត និងបច្ចេកវិទ្យាផ្សេងទៀតដែលកំពុងវិវត្ត និង*រំលឹកឡើងវិញ* អំពីសន្និសីទអន្តរជាតិ ធ្វើនៅទីក្រុងវីយែន ក្នុងឆ្នាំ១៩៩៩ ស្ដីពីការប្រយុទ្ធប្រឆាំងនឹងការផ្សព្វផ្សាយរូបភាពអាសអាភាសកុមារ តាមអ៊ីនធឺណែត ជាពិសេស សេចក្តីសន្និដ្ឋាននៃសន្និសីទនេះ អំពាវនាវឱ្យពិភពលោកទាំងមូល ដាក់ជាបទឧក្រិដ្ឋចំពោះការផលិត ការចែកចាយ ការនាំចេញ ការបញ្ជូន ការនាំចូល ការកាន់កាប់ដោយចេតនា និងការផ្សព្វផ្សាយរូបភាពអាសអាភាសកុមារ និងសង្កត់ធ្ងន់លើសារសំខាន់នៃកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូរជិតស្និទ្ធ រវាងរដ្ឋាភិបាល និងឧស្សាហកម្មអ៊ីនធឺណែត។

*ជឿជាក់ថា* ការលប់បំបាត់ការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសកុមារ នឹងត្រូវបានសម្រួលតាមរយៈការអនុម័តយកវិធីសាស្ត្រចម្រុះផ្នែកព្រមគ្នា ដោយដោះស្រាយកត្តារួមចំណែក មានជាអាទិ៍ ភាពខ្វះខាតខាងសេដ្ឋកិច្ច រចនាសម្ព័ន្ធខាងសង្គម និងសេដ្ឋកិច្ច ដែលមានវិសមធម៌ ភាពមិនប្រក្រតីនៃគ្រួសារ កង្វះខាតខាងការអប់រំ ការផ្លាស់ទីលំនៅពីជនបទមកទីក្រុង ការរើសអើងភេទ ការប្រព្រឹត្តខាងផ្លូវភេទរបស់មនុស្សពេញវ័យដែលគ្មានការទទួលខុសត្រូវ ការអនុវត្តជាទម្លាប់ប្រកបដោយគ្រោះថ្នាក់ ជម្លោះប្រដាប់អាវុធ និងការជួញដូរកុមារ។

*ជឿជាក់ផងដែរថា* ការខិតខំលើកកំពស់ការយល់ដឹងជាសាធារណៈ គឺជាការចាំបាច់ ដើម្បីកាត់បន្ថយតម្រូវការរបស់អតិថិជន ចំពោះការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសកុមារ និង*មានជំនឿ* លើសារសំខាន់នៃការពង្រឹងភាពជាដៃគូនៅទូទាំងពិភពលោកជាមួយតួអង្គទាំងអស់ និងការលើកកំពស់ការអនុវត្តច្បាប់ថ្នាក់ជាតិ។

*កត់សំគាល់* បទប្បញ្ញត្តិនៃលិខិតុបករណ៍គតិយុត្តិអន្តរជាតិពាក់ព័ន្ធនឹងការការពារកុមារ រួមមានអនុសញ្ញាក្រុងឡាអេស្ដីពីការការពារកុមារ និងសហប្រតិបត្តិការសុំកូនអន្តរប្រទេស អនុសញ្ញាក្រុងឡាអេស្ដីពីទិដ្ឋភាពរដ្ឋប្បវេណីនៃការចាប់ពង្រត់កុមារជាលក្ខណៈអន្តរជាតិ អនុសញ្ញាក្រុងឡាអេ ស្ដីពីដែនសមត្ថកិច្ចច្បាប់ដែលអាចអនុវត្តបាន ការទទួលស្គាល់ ការអនុវត្ត និងសហប្រតិបត្តិការលើការទទួលខុសត្រូវរបស់ឪពុក-ម្ដាយ និងវិធានការសម្រាប់ការពារកុមារ និងអនុសញ្ញាលេខ ១៨២ របស់អង្គការពលកម្មអន្តរជាតិស្ដីពីការហាមឃាត់ និងវិធានការបន្ទាន់ដើម្បីលប់បំបាត់ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ។

*បានទទួលការលើកទឹកចិត្ត* ដោយការគាំទ្រដ៏ច្រើនលើសលប់ លើអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលបញ្ជាក់ឱ្យឃើញនូវការប្តេជ្ញាកាន់តែទូលំទូលាយ ក្នុងការលើកស្ទួយ និងការពារសិទ្ធិកុមារ។

*ទទួលស្គាល់* សារៈប្រយោជន៍នៃការអនុវត្តបទប្បញ្ញត្តិនៃកម្មវិធីសកម្មភាព ដើម្បីបង្ការការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសកុមារ និងសេចក្តីប្រកាស និងកម្មវិធីសកម្មភាពដែលបានអនុម័ត ក្នុងសមាជពិភពលោកប្រឆាំងនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារក្នុងគោលដៅពាណិជ្ជកម្ម ធ្វើនៅទីក្រុងស្តុកខុម ពីថ្ងៃទី២៧ ដល់៣១ ខែសីហា ឆ្នាំ១៩៩៦ និងសេចក្តីសម្រេច និងអនុសាសន៍សមស្របផ្សេងទៀត របស់អង្គការអន្តរជាតិដែលពាក់ព័ន្ធ។

*គិតគូរ* អំពីសារៈសំខាន់នៃប្រពៃណី និងតម្លៃខាងវប្បធម៌របស់ប្រជាពលរដ្ឋម្នាក់ៗ ក្នុងការការពារកុមារ និងក្នុងការធ្វើឱ្យកុមារមានការរីកចម្រើនដោយសុខដុម។

*បានព្រមព្រៀងគ្នាដូចតទៅ :*

## មាត្រា ១

រដ្ឋភាគី ត្រូវហាមឃាត់ការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសកុមារ ដូចបានកំណត់ដោយពិធីសារនេះ។

## មាត្រា ២

សម្រាប់គោលបំណងនៃពិធីសារនេះ :

(ក) ការលក់កុមារ គឺជាអំពើ ឬកិច្ចការជំនួញរបស់មនុស្សណាម្នាក់ ឬក្រុមមនុស្សណាមួយ ដើម្បីផ្ទេរកុមារទៅមនុស្សម្នាក់ទៀត ឬក្រុមមនុស្សមួយទៀត បំណងយកកម្រៃ ឬអត្ថប្រយោជន៍ផ្សេងទៀត។

(ខ) ពេស្យាកម្មកុមារ គឺជាការប្រើប្រាស់កុមារក្នុងសកម្មភាពផ្លូវភេទ បំណងយកកម្រៃ ឬអត្ថប្រយោជន៍តាមទម្រង់ផ្សេងៗ។

(គ) រូបភាពឬសម្ភារៈអាសអាភាសកុមារ គឺជាការបង្ហាញទាំងឡាយ ទោះតាមមធ្យោបាយអ្វីក៏ដោយ អំពីសកម្មភាពរួមភេទជារូបពិត ឬដោយការចម្លងរូបភាពពិត ឬការបង្ហាញអវយវៈភេទរបស់កុមារ សម្រាប់គោលបំណងចម្បងខាងផ្លូវភេទ។

### មាត្រា ៣

១. រដ្ឋភាគីនីមួយៗត្រូវធានាជាអប្បបរមាថា អំពើ និងសកម្មភាពខាងក្រោមនេះ ត្រូវទទួលការផ្តន្ទាទោសយ៉ាងពេញលេញ ក្រោមច្បាប់ព្រហ្មទណ្ឌរបស់ខ្លួន ទោះជាបទល្មើសទាំងនោះត្រូវបានប្រព្រឹត្តនៅក្នុងប្រទេសឬឆ្លងប្រទេស ឬជាលក្ខណៈបុគ្គល ឬជាលក្ខណៈចាត់តាំងក៏ដោយៈ

(ក) ក្នុងបរិបទស្តីពីការលក់កុមារ ដូចបានកំណត់ក្នុងមាត្រា២ :

(i) រាល់ការប្រគល់ ការបញ្ជូន ឬការយកកុមារ ទោះតាមមធ្យោបាយណាក៏ដោយ ក្នុងបំណងៈ

ក. ធ្វើអាជីវកម្មខាងផ្លូវភេទលើកុមារ

ខ. ផ្ទេរសរីរាង្គកុមារ ដើម្បីយកកម្រៃ

គ. ដាក់កុមារឱ្យធ្វើការងារដោយបង្ខំ

(ii) ការអូសទាញឱ្យយល់ព្រមលើសុំកូនដោយមិនត្រឹមត្រូវ ក្នុងនាមជាអន្តរការី ដោយរំលោភលើលិខិតុបករណ៍គតិយុត្តិអន្តរជាតិ ស្តីពីការសុំកូន ដែលកំពុងអនុវត្ត។

(ខ) ការឱ្យ ការទទួល ការធ្វើសញ្ជារកម្ម ឬការផ្គត់ផ្គង់កុមារសម្រាប់ពេស្យាកម្មកុមារ ដូចបានកំណត់ក្នុងមាត្រា២ ។

(គ) ការផលិត ការចែកចាយ ការផ្សព្វផ្សាយ ការនាំចូល ការនាំចេញ ការឱ្យ ការលក់ ឬការកាន់កាប់សម្រាប់គោលបំណងខាងលើ នូវអំពើអាសអាភាសកុមារ ដូចបានកំណត់ក្នុងមាត្រា២។

(២) ដោយស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ជាតិរបស់រដ្ឋភាគី បទប្បញ្ញត្តិដូចគ្នានេះ ត្រូវអនុវត្តចំពោះការប៉ុនប៉ងប្រព្រឹត្តអំពើណាមួយ ដូចបានរៀបរាប់ខាងលើ ព្រមទាំងចំពោះការសមគំនិត ឬការចូលរួមប្រព្រឹត្តអំពើណាមួយ ដូចបានរៀបរាប់ខាងលើ។

(៣) រដ្ឋភាគីនីមួយៗ ត្រូវដាក់បទល្មើសទាំងនោះ ជាបទល្មើសអាចផ្តន្ទាទោសបាន សមស្របទៅនឹងចរិតធ្ងន់ធ្ងរនៃបទល្មើស។

(៤) ដោយស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ជាតិរបស់ខ្លួន រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការតាមការចាំបាច់ ដើម្បីកំណត់កាតព្វកិច្ចទទួលខុសត្រូវរបស់នីតិបុគ្គល ចំពោះបទល្មើសដូចមានកំណត់ក្នុងកថាខណ្ឌ១នៃមាត្រានេះ។ ដោយស្ថិតក្រោមគោលការណ៍គតិយុត្តិនៃរដ្ឋភាគី កាតព្វកិច្ចទទួលខុសត្រូវរបស់នីតិបុគ្គល អាចមានខាងព្រហ្មទណ្ឌ រដ្ឋប្បវេណី ឬខាងរដ្ឋបាល។

(៥) រដ្ឋភាគី ត្រូវចាត់វាល់វិធានការសមស្របតាមផ្លូវច្បាប់ និងរដ្ឋបាល ដើម្បីធានាថា បុគ្គលគ្រប់រូបពាក់ព័ន្ធនឹងស្នំកូន អនុវត្តស្របតាមបទបញ្ញត្តិ នៃលិខិតុបករណ៍គតិយុត្តិអន្តរជាតិ ដែលកំពុងអនុវត្ត។

មាត្រា ៤

១. រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការចាំបាច់ ដើម្បីបង្កើតយុត្តាធិការរបស់ខ្លួនលើបទល្មើស ដូចមានកំណត់ក្នុងកថាខណ្ឌទី១នៃមាត្រា៣ បើបទល្មើសទាំងនោះត្រូវបានប្រព្រឹត្តលើដែនដីរបស់ រដ្ឋភាគី ឬលើនាវា ឬយន្តហោះ ដែលចុះបញ្ជីនៅក្នុងរដ្ឋនោះ។

២. រដ្ឋភាគីនីមួយៗ អាចចាត់វិធានការចាំបាច់ ដើម្បីបង្កើតយុត្តាធិការរបស់ខ្លួន គ្រប់គ្រង បទល្មើស ដូចមានយោងក្នុងកថាខណ្ឌទី១ នៃមាត្រា៣ ក្នុងករណីដូចខាងក្រោម :

(ក) បើជនជាប់សង្ស័យនៃបទល្មើស ជាជនជាតិរបស់រដ្ឋនោះ ឬជាជនមានលំនៅដ្ឋាន ជាប់លាប់លើទឹកដីរបស់រដ្ឋនោះ។

(ខ) បើជនរងគ្រោះ ជាជនជាតិរបស់រដ្ឋនោះ។

៣. រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការចាំបាច់ដូចគ្នានេះផងដែរ ដើម្បីបង្កើតយុត្តាធិការរបស់ ខ្លួន គ្រប់គ្រងបទល្មើសដូចបានបញ្ជាក់ខាងលើ បើជនជាប់សង្ស័យនៃបទល្មើស មានវត្តមានលើ ដែនដីរបស់រដ្ឋភាគី ហើយរដ្ឋភាគី មិនធ្វើបត្យាប័នជនជាប់សង្ស័យនេះ ទៅរដ្ឋភាគីផ្សេងទៀត ដោយមូលហេតុថា បទល្មើសត្រូវបានប្រព្រឹត្តដោយជនជាតិណាម្នាក់របស់ខ្លួន។

៤. ពិធីសារនេះ មិនផាត់ចេញនូវយុត្តាធិការព្រហ្មទណ្ឌណាមួយដែលត្រូវអនុវត្តស្របតាម ច្បាប់ផ្ទៃក្នុងរបស់ខ្លួនទេ។

មាត្រា ៥

១. បទល្មើសដូចចែងក្នុងកថាខណ្ឌទី១ នៃមាត្រា៣ ត្រូវចាត់បញ្ចូលជាបទល្មើសដែលអាច ធ្វើបត្យាប័ន ក្នុងសន្ធិសញ្ញាបត្យាប័នណាមួយដែលមាន រវាងរដ្ឋភាគី និងត្រូវបញ្ចូលជាបទល្មើស ដែលអាចធ្វើបត្យាប័នបាន ក្នុងគ្រប់សន្ធិសញ្ញាបត្យាប័ន ដែលបានចុះកិច្ចសន្យារវាងរដ្ឋភាគី ស្រប តាមលក្ខខណ្ឌបញ្ញត្តិក្នុងសន្ធិសញ្ញានោះ។

២. បើរដ្ឋភាគីដែលធ្វើបត្យាប័នកំណត់តាមអត្ថិភាពនៃសន្ធិសញ្ញាមួយ បានទទួលការស្នើសុំបត្យាប័នពីរដ្ឋភាគីមួយទៀតដែលមិនមានសន្ធិសញ្ញាបត្យាប័នជាមួយគ្នា រដ្ឋនោះ អាចចាត់ទុកពិធីសារនេះ ជាមូលដ្ឋានគតិយុត្តិសម្រាប់ធ្វើបត្យាប័នចំពោះបទល្មើសនោះ។ ការធ្វើបត្យាប័ន ត្រូវស្ថិតក្រោមលក្ខខណ្ឌបញ្ញត្តិដែលកំណត់ដោយច្បាប់របស់រដ្ឋដែលទទួលពាក្យសុំ។

៣. រដ្ឋភាគីដែលមិនធ្វើបត្យាប័នកំណត់តាមអត្ថិភាពនៃសន្ធិសញ្ញាណាមួយ ត្រូវទទួលស្គាល់បទល្មើសទាំងនោះ ជាបទល្មើសដែលអាចធ្វើបត្យាប័ន រវាងរដ្ឋភាគី អាស្រ័យតាមលក្ខខណ្ឌបញ្ញត្តិ ដែលកំណត់ដោយច្បាប់របស់រដ្ឋ ដែលទទួលការស្នើសុំ។

៤. ដើម្បីធ្វើបត្យាប័នរវាងរដ្ឋភាគី បទល្មើសទាំងនោះត្រូវចាត់ទុកថាបានប្រព្រឹត្ត មិនត្រឹមតែនៅកន្លែងកើតបទល្មើសប៉ុណ្ណោះទេ ប៉ុន្តែនៅក្នុងទឹកដីរបស់រដ្ឋដែលបានកំណត់ជាយុត្តាធិការនៃរដ្ឋនោះ ស្របតាមមាត្រា៨ ។

៥. បើការស្នើសុំបត្យាប័នត្រូវបានធ្វើចំពោះបទល្មើសដូចចែងក្នុងកថាខណ្ឌទី១ នៃមាត្រា៣ ហើយរដ្ឋភាគីដែលទទួលការស្នើសុំមិនធ្វើបត្យាប័ន ឬនឹងមិនធ្វើបត្យាប័ន ដោយមកពីសញ្ជាតិរបស់ចារីនៃបទល្មើស រដ្ឋនោះត្រូវចាត់វិធានការសមស្រប ដើម្បីប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីធ្វើការចោទប្រកាន់។

## មាត្រា ៦

១. រដ្ឋភាគី ត្រូវចាត់វិធានការជួយគ្នាទៅវិញទៅមកឱ្យបានទូលំទូលាយបំផុត ទាក់ទងនឹងការស៊ើបអង្កេត ឬនីតិវិធីខាងព្រហ្មទណ្ឌ ឬនីតិវិធីធ្វើបត្យាប័នចំពោះបទល្មើស ដូចមានកំណត់ក្នុងកថាខណ្ឌទី១ នៃមាត្រា៣ រួមមាន ការជួយផ្តល់ភស្តុតាងដែលខ្លួនមាន និងដែលចាំបាច់សម្រាប់ដំណើរការក្តី។

២. រដ្ឋភាគីត្រូវអនុវត្តកាតព្វកិច្ចក្រោមកថាខណ្ឌទី១ នៃមាត្រានេះ ស្របតាមសន្ធិសញ្ញា ឬការរៀបចំចាត់ចែងជួយគ្នាទៅវិញទៅមកតាមផ្លូវច្បាប់ ដែលអាចមានរវាងគ្នានិងគ្នា។ បើគ្មានសន្ធិសញ្ញា ឬការរៀបចំចាត់ចែងទាំងនោះទេ រដ្ឋភាគីត្រូវជួយគ្នាទៅវិញទៅមក ដោយយោងតាមច្បាប់ក្នុងប្រទេសរៀងខ្លួន។

## មាត្រា ៧

ស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ជាតិរបស់ខ្លួន រដ្ឋភាគីត្រូវ :

(ក) ចាត់វិធានការដែលយល់ថាសមស្រប ដើម្បីឃាត់ទុក ឬរឹបអូសនូវៈ

(i) ទំនិញ ដូចជា សម្ភារៈ ទ្រព្យ និងមធ្យោបាយខាងសម្ភារៈផ្សេងទៀត ដែលយកមកប្រើ ដើម្បីប្រព្រឹត្តបទល្មើស ឬសម្រួលដល់ការប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងពិធីសារនេះ។

(ii) ផលនៃបទល្មើស។

(ខ) អនុវត្តការស្នើសុំពីរដ្ឋភាគីម្ខាងទៀត ដើម្បីឃាត់ទុក ឬរឹបអូសទ្រព្យ ឬផលនៃបទល្មើស ដែលមានចែងក្នុងវាក្យខណ្ឌ(i) និងវាក្យខណ្ឌ(ii) នៃកថាខណ្ឌ(ក)។

(គ) ចាត់វិធានការបិទជាបណ្ដោះអាសន្ន ឬជាស្ថាពរ នូវទីតាំងទាំងឡាយដែលត្រូវបានប្រើប្រាស់ ដើម្បីប្រព្រឹត្តបទល្មើសទាំងនោះ។

## មាត្រា ៨

១. រដ្ឋភាគី ត្រូវអនុម័តវិធានការសមស្រប ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍កុមាររងគ្រោះ ដោយសារការអនុវត្តដែលហាមឃាត់ក្នុងពិធីសារនេះ នៅគ្រប់ដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌ ជាពិសេស ដោយៈ

(ក) ការទទួលស្គាល់ភាពងាយរងគ្រោះនៃកុមាររងគ្រោះ និងការសម្របសម្រួលនីតិវិធីដើម្បីទទួលស្គាល់តម្រូវការពិសេសរបស់កុមារ ជាអាទិ៍ តម្រូវការពិសេសរបស់កុមារក្នុងការធ្វើជាសាក្សី។

(ខ) ការប្រាប់កុមាររងគ្រោះអំពីសិទ្ធិ តួនាទីរបស់ពួកគេ និងវិសាលភាព កាលវិភាគ និងការវិវត្តទៅមុខនៃនីតិវិធី និងអំពីចំណាត់ការរឿងក្ដីរបស់កុមារនោះ។

(គ) អនុញ្ញាតឱ្យមានការបង្ហាញ និងការពិចារណាអំពីទស្សនៈ សេចក្ដីត្រូវការ និងកង្វល់របស់កុមាររងគ្រោះ ក្នុងនីតិវិធីដែលប៉ះពាល់ដល់ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់កុមារ ដោយឱ្យស្របតាមបទប្បញ្ញត្តិនៃនីតិវិធីច្បាប់ជាតិ។

(ឃ) ផ្ដល់សេវាគាំទ្រសមស្របចំពោះកុមាររងគ្រោះ នៅគ្រប់ដំណាក់កាលនៃនីតិវិធីខាងផ្លូវច្បាប់។

(ង) ការពារជីវិតឯកជន និងអត្តសញ្ញាណរបស់កុមាររងគ្រោះឱ្យបានសមស្រប និងចាត់វិធានការស្របតាមច្បាប់ជាតិ ជៀសវាងការផ្សព្វផ្សាយព័ត៌មានមិនសមស្របដែលនាំឱ្យស្គាល់អត្តសញ្ញាណរបស់កុមាររងគ្រោះ។

(ច) ក្នុងករណីសមស្រប ផ្តល់សុវត្ថិភាពដល់កុមាររងគ្រោះ ព្រមទាំងគ្រួសាររបស់កុមាររងគ្រោះ និងសាក្សីដាក់បន្ទុកឱ្យផុតពីការបំភិតបំភ័យ និងការសងសឹក។

(ឆ) ជៀសវាងការយឺតយ៉ាវដោយមិនចាំបាច់ ក្នុងចំណាត់ការរឿងក្តី និងការអនុវត្តដីកា ឬសេចក្តីសម្រេចផ្តល់សំណងចំពោះកុមាររងគ្រោះ។

២. រដ្ឋភាគីត្រូវធានាថា មន្ទិលសង្ស័យអំពីអាយុពិតរបស់ជនរងគ្រោះ មិនរារាំងដល់ការផ្តើមស៊ើបអង្កេតព្រហ្មទណ្ឌ រួមទាំង ការស៊ើបអង្កេត ដើម្បីកំណត់អាយុជនរងគ្រោះឡើយ។

៣. រដ្ឋភាគី ត្រូវចាត់វិធានការ ដើម្បីធានាថា ការប្រព្រឹត្តដោយប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌកុមារដែលរងគ្រោះពីបទល្មើសដូចមានចែងក្នុងពិធីសារនេះ ត្រូវគិតជាចម្បងដល់ឧត្តមប្រយោជន៍របស់កុមារ។

៤. រដ្ឋភាគី ត្រូវចាត់វិធានការ ដើម្បីធ្វើការបណ្តុះបណ្តាលសមស្រប ជាពិសេស ការបណ្តុះបណ្តាលផ្នែកច្បាប់ និងចិត្តសាស្ត្រដល់ជនទាំងឡាយ ដែលធ្វើការជាមួយជនរងគ្រោះពីបទល្មើសដែលហាមឃាត់ក្នុងពិធីសារនេះ។

៥. រដ្ឋភាគី ក្នុងករណីសមស្រប ត្រូវអនុម័តវិធានការ ដើម្បីការពារសុវត្ថិភាព និងបូរណភាពរបស់ជនទាំងឡាយ និង/ឬអង្គការដែលពាក់ព័ន្ធក្នុងការងារបង្ការ និង/ឬការពារ និងស្តារនីតិសម្បទាជនរងគ្រោះនៃបទល្មើសទាំងនេះ។

៦. គ្មានបទប្បញ្ញត្តិណាមួយនៃមាត្រានេះ ត្រូវបានបកស្រាយថា ជាការប៉ះពាល់ ឬមានវិសមភាពនឹងសិទ្ធិរបស់ជនជាប់ចោទ ចំពោះការជំរះក្តីមួយដែលមិនលំអៀង និងយុត្តិធម៌ឡើយ។

មាត្រា ៩

១. រដ្ឋភាគីត្រូវអនុម័ត ឬពង្រឹង អនុវត្ត និងផ្សព្វផ្សាយច្បាប់ វិធានការរដ្ឋបាល គោលនយោបាយ និងកម្មវិធីសង្គមដើម្បីបង្ការបទល្មើស ដូចមានចែងក្នុងពិធីសារនេះ។ រដ្ឋភាគីត្រូវផ្តល់ការយកចិត្តទុកដាក់ជាពិសេសដល់ការការពារកុមារដែលងាយរងគ្រោះបំផុតពីការអនុវត្តទាំងនោះ។

២. រដ្ឋភាគី ត្រូវលើកកំពស់ការយល់ដឹងដល់សាធារណៈជនទាំងអស់ រួមមាន កុមារផង តាមរយៈការផ្សព្វផ្សាយព័ត៌មានតាមគ្រប់មធ្យោបាយសមស្រប ការអប់រំ និងការបណ្តុះបណ្តាល អំពីវិធានការបង្ការ និងអំពីឥទ្ធិពលប្រកបដោយគ្រោះថ្នាក់នៃបទល្មើស ដូចចែងក្នុងពិធីសារនេះ។ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនក្រោមមាត្រានេះ រដ្ឋភាគីត្រូវជំរុញឱ្យមានការចូលរួមពីសហគមន៍ និងជាពិសេស កុមារ និងកុមាររងគ្រោះក្នុងកម្មវិធីព័ត៌មាន អប់រំ និងបណ្តុះបណ្តាល រួមមាន នៅថ្នាក់អន្តរជាតិផង។

៣. រដ្ឋភាគីត្រូវចាត់វាល់វិធានការដែលអាចធ្វើបាន សំដៅធានាឱ្យមានគ្រប់ជំនួយសមស្រប ដល់ជនរងគ្រោះនៃបទល្មើសទាំងនោះ រួមមាន ការធ្វើសមាហរណកម្មពេញលេញនៃជនទាំងនោះ ទៅក្នុងសង្គម និងការស្តារសម្បទាខាងរាងកាយ និងខាងផ្លូវចិត្ត នៃកុមារទាំងនោះផង។

៤. រដ្ឋភាគីត្រូវធានាថា កុមាររងគ្រោះនៃបទល្មើសដូចមានចែងក្នុងពិធីសារនេះ មានសិទ្ធិទទួលបាននីតិវិធីគ្រប់គ្រាន់ ដោយមិនរើសអើង ដើម្បីទទួលបានសំណងលើការខូចខាតពីជនទាំងឡាយដែលទទួលខុសត្រូវតាមផ្លូវច្បាប់។

៥. រដ្ឋភាគីត្រូវចាត់វិធានការសមស្រប សំដៅហាមឃាត់ប្រកបដោយប្រសិទ្ធភាព នូវការផលិត និងការផ្សព្វផ្សាយសម្ភារៈដែលផ្សាយពាណិជ្ជកម្មពីបទល្មើស ដូចមានកំណត់ក្នុងពិធីសារនេះ។

**មាត្រា ១០**

១. រដ្ឋភាគីចាត់វាល់វិធានការចាំបាច់ ដើម្បីពង្រឹងសហប្រតិបត្តិការអន្តរជាតិ តាមការព្រមព្រៀងពហុភាគី ថ្នាក់តំបន់ និងទ្វេភាគី ដើម្បីបង្ការ ស្វែងរក ស៊ើបអង្កេត ចោទប្រកាន់ និងផ្តន្ទាទោសជនដែលទទួលខុសត្រូវចំពោះអំពើពាក់ព័ន្ធការលក់កុមារ ពេស្យាកម្មកុមារ រូបភាព ឬសម្ភារៈអាសអាភាសកុមារ និងទេសចរណ៍ផ្លូវភេទកុមារ។ រដ្ឋភាគី ត្រូវលើកស្ទួយផងដែរ នូវសហប្រតិបត្តិការ និងការសម្របសម្រួលអន្តរជាតិ រវាងអាជ្ញាធរ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងអង្គការអន្តរជាតិ។

២. រដ្ឋភាគីត្រូវលើកស្ទួយសហប្រតិបត្តិការអន្តរជាតិ ដើម្បីជួយកុមាររងគ្រោះក្នុងការស្តារសម្បទាខាងផ្លូវកាយ និងផ្លូវចិត្ត ការធ្វើសមាហរណកម្មទៅក្នុងសង្គម និងការធ្វើមាតុភូមិនិវត្តន៍។

៣. រដ្ឋភាគី ត្រូវពង្រឹងសហប្រតិបត្តិការអន្តរជាតិ ដើម្បីដោះស្រាយមូលហេតុជាឫសគល់ ដូចជា ភាពក្រីក្រ និងភាពឱនថយ ដែលរួមចំណែកឱ្យកុមារងាយរងគ្រោះពីការលក់កុមារ ពេស្យាកម្មកុមារ រូបភាពឬសម្ភារៈអាសអាភាស និងទេសចរណ៍ផ្លូវភេទកុមារ។

៤. រដ្ឋភាគី ដែលមានលទ្ធភាពធ្វើទៅបាន ត្រូវផ្តល់ជំនួយហិរញ្ញវត្ថុ បច្ចេកទេស ឬជំនួយផ្សេងទៀត តាមរយៈកម្មវិធីពហុភាគី ថ្នាក់តំបន់ ទ្វេភាគី ឬកម្មវិធីផ្សេងទៀតដែលអាចមាន។

## មាត្រា ១១

គ្មានបទប្បញ្ញត្តិណាមួយ នៃពិធីសារនេះ ប៉ះពាល់ដល់បទបញ្ញត្តិទាំងឡាយ ដែលនាំឱ្យសម្រេចបាននូវសិទ្ធិកុមារប្រសើរជាងនេះ ដែលអាចមានចែងក្នុង:

(ក) ច្បាប់របស់រដ្ឋភាគី និង

(ខ) ច្បាប់អន្តរជាតិដែលចូលជាធរមានសម្រាប់រដ្ឋនោះឡើយ។

## មាត្រា ១២

១. រដ្ឋភាគីនីមួយៗ ក្នុងរយៈពេល២ឆ្នាំ ចាប់ពីពិធីសារនេះចូលជាធរមានសម្រាប់រដ្ឋនោះ ត្រូវដាក់របាយការណ៍ជូនគណៈកម្មាធិការសិទ្ធិកុមារ ដោយផ្តល់ព័ត៌មានទូលំទូលាយលើវិធានការនានារបស់រដ្ឋភាគី ក្នុងការអនុវត្តបទប្បញ្ញត្តិនៃពិធីសារនេះ។

២. បន្ទាប់ពីដាក់ជូនរបាយការណ៍ទូលំទូលាយហើយ រដ្ឋភាគីនីមួយៗ ត្រូវបញ្ចូលទៅក្នុងរបាយការណ៍នានារបស់ខ្លួន ជូនទៅគណៈកម្មាធិការសិទ្ធិកុមារ ស្របតាមមាត្រា៤៤នៃអនុសញ្ញានូវព័ត៌មានបន្ថែម ទាក់ទងនឹងការអនុវត្តពិធីសារនេះ។ រដ្ឋភាគីផ្សេងទៀតនៃពិធីសារនេះ ត្រូវធ្វើរបាយការណ៍ រៀងរាល់ ៥ឆ្នាំម្តង។

៣. គណៈកម្មាធិការសិទ្ធិកុមារ អាចស្នើសុំឱ្យរដ្ឋភាគីផ្តល់ព័ត៌មានបន្ថែម ពាក់ព័ន្ធនឹងការអនុវត្តពិធីសារនេះ។

## មាត្រា ១៣

១. ពិធីសារនេះ បើកឱ្យរដ្ឋភាគីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ឬរដ្ឋដែលបានចុះហត្ថលេខាលើអនុសញ្ញាស្តីពីសិទ្ធិកុមារ ចុះហត្ថលេខា។

២. ពិធីសារនេះ ជាកម្មវត្ថុឱ្យសច្ចាប័ន និងបើកឱ្យសុំចូលជាសមាជិក ចំពោះរដ្ឋភាគីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ឬរដ្ឋដែលបានចុះហត្ថលេខាលើអនុសញ្ញាស្តីពីសិទ្ធិកុមារ។ លិខិតុបករណ៍ឱ្យសច្ចាប័ន ឬសុំចូលជាសមាជិក ត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ។

### មាត្រា ១៤

១. ពិធីសារនេះ ចូលជាធរមានក្នុងរយៈពេល៣ខែ បន្ទាប់ពីកាលបរិច្ឆេទ នៃការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬសុំចូលជាសមាជិកទី១០។

២. ចំពោះរដ្ឋនីមួយៗដែលឱ្យសច្ចាប័ន ឬសុំចូលជាសមាជិក បន្ទាប់ពីពិធីសារនេះចូលជាធរមាន ពិធីសារនេះ ត្រូវចូលជាធរមានក្នុងរយៈពេល១ខែ បន្ទាប់ពីកាលបរិច្ឆេទ នៃការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬសុំចូលជាសមាជិករបស់រដ្ឋនោះ។

### មាត្រា ១៥

១. រដ្ឋភាគី អាចប្រកាសដកខ្លួនចេញពីពិធីសារនេះបានគ្រប់ពេល ដោយការជូនដំណឹងជាលាយល័ក្ខអក្សរ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយអគ្គលេខាធិការត្រូវជូនដំណឹងពីការប្រកាសដកខ្លួននេះ ទៅរដ្ឋភាគីផ្សេងទៀតនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ និងរដ្ឋទាំងអស់ដែលបានចុះហត្ថលេខាលើអនុសញ្ញាស្តីពីសិទ្ធិកុមារ។ ការប្រកាសដកខ្លួនមាន អនុភាពក្នុងរយៈពេល ១ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទដែលអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបានការជូនដំណឹង។

២. ការប្រកាសដកខ្លួននេះ ពុំមានអានុភាពឱ្យរដ្ឋភាគីរួចផុតពីកាតព្វកិច្ចរបស់ខ្លួន ក្រោមពិធីសារនេះ ចំពោះបទល្មើសណាដែលកើតមុនកាលបរិច្ឆេទនៃការប្រកាសដកខ្លួន ចូលជាធរមានឡើយ។ទោះតាមមធ្យោបាយណាក៏ដោយ ការប្រកាសដកខ្លួននេះ មិនប៉ះពាល់ដល់ការបន្តពិនិត្យបញ្ហាទាំងឡាយ ដែលគណៈកម្មាធិការសិទ្ធិកុមារកំពុងពិនិត្យ មុនកាលបរិច្ឆេទប្រកាសដកខ្លួនចូលជាធរមានឡើយ។

### មាត្រា ១៦

១. រដ្ឋភាគី អាចសុំធ្វើវិសោធនកម្ម និងដាក់សេចក្តីស្នើសុំនេះ ជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ។ អគ្គលេខាធិការ ត្រូវបញ្ជូនសេចក្តីស្នើវិសោធនកម្មទៅរដ្ឋភាគី ដោយស្នើសុំឱ្យ

រដ្ឋភាគីបញ្ជាក់ថាតើ រដ្ឋភាគីយល់ព្រមឱ្យមានសន្និសីទនៃរដ្ឋភាគីទាំងអស់ ដើម្បីពិនិត្យ និងបោះឆ្នោតលើសេចក្តីស្នើសុំឬទេ។ ក្នុងរយៈពេល៤ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការឆ្លើយឆ្លងនោះ ក្នុងករណីមានសំឡេង១ភាគ៣យ៉ាងតិចនៃរដ្ឋភាគី គាំទ្រឱ្យមានសន្និសីទបែបនេះ អគ្គលេខាធិការត្រូវកោះធ្វើសន្និសីទ ក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ។ វិសោធនកម្មដែលបានអនុម័តដោយមតិភាគច្រើននៃរដ្ឋភាគីវត្តមាន និងបានបោះឆ្នោតក្នុងសន្និសីទ ត្រូវដាក់ជូនមហាសន្និបាតសហប្រជាជាតិ ដើម្បីសុំការយល់ព្រម។

២. វិសោធនកម្មដែលបានអនុម័តស្របតាមកថាខណ្ឌទី១នៃមាត្រានេះ ត្រូវចូលជាធរមាននៅពេលវិសោធនកម្មនេះ ទទួលបានការយល់ព្រមពីមហាសន្និបាត និងបានទទួលយកដោយមតិភាគច្រើន២ភាគ៣នៃរដ្ឋភាគី ។

៣. នៅពេលវិសោធនកម្មចូលជាធរមានហើយ វិសោធនកម្មនោះ នឹងក្លាយជាកាតព្វកិច្ចសម្រាប់រដ្ឋភាគីដែលយល់ព្រមទទួលយកវិសោធនកម្មនោះ រដ្ឋភាគីក្រៅពីនេះ នៅតែជាប់កាតព្វកិច្ច ចំពោះបទប្បញ្ញត្តិនៃពិធីសារនេះ និងវិសោធនកម្មមុនៗ ដែលរដ្ឋភាគីនោះបានយល់ព្រមទទួលយក។

### មាត្រា ១៧

១. ពិធីសារនេះ ដែលមានអត្ថបទជាភាសាអារ៉ាប់ អង់គ្លេស បារាំង ចិន រុស្ស៊ី និងអេស្ប៉ាញ៉ុល មានតម្លៃយថាភូតស្មើគ្នា និងត្រូវដំកល់ទុកនៅប័ណ្ណសារដ្ឋាននៃអង្គការសហប្រជាជាតិ។

២. អគ្គលេខាធិការសហប្រជាជាតិ ត្រូវបញ្ជូនសេចក្តីចម្លងនៃពិធីសារនេះ ដោយមានបញ្ជាក់ការចម្លងស្របតាមច្បាប់ដើម ជូនរដ្ឋភាគីទាំងអស់នៃអនុសញ្ញា និងរដ្ឋទាំងអស់ដែលបានចុះហត្ថលេខាលើអនុសញ្ញាស្តីពីសិទ្ធិកុមារ។

# ១២គ. ពិធីសារបន្ថែមលើអនុសញ្ញាស្តីពីសិទ្ធិកុមារ ពាក់ព័ន្ធនឹងនីតិវិធីបណ្តឹង

*ពិធីសារនេះត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិកាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១១*
*យោងតាមមាត្រា១៩(១) ពិធីសារនេះមិនទាន់ចូលជាធរមាននៅឡើយទេ*
*កម្ពុជាមិនទាន់ទាំងចុះហត្ថលេខានៅឡើយ*

*រដ្ឋភាគីនៃពិធីសារនេះ*

*ដោយយល់ឃើញថា* អនុលោមតាមគោលការណ៍ ដែលបានប្រកាសជាផ្លូវការនៅក្នុងធម្មនុញ្ញសហប្រជាជាតិ ការទទួលស្គាល់សេចក្តីថ្លៃថ្នូរពីកំណើត និងសិទ្ធិស្មើភាពគ្នា និងមិនអាចដកហូត ឬផ្ទេរបាននៃសមាជិកទាំងអស់របស់គ្រួសារមនុស្ស គឺជាមូលដ្ឋានគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពនៅក្នុងពិភពលោក។

*ដោយកត់សម្គាល់ឃើញថា* រដ្ឋភាគីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ (ដែលចាប់ពីនេះតទៅហៅថា "អនុសញ្ញា") ទទួលស្គាល់សិទ្ធិដូចមានចែងនៅក្នុងអនុសញ្ញានេះសម្រាប់កុមារម្នាក់ៗនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយគ្មានការរើសអើងនៃប្រភេទណាមួយ ដោយមិនគិតពីពូជអម្បូរ ពណ៌សម្បុរ ភេទ ភាសា សាសនា ទស្សនៈនយោបាយ ឬទស្សនៈផ្សេងទៀត ដើមកំណើតជាតិ ជាតិពន្ធុ ឬដើមកំណើតសង្គម ទ្រព្យសម្បត្តិ ពិការភាព ឋានៈពីកំណើត ឬឋានៈផ្សេងទៀតរបស់ឪពុកម្តាយ ឬអាណាព្យាបាលតាមផ្លូវច្បាប់របស់កុមារឡើយ។

*ដោយអះអាងជាថ្មី*ពីសកលភាព ភាពមិនអាចបំបែកបាន ភាពពំនាក់អាស្រ័យគ្នា និងភាពទាក់ទងគ្នា នៃសិទ្ធិមនុស្សទាំងអស់ និងសេរីភាពជាមូលដ្ឋាន។

*ដោយអះអាងជាថ្មីផងដែរ* ពីឋានៈរបស់កុមារ ថាជាកម្មវត្ថុនៃសិទ្ធិ និងជាមនុស្សម្នាក់ប្រកបដោយសេចក្តីថ្លៃថ្នូរ និងមានសមត្ថភាពវិវត្តន៍ជានិច្ច។

*ដោយទទួលស្គាល់ថា* ស្ថានភាពពិសេស និងស្ថានភាពពឹងផ្អែកគេរបស់កុមារ អាចបង្កឱ្យមានការពិបាកយ៉ាងពិតប្រាកដដល់ពួកគេ ក្នុងការស្វែងរកមធ្យោបាយដោះស្រាយពីការរំលោភសិទ្ធិពួកគេ។

*ដោយយល់ឃើញថា* ពិធីសារនេះនឹងពង្រឹង និងបំពេញបន្ថែមនូវយន្តការជាតិ និងតំបន់ ដោយអនុញ្ញាតឱ្យកុមារ ដាក់ពាក្យបណ្តឹងពីការរំលោភសិទ្ធិពួកគេ។

*ដោយទទួលស្គាល់ថា* ឧត្តមប្រយោជន៍កុមារ គឺជាតម្លៃតបស្នងដ៏សំខាន់មួយ ដែលត្រូវគោរព ក្នុងការស្វែងរកមធ្យោបាយដោះស្រាយពីការរំលោភសិទ្ធិកុមារ ហើយថាមធ្យោបាយដោះស្រាយបែបនេះ ត្រូវតែគិតគូរពីតម្រូវការឱ្យមាននីតិវិធីដែលឆ្លើយតបទៅនឹងតម្រូវការកុមារ នៅគ្រប់កម្រិត។

*ដោយលើកទឹកចិត្ត* ឱ្យរដ្ឋភាគីបង្កើតយន្តការជាតិសមស្រប ដើម្បីជួយដល់កុមារ ដែលសិទ្ធិរបស់ពួកគេ ត្រូវបានរំលោភ ឱ្យទទួលបានមធ្យោបាយដោះស្រាយប្រកបដោយប្រសិទ្ធភាព នៅក្នុងស្រុក។

*ដោយរំលឹកឡើងវិញពី* តួនាទីដ៏សំខាន់ដែលស្ថាប័នជាតិសិទ្ធិមនុស្ស និងស្ថាប័នឯកទេសពាក់ព័ន្ធដទៃទៀតដែលមានអាណត្តិ លើកស្ទួយ និងការពារសិទ្ធិកុមារ អាចដើរតួនាទីចំពោះរឿងនេះ។

*ដោយយល់ឃើញថា* ដើម្បីពង្រឹង និងបំពេញបន្ថែមយន្តការជាតិទាំងនោះ និងដើម្បីលើកកំពស់បន្ថែមទៀតនូវការអនុវត្តអនុសញ្ញានេះ ហើយតាមដែលអាចធ្វើបាន ពិធីសារបន្ថែមពាក់ព័ន្ធនឹងការលក់ដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ និងពិធីសារបន្ថែមពាក់ព័ន្ធនឹងការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ នឹងរិតតែសមស្របដែលអាចឱ្យគណៈកម្មាធិការស្តីពីសិទ្ធិកុមារ (ដែលពីនេះតទៅហៅថា "គណៈកម្មាធិការ") អនុវត្តនូវមុខងារដែលមានចែងនៅក្នុងពិធីសារនេះ។

*បានព្រមព្រៀងគ្នាដូចតទៅ៖*

## ជំពូក ១
## បទប្បញ្ញត្តិទូទៅ

## មាត្រា ១

## *សមត្ថកិច្ចរបស់គណៈកម្មាធិការសិទ្ធិកុមារ*

១. រដ្ឋភាគីនៃពិធីសារនេះទទួលស្គាល់នូវសមត្ថកិច្ចរបស់គណៈកម្មាធិការនេះ ដូចមានចែងនៅក្នុងពិធីសារនេះ។

២. គណៈកម្មាធិការនេះ មិនអនុវត្តសមត្ថកិច្ចរបស់ខ្លួន ទាក់ទងទៅនឹងរដ្ឋភាគីនៃពិធីសារនេះ លើបញ្ហាពាក់ព័ន្ធនឹងការរំលោភសិទ្ធិ ដូចមានចែងនៅក្នុងលិខិតុបករណ៍ ដែលរដ្ឋនោះមិនមែនជាភាគីនោះទេ។

៣. គ្មានបណ្តឹងណាមួយ ត្រូវបានទទួលដោយគណៈកម្មាធិការទេ ប្រសិនបើបណ្តឹងនោះ ពាក់ព័ន្ធនឹងរដ្ឋមួយ ដែលមិនមែនជាភាគីនៃពិធីសារនេះ។

## មាត្រា ២

## *គោលការណ៍ទូទៅដែលណែនាំពីមុខងាររបស់គណៈកម្មាធិការ*

ក្នុងការបំពេញមុខងារដែលបានប្រគល់ជូនខ្លួនដោយពិធីសារនេះ គណៈកម្មាធិការ ត្រូវបានណែនាំដោយ គោលការណ៍នៃឧត្តមប្រយោជន៍កុមារ។ គណៈកម្មាធិការនេះក៏ត្រូវគោរពសិទ្ធិ និងការយល់ឃើញរបស់កុមារផងដែរ ការយល់ឃើញរបស់កុមារ ត្រូវបានផ្តល់សារៈប្រយោជន៍យ៉ាងត្រឹមត្រូវ ដោយអនុលោមទៅតាមអាយុ និងភាពចាស់ទុំរបស់កុមារ។

## មាត្រា ៣

## *វិធាននៃនីតិវិធី*

១. គណៈកម្មាធិការត្រូវអនុម័តវិធាននៃនីតិវិធី ដើម្បីយកទៅអនុវត្ត នៅពេលបំពេញមុខងារដែលប្រគល់ជូនខ្លួនដោយពិធីសារនេះ។ នៅក្នុងការអនុវត្ត គណៈកម្មាធិការ ត្រូវគោរពតាមមាត្រា២ នៃពិធីសារនេះ ជាពិសេស ដើម្បីធានានូវនីតិវិធីដែលឆ្លើយតបទៅនឹងតម្រូវការកុមារ។

២. គណៈកម្មាធិការត្រូវបញ្ចូលក្នុងវិធាននៃនីតិវិធីរបស់ខ្លួននូវវិធានការការពារ ដើម្បីទប់ស្កាត់ឧបាយកល បញ្ឆោតកុមារ ដោយជនទាំងឡាយណាដែលកំពុងធ្វើសកម្មភាពក្នុងនាមកុមារ ហើយអាចបដិសេធមិន ពិនិត្យបណ្តឹងណាមួយដែលខ្លួនពិចារណាថាមិនមែនជាឧត្តមប្រយោជន៍កុមារ។

## មាត្រា ៤

## *វិធានការការពារ*

១. រដ្ឋភាគីត្រូវចាត់វិធានការសមស្រប ដើម្បីធានាថា បុគ្គលគ្រប់រូបដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន មិនមែនជាកម្មវត្ថុនៃការរំលោភបំពានសិទ្ធិមនុស្ស ការធ្វើទុក្ខបុកម្នេញ ឬការបំភិតបំភ័យណាមួយ ដោយសារតែការដាក់បណ្តឹងឬសហការជាមួយនឹងគណៈកម្មាធិការស្របតាមពិធីសារនេះឡើយ។

២. អត្តសញ្ញាណរបស់បុគ្គល ឬក្រុមបុគ្គលពាក់ព័ន្ធណាមួយ មិនត្រូវបានបង្ហាញជាសាធារណៈ ដោយគ្មានការយល់ព្រមពីបុគ្គល ឬក្រុមបុគ្គលនោះឡើយ។

# ជំពូក ២

# នីតិវិធីបណ្តឹង

## មាត្រា ៥

## *បណ្តឹងបុគ្គល*

១. បណ្តឹងអាចធ្វើបានដោយ ឬក្នុងនាមបុគ្គលណាម្នាក់ឬក្រុមបុគ្គលណាមួយ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចនៃរដ្ឋភាគីមួយ ដោយអះអាងថាជាជនរងគ្រោះនៃការរំលោភបំពានសិទ្ធិណាមួយដោយរដ្ឋភាគីនោះ ដូចមានចែងនៅក្នុងលិខិតុបករណ៍ខាងក្រោមនេះ ដែលនៅក្នុងនោះ រដ្ឋនោះគឺជាភាគីនៃ៖

ក. អនុសញ្ញាស្តីពីសិទ្ធិកុមារ។

ខ. ពិធីសារបន្ថែមនៃអនុសញ្ញាពាក់ព័ន្ធនឹងការលក់ដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ។

គ. ពិធីសារបន្ថែមនៃអនុសញ្ញាពាក់ព័ន្ធទៅនឹងការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ។

២. ប្រសិនបណ្តឹង ធ្វើឡើងក្នុងនាមបុគ្គលម្នាក់ ឬក្រុមបុគ្គលណាមួយ បណ្តឹងនេះត្រូវតែមានការយល់ព្រមពីបុគ្គលទាំងនោះ ប្រសិនបើមិនដូច្នេះទេ អ្នកប្តឹងអាចធ្វើយុត្តិកម្មបានពីការធ្វើពាក្យបណ្តឹងក្នុងនាមបុគ្គល ឬក្រុមបុគ្គលនោះដោយគ្មានការយល់ព្រមបែបនេះ។

## មាត្រា ៦

## *វិធានការបណ្តោះអាសន្ន*

១. នៅពេលណាក៏បានបន្ទាប់ពីការទទួលបានពាក្យបណ្តឹង និងមុនពេលឈានដល់ការសម្រេចលើអង្គសេចក្តី គណៈកម្មាធិការអាចបញ្ជូនទៅរដ្ឋភាគីពាក់ព័ន្ធដើម្បីពិនិត្យជាបន្ទាន់លើសំណើដែលរដ្ឋភាគីចាត់វិធានការបណ្តោះអាសន្នតាមការចាំបាច់ក្នុងកាលៈទេសៈពិសេស ដើម្បីបញ្ចៀសនូវការខូតខាត ដែលមិនអាចជួសជុលបាន ដែលអាចកើតមានដល់ជនរងគ្រោះម្នាក់ ឬច្រើននាក់ ពីការរំលោភបំពាន ទៅតាមការចោទប្រកាន់។

២. ប្រសិនបើគណៈកម្មាធិការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ក្រោមកថាខណ្ឌទី១នៃមាត្រានេះ នោះមិនមែនមានន័យថា ជាការសម្រេចពីការទទួលយកបាននៃពាក្យបណ្តឹង ឬការសម្រេចលើអង្គសេចក្តីនៃបណ្តឹងនោះឡើយ។

## មាត្រា ៧

## *ការទទួលយកបាននៃបណ្តឹង*

គណៈកម្មាធិការត្រូវពិចារណាលើបណ្តឹងដែលមិនអាចទទួលយកបាន នៅពេលដែល៖

ក. បណ្តឹងនោះមានលក្ខណៈអនាមិក។

ខ. បណ្តឹងនោះមិនសរសេរជាលាយលក្ខណ៍អក្សរ។

គ. បណ្ដឹងនោះ បំពានលើសិទ្ធិក្នុងការដាក់ពាក្យបណ្ដឹង ឬមិនស្របនឹងបទប្បញ្ញត្តិនៃអនុសញ្ញា និង/ឬពិធីសារបន្ថែមនេះ។

ឃ. បញ្ហាដដែលនេះត្រូវបានគណៈកម្មាធិការពិនិត្យរួចហើយ ឬត្រូវបាន ឬកំពុងត្រូវបានពិនិត្យ ក្រោមនីតិវិធីនៃការស៊ើបអង្កេត ឬការដោះស្រាយអន្តរជាតិ។

ង. ដំណោះស្រាយទាំងប៉ុន្មាន ដែលមាននៅក្នុងស្រុក មិនទាន់ត្រូវបានប្រើប្រាស់ឱ្យអស់លទ្ធភាពនៅឡើយ។ ដំណោះស្រាយនេះ មិនមែនជាវិធានទៀតទេ ប្រសិនបើការអនុវត្តមធ្យោបាយដំណោះស្រាយទាំងនេះ បានអូសបន្លាយរយៈពេលយូរហួសហេតុ ឬមិនទំនងជានាំមកនូវការដោះស្រាយមួយប្រកបដោយប្រសិទ្ធភាព។

ច. បណ្ដឹងមិនបានបញ្ជាក់ពីមូលហេតុច្បាស់លាស់ ឬគ្មានភស្តុតាងគ្រប់គ្រាន់សម្រាប់ធ្វើជាអំណះអំណាង។

ឆ. អង្គហេតុដែលជាកម្មវត្ថុនៃបណ្ដឹង បានកើតមាននៅមុនពេលពិធីសារនេះចូលជាធរមានសម្រាប់រដ្ឋភាគីដែលពាក់ព័ន្ធនោះ បើពុំនោះទេ លុះត្រាតែអង្គហេតុនេះ បានបន្តរហូតមកដល់ក្រោយកាលបរិច្ឆេទ នៃការចូលជាធរមាននៃពិធីសារនេះ សំរាប់រដ្ឋនោះ។

ជ. បណ្ដឹងមិនត្រូវបានដាក់ជូន ក្នុងរយៈពេលមួយឆ្នាំ បន្ទាប់ពីប្រើអស់លទ្ធភាពនៃមធ្យោបាយដំណោះស្រាយនៅក្នុងស្រុក លើកលែងតែក្នុងករណីដែលអ្នកប្ដឹងអាចបង្ហាញថា មិនមានលទ្ធភាពដាក់ពាក្យបណ្ដឹងបាន ក្នុងពេលវេលាកំណត់នោះ។

## មាត្រា ៨

## *ការបញ្ជូនពាក្យបណ្ដឹង*

១. លុះត្រាតែគណៈកម្មាធិការយល់ថា ពាក្យបណ្ដឹងនេះមិនអាចទទួលយកបានទេដោយមិនបាននិយាយយោងលើរដ្ឋភាគីពាក់ព័ន្ធ ទើបគណៈកម្មាធិការត្រូវ

នាំយកដំណឹងណាមួយដែលខ្លួនទទួលបានជាសម្ងាត់ស្របតាមពិធីសារនេះ ជូនរដ្ឋភាគីពាក់ព័ន្ធឱ្យយកចិត្តទុកដាក់ឆាប់បំផុតតាមតែអាចធ្វើទៅបាន។

២. រដ្ឋភាគីត្រូវដាក់ជូនគណៈកម្មាធិការវិញ នូវការពន្យល់ជាលាយលក្ខណ៍អក្សរ ឬសេចក្ដីថ្លែងការណ៍បំភ្លឺបញ្ហា និងការដោះស្រាយ ប្រសិនបើមាន។ រដ្ឋភាគីត្រូវបញ្ជូនការឆ្លើយតបរបស់ខ្លួនឱ្យបានឆាប់ តាមតែអាចធ្វើបាន និងក្នុងរយៈពេល៦ខែ។

## មាត្រា ៩

## ដំណោះស្រាយប្រកបដោយមិត្តភាព

១. គណៈកម្មាធិការត្រូវធានាឱ្យមានអន្ដរការីរបស់ខ្លួនចំពោះភាគីពាក់ព័ន្ធ ដោយសង្ឃឹមថា នឹងឈានដល់ការដោះស្រាយបញ្ហា ប្រកបដោយមិត្តភាពមួយដោយឈរលើមូលដ្ឋានគោរពកាតព្វកិច្ច ដូចមានចែងនៅក្នុងអនុសញ្ញា និង/ឬក្នុងពិធីសារបន្ថែមនានារបស់អនុសញ្ញានេះ។

២. កិច្ចព្រមព្រៀងស្ដីពីដំណោះស្រាយប្រកបដោយមិត្តភាពមួយដែលត្រូវបានសម្រេច ក្រោមការជួយឧបត្ថម្ភពីគណៈកម្មាធិការ បិទការពិចារណាលើពាក្យបណ្ដឹង ក្រោមពិធីសារនេះ។

## មាត្រា ១០

## ការពិនិត្យពាក្យបណ្ដឹង

១. គណៈកម្មាធិការ ត្រូវពិនិត្យពាក្យបណ្ដឹងដែលទទួលបាន ស្របតាមពិធីសារនេះ ឆាប់ៗតាមតែអាចធ្វើបាន ទៅលើឯកសារទាំងអស់ដែលបានដាក់ជូនគណៈកម្មាធិការ ហើយឯកសារនេះត្រូវបានបញ្ជូនទៅភាគីពាក់ព័ន្ធ។

២. គណៈកម្មាធិការត្រូវប្រជុំជាសម្ងាត់ នៅពេលពិនិត្យពាក្យបណ្ដឹងដែលទទួលបានស្របតាមពិធីសារនេះ។

៣. ប្រសិនបើគណៈកម្មាធិការ បានស្នើឱ្យមានវិធានការបណ្តោះអាសន្ន គណៈកម្មាធិការត្រូវរួសរាន់ពិនិត្យលើពាក្យបណ្តឹងនោះ។

៤. នៅពេលពិនិត្យពាក្យបណ្តឹង ដែលចោទប្រកាន់ពីការរំលោភបំពានសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច ឬវប្បធម៌ គណៈកម្មាធិការត្រូវពិនិត្យពីភាពសមហេតុផលនៃវិធានការដែលបានធ្វើឡើងដោយរដ្ឋភាគី អនុលោមតាមមាត្រា៤ នៃអនុសញ្ញា។ ការអនុវត្តបែបនេះ គណៈកម្មាធិការត្រូវចងចាំថា រដ្ឋភាគីអាចអនុម័តវិធានការគោលនយោបាយដែលអាចធ្វើបានជាច្រើន សម្រាប់អនុវត្តន៍សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅក្នុងអនុសញ្ញានេះ។

៥. បន្ទាប់ពីពិនិត្យពាក្យបណ្តឹងរួច គណៈកម្មាធិការត្រូវបញ្ជូនការយល់ឃើញរបស់ខ្លួនស្តីពីបណ្តឹងនោះ រួមជាមួយអនុសាសន៍របស់ខ្លួន ប្រសិនបើមានទៅភាគីពាក់ព័ន្ធ ដោយមិនត្រូវពន្យាពេលឡើយ។

## *មាត្រា ១១*

## *ការតាមដាន*

១. រដ្ឋភាគីត្រូវពិនិត្យឱ្យបានត្រឹមត្រូវចំពោះការយល់ឃើញរបស់គណៈកម្មាធិការ រួមជាមួយអនុសាសន៍របស់គណៈកម្មាធិការ ប្រសិនបើមាន ហើយត្រូវបញ្ជូនចម្លើយជាលាយលក្ខណ៍អក្សរទៅគណៈកម្មាធិការវិញ រួមទាំងព័ត៌មានស្តីពីវិធានការដែលបានចាត់ឡើងនិងដែលបានពិនិត្យទាក់ទងទៅនឹងការយល់ឃើញនិងអនុសាសន៍របស់គណៈកម្មាធិការ។ រដ្ឋភាគីត្រូវបញ្ជូនចម្លើយរបស់ខ្លួនឱ្យបានឆាប់តាមតែអាចធ្វើបាន និងក្នុងរយៈពេល ៦ខែ។

២. គណៈកម្មាធិការអាចអញ្ជើញរដ្ឋភាគីឱ្យផ្តល់ព័ត៌មានបន្ថែម អំពីវិធានការនានាដែលរដ្ឋភាគីបានចាត់ឡើង ជាការឆ្លើយតបទៅនឹងការយល់ឃើញ ឬអនុសាសន៍របស់គណៈកម្មាធិការ ឬការអនុវត្តកិច្ចព្រមព្រៀង តាមដំណោះស្រាយប្រកបដោយមិត្តភាព ប្រសិនបើមាន រួមទាំងវិធានការផ្សេងទៀត តាមតែគណៈកម្មាធិការយល់ថាសមស្រប នៅក្នុងរបាយការណ៍បន្តបន្ទាប់របស់រដ្ឋ

ភាគី ក្រោមមាត្រា៤៤ នៃអនុសញ្ញា មាត្រា១២ នៃពិធីសារបន្ថែមលើអនុសញ្ញាពាក់ព័ន្ធនឹងការលក់ដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ ឬមាត្រា៨ នៃពិធីសារបន្ថែមលើអនុសញ្ញាពាក់ព័ន្ធនឹងការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ ប្រសិនបើអាច។

## មាត្រា ១២

## *បណ្តឹងរវាងរដ្ឋ*

១. នៅពេលណាក៏ដោយ រដ្ឋភាគីមួយនៃពិធីសារនេះអាចប្រកាសថា ខ្លួនទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការ ក្នុងការទទួល និងពិនិត្យបណ្តឹង ដែលក្នុងនោះរដ្ឋភាគីមួយអះអាងថា រដ្ឋភាគីមួយទៀត មិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន ក្រោមលិខិតុបករណ៍ណាមួយនៃលិខិតុបករណ៍នានាខាងក្រោមនេះ ដែលរដ្ឋនោះគឺជាភាគីនៃ៖

ក. អនុសញ្ញា។

ខ. ពិធីសារបន្ថែមស្តីពីអនុសញ្ញាពាក់ព័ន្ធនឹងការលក់ដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ។

គ. ពិធីសារបន្ថែមស្តីពីអនុសញ្ញាពាក់ព័ន្ធនឹងការចូលរួមរបស់កុមារ ក្នុងជម្លោះប្រដាប់អាវុធ។

២. គណៈកម្មាធិការ មិនត្រូវទទួលបណ្តឹងពាក់ព័ន្ធនឹងរដ្ឋភាគីមួយ ដែលមិនបានធ្វើសេចក្តីប្រកាស ឬបណ្តឹងពីរដ្ឋភាគីដែលមិនបានធ្វើសេចក្តីប្រកាសបែបនេះឡើយ។

៣. គណៈកម្មាធិការត្រូវធានាឱ្យមានអន្តរការីដែលអាចប្រើប្រាស់បានរបស់ខ្លួនចំពោះរដ្ឋភាគីពាក់ព័ន្ធ ដោយសង្ឃឹមថា នឹងឈានដល់ការដោះស្រាយបញ្ហាប្រកបដោយមិត្តភាព ដោយឈរលើមូលដ្ឋាននៃការគោរពកាតព្វកិច្ច ដូចមានចែងនៅក្នុងអនុសញ្ញា និង/ឬពិធីសារបន្ថែមនានានៃអនុសញ្ញានេះ។

៤. រដ្ឋភាគីត្រូវតម្កល់សេចក្តីប្រកាសរបស់ខ្លួនស្របតាមកថាខណ្ឌទី១ នៃមាត្រានេះ នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលជាអ្នកត្រូវបញ្ជូនច្បាប់ចម្លង នៃសេចក្តីប្រកាសនេះទៅរដ្ឋភាគីដទៃទៀត។ សេចក្តីប្រកាសនេះ អាចត្រូវបាន ដកមកវិញនៅពេលណាក៏បាន តាមរយៈការជូនដំណឹងទៅអគ្គលេខាធិការ។ ការ ដកសេចក្តីប្រកាសមកវិញបែបនេះ មិនត្រូវធ្វើឱ្យខូចខាតដល់ការពិនិត្យបញ្ហា ណាមួយដែលជាកម្មវត្ថុនៃបណ្តឹងដែលត្រូវបានបញ្ជូនរួចហើយ ក្រោមមាត្រា នេះទេ។ គ្មានបណ្តឹងបន្ថែមដោយរដ្ឋភាគីណាមួយ ត្រូវបានទទួលក្រោម មាត្រានេះទេ បន្ទាប់ពីការជូនដំណឹងពីការដកសេចក្តីប្រកាសនេះ ត្រូវបាន ទទួលដោយអគ្គលេខាធិការ លុះត្រាតែ រដ្ឋភាគីពាក់ព័ន្ធ បានធ្វើសេចក្តី ប្រកាសបែបនេះជាថ្មី។

## ជំពូក ៣
## នីតិវិធីស៊ើបសួរ

### *មាត្រា ១៣*

### *នីតិវិធីស៊ើបសួរចំពោះការរំលោភបំពានធ្ងន់ធ្ងរ និងជាប្រព័ន្ធ*

១. ប្រសិនបើគណៈកម្មាធិការ ទទួលបានព័ត៌មានគួរឱ្យទុកចិត្តបាន ដោយ បង្ហាញឱ្យឃើញពីការរំលោភបំពានធ្ងន់ធ្ងរ ឬជាប្រព័ន្ធ ដោយរដ្ឋភាគីទៅលើ សិទ្ធិដែលមានចែងនៅក្នុងអនុសញ្ញា ឬមានចែងនៅក្នុងពិធីសារបន្ថែមពាក់ព័ន្ធ នឹងការលក់ដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ ឬពិធី សារបន្ថែមពាក់ព័ន្ធនឹងការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ គណៈ កម្មាធិការត្រូវអញ្ជើញរដ្ឋភាគីនោះ ឱ្យសហការពិនិត្យព័ត៌មាន និងក្នុងគោលដៅ នេះ ឱ្យផ្តល់សេចក្តីសង្កេតចំពោះព័ត៌មានដែលពាក់ព័ន្ធ ដោយមិនត្រូវពន្យាពេល ឡើយ។

២. ដោយយកមកពិចារណានូវសេចក្ដីសង្កេតណាមួយ ដែលរដ្ឋភាគីពាក់ព័ន្ធបានបញ្ជូនមក រួមទាំងព័ត៌មានដែលគួរឱ្យទុកចិត្តបានផ្សេងទៀតដែលខ្លួនមាន គណៈកម្មាធិការអាចចាត់តាំងសមាជិករបស់ខ្លួនមួយ ឬច្រើនរូប ឱ្យបើកការស៊ើបសួរ និងរាយការណ៍ជាបន្ទាន់ទៅគណៈកម្មាធិការ។ ប្រសិនបើមានការធានា និងមានការយល់ព្រមពីរដ្ឋភាគី ការស៊ើបសួរនេះ អាចមានទាំងការធ្វើទស្សនកិច្ចទៅក្នុងទឹកដីនៃរដ្ឋភាគីនោះផង។

៣. ការស៊ើបសួរនេះត្រូវធ្វើជាសម្ងាត់ និងត្រូវស្វែងរកកិច្ចសហប្រតិបត្តិការពីរដ្ឋភាគីនូវគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនេះ។

៤. បន្ទាប់ពីបានពិនិត្យលើការរកឃើញពីការស៊ើបសួរបែបនេះ គណៈកម្មាធិការត្រូវបញ្ជូន ដោយគ្មានពន្យាពេលឡើយនូវការរកឃើញទាំងនេះ រួមជាមួយនឹងការផ្ដល់យោបល់ និងអនុសាសន៍ ទៅរដ្ឋភាគីដែលពាក់ព័ន្ធ។

៥. រដ្ឋភាគីដែលពាក់ព័ន្ធត្រូវដាក់សេចក្ដីសង្កេតរបស់ខ្លួនជូនគណៈកម្មាធិការវិញ ឱ្យបានឆាប់តាមតែអាចធ្វើទៅបាន និងក្នុងរយៈពេល៦ខែ ក្រោយពីទទួលបានការរកឃើញ ការផ្ដល់យោបល់និងអនុសាសន៍ ដែលគណៈកម្មាធិការបានបញ្ជូនមកឱ្យខ្លួន។

៦. បន្ទាប់ពីកិច្ចដំណើរការស៊ើបសួរបែបនេះបានបញ្ចប់ ស្របទៅតាមកថាខ័ណ្ឌទី២នៃមាត្រានេះ និងបន្ទាប់ពីធ្វើការពិគ្រោះយោបល់ជាមួយរដ្ឋភាគីដែលពាក់ព័ន្ធ គណៈកម្មាធិការ អាចសម្រេចដាក់បញ្ចូលសេចក្ដីសង្ខេបដែលលទ្ធផលនៃកិច្ចដំណើការនេះ ទៅក្នុងរបាយការណ៍របស់ខ្លួន ដូចមានចែងនៅក្នុងមាត្រា១៦នៃពិធីសារនេះ។

៧. នៅពេលចុះហត្ថលេខាឬផ្ដល់សច្ចាប័នឬចូលជាសមាជិកនៃពិធីសារនេះ រដ្ឋភាគីនីមួយៗអាចប្រកាសថា ខ្លួនមិនទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការដូចមានចែងក្នុងមាត្រានេះ ចំពោះសិទ្ធិដែលមានចែងក្នុងលិខិតុបករណ៍មួយ ឬទាំងអស់ដូចបានរៀបរាប់នៅក្នុងកថាខ័ណ្ឌទី១។

៨. រដ្ឋភាគីណាមួយដែលបានធ្វើសេចក្តីប្រកាស ស្របតាមកថាខ័ណ្ឌទី៧ នៃមាត្រានេះ អាចដកសេចក្តីប្រកាសវិញបាន នៅពេលណាក៏បាន ដោយគ្រាន់តែជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។

## មាត្រា ១៤

## *ការតាមដានចំពោះនីតិវិធីស៊ើបសួរ*

១. ក្នុងករណីចាំបាច់ បន្ទាប់ពីផុតរយៈពេល៦ខែដូចមានចែងក្នុងមាត្រា១៣ កថាខ័ណ្ឌទី៥ គណៈកម្មាធិការ អាចអញ្ជើញរដ្ឋភាគីដែលពាក់ព័ន្ធ ឱ្យផ្តល់ព័ត៌មានមកខ្លួនអំពីវិធានការដែលបានចាត់ឡើង និងដែលបានពិនិត្យ ក្នុងការឆ្លើយតបទៅនឹងការស៊ើបសួរដែលបានធ្វើឡើង ស្របតាមមាត្រា១៣ នៃពិធីសារនេះ។

២. គណៈកម្មាធិការ អាចអញ្ជើញរដ្ឋភាគី ឱ្យផ្តល់ព័ត៌មានបន្ថែមអំពីវិធានការណាមួយដែលខ្លួនបានចាត់ឡើង ក្នុងការឆ្លើយតបនឹងការស៊ើបសួរដែលបានធ្វើឡើងស្របតាមមាត្រា១៣ រួមទាំងតាមតែគណៈកម្មាធិការយល់ថាសមស្របនៅក្នុងរបាយការណ៍បន្ទាប់របស់រដ្ឋភាគី ក្រោមមាត្រា៤៤ នៃអនុសញ្ញា មាត្រា១២ នៃពិធីសារបន្ថែមលើអនុសញ្ញាពាក់ព័ន្ធនឹងការលក់ដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ ឬមាត្រា៨ នៃពិធីសារបន្ថែមលើអនុសញ្ញាពាក់ព័ន្ធនឹងការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ ប្រសិនបើអាច។

# **ជំពូក ៤**

# **អវសានបញ្ញត្តិ**

## មាត្រា ១៥

## *ជំនួយ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ*

១. ដោយមានការយល់ព្រមពីរដ្ឋភាគីដែលពាក់ព័ន្ធ គណៈកម្មាធិការ អាចផ្ញើជូនទីភ្នាក់ងារឯកទេសនៃអង្គការសហប្រជាជាតិ ស្ថាប័នមូលនិធិនិងកម្មវិធី និងស្ថាប័ន

មានសមត្ថកិច្ចផ្សេងទៀត នូវការយល់ឃើញ ឬអនុសាសន៍របស់ខ្លួន ពាក់ព័ន្ធនឹងបណ្តឹង និងការស៊ើបសួរ ដែលបង្ហាញពីតម្រូវការសំរាប់ប្រឹក្សាយោបល់ ឬជំនួយបច្ចេកទេស រួមជាមួយនឹងសេចក្តីសង្កេត ព្រមទាំងសំណើរបស់រដ្ឋភាគី ឆ្លើយតបចំពោះការយល់ឃើញ ឬអនុសាសន៍ទាំងនេះ ប្រសិនបើមាន។

២. ដោយមានការយល់ព្រមពីរដ្ឋភាគីដែលពាក់ព័ន្ធ គណៈកម្មាធិការក៏អាចប្រាប់ឱ្យស្ថាប័នទាំងនោះបានដឹងពីបញ្ហាណាមួយដែលកើតចេញពីបណ្តឹង ក្រោមពិធីសារនេះ ដែលអាចជួយស្ថាប័នទាំងនោះ តាមសមត្ថកិច្ចរបស់ខ្លួនរៀងៗខ្លួន ក្នុងការសម្រេចលើភាពអាចណែនាំទៅបាន នៃវិធានការអន្តរជាតិ ដែលទំនងជានឹងចូលរួមវិភាគទានជួយដល់រដ្ឋភាគី ក្នុងការសម្រេចបានវឌ្ឍនភាពក្នុងការអនុវត្តសិទ្ធិនានា ដែលត្រូវបានទទួលស្គាល់នៅក្នុងអនុសញ្ញា និង/ឬនៅក្នុងពិធីសារបន្ថែមនានានៃអនុសញ្ញានេះ។

## មាត្រា ១៦

## *របាយការណ៍ជូនមហាសន្និបាត*

គណៈកម្មាធិការ ត្រូវបញ្ចូលទៅក្នុងរបាយការណ៍របស់ខ្លួន ដែលត្រូវដាក់ជូនមហាសន្និបាតរៀងរាល់ពីរឆ្នាំម្តង ដោយអនុលោមតាមមាត្រា៤៤ កថាខ័ណ្ឌទី៥ នៃអនុសញ្ញានេះ នូវសេចក្តីសង្ខេបនៃសកម្មភាពការងារ របស់ខ្លួន តាមពិធីសារនេះ។

## មាត្រា ១៧

## *ការផ្សព្វផ្សាយ និងព័ត៌មានស្តីពីពិធីសារបន្ថែម*

រដ្ឋភាគីនីមួយៗ មានភារកិច្ចត្រូវធ្វើឱ្យជ្រួតជ្រាបបានទូលំទូលាយ និងផ្សព្វផ្សាយពិធីសារនេះ និងសម្របសម្រួលឱ្យទទួលបានព័ត៌មានអំពីការយល់ឃើញ និងអនុសាសន៍របស់គណៈកម្មាធិការ ជាពិសេស ចំពោះបញ្ហាដែលទាក់ទងនឹងរដ្ឋភាគីនោះ តាមរយៈមធ្យោបាយសមស្រប និងសកម្ម និងតាមទម្រង់ដែលមនុស្សពេញវ័យ និងក្មេងៗដូចកុមារ រួមទាំងជនពិការផង អាចមានលទ្ធភាពទទួលបានដូចៗគ្នា។

## មាត្រា ១៨

## *ការចុះហត្ថលេខា ការផ្ដល់សច្ចាប័ន និងការចូលជាសមាជិក*

១. ពិធីសារនេះ បើកឱ្យចុះហត្ថលេខាដោយរដ្ឋណាមួយ ដែលបានចុះហត្ថលេខា ផ្ដល់សច្ចាប័ន ឬចូលជាសមាជិកនៃអនុសញ្ញា ឬក៏ពិធីសារណាមួយក្នុង ចំណោមពិធីសារបន្ថែមពីរដំបូងនៃអនុសញ្ញានេះ។

២. ពិធីសារនេះគឺជាកម្មវត្ថុនៃការផ្ដល់សច្ចាប័ន ដោយរដ្ឋណាមួយដែលបានផ្ដល់ សច្ចាប័ន ឬចូលជាសមាជិកនៃអនុសញ្ញានេះ ឬពិធីសារណាមួយក្នុងចំណោម ពិធីសារបន្ថែមពីរដំបូងនៃអនុសញ្ញានេះ។ លិខិតុបករណ៍នៃការឱ្យសច្ចាប័ន ត្រូវ តម្កល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ។

៣. ពិធីសារនេះ ត្រូវបើកឱ្យចូលជាសមាជិកដោយរដ្ឋណាមួយ ដែលបានផ្ដល់ សច្ចាប័នឬចូលជាសមាជិកនៃអនុសញ្ញានេះឬពិធីសារណាមួយក្នុងចំណោម ពិធីសារបន្ថែមពីរដំបូងនៃអនុសញ្ញានេះ។

៤. ការចូលជាសមាជិក ត្រូវចូលជាធរមាន ដោយការតម្កល់លិខិតុបករណ៍ចូល ជាសមាជិកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ។

## មាត្រា ១៩

## *ការចូលជាធរមាន*

១. ពិធីសារនេះ ត្រូវចូលជាធរមានរយៈពេលបីខែ បន្ទាប់ពីការតម្កល់លិខិតុបករណ៍ ទី១០ នៃការផ្ដល់សច្ចាប័ន ឬការចូលជាសមាជិក។

២. ចំពោះរដ្ឋនីមួយៗដែលបានផ្ដល់សច្ចាប័ន ឬចូលជាសមាជិក បន្ទាប់ពីការ តម្កល់លិខិតុបករណ៍ទី១០ នៃការផ្ដល់សច្ចាប័ន ឬការចូលជាសមាជិក ពិធី សារនេះ ត្រូវចូលជាធរមាន ក្នុងរយៈពេលបីខែ បន្ទាប់ពីកាលបរិច្ឆេទនៃការ តម្កល់លិខិតុបករណ៍នៃការផ្ដល់សច្ចាប័ន ឬការចូលជាសមាជិកនៃរដ្ឋនោះ។

## មាត្រា ២០
## *ការរំលោភបំពានដែលកើតមានបន្ទាប់ពីការចូលជាធរមាន*

១. គណៈកម្មាធិការ ត្រូវមានសមត្ថកិច្ចតែមួយគត់ទាក់ទងទៅនឹងការរំលោភបំពានសិទ្ធិណាមួយដោយរដ្ឋភាគី ដូចមានចែងនៅក្នុងអនុសញ្ញា និង/ឬនៅក្នុងពិធីសារបន្ថែមទាំងពីរដំបូងនៃអនុសញ្ញា ដែលការបំពាននេះ កើតឡើងបន្ទាប់ពីពិធីសារនេះចូលជាធរមាន។

២. ក្នុងករណីដែលរដ្ឋមួយ ក្លាយជាភាគីនៃពិធីសារនេះ បន្ទាប់ពីពិធីសារនេះចូលជាធរមាន កាតព្វកិច្ចនៃរដ្ឋនោះ ចំពោះគណៈកម្មាធិការ ត្រូវពាក់ព័ន្ធតែជាមួយនឹងការរំលោភបំពានសិទ្ធិ ដូចមានចែងនៅក្នុងអនុសញ្ញា និង/ឬនៅក្នុងពិធីសារបន្ថែមទាំងពីរដំបូងនៃអនុសញ្ញា ដែលការបំពាននេះកើតឡើងបន្ទាប់ពីពិធីសារនេះ ចូលជាធរមានសម្រាប់រដ្ឋពាក់ព័ន្ធនោះ។

## មាត្រា ២១
## *វិសោធនកម្ម*

១. រដ្ឋភាគីអាចស្នើសុំធ្វើវិសោធនកម្មពិធីសារនេះ និងដាក់សេចក្តីស្នើសុំនេះជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ។ អគ្គលេខាធិការត្រូវបញ្ជូនសេចក្តីស្នើវិសោធនកម្មនេះទៅរដ្ឋភាគី ដោយស្នើសុំឱ្យបញ្ជាក់ប្រាប់ថាតើ ពួកគេយល់ព្រមឱ្យមានកិច្ចប្រជុំនៃរដ្ឋភាគីទាំងអស់ ក្នុងគោលបំណងពិនិត្យ និងសម្រេចលើសេចក្តីស្នើសុំឬទេ។ ក្នុងករណីមានសំឡេងមួយភាគបីយ៉ាងតិច នៃរដ្ឋភាគី ប្រកាសយល់ព្រមឱ្យមានកិច្ចប្រជុំ ក្នុងរយៈពេលបួនខែនៃកាលបរិច្ឆេទនៃការប្រាស្រ័យទាក់ទងបែបនេះ អគ្គលេខាធិការ ត្រូវកោះឱ្យមានកិច្ចប្រជុំនោះ ក្រោមការជួយឧបត្ថម្ភពីអង្គការសហប្រជាជាតិ។ វិសោធនកម្មណាមួយដែលត្រូវបានអនុម័តដោយមតិភាគច្រើនពីរភាគបីនៃរដ្ឋភាគី ដែលមានវត្តមាន

និងធ្វើការបោះឆ្នោត ត្រូវដាក់ជូនមហាសន្និបាត ដោយអគ្គលេខាធិការដើម្បីសុំការយល់ព្រម និងបន្ទាប់មកត្រូវដាក់ជូនរដ្ឋភាគីទាំងអស់ ដើម្បីឱ្យមានការទទួលស្គាល់។

២. វិសោធនកម្មដែលត្រូវបានអនុម័ត និងយល់ព្រម អនុលោមតាមកថាខ័ណ្ឌទី១ នៃមាត្រានេះ ត្រូវចូលជាធរមាននៅថ្ងៃទី៣០ បន្ទាប់ពីលិខិតុបករណ៍នៃការទទួលស្គាល់ដែលត្រូវបានតម្កល់នៅនឹងអគ្គលេខាធិការ មានចំនួនកើនដល់២ភាគ៣នៃរដ្ឋភាគី ដែលមានវត្តមាននៅកាលបរិច្ឆេទនៃការអនុម័តវិសោធនកម្មនោះ។ បន្ទាប់ពីនោះ វិសោធនកម្មនេះ ត្រូវចូលជាធរមានសម្រាប់រដ្ឋភាគីមួយ នៅថ្ងៃទី៣០ បន្ទាប់ពីការតម្កល់លិខិតុបរកណ៍នៃការទទួលស្គាល់របស់ខ្លួន។ វិសោធនកម្មត្រូវមានប្រសិទ្ធភាពអនុវត្តបាន ចំពោះតែរដ្ឋភាគីណា ដែលបានយល់ព្រមទទួលយកតែប៉ុណ្ណោះ។

## មាត្រា ២២

## ការប្រកាសដកខ្លួន

១. រដ្ឋភាគីណាក៏ដោយ អាចប្រកាសដកខ្លួនពីពិធីសារនេះ នៅពេលណាក៏បាន ដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។ ការប្រកាសដកខ្លួននេះ មានប្រសិទ្ធភាព មួយឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទដែលអគ្គលេខាធិការ ទទួលបានសេចក្ដីជូនដំណឹងនេះ។

២. ការប្រកាសដកខ្លួននេះ នឹងមិនធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តជាបន្ត នៃបទប្បញ្ញត្តិរបស់ពិធីសារនេះ ចំពោះបណ្ដឹងណាមួយដែលបានស្នើឡើងក្រោមមាត្រា៥ ឬមាត្រា១២ ឬការស៊ើបសួរណាមួយដែលបានផ្ដួចផ្ដើមធ្វើក្រោមមាត្រា១៣ នៅមុនកាលបរិច្ឆេទចូលជាធរមាននៃការប្រកាសដកខ្លួននេះទេ។

## មាត្រា ២៣

## *ការតម្កល់ទុក និងការជូនដំណឹងដោយអគ្គលេខាធិការ*

១. អគ្គលេខាធិការអង្គការសហប្រជាជាតិ គឺជាកន្លែងតម្កល់ទុកនៃពិធីសារនេះ។

២. អគ្គលេខាធិការត្រូវជូនដំណឹងទៅរដ្ឋទាំងអស់អំពី៖

ក. ការចុះហត្ថលេខា ការផ្តល់សច្ចាប័ន និងការចូលជាសមាជិក ស្របតាមពិធីសារនេះ។

ខ. កាលបរិច្ឆេទនៃការចូលជាធរមាននៃពិធីសារនេះ និងការធ្វើវិសោធនកម្មណាមួយនៃពិធីសារនេះ ស្របតាមមាត្រា២១។

គ. ការប្រកាសដកខ្លួនណាមួយ ស្របតាមមាត្រា២២ នៃពិធីសារនេះ។

## មាត្រា ២៤

## *ភាសា*

១. ពិធីសារនេះ ដែលមានអត្ថបទជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ មានតម្លៃយថាភូតស្មើគ្នា និងត្រូវតម្កល់ទុកនៅបណ្ណសារដ្ឋាននៃអង្គការសហប្រជាជាតិ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនសេចក្តីចម្លងនៃពិធីសារនេះ ដោយមានបញ្ជាក់ការចម្លងត្រឹមត្រូវតាមច្បាប់ដើមនៃពិធីសារនេះ ជូនរដ្ឋភាគីទាំងអស់៕

# អនុសញ្ញា ស្តីពី សិទ្ធិជនពិការ
# និង
# ពិធីសារបន្ថែម

អនុសញ្ញាជាភាសាខ្មែរនេះ ត្រូវបានពិនិត្យកែប្រែឡើងវិញ
ដោយសមាជិកក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី

## ១៣-អនុសញ្ញាស្តីពីសិទ្ធិជនពិការ

ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៦
និងចូលជាធរមានកាលពីថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០៨ ស្របតាមមាត្រា៤៥(១)
កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញានេះ កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២

# បុព្វកថា

**រដ្ឋភាគីនៃអនុសញ្ញានេះ ៖**

ក- *ដោយរំលឹកឡើងវិញពី*គោលការណ៍ទាំងឡាយដែលមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ ដែលទទួលស្គាល់សេចក្តីថ្លៃថ្នូរ និងតម្លៃ ហើយនឹងសិទ្ធិស្មើគ្នា ដែលមិនអាចលក់ដូរបាន ដែលមានពីកំណើតនៃសមាជិកគ្រប់រូបក្នុងសង្គមមនុស្ស គឺជាគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពក្នុងពិភពលោក ។

ខ- *ដោយទទួលស្គាល់ថា* តាមសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស អង្គការសហប្រជាជាតិបានប្រកាស និងបានយល់ព្រមថា មនុស្សគ្រប់រូប មានសិទ្ធិទទួលបានសិទ្ធិ និងសេរីភាពគ្រប់បែបយ៉ាង ដូចដែលមានចែងក្នុងសេចក្តីប្រកាសជាសកល និងក្នុងកតិកាសញ្ញាអន្តរជាតិទាំងនេះ ដោយគ្មានការបែងចែកនៃប្រភេទណាមួយឡើយ។

គ- *ដោយគូសបញ្ជាក់ឡើងវិញថា* សកលភាព ភាពមិនអាចបំបែកបាន ភាពពំនាក់អាស្រ័យគ្នា និងភាពទាក់ទងគ្នានៃសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់ ព្រមទាំងសេចក្តីត្រូវការរបស់ជនពិការ ត្រូវបានធានាយ៉ាងពេញលេញដោយគ្មានការរើសអើង ។

ឃ- *ដោយរំលឹកឡើងវិញពី* កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទំរង់នៃការប្រកាន់ពូជសាសន៍ អនុសញ្ញាអន្តរជាតិ ស្តីពី ការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ

អនុសញ្ញាស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មផ្សេងទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក អនុសញ្ញាស្តីពីសិទ្ធិកុមារ និងអនុសញ្ញាអន្តរជាតិ ស្តីពី ការការពារសិទ្ធិរបស់កម្មករទេសន្តប្រវេសន៍ទាំងអស់ និងសមាជិកគ្រួសាររបស់ពួកគេ។

ង- *ដោយទទួលស្គាល់ថា* ពិការភាពគឺជាទស្សនទានដែលមានការវិវត្ត ហើយពិការភាព កើតចេញពីអន្តរកម្មរវាងជនពិការ និងឧបសគ្គទាំងឡាយទាក់ទងទៅនឹងអាកប្បកិរិយា និងបរិយាកាសជុំវិញ ដែលរារាំងពួកគេមិនឱ្យចូលរួមក្នុងសង្គមបានពេញលេញ និងប្រកបដោយប្រសិទ្ធភាព ដោយឈរលើមូលដ្ឋានស្មើភាពជាមួយអ្នកដទៃ។

ច- *ដោយទទួលស្គាល់ពី* សារៈសំខាន់នៃគោលការណ៍ និងសេចក្តីណែនាំពីគោលនយោបាយ ដែលមាននៅក្នុងកម្មវិធីសកម្មភាពពិភពលោកទាក់ទងនឹងជនពិការ និងនៅក្នុងវិធានបមាណីនានាស្តីពីការផ្តល់ឱកាសស្មើៗគ្នា ដល់ជនពិការដើម្បីបញ្ចុះបញ្ចូលជំរុញ បង្កើត និងវាយតំលៃគោលនយោបាយ ផែនការកម្មវិធី និងសកម្មភាពផ្សេងៗនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងលើឆាកអន្តរជាតិ ដើម្បីផ្តល់ឱកាសឱ្យបានស្មើៗគ្នាថែមទៀតដល់ជនពិការ។

ឆ- *ដោយគូសបញ្ជាក់បន្ថែមពី* សារៈសំខាន់នៃការបញ្ចូលបញ្ហាពិការភាព ឲ្យទៅជាផ្នែកមួយពេញលេញនៃយុទ្ធសាស្ត្រពាក់ព័ន្ធនានា ក្នុងការអភិវឌ្ឍប្រកបដោយនិរន្តភាព។

ជ- *ដោយទទួលស្គាល់ផងដែរថា* ការរើសអើងប្រឆាំងនឹងបុគ្គលណាម្នាក់ ដោយសារតែពិការភាព គឺជាការរំលោភលើសេចក្តីថ្លៃថ្នូរ និងតំលៃរបស់មនុស្សដែលមានពីកំណើត។

ឈ- *ដោយទទួលស្គាល់បន្ថែមទៀត* ពីពិការភាពផ្សេងគ្នារបស់ជនពិការ។

ញ- *ដោយទទួលស្គាល់ពី*តម្រូវការលើកស្ទួយ និងការពារសិទ្ធិមនុស្ស របស់ជនពិការគ្រប់រូប រួមទាំងអ្នកទាំងឡាយណាដែលត្រូវការគាំពារកម្រិតខ្ពស់។

ដ- *ដោយមានការបារម្ភថា* បើទោះជាមានឧបករណ៍ និងការធានារ៉ាប់រងផ្សេងៗយ៉ាងនេះក្តី ក៏ជនពិការនៅតែបន្តប្រឈមមុខនឹងឧបសគ្គក្នុងការចូលរួមរបស់គេដោយស្មើភាពគ្នា ជាមួយសមាជិកឯទៀតក្នុងសង្គម និងការរំលោភសិទ្ធិមនុស្សរបស់ពួកគេនៅទូទាំងពិភពលោក។

ឋ- *ដោយទទួលស្គាល់ពី* សារៈសំខាន់នៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីលើកកម្ពស់ស្ថានភាពរស់នៅរបស់ជនពិការនៅគ្រប់ប្រទេស ជាពិសេស នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍។

ឌ- *ដោយទទួលស្គាល់ពី* វិភាគទានដ៏មានតំលៃ និងមានសក្តានុពលរបស់ជនពិការ ចំពោះសុខុមាលភាពទាំងស្រុង និងភាពប្លែកៗគ្នានៃសហគមន៍របស់ខ្លួន និងការលើកស្ទួយជនពិការឱ្យទទួលបានពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តនិងការចូលរួមយ៉ាងពេញលេញរបស់ពួកគេក្នុងសង្គម សម្រេចបានជាលទ្ធផល គឺការលើកកម្ពស់សតិអារម្មណ៍របស់ជនពិការ ថាខ្លួនជាផ្នែកមួយនៃសង្គម និងភាពជឿនលឿនដ៏មានខ្លឹមសារក្នុងការអភិវឌ្ឍន៍មនុស្ស សង្គមកិច្ច និងសេដ្ឋកិច្ច និងការលុបបំបាត់ភាពក្រីក្រ។

ឍ- *ដោយទទួលស្គាល់ពី* សារៈសំខាន់នៃស្វ័យភាពជាឯកត្តបុគ្គល និងឯករាជ្យភាពរបស់ជនពិការម្នាក់ៗ រួមទាំងសេរីភាព ក្នុងការមានជំរើសរបស់ខ្លួនផ្ទាល់។

ណ- *ដោយយល់ឃើញថា* ជនពិការ គួរតែមានឱកាសចូលរួមយ៉ាងសកម្ម ក្នុងដំណើរការធ្វើសេចក្តីសម្រេចអំពីគោលនយោបាយ និងកម្មវិធីនានា រួមទាំងកិច្ចការ ដែលពាក់ព័ន្ធនឹងបញ្ហារបស់ពួកគេផ្ទាល់។

ត- *ដោយមានក្តីកង្វល់អំពី* ស្ថានភាពលំបាកដែលជនពិការ បានជួបប្រទះ នូវការរើសអើងជាច្រើន ឬការរើសអើងដែលមានទម្រង់ធ្ងន់ធ្ងរ ដែលឈរ

លើមូលដ្ឋាននៃការប្រកាន់ពូជសាសន៍ ពណ៌ សម្បុរ ភេទ ភាសា សាសនា គំនិតនយោបាយ ឬទស្សនៈផ្សេងទៀត ជាតិ ជាតិពន្ធុ ប្រភពដើមជនជាតិ និងសង្គម ទ្រព្យសម្បត្តិ ដើមកំណើត អាយុ ឬឋានៈផ្សេងៗទៀត។

ថ- *ដោយទទួលស្គាល់ថា* ស្ត្រីនិងកុមារីពិការតែងតែជួបប្រទះ នូវភយន្តរាយធំជាងគេ ទាំងនៅក្នុង និងក្រៅផ្ទះ ដូចជាអំពើហឹង្សា ការបង្ករបួសស្នាម ឬការបំពាន ការមិនអើពើ ឬការមិនស្និទ្ធស្នាល អំពើធ្វើទុក្ខបុកម្នេញ ឬការកេងប្រវ័ញ្ច។

ទ- *ដោយទទួលស្គាល់ថា* កុមារពិការ គួរតែបានទទួលយ៉ាងពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយកុមារដទៃ និង*ដោយរំលឹកឡើងវិញពី* កាតព្វកិច្ចដែលត្រូវសម្រេចឱ្យបាននូវគោលដៅទាំងនេះរបស់ រដ្ឋភាគីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

ធ- *ដោយគូសបញ្ជាក់ពី* តម្រូវការ ដើម្បីដាក់បញ្ចូលទស្សនៈវិស័យផ្នែកយេនឌ័រទៅក្នុងកិច្ចខិតខំប្រឹងប្រែងទាំងអស់ ដើម្បីលើកស្ទួយជនពិការឱ្យទទួលបានពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្ត។

ន- *ដោយគូសបញ្ជាក់ពី*ភាពជាក់ស្តែងដែលថា ជនពិការភាគច្រើនរស់នៅក្នុងស្ថានភាពក្រីក្រ ហើយជាមួយនឹងស្ថានភាពបែបនេះ*ដោយទទួលស្គាល់ពី* តម្រូវការដ៏សំខាន់ ក្នុងការលើកឡើងពីផលប៉ះពាល់ជាអវិជ្ជមាននៃភាពក្រីក្រដល់ជនពិការ។

ប- *ដោយចងចាំថា* លក្ខខណ្ឌនៃសន្តិភាព និងសន្តិសុខ ផ្អែកលើមូលដ្ឋាននៃការគោរពយ៉ាងពេញលេញនូវគោលបំណង និងគោលការណ៍ដែលមានចែងនៅក្នុងធម្មនុញ្ញសហប្រជាជាតិ និងការប្រតិបត្តិតាមលិខិតុបករណ៍សិទ្ធិមនុស្សដែលនៅមានជាធរមាន គឺជាប្រការសំខាន់ និងខានមិនបាន ដើម្បីការការពារឱ្យបានពេញលេញដល់ជនពិការ ជាពិសេស នៅពេលមានជំលោះប្រដាប់អាវុធ និងការចូលកាន់កាប់របស់បរទេស។

ផ- *ដោយទទួលស្គាល់ពី* សារៈសំខាន់នៃការទទួលបាននូវការសម្រួលដល់បរិយាកាសផ្នែកវប្បធម៌ សេដ្ឋកិច្ច សង្គមកិច្ច កាយសម្បទា សុខភាព ការអប់រំ និងព័ត៌មាននិងទំនាក់ទំនង ដើម្បីជួយឱ្យជនពិការអាចទទួលបានយ៉ាងពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់។

ព- *ដោយយល់ច្បាស់ថា* បុគ្គលម្នាក់ៗដែលមានកាតព្វកិច្ចចំពោះអ្នកដទៃ និងចំពោះសហគមន៍របស់ខ្លួន ត្រូវមានការទទួលខុសត្រូវ ដើម្បីខិតខំប្រឹងប្រែងក្នុងការលើកស្ទួយ និងការប្រតិបត្តិ តាមសិទ្ធិទាំងឡាយ ដែលមានចែងនៅក្នុងធម្មនុញ្ញអន្តរជាតិស្តីពីសិទ្ធិមនុស្ស។

ភ- *ដោយមានជំនឿថា* គ្រួសារ គឺជាធាតុបង្កពីធម្មជាតិ ជាមូលដ្ឋាននៃសង្គម ហើយមានសិទ្ធិទទួលបាននូវការការពារពីសង្គម និងរដ្ឋ ហើយជនពិការ និងសមាជិកក្រុមគ្រួសាររបស់គេ គួរទទួលបានការការពារ និងការជួយជ្រោមជ្រែងជាចាំបាច់ ដើម្បីឱ្យក្រុមគ្រួសារគេ អាចចូលរួមចំណែកធ្វើឱ្យជនពិការ ទទួលបានសិទ្ធិដោយស្មើភាពគ្នា និងដោយពេញលេញ។

ម- *ដោយមានជំនឿថា* អនុសញ្ញាអន្តរជាតិទាំងមូល និងគ្រប់ជ្រុងជ្រោយមួយ ដើម្បីការពារ និងលើកស្ទួយសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ជនពិការ នឹងរួមវិភាគទានយ៉ាងថ្លៃថ្លា ក្នុងការកែតម្រូវគុណវិបត្តិសង្គមដ៏ជ្រាលជ្រៅ ចំពោះជនពិការ និងលើកស្ទួយជនពិការឱ្យមានឱកាសស្មើគ្នា ក្នុងការចូលរួមលើវិស័យពាក់ព័ន្ធដល់សិទ្ធិពលរដ្ឋ នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ទាំងក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងបណ្តាអារ្យប្រទេស។

**បានព្រមព្រៀងគ្នាដូចតទៅៈ**

### មាត្រា១ :គោលបំណង

គោលបំណងនៃអនុសញ្ញានេះ គឺដើម្បីលើកស្ទួយ ការពារ និងធានាឱ្យជនពិការ ទទួលបានដោយពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់ និងដើម្បីលើកស្ទួយការគោរពសេចក្តីថ្លៃថ្នូរដែលមានពីកំណើតមករបស់ជនពិការ។

ជនពិការសំដៅលើអ្នកទាំងឡាយដែលមានភាពអន់ខ្សោយរយៈពេលយូរផ្នែកកាយសម្បទា ផ្លូវចិត្ត ប្រាជ្ញា ឬវិញ្ញាណដែលនៅពេលជួបប្រទះជាមួយឧបសគ្គនានា អាចរារាំងពួកគេ មិនឱ្យមានការចូលរួមយ៉ាងពេញលេញ និងមានប្រសិទ្ធភាពក្នុងសង្គម ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ។

### មាត្រា២ : និយមន័យ

សំរាប់គោលបំណងនៃអនុសញ្ញានេះ៖

- "*ទំនាក់ទំនង*" រាប់បញ្ចូលទាំងភាសា ការបង្ហាញជាអត្ថបទ អក្សរស្ទាបទំនាក់ទំនងដោយការស្ទាប ការបោះពុម្ពជាអក្សរធំៗ ការអាចទទួលបានប្រព័ន្ធពហុព័ត៌មាន ព្រមទាំងសំណេរ ខ្សែអាត់សំលេង ភាសាសាមញ្ញៗ ឧបករណ៍បកស្រាយទិន្នន័យព័ត៌មានអំពីមនុស្ស និងវិធីសម្រាប់តម្លើង និងជំនួសផ្សេងៗ មធ្យោបាយ និងទម្រង់នានានៃការទំនាក់ទំនង រួមទាំងព័ត៌មានដែលអាចទទួលបាន និងបច្ចេកវិទ្យាទំនាក់ទំនង។

- "*ភាសា*" រួមបញ្ចូលទាំងភាសានិយាយ ភាសាសញ្ញា និងទំរង់ផ្សេងទៀតនៃភាសាដែលមិនប្រើក្នុងការនិយាយ។

- "*ការរើសអើងដោយសារពិការភាព*" មានន័យថា ការបែងចែក ការផាត់ចេញ ឬការដាក់កំហិតណាមួយ ដោយសារតែពិការភាព ដែលមានគោលបំណង ឬមានអានុភាពធ្វើឱ្យចុះទន់ខ្សោយ ឬលុបបំបាត់ការទទួលស្គាល់ ការទទួលបាន ឬប្រើប្រាស់នូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ ក្នុងវិស័យនយោបាយ សេដ្ឋកិច្ចសង្គមកិច្ច វប្បធម៌ ពលរដ្ឋ ឬក្នុងវិស័យផ្សេងៗទៀត។ ការរើសអើងនេះ រាប់បញ្ចូលរាល់ទម្រង់នៃការរើសអើង រួមទាំងការបដិសេធនូវដំណោះស្រាយដ៏សមហេតុផលផង។

- "*ដំណោះស្រាយដ៏សមហេតុផល*" មានន័យថាការកែឱ្យសមរម្យ និងចាំបាច់ និងការកែតម្រូវ ដែលមិនបង្ខំឱ្យការទទួលខុសត្រូវមានភាពវិសមាមាត្រ ឬ

មិនត្រឹមត្រូវ ដែលមានភាពចាំបាច់តែក្នុង ករណីពិសេស ដើម្បីធានាដល់ជនពិការឱ្យទទួលបាន និងប្រើប្រាស់បាននូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ។

-"*ការរចនាជាសកល*" មានន័យថាការរចនាផលិតផល បរិស្ថាន កម្មវិធី និងសេវាកម្មផ្សេងៗ ដែលមនុស្សគ្រប់រូប អាចប្រើប្រាស់បាន ដោយមិនទាមទារការសម្របតាម ឬការរចនាពិសេសផ្សេងទៀត ក្នុងវិសាលភាពធំបំផុត ដែលអាចធ្វើបាន។ "*ការរចនាជាសកល*" មិនត្រូវផាត់ចោលឧបករណ៍ ជំនួយទាំងឡាយសំរាប់ក្រុមជនពិការពិសេស ដែលត្រូវការឧបករណ៍ជំនួយទាំងនេះឡើយ។

### មាត្រា៣ : គោលការណ៍ទូទៅ

គោលការណ៍ទូទៅនៃអនុសញ្ញានេះមានដូចជា៖

ក. ការគោរពសេចក្តីថ្លៃថ្នូរដែលមានពីកំណើត ស្វ័យភាពបុគ្គល រួមទាំងសេរីភាពក្នុងការជ្រើសរើសដោយខ្លួនឯងផ្ទាល់ និងឯករាជ្យភាពរបស់បុគ្គល។

ខ. ការមិនរើសអើង។

គ. ការចូលរួមយ៉ាងពេញលេញ និងមានប្រសិទ្ធភាព និងការដាក់បញ្ចូលទៅក្នុងសង្គម។

ឃ. ការគោរពភាពខុសៗគ្នានៃជនពិការ និងការទទួលយកជន ពិការជាចំណែកនៃភាពចំរុះគ្នា របស់មនុស្ស និងមនុស្សជាតិ។

ង. ឱកាសស្មើភាពគ្នា។

ច. ការបង្កលក្ខណៈងាយស្រួលដល់ជនពិការ។

ឆ. សមភាពរវាងបុរស និងស្ត្រី។

ជ. ការគោរពសមត្ថភាពរីកចំរើនរបស់កុមារពិការ និងការគោរពសិទ្ធិកុមារពិការ ដើម្បីរក្សានូវអត្តសញ្ញាណរបស់ពួកគេ។

## មាត្រា៤ : កាតព្វកិច្ចទូទៅ

១- រដ្ឋភាគីត្រូវធានា និងលើកស្ទួយសមិទ្ធិពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់សំរាប់ជនពិការ ដោយគ្មានការរើសអើងចំពោះពិការភាពណាមួយឡើយ។ ដើម្បីសម្រេចបាននូវគោលដៅនេះ រដ្ឋភាគីត្រូវរ៉ាប់រង៖

ក. អនុម័តរាល់វិធានការផ្លូវច្បាប់ រដ្ឋបាល និងវិធានការដទៃទៀតដែលសមស្រប ដើម្បីអនុវត្តនូវសិទ្ធិទាំងឡាយ ដែលត្រូវបានទទួលស្គាល់ នៅក្នុងអនុសញ្ញានេះ។

ខ. ចាត់រាល់វិធានការសមស្រប រួមទាំងវិធានការផ្នែកនីតិកម្ម ដើម្បីកែប្រែ ឬលុបចោលច្បាប់ បទបញ្ជា ទំនៀមទំលាប់ និងការអនុវត្តន៍ជាក់ស្តែងដែលនៅជាធរមាន ហើយដែលបង្កើតការរើសអើង ប្រឆាំងនឹងជនពិការ។

គ. យកចិត្តទុកដាក់ដល់ការការពារ និងការលើកស្ទួយសិទ្ធិមនុស្សរបស់ជនពិការនៅរាល់គោលនយោបាយនិងកម្មវិធីទាំងអស់.

ឃ. ទប់ស្កាត់ពីការចូលរួមក្នុងអំពើ ឬការអនុវត្តន៍ជាក់ស្តែងណាមួយដែលគ្មានសង្គតភាពជាមួយនឹងអនុសញ្ញានេះ ហើយធានាថា អាជ្ញាធរ និងស្ថាប័នសារធារណ:នានា អនុវត្តស្របតាមអនុសញ្ញានេះ។

ង. ចាត់រាល់វិធានការសមស្របដើម្បីលប់បំបាត់ការរើសអើង ដោយសារតែពិការភាពពីបុគ្គលណាម្នាក់ ពីអង្គការ ឬស្ថាប័នឯកជនណាមួយ។

ច. ព្យាយាម ឬលើកស្ទួយការស្រាវជ្រាវ និងអភិវឌ្ឍន៍ការរចនាសកលនូវទំនិញ សេវាកម្ម សំភារ:និងគ្រឿងបរិក្ខារ ដូចមានចែងក្នុងមាត្រា២នៃអនុសញ្ញានេះ ដែលគួរតែតម្រូវឲ្យមានការសម្រប តាមជាអប្បបរមាតាមតែអាចធ្វើបាន និងមានតំលៃថោក ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ជនពិការ ក្នុងបំណងលើកស្ទួយការប្រើប្រាស់ និងភាពអាចរកបាន នូវរបស់ទាំងអស់ខាងលើនេះ និងដើម្បីលើកស្ទួយការរចនាសកល ក្នុងការរៀបចំបមាណី និងគោលការណ៍ណែនាំ។

ឆ. ព្យាយាម ឬលើកស្ទួយការស្រាវជ្រាវ ការអភិវឌ្ឍន៍ ការប្រើប្រាស់ និងភាពអាចរកបាននៃបច្ចេកវិទ្យាថ្មីៗ រួមទាំងបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង ជំនួយចល័ត ឧបករណ៍ និងបច្ចេកវិទ្យា ជំនួយដែលសមស្របសំរាប់ជនពិការ ដោយផ្តល់អាទិភាពទៅបច្ចេក វិទ្យាដែលមានតម្លៃសមរម្យ។

ជ. ផ្តល់ឱ្យជនពិការ នូវលទ្ធភាពទទួលបានព័ត៌មាន អំពីជំនួយចល័ត ឧបករណ៍ និងបច្ចេកវិទ្យាជំនួយ រួមទាំងបច្ចេកវិទ្យាថ្មីៗ ព្រមទាំងទម្រង់ផ្សេងៗទៀតនៃជំនួយ សំភារៈ និងសេវាកម្មជួយគាំពារ ដទៃទៀត។

ឈ. លើកស្ទួយដល់ការបណ្តុះបណ្តាលអ្នកមានវិជ្ជាជីវៈ និងបុគ្គលិកធ្វើការជាមួយជនពិការ ពីសិទ្ធិដែលត្រូវបានទទួលស្គាល់ក្នុងអនុសញ្ញានេះដើម្បីផ្តល់សេវាកម្ម និងជំនួយឱ្យកាន់តែប្រសើរថែមទៀត ដែលត្រូវបានធានាដោយសិទ្ធិទាំងនោះ។

២- ចំពោះសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ រដ្ឋភាគីត្រូវចាត់វិធានការឲ្យបានជាអតិបរមា តាមធនធានដែលខ្លួនមាន និងតាមការចាំបាច់ នៅក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងទស្សនៈសម្រេចឱ្យបានបន្តិចម្តងៗ និងពេញលេញនូវសិទ្ធិទាំងនេះ ដោយគ្មានធ្វើឱ្យខូចខាតដល់កាតព្វកិច្ចទាំងឡាយដែលមានចែងនៅក្នុងអនុសញ្ញានេះ ដែលនឹងត្រូវតែអនុវត្តភ្លាមៗ ស្របតាមច្បាប់អន្តរជាតិ។

៣- ក្នុងការអភិវឌ្ឍន៍ និងការអនុវត្តន៍ច្បាប់ និងគោលនយោបាយនានាដើម្បីអនុវត្តអនុសញ្ញានេះ និងក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចផ្សេងទៀតស្តីពីបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងជនពិការ រដ្ឋភាគីត្រូវពិគ្រោះយោបល់យ៉ាងជិតស្និទ និងយ៉ាងសកម្មជាមួយជនពិការដែលពាក់ព័ន្ធ រួមទាំងកុមារពិការ តាមរយៈអង្គការតំណាងរបស់ពួកគេ។

៤- គ្មានបទប្បញ្ញត្តិណាមួយនៅក្នុងអនុសញ្ញានេះ ត្រូវប៉ះពាល់ដល់បទបញ្ញត្តិណាមួយ ដែលសម្រួលច្រើនជាង ដល់ការសម្រេចបាននូវសិទ្ធិទាំងឡាយ

របស់ជនពិការ និងដែលអាចមានចែងនៅក្នុងច្បាប់របស់រដ្ឋភាគី ឬច្បាប់អន្តរជាតិ ដែលមាននៅជាធរមាន ចំពោះរដ្ឋនោះទេ។ មិនត្រូវមានការដាក់កំហិត ឬដកហូត សិទ្ធិណាមួយនៃសិទ្ធិមនុស្ស និងសេរីភាពជាសារវន្ត ដែលត្រូវបានទទួលស្គាល់ ឬ នៅមានជាធរមានក្នុងរដ្ឋភាគីណាមួយនៃអនុសញ្ញានេះទេ ដោយអនុលោមទៅ តាមច្បាប់ អនុសញ្ញានានា បទបញ្ជា ឬទំនៀមទំលាប់ ដោយយកលេសថា អនុសញ្ញានេះមិនទទួលស្គាល់សិទ្ធិ ឬសេរីភាពបែបនេះ ឬក៏ថា រដ្ឋភាគីនោះ ទទួលស្គាល់សិទ្ធិ និងសេរីភាពទាំងនេះ ក្នុងវិសាលភាពមួយតូចជាងនេះ។

៥- បទប្បញ្ញត្តិនៃអនុសញ្ញានេះ ត្រូវមានវិសាលភាពគ្របដណ្តប់ ដល់ផ្នែកទាំងអស់នៃរដ្ឋសហព័ន្ធ ដោយគ្មានការកំណត់ ឬការលើកលែងណាមួយឡើយ។

### មាត្រា៥ : សមតាព និងការមិនរើសអើង

១- រដ្ឋភាគីទាំងឡាយ ទទួលស្គាល់ថា មនុស្សទាំងអស់ ស្មើភាពគ្នា ចំពោះមុខច្បាប់ និងស្ថិតនៅក្រោមច្បាប់ ហើយមានសិទ្ធិទទួលបាន ដោយគ្មានការរើសអើងណាមួយ ដល់ការការពារស្មើគ្នា និងផលប្រយោជន៍នៃច្បាប់ស្មើគ្នា។

២- រដ្ឋភាគី ត្រូវហាមឃាត់រាល់ការរើសអើងដោយសារតែពិការភាព និងធានាដល់ជនពិការ នូវការការពារតាមផ្លូវច្បាប់ស្មើគ្នា និងមានប្រសិទ្ធភាព ប្រឆាំងនឹងការរើសអើងតាមគ្រប់រូបភាព។

៣- ដើម្បីលើកស្ទួយសមភាព និងលុបបំបាត់ការរើសអើង រដ្ឋភាគី ត្រូវចាត់រាល់វិធានការសមស្រប ដើម្បីធានានូវការផ្តល់ដំណោះស្រាយដ៏សមហេតុផល។

៤- វិធានការជាក់លាក់ដែលចាំបាច់ ដើម្បីបង្កើនល្បឿន ឬធ្វើឱ្យបានសម្រេចតាមព្រឹត្តិហេតុ នូវសមភាពរបស់ជនពិការ មិនត្រូវចាត់ទុកជាការរើសអើងតាមអត្ថន័យ ដែលមានចែងនៅក្នុងអនុ សញ្ញានេះទេ។

## មាត្រា៦ : ស្ត្រីពិការ

១- រដ្ឋភាគីទទួលស្គាល់ថា ស្ត្រីនិងកុមារីពិការ ងាយរងការរើសអើងច្រើនបែបយ៉ាងណាស់ ហើយចំពោះបញ្ហានេះ ត្រូវចាត់វិធានការនានា ដើម្បីធានាឱ្យពួកគេទទួលបានភាពស្មើគ្នា និងពេញលេញ នូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់។

២- រដ្ឋភាគីត្រូវចាត់រាល់វិធានការសមស្រប ដើម្បីធានាឱ្យស្ត្រីទទួលបានការអភិវឌ្ឍន៍ វឌ្ឍនភាព និងការផ្តល់សិទ្ធិអំណាចឱ្យបានពេញលេញ ក្នុងគោលបំណងដើម្បីធានាពួកគេឱ្យអនុវត្ត និងទទួល បាននូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្ត ដូចមានចែងនៅក្នុងអនុសញ្ញានេះ។

## មាត្រា៧ : កុមារពិការ

១- រដ្ឋភាគី ត្រូវចាត់រាល់វិធានការចាំបាច់នានា ដើម្បីធានាឱ្យកុមារពិការទទួលបានដោយពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយកុមារផ្សេងទៀត។

២-នៅគ្រប់សកម្មភាពដែលទាក់ទងនឹងកុមារពិការ ឧត្តមប្រយោជន៍របស់កុមារពិការ ត្រូវលើកយកមកពិចារណាមុនគេ។

៣- រដ្ឋភាគីត្រូវធានាថា កុមារពិការមានសិទ្ធិបញ្ចេញមតិរបស់ខ្លួនដោយសេរី ពីបញ្ហាគ្រប់បែបយ៉ាង ដែលប៉ះពាល់ដល់ពួកគេ។ ទស្សនៈរបស់ពួកគេ ត្រូវទទួលបានការពិចារណា ថ្លឹងថ្លែងឱ្យបានសមស្របទៅនឹងអាយុ និងភាពចាស់ទុំរបស់ពួកគេ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយកុមារផ្សេងទៀត ហើយពួកគេត្រូវទទួលបានការជួយជ្រោមជ្រែងសមស្របទៅនឹងពិការភាព និងអាយុរបស់ពួកគេ ដើម្បីឱ្យពួកគេទទួលបានសិទ្ធិនេះយ៉ាងពិតប្រាកដ។

## មាត្រា៨ : ការលើកកម្ពស់ការយល់ដឹង

១- រដ្ឋភាគីត្រូវអនុម័តជាបន្ទាន់នូវវិធានការសមស្រប និងមានប្រសិទ្ធភាពដូចខាងក្រោម៖

ក. លើកកម្ពស់ការយល់ដឹងអំពីជនពិការ ក្នុងសង្គមជាតិទាំងមូល រួមទាំងនៅតាមគ្រួសារ និងលើកតម្កើងការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ជនពិការ។

ខ. ប្រយុទ្ធប្រឆាំងនឹងការរើសអើង ការប្រកាន់ពូជសាសន៍ និងការប្រព្រឹត្តមិនសមរម្យផ្សេងៗ ដល់ជនពិការ រួមទាំងសកម្មភាពរើសអើងទាំងឡាយ ទាក់ទងនឹងភេទ និងអាយុ ក្នុងគ្រប់ទិដ្ឋភាពនៃជីវិត។

គ. លើកស្ទួយការយល់ដឹងពីសមត្ថភាព និងការរួមវិភាគទាន ដល់ជនពិការ។

២- វិធានការទាំងឡាយ ដើម្បីសម្រេចបាននូវគោលបំណងនេះ រួមមាន៖

ក. ផ្តួចផ្តើមនិងថែរក្សាយុទ្ធនាការដើម្បីបង្កើនការយល់ដឹងជាសាធារណៈប្រកបដោយប្រសិទ្ធភាព ដែលត្រូវបានរចនាឡើងសម្រាប់៖

i) លើកទឹកចិត្តដល់ការចង់យល់ដឹង និងទទួលគាំទ្រសិទ្ធិជនពិការឱ្យបានយល់ដឹង និងទទួលការគាំទ្រ។

ii) លើកស្ទួយការយល់ឃើញជាវិជ្ជមាន និងការយល់ដឹងពីសង្គមកាន់តែទូលាយ ចំពោះជនពិការ។

iii) លើកស្ទួយការទទួលស្គាល់ជំនាញ គុណសម្បត្តិ និងលទ្ធភាពរបស់ជនពិការ និងទទួលស្គាល់ការរួមវិភាគទានរបស់ជនពិការ នៅទីកន្លែងធ្វើការ និងនៅទីផ្សារការងារ។

ខ. លើកតម្កើងនៅគ្រប់កម្រិតនៃប្រព័ន្ធអប់រំ រួមទាំងកុមារដែលមានអាយុក្មេងខ្ចីទាំងអស់ នូវឥរិយាបទចេះគោរពសិទ្ធិរបស់ជនពិការ។

គ. ជំរុញគ្រប់ស្ថាប័នព័ត៌មាន ឱ្យផ្សព្វផ្សាយពីជនពិការក្នុងលក្ខណៈមួយស្របទៅតាមគោលបំណងនៃអនុសញ្ញានេះ។

ឃ. លើកស្ទួយ កម្មវិធីបណ្តុះបណ្តាល ការយល់ដឹងអំពីជនពិការ និងសិទ្ធិរបស់ជនពិការ។

## មាត្រា៩ ៖ ការបង្កលក្ខណៈងាយស្រួល

១- ដើម្បីជួយជនពិការឱ្យរស់នៅដោយឯករាជ្យ និងចូលរួមយ៉ាងពេញលេញក្នុងគ្រប់ទិដ្ឋភាពនៃជីវិត រដ្ឋភាគីត្រូវចាត់វិធានការសមស្រប ដើម្បីធានាដល់ជនពិការ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកផ្សេងទៀត ទទួលបាននូវបរិស្ថានជុំវិញខ្លួនមធ្យោបាយធ្វើដំណើរ ព័ត៌មាននិងទំនាក់ទំនង រួមទាំងប្រព័ន្ធនិងបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង គ្រឿងបរិក្ខារ និងសេវាកម្មផ្សេងទៀត ដែលបើក ឬផ្ដល់ឱ្យប្រើប្រាស់ជាសាធារណៈ ទាំងនៅទីក្រុង ទាំងនៅតាមទីជនបទ។ ដោយត្រូវរួមបញ្ចូលនូវអត្តសញ្ញាណ និងការលុបបំបាត់ឧបសគ្គ និងរបាំងទាំងឡាយដល់ការទទួលបានសិទ្ធិទាំងនេះ វិធានការទាំងនេះត្រូវអនុវត្តចំពោះ៖

ក. អាគារ ផ្លូវថ្នល់ មធ្យោបាយធ្វើដំណើរ និងគ្រឿងបរិក្ខារក្នុងផ្ទះ និងក្រៅផ្ទះផ្សេងទៀត រួមទាំងសាលារៀន លំនៅដ្ឋាន គ្រឹះស្ថានសុខាភិបាល និងកន្លែងការងារ។

ខ. ព័ត៌មាន ទំនាក់ទំនង និងសេវាកម្មដទៃទៀត រួមទាំងសេវាកម្មអេឡិចត្រូនិច និងសេវាកម្មសង្គ្រោះបន្ទាន់។

២- រដ្ឋភាគី ត្រូវចាត់វិធានការសមស្របផងដែរដើម្បី៖

ក. តាក់តែង ប្រកាសឱ្យប្រើ និងតាមដានការអនុវត្តន៍គោលការណ៍ណែនាំ និងបទដ្ឋានអប្បបរមា សំរាប់ការទទួលបាននូវគ្រឿងបរិក្ខារ និងសេវាកម្មដែលបើក និងផ្ដល់ឱ្យសាធារណជន។

ខ. ធានាថាអង្គភាពឯកជនដែលផ្ដល់សេវាកម្មនិងគ្រឿងបរិក្ខារដែលបើក ឬផ្ដល់ឱ្យសាធារណជន ត្រូវពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយ ពីការបង្កលក្ខណៈងាយស្រួលដល់ជនពិការ។

គ. ផ្ដល់ការបណ្ដុះបណ្ដាល ដល់អ្នកពាក់ព័ន្ធ ពីបញ្ហាពាក់ព័ន្ធនឹងការបង្កលក្ខណៈងាយស្រួល ដែលជនពិការកំពុងជួបប្រទះ។

ឃ. ដាក់ស្លាកសញ្ញា ជាអក្សរស្ទាប និងជាទំរង់ងាយអាន ងាយយល់ នៅតាមអគារ និងទីកន្លែងសាធារណៈដទៃទៀត។

ង. ផ្តល់ទម្រង់នៃជំនួយផ្ទាល់ និងអន្តរការី រួមបញ្ចូល អ្នកនាំផ្លូវ អ្នកជំនាញអាន និងអ្នកបកប្រែភាសាសញ្ញាអាជីព ដើម្បីបង្កភាពងាយស្រួលដល់ការប្រើប្រាស់អគារ និងទីកន្លែងសាធារណៈផ្សេងទៀតបាន។

ច. លើកស្ទួយទំរង់នៃការជួយ និងការគាំពារសមស្របដទៃទៀតដល់ជនពិការ ដើម្បីធានាថា ពួកគេទទួលបានព័ត៌មាន។

ឆ. លើកស្ទួយជនពិការ ឱ្យទទួលបានប្រព័ន្ធ និងបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនងថ្មីៗ រួមទាំងអ៊ិនធឺណេតផង។

ជ. លើកស្ទួយការរចនា ការអភិវឌ្ឍន៍ផលិតកម្ម និងការចែកចាយប្រព័ន្ធ និងបច្ចេកវិទ្យាព័ត៌មាន ដែលអាចទទួលបាន នៅដំណាក់ដំបូង ដូច្នេះប្រព័ន្ធ និងបច្ចេកវិទ្យាទាំងនេះ នឹងមានតម្លៃថោកល្មមអាចទទួលយកបាន។

## មាត្រា១០ : សិទ្ធិរស់រានមានជីវិត

រដ្ឋភាគីអះអាងជាថ្មីថា មនុស្សគ្រប់រូបមានសិទ្ធិរស់រានមានជីវិតចាប់តាំងពីកំណើតមក និងត្រូវចាត់វិធានការចាំបាច់ ដើម្បីធានាឱ្យជនពិការ ទទួលបានដោយប្រសិទ្ធភាព និងស្មើភាពគ្នាជា មួយអ្នកដទៃទៀតដែរ។

## មាត្រា១១ : ស្ថានភាពនៃហានិភ័យ និងស្ថានភាពបន្ទាន់ផ្នែកមនុស្សធម៌

អនុលោមតាមកាតព្វកិច្ចរបស់ខ្លួន តាមច្បាប់អន្តរជាតិ រួមទាំង ច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ រដ្ឋភាគីត្រូវចាត់វិធានការចាំបាច់ ដើម្បីធានាដល់ការការពារ និងសុវត្ថិភាពរបស់ជនពិការ ក្នុងស្ថានភាពនៃហានិភ័យ រួមទាំង ជំលោះប្រដាប់អាវុធ ស្ថានភាពបន្ទាន់ផ្នែកមនុស្សធម៌និងគ្រោះមហន្តរាយធម្មជាតិ។

## មាត្រា១២ : ការទទួលស្គាល់ពីភាពស្មើគ្នាចំពោះមុខច្បាប់

១- រដ្ឋភាគី អះអាងជាថ្មីថា ជនពិការ មានសិទ្ធិត្រូវបានទទួលស្គាល់នៅគ្រប់ទីកន្លែងទាំងអស់ ថា ជាមនុស្សនៅចំពោះមុខច្បាប់។

២- រដ្ឋភាគីត្រូវទទួលស្គាល់ថា ជនពិការមានសមត្ថភាពតាមផ្លូវច្បាប់ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកផ្សេងទៀត ក្នុងគ្រប់ទិដ្ឋភាពនៃឆាកជីវិត។

៣- រដ្ឋភាគី ត្រូវចាត់វិធានការសមស្របនានា ដើម្បីផ្តល់លទ្ធភាពឱ្យជនពិការ ទទួលបានការជួយឧបត្ថម្ភ ដែលពួកគេអាចត្រូវការក្នុងការអនុវត្តន៍សមត្ថភាពតាមផ្លូវច្បាប់របស់ពួកគេ។

៤- រដ្ឋភាគី ត្រូវធានាថា រាល់វិធានការដែលពាក់ព័ន្ធនឹងការអនុវត្តន៍សមត្ថភាពតាមផ្លូវច្បាប់ ផ្តល់នូវការការពារយ៉ាងសមរម្យ និងមានប្រសិទ្ធភាព ដើម្បីទប់ស្កាត់ការបំពាន អនុលោមតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ការការពារបែបនេះត្រូវធានាថា វិធានការទាំងឡាយ ដែលទាក់ទងនឹងការអនុវត្តន៍សមត្ថភាពតាមផ្លូវច្បាប់ គោរពសិទ្ធិ ឆន្ទៈ និងចំណង់ចំណូលចិត្តរបស់ជនពិការ ត្រូវបានរួចផុតពីទំនាស់ផលប្រយោជន៍និងឥទ្ធិពលមិនត្រឹមត្រូវ ត្រូវតែសមាមាត្រ និងបន្ថែមបន្ថយទៅតាមកាលៈទេសៈរបស់ជនពិការ អនុវត្តក្នុងរយៈពេលខ្លីបំផុត តាមដែលអាចធ្វើទៅបាន និងត្រូវបានពិនិត្យឡើងវិញជាទៀងទាត់ ដោយអាជ្ញាធរមានសមត្ថកិច្ចឯករាជ្យ និងមិនលំអៀងមួយ ឬស្ថាប័នតុលាការ។ ការការពារទាំងនេះ ត្រូវតែសមាមាត្រទៅនឹងកម្រិតដែលវិធានការបែបនេះ មានផលប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ជនពិការ។

៥- អនុលោមតាមបទបញ្ញត្តិនៃមាត្រានេះ រដ្ឋភាគី ត្រូវចាត់រាល់វិធានការសមស្រប និងមានប្រសិទ្ធភាព ដើម្បីធានាឱ្យជនពិការមានសិទ្ធិស្មើគ្នា ក្នុងការធ្វើជាម្ចាស់លើទ្រព្យសម្បត្តិ ឬទទួលមរតក ក្នុងការត្រួតពិនិត្យកិច្ចការហិរញ្ញវត្ថុផ្ទាល់ខ្លួនផ្សេងៗ និងមានសិទ្ធិស្មើគ្នាចំពោះការខ្ចីឥណទានធនាគារ ការបញ្ចាំ និងទម្រង់ផ្សេងៗទៀតនៃឥណទានហិរញ្ញវត្ថុ ហើយត្រូវធានាថា ជនពិការមិនត្រូវបានគេដកហូតយកទ្រព្យសម្បត្តិរបស់ពួកគេតាមអំពើចិត្តនោះទេ។

## មាត្រា១៣ ៖ សិទ្ធិទទួលបានសេវាកម្មយុត្តិធម៌

១- រដ្ឋភាគីត្រូវធានាពីសិទ្ធិទទួលបានសេវាយុត្តិធម៌ដែលមានប្រសិទ្ធភាព សំរាប់ជនពិការ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកផ្សេងទៀត រួមទាំងតាមរយៈបទប្បញ្ញត្តិនៃដំណោះស្រាយ សមស្របតាមអាយុ និងតាមនីតិវិធី ដើម្បីជួយសំរួលតួនាទីដ៏មានប្រសិទ្ធភាពរបស់ពួកគេ ទោះក្នុងនាមជាអ្នកចូលរួមដោយផ្ទាល់ ឬដោយប្រយោលក្តី រួមទាំងធ្វើជាសាក្សីនៅរាល់ចំណាត់ការរឿងក្តី រួមទាំងនៅដំណាក់កាលស៊ើបអង្កេតនិងដំណាក់កាលដំបូងៗផ្សេងទៀត។

២- ដើម្បីជួយធានាពីសិទ្ធិទទួលបានសេវាយុត្តិធម៌ដែលមានប្រសិទ្ធភាព សំរាប់ជនពិការ រដ្ឋភាគីត្រូវលើកស្ទួយការបណ្តុះបណ្តាលឱ្យបានសមស្រប ដល់អ្នកទាំងឡាយដែលកំពុងបំរើការងារក្នុងវិស័យយុត្តិធម៌ រួមទាំងនគរបាល និងបុគ្គលិកពន្ធនាគារផង។

## មាត្រា១៤ ៖ សេរីភាព និងសន្តិសុខបុគ្គល

១- ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកផ្សេងទៀត រដ្ឋភាគីត្រូវធានាថាជនពិការ៖

ក. មានសិទ្ធិសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។

ខ. មិនត្រូវបានដកហូតសេរីភាពរបស់ពួកគេ ដោយខុសច្បាប់ ឬតាមទំនើងចិត្តឡើយ ហើយធានាថា ការដកហូតសេរីភាពណាមួយ ត្រូវតែអនុលោមទៅតាមច្បាប់ និងធានាថាគ្មានការដកហូតសេរីភាព ដោយសំអាងលើពិការភាពទោះក្នុងករណីណាក៏ដោយ។

២- រដ្ឋភាគីត្រូវធានាថា ប្រសិនបើជនពិការត្រូវបានដកហូតសេរីភាព ទោះតាមនីតិវិធីណាក៏ដោយ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ ជនពិការមានសិទ្ធិទទួលបាននូវការធានារ៉ាប់រង អនុលោមតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ហើយការប្រព្រឹត្តចំពោះជនពិការត្រូវស្របតាមគោលបំណង និងគោលការណ៍នៃអនុសញ្ញានេះ រួមទាំងការផ្តល់នូវដំណោះស្រាយដ៏សមហេតុផលផង។

## មាត្រា១៥ : សេរីភាពចាកផុតពីការធ្វើទារុណកម្ម ឬការប្រព្រឹត្តឬទណ្ឌកម្មផ្សេងទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក

១- គ្មាននរណាម្នាក់ត្រូវទទួលរងទារុណកម្ម ឬការប្រព្រឹត្ត ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោកឡើយ។ ជាពិសេស គ្មាននរណាម្នាក់ ត្រូវទទួលរងនូវការធ្វើពិសោធវេជ្ជសាស្ត្រ ឬវិទ្យាសាស្ត្រ ដោយគ្មានការស្ម័គ្រចិត្តយល់ព្រមពីសាមីខ្លួនឡើយ។

២- រដ្ឋភាគីត្រូវចាត់វាល់វិធានការតាមផ្លូវច្បាប់ ផ្លូវរដ្ឋបាល ផ្លូវតុលាការ ឬវិធានការដទៃទៀត ឱ្យមានប្រសិទ្ធភាព ដើម្បីការពារជនពិការឱ្យរួចចាកផុតពីការធ្វើទារុណកម្ម ឬការប្រព្រឹត្ត ឬទណ្ឌកម្មផ្សេងទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក ដោយឈរលើមូលដ្ឋានមួយស្មើភាពគ្នាជាមួយអ្នកដទៃ។

## មាត្រា១៦ : សេរីភាពចាកផុតពីការកេងប្រវ័ញ្ច អំពើហិង្សា និងការរំលោភបំពាន

១- រដ្ឋភាគី ត្រូវចាត់វាល់វិធានការសមស្របតាមផ្លូវច្បាប់ រដ្ឋបាល សង្គម អប់រំ និងវិធានការដទៃទៀត ដើម្បីការពារជនពិការទាំងក្នុងផ្ទះ ទាំងក្រៅផ្ទះ ពីគ្រប់ទំរង់នៃការកេងប្រវ័ញ្ច អំពើហិង្សា និងការរំលោភបំពាន រួមទាំងទិដ្ឋភាពនានា ដោយឈរលើមូលដ្ឋានយេនឌ័ររបស់ពួកគេផង។

២- រដ្ឋភាគីក៏ត្រូវចាត់វាល់វិធានការសមស្រប ដើម្បីទប់ស្កាត់គ្រប់ទម្រង់នៃការកេងប្រវ័ញ្ច អំពើហិង្សា និងការរំលោភបំពាន ដោយធានាឱ្យមានទំរង់សមស្របនៃការជួយឧបត្ថម្ភ និងការគាំទ្រ ដែលឆ្លើយតបបាន ទៅនឹងតម្រូវការតាមអាយុនិងយេនឌ័រដល់ជនពិការ ក្រុមគ្រួសារនិងអ្នកថែទាំរបស់គេ រួមទាំងតាមរយៈការផ្ដល់ព័ត៌មាន និងការអប់រំ អំពីវិធីចៀសវាង ទទួលស្គាល់ និងរាយការណ៍យ៉ាងដូចម្ដេចពីករណីនានានៃការកេងប្រវ័ញ្ច អំពើហិង្សានិងការរំលោភបំពាន។ រដ្ឋភាគីត្រូវធានាថា សេវាកម្មការពារទាំងនោះ ត្រូវមានលក្ខណៈឆ្លើយតបទៅតាមតម្រូវការនៃអាយុ យេនឌ័រ និងពិការភាព។

៣- ដើម្បីទប់ស្កាត់ការកើតឡើងនៃការកេងប្រវ័ញ្ច អំពើហិង្សា និងការរំលោភបំពានតាមគ្រប់រូបភាព រដ្ឋភាគីត្រូវធានាថា កម្មវិធី និងគ្រឿងបរិក្ខារគ្រប់បែបយ៉ាង ដែលរចនាឡើងដើម្បីបំរើជនពិការ ត្រូវបានត្រួតពិនិត្យយ៉ាងម៉ដ្ឋចត់បំផុត ដោយអាជ្ញាធរឯករាជ្យ។

៤- រដ្ឋភាគីត្រូវចាត់រាល់វិធានការសមស្រប ដើម្បីលើកស្ទួយការធ្វើឱ្យប្រសើរឡើងវិញ ខាងផ្លូវចិត្ត បញ្ញា និងកាយសម្បទា ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មចូលក្នុងសង្គមជាតិវិញនៃជនពិការ ដែលជាជនរងគ្រោះពីទំរង់ណាមួយនៃការកេងប្រវ័ញ្ច អំពើហិង្សា និងការរំលោភបំពាន រួមទាំងតាមរយៈការផ្តល់សេវាកម្មការពារ។ ការធ្វើឱ្យប្រសើរឡើងវិញ និងការធ្វើសមាហរណកម្មឡើងវិញបែបនេះ ត្រូវកើតឡើង ក្នុងបរិយាកាសមួយ ដែលទ្រទ្រង់ដល់សុខភាព សុខុមាលភាព ការគោរពបុគ្គល សេចក្តីថ្លៃថ្នូរ និងស្វ័យភាពរបស់បុគ្គល និងត្រូវគិតគូរដល់តម្រូវការជាក់ស្តែង តាមអាយុ និងយេនឌ័រ។

៥- រដ្ឋភាគីត្រូវបង្កើតច្បាប់ និងគោលនយោបាយដែលមានប្រសិទ្ធភាព រួមទាំងច្បាប់ និងគោលនយោបាយដែលផ្តោតការយកចិត្តទុកដាក់ដល់ស្ត្រី និងកុមារ ដើម្បីធានាថា ករណីនៃការកេងប្រវ័ញ្ច អំពើហិង្សា និងការរំលោភបំពានលើជនពិការ ត្រូវបានកំណត់ជាមុខសញ្ញា ស្ថិតក្រោមការស៊ើបអង្កេត និងចោទប្រកាន់ឱ្យបានត្រឹមត្រូវ។

### មាត្រា១៧ : ការការពារបូរណភាពនៃបុគ្គល

ជនពិការគ្រប់រូប មានសិទ្ធិបញ្ចេញមតិជាវិជ្ជមាន ចំពោះបូរណភាពរបស់ខ្លួន ទាំងខាងផ្លូវកាយ និងខាងផ្លូវចិត្ត ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកផ្សេងទៀត។

### មាត្រា១៨ : សេរីភាពនៃការធ្វើដំណើរ និងការទទួលបានសញ្ជាតិ

១- រដ្ឋភាគី ត្រូវទទួលស្គាល់សិទ្ធិរបស់ជនពិការ ចំពោះសេរីភាពក្នុងការធ្វើដំណើរ សេរីភាពក្នុងការជ្រើសរើសទីលំនៅ និងសញ្ជាតិរបស់ខ្លួន ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកផ្សេងទៀត រួមទាំងការធានាឱ្យជនពិការៈ

ក. មានសិទ្ធិទទួលបាន និងប្តូរសញ្ជាតិ ហើយមិនត្រូវដកហូតសញ្ជាតិរបស់ពួកគេ ដោយមិនសមហេតុផល ឬដោយសារតែពិការភាពនោះទេ។

ខ. មិនត្រូវដកហូតលទ្ធភាពរបស់ពួកគេ ក្នុងការទទួលបាន កាន់កាប់ និងប្រើប្រាស់ឯកសារ សញ្ជាតិ ឬអត្តសញ្ញាណប័ណ្ណ ឬក្នុងការប្រើប្រាស់នីតិវិធីពាក់ព័ន្ធនានា ដូចជា នីតិវិធីអន្តោប្រវេសន៍ជាដើម ដែលពួកគេអាចត្រូវការ ដើម្បីសម្រួលដល់ការអនុវត្តសិទ្ធិមានសេរីភាពក្នុងការធ្វើដំណើរ ដោយសារតែពិការភាពនោះទេ។

គ. មានសេរីភាពចាកចេញពីប្រទេសណាមួយ រួមទាំងប្រទេសកំណើតរបស់ខ្លួនផងដែរ។

ឃ. មិនត្រូវដកហូតសិទ្ធិចូលក្នុងប្រទេសរបស់ខ្លួន ដោយមិនសមហេតុផល ឬដោយសារតែពិការភាពនោះឡើយ។

២- កុមារពិការត្រូវបានចុះបញ្ជីភ្លាម បន្ទាប់ពីប្រសូត និងត្រូវមានសិទ្ធិពីកំណើត ក្នុងការទទួលបានឈ្មោះមួយ សិទ្ធិទទួលបានសញ្ជាតិមួយ និងតាមលទ្ធភាពដែលអាចធ្វើបាន មានសិទ្ធិស្គាល់ឪពុក-ម្តាយ និងទទួលបានការថែទាំពីឪពុក-ម្តាយ។

### មាត្រា១៩ : ការរស់នៅដោយឯករាជ្យ និងការរួមរស់ក្នុងសហគមន៍

រដ្ឋភាគីនៃអនុសញ្ញានេះ ទទួលស្គាល់សិទ្ធិស្មើភាពគ្នារបស់ជនពិការ ក្នុងការរស់នៅក្នុងសហគមន៍ ដោយស្មើភាពគ្នាជាមួយអ្នកផ្សេងទៀត ក្នុងការជ្រើសរើស ហើយត្រូវចាត់វិធានការសមស្រប និងមានប្រសិទ្ធភាពដើម្បីជួយឱ្យជនពិការទទួលបានយ៉ាងពេញលេញនូវសិទ្ធិនេះ និងការរួមរស់ និងការចូលរួមយ៉ាងពេញលេញរបស់ជនពិការ ក្នុងសហគមន៍ ដោយរួមមានការធានាថា៖

ក. ជនពិការទទួលបានឱកាសជ្រើសរើសកន្លែងតាំងទីលំនៅនិងទីកន្លែង និងអ្នកដែលគេត្រូវរស់នៅជាមួយ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកផ្សេងទៀត និងមិនត្រូវបានគេតម្រូវឱ្យរស់នៅតាមការរៀបចំជាពិសេសណាមួយឡើយ។

ខ. ជនពិការមានលទ្ធភាពទទួលបានសេវាទ្រទ្រង់ការរស់នៅ កន្លែងស្នាក់អាស្រ័យ និងសេវាទ្រទ្រង់សហគមន៍ផ្សេងទៀត រួមទាំងជំនួយបុគ្គលដែលចាំបាច់ដើម្បីទ្រទ្រង់ការរស់នៅនិងការបញ្ចូលខ្លួនទៅក្នុងសហគមន៍ និងបង្ការពីភាពឯកោ ឬការឃ្លាតឆ្ងាយពីសហគមន៍។

គ. សេវាកម្មនិងគ្រឿងបរិក្ខារសហគមន៍សំរាប់ប្រជាពលរដ្ឋទូទៅក៏សំរាប់ជនពិការដែរ ដោយឈរលើមូលដ្ឋានស្មើភាពគ្នា និងឆ្លើយតបបានទៅនឹងតម្រូវការរបស់ជនពិការ។

## មាត្រា២០ : ភាពចល័តផ្ទាល់ខ្លួន

រដ្ឋភាគី ត្រូវចាត់វិធានការនានាមានប្រសិទ្ធភាព និងល្អបំផុត តាមដែលអាចធ្វើទៅបាន ដើម្បីធានាភាពចល័តផ្ទាល់ខ្លួន ដោយឯករាជ្យរបស់ជនពិការដែលរួមមាន៖

ក. ការជួយសម្រួលភាពចល័តផ្ទាល់ខ្លួនរបស់ជនពិការ ក្នុងលក្ខណៈ និងតាមពេលវេលានៃការជ្រើសរើសរបស់គេ និងមានតម្លៃសមរម្យ។

ខ. ការជួយសម្រួលឱ្យជនពិការ មានលទ្ធភាពទទួលបានឧបករណ៍ជំនួយដល់ភាពចល័ត ដែលមានគុណភាព គ្រឿងសំភារៈជួយសម្រួល បច្ចេកវិទ្យាទម្រង់នៃជំនួយផ្ទាល់ និងអន្តរការី រួមទាំងការធ្វើឱ្យរបស់របរទាំងនេះ ស្ថិតក្នុងតម្លៃសមរម្យ។

គ. ការផ្តល់ការបណ្តុះបណ្តាលជំនាញ ទាក់ទងនឹងការចល័តដល់ជនពិការ និងដល់បុគ្គលិកឯកទេសដែលធ្វើការជាមួយជនពិការ.

ឃ. ការលើកទឹកចិត្តអង្គភាពនានា ដែលផលិតឧបករណ៍ជំនួយដល់ការចល័ត គ្រឿងសំភារៈជួយសម្រួល និងបច្ចេកវិទ្យាជំនួយ ឱ្យគិតពិចារណាដល់គ្រប់ទិដ្ឋភាពនៃការចល័តរបស់ជនពិការ។

## មាត្រា២១ : សេរីភាពនៃការសំដែងមតិ យោបល់ និងសិទ្ធិទទួលបានព័ត៌មាន

រដ្ឋភាគី ត្រូវចាត់វាល់វិធានការសមស្រប ដើម្បីធានាថា ជនពិការអាចអនុវត្តសិទ្ធិសេរីភាពរបស់ខ្លួនបាន ក្នុងការសំដែងមតិយោបល់ រួមទាំងសេរីភាពក្នុងការស្វែងរក ទទួល និងផ្តល់ព័ត៌មាន និងទស្សនៈ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកផ្សេងទៀត និងតាមរយៈគ្រប់ទម្រង់នៃទំនាក់ទំនង ស្របតាមការជ្រើសរើសរបស់គេ ដូចដែលមានចែងនៅក្នុងមាត្រា២នៃអនុសញ្ញានេះ តាមរយៈ៖

ក. ការផ្តល់ព័ត៌មានសម្រាប់សាធារណជន ឱ្យដល់ជនពិការ តាមទម្រង់ និងបច្ចេកវិទ្យា ដែលគេអាចទទួលបានសមស្រប ទៅនឹងប្រភេទផ្សេងៗនៃពិការភាព ឱ្យបានទាន់ពេលវេលា និងគ្មានការបង់ប្រាក់បន្ថែម។

ខ. ការទទួល និងជួយសំរួលដល់ការប្រើប្រាស់ភាសាសញ្ញា អក្សរស្ទាប និងទំនាក់ទំនងផ្សេងៗទៀត ព្រមទាំងគ្រប់មធ្យោបាយ របៀប និងទម្រង់នៃទំនាក់ទំនងផ្សេងទៀតដែលអាចទទួលយកបាន តាមការជ្រើសរើសរបស់ជនពិការ ក្នុងការទាក់ទងជាផ្លូវការ។

គ. ការជំរុញឱ្យនីតិបុគ្គលឯកជននានា ដែលផ្តល់សេវាកម្មផ្សេងៗដល់សាធារណជន រួមទាំង តាមរយៈអ៊ិនធឺណេត ផ្តល់ព័ត៌មាន និងសេវាកម្មផ្សេងៗតាមទម្រង់ដែលជនពិការ អាចទទួល និងប្រើប្រាស់បាន។

ឃ. ការលើកទឹកចិត្តដល់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន រួមទាំងអ្នកផ្តល់ព័ត៌មានតាមអ៊ិនធឺណេត ដើម្បីផលិត ដែលជនពិការអាចទទួលយកបាន។

ង. ការទទួលស្គាល់ និងការលើកស្ទួយការប្រើប្រាស់ភាសាសញ្ញា។

## មាត្រា២២ : ការគោរពសិទ្ធិផ្ទាល់ខ្លួន

១- ដោយមិនគិតពីកន្លែងស្នាក់អាស្រ័យ ឬការរៀបចំរបៀបរស់នៅរបស់ពួកគេ គ្មានជនពិការណាម្នាក់ ត្រូវទទួលរងការជ្រៀតជ្រែកសិទ្ធិផ្ទាល់ខ្លួន គ្រួសារ ផ្ទះសំបែង ឬលិខិតឆ្លើយឆ្លង ឬប្រភេទផ្សេងៗទៀតនៃទំនាក់ទំនងរបស់ពួកគេ តាមទំនើងចិត្ត ឬដោយខុសច្បាប់ ឬទទួលរងការបំពារបំពាន មិនស្របច្បាប់ដល់

កត្តិយស និងកេរ្តិ៍ឈ្មោះរបស់ពួកគេឡើយ។ ជនពិការមានសិទ្ធិទទួលបានការការពារពីច្បាប់ប្រឆាំងនឹងការជ្រៀតជ្រែក ឬការបំពារបំពានទាំងនេះ។

២- រដ្ឋភាគី ត្រូវការពារសិទ្ធិផ្ទាល់ខ្លួនរបស់បុគ្គល ព័ត៌មានពីសុខភាព និងស្តារលទ្ធភាពពលកម្មរបស់ជនពិការ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកផ្សេងទៀត។

## មាត្រា២៣ : ការគោរពលំនៅដ្ឋាន និងគ្រួសារ

១- រដ្ឋភាគីត្រូវចាត់វិធានការនានាដែលសមស្រប និងមានប្រសិទ្ធភាព ដើម្បីលុបបំបាត់ចោលការរើសអើងប្រឆាំងនឹងជនពិការ តាមគ្រប់រឿងរ៉ាវដែលទាក់ទងនឹងអាពាហ៍ពិពាហ៍ គ្រួសារ មាតាបិតាភាព និងទំនាក់ទំនងសាច់ញាតិ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកផ្សេងទៀត ធ្វើដូច្នេះ ដើម្បីធានាថា៖

ក. ជនពិការគ្រប់រូបដែលដល់អាយុគ្រប់រៀបការ មានសិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍ និងកសាងគ្រួសារមួយ ដោយឈរលើមូលដ្ឋានព្រមព្រៀងពេញលេញ និងដោយសេរី ពីអនាគតសហព័ទ្ធ។

ខ. ជនពិការមានសិទ្ធិធ្វើការសម្រេចចិត្តដោយសេរី និងដោយទទួលខុសត្រូវ ក្នុងការកំណត់ចំនួនកូន និងចន្លោះពេលមានកូន និងក្នុងការទទួលព័ត៌មានសមស្រប ទៅតាមវ័យ អំពីការអប់រំពីការពន្យាកំណើត និងសុខភាពបន្តពូជ ព្រមទាំងមធ្យោបាយចាំបាច់នានាដែលជួយឱ្យពួកគេ អាចអនុវត្តសិទ្ធិទាំងនេះបាន។

គ. ជនពិការ រួមទាំងកុមារ រក្សាបាននូវស្ថានភាពពូជធាររបស់ខ្លួន ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកផ្សេងទៀត។

២- រដ្ឋភាគីត្រូវធានាពីសិទ្ធិ និងការទទួលខុសត្រូវរបស់ជនពិការទាក់ទងនឹងអាណាព្យាបាលភាព ការគ្រប់គ្រងកុមារ ការបង្កើតមូលនិធិមនុស្សធម៌ ការយកក្មេងមកចិញ្ចឹម ឬស្ថាប័ននានា ដែលស្រដៀងគ្នា ដែលទស្សនទានទាំងនោះមាននៅក្នុងច្បាប់ជាតិ។ នៅគ្រប់ករណី ឧត្តមប្រយោជន៍របស់កុមារ ត្រូវតែមានឧត្តមភាព។ រដ្ឋភាគី ត្រូវផ្តល់ជំនួយសមស្របដល់ជនពិការក្នុងការបំពេញការទទួលខុសត្រូវចិញ្ចឹមកូនរបស់ពួកគេ។

៣- រដ្ឋភាគីត្រូវធានាថា កុមារពិការ មានសិទ្ធិស្មើគ្នា ពាក់ព័ន្ធនឹងជីវិតគ្រួសារ។ ក្នុងគំនិតធ្វើឱ្យសិទ្ធិទាំងនេះបានសម្រេច និងដើម្បីបង្ការការបិទបាំង ការបំបរបង់ ការមិនយកចិត្តទុកដាក់ និងការដាក់កុមារពិការឱ្យនៅឯកោ រដ្ឋភាគីត្រូវផ្តល់ព័ត៌មាន សេវាកម្ម និងការជួយឧបត្ថម្ភដល់កុមារពិការ និងក្រុមគ្រួសាររបស់ពួកគេ ឱ្យបានចាប់ពីដំណាក់កាលដំបូង និងគ្រប់ជ្រុងជ្រោយ។

៤- រដ្ឋភាគីត្រូវធានាថា កុមារ មិនត្រូវបានបំបែកឱ្យរស់នៅទីទៃ ពីឪពុកម្តាយ ដោយផ្ទុយពីបំណងរបស់គេឡើយ លើកលែងតែដោយអាជ្ញាធរមានសមត្ថកិច្ច ដែលសម្រេចដោយការត្រួតពិនិត្យរបស់តុលាការ អនុលោមតាមច្បាប់ និងនីតិវិធីដែលនៅមានជាធរមាន ថាការបំបែកបែបនេះ មានលក្ខណៈចាំបាច់សំរាប់ឧត្តមប្រយោជន៍របស់កុមារ។ គ្មានករណីណា ដែលកុមារ ត្រូវបានបំបែកពីឪពុកម្តាយ ដោយសារតែពិការភាពរបស់កុមារ ឬដោយសារតែពិការភាពរបស់ឪពុកឬម្តាយ ឬដោយសារតែឪពុក-ម្តាយពិការទាំងពីរនាក់នោះឡើយ។

៥- ក្នុងករណីដែលគ្រួសាររបស់កុមារពិការផ្ទាល់ មិនអាចបីបាច់ថែរក្សាកុមារពិការបាន រដ្ឋភាគីត្រូវខិតខំគ្រប់បែបយ៉ាង ដើម្បីផ្តល់ការថែទាំជំនួស ក្នុងរង្វង់គ្រួសារមួយដែលធំជាង ហើយបើមិនបានដូច្នេះទេ គួរតែនៅក្នុងរង្វង់សហគមន៍មួយដែលមានការរៀបចំជាលក្ខណៈគ្រួសារ។

## មាត្រា២៤ : ការអប់រំ

១- រដ្ឋភាគីទទួលស្គាល់សិទ្ធិរបស់ជនពិការចំពោះការអប់រំ។ក្នុងទស្សនៈដើម្បីធ្វើឱ្យសិទ្ធិនេះបានសម្រេច ដោយគ្មានការរើសអើង និងដោយឈរលើមូលដ្ឋាននៃការផ្តល់ឱកាសស្មើភាពគ្នា រដ្ឋភាគី ត្រូវធានាឱ្យមានប្រព័ន្ធអប់រំបញ្ចូលគ្នាមួយ នៅគ្រប់កម្រិតសិក្សា និងការសិក្សាពេញមួយជីវិត ដែលមានការតម្រង់ទិសទៅរកៈ

ក. ការអភិវឌ្ឍន៍ទាំងស្រុងនៃសក្តានុពលមនុស្ស សេចក្តីថ្លៃថ្នូរ តម្លៃបុគ្គល និងការពង្រឹងការគោរពសិទ្ធិមនុស្ស សេរីភាពជាសារវន្ត និងភាពចំរុះគ្នានៃមនុស្សជាតិ។

ខ. ការអភិវឌ្ឍន៍បុគ្គលិកលក្ខណៈ ទេពកោសល្យ និងគំនិតច្នៃប្រឌិតរបស់ជនពិការ ក៏ដូចជា សមត្ថភាពខាងកាយសម្បទា និងប្រាជ្ញាស្មារតី ឱ្យដល់សក្តានុពលពេញទំហឹងរបស់ពួកគេ។

គ.ជួយឱ្យជនពិការចូលរួមយ៉ាងសកម្មក្នុងសង្គមដោយសេរី។

២- ដើម្បីធ្វើឱ្យសិទ្ធិទាំងនេះបានសម្រេច រដ្ឋភាគីត្រូវធានាថា៖

ក. ជនពិការមិនត្រូវបានផាត់ចេញពីប្រព័ន្ធអប់រំទូទៅ ដោយសារតែពិការភាពនោះទេ ហើយកុមារពិការ មិនត្រូវបានផាត់ចេញពីការអប់រំដែលខានពុំបាន និងឥតបង់ថ្លៃ នៅកម្រិតបឋម ឬមធ្យមសិក្សា ដោយសារតែពិការភាពនោះទេ។

ខ. ជនពិការអាចទទួលបានការអប់រំរួមគ្នា មានគុណភាព និងមិនបង់ថ្លៃ នៅកម្រិតបឋម និងមធ្យមសិក្សា ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកផ្សេងទៀត នៅក្នុងសហគមន៍ដែលគេរស់នៅ។

គ. ត្រូវផ្តល់ដំណោះស្រាយដ៏សមហេតុផលទៅតាមតម្រូវការរបស់បុគ្គលម្នាក់ៗ។

ឃ. ជនពិការ ទទួលបានការឧបត្ថម្ភដែលគេត្រូវការ ក្នុងក្របខ័ណ្ឌប្រព័ន្ធអប់រំទូទៅ ដើម្បីជួយពួកគេ ឱ្យទទួលបានការអប់រំប្រកបដោយប្រសិទ្ធភាព។

ង. វិធានការជួយឧបត្ថម្ភជាពិសេសសម្រាប់ជនពិការម្នាក់ៗដ៏មានប្រសិទ្ធភាព ត្រូវបានផ្តល់ឱ្យ ក្នុងបរិយាកាស ដែលបង្កើនការអភិវឌ្ឍន៍សង្គម និងសិក្សាធិការជាអតិបរមា ស្របទៅតាមគោលដៅ នៃការបញ្ចូលខ្លួនជនពិការយ៉ាងពេញលេញទៅក្នុងសង្គម។

៣- រដ្ឋភាគីត្រូវជួយជនពិការឱ្យអាចរៀនយកជំនាញអភិវឌ្ឍន៍សង្គម និងបំណិនជីវិត ដើម្បីជួយឱ្យពួកគេចូលរួមបានដោយស្មើភាពគ្នា និងយ៉ាងពេញលេញ ក្នុងការអប់រំ និងជាសមាជិកនៃសហគមន៍។ ដើម្បីសម្រេចគោលដៅនេះ រដ្ឋភាគីត្រូវចាត់វិធានការសមស្របនានា រួមមាន៖

ក. ជួយសម្រួលដល់ការរៀនអក្សរស្ទាប អក្សរជំនួស របៀបនៃការតម្លើង និងជំនួស ព្រមទាំងមធ្យោបាយ និងទម្រង់ផ្សេងៗនៃទំនាក់ទំនង ជំនាញនៃការចល័តនិងតំរង់ទិសព្រមទាំងជួយសម្រួលដល់ការគាំទ្រនិងការណែនាំក្រុមជាដៃគូ។

ខ. ជួយសំរួលដល់ការរៀនភាសាសញ្ញា និងការលើកស្ទួយអត្តសញ្ញាណផ្នែកភាសារបស់សហគមន៍ជនពិការគ។

គ. ធានាថា ការអប់រំសំរាប់ជនពិការ ជាពិសេសកុមារដែលថ្លង់ ពិការភ្នែក ឬពិការភ្នែក ហើយថ្លង់ ត្រូវបានធ្វើឡើងក្នុងទំរង់ និងភាសា និងមធ្យោបាយទំនាក់ទំនង សម្រាប់ជនពិការម្នាក់ៗដ៏សមស្របបំផុតក្នុងបរិយាកាសបង្កើនការអភិវឌ្ឍន៍សង្គម និងសិក្សាធិការជាអតិបរមា។

៤- ដើម្បីជួយធានាដល់ការសម្រេចឱ្យបាននូវសិទ្ធិនេះ រដ្ឋភាគីត្រូវចាត់វិធានការសមស្របនានា ដើម្បីផ្តល់ការងារដល់គ្រូបង្រៀន រួមទាំងគ្រូពិការដែលមានគុណសម្បត្តិ ក្នុងការបង្រៀនភាសាសញ្ញា និង/ឬអក្សរស្ទាប និងដើម្បីបណ្តុះបណ្តាលដល់អ្នកជំនាញនិងបុគ្គលិកដែលធ្វើការនៅគ្រប់កម្រិតសិក្សា។ ការបណ្តុះបណ្តាលបែបនេះ ត្រូវដាក់បញ្ចូលការយល់ដឹងអំពីពិការភាព និងការប្រើប្រាស់របៀបនៃការតម្លើងនិងជំនួស ព្រមទាំងមធ្យោបាយ និងទម្រង់ផ្សេងៗ នៃទំនាក់ទំនង បច្ចេកទេស និងសំភារៈអប់រំសមស្រប ដើម្បីជួយដល់ជនពិការ។

៥- រដ្ឋភាគីត្រូវធានាថា ជនពិការអាចទទួលបានការអប់រំថ្នាក់ឧត្តមសិក្សាជាទូទៅ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការអប់រំមនុស្សពេញវ័យ និងការអប់រំពេញមួយជីវិត ដោយគ្មានការរើសអើង និងដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកផ្សេងទៀត។ ដើម្បីសម្រេចបាននូវគោលដៅនេះ រដ្ឋភាគីត្រូវធានាថា ដំណោះស្រាយដ៏សមហេតុផល ត្រូវបានផ្តល់ជូនដល់ជនពិការ។

### មាត្រា២៥ : សុខភាព

រដ្ឋភាគីទទួលស្គាល់ថា ជនពិការ មានសិទ្ធិក្នុងការទទួលបាននូវបមាណីសុខភាពខ្ពស់បំផុត ដោយគ្មានការរើសអើង ដោយសារតែពិការភាពនោះឡើយ។

រដ្ឋភាគី ត្រូវចាត់វាល់វិធានការសមស្រប ដើម្បីធានាដល់ជនពិការ ឱ្យទទួលបានសេវាកម្មសុខភាពដែលពាក់ព័ន្ធដល់យែនឌ័រ រួមទាំងសុខភាពទាក់ទងនឹងការស្តារនីតិសម្បទា។ ជាពិសេស រដ្ឋភាគីត្រូវ៖

ក. ផ្តល់ដល់ជនពិការនូវឋាន: គុណភាព និងបមាណីដូចគ្នានៃកម្មវិធី និងសេវាថែទាំសុខភាព ដោយមិនបង់ប្រាក់ ឬតាមតំលៃមួយសមស្របដូចអ្នកផ្សេងទៀតដែរ រួមទាំងបញ្ហាសុខភាពផ្លូវភេទនិងបន្តពូជ និងកម្មវិធីសុខភាពសាធារណៈជាមូលដ្ឋាន។

ខ. ផ្តល់សេវាកម្មសុខភាពទាំងនេះទៅតាមតម្រូវការរបស់ជនពិការ យកចិត្តទុកដាក់ជាពិសេស ព្រោះតែពិការភាពរបស់ពួកគេ រួមទាំងការផ្តល់អត្តសញ្ញាណកម្មពីដំបូង និងការធ្វើអន្តរាគមន៍ឲ្យបានសមរម្យ និងសេវាកម្មដែលបានរចនាឡើង ដើម្បីបន្ថយ និងបង្ការពិការបន្ថែមទៀតឱ្យបានជាអប្បបរមា រួមទាំងកុមារនិងមនុស្សចាស់។

គ. ផ្តល់សេវាកម្មសុខភាពទាំងនេះនៅជិតសហគមន៍របស់ជនពិការបំផុតតាមតែអាចធ្វើទៅបាន រួមទាំងនៅតាមតំបន់ជនបទ។

ឃ. តម្រូវឱ្យអ្នកមានវិជ្ជាជីវៈសុខភាព ផ្តល់ការថែទាំសុខភាពដល់ជនពិការ ឱ្យមានគុណភាពដូចគ្នានឹងការថែទាំអ្នកដទៃ ដោយឈរលើមូលដ្ឋាននៃការយល់ព្រមដោយសេរី និងដោយបានទទួលព័ត៌មានច្បាស់លាស់ ដោយសារត្រូវបានលើកកម្ពស់ពីការយល់ដឹងអំពីសិទ្ធិមនុស្ស សេចក្តីថ្លៃថ្នូរ ស្វ័យភាព និងតម្រូវការរបស់ជនពិការ តាមរយៈការបណ្តុះបណ្តាល និងការប្រកាសពីបមាណីក្រមសីល-ធម៌ សំរាប់ការថែទាំសុខភាពសាធារណៈ និងឯកជន។

ង. ហាមឃាត់ការរើសអើងដល់ជនពិការ ក្នុងការផ្តល់ការធានារ៉ាប់រងសុខភាព និងការធានារ៉ាប់រងជីវិត ដែលការធានារ៉ាប់រងបែបនេះ ត្រូវបានអនុញ្ញាតដោយច្បាប់ជាតិដែលត្រូវបានផ្តល់ឱ្យក្នុងលក្ខណៈមួយយុត្តិធម៌និងសមហេតុផល។

ច. ទប់ស្កាត់ការបដិសេធដែលមានលក្ខណៈរើសអើងចំពោះការផ្តល់ការថែទាំសុខភាព ឬសេវាកម្មសុខភាព ឬចំណីអាហារ និងសារធាតុរាវ ដោយសារតែពិការភាព។

## មាត្រា២៦ ៖ ការធ្វើឲ្យមានលទ្ធភាពពលកម្ម និងការស្តារលទ្ធភាពពលកម្ម

១- រដ្ឋភាគី ត្រូវចាត់វិធានការសមស្រប និងមានប្រសិទ្ធភាព រួមទាំងតាមរយៈការជួយគ្នាជាដៃគូ ដើម្បីឱ្យជនពិការអាចទទួលបាន និងរក្សាបានឯករាជ្យភាពជាអតិបរមា សមត្ថភាពគ្រប់គ្រាន់ខាងកាយសម្បទា ផ្លូវចិត្ត សង្គមកិច្ច និងខាងវិជ្ជាជីវៈ ព្រមទាំងការចូលរួម និងការបញ្ចូលខ្លួនដោយពេញលេញនៅក្នុងគ្រប់ទិដ្ឋភាពនៃឆាកជីវិត។ ដើម្បីសម្រេចបានគោលដៅនេះ រដ្ឋភាគីត្រូវរៀបចំពង្រឹង និងពង្រីកសេវាកម្ម និងកម្មវិធីនៃការធ្វើឱ្យមានលទ្ធភាពពលកម្ម និងការស្តារលទ្ធភាពពលកម្មឱ្យបានខ្លាំងក្លា ជាពិសេសក្នុងវិស័យសុខភាព ការងារ ការអប់រំ និងសេវាកម្មសង្គម។ តាមរបៀបបែបនេះ សេវាកម្ម និងកម្មវិធីទាំងនេះ៖

ក. ចាប់ផ្តើមនៅតំណាក់កាលដំបូងបំផុត តាមតែអាចធ្វើបាន ហើយផ្អែកទៅលើការវាយតម្លៃ ពហុប្រធានបទលើសេចក្តីត្រូវការ និងចំនុចខ្លាំងរបស់បុគ្គលម្នាក់ៗ។

ខ. គាំទ្រដល់ការចូលរួម និងការបញ្ចូលខ្លួនទៅក្នុងសហគមន៍ និងគ្រប់ទិដ្ឋភាពនៃសង្គម ដែលត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត និងអាចធ្វើបានដោយជនពិការ នៅជិតសហគមន៍ដែលពួកគេរស់នៅ តាមដែលអាចធ្វើទៅបាន រួមទាំងនៅតាមតំបន់ជនបទ។

២- រដ្ឋភាគីត្រូវលើកស្ទួយការអភិវឌ្ឍន៍ ការបណ្តុះបណ្តាលបឋម និងការបណ្តុះបណ្តាលបន្ត ដល់អ្នកមានវិជ្ជាជីវៈ និងបុគ្គលិកធ្វើការខាងសេវាកម្មនៃការធ្វើឱ្យមានលទ្ធភាពពលកម្ម និងការស្តារលទ្ធភាពពលកម្ម។

៣- រដ្ឋភាគីត្រូវលើកស្ទួយចំណេះដឹង ការទទួលបាន និងការប្រើប្រាស់ឧបករណ៍ និងបច្ចេកវិទ្យាជំនួយផ្សេងៗ ដែលត្រូវបានរចនាឡើងសំរាប់ជនពិការដោយសារតែពួកគេពាក់ព័ន្ធទៅនឹងការធ្វើឱ្យមានលទ្ធភាពពលកម្ម និងការស្តារលទ្ធភាពពលកម្ម។

## មាត្រា២៧ : ការងារ និងអាជីព

១- រដ្ឋភាគីទទួលស្គាល់សិទ្ធិរបស់ជនពិការក្នុងការមានការងារធ្វើ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ។ សិទ្ធិនេះ រួមទាំងសិទ្ធិមានឱកាសចិញ្ចឹមជីវិត ដោយប្រកបការងារដែលគេអាចជ្រើសរើស ឬទទួលយកដោយសេរីលើទីផ្សារការងារ និងបរិយាកាសការងារដែលបើកចំហ មិនរើសអើង និងអាចឱ្យជនពិការចូលធ្វើបាន។ រដ្ឋភាគីត្រូវធានា និងលើកស្ទួយដល់ការធ្វើឱ្យបានសម្រេចនូវសិទ្ធិការងារ រួមទាំងសំរាប់អ្នកទាំងឡាយដែលធ្លាក់ខ្លួនពិការ នៅពេលកំពុងបំពេញការងារដោយចាត់វិធានការសមស្រប រួមទាំងវិធានការតាមផ្លូវច្បាប់ដើម្បីៈ

ក. ហាមឃាត់ការរើសអើងដោយសារតែពិការភាពចំពោះគ្រប់បញ្ហាដែលទាក់ទងនឹងរាល់ទម្រង់នៃការងារ រួមទាំងលក្ខខណ្ឌនៃការជ្រើសរើស ការជួល និងការបម្រើការងារ ការបន្តការងារ ការអភិវឌ្ឍន៍មុខរបរ និងលក្ខខណ្ឌការងារ ដែលមានសុវត្ថិភាព និងផាសុកភាព។

ខ. ការពារសិទ្ធិជនពិការ ដោយឈរលើមូលដ្ឋានស្មើភាពគ្នា ជាមួយអ្នកផ្សេងទៀត ចំពោះលក្ខខណ្ឌការងារត្រឹមត្រូវ និងអនុគ្រោះ រួមទាំងឱកាសស្មើគ្នា និងប្រាក់កំរៃស្មើគ្នា ចំពោះការងារដែលមានតំលៃស្មើគ្នា លក្ខខណ្ឌការងារដែលមានសុវត្ថិភាពនិងផាសុកភាព រួមទាំងការការពារពីការយាយីនិងការសងជំងឺចិត្ត។

គ. ធានាថា ជនពិការអាចអនុវត្តសិទ្ធិបង្កើតសហជីព ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកផ្សេងទៀត។

ឃ. ឱ្យជនពិការអាចទទួលបានដោយប្រសិទ្ធភាព នូវកម្មវិធីណែនាំពីវិជ្ជាជីវៈ និងបច្ចេកទេសទូទៅ សេវាកម្មរកការងារឱ្យធ្វើ និងការបណ្តុះបណ្តាលបន្ត និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។

ង. បង្កើនឱកាសមានការងារធ្វើនិងការអភិវឌ្ឍន៍មុខរបរសម្រាប់ជនពិការនៅក្នុងទីផ្សារការងារ ក៏ដូចជាជំនួយក្នុងការស្វែងរកការទទួលបាន ការរក្សា និងការវិលត្រឡប់ចូលបំរើការងារវិញ។

ច. បង្កើនឱកាសដល់ជនពិការឱ្យមានមុខរបរផ្ទាល់ខ្លួន មានភាពជាសហគ្រិន ការបង្កើតសារជីវកម្ម និងចាប់ផ្តើមធ្វើធុរកិច្ចដោយខ្លួនឯង។

ឆ. ផ្តល់ការងារដល់ជនពិការក្នុងស្ថាប័នសាធារណៈ។

ជ.បង្កើនការងារសម្រាប់ជនពិការក្នុងស្ថាប័នឯកជន តាមរយៈវិធានការ និងគោលនយោបាយសមស្រប ដែលអាចរួមមានកម្មវិធីសកម្មភាពជាវិជ្ជមាន កម្មវិធីលើកទឹកចិត្ត និងវិធានការផ្សេងៗទៀត។

ឈ. ធានាឱ្យមានដំណោះស្រាយដ៏សមហេតុផល ដល់ជនពិការនៅក្នុងកន្លែងធ្វើការ។

ញ.បង្កើនលទ្ធភាពឱ្យជនពិការ អាចទទួលបានបទពិសោធន៍ការងារនៅក្នុងទីផ្សារការងារសេរី។

ដ. ជំរុញការស្តារឡើងវិញផ្នែកជំនាញ និងវិជ្ជាជីវៈ ការរក្សាការងារ និងកម្មវិធីនានាដែលជួយឱ្យជនពិការ អាចត្រឡប់ចូលបំរើការងារវិញ។

២- រដ្ឋភាគី ត្រូវធានាថា ជនពិការមិនត្រូវធ្លាក់ទៅក្នុងភាពជាទាសករ ឬខ្ញុំកញ្ជះគេ ហើយត្រូវបានគេការពារ ពីការធ្វើពលកម្មដោយបង្ខំ ឬដោយមិនអាចប្រកែកបាន ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកផ្សេងទៀត។

### មាត្រា២៨ : ជីវភាពរស់នៅសមរម្យ និងការការពារផ្នែកសង្គមកិច្ច

១- រដ្ឋភាគីទទួលស្គាល់សិទ្ធិរបស់ជនពិការ ចំពោះជីវភាពរស់នៅសមរម្យសម្រាប់ខ្លួនគេផ្ទាល់ និងសម្រាប់ក្រុមគ្រួសាររបស់ពួកគេ រួមទាំងការមានអាហារហូបចុកគ្រប់គ្រាន់ មានសំលៀកបំពាក់ និងផ្ទះសំបែងសមរម្យ និងការកែលំអលក្ខខណ្ឌជីវភាពរស់នៅជាប្រចាំ ហើយរដ្ឋភាគីត្រូវចាត់វិធានការសមស្រប ដើម្បីការពារ និងលើកស្ទួយដល់ការធ្វើឱ្យបានសម្រេចនូវសិទ្ធិនេះ ដោយគ្មានការរើសអើងដោយសារពិការភាពនោះឡើយ។

២- រដ្ឋភាគី ទទួលស្គាល់សិទ្ធិរបស់ជនពិការ ពីការការពារផ្នែកសង្គមកិច្ច និងពីការទទួលបានសិទ្ធិនេះ ដោយគ្មានការរើសអើងដោយសារពិការភាព និងត្រូវចាត់វិធានការសមស្រប ដើម្បីការពារនិងលើកស្ទួយដល់ការធ្វើឱ្យបានសម្រេចនូវសិទ្ធិនេះ រួមទាំងវិធានការដូចខាងក្រោម៖

ក. ធានាដល់ជនពិការ ឱ្យទទួលបានដោយស្មើភាពគ្នា នូវសេវាកម្មទឹកស្អាត និងធានាដល់ជនពិការឱ្យទទួលបានសេវាកម្ម គ្រឿងឧបករណ៍ និងជំនួយផ្សេងៗដែលសមស្រប និងមានតម្លៃសមរម្យ សម្រាប់បម្រើសេចក្ដីត្រូវការពាក់ពន្ធ័នឹងពិការភាព។

ខ. ធានាដល់ជនពិការ ជាពិសេសស្ត្រី និងកុមារីពិការ និងមនុស្សចាស់ពិការ ឱ្យទទួលបានកម្មវិធីកាត់បន្ថយភាពក្រីក្រ និងកម្មវិធីការពារផ្នែកសង្គមកិច្ច។

គ. ធានាដល់ជនពិការ និងក្រុមគ្រួសាររបស់គេ ដែលកំពុងរស់នៅក្នុងស្ថានភាពក្រីក្រ ឱ្យទទួលបានជំនួយឧបត្ថម្ភពីរដ្ឋ តាមរយៈខ្ទង់ចំណាយលើផ្នែកពិការភាព រួមទាំងការបណ្ដុះបណ្ដាល ការផ្ដល់ប្រឹក្សា ជំនួយហិរញ្ញវត្ថុនិងការថែទាំក្នុងកំឡុងពេលសំរាក។

ឃ. ធានាដល់ជនពិការ ឱ្យទទួលបានកម្មវិធីផ្ទះសំបែងសាធា រណៈ។

ង. ធានាដល់ជនពិការ ឱ្យទទួលបានដោយស្មើភាពគ្នានូវកម្មវិធី និងផលប្រយោជន៍សោធននិវត្តន៍។

### មាត្រា២៩ : ការចូលរួមក្នុងជីវិតាពនយោបាយ និងជីវិតាពសាធារណៈ

រដ្ឋភាគី ត្រូវធានាដល់ជនពិការពីសិទ្ធិនយោបាយ និងឱកាសដែលជនពិការទទួលបាន ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកផ្សេងទៀត ត្រូវ៖

ក. ធានាថា ជនពិការអាចចូលរួមដោយប្រសិទ្ធភាព និងយ៉ាងពេញលេញក្នុងជីវភាពនយោបាយ និងជីវភាពសាធារណៈដោយផ្ទាល់ឬតាមរយៈអ្នកតំណាងដែលត្រូវបានជ្រើសរើសដោយសេរី ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកផ្សេងទៀត រួមទាំងសិទ្ធិ និងឱកាសសម្រាប់ជនពិការ ក្នុងការបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោត ដោយ៖

(i)- ធានាថា នីតិវិធី ឧបករណ៍ និងសំភារៈបោះឆ្នោត មានលក្ខណៈសមស្របអាចធ្វើទៅបានងាយយល់ និងងាយប្រើប្រាស់។

(ii)- ការពារសិទ្ធិរបស់ជនពិការ ក្នុងការបោះឆ្នោតដោយសំងាត់ នៅក្នុងការបោះឆ្នោត និងក្នុងការធ្វើប្រជាមតិជាសាធារណៈ ដោយគ្មានការបំភិតបំភ័យ និងក្នុងការឈរឈ្មោះឱ្យគេបោះឆ្នោត ដើម្បីចូលកាន់មុខតំណែង និងបំពេញគ្រប់មុខងារសាធារណៈ ឱ្យមានប្រសិទ្ធភាព នៅគ្រប់ជាន់ថ្នាក់ នៃស្ថាប័នរដ្ឋាភិបាល ដោយជួយសំរួលដល់ការប្រើប្រាស់បច្ចេកវិទ្យាជំនួយថ្មីៗ ដែលសមស្រប។

(iii)- ធានាដល់ជនពិការ នូវការសំដែងឆន្ទៈ ដោយសេរី ក្នុងឋានៈជាអ្នកបោះឆ្នោត ហើយដើម្បីសម្រេចគោលដៅនេះ ក្នុងករណីចាំបាច់ និងតាមសំណើរបស់ជនពិការ អនុញ្ញាតឱ្យមានការជួយក្នុងការបោះឆ្នោតជំនួស ដោយអ្នកណាម្នាក់តាមការជ្រើសរើសរបស់ពួកគេ។

ខ. ជំរុញយ៉ាងសកម្មឱ្យមានបរិយាកាសមួយ ដែលជនពិការអាចចូលរួមយ៉ាងពេញលេញ និងជាក់ស្តែងក្នុងដំណើរការកិច្ចការសាធារណៈ ដោយគ្មានការរើសអើង និងដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកផ្សេងទៀត ព្រមទាំងលើកទឹកចិត្តឱ្យពួកគេ ចូលរួមក្នុងកិច្ចការសាធារណៈ រួមមាន៖

(i)- ការចូលរួមក្នុងអង្គការក្រៅរដ្ឋាភិបាល និងសមាគមនានាដែលពាក់ព័ន្ធនឹងជីវភាពនយោបាយ និងជីវភាពសាធារណៈរបស់ប្រទេសនិងក្នុងសកម្មភាព និងរដ្ឋបាលរបស់គណបក្សនយោបាយ។

(ii)- ការបង្កើត និងការចូលរួមក្នុងអង្គការនានារបស់ជនពិការ ដើម្បីធ្វើជាអ្នកតំណាងជនពិការ នៅថ្នាក់មូលដ្ឋាន ថ្នាក់តំបន់ ថ្នាក់ជាតិ និងនៅលើឆាកអន្តរជាតិ។

## មាត្រា៣០: ការចូលរួមក្នុងជីវភាពវប្បធម៌ ការឈប់សម្រាក ការលំហែ និងកីឡា

១- រដ្ឋភាគីទទួលស្គាល់សិទ្ធិរបស់ជនពិការ ក្នុងការចូលរួមក្នុងជីវភាពវប្បធម៌ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកផ្សេងទៀត ហើយរដ្ឋភាគីត្រូវចាត់វាល់វិធានការសមស្រប ដើម្បីធានាថា ជនពិការ៖

ក. មានសិទ្ធិទទួលបានសំភារៈវប្បធម៌តាមទ្រង់ទ្រាយដែលគេអាចទទួលបាន។

ខ. មានសិទ្ធិទទួលបានកម្មវិធីទូរទស្សន៍ ភាពយន្ត ល្ខោន និងសកម្មភាពវប្បធម៌ផ្សេងៗ ក្នុងទ្រង់ទ្រាយដែលគេអាចទទួលបាន។

គ. មានសិទ្ធិចូលដល់ទីកន្លែងសម្រាប់ការសំដែង ឬសេវាកម្មវប្បធម៌ ដូចជារោងល្ខោន សារមន្ទីរ រោងភាពយន្ត បណ្ណាល័យ និងសេវាកម្មទេសចរណ៍ ព្រមទាំងតាមលទ្ធភាពដែលអាចធ្វើទៅបាន មានសិទ្ធិចូលដល់បូជនីយស្ថាន និងរមណីយដ្ឋានសំខាន់ៗរបស់វប្បធម៌ជាតិ។

២- រដ្ឋភាគី ត្រូវចាត់វិធានការសមស្របនានា ដើម្បីឱ្យជនពិការអាចមានឱកាសអភិវឌ្ឍន៍ និងប្រើប្រាស់សក្តានុពលខាងបញ្ញា សិល្បៈ និងគំនិតច្នៃប្រឌិតរបស់ខ្លួនមិនត្រឹមតែដើម្បីផលប្រយោជន៍របស់ខ្លួនប៉ុណ្ណោះទេ ថែមទាំងដើម្បីភាពសំបូរបែបរបស់សង្គមទៀតផង។

៣- រដ្ឋភាគីត្រូវចាត់រាល់វិធានការសមស្រប ដោយអនុលោមតាមច្បាប់អន្តរជាតិដើម្បីធានាថា ច្បាប់ទាំងឡាយដែលការពារកម្មសិទ្ធិបញ្ញាមិនបង្កឧបសគ្គដែលមិនសមហេតុផល ឬរើសអើងអ្វីឡើយ ដល់ជនពិការ ក្នុងការទទួលបានសំភារៈវប្បធម៌។

៤- ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកផ្សេងទៀត ជនពិការត្រូវមានសិទ្ធិបានការទទួលស្គាល់ និងការគាំទ្រនៃអត្តសញ្ញាណផ្នែកភាសា និងវប្បធម៌ជាក់លាក់របស់ខ្លួន រួមទាំងភាសា សញ្ញា និងវប្បធម៌មនុស្សគ។

៥- ក្នុងទស្សនៈជួយឱ្យជនពិការ អាចចូលរួមដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកផ្សេងទៀត និងក្នុងសកម្មភាពនានា ផ្នែកកីឡា ការលំហែ និងការកំសាន្ត រដ្ឋភាគីត្រូវចាត់វិធានការសម ស្របផ្សេងៗដូចតទៅ៖

ក. ជំរុញ និងលើកស្ទួយការចូលរួមរបស់ជនពិការឱ្យបានខ្លាំងក្លា តាមដែលអាចធ្វើទៅបាន ក្នុងសកម្មភាពកីឡាជាសាធារណៈនៅគ្រប់កម្រិត។

ខ. ធានាថាជនពិការមានឱកាសរៀបចំ ចាត់ចែង អភិវឌ្ឍ និងចូលរួមក្នុងសកម្មភាពកីឡា និងការកំសាន្ត ពិសេសសម្រាប់ជនពិការ ហើយដើម្បីសម្រេចបានគោលដៅនេះ ត្រូវជំរុញឱ្យមានការផ្ដល់ការណែនាំ ការបណ្ដុះបណ្ដាល និងធនធានសមស្រប ដោយផ្អែកលើគោលការណ៍ស្មើភាពគ្នាជាមួយអ្នកផ្សេងទៀត។

គ. ធានាថា ជនពិការ អាចមានទីកន្លែងសម្រាប់លេងកីឡា ការកំសាន្ត និងទេសចរណ៍។

ឃ. ធានាថាកុមារពិការមានសិទ្ធិទទួលបានស្មើភាពគ្នាជាមួយកុមារផ្សេងទៀត ក្នុងការចូលរួមក្នុងសកម្មភាពកីឡា ការលំហែ ការកំសាន្ត និងការសំដែងរួមទាំងសកម្មភាពទាំងឡាយនៅក្នុងប្រព័ន្ធសាលារៀនផង។

ង. ធានាថា ជនពិការ មានសិទ្ធិទទួលបានសេវាកម្មពីអ្នកទាំងឡាយដែលពាក់ព័ន្ធនឹងការរៀបចំសកម្មភាពកីឡា ការលំហែ ទេសចរណ៍ និងការកំសាន្ត។

## មាត្រា៣១: ស្ថិតិ និងការប្រមូលទិន្នន័យ

១- រដ្ឋភាគីទទួលខុសត្រូវប្រមូលព័ត៌មានសមស្រប រួមទាំងទិន្នន័យស្ថិតិ និងស្រាវជ្រាវ ដើម្បីឱ្យជនពិការអាចតាក់តែង និងអនុវត្តគោលនយោបាយ ដើម្បីធ្វើឱ្យអនុសញ្ញានេះមានប្រសិទ្ធភាព។ ដំណើរការប្រមូលនិងរក្សាព័ត៌មាននេះត្រូវៈ

ក.អនុលោមតាមវិធានការការពារ ដែលបានបង្កើតស្របច្បាប់ រួមទាំងច្បាប់ស្ដីពីការការពារទិន្នន័យ ដើម្បីធានាការសំងាត់ និងការគោរពសិទ្ធិឯកជនរបស់ជនពិការ។

ខ. អនុលោមតាមបទដ្ឋានដែលបានទទួលស្គាល់ជាអន្តរជាតិ ដើម្បីការពារសិទ្ធិមនុស្ស និងសេរីភាពជាសារវន្ត និងគោលការណ៍ក្រមសីលធម៌ក្នុងការប្រមូល និងការប្រើប្រាស់ស្ថិតិ។

២- ព័ត៌មានដែលប្រមូលបាន ស្របតាមមាត្រានេះ ត្រូវបានបំបែក និងត្រូវបានប្រើប្រាស់តាមការសមស្រប ដើម្បីជួយវាយតម្លៃការអនុវត្តន៍កាតព្វកិច្ចរបស់រដ្ឋភាគី តាមអនុសញ្ញានេះ និងដើម្បីកំណត់ និងដោះស្រាយឧបសគ្គនានាដែលជនពិការជួបប្រទះក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន។

៣- រដ្ឋភាគី ត្រូវទទួលខុសត្រូវចំពោះការផ្សព្វផ្សាយស្ថិតិទាំងនេះ និងធានាថា ស្ថិតិទាំងនេះ នឹងបានទៅដល់ដៃជនពិការ និងអ្នកដទៃទៀត។

## មាត្រា៣២: កិច្ចសហប្រតិបត្តិការអន្តរជាតិ

១- រដ្ឋភាគី ទទួលស្គាល់ពីសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការអន្តរជាតិ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការនេះ ក្នុងការគាំទ្រដល់ការខិតខំប្រឹងប្រែងថ្នាក់ជាតិ ចំពោះការធ្វើឱ្យបានសម្រេចនូវគោលបំណង និងទិសដៅរបស់អនុសញ្ញានេះ ហើយនឹងចាត់វិធានការសមស្រប និងមានប្រសិទ្ធភាពចំពោះបញ្ហានេះ រវាងនិងក្នុងចំណោមរដ្ឋ និងដៃគូជាមួយអង្គការអន្តរជាតិ និងតំបន់ដែលពាក់ព័ន្ធ និងសង្គមស៊ីវិល តាមការសមស្រប ជាពិសេសអង្គការជនពិការ។ វិធានការបែបនេះ រួមមានជាអាទ៍ៈ

ក. ការធានាថា កិច្ចសហប្រតិបត្តិការអន្តរជាតិ រួមទាំងកម្មវិធីអភិវឌ្ឍន៍អន្តរជាតិនានា ត្រូវមានបញ្ចូលជនពិការ ហើយត្រូវបានដល់ដៃជនពិការ។

ខ. ការសម្របសម្រួល និងការគាំទ្រដល់ការកសាងសមត្ថភាព រួមទាំងតាមរយៈការផ្លាស់ប្តូរ និងការចែករំលែកព័តមាន បទពិសោធន៍ កម្មវិធីបណ្តុះបណ្តាល និងការអនុវត្តល្អៗ។

គ. ការសម្របសម្រួលដល់កិច្ចសហប្រតិបត្តិការ ក្នុងការស្រាវជ្រាវ និងការទទួលបានចំណេះដឹង បច្ចេកទេស និងវិទ្យាសាស្ត្រ។

ឃ.ការផ្តល់ជំនួយសេដ្ឋកិច្ច និងបច្ចេកទេសសមស្រប រួមទាំង តាមរយៈការជួយសម្រួលដល់ការទទួលបាន និងការចែករំលែក នូវបច្ចេកវិទ្យាជំនួយ និងអាចទទួលបាន និងតាមរយៈការផ្ទេរបច្ចេក វិទ្យា។

២. បទបញ្ញត្តិនៃមាត្រានេះ មិនធ្វើឱ្យប៉ះពាល់ដល់កាតព្វកិច្ចរបស់រដ្ឋភាគីនីមួយៗ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន តាមអនុសញ្ញានេះឡើយ។

## មាត្រា៣៣: ការអនុវត្ត និងតាមដានត្រួតពិនិត្យថ្នាក់ជាតិ

១- អនុលោមតាមប្រព័ន្ធនៃរចនាសម្ព័ន្ធរបស់ខ្លួន រដ្ឋភាគីត្រូវចាត់តាំងអ្នកសម្របសម្រួលម្នាក់ ឬច្រើននាក់ក្នុងស្ថាប័នរដ្ឋាភិបាល សម្រាប់កិច្ចការដែលទាក់ទងនឹងការអនុវត្តអនុសញ្ញានេះ ហើយត្រូវធ្វើការពិចារណាឱ្យបានត្រឹមត្រូវក្នុងការបង្កើត ឬការចាត់តាំងយន្តការសម្របសម្រួលមួយនៅក្នុងរដ្ឋាភិបាល ដើម្បីជួយសម្រួលដល់សកម្មភាពដែលពាក់ព័ន្ធក្នុងវិស័យ និងនៅកម្រិតផ្សេងគ្នា។

២- អនុលោមតាមប្រព័ន្ធរដ្ឋបាល និងប្រព័ន្ធច្បាប់របស់ខ្លួន រដ្ឋភាគីត្រូវរក្សាពង្រឹង ចាត់តាំង ឬបង្កើតនូវក្របខណ្ឌមួយនៅក្នុងរដ្ឋភាគី រួមទាំងយន្តការឯករាជ្យមួយ ឬច្រើន តាមការសមស្រប ដើម្បីលើកស្ទួយ ការពារ និងតាមដាន ត្រួតពិនិត្យការអនុវត្តអនុសញ្ញានេះ។ នៅពេលតែងតាំង ឬបង្កើតយន្តការបែបនេះ រដ្ឋភាគី ត្រូវយកចិត្តទុកដាក់ចំពោះគោលការណ៍ដែលពាក់ព័ន្ធដល់ឋានៈ និងការប្រព្រឹត្តទៅរបស់ស្ថាប័នជាតិនានា ដើម្បីការពារ និងលើកស្ទួយសិទ្ធិមនុស្ស។

៣- សង្គមស៊ីវិល ជាពិសេសជនពិការនិងអង្គការតំណាងឱ្យជនពិការ ត្រូវមានទំនាក់ទំនងនិងចូលរួមយ៉ាងពេញលេញក្នុងដំណើរការតាមដានត្រួតពិនិត្យ។

## មាត្រា៣៤: គណៈកម្មាធិការទទួលបន្ទុកសិទ្ធិជនពិការ

១- គណៈកម្មាធិការទទួលបន្ទុកសិទ្ធិជនពិការមួយ (តទៅនេះ ហៅថា គណៈកម្មាធិការ) ត្រូវបានបង្កើតឡើង ដែលនឹងត្រូវបំពេញមុខនាទីដូចមានចែងនៅក្នុងមាត្រានេះ។

២- នៅពេលដែលអនុសញ្ញានេះចូលជាធរមាន គណៈកម្មាធិការនេះ ត្រូវមានអ្នកជំនាញការ ១២រូប។ បន្ទាប់ពីមានការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកចំនួន៦០បន្ថែមទៀត លើអនុសញ្ញានេះ ចំនួនសមាជិករបស់គណៈកម្មាធិការនេះត្រូវបង្កើនចំនួន ៦រូបទៀត តែទោះយ៉ាងណា ត្រូវរក្សាចំនួនសមាជិកអតិបរមាត្រឹម ១៨រូប។

៣- សមាជិកគណៈកម្មាធិការនេះ ត្រូវបំពេញការងារ តាមសមត្ថភាពរៀងៗខ្លួន និងត្រូវមានសីលធម៌ខ្ពស់ ព្រមទាំងមានសមត្ថភាព និងបទពិសោធន៍ដែលត្រូវបានទទួលស្គាល់លើវិស័យ ដែលគ្របដណ្ដប់ដោយអនុសញ្ញានេះ។ នៅពេលតែងតាំងបេក្ខភាពរបស់ខ្លួន រដ្ឋភាគីត្រូវបានអញ្ជើញឱ្យធ្វើការពិចារណាឱ្យបានត្រឹមត្រូវ ទៅលើបទបញ្ញត្តិដែលមានចែងនៅក្នុងមាត្រា៤ វាក្យខ័ណ្ឌ៣ នៃអនុសញ្ញានេះ។

៤- សមាជិកគណៈកម្មាធិការ ត្រូវបានជ្រើសរើសដោយការបោះឆ្នោតដោយរដ្ឋភាគី ដោយឈរលើមូលដ្ឋាននៃការបែងចែកស្មើភាព តាមលក្ខណៈភូមិសាស្ត្រ ភាពតំណាងនៃទម្រង់ផ្សេងៗរបស់អរិយធម៌ និងភាពតំណាងនៃប្រព័ន្ធច្បាប់សំខាន់ៗត្រូវមានតុល្យភាព តំណាងយេនឌ័រ និងការចូលរួមពីអ្នកជំនាញការដែលជាជនពិការ។

៥- សមាជិកគណៈកម្មាធិការ ត្រូវជ្រើសរើសដោយការបោះឆ្នោត ជាសំងាត់ ពីបញ្ជីឈ្មោះបេក្ខជន ដែលត្រូវបានតែងតាំងដោយរដ្ឋភាគីពីក្នុងចំណោមជនជាតិនៃរដ្ឋភាគីនោះ នៅឯកិច្ចប្រជុំនៃសន្និសីទរបស់រដ្ឋភាគី។ ក្នុងកិច្ចប្រជុំទាំងនោះ កូរ៉ុមត្រូវកំណត់ចំនួនពីរភាគបីនៃរដ្ឋភាគី ហើយបេក្ខជនដែលត្រូវបានគេបោះឆ្នោតឱ្យចូលជាសមាជិកនៃគណៈកម្មាធិការនេះ គឺជាអ្នកដែលទទួលបានសំលេងឆ្នោតច្រើនជាងគេ និងទទួលបានសំលេងភាគច្រើនដាច់ខាតពីតំណាងនៃរដ្ឋភាគី ដែលមានវត្តមាន និងមានសិទ្ធិបោះឆ្នោត។

៦- ការបោះឆ្នោតដំបូងត្រូវធ្វើឡើងមិនឱ្យហួសរយៈពេល៦ខែ ក្រោយពីថ្ងៃដែលអនុសញ្ញានេះ ចូលជាធរមាន។ យ៉ាងហោច៤ខែមុនថ្ងៃបោះឆ្នោតនីមួយៗ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវផ្ញើលិខិតទៅរដ្ឋភាគី ដើម្បីអញ្ជើញរដ្ឋទាំងនោះ ឱ្យដាក់សំណើតែងតាំងបេក្ខភាពរបស់ខ្លួន ក្នុងរយៈពេលពីរខែ។ បន្ទាប់មក អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវរៀបចំបញ្ជីឈ្មោះតាមលំដាប់អក្ខរក្រមនៃបេក្ខជនទាំងអស់ ដែលត្រូវបានតែងតាំង ដោយបញ្ជាក់ពីឈ្មោះរដ្ឋភាគីដែលបានតែងតាំងបេក្ខជនទាំងនោះផង ហើយត្រូវដាក់ជូនរដ្ឋភាគីនៃអនុសញ្ញានេះវិញ។

៧- សមាជិកគណៈកម្មាធិការ ត្រូវបានជ្រើសតាំងសម្រាប់ អណត្តិរយៈពេល៤ឆ្នាំ។ សមាជិកទាំងនេះ ត្រូវមានសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតសាជាថ្មីបានតែម្តងប៉ុណ្ណោះ។ ប៉ុន្តែអណត្តិរបស់សមាជិកចំនួន៦រូប នៃសមាជិកទាំងអស់ដែលត្រូវបានជ្រើសរើសកាលពីការបោះឆ្នោតលើកទី១ ត្រូវផុតកំណត់នៅចុងបញ្ចប់នៃឆ្នាំទីពីរ។ បន្ទាប់ពីការបោះឆ្នោតលើកទី១ភ្លាម ឈ្មោះរបស់សមាជិកទាំង៦រូបនេះ ត្រូវបានចាប់ឆ្នោតជ្រើសរើស ដោយប្រធាននៃកិច្ចប្រជុំ យោងតាមកថាខ័ណ្ឌទី៥ នៃមាត្រានេះ។

៨- ការបោះឆ្នោតជ្រើសរើសសមាជិក ៦រូបបន្ថែម នៃគណៈកម្មាធិការនេះ ត្រូវធ្វើឡើងក្នុងឱកាសនៃការបោះឆ្នោតជាទៀងទាត់ ស្របទៅតាមបទបញ្ញត្តិពាក់ព័ន្ធនៃមាត្រានេះ។

៩- ប្រសិនបើសមាជិកណាម្នាក់នៃគណៈកម្មាធិការនេះស្លាប់ ឬលាលែងពីតំណែង ឬប្រកាសថា គាត់មិនអាចបំពេញភារកិច្ចរបស់ខ្លួនបានទៀតទេ ដោយសារមូលហេតុអ្វីក៏ដោយ រដ្ឋភាគីដែលតែងតាំងសមាជិកនោះ ត្រូវតែងតាំងអ្នកជំនាញការម្នាក់ទៀត ដែលមានគុណសម្បត្តិ និងបំពេញបានតាមលក្ខខណ្ឌដែលតម្រូវ នៅក្នុងបទបញ្ញត្តិពាក់ព័ន្ធនៃមាត្រានេះ ដើម្បីបន្តបំពេញការងាររហូតដល់ចប់អាណត្តិ។

១០- គណៈកម្មាធិការ ត្រូវបង្កើតបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

១១- អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវផ្តល់បុគ្គលិក និងសំភារៈបរិក្ខារចាំបាច់ដើម្បីឱ្យគណៈកម្មាធិការនេះ បំពេញតួនាទីប្រកបដោយប្រសិទ្ធភាពតាមអនុសញ្ញានេះ ហើយត្រូវកោះប្រជុំលើកដំបូងរបស់គណៈកម្មាធិការ។

១២- ដោយមានការអនុម័តយល់ព្រមពីមហាសន្និបាតអង្គការសហប្រជាជាតិ សមាជិកគណៈកម្មាធិការ ដែលត្រូវបានបង្កើតឡើងតាមអនុសញ្ញានេះ ត្រូវទទួលបានប្រាក់ឧបត្ថម្ភពីប្រភពអង្គការសហប្រជាជាតិ តាមលក្ខខណ្ឌ និងខទាំងឡាយ ដូចដែលមហាសន្និបាតបានសម្រេច គិតគូរអំពីសារៈសំខាន់នៃការទទួលខុសត្រូវរបស់គណៈកម្មាធិការនេះ។

១៣- សមាជិកគណៈកម្មាធិការ ត្រូវមានសិទ្ធិប្រើប្រាស់សំភារៈផ្សេងៗ មានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិជាអ្នកជំនាញការដែលកំពុងបំពេញបេសកកម្មឱ្យអង្គការសហប្រជាជាតិ ដូចដែលមានចែងក្នុង ប្រការពាក់ព័ន្ធទាំងឡាយនៃសន្ធិសញ្ញាស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់អង្គការសហប្រជាជាតិ។

## មាត្រា៣៥: របាយការណ៍របស់រដ្ឋភាគី

១- តាមរយៈអគ្គលេខាធិការអង្គការសហប្រជាជាតិ រដ្ឋភាគីនីមួយៗ ត្រូវដាក់របាយការណ៍រួម ស្តីពីការចាត់វិធានការណ៍នានា ដើម្បីអនុវត្តកាតព្វកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពតាមអនុសញ្ញានេះ និងស្តីពីការវិវត្តដែលសម្រេចបានលើកិច្ចការទាំងនេះ ក្នុងរយៈពេលពីរឆ្នាំ បន្ទាប់ពីអនុសញ្ញានេះ ចូលជាធរមាន។

២- បន្ទាប់ពីនេះ រដ្ឋភាគី ត្រូវដាក់របាយការណ៍បន្តបន្ទាប់របស់ខ្លួន យ៉ាងហោចណាស់រៀងរាល់បួនឆ្នាំម្តង និងព័ត៌មានបន្ថែមទៀត នៅពេលណាដែលគណៈកម្មាធិការស្នើសុំ។

៣- គណៈកម្មាធិការ ត្រូវសម្រេចពីគោលការណ៍ណែនាំ ដែលអាចអនុវត្តបានចំពោះមាតិកានៃរបាយការណ៍។

៤- រដ្ឋភាគីដែលបានដាក់របាយការណ៍រួមលើកដំបូងទៅគណៈកម្មាធិការ ពុំចាំបាច់លើកឡើងពីព័ត៌មានដដែលៗ ដែលបានផ្តល់កាលពីមុន នៅក្នុងរបាយការណ៍បន្តបន្ទាប់លើកក្រោយទៀតនោះទេ។ នៅពេលរៀបចំធ្វើរបាយការណ៍ជូនគណៈកម្មាធិការ រដ្ឋភាគី ត្រូវពិចារណាធ្វើកិច្ចការនេះ ក្នុងដំណើរការមួយដែលបើកចំហ និងមានតម្លាភាព និងត្រូវផ្តល់ការពិចារណាឱ្យបានត្រឹមត្រូវ ទៅតាមបទបញ្ញត្តិដែលមានចែងក្នុងមាត្រា៤ វាក្យខ័ណ្ឌ៣នៃអនុសញ្ញានេះ។

៥- របាយការណ៍ អាចបង្ហាញពីកត្តាផ្សេងៗ និងការលំបាកនានា ដែលប៉ះពាល់ដល់កម្រិត នៃការបំពេញកាតព្វកិច្ច តាមអនុសញ្ញានេះ។

## មាត្រា៣៦: ការពិនិត្យពិចារណាលើរបាយការណ៍

១- របាយការណ៍នីមួយៗត្រូវបានពិនិត្យពិចារណាដោយគណៈកម្មាធិការ ដែលត្រូវធ្វើសំណូមពរ និងផ្តល់អនុសាសន៍ទូទៅ ដល់របាយការណ៍ តាមដែលគណៈកម្មាធិការយល់ឃើញថា សមស្រប រួចត្រូវបញ្ជូនសំណូមពរនិងអនុសាសន៍ទាំងនេះ ទៅរដ្ឋភាគីសាមីវិញ។ រដ្ឋភាគីនោះ អាចឆ្លើយតបនឹងព័ត៌មានណាមួយដែលខ្លួនជ្រើសរើស ទៅគណៈកម្មាធិការវិញ។ គណៈកម្មាធិការ អាចស្នើសុំព័ត៌មានបន្ថែមពីរដ្ឋភាគីដែលពាក់ព័ន្ធនឹងការអនុវត្តអនុសញ្ញានេះ។

២- ប្រសិនបើរដ្ឋភាគីមួយ យឺតយ៉ាវខ្លាំងក្នុងការដាក់ជូនរបាយការណ៍ គណៈកម្មាធិការអាចជូនដំណឹងដល់រដ្ឋភាគីសាមីនោះអំពីសេចក្តីត្រូវការ ដើម្បីត្រួតពិនិត្យការអនុវត្តអនុសញ្ញានេះ នៅក្នុងរដ្ឋភាគីនោះ ដោយផ្អែកលើព័ត៌មានគួរឱ្យទុកចិត្តដែលគណៈកម្មាធិការ ទទួលបាន ប្រសិនបើរបាយការណ៍ពាក់ព័ន្ធ មិនត្រូវបានប្រគល់ជូនក្នុងរយៈពេលបីខែ បន្ទាប់ពីការជូនដំណឹង។ គណៈកម្មាធិការត្រូវអញ្ជើញរដ្ឋភាគីសាមីឱ្យចូលរួមក្នុងការត្រួតពិនិត្យបែបនេះ។ ប្រសិនបើរដ្ឋភាគីឆ្លើយតប ដោយប្រគល់របាយការណ៍ពាក់ព័ន្ធបទបញ្ញត្តិក្នុងកថាខណ្ឌទី១នៃមាត្រានេះ នឹងត្រូវបានអនុវត្ត។

៣- អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវចែករបាយការណ៍ទាំងនោះ ដល់គ្រប់រដ្ឋភាគីទាំងអស់។

៤- រដ្ឋភាគី ត្រូវផ្សព្វផ្សាយរបាយការណ៍របស់ខ្លួន ឱ្យបានទូលំទូលាយដល់សាធារណៈជន ក្នុងប្រទេសរបស់ខ្លួន ហើយជួយសម្រួលដល់ការទទួលបានសំណូមពរ និងអនុសាសន៍ទូទៅដែលពាក់ព័ន្ធនឹងរបាយការណ៍នេះ។

៥- គណៈកម្មាធិការ ត្រូវបញ្ជូនរបាយការណ៍ដែលបានទទួលពីរដ្ឋភាគីតាមតែខ្លួនយល់ឃើញថាសមស្រប ទៅទីភ្នាក់ងារជំនាញ ស្ថាប័ន មូលនិធិ និងកម្មវិធីនានារបស់អង្គការសហប្រជាជាតិ និងអង្គភាពមានសមត្ថកិច្ចផ្សេងៗទៀត ដើម្បីស្នើសុំ ឬបញ្ជាក់ពីតម្រូវការផ្នែកប្រឹក្សា ឬជំនួយបច្ចេកទេស ដូចមាននៅក្នុងរបាយការណ៍ទាំងនោះ ដោយរួមជាមួយនឹងការកត់សម្គាល់ និងអនុសាសន៍របស់គណៈកម្មាធិការ ចំពោះសំណើ និងសេចក្តីបញ្ជាក់ទាំងនេះ ប្រសិនបើមាន។

### មាត្រា៣៧: កិច្ចសហប្រតិបត្តិការ រវាងរដ្ឋភាគី និងគណៈកម្មាធិការ

១- រដ្ឋភាគីនីមួយៗ ត្រូវធ្វើសហប្រតិបត្តិការជាមួយគណៈកម្មាធិការ និងជួយសមាជិកគណៈកម្មាធិការនេះ ក្នុងការបំពេញការងារក្នុងអណត្តិរបស់ពួកគេ។

២- ក្នុងទំនាក់ទំនងរបស់ខ្លួនជាមួយរដ្ឋភាគី គណៈកម្មាធិការ ត្រូវគិតពិចារណាឱ្យបានត្រឹមត្រូវដល់វិធី និងមធ្យោបាយនៃការលើកកម្ពស់សមត្ថភាពជាតិក្នុងការអនុវត្តអនុសញ្ញានេះ រួមទាំងតាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិ។

### មាត្រា៣៨: ទំនាក់ទំនងរបស់គណៈកម្មាធិការជាមួយស្ថាប័នផ្សេងៗទៀត

ដើម្បីជំរុញឱ្យមានការអនុវត្តអនុសញ្ញានេះ ឱ្យមានប្រសិទ្ធភាព និងដើម្បីលើកទឹកចិត្តដល់កិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងវិស័យដូចមានចែងក្នុងអនុសញ្ញានេះ៖

ក- ទីភ្នាក់ងារជំនាញ និងស្ថាប័ននានារបស់អង្គការសហប្រជាជាតិ ត្រូវមានអ្នកតំណាង ដើម្បីចូលរួមក្នុងការពិចារណា លើការអនុវត្តនៃបទបញ្ញត្តិរបស់អនុសញ្ញានេះ អនុសាសន៍ តាមវិសាលភាពនៃអាណត្តិរបស់អង្គការនីមួយៗ។ គណៈកម្មាធិការ អាចកោះអញ្ជើញទីភ្នាក់ងារជំនាញ និងស្ថាប័នមានសមត្ថកិច្ចនានា តាមតែខ្លួនយល់ឃើញថាសមស្រប ដើម្បីផ្តល់ប្រឹក្សាជំនាញពីការអនុវត្តអនុសញ្ញាក្នុងវិស័យដែលស្ថិតក្នុងក្របខ័ណ្ឌនៃអណត្តិរបស់ខ្លួន។ គណៈកម្មាធិការ អាចអញ្ជើញទីភ្នាក់ងារជំនាញ និងស្ថាប័ននានារបស់អង្គការសហប្រជាជាតិ ឲ្យផ្តល់របាយការណ៍ស្តីពីការអនុវត្តអនុសញ្ញា ក្នុងវិស័យដែលស្ថិតក្នុងក្របខ័ណ្ឌនៃសកម្មភាពរបស់ខ្លួន។

ខ-នៅពេលបំពេញអណត្តិរបស់ខ្លួន គណៈកម្មាធិការត្រូវពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធដទៃទៀត ដែលត្រូវបានបង្កើតឡើងដោយសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិតាមការសមស្រប ដើម្បីធានាពីភាពស៊ីសង្វាក់គ្នានៃគោលការណ៍ណែនាំសម្រាប់ធ្វើរបាយការណ៍នីមួយៗ សំណូមពរ និងអនុសាសន៍ទូទៅ និងដើម្បីជៀសវាងនូវភាពត្រួតគ្នា និងជាន់ភារកិច្ចគ្នាក្នុងការបំពេញមុខងារ។

### មាត្រា៣៩: របាយការណ៍របស់គណៈកម្មាធិការ

គណៈកម្មាធិការ ត្រូវធ្វើរបាយការណ៍ជារៀងរាល់ពីរឆ្នាំម្តងជូនមហាសន្និបាត និងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិស្តីពីសកម្មភាពរបស់ខ្លួន ហើយអាចធ្វើសំណូមពរ និងផ្តល់អនុសាសន៍ទូទៅ ដោយផ្អែកលើការត្រួតពិនិត្យរបាយការណ៍ និងព័ត៌មានដែលទទួលបានពីរដ្ឋភាគី។ សំណូមពរ និងអនុសាសន៍ទូទៅទាំងនោះ ត្រូវដាក់បញ្ចូលក្នុងរបាយការណ៍របស់គណៈកម្មាធិការ រួមជាមួយនឹងមតិរបស់រដ្ឋភាគី ប្រសិនបើមាន។

### មាត្រា៤០: សន្និសីទរបស់រដ្ឋភាគី

១- រដ្ឋភាគី ត្រូវជួបប្រជុំគ្នាជាទៀងទាត់ក្នុងសន្និសីទរបស់ខ្លួន ដើម្បីពិនិត្យពិចារណាលើបញ្ហាណាមួយ ដែលទាក់ទងនឹងការអនុវត្តអនុសញ្ញានេះ។

២- អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវកោះប្រជុំសន្និសីទរបស់រដ្ឋភាគី មិនឱ្យហួសរយៈពេល៦ខែ បន្ទាប់ពីអនុសញ្ញានេះចូលជាធរមាន។ កិច្ចប្រជុំជាបន្តបន្ទាប់ ត្រូវបានកោះប្រជុំ ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ រៀងរាល់ពីរឆ្នាំម្តង ឬតាមការសម្រេចរបស់សន្និសីទនៃរដ្ឋភាគី។

### មាត្រា៤១: អ្នកតម្កល់ទុកឯកសារ

អគ្គលេខាធិការអង្គការសហប្រជាជាតិ ជាអ្នករក្សាទុកអនុសញ្ញានេះ។

### មាត្រា៤២: ការចុះហត្ថលេខា

អនុសញ្ញានេះ ត្រូវបើកចំហដល់រដ្ឋទាំងអស់ និងអង្គការសមាហរណកម្មនានាថ្នាក់តំបន់ ចុះហត្ថលេខានៅឯទីស្នាក់ការអង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉ក ត្រឹមថ្ងៃទី៣០-មិថុនា-២០០៧។

### មាត្រា៤៣: សេចក្តីយល់ព្រមអនុវត្តន៍

អនុសញ្ញានេះ ត្រូវតែជាកម្មវត្ថុនៃការផ្តល់សច្ចាប័នដោយរដ្ឋហត្ថលេខី ហើយជាកម្មវត្ថុនៃការបញ្ជាក់ជាផ្លូវការ ដោយអង្គការសមាហរណកម្មនានាថ្នាក់តំបន់ដែលជាហត្ថលេខី។ អនុសញ្ញានេះ ត្រូវបើកចំហចំពោះការចូលជាសមាជិកដោយរដ្ឋ ឬអង្គការសមាហរណកម្មតំបន់ដែលមិនបានចុះហត្ថលេខាលើអនុសញ្ញានេះ។

## មាត្រា៨៨: អង្គការសមាហរណកម្មនានាថ្នាក់តំបន់

១- "អង្គការសមាហរណកម្មតំបន់" មានន័យថា ជាអង្គការដែលបង្កើតឡើងដោយរដ្ឋ ដែលមានអធិបតេយ្យភាពនៃតំបន់ណាមួយដែលរដ្ឋជាសមាជិកនៅក្នុងតំបន់នោះ បានប្រគល់សមត្ថកិច្ចឱ្យដោះស្រាយបញ្ហានានា ដែលគ្រប់គ្រងដោយអនុសញ្ញានេះ។ អង្គការទាំងនេះ ត្រូវប្រកាសនៅក្នុងលិខិតុបករណ៍នៃការបញ្ជាក់ជាផ្លូវការ ឬការចូលជាសមាជិករបស់ខ្លួនអំពីវិសាលភាពនៃសមត្ថកិច្ចរបស់ខ្លួនក្នុងការដោះស្រាយបញ្ហានានាដែលគ្រប់គ្រងដោយអនុសញ្ញានេះ។ បន្ទាប់មកអង្គការទាំងនោះ ត្រូវជូនដំណឹងដល់អ្នកតម្កល់ទុកឯកសារពីការកែប្រែខសំខាន់ៗណាមួយ នៅក្នុងវិសាលភាពនៃសមត្ថកិច្ចរបស់ខ្លួន។

២- បទបញ្ញត្តិទាំងឡាយដែលនិយាយយោងដល់ "រដ្ឋភាគី" នៅក្នុងអនុសញ្ញានេះត្រូវអនុវត្តចំពោះអង្គការទាំងនេះ នៅក្នុងព្រំដែននៃសមត្ថកិច្ចរបស់ខ្លួន។

៣- ចំពោះគោលបំណងនៃមាត្រា៤៥ កថាខ័ណ្ឌទី១ និងមាត្រា៤៧ កថាខ័ណ្ឌទី២ និងទី៣នៃ អនុសញ្ញានេះ លិខិតុបករណ៍ណាក៏ដោយ ដែលត្រូវតម្កល់ទុកដោយអង្គការសមាហរណកម្មថ្នាក់តំបន់មួយ មិនត្រូវបានរាប់បញ្ចូលទេ។

៤- ចំពោះបញ្ហាស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន អង្គការសមាហរណកម្មថ្នាក់តំបន់ អាចប្រើប្រាស់សិទ្ធិរបស់ខ្លួនដើម្បីបោះឆ្នោតនៅឯសន្និសីទនៃរដ្ឋភាគី ដោយមានចំនួនសន្លឹកឆ្នោតស្មើនឹងចំនួននៃប្រទេសជាសមាជិករបស់អង្គការនេះ ដែលជាភាគីនៃអនុសញ្ញា។ អង្គការនេះ មិនអាចប្រើសិទ្ធិបោះឆ្នោតរបស់ខ្លួនបានទេ ប្រសិនបើប្រទេសជាសមាជិករបស់ខ្លួន ប្រើសិទ្ធិបោះឆ្នោតនោះហើយ ឬបញ្ច្រាស់គ្នាមកវិញ។

## មាត្រា៤៩: ការចូលជាធរមាន

១- អនុសញ្ញានេះ ត្រូវចូលជាធរមាននៅថ្ងៃទី៣០ បន្ទាប់ពីមានការតម្កល់ទុកលិខិតុបករណ៍ចំនួន២០ នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិក។

២- ចំពោះរដ្ឋ ឬអង្គការសមាហរណកម្មថ្នាក់តំបន់នីមួយៗដែលនឹងផ្តល់សច្ចាប័ន ការបញ្ជាក់ជាផ្លូវការឬការចូលជាសមាជិកនៃ អនុសញ្ញានេះ ក្រោយពីការតម្កល់ទុកលិខិតុបករណ៍ចំនួន២០នោះ អនុសញ្ញានេះ ត្រូវចូលជាធរមាននៅ៣០ថ្ងៃចំពោះរដ្ឋនោះ ក្រោយពីការតម្កល់ទុកលិខិតុបករណ៍របស់ខ្លួន។

## មាត្រា៤៦: ការដាក់លក្ខខណ្ឌ

១- ការដាក់លក្ខខណ្ឌដែលមិនស្របនឹងកម្មវត្ថុ និងគោលបំណងនៃអនុសញ្ញានេះ មិនត្រូវបានអនុញ្ញាតឡើយ។

២- ការដាក់លក្ខខណ្ឌដូចខាងលើនេះ អាចត្រូវបានដកវិញនៅពេលណាក៏បាន។

## មាត្រា៤៧: ការធ្វើវិសោធនកម្ម

១- រដ្ឋភាគីណាក៏ដោយ អាចស្នើសុំធ្វើវិសោធនកម្មអនុសញ្ញានេះបាន រួចដាក់សំណើនោះ ជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ។ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវជូនព័ត៌មានស្តីពីសំណើធ្វើវិសោធនកម្មទាំងឡាយ ទៅរដ្ឋភាគី ដោយស្នើសុំឱ្យរដ្ឋទាំងនោះបញ្ជាក់ថាតើខ្លួនគាំទ្រឱ្យមានសន្និសីទនៃរដ្ឋភាគីចំពោះគោលបំណងនៃការពិចារណា និងការសម្រេចលើសំណើទាំងនោះឬអត់។ ក្នុងរយៈពេល៤ខែ គិតចាប់ពីថ្ងៃដែលជូនដំណឹងនោះមក ក្នុងករណីដែលរដ្ឋភាគីយ៉ាងតិចមួយភាគបីគាំទ្រឱ្យមានសន្និសីទបែបនេះ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវកោះប្រជុំសន្និសីទនេះ ក្រោមកិច្ចឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ។ ការធ្វើវិសោធនកម្មណាមួយ ដែលអនុម័តដោយសំលេងភាគច្រើន ពីរភាគបីនៃរដ្ឋភាគីដែលមានវត្តមាន និងមានសិទ្ធិបោះឆ្នោត ត្រូវបានអគ្គលេខាធិការអង្គការសហប្រជាជាតិ ដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិ សម្រាប់ការអនុម័តយល់ព្រម រួចហើយជូនទៅគ្រប់រដ្ឋភាគីសម្រាប់ការទទួលយល់ព្រម។

២- ការធ្វើវិសោធនកម្មដែលបានយល់ព្រម និងអនុម័ត អនុលោមទៅតាមកថាខ័ណ្ឌទី១ នៃមាត្រានេះ ត្រូវចូលជាធរមាន៣០ថ្ងៃ បន្ទាប់ពីមានចំនួនលិខិតុបករណ៍នៃការទទួលយល់ព្រម ត្រូវបានតម្កល់ទុក ឡើងដល់ពីរភាគបីនៃរដ្ឋភាគី

នៅថ្ងៃធ្វើការអនុម័តវិសោធនកម្មនេះ។ បន្ទាប់មក វិសោធនកម្មនេះ ត្រូវចូលជាធរមានសម្រាប់រដ្ឋភាគីណាក៏ដោយ នា៣០ថ្ងៃ ក្រោយពីការតម្កល់ទុកលិខិតុបករណ៍នៃការទទួលយល់ព្រមរបស់ខ្លួន។ វិសោធនកម្មអនុវត្តបាន តែចំពោះរដ្ឋភាគីណាដែលបានទទួលយល់ព្រមលើការធ្វើវិសោធនកម្មនោះតែប៉ុណ្ណោះ។

៣- ប្រសិនបើការធ្វើវិសោធនកម្មនេះ ត្រូវបានសម្រេចដោយសន្និសីទនៃរដ្ឋភាគីដោយការយល់ព្រមជាឯកច្ឆ័ន្ទ ការធ្វើវិសោធនកម្មដែលបានយល់ព្រម និងអនុម័ត ដោយអនុលោមតាមកថាខ័ណ្ឌទី១នៃមាត្រានេះ ដែលពាក់ព័ន្ធទាំងស្រុងទៅនឹងមាត្រា៣៤,៣៨,៣៩និង៤០ ត្រូវចូលជាធរមាន សម្រាប់គ្រប់រដ្ឋភាគី នា៣០ថ្ងៃ បន្ទាប់ពីមានចំនួនលិខិតុបករណ៍នៃការទទួលយល់ព្រម ត្រូវបានតម្កល់ទុកឡើងដល់ពីរភាគបីនៃរដ្ឋភាគី នៅថ្ងៃធ្វើការអនុម័តវិសោធនកម្មនេះ។

## មាត្រា៤៨: ការដកខ្លួនចេញពីអនុសញ្ញា

រដ្ឋភាគីមួយអាចដកខ្លួនចេញពីអនុសញ្ញានេះបាន ដោយជូនដំណឹងជាលាយល័ក្ខណ៍អក្សរ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។ ការដកខ្លួននេះត្រូវមានប្រសិទ្ធភាព នៅ១ឆ្នាំក្រោយ បន្ទាប់ពីថ្ងៃដែលអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបានសេចក្តីជូនដំណឹងនោះ។

## មាត្រា៤៩: លក្ខណៈងាយស្រួលប្រើប្រាស់

អត្ថបទនៃអនុសញ្ញានេះ ត្រូវតែធ្វើឡើងក្នុងទំរង់ដែលមានលក្ខណៈងាយស្រួលប្រើប្រាស់។

## មាត្រា៥០: អត្ថបទដើម

អត្ថបទដើមនៃអនុសញ្ញានេះ មានជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ មានតម្លៃស្មើគ្នា។ ដើម្បីទុកជាសក្ខីភាព តំណាងពេញសមត្ថភាពដែលបានចុះហត្ថលេខាខាងក្រោម ដោយទទួលបានការអនុញ្ញាតត្រឹមត្រូវពីរដ្ឋាភិបាលនីមួយៗ បានចុះហត្ថលេខាលើអនុសញ្ញានេះ។

# ១៣-ក- ពិធីសារបន្ថែមលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ

ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៦
និងចូលជាធរមានកាលពីថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០៨ ស្របតាមមាត្រា១៣(១)
កម្ពុជាបានចុះហត្ថលេខាលើពិធីសារបន្ថែមនេះកាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៧

រដ្ឋភាគីនៃពិធីសារនេះ បានព្រមព្រៀងគ្នាដូចតទៅ៖

**មាត្រា១.-**

១. រដ្ឋភាគីនៃពិធីសារនេះ "រដ្ឋភាគី" ទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការសិទ្ធិជនពិការ "គណៈកម្មាធិការ" ក្នុងការទទួល និងពិនិត្យបណ្តឹងដែលធ្វើដោយបុគ្គល ឬក្នុងនាមបុគ្គលឬក្រុមបុគ្គល ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់រដ្ឋភាគី ដែលអះអាងថា ជាជនរងគ្រោះពីការរំលោភដោយរដ្ឋភាគី ទៅលើបទបញ្ញាតិនៃអនុសញ្ញានេះ។

២. គណៈកម្មាធិការមិនទទួលបណ្តឹងមកពិនិត្យទេ ប្រសិនបើបណ្តឹងនោះពាក់ព័ន្ធនឹងរដ្ឋភាគីនៃអនុសញ្ញាដែលមិនមែនជាភាគីនៃពិធីសារនេះ។

**មាត្រា២.-**

គណៈកម្មាធិការ ត្រូវចាត់ទុកថា ជាបណ្តឹងដែលមិនអាចទទួលដោះស្រាយឲ្យបាន ប្រសិនបើ៖

ក- ជាបណ្តឹងអនាមិក។

ខ- ជាបណ្តឹងរំលោភសិទ្ធិដាក់ពាក្យបណ្តឹងបែបនេះឬមានវិសមិតភាពនឹងបទបញ្ញាតិនៃអនុសញ្ញានេះ។

គ- ជាបញ្ហាដដែលនេះ ត្រូវបានគណៈកម្មាធិការពិនិត្យរួចម្តងហើយ ឬត្រូវបាន និងកំពុងពិនិត្យ ស្របតាមនីតិវិធីនៃការស៊ើបអង្កេត ឬការដោះស្រាយជាអន្តរជាតិ។

ឃ- មិនទាន់បានប្រើប្រាស់អស់ដំណោះស្រាយទាំងប៉ុន្មានដែលមាននៅក្នុងស្រុក។ នេះមិនមែនជាវិធានការ ដែលអនុវត្តដំណោះស្រាយ ត្រូវបានពន្យា

ដោយមិនសមហេតុផល ឬមិនទំនងជានាំមកនូវដំណោះស្រាយជាវិជ្ជមាន និងមានប្រសិទ្ធភាពទេនោះ។

ង- មិនបានបញ្ជាក់ពីមូលហេតុច្បាស់លាស់ ឬគ្មានភស្តុតាងគ្រប់គ្រាន់សម្រាប់ធ្វើជាអំណះអំណាង ឬ

ច- នៅពេលដែលអង្គហេតុជាកម្មវត្ថុនៃបណ្ដឹង បានកើតមាននៅមុនថ្ងៃចូលជាធរមាននៃពិធីសារនេះ សម្រាប់រដ្ឋភាគីពាក់ព័ន្ធ បើពុំនោះទេ លើកលែងតែអង្គហេតុនោះ បានបន្តរហូតដល់ក្រោយថ្ងៃចូលជាធរមាននៃពិធីសារនេះ។

### មាត្រា៣.-

ស្របតាមបទបញ្ញត្តិមាត្រា២នៃពិធីសារនេះ គណៈកម្មាធិការ ត្រូវផ្ដល់ដំណឹងជាសំងាត់ ដល់រដ្ឋភាគីពាក់ព័ន្ធអំពីបណ្ដឹងដែលបានបញ្ជូនមកឱ្យខ្លួន។ ក្នុងរយៈពេល៦ខែ រដ្ឋចុងចំលើយ ត្រូវបញ្ជូនការពន្យល់ជាលាយល័ក្ខណ៍អក្សរ ឬសេចក្ដីថ្លែងការណ៍បំភ្លឺបញ្ហា និងការដោះស្រាយរបស់រដ្ឋនោះទៅគណៈកម្មាធិការប្រសិនជាមាន។

### មាត្រា៤.-

១- នៅគ្រប់ពេល បន្ទាប់ពីការទទួលបណ្ដឹង និងនៅមុនពេលឈានដល់ការសម្រេចលើអង្គសេចក្ដី គណៈកម្មាធិការ អាចបញ្ជូនទៅរដ្ឋភាគីពាក់ព័ន្ធ ដើម្បីពិនិត្យជាបន្ទាន់លើសំណើឲ្យរដ្ឋភាគីនេះ ចាត់វិធានការបណ្ដោះអាសន្ន ដែលអាចជាការចាំបាច់ ដើម្បីជៀសវាងការខូចខាត ដែលមិនអាចកែបាន ដល់ជនរងគ្រោះ ឬជួសជុលសំណងដល់ជនរងគ្រោះម្នាក់ ឬច្រើននាក់ដែលអះអាងថា បានទទួលរងការរំលោភ។

២- ក្នុងករណីគណៈកម្មាធិការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ស្របតាមកថាខ័ណ្ឌទី១នៃមាត្រានេះ គណៈកម្មាធិការមិនបាច់បញ្ជាក់អំពីការសម្រេចទទួលយក ឬការសម្រេចលើអង្គសេចក្ដីនៃបណ្ដឹងឡើយ។

មាត្រា៥.-

គណៈកម្មាធិការ ត្រូវប្រជុំជាសំងាត់នៅពេលពិនិត្យបណ្តឹងទាំងឡាយដែលស្ថិតនៅក្រៅយុត្តាធិការនៃពិធីសារនេះ។ បន្ទាប់ពីពិនិត្យបណ្តឹងរួច គណៈកម្មាធិការ ត្រូវបញ្ជូនការយល់ឃើញអំពីបណ្តឹងនោះ រួមជាមួយអនុសាសន៍របស់ខ្លួន ប្រសិនជាមាន ទៅរដ្ឋភាគីពាក់ព័ន្ធ និងទៅអ្នកប្តឹងទាមទារ។

មាត្រា៦.-

១. ប្រសិនបើ គណៈកម្មាធិការ ទទួលព័ត៌មានគួរឱ្យទុកចិត្តដែលបង្ហាញឱ្យឃើញពីការរំលោភធ្ងន់ធ្ងរ ឬជាប្រព័ន្ធដោយរដ្ឋភាគី ទៅលើសិទ្ធិទាំងឡាយដែលមានចែងក្នុងអនុសញ្ញានេះ គណៈកម្មាធិការ ត្រូវអញ្ជើញរដ្ឋភាគីនោះ ឱ្យសហការពិនិត្យព័ត៌មាន និងផ្តល់ការកត់សម្គាល់ចំពោះព័ត៌មានពាក់ព័ន្ធ។

២. ក្នុងការពិចារណាលើការកត់សម្គាល់របស់រដ្ឋភាគីពាក់ព័ន្ធដែលបានបញ្ជូនមក ក៏ដូចជាព័ត៌មានពាក់ព័ន្ធ ដែលអាចទុកចិត្តបានផ្សេងទៀតផង គណៈកម្មាធិការ អាចចាត់តាំងសមាជិកម្នាក់ ឬច្រើននាក់ ឱ្យធ្វើការស៊ើបអង្កេត និងរាយការណ៍ជាបន្ទាន់មកគណៈកម្មាធិការ។ ប្រសិនជាមានការធានា និងដោយមានការយល់ព្រមពីរដ្ឋភាគី ការស៊ើបអង្កេតនេះ អាចរួមទាំងការអញ្ជើញទៅកាន់ទឹកដីនៃរដ្ឋនោះផង។

៣. ក្រោយពីការពិនិត្យរបកគំហើញនៃការស៊ើបអង្កេតនេះរួច គណៈកម្មាធិការ ត្រូវបញ្ជូនរបកគំហើញទាំងនេះ ទៅរដ្ឋភាគីពាក់ព័ន្ធ រួមជាមួយនឹងការផ្តល់យោបល់ និងអនុសាសន៍។

៤.រដ្ឋភាគីពាក់ព័ន្ធត្រូវបញ្ជូនការកត់សម្គាល់របស់ខ្លួនទៅគណៈកម្មាធិការក្នុងរយៈពេល៦ខែ បន្ទាប់ពីការទទួលរបកគំហើញ ការផ្តល់យោបល់ និងអនុសាសន៍ ដែលគណៈកម្មាធិការបានបញ្ជូនមក

៥. ការស៊ើបអង្កេតនេះ ត្រូវធ្វើជាសំងាត់ និងត្រូវស្វែងរកកិច្ចសហការពីរដ្ឋភាគី នៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនេះ។

**មាត្រា៧.-**

១. គណៈកម្មាធិការ អាចអញ្ជើញរដ្ឋភាគីពាក់ព័ន្ធ បញ្ចូលបន្ថែមទៅក្នុងរបាយការណ៍របស់ខ្លួន ស្របតាមមាត្រា៣៥ នៃអនុសញ្ញានេះ នូវព័ត៌មានលំអិតនៃវិធានការនានាដែលបានចាត់ឡើង ដើម្បីឆ្លើយតបទៅនឹងការស៊ើបអង្កេត ដែលបានធ្វើឡើងតាមមាត្រា៦ នៃពិធីសារនេះ។

២. ក្នុងករណីចាំបាច់ គណៈកម្មាធិការ អាចអញ្ជើញរដ្ឋភាគីពាក់ព័ន្ធឱ្យផ្តល់ព័ត៌មានឱ្យខ្លួន អំពីវិធានការទាំងឡាយដែលបានចាត់ឡើង ដើម្បីឆ្លើយតបទៅនឹងការស៊ើបអង្កេតនេះ បន្ទាប់ពីផុតរយៈពេល៦ខែ ដូចមានចែងក្នុងមាត្រា៦ កថាខ័ណ្ឌទី៤ នៃពិធីសារនេះ។

**មាត្រា៨.-**

រដ្ឋភាគីនីមួយៗ អាចប្រកាសនៅពេលចុះហត្ថលេខា ឬផ្តល់សច្ចាប័នលើពិធីសារនេះ ឬចូលជាសមាជិកនៃពិធីសារនេះថា ខ្លួនមិនទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការនេះ ដូចមានចែងក្នុងមាត្រា៦ និងមាត្រា៧ ឡើយ។

**មាត្រា៩.-**

អគ្គលេខាធិការអង្គការសហប្រជាជាតិ ជាអ្នកទទួលរក្សាទុកពិធីសារនេះ។

**មាត្រា១០.-**

ពិធីសារនេះ បើកចំហដល់រដ្ឋហត្ថលេខី និងអង្គការសមាហរណកម្មថ្នាក់តំបន់នៃអនុសញ្ញា ចុះហត្ថលេខានៅទីស្នាក់ការអង្គការសហប្រជាជាតិក្នុងទីក្រុងញូវយ៉ក ចាប់ពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៧ តទៅ។

**មាត្រា១១.-**

ពិធីសារនេះ ត្រូវជាកម្មវត្ថុនៃការឱ្យសច្ចាប័ន ដោយរដ្ឋហត្ថលេខីនៃពិធីសារនេះដែលបានផ្តល់សច្ចាប័ន ឬបានចូលជាសមាជិកនៃអនុសញ្ញា។ ពិធីសារនេះត្រូវជាកម្មវត្ថុនៃការបញ្ជាក់ជាផ្លូវការ ដោយអង្គការសមាហរណកម្មថ្នាក់តំបន់ដែល

ជាហត្ថលេខីនៃពិធីសារនេះ ដែលបានបញ្ជាក់ជាផ្លូវការ ឬបានចូលជាសមាជិកនៃអនុសញ្ញា។ ពិធីសារនេះបើកចំហសម្រាប់ការចូលជាសមាជិកដោយរដ្ឋ ឬអង្គការសមាហរណកម្មថ្នាក់តំបន់ណាមួយ ដែលបានផ្តល់សច្ចាប័ន បានបញ្ជាក់ជាផ្លូវការ ឬបានចូលជាសមាជិកនៃអនុសញ្ញានេះ ហើយដែលមិនទាន់បានចុះហត្ថលេខាលើពិធីសារនេះ។

មាត្រា១២.-

១. "អង្គការសមាហរណកម្មតំបន់" គឺជាអង្គការមួយ ដែលត្រូវបានបង្កើតឡើងដោយរដ្ឋអធិបតេយ្យទាំងឡាយនៃតំបន់ណាមួយ ហើយដែលរដ្ឋសមាជិកទាំងនោះ បានផ្ទេរសមត្ថកិច្ចមកឲ្យ ក្នុងក្របខ័ណ្ឌនៃបញ្ហាដែលគ្រប់គ្រងដោយអនុសញ្ញា និងពិធីសារនេះ។ អង្គការទាំងនេះ ត្រូវប្រកាសក្នុងលិខិតុបករណ៍នៃការបញ្ជាក់ ឬការចូលជាសមាជិកផ្លូវការអំពីដែនសមត្ថកិច្ចរបស់ខ្លួន ពាក់ព័ន្ធនឹងបញ្ហាដែលគ្រប់គ្រងដោយអនុសញ្ញា និងពិធីសារនេះ។ បន្ទាប់មក អង្គការទាំងនោះ ត្រូវជូនដំណឹងទៅប័ណ្ណសារដ្ឋានអង្គការសហប្រជាជាតិ អំពីការកែប្រែខ្លឹមសារណាមួយ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

២. បញ្ញត្តិដែលចែងពីពាក្យថា "រដ្ឋភាគី" នៅក្នុងពិធីសារនេះ ត្រូវអនុវត្តចំពោះអង្គការទាំងនេះ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

៣. សម្រាប់គោលបំណងនៃមាត្រា១៣ កថាខ័ណ្ឌទី១ និងមាត្រា១៥ កថាខ័ណ្ឌទី២ នៃពិធីសារនេះ លិខិតុបករណ៍ណាមួយដែលបានតម្កល់ដោយអង្គការសមាហរណកម្មតំបន់មួយ មិនត្រូវបានទទួលស្គាល់ជាផ្លូវការឡើយ។

៤. អង្គការសមាហរណកម្មតំបន់ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន អាចប្រើប្រាស់សិទ្ធិបោះឆ្នោត នៅក្នុងការប្រជុំរដ្ឋភាគី ចំនួនសន្លឹកឆ្នោត ត្រូវស្មើនឹងចំនួនរដ្ឋសមាជិក ដែលជាភាគីនៃពិធិសារនេះ។ អង្គការនេះមិនអាចប្រើសិទ្ធិបោះឆ្នោតបានទេ ប្រសិនបើរដ្ឋសមាជិករបស់ខ្លួនណាមួយ ប្រើសិទ្ធិនេះរួចហើយ ឬបញ្ច្រាស់គ្នាមកវិញ។

### មាត្រា១៣.-

១. ស្របតាមការចូលជាធរមាននៃអនុសញ្ញានេះ ពិធីសារនេះ ត្រូវចូលជាធរមាន៣០ថ្ងៃបន្ទាប់ពីថ្ងៃតម្កល់លិខិតុបករណ៍ឱ្យសច្ចាប័នឬចូលជាសមាជិកទី១០.

២. ចំពោះរដ្ឋ ឬអង្គការសមាហរណកម្មនីមួយៗ ដែលឱ្យសច្ចាប័នលើពិធីសារនេះ បញ្ជាក់ជាផ្លូវការ ឬចូលជាសមាជិកនៃពិធីសារនេះ ក្រោយពីការតម្កល់លិខិតុបករណ៍ឱ្យសច្ចាប័នឬលិខិតុបករណ៍ចូលសមាជិកទី១០ ហើយពិធីសារនេះត្រូវចូលជាធរមាន៣០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទដែលរដ្ឋនីមួយៗ ដាក់តម្កល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬលិខិតុបករណ៍ចូលសមាជិករបស់ខ្លួន។

### មាត្រា១៤.-

១. លក្ខខ័ណ្ឌដែលវិសមិតភាពជាមួយគោលដៅ និងគោលបំណងនៃពិធីសារនេះ មិនត្រូវបានអនុញ្ញាតឡើយ។

២. ការដាក់ខលក្ខខណ្ឌ អាចត្រូវបានដកចេញវិញបានគ្រប់ពេលវេលា។

### មាត្រា១៥.-

១. រដ្ឋភាគីនៃពិធីសារនេះ អាចស្នើសុំធ្វើវិសោធនកម្មលើពិធីសារនេះ និងដាក់ជូនសំណើនេះ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។ អគ្គលេខាធិការត្រូវបញ្ជូនសេចក្តីស្នើសុំធ្វើវិសោធនកម្មនេះទៅរដ្ឋភាគីនៃពិធីសារនេះ ដោយសុំឱ្យរដ្ឋភាគីបញ្ជាក់ប្រាប់មកអគ្គលេខាធិការវិញ ថាតើយល់ព្រមឱ្យមានសន្និសីទនៃរដ្ឋភាគី ដើម្បីពិនិត្យ និងសម្រេចលើសេចក្តីស្នើសុំធ្វើវិសោធនកម្មឬទេ។ ក្នុងរយៈពេល៤ខែ គិតពីកាលបរិច្ឆេទនៃការជូនព័ត៌មានទៅរដ្ឋភាគី បើមានសម្លេង១ភាគ៣យ៉ាងតិច នៃរដ្ឋភាគីគាំទ្រឱ្យមានកិច្ចប្រជុំនេះ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវកោះប្រជុំ ក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ។ គ្រប់វិសោធនកម្មដែលអនុម័តដោយសំលេងភាគច្រើនពីរភាគបីនៃរដ្ឋភាគីវត្តមាន និងមានសិទ្ធិបោះឆ្នោត នៅឯកិច្ចប្រជុំ ត្រូវដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិ ដើម្បីសុំការយល់ព្រម ហើយបន្ទាប់មក ត្រូវបញ្ជូនទៅរដ្ឋភាគីទាំងអស់ ដើម្បីសុំការទទួលយក។

២. វិសោធនកម្មដែលបានអនុម័ត និងយល់ព្រម ស្របតាមកថាខ័ណ្ឌទី១ នៃមាត្រានេះ ចូលជាធរមាន៣០ថ្ងៃ បន្ទាប់ពីចំនួនលិខិតុបករណ៍នៃការទទួលយកបានតម្កល់គ្រប់ចំនួន២ភាគ៣នៃចំនួនរដ្ឋភាគី នៅកាលបរិច្ឆេទនៃការអនុម័តវិសោធនកម្មនេះ។ បន្ទាប់មក វិសោធនកម្ម ត្រូវចូលជាធរមាន៣០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទដែលរដ្ឋនោះ តម្កល់លិខិតុបករណ៍នៃការទទួលយករបស់ខ្លួន។ វិសោធនកម្មនេះ នឹងក្លាយជាកាតព្វកិច្ចសម្រាប់រដ្ឋភាគីទាំងឡាយដែលយល់ព្រមទទួលយក។

## មាត្រា១៦.-

រដ្ឋភាគី អាចប្រកាសដកខ្លួនចេញពីពិធីសារនេះ ដោយការជូនដំណឹងជាលាយល័ក្ខណ៍អក្សរ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។ ការប្រកាសដកខ្លួននេះ មានអានុភាព១ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទ ដែលអគ្គលេខាធិការបានទទួលការជូនដំណឹងនេះ។

## មាត្រា១៧.-

អត្ថបទនៃពិធីសារនេះ ត្រូវតែធ្វើឡើងក្នុងទម្រង់ដែលមានលក្ខណៈងាយស្រួលប្រើប្រាស់បាន រក្សាទុកសម្រាប់ប្រើប្រាស់ជាផ្លូវការ។

## មាត្រា១៨.-

ពិធីសារនេះ មានអត្ថបទជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ ដែលមានតម្លៃស្មើគ្នា។

**ជាបន្ទាល់នៃអនុសញ្ញានេះ** បុណ្ណទូតដែលចុះហត្ថលេខាខាងក្រោម ដោយបានទទួលនូវការអនុញ្ញាតយ៉ាងត្រឹមត្រូវពីរដ្ឋាភិបាលរបស់ខ្លួនរៀងៗខ្លួន បានចុះហត្ថលេខាលើពិធីសារនេះ។

# អនុសញ្ញាអន្តរជាតិ
# ស្តីពី
# ការការពារសិទ្ធិរបស់
# ពលករទេសន្តរប្រវេសន៍
# គ្រប់រូប និងសមាជិក
# គ្រួសាររបស់ពួកគេ

# ១៨. អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ

អនុម័តដោយសេចក្តីសម្រេចមហាសន្និបាតលេខ៤៥/១៥៨ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩០
ចូលជាធរមាននៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៣
កម្ពុជាបានចុះហត្ថលេខានៅថ្ងៃទី២៧ កញ្ញា ២០០៤

## បុព្វកថា

**រដ្ឋភាគីនៃអនុសញ្ញានេះ :**

*ដោយធ្វើការពិចារណា*លើគោលការណ៍ដែលមាននៅក្នុងលិខិតុបករណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិ ដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ជាពិសេស សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងស្ត្រីភេទ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ ។

*ដោយធ្វើការពិចារណាផងដែរ* លើគោលការណ៍ និងបទដ្ឋានដែលបានដាក់ចេញ នៅក្នុងលិខិតុបករណ៍ពាក់ព័ន្ធ ដែលបរិយាយនៅក្នុងក្របខ័ណ្ឌនៃអង្គការពលកម្មអន្តរជាតិ ជាពិសេស នៅក្នុងអនុសញ្ញាស្តីពីការធ្វើទេសន្តរប្រវេសន៍ដើម្បីស្វែងរកការងារធ្វើ (អនុសញ្ញាលេខ៩៧) អនុសញ្ញាស្តីពីការធ្វើទេសន្តរប្រវេសន៍នៅក្នុងស្ថានភាពដែលមានការរំលោភបំពាន និងការ

លើកកម្ពស់សមភាពនៃការផ្តល់ឱកាស និងការគ្រប់គ្រងពលករទេសន្តរប្រវេសន៏ (អនុសញ្ញាលេខ១៤៣) អនុសាសន៏ពាក់ព័ន្ធនឹងការធ្វើទេសន្តរប្រវេសន៏ដើម្បីស្វែងរកការងារធ្វើ (អនុសញ្ញាលេខ៨៦) អនុសាសន៏ពាក់ព័ន្ធនឹងពលករទេសន្តរប្រវេសន៏ (អនុសញ្ញាលេខ១៥១) អនុសញ្ញាស្តីពីពលកម្មដោយបង្ខំ ឬដោយជាប់កាតព្វកិច្ច (អនុសញ្ញាលេខ២៩) និងអនុសញ្ញាស្តីពីការលុបបំបាត់ពលកម្មដោយបង្ខំ (អនុសញ្ញាលេខ១០៥) ។

*ដោយគូសបញ្ជាក់សាជាថ្មី* នូវសារៈសំខាន់នៃគោលការណ៏ ដែលមានចែងនៅក្នុងអនុសញ្ញាប្រឆាំងនឹងការរើសអើង ក្នុងការអប់រំ របស់អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌នៃសហប្រជាជាតិ (UNESCO) ។

*ដោយរំឭកឡើងវិញ* ពីអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្ត ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថាបបន្ថោក, សេចក្តីប្រកាសរបស់សភាអង្គការសហប្រជាជាតិលើកទី៤ស្តីពីការបង្ការទប់ស្កាត់បទឧក្រិដ្ឋ និងការគ្រប់គ្រងជនល្មើស ក្រមសីលធម៌សម្រាប់មន្ត្រីប្រតិបត្តិច្បាប់ និងអនុសញ្ញាស្តីពីទាសភាព ។

*ដោយរំឭកឡើងវិញថា*គោលដៅមួយក្នុងចំណោមគោលដៅនានារបស់អង្គការពលកម្មអន្តរជាតិ ដូចដែលបានចែងនៅក្នុងធម្មនុញ្ញរបស់អង្គការនេះ គឺការការពារផលប្រយោជន៏ពលករ នៅពេលពួកគេទៅធ្វើការនៅប្រទេសផ្សេង ក្រៅពីប្រទេសរបស់ខ្លួន និង*ដោយចងចាំ*ពីជំនាញ និងបទពិសោធន៏ដែលអង្គការនេះមាន ពាក់ព័ន្ធនឹងបញ្ហាពលករទេសន្តរប្រវេសន៏និងសមាជិកគ្រួសាររបស់ពួកគេ ។

*ដោយទទួលស្គាល់* ពីសារៈសំខាន់នៃការងារពាក់ព័ន្ធនឹងពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ដែលបានធ្វើឡើងដោយស្ថាប័នផ្សេងៗរបស់អង្គការសហប្រជាជាតិ ជាពិសេស គណៈកម្មការសិទ្ធិមនុស្ស និងគណៈកម្មការអភិវឌ្ឍសង្គម ព្រមទាំងអង្គការស្បៀង និងកសិកម្មសហប្រជាជាតិ(FAO) អង្គការអប់រំវិទ្យាសាស្ត្រនិងវប្បធម៌សហប្រជាជាតិ (UNESCO) និងអង្គការសុខភាពពិភពលោក (WHO) ក៏ដូចជាអង្គការអន្តរជាតិដទៃទៀតដែរ ។

*ដោយទទួលស្គាល់ផងដែរ* ពីវឌ្ឍនភាពដែលរដ្ឋមួយចំនួន សម្រេចបានក្នុងកម្រិតតំបន់ឬទ្វេភាគីឆ្ពោះទៅរកការការពារសិទ្ធិពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ និងពីសារៈសំខាន់ និងសារៈប្រយោជន៍ នៃកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគីក្នុងវិស័យនេះ ។

*ដោយដឹង* ពីសារៈសំខាន់និងវិសាលភាពនៃបាតុភូតធ្វើទេសន្តរប្រវេសន៍ ដែលពាក់ព័ន្ធនឹងមនុស្សរាប់លាននាក់ និងប៉ះពាល់ដល់រដ្ឋមួយចំនួន នៅក្នុងសហគមន៍អន្តរជាតិ ។

*ដោយជ្រួតជ្រាប* ពីផលប៉ះពាល់នៃលំហូរពលករទេសន្តរប្រវេសន៍ មកលើប្រជាជន និងរដ្ឋសាមីនានា និងពីបំណងប្រាថ្នាបង្កើតបទដ្ឋាននានា ដែលអាចរួមចំណែកដល់សុខុមនីយកម្មនៃឥរិយាបថរបស់រដ្ឋនានា តាមរយៈការទទួលយកគោលការណ៍ជាមូលដ្ឋាន ស្តីពីការគ្រប់គ្រងពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ។

*ដោយយល់ឃើញ* ពីស្ថានភាពនៃភាពងាយរងគ្រោះដែលពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ តែងជួបប្រទះក្នុងចំណោមបញ្ហាដទៃទៀត ដោយសារតែពួកគេមិនមានវត្តមាននៅក្នុងរដ្ឋកំណើតរបស់ពួកគេ និងដោយសារតែការលំបាកនានា ដែលពួកគេអាចជួបប្រទះកើតចេញពីវត្តមានរបស់ពួកគេ នៅក្នុងរដ្ឋដែលទទួលឱ្យធ្វើការ ។

*ដោយជឿថា* សិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ពុំត្រូវបានទទួលស្គាល់ឱ្យបានគ្រប់គ្រាន់ នៅគ្រប់ទីកន្លែងនៅឡើយទេ ហេតុដូច្នេះ វាទាមទារឱ្យមានការការពារសមស្របជាលក្ខណៈអន្តរជាតិ ។

*ដោយធ្វើការពិចារណា* លើតថភាពដែលថា ជារឿយៗ ការធ្វើទេសន្តរប្រវេសន៍ គឺជាមូលហេតុនៃបញ្ហាធ្ងន់ធ្ងរ ដល់សមាជិកគ្រួសាររបស់ពលករទេសន្តរប្រវេសន៍ និងពលករខ្លួនឯង ជាពិសេស ដោយសារការត្រូវរស់នៅឆ្ងាយពីក្រុមគ្រួសាររបស់ខ្លួន ។

*ដោយចងចាំថា* បញ្ហាដែលមនុស្សជួបប្រទះ ដោយសារការធ្វើទេសន្តរប្រវេសន៍ កាន់តែមានសភាពធ្ងន់ធ្ងរនៅក្នុងករណីនៃការធ្វើទេសន្តរប្រវេសន៍មិនស្របច្បាប់ ហើយហេតុដូច្នេះ *ត្រូវជឿថា* គួរមានការលើកទឹកចិត្តឱ្យមានវិធានការសមស្រប ដើម្បីបង្ការទប់ស្កាត់និងលុបបំបាត់ចលនាលួចលាក់ និងការជួញដូរពលករទេសន្តរប្រវេសន៍ ហើយក្នុងពេលជាមួយគ្នា ធានាឱ្យមានការការពារសិទ្ធិមនុស្សជាមូលដ្ឋានរបស់ពួកគេ ។

*ដោយយល់ឃើញថា* ពលករដែលពុំមានឯកសារត្រឹមត្រូវ ឬស្ថិតនៅក្នុងស្ថានភាពមិនស្របច្បាប់ តែងត្រូវគេជួលឱ្យធ្វើការ ក្រោមលក្ខខណ្ឌមិនសូវអំណោយផល បើធៀបជាមួយនឹងពលករដទៃទៀត ហើយនិយោជកមួយចំនួន តែងចង់បានពលករបែបនេះ ឱ្យធ្វើការងារឱ្យខ្លួន ដើម្បីទាញប្រយោជន៍ពីការប្រកួតប្រជែងដោយមិនស្មើភាព ។

*ដោយបានពិចារណាឃើញផងដែរថា* ជម្រើសផ្តល់ការងារដល់ពលករទេសន្តរប្រវេសន៍ដែលខុសច្បាប់ នឹងមិនត្រូវបានលើកទឹកចិត្តឱ្យយកមកប្រើប្រាស់ឡើយ ប្រសិនបើសិទ្ធិមនុស្សជាមូលដ្ឋានរបស់ពលករទេសន្តរប្រវេសន៍ទាំងអស់ ត្រូវបានទទួលស្គាល់កាន់តែទូលំទូលាយ ហើយលើសពីនេះទៅទៀត *ក៏ពិចារណាឃើញថា* ការផ្តល់សិទ្ធិបន្ថែមមួយចំនួនដល់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេដែលស្របច្បាប់ នឹងលើកទឹកចិត្តឱ្យពលករទេសន្តរប្រវេសន៍ និងនិយោជកទាំងអស់ គោរព និងអនុវត្តតាមច្បាប់ និងនីតិវិធីនានា ដែលកំណត់ដោយរដ្ឋពាក់ព័ន្ធ ។

*ដោយយល់* ពីភាពចាំបាច់ ក្នុងការផ្តល់ការការពារជាអន្តរជាតិដល់សិទ្ធិពលករទេសន្តរប្រវេសន៍ទាំងអស់ និងសមាជិកគ្រួសាររបស់ពួកគេ ដោយគូសបញ្ជាក់ឡើងវិញ និងដោយបង្កើតបទដ្ឋានគ្រឹះនៅក្នុងអនុសញ្ញារួមមួយដែលអាចយកមកអនុវត្តបានជាសកល ។

**ដូច្នេះ បានឯកភាពគ្នាដូចខាងក្រោម :**

# ផ្នែកទី១: វិសាលភាព និងនិយមន័យ

## មាត្រា ១

លើកលែងតែមានការចែងផ្សេងពីនេះ អនុសញ្ញានេះ អាចអនុវត្តបានចំពោះគ្រប់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ដោយមិនមានការបែងចែកភេទ ពូជសាសន៍ ពណ៌សម្បុរ ភាសា សាសនា ឬជំនឿ ទស្សនៈនយោបាយ ឬទស្សនៈយល់ឃើញផ្សេងទៀត សញ្ជាតិ ជាតិសាសន៍ ឬដើមកំណើតសង្គម អាយុ ស្ថានភាពសេដ្ឋកិច្ច ទ្រព្យសម្បត្តិ ស្ថានភាពគ្រួសារ កំណើត ឬស្ថានភាពដទៃទៀតឡើយ។

អនុសញ្ញានេះ ត្រូវអនុវត្តនៅក្នុងដំណើរការធ្វើទេសន្តរប្រវេសន៍ទាំងមូលរបស់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ដូចជា ការរៀបចំធ្វើទេសន្តរប្រវេសន៍ ការចេញដំណើរ ការឆ្លងកាត់ និងរយៈពេលស្នាក់នៅទាំងស្រុង និងសកម្មភាពបានកម្រៃ នៅក្នុងរដ្ឋដែលទទួលឱ្យធ្វើការ និងពេលដែលពួកគេត្រលប់មករដ្ឋកំណើត ឬរដ្ឋដែលពួកគេ មានទីលំនៅអចិន្ត្រៃយ៍វិញ។

## មាត្រា ២

សម្រាប់គោលបំណងនៃអនុសញ្ញានេះ :

ពាក្យថា "ពលករទេសន្តរប្រវេសន៍" សំដៅលើបុគ្គលដែលត្រូវចូលរួម ឬបានចូលរួមនៅក្នុងសកម្មភាពបានកម្រៃ នៅក្នុងរដ្ឋមួយ ដែលបុគ្គលនោះមិនមានសញ្ជាតិនៃរដ្ឋនោះ។

(ក) ពាក្យថា"ពលករតាមព្រំដែន" សំដៅលើពលករទេសន្តរប្រវេសន៍ដែលមានទីសំណាក់នៅក្នុងរដ្ឋជិតខាងរបស់ខ្លួន ហើយតាមធម្មតា ពួកគេតែងត្រលប់មកលំនៅដ្ឋានអចិន្ត្រៃយ៍របស់គេវិញជារៀងរាល់ថ្ងៃ ឬយ៉ាងហោចណាស់ ម្តងក្នុងមួយសប្តាហ៍ ។

(ខ) ពាក្យថា "ពលករតាមរដូវ" សំដៅលើពលករទេសន្តរប្រវេសន៍ ដែលត្រូវទៅធ្វើការតាមរដូវ តាមលក្ខណៈចរិកនៃការងារនេះ ហើយក្នុងមួយឆ្នាំៗ ការងារនេះ ត្រូវធ្វើតែក្នុងមួយរយៈពេលប៉ុណ្ណោះ ។

(គ) ពាក្យថា "ពលករតាមសមុទ្រ" ដែលរាប់បញ្ចូលទាំងអ្នកនេសាទផង សំដៅលើពលករទេសន្តរប្រវេសន៍ ដែលគេជួលឱ្យធ្វើការនៅលើនាវាដែលចុះបញ្ជីកានៅក្នុងរដ្ឋដែលពលកររូបនេះមិនមានសញ្ជាតិនៃរដ្ឋនោះ។

(ឃ) ពាក្យថា"ពលករដែលធ្វើការងារលើទីតាំងក្នុងសមុទ្រ"សំដៅលើពលករទេសន្តរប្រវេសន៍ដែលគេជួលឱ្យធ្វើការលើទីតាំងណាមួយក្នុងសមុទ្រ ហើយដែលទីតាំងនោះ ស្ថិតក្នុងយុត្តាធិការរបស់រដ្ឋមួយ ដែលពលកររូបនេះមិនមានសញ្ជាតិនៃរដ្ឋនោះ។

(ង) ពាក្យថា "ពលករត្រាច់ចរ" សំដៅលើពលករទេសន្តរប្រវេសន៍ដែលមានទីលំនៅអចិន្ត្រៃយ៍នៅក្នុងរដ្ឋមួយ ហើយត្រូវធ្វើដំណើរទៅរដ្ឋមួយទៀត ឬរដ្ឋដទៃទៀតក្នុងរយៈពេលខ្លី ដោយសារតែលក្ខណៈចរិកនៃការងាររបស់ខ្លួន។

(ច) ពាក្យថា "ពលករធ្វើការតាមគម្រោង" សំដៅលើពលករទេសន្តរប្រវេសន៍ ដែលរដ្ឋមួយទទួលឱ្យធ្វើការងារ ក្នុងរយៈពេលមួយមានកំណត់ដើម្បីធ្វើការងារតែក្នុងគម្រោងជាក់លាក់ណាមួយ ដែលនិយោជករបស់ពលករក្នុងរដ្ឋនោះ ត្រូវអនុវត្ត។

(ឆ) ពាក្យថា"ពលករតាមការងារជាក់លាក់"សំដៅលើពលករទេសន្តរប្រវេសន៍ :

(i) ដែលនិយោជករបស់ខ្លួន បានបញ្ជូនទៅកាន់រដ្ឋមួយ ដែលគាត់ត្រូវបំពេញតួនាទី ភារកិច្ចណាមួយជាក់លាក់ នៅក្នុងរយៈពេលមួយមានកំណត់ ឬ

(ii) ដែលការងាររបស់គាត់ តម្រូវឱ្យមានជំនាញវិជ្ជាជីវៈ ពាណិជ្ជកម្ម បច្ចេកទេស ឬជំនាញឯកទេសកម្រិតខ្ពស់ដទៃទៀត នៅក្នុងរយៈពេលមួយជាក់លាក់ និងមានកំណត់ ឬ

(iii) ដែលការងាររបស់គាត់ ជាប្រភេទការងារក្នុងរយៈពេលខ្លី ឬជាការងារបណ្ដោះអាសន្ន ក្នុងរយៈពេលមួយជាក់លាក់ និងមានកំណត់ បន្ទាប់ពីមានការស្នើសុំពីនិយោជកនៅក្នុងរដ្ឋដែលពលកររូបនោះបំពេញការងារ និងដែលត្រូវចាកចេញពីរដ្ឋដែលខ្លួនបំពេញការងារវិញ នៅថ្ងៃផុតកំណត់នៃរយៈពេលដែលខ្លួនទទួលបានការអនុញ្ញាតឱ្យស្នាក់នៅ ឬត្រូវចាកចេញមុនកាលកំណត់ ប្រសិនបើពលកររូបនោះ មិនមានការចាំបាច់ក្នុងការបំពេញការងារ ឬគ្មានការងារអ្វីផ្សេងទៀតទេនោះ ។

(ជ) ពាក្យថា "ពលករស្វ័យបម្រើការងារ" សំដៅលើពលករទេសន្តរប្រវេសន៍ ដែលធ្វើសកម្មភាពបានកម្រៃ ដោយមិនស្ថិតក្រោមកិច្ចសន្យាការងារ និងទទួលបានចំណូលតាមធម្មតា ពីសកម្មភាពបំពេញការងារដោយឯកឯង ឬរួមជាមួយសមាជិកគ្រួសាររបស់ខ្លួន ហើយពលករស្វ័យបម្រើការងារ សំដៅលើពលករទេសន្តរប្រវេសន៍ផ្សេងទៀត ដែលច្បាប់របស់រដ្ឋអនុញ្ញាតឱ្យពួកគេបំពេញការងារ ឬកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគី ទទួលស្គាល់ថាជាពលករស្វ័យបម្រើការងារ ។

### មាត្រា ៣

អនុសញ្ញានេះមិនត្រូវអនុវត្តចំពោះ :

(ក) បុគ្គលដែលត្រូវបានបញ្ជូន ឬជួលឱ្យធ្វើការដោយអង្គការ និងទីភ្នាក់ងារអន្តរជាតិ ឬបុគ្គលដែលត្រូវបានបញ្ជូន ឬជួលដោយរដ្ឋខាងក្រៅដែនដីរបស់ខ្លួន ឱ្យបំពេញមុខងារជាផ្លូវការ ហើយដែលការទទួលយក និងឋានៈរបស់ពួកគេ ត្រូវបានកំណត់ដោយច្បាប់អន្តរជាតិទូទៅ ឬដោយកិច្ចព្រមព្រៀង ឬអនុសញ្ញាអន្តរជាតិជាក់លាក់ ។

(ខ) បុគ្គលដែលត្រូវបានបញ្ជូន ឬជួលឱ្យធ្វើការដោយរដ្ឋណាមួយ ឬ ក្នុងនាមតំណាងរបស់រដ្ឋនោះ នៅក្រៅដែនដីរបស់ខ្លួន ហើយដែលចូលរួម នៅក្នុងកម្មវិធីអភិវឌ្ឍន៍ និងកម្មវិធីសហប្រតិបត្តិការផ្សេងទៀត ហើយដែល ការទទួលយក និងឋានៈរបស់ពួកគេ ត្រូវបានកំណត់ដោយកិច្ចព្រមព្រៀង ជាមួយរដ្ឋដែលពួកគេបំពេញការងារ ហើយពួកគេមិនត្រូវបានចាត់ទុកជា ពលករទេសន្តរប្រវេសន៍ ស្របទៅតាមកិច្ចព្រមព្រៀងនោះទេ។

(គ) បុគ្គលជាវិនិយោគិនដែលមានទីលំនៅក្នុងរដ្ឋមួយក្រៅពីរដ្ឋកំណើត របស់ខ្លួន។

(ឃ) ជនភៀសខ្លួន ឬបុគ្គលគ្មានរដ្ឋ លើកលែងតែមានបញ្ញត្តិចែងឱ្យ អនុវត្តផ្ទុយពីនេះ នៅក្នុងច្បាប់ជាតិ ឬលិខិតុបករណ៍អន្តរជាតិដែលនៅជា ធរមាន សម្រាប់រដ្ឋភាគីដែលពាក់ព័ន្ធ។

(ង) សិស្ស និស្សិត និងកម្មសិក្សាការី ។

(ច) ពលករតាមសមុទ្រ និងពលករធ្វើការងារលើទីតាំងក្នុងសមុទ្រ ដែលមិនត្រូវបានទទួលឱ្យស្នាក់នៅ និងមិនអនុញ្ញាតឱ្យធ្វើសកម្មភាពបាន កម្រៃ នៅក្នុងរដ្ឋដែលទទួលឱ្យធ្វើការ។

## មាត្រា ៤

សម្រាប់គោលបំណងនៃអនុសញ្ញានេះ ពាក្យថា "សមាជិកគ្រួសារ" សំដៅលើបុគ្គលដែលរៀបអាពាហ៍ពិពាហ៍ ជាមួយពលករទេសន្តរប្រវេសន៍ ឬបង្កើតញាតិភាពជាមួយពលករទេសន្តរប្រវេសន៍ ដែលមានលក្ខណៈសម មូលទៅនឹងចំណងអាពាហ៍ពិពាហ៍ ស្របតាមច្បាប់ជាធរមាន រួមមាន កូន និងអ្នកនៅក្នុងបន្ទុកដទៃទៀត ដែលត្រូវបានទទួលស្គាល់ថា ជាសមាជិក គ្រួសារតាមច្បាប់ ឬកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគីដែលនៅជាធរមាន រវាងរដ្ឋដែលពាក់ព័ន្ធ ។

## មាត្រា ៥

សម្រាប់គោលបំណងនៃអនុសញ្ញានេះ ពលករទេសន្តរប្រវេសន៍ និង សមាជិកគ្រួសាររបស់ពួកគេ :

(ក) ត្រូវចាត់ទុកថាមានឯកសារត្រឹមត្រូវ ឬស្ថិតនៅក្នុងស្ថានភាពស្រប ច្បាប់ ប្រសិនបើពួកគេទទួលបានការអនុញ្ញាតឱ្យចូល ឱ្យស្នាក់នៅ និង ចូលរួមក្នុងសកម្មភាពបានកម្រៃ នៅក្នុងរដ្ឋដែលទទួលឱ្យធ្វើការ ដោយ អនុលោមទៅតាមច្បាប់របស់រដ្ឋនោះ និងទៅតាមកិច្ចព្រមព្រៀងអន្តរជាតិ ដែលរដ្ឋនោះ ជាភាគី ។

(ខ) ត្រូវបានចាត់ទុកថាពុំមានឯកសារត្រឹមត្រូវ ឬស្ថិតនៅក្នុងស្ថានភាព មិនស្របច្បាប់ ប្រសិនបើពួកគេ មិនអនុលោមទៅតាមលក្ខខណ្ឌ ដែលមាន ចែងនៅក្នុងអនុកថាខណ្ឌ (ក) នៃមាត្រានេះ ។

## មាត្រា ៦

សម្រាប់គោលបំណងនៃអនុសញ្ញានេះ

(ក) ពាក្យថា "រដ្ឋកំណើត" មានន័យថារដ្ឋដែលបុគ្គលសាមីមានសញ្ជាតិ ។

(ខ) ពាក្យថា "រដ្ឋដែលទទួលឱ្យធ្វើការ" មានន័យថា រដ្ឋដែលពលករ ទេសន្តរប្រវេសន៍បំពេញការងារដើម្បីរកកម្រៃ ។

(គ) ពាក្យថា "រដ្ឋឆ្លងកាត់" មានន័យថា រដ្ឋណាមួយដែលបុគ្គលសាមី ឆ្លងកាត់ នៅពេលដែលគាត់ធ្វើដំណើរទៅកាន់រដ្ឋ ដែលទទួលឱ្យធ្វើការ ឬពី រដ្ឋដែលទទួលឱ្យធ្វើការ ទៅរដ្ឋកំណើត ឬទៅរដ្ឋដែលគាត់កំពុងរស់នៅ ។

## ផ្នែកទី២៖ ការមិនរើសអើង ដោយការគោរពសិទ្ធិ

### មាត្រា ៧

អនុលោមតាមលិខិតុបករណ៍អន្តរជាតិនានាស្តីពីសិទ្ធិមនុស្ស រដ្ឋភាគីត្រូវគោរព និងធានាយ៉ាងណា ឱ្យពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ ទទួលបានសិទ្ធិដែលមានចែងនៅក្នុងអនុសញ្ញានេះ នៅក្នុងដែនដី ឬយុត្តាធិការរបស់ខ្លួន ដោយគ្មានការបែងចែកនៃប្រភេទណាមួយឡើយ ដូចជាភេទ ពូជសាសន៍ ពណ៌សម្បុរ ភាសា សាសនា ឬជំនឿ ទស្សនៈនយោបាយ ឬទស្សនៈយល់ឃើញផ្សេងទៀត ជាតិសាសន៍ ឬដើមកំណើតជាតិពន្ធុ ឬសង្គម សញ្ជាតិ អាយុ ស្ថានភាពសេដ្ឋកិច្ច ទ្រព្យសម្បត្តិ ស្ថានភាពគ្រួសារ កំណើត ឬស្ថានភាពដទៃទៀតឡើយ ។

## ផ្នែកទី៣៖
## សិទ្ធិមនុស្សរបស់ពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ

### មាត្រា ៨

១-ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ត្រូវមានសេរីភាពក្នុងការចាកចេញពីរដ្ឋណាមួយ រួមទាំង រដ្ឋកំណើតរបស់ពួកគេផង ។ សិទ្ធិនេះមិនត្រូវទទួលរងការដាក់កំហិតអ្វីទាំងអស់ លើកលែងតែការដាក់កំហិតទាំងឡាយណា ដែលតម្រូវដោយច្បាប់ និងដែលចាំបាច់ដើម្បីការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាពឬសីលធម៌សាធារណៈ ឬសិទ្ធិ និងសេរីភាពរបស់អ្នកដទៃទៀត ហើយដែលស្របទៅតាមសិទ្ធិដទៃទៀត ដែលត្រូវបានទទួលស្គាល់នៅក្នុងអនុសញ្ញានេះ ។

២-ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ត្រូវមានសិទ្ធិចូល និងបន្តស្នាក់នៅក្នុងរដ្ឋកំណើតរបស់ខ្លួន នៅពេលណាក៏បាន ។

## មាត្រា៩

សិទ្ធិរស់រានមានជីវិតរបស់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ត្រូវបានការពារដោយច្បាប់ ។

## មាត្រា ១០

ពុំមានពលករទេសន្តរប្រវេសន៍ ឬសមាជិកគ្រួសាររបស់ពួកគេណាម្នាក់ត្រូវទទួលរងទារុណកម្ម ឬការប្រព្រឹត្ត ឬទណ្ឌកម្មឯទៀតដែលឃោរឃៅអមនុស្សធម៌ ឬបន្ទាបបន្ថោកឡើយ ។

## មាត្រា ១១

១-ពុំមានពលករទេសន្តរប្រវេសន៍ ឬសមាជិកគ្រួសារណាម្នាក់របស់ពួកគេ ត្រូវបានគេរក្សាទុកក្នុងទាសភាព ឬសេវភាពឡើយ ។

២-ពុំមានពលករទេសន្តរប្រវេសន៍ ឬសមាជិកគ្រួសារណាម្នាក់របស់ពួកគេ ត្រូវបានគេតម្រូវឱ្យធ្វើពលកម្មដោយបង្ខំឬដោយជាប់កាតព្វកិច្ចឡើយ ។

៣-កថាខណ្ឌទី២នៃមាត្រានេះ មិនត្រូវយកមករារាំងមិនឱ្យអនុវត្តនៅក្នុងរដ្ឋដែលមានការដាក់ពន្ធនាគារ ដោយតម្រូវឱ្យមានការធ្វើពលកម្មធ្ងន់ធ្ងរទុកជាទោសទណ្ឌសម្រាប់បទល្មើសអ្វីមួយឡើយ តែការអនុវត្តពលកម្មធ្ងន់ធ្ងរ ទៅតាមការកាត់ទោស ឱ្យមានការដាក់ទោសទណ្ឌបែបនេះ ត្រូវធ្វើដោយតុលាការដែលមានសមត្ថកិច្ច ។

៤-សម្រាប់គោលបំណងនៃមាត្រានេះ ពាក្យថា "ពលកម្មដោយបង្ខំ ឬដោយជាប់កាតព្វកិច្ច" មិនត្រូវរាប់បញ្ចូល ៖

(ក) ការងារ ឬសេវាទាំងឡាយដែលមិនត្រូវបានលើកឡើងនៅក្នុងកថាខណ្ឌទី៣ នៃមាត្រានេះ ដែលជាធម្មតា តម្រូវឱ្យជនដែលត្រូវបានឃុំខ្លួនដោយសារតែដីកាស្របច្បាប់របស់តុលាការ ឬពីជនណាម្នាក់ នៅក្នុងកំឡុងពេលដោះលែង ដោយមានលក្ខខណ្ឌពីការឃុំខ្លួនបែបនេះ ។

(ខ) សេវាកម្មណា ដែលត្រូវមាននៅក្នុងករណីបន្ទាន់ ឬករណីមានគ្រោះមហន្តរាយដែលគំរាមកំហែងដល់អាយុជីវិតឬសុខុមាលភាពរបស់សហគមន៍

(គ) ការងារ ឬសេវាកម្មណាដែលបង្កើតជាផ្នែកមួយនៃកាតព្វកិច្ចស៊ីវិលធម្មតា ដរាបណាការងារ ឬសេវានេះ ក៏ត្រូវបានដាក់ឱ្យអនុវត្តលើប្រជាពលរដ្ឋរបស់រដ្ឋសាមីនោះផងដែរ ។

## មាត្រា ១២

១-ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ត្រូវមានសិទ្ធិមានសេរីភាពខាងគំនិត មនសិការ និងកាន់សាសនាអ្វីមួយ ។ សិទ្ធិនេះត្រូវរាប់បញ្ចូលសេរីភាពកាន់ ឬគោរពតាមសាសនា ឬជំនឿអ្វីមួយ ទៅតាមជម្រើស និងសេរីភាពរបស់ពួកគេ ជាឯកត្តបុគ្គលក្តី ឬជាមួយអ្នកដទៃ នៅក្នុងសហគមន៍ក្តី និងនៅតាមទីកន្លែងសាធារណៈ ឬឯកជន ដើម្បីបង្ហាញពីសាសនា ឬជំនឿរបស់ពួកគេ តាមរយៈការគោរពបូជា ការគោរពតាម ការប្រតិបត្តិ និងការបង្ហាត់បង្រៀន ជាដើម ។

២-ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ មិនត្រូវទទួលរងការបង្ខិតបង្ខំ ដែលធ្វើឱ្យប៉ះពាល់ដល់សេរីភាពរបស់ពួកគេ នៅក្នុងការប្រកាន់យក ឬគោរពតាមសាសនា ឬជំនឿ ទៅតាមជម្រើសរបស់ពួកគេឡើយ ។

៣-សេរីភាពបង្ហាញពីសាសនា ឬជំនឿរបស់បុគ្គលណាម្នាក់ អាចទទួលរងការដាក់កំហិតដែលត្រូវបានកំណត់ដោយច្បាប់ ហើយដែលចាំបាច់ ដើម្បីការពារសុវត្ថិភាពសាធារណៈ សណ្ដាប់ធ្នាប់សាធារណៈ និងសុខភាព ឬសីលធម៌សាធារណៈ ឬសិទ្ធិ និងសេរីភាពជាមូលដ្ឋានរបស់មនុស្សដទៃទៀតតែប៉ុណ្ណោះ។

៤-រដ្ឋភាគីនៃអនុសញ្ញានេះ ត្រូវគោរពសេរីភាពរបស់ឪពុកម្ដាយ ដែលយ៉ាងហោចណាស់ មានម្នាក់ក្នុងចំណោមពួកគេទាំងពីរនាក់ ជាពលករទេសន្ដរប្រវេសន៍ និងអាណាព្យាបាលស្របច្បាប់ ប្រសិនបើអាចអនុវត្តបាន ដើម្បីធានាឱ្យមានការអប់រំ សាសនា និងសីលធម៌ដល់កូនៗរបស់ពួកគេសមស្របទៅតាមជំនឿផ្ទាល់ខ្លួនរបស់ពួកគេ។

## មាត្រា ១៣

១-ពលករទេសន្ដរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ត្រូវមានសិទ្ធិប្រកាន់គំនិត ដោយមិនមានការជ្រៀតជ្រែកឡើយ។

២-ពលករទេសន្ដរប្រវេសន៍និងសមាជិកគ្រួសាររបស់ពួកគេ ត្រូវមានសិទ្ធិមានសេរីភាពក្នុងការបញ្ចេញមតិយោបល់។ សិទ្ធិនេះ ត្រូវរួមមានសេរីភាពក្នុងការស្វែងរក ទទួល និងផ្ដល់ព័ត៌មាន និងគំនិតគ្រប់ប្រភេទ ដោយមិនគិតពីព្រំដែន មិនថាផ្ទាល់មាត់ លាយល័ក្ខណ៍អក្សរ ឬបោះពុម្ពក្នុងទម្រង់សិល្បៈ ឬតាមរយៈប្រព័ន្ធផ្សព្វផ្សាយដទៃផ្សេងទៀត ទៅតាមជម្រើសរបស់ពួកគេ។

៣-ការអនុវត្តសិទ្ធិ ដែលមានចែងនៅក្នុងកថាខណ្ឌទី២ នៃមាត្រានេះ ត្រូវភ្ជាប់ជាមួយកាតព្វកិច្ច និងការទទួលខុសត្រូវពិសេស។ ដូច្នេះ អាចមានការដាក់កំហិតមួយចំនួន ប៉ុន្តែការដាក់កំហិតទាំងនេះ ត្រូវធ្វើឡើងដោយច្បាប់តែប៉ុណ្ណោះ និងមានភាពចាំបាច់ដូចខាងក្រោម ៖

(ក) ដើម្បីគោរពសិទ្ធិ និងកេរ្តិ៍ឈ្មោះរបស់អ្នកដទៃ។

(ខ) ដើម្បីការពារសន្តិសុខជាតិរបស់រដ្ឋសាមី ឬសណ្តាប់ធ្នាប់សាធារណៈ ឬសុខភាព ឬសីលធម៌សាធារណៈ។

(គ) ដើម្បីគោលបំណងទប់ស្កាត់មិនឱ្យមានការឃោសនាអំពីសង្គ្រាម។

(ឃ) ដើម្បីគោលបំណងទប់ស្កាត់មិនឱ្យមានការបំផុសបំផុលឱ្យមានការស្អប់គ្នា ខាងជាតិសាសន៍ ពូជសាសន៍ ឬសាសនា ដែលជាការញុះញង់ឱ្យមានការរើសអើង អរិភាព ឬអំពើហិង្សា។

## មាត្រា ១៤

ពុំមានពលករទេសន្តរប្រវេសន៍ ឬសមាជិកគ្រួសាររបស់ពួកគេណាម្នាក់ត្រូវទទួលរងការរំខានតាមអំពើចិត្ត ឬដោយខុសច្បាប់ ចំពោះភាពឯកជន គ្រួសារ លំនៅដ្ឋាន លិខិតឆ្លើយឆ្លង ឬការប្រាស្រ័យទាក់ទងដទៃទៀតរបស់ពួកគេ ឬត្រូវទទួលរងការវាយប្រហារដោយមិនស្របច្បាប់លើកិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ពួកគេឡើយ។ ពលករទេសន្តរប្រវេសន៍និងសមាជិកគ្រួសាររបស់ពួកគេម្នាក់ៗ ត្រូវមានសិទ្ធិទទួលបានការការពារពីច្បាប់ប្រឆាំងនឹងការរំខាន ឬការវាយប្រហារបែបនេះ។

## មាត្រា ១៥

ពុំមានពលករទេសន្តរប្រវេសន៍ ឬសមាជិកគ្រួសាររបស់ពួកគេណាម្នាក់ត្រូវបានគេដកហូតទ្រព្យសម្បត្តិតាមអំពើចិត្ត មិនថាពួកគេជាម្ចាស់កម្មសិទ្ធិតែឯង ឬរួមជាមួយអ្នកដទៃទៀតឡើយ។ ស្ថិតនៅក្រោមច្បាប់ជាធរមានរបស់រដ្ឋដែលទទួលឱ្យធ្វើការ ទ្រព្យសម្បត្តិរបស់ពលករទេសន្តរប្រវេសន៍និងសមាជិកគ្រួសាររបស់ពួកគេ ដែលត្រូវធ្វើអស្សាមិករណ៍ទាំងស្រុង ឬដោយផ្នែក បុគ្គលដែលពាក់ព័ន្ធ ត្រូវមានសិទ្ធិទទួលបានសំណងដោយយុត្តិធម៌ និងគ្រប់គ្រាន់។

## មាត្រា ១៦

១-ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ មានសិទ្ធិទទួលបានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។

២-ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ត្រូវមានសិទ្ធិទទួលបានការការពារដោយប្រសិទ្ធភាពពីរដ្ឋ ប្រឆាំងទៅនឹងអំពើហិង្សា ការបង្ករបួសស្នាមដល់រាងកាយ ការគំរាមកំហែង និងការបំភិតបំភ័យ មិនថាបង្កឡើងដោយមន្ត្រីសាធារណៈ ឬដោយបុគ្គលឯកជន ក្រុម ឬស្ថាប័ននោះទេ។

៣-ការផ្ទៀងផ្ទាត់ណាក៏ដោយដែលធ្វើឡើងដោយមន្ត្រីអនុវត្តច្បាប់លើអត្តសញ្ញាណរបស់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ត្រូវធ្វើឡើងទៅតាមនីតិវិធី ដែលកំណត់ដោយច្បាប់។

៤-ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ មិនត្រូវទទួលរងការចាប់ចង ឬការឃុំខ្លួនជាបុគ្គល ឬជាក្រុម ដោយគ្មានហេតុផលច្បាស់លាស់ឡើយ។ ពួកគេ មិនត្រូវបានដកហូតសេរីភាពឡើយ លើកលែងតែមានមូលដ្ឋាន និងអនុលោមទៅតាមនីតិវិធី ដែលកំណត់ដោយច្បាប់។

៥-ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ដែលត្រូវបានចាប់ខ្លួន ត្រូវបានជូនដំណឹងនៅពេលចាប់ខ្លួនភ្លាមៗ តាមតែអាចធ្វើបាន ជាភាសាមួយដែលពួកគេអាចយល់បាន អំពីមូលហេតុនៃការចាប់ខ្លួន ហើយពួកគេត្រូវបានជូនដំណឹងភ្លាមៗជាភាសាដែលពួកគេអាចយល់បាន អំពីការចោទប្រកាន់លើពួកគេ។

៦-ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ដែលត្រូវបានចាប់ខ្លួន ឬឃុំខ្លួន ពីបទព្រហ្មទណ្ឌណាមួយ ត្រូវយកទៅកាត់ទោសភ្លាមៗនៅមុខចៅក្រម ឬមន្ត្រីដទៃទៀត ដែលត្រូវបានច្បាប់អនុញ្ញាតឱ្យអនុវត្តអំណាចតុលាការ ហើយត្រូវមានសិទ្ធិទទួលបានការកាត់សេចក្តី នៅក្នុងរយៈពេលសមស្របមួយ ឬត្រូវបានដោះលែងឱ្យរួចខ្លួនវិញ។ ការឃុំខ្លួនពួកគេដើម្បីរង់ចាំសវនាការកាត់សេចក្តី មិនមែនជាគោលការណ៍ទូទៅនោះទេ ប៉ុន្តែការដោះលែងពួកគេ ត្រូវមានការធានាថា ពួកគេ ត្រូវចូលបង្ហាញខ្លួននៅសវនាការកាត់សេចក្តី និងនៅដំណាក់កាលដទៃទៀតនៃដំណើរការនីតិវិធីរបស់តុលាការ ហើយត្រូវចូលរួមក្នុងការអនុវត្តសាលក្រម ប្រសិនបើមាន។

៧-នៅពេលដែលពលករទេសន្តរប្រវេសន៍ណាម្នាក់ ឬសមាជិកគ្រួសាររបស់ពួកគេណាម្នាក់ ត្រូវបានចាប់ខ្លួន ឬចាប់ដាក់ពន្ធនាគារ ឬការឃុំខ្លួនរង់ចាំសវនាការកាត់សេចក្តី ឬត្រូវបានឃុំខ្លួន តាមរបៀបដទៃផ្សេងទៀត ៖

(ក) កុងស៊ុលឬអាជ្ញាធរការទូតនៃរដ្ឋកំណើតរបស់ពួកគេឬនៃរដ្ឋតំណាងឱ្យផលប្រយោជន៍របស់រដ្ឋនោះ ត្រូវទទួលបានការជូនដំណឹងពីការចាប់ខ្លួន ឬការឃុំខ្លួន និងពីមូលហេតុនៃការចាប់ខ្លួន ឬការឃុំខ្លួននេះភ្លាមៗ ដោយមិនមានការពន្យារពេល ប្រសិនបើអ្នកដែលត្រូវបានគេចាប់ ឬឃុំខ្លួនស្នើសុំបែបនេះ។

(ខ) សាមីជនត្រូវមានសិទ្ធិប្រាស្រ័យទាក់ទងជាមួយនឹងអាជ្ញាធរខាងលើ។ ការប្រាស្រ័យទាក់ទងណាមួយដែលធ្វើឡើងដោយសាមីជនជាមួយអាជ្ញាធរខាងលើ ត្រូវបញ្ជូនទៅភ្លាមៗដោយមិនពន្យារពេល ហើយសាមីជនត្រូវមានសិទ្ធិទទួលបានព័ត៌មាន ដែលផ្ញើដោយអាជ្ញាធរខាងលើវិញ ដោយមិនមានការពន្យារពេលដែរ។

(គ) សាមីជន ត្រូវទទួលបានព័ត៌មានភ្លាមៗពីសិទ្ធិនេះ និងសិទ្ធិនានាដែលមានចែងនៅក្នុងសន្ធិសញ្ញាពាក់ព័ន្ធនានាប្រសិនបើមាន ដែលអនុវត្តរវាងរដ្ឋពាក់ព័ន្ធនានា ដើម្បីឆ្លើយតប និងជួបជាមួយតំណាងអាជ្ញាធរខាងលើ និងធ្វើការរៀបចំជាមួយពួកគេដើម្បីឱ្យមានអ្នកតំណាងតាមផ្លូវច្បាប់របស់ពួកគេ ។

៨-ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ដែលត្រូវបានគេដកហូតសេរីភាព តាមរយៈការចាប់ខ្លួន ឬការឃុំខ្លួន ត្រូវមានសិទ្ធិចូលរួមក្នុងដំណើរការក្តីនៅចំពោះមុខតុលាការ ដើម្បីឱ្យតុលាការនោះ អាចសម្រេចក្តីភ្លាមៗ អំពីភាពស្របច្បាប់នៃការឃុំខ្លួនរបស់ពួកគេ និងបញ្ជាឱ្យមានការដោះលែង ប្រសិនបើការឃុំខ្លួននេះ ធ្វើឡើងដោយមិនត្រឹមត្រូវតាមច្បាប់ ។ នៅពេលដែលពួកគេចូលរួមក្នុងដំណើរការក្តីបែបនេះ ពួកគេត្រូវមានជំនួយពីអ្នកបកប្រែ ដោយមិនចាំបាច់ចំណាយឡើយ ប្រសិនបើពួកគេមិនអាចយល់ ឬនិយាយភាសា ដែលត្រូវបានប្រើប្រាស់នៅពេលដំណើរការក្តីនោះបានទេ ។

៩-ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ដែលធ្លាប់រងគ្រោះដោយសារការចាប់ខ្លួន ឬការឃុំខ្លួន ដោយខុសច្បាប់ ត្រូវមានសិទ្ធិទទួលបានសំណងជំងឺចិត្ត ។

## មាត្រា ១៧

១-ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេដែលត្រូវបានគេដកហូតសេរីភាព ត្រូវទទួលបានការប្រព្រឹត្តលើដោយមនុស្សធម៌ និងដោយការគោរពសេចក្តីថ្លៃថ្នូរពីកំណើត ក្នុងនាមជាមនុស្សរបស់ពួកគេ និងការគោរពអត្តសញ្ញាណវប្បធម៌របស់ពួកគេ ។

២-លើកលែងតែក្នុងករណីពិសេសមួយចំនួន ជនជាប់ចោទជាពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ត្រូវដាក់ឱ្យនៅដោយឡែកពីជនជាប់ពិរុទ្ធ ហើយត្រូវទទួលបានការប្រព្រឹត្តលើដោយឡែក ដែលសមស្របទៅតាមឋានៈរបស់ពួកគេ ជាជនដែលមិនទាន់ជាប់ពិរុទ្ធ។ ជនជាប់ចោទជាអនីតិជនត្រូវដាក់ឱ្យនៅដោយឡែកពីមនុស្សពេញវ័យ ហើយត្រូវនាំទៅកាត់សេចក្ដីឱ្យបានឆាប់បំផុតតាមតែអាចធ្វើបាន។

៣-ពលករទេសន្តរប្រវេសន៍ ឬសមាជិកគ្រួសារណាម្នាក់របស់ពួកគេដែលត្រូវបានឃុំខ្លួន នៅក្នុងរដ្ឋឆ្លងកាត់ ឬនៅក្នុងរដ្ឋដែលទទួលឱ្យធ្វើការចំពោះការរំលោភបំពានបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងការធ្វើទេសន្តរប្រវេសន៍ ត្រូវដាក់ឱ្យនៅដោយឡែកពីជនជាប់ពិរុទ្ធ ឬពិរុទ្ធជនដែលជាប់ឃុំរង់ចាំសវនាការកាត់សេចក្ដី ក្នុងកម្រិតដែលអាចធ្វើបាន។

៤-នៅក្នុងកំឡុងពេលជាប់ពន្ធនាគារ អនុលោមតាមការផ្ដន្ទាទោសដែលសំរេចដោយតុលាការ គោលបំណងសំខាន់នៃការគ្រប់គ្រងពលករទេសន្តរប្រវេសន៍ ឬសមាជិកគ្រួសាររបស់ពួកគេ គឺការកែប្រែ និងការស្ដារនីតិសម្បទាសង្គមរបស់ជននោះ។ ជនល្មើសជាអនីតិជន ត្រូវដាក់ឱ្យនៅដោយឡែកពីមនុស្សពេញវ័យ ហើយត្រូវទទួលបានការប្រព្រឹត្តលើដែលសមស្របទៅតាមអាយុ និងឋានៈតាមផ្លូវច្បាប់របស់ពួកគេ។

៥-នៅក្នុងកំឡុងពេលឃុំខ្លួន ឬជាប់ពន្ធនាគារពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ត្រូវទទួលបានសិទ្ធិដូចគ្នានឹងប្រជាពលរដ្ឋក្នុងរដ្ឋនោះដែរ ដើម្បីទទួលបានការមកសួរសុខទុក្ខ ពីសំណាក់សមាជិកគ្រួសាររបស់ពួកគេ។

៦-នៅពេលដែលពលករទេសន្តរប្រវេសន៍ត្រូវបានគេដកហូតសេរីភាព អាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋដែលពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់ចំពោះបញ្ហានានាដែលអាចកើតមានចំពោះសមាជិកគ្រួសាររបស់ពួកគេ ជាពិសេសចំពោះសហព័ទ្ធ និងកូនដែលជាអនីតិជនរបស់ពួកគេ ។

៧-ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ដែលទទួលរងការឃុំខ្លួន ឬការដាក់ពន្ធនាគារតាមទម្រង់ណាមួយ ស្របទៅតាមច្បាប់ជាធរមាននៅក្នុងរដ្ឋដែលទទួលឱ្យធ្វើការ ឬនៅក្នុងរដ្ឋឆ្លងកាត់ ត្រូវទទួលបានសិទ្ធិដូចគ្នា ទៅនឹងប្រជាពលរដ្ឋរបស់រដ្ឋទាំងនោះ ដែលស្ថិតនៅក្នុងស្ថានភាពដូចគ្នានេះដែរ ។

៨-ប្រសិនបើពលករទេសន្តរប្រវេសន៍ ឬសមាជិកគ្រួសាររបស់ពួកគេត្រូវបានចាប់ឃុំខ្លួន សម្រាប់គោលបំណងធ្វើការផ្ទៀងផ្ទាត់ពីអំពើល្មើសណាមួយ ចំពោះបទប្បញ្ញត្តិពាក់ព័ន្ធនឹងការធ្វើទេសន្តរប្រវេសន៍ សាម៉ីជន នឹងមិនត្រូវរ៉ាប់រងចំពោះ ចំណាយដែលកើតឡើងពីការផ្ទៀងផ្ទាត់នេះឡើយ ។

## មាត្រា ១៨

១-ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ត្រូវមានសិទ្ធិទទួលបានសមភាព ដូចប្រជាពលរដ្ឋរបស់រដ្ឋដែលពាក់ព័ន្ធ នៅមុខតុលាការ និងសាលាក្តីនានា។ នៅក្នុងការសំរេចពីបទល្មើសព្រហ្មទណ្ឌណាមួយប្រឆាំងនឹងពួកគេឬពីសិទ្ធិ និងកាតព្វកិច្ចក្នុងការធ្វើបណ្តឹងទៅតាមច្បាប់ ពួកគេត្រូវមានសិទ្ធិទទួលបានសវនាការជាសាធារណៈ និងយុត្តិធម៌ ដោយសាលាក្តីដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង ដែលត្រូវបានបង្កើតឡើងដោយច្បាប់ ។

២-ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ដែលត្រូវបានចោទប្រកាន់ពីបទព្រហ្មទណ្ឌ ត្រូវមានសិទ្ធិទទួលបានការសន្មត់ជាមុនថាគ្មានទោស រហូតដល់មានភស្តុតាងបង្ហាញពីពិរុទ្ធភាពទៅតាមច្បាប់ ។

៣-នៅក្នុងការសំរេចពីការចោទប្រកាន់ ពីបទព្រហ្មទណ្ឌ ចំពោះពួកគេ ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ត្រូវមានសិទ្ធិទទួលបានការធានាក្នុងកម្រិតអប្បបរមា ដូចខាងក្រោម ៖

(ក) ត្រូវទទួលបានព័ត៌មានភ្លាមៗ និងពិស្តារ អំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ចំពោះពួកគេតាមភាសាមួយដែលពួកគេអាចយល់បាន ។

(ខ) ត្រូវមានពេលវេលា និងមធ្យោបាយរូបវ័ន្តគ្រប់គ្រាន់ ដើម្បីរៀបចំការការពារក្តីរបស់ពួកគេ និងធ្វើការប្រាស្រ័យទាក់ទងជាមួយមេធាវី ទៅតាមជម្រើសផ្ទាល់ខ្លួនរបស់ពួកគេ ។

(គ) ត្រូវទទួលបានការកាត់សេចក្តី ដោយពុំមានការពន្យារពេលមិនសមហេតុផល ។

(ឃ) ត្រូវទទួលបានការកាត់សេចក្តី ដោយមានវត្តមានរបស់ពួកគេ និងការពារខ្លួនដោយខ្លួនឯង ឬដោយមានជំនួយផ្លូវច្បាប់ ទៅតាមជម្រើសរបស់ពួកគេ ត្រូវទទួលបានព័ត៌មានពីសិទ្ធិមានមេធាវី ប្រសិនបើពួកគេពុំមានជំនួយផ្លូវច្បាប់ និងត្រូវទទួលបានជំនួយផ្លូវច្បាប់ ដែលផ្តល់ឱ្យពួកគេ នៅក្នុងករណីណាក៏ដោយដែលផលប្រយោជន៍យុត្តិធម៌តម្រូវបែបនេះ ហើយពួកគេមិនចាំបាច់បង់ថ្លៃ នៅក្នុងករណីបែបនេះឡើយ ប្រសិនបើពួកគេពុំមានមធ្យោបាយគ្រប់គ្រាន់ ដើម្បីបង់ថ្លៃ ។

(ង) ពិនិត្យ ឬបានពិនិត្យសាក្សីដាក់បន្ទុក និងទទួលបានការចូលរួម និងការពិនិត្យសាក្សីដែលតំណាងឱ្យពួកគេ តាមលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក ។

(ច) ទទួលបានជំនួយពីអ្នកបកប្រែដោយមិនគិតថ្លៃ ប្រសិនបើពួកគេមិនអាចយល់ ឬមិនចេះនិយាយភាសាដែលប្រើនៅក្នុងតុលាការ ។

(ឆ) មិនត្រូវបានគេបង្ខំឱ្យសារភាពប្រឆាំងខ្លួនឯង ឬសារភាពថាខ្លួនមានកំហុសឡើយ ។

៤-នៅក្នុងករណីអនីតិជន នីតិវិធីត្រូវពិចារណាពីអាយុរបស់ពួកគេ និងពីបំណងលើកកម្ពស់ការស្តារនីតិសម្បទារបស់ពួកគេ ។

៥-ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ដែលត្រូវផ្តន្ទាទោសពីបទល្មើសមួយ ត្រូវមានសិទ្ធិស្នើសុំឱ្យសាលាក្តីកម្រិតខ្ពស់ ពិនិត្យឡើងវិញពីការផ្តន្ទាទោស និងការកាត់ទោសពួកគេ ទៅតាមផ្លូវច្បាប់ ។

៦-នៅពេលដែលពលករទេសន្តរប្រវេសន៍ ឬសមាជិកគ្រួសាររបស់ពួកគេ ត្រូវបានផ្តន្ទាទោសពីបទល្មើសព្រហ្មទណ្ឌណាមួយតាមអំណាចសាលក្រមស្ថាពរ ហើយនៅពេលបន្ទាប់មកទៀត ការផ្តន្ទាទោសពួកគេត្រូវបានកែប្រែ ឬសាម៉ីជន ត្រូវបានលើកលែងទោស ដោយហេតុថាអង្គហេតុថ្មី ឬអង្គហេតុដែលរកឃើញថ្មីៗ បង្ហាញយ៉ាងច្បាស់ថា តុលាការមិនបានជំនុំជម្រះឱ្យត្រឹមត្រូវ នោះបុគ្គលដែលទទួលរងការដាក់ទោសទណ្ឌ ដោយសារការផ្តន្ទាទោសបែបនេះត្រូវទទួលបានសំណងជំងឺចិត្តទៅតាមច្បាប់ លើកលែងតែក្នុងករណីដែលមានភស្តុតាងបង្ហាញថា អង្គហេតុដែលគេមិនបានដឹងពីខាងដើម មិនត្រូវបានបើកបង្ហាញឱ្យដឹងទាំងស្រុងឬដោយអន្លើ ដោយសារតែសាម៉ីជននោះ

៧-ពុំមានពលករទេសន្តរប្រវេសន៍ ឬសមាជិកគ្រួសាររបស់ពួកគេណាម្នាក់ ត្រូវបានគេនាំមកកាត់សេចក្តី ឬដាក់ទោសទណ្ឌម្តងទៀត ដោយសារតែបទល្មើសដែលពួកគេត្រូវបានផ្តន្ទាទោសរួចរាល់ ឬត្រូវបានដោះលែងឱ្យមានសេរីភាពទៅហើយ ដោយអនុលោមទៅតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋសាម៉ីនោះទេ។

## មាត្រា ១៩

១-ពុំមានពលករទេសន្តរប្រវេសន៍ ឬសមាជិកគ្រួសាររបស់ពួកគេណាម្នាក់ ត្រូវបានផ្តន្ទាទោសពីបទល្មើសព្រហ្មទណ្ឌណាមួយ ដោយសារតែអំពើដែលមិនបង្កើតបានជាបទល្មើសព្រហ្មទណ្ឌ តាមច្បាប់ជាតិ ឬអន្តរជាតិ នៅពេលដែលបទល្មើសព្រហ្មទណ្ឌនោះត្រូវបានប្រព្រឹត្តឡើយ ទោះជាអំពើនោះសកម្មក្តីឬអកម្មក្តី ហើយពួកគេក៏មិនត្រូវទទួលទោសទណ្ឌក្នុងកម្រិតធ្ងន់ធ្ងរជាងទោសទណ្ឌ ដែលត្រូវអនុវត្តនៅពេលដែលបទល្មើសព្រហ្មទណ្ឌនោះត្រូវបានប្រព្រឹត្តឡើយ។ បន្ទាប់ពីការប្រព្រឹត្តបទល្មើសនេះ ប្រសិនបើមានបទប្បញ្ញត្តិដែលតម្រូវឱ្យមានការដាក់ទោសទណ្ឌស្រាលជាងនេះ នោះសាម៉ីជន ត្រូវទទួលបានប្រយោជន៍ ពីបទប្បញ្ញត្តិថ្មីនេះ។

២-គួរមានការពិចារណាលើកត្តាមនុស្សធម៌ ដែលពាក់ព័ន្ធនឹងឋានៈរបស់ពលករទេសន្តរប្រវេសន៍ ជាពិសេសការគោរពសិទ្ធិតាំងទីលំនៅ ឬសិទ្ធិធ្វើការងាររបស់ពួកគេ នៅពេលធ្វើការកាត់ទោសលើបទល្មើសព្រហ្មទណ្ឌអ្វីមួយ ដែលប្រព្រឹត្តដោយពលករទេសន្តរប្រវេសន៍ ឬសមាជិកគ្រួសាររបស់ពួកគេណាម្នាក់។

## មាត្រា ២០

១-ពុំមានពលករទេសន្តរប្រវេសន៍ ឬសមាជិកគ្រួសាររបស់ពួកគេណាម្នាក់ ត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារ គ្រាន់តែដោយសារពួកគេ ខកខានមិនបានបំពេញកាតព្វកិច្ចនៃកិច្ចសន្យានោះឡើយ ។

២-ពុំមានពលករទេសន្តរប្រវេសន៍ ឬសមាជិកគ្រួសាររបស់ពួកគេណាម្នាក់ ត្រូវបានគេដកហូតលិខិតអនុញ្ញាតឱ្យស្នាក់នៅ ឬលិខិតអនុញ្ញាតឱ្យធ្វើការ ឬត្រូវបានគេបណ្តេញចេញ គ្រាន់តែដោយសារពួកគេ ខកខានមិនបានបំពេញកាតព្វកិច្ច ដែលកើតចេញពីកិច្ចសន្យាការងារនោះឡើយ លុះត្រាតែការបំពេញកាតព្វកិច្ចនេះ គឺជាលក្ខខណ្ឌមួយ សម្រាប់ទទួលបានលិខិតអនុញ្ញាតឱ្យស្នាក់នៅ ឬលិខិតអនុញ្ញាតឱ្យធ្វើការងារនោះ ។

## មាត្រា ២១

វាគឺជាអំពើខុសច្បាប់សម្រាប់ជនណាក៏ដោយ ក្រៅពីមន្ត្រីសាធារណៈដែលត្រូវបានអនុញ្ញាតត្រឹមត្រូវដោយច្បាប់ ធ្វើការរឹបអូស បំផ្លាញ ឬប៉ុនប៉ងបំផ្លាញឯកសារសម្គាល់អត្តសញ្ញាណ ឯកសារអនុញ្ញាតឱ្យចូល ឬស្នាក់នៅការតាំងទីលំនៅ ឬការបង្កើតគ្រឹះស្ថាននៅក្នុងដែនដីរបស់ប្រទេស ឬលិខិតអនុញ្ញាតការងារ ។ ពុំមានការរឹបអូសឯកសារទាំងនេះ ត្រូវបានអនុញ្ញាតដោយគ្មានផ្តល់វិក័យប័ត្រពិស្តារពីសំភារៈដែលត្រូវបានរឹបអូសនោះឡើយ ។ ទោះជានៅក្នុងករណីណាក៏ដោយ មិនត្រូវបានអនុញ្ញាតឱ្យបំផ្លាញលិខិតឆ្លងដែន ឬឯកសារសមមូលរបស់ពលករទេសន្តរប្រវេសន៍ឬសមាជិកគ្រួសាររបស់ពួកគេណាម្នាក់ឡើយ ។

## មាត្រា ២២

១-ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ មិនត្រូវទទួលរងវិធានការបណ្តេញចេញរួមគ្នានោះទេ។ករណីបណ្តេញចេញនីមួយៗត្រូវមានការពិនិត្យ និងសម្រេចទៅតាមករណីបុគ្គលម្នាក់ៗ។

២-ពលករទេសន្តរប្រវេសន៍និងសមាជិកគ្រួសាររបស់ពួកគេអាចត្រូវបានបណ្តេញចេញពីដែនដីរបស់រដ្ឋភាគី តែទៅតាមសេចក្តីសម្រេចដែលធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ច ដោយអនុលោមទៅតាមច្បាប់តែប៉ុណ្ណោះ។

៣-សេចក្តីសម្រេចនេះ ត្រូវផ្សព្វផ្សាយដល់ពួកគេ តាមភាសាមួយដែលពួកគេអាចយល់បាន។ តាមការស្នើសុំរបស់ពួកគេ បើទោះបីជាមិនតម្រូវ សេចក្តីសម្រេចនេះ ត្រូវផ្សព្វផ្សាយដល់ពួកគេជាលាយល័ក្ខណ៍អក្សរលើកលែងតែនៅក្នុងកាលៈទេសៈពិសេស ដែលពាក់ព័ន្ធនឹងបញ្ហាសន្តិសុខជាតិ និងមូលហេតុនៃការធ្វើសេចក្តីសម្រេចបែបនេះ។ សាមីជន ត្រូវទទួលបានព័ត៌មានអំពីសិទ្ធិទាំងនេះ មុនពេល ឬយូរបំផុត នៅពេលដែលចេញសេចក្តីសម្រេចនេះ។

៤-លើកលែងតែនៅក្នុងករណីដែលអាជ្ញាធរតុលាការ បានចេញសេចក្តីសម្រេចស្ថាពររួចទៅហើយ សាមីជនត្រូវមានសិទ្ធិដាក់ជូនទៅអាជ្ញាធរនោះនូវមូលហេតុដែលខ្លួនមិនគួរត្រូវបានបណ្តេញចេញ និងស្នើសុំឱ្យអាជ្ញាធរមានសមត្ថកិច្ច ពិនិត្យឡើងវិញលើករណីរបស់ខ្លួន លើកលែងតែមានមូលហេតុសំខាន់ផ្នែកសន្តិសុខជាតិ តម្រូវឱ្យមានការអនុវត្តផ្សេងពីនេះ។ នៅពេលកំពុងរង់ចាំការពិនិត្យឡើងវិញនេះ សាមីជនត្រូវមានសិទ្ធិស្នើសុំឱ្យបង្អង់ការអនុវត្តសេចក្តីសម្រេចពីការបណ្តេញចេញនេះ។

៥-ប្រសិនបើសេចក្តីសម្រេចអំពីការបណ្តេញចេញ ដែលត្រូវបានអនុវត្តរួចហើយ ត្រូវបានទុកជាមោឃៈ នៅពេលបន្ទាប់មក សាម៉ីជនមានសិទ្ធិស្នើសុំសំណងជំងឺចិត្តទៅតាមច្បាប់ ហើយសេចក្តីសម្រេចពីការបណ្តេញចេញនេះ មិនត្រូវយកមកប្រើប្រាស់ ដើម្បីរារាំងពួកគេមិនឱ្យចូលមកក្នុងរដ្ឋដែលពាក់ព័ន្ធឡើងវិញឡើយ ។

៦-នៅក្នុងករណីមានការបណ្តេញចេញ សាម៉ីជនត្រូវមានឱកាសសមស្រប ដើម្បីដោះស្រាយការទាមទារប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងទៀត ដែលពួកគេត្រូវទទួលបាន ក៏ដូចជាទូទាត់បំណុលនានាដែលនៅសល់មុនពេល ឬក្រោយពេលចាកចេញរបស់ពួកគេ ។

៧-ដោយមិនធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តសេចក្តីសម្រេចអំពីការបណ្តេញចេញ ពលករទេសន្តរប្រវេសន៍ ឬសមាជិកគ្រួសាររបស់ពួកគេ ដែលស្ថិតនៅក្រោមសេចក្តីសម្រេចនេះ អាចស្នើសុំចូលទៅក្នុងរដ្ឋមួយទៀត ក្រៅពីរដ្ឋកំណើតរបស់ពួកគេបាន ។

៨-នៅក្នុងករណីដែលមានការបណ្តេញពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេចេញ ការចំណាយលើការបណ្តេញចេញនេះ មិនត្រូវរ៉ាប់រងដោយសាម៉ីជននោះឡើយ ។ សាម៉ីជនអាចនឹងតម្រូវឱ្យរ៉ាប់រងថ្លៃធ្វើដំណើររបស់ខ្លួន ។

៩-ការបណ្តេញចេញពីរដ្ឋដែលទទួលឱ្យធ្វើការ មិនត្រូវមានផលប៉ះពាល់លើសិទ្ធិណាមួយរបស់ពលករទេសន្តរប្រវេសន៍ ឬសមាជិកគ្រួសាររបស់ពួកគេ ទទួលបានស្របទៅតាមច្បាប់របស់រដ្ឋនោះ រួមទាំងសិទ្ធិទទួលបានប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងទៀត ដែលពួកគេត្រូវទទួលបាន ។

## មាត្រា ២៣

ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ត្រូវមានសិទ្ធិទទួលបានការការពារ និងជំនួយពីកុងស៊ុល ឬអាជ្ញាធរទូតនៃរដ្ឋកំណើតរបស់ពួកគេ ឬនៃរដ្ឋតំណាងឱ្យផលប្រយោជន៍របស់រដ្ឋនោះ នៅពេលណាក៏ដោយសិទ្ធិដែលត្រូវបានទទួលស្គាល់នៅក្នុងអនុសញ្ញានេះ ត្រូវបានទទួលរងប៉ះពាល់។ ជាពិសេស ក្នុងករណីនៃការបណ្តេញចេញ សាម៉ីជន ត្រូវទទួលបានព័ត៌មានអំពីសិទ្ធិនេះភ្លាមៗ ដោយមិនមានការពន្យារពេល ហើយអាជ្ញាធររបស់រដ្ឋដែលធ្វើការបណ្តេញចេញ ត្រូវសម្រួលដល់ការអនុវត្តសិទ្ធិនេះ។

## មាត្រា ២៤

គ្រប់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ត្រូវមានសិទ្ធិឱ្យគេទទួលស្គាល់នៅគ្រប់ទីកន្លែង ក្នុងនាមជាមនុស្សនៅពីមុខច្បាប់។

## មាត្រា ២៥

ពលករទេសន្តរប្រវេសន៍ ត្រូវទទួលបានការប្រព្រឹត្តលើ ដែលមិនត្រូវទាបជាងការប្រព្រឹត្តលើ ដែលអនុវត្តចំពោះប្រជាពលរដ្ឋនៃរដ្ឋដែលទទួលឱ្យធ្វើការពាក់ព័ន្ធនឹងបៀវត្ស និង:

(ក) លក្ខខណ្ឌការងារដទៃទៀត ដូចជា ការងារបន្ថែមម៉ោង ចំនួនម៉ោងធ្វើការ ការសម្រាកប្រចាំសប្តាហ៍ ការឈប់សម្រាក ដោយមានប្រាក់ឈ្នួលសុវត្ថិភាព សុខភាព ការបញ្ឈប់ទំនាក់ទំនងការងារ និងលក្ខខណ្ឌការងារដទៃផ្សេងទៀត ដោយអនុលោមទៅតាមច្បាប់ជាតិ និងការអនុវត្តក្នុងប្រទេស ដែលត្រូវគ្របដណ្តប់ដោយប្រការទាំងនេះ។

(ខ) លក្ខខណ្ឌបំរើការងារផ្សេងទៀត ដូចជា ប្រាក់ឈ្នួលអប្បបរមា ការដាក់កំហិតទៅលើការងារនៅផ្ទះនិងបញ្ហាដទៃផ្សេងទៀតដែលត្រូវបានចាត់ទុកជាលក្ខខណ្ឌការងារអនុលោមទៅតាមច្បាប់និងការអនុវត្តក្នុងប្រទេស ។

២-ការព្យួរសិទ្ធិក្នុងកិច្ចសន្យាការងារឯកជន ពីគោលការណ៍សមភាពនៃការប្រព្រឹត្តលើ ដូចបានចែងនៅក្នុងកថាខណ្ឌទី១ នៃមាត្រានេះ ត្រូវចាត់ទុកថាជាការខុសច្បាប់ ។

៣-រដ្ឋភាគី ត្រូវចាត់វាល់វិធានការសមស្រប ដើម្បីធានាថា ពលករទេសន្តរប្រវេសន៍ មិនត្រូវបានដកហូតសិទ្ធិណាមួយ ដែលកើតចេញពីគោលការណ៍នេះ ដោយសារមូលហេតុនៃភាពមិនស្របច្បាប់នៃការស្នាក់នៅ ឬការងាររបស់ពួកគេឡើយ ។ ជាពិសេស និយោជកមិនត្រូវរួចខ្លួនពីកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចនៃកិច្ចសន្យាឡើយ ហើយកាតព្វកិច្ចរបស់ពួកគេក៏មិនត្រូវបានកម្រិតត្រឹមលក្ខណៈណាមួយ ដោយសារមូលហេតុនៃភាពមិនស្របច្បាប់នេះដែរ ។

## មាត្រា ២៦

១-រដ្ឋភាគី ទទួលស្គាល់សិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ :

(ក) ដើម្បីចូលរួមក្នុងកិច្ចប្រជុំ និងសកម្មភាពនានារបស់សហជីពនិងសមាគមដទៃផ្សេងទៀត ដែលត្រូវបានបង្កើតឡើង ដោយអនុលោមទៅតាមច្បាប់ សំដៅការពារផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងផលប្រយោជន៍ដទៃទៀតអាស្រ័យទៅតាមវិធានរបស់អង្គការដែលពាក់ព័ន្ធ ។

(ខ) ដើម្បីចូលរួមដោយសេរី នៅក្នុងសហជីពណាមួយ និងសមាគម ដូចរៀបរាប់ខាងលើ អាស្រ័យទៅតាមវិធានរបស់អង្គការដែលពាក់ព័ន្ធ ។

(គ) ដើម្បីស្វែងរកជំនួយ និងការជួយគាំទ្រពីសហជីពណាមួយ និងសមាគម ដូចរៀបរាប់ខាងលើ។

២-ពុំមានការដាក់កំហិតណាមួយ អាចត្រូវធ្វើលើការអនុវត្តសិទ្ធិទាំងនេះឡើយ លើកលែងតែការដាក់កំហិតនេះ ត្រូវបានកំណត់ដោយច្បាប់ ហើយដែលមានភាពចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ ដើម្បីប្រយោជន៍ផ្នែកសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ ឬការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃទៀត។

## មាត្រា ២៧

១-ពាក់ព័ន្ធនឹងសន្តិសុខសង្គម ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ត្រូវទទួលបានការប្រព្រឹត្តលើដូចគ្នានឹងការប្រព្រឹត្តលើដែលផ្តល់ដល់ប្រជាពលរដ្ឋនៅក្នុងរដ្ឋដែលទទួលឱ្យធ្វើការដរាបណាពួកគេបំពេញបានតាមលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ជាធរមានរបស់រដ្ឋនោះ និងនៅក្នុងសន្ធិសញ្ញាទ្វេភាគី និងពហុភាគីដែលនៅជាធរមាន។ អាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋកំណើត និងរដ្ឋដែលទទួលឱ្យធ្វើការ អាចបង្កើតការរៀបចំចាំបាច់បានគ្រប់ពេល ដើម្បីកំណត់ពីទម្រង់ការនៃការអនុវត្តបទដ្ឋាននេះ។

២-ក្នុងករណីដែលច្បាប់នៅជាធរមាន មិនបានផ្តល់ឱ្យពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេនូវផលប្រយោជន៍នេះទេ រដ្ឋដែលពាក់ព័ន្ធ ត្រូវពិនិត្យពីលទ្ធភាពនៃការសងវិញដល់បុគ្គលដែលមានប្រយោជន៍នូវចំនួនបដិភាគ ដែលពួកគេបានផ្តល់ឱ្យ អាស្រ័យទៅតាមផលប្រយោជន៍នោះ ដោយឈរលើមូលដ្ឋាននៃការប្រព្រឹត្តលើដែលត្រូវផ្តល់ដល់ប្រជាពលរដ្ឋរបស់ខ្លួន ដែលស្ថិតនៅក្នុងកាលៈទេសៈស្រដៀងគ្នានេះដែរ។

## មាត្រា ២៨

ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ត្រូវមានសិទ្ធិទទួលបានការថែទាំសុខភាព ដែលពួកគេត្រូវការជាបន្ទាន់ សំរាប់ការរក្សាអាយុជីវិតរបស់ពួកគេ ឬការបញ្ចៀសគ្រោះថ្នាក់ដែលមិនអាចកែខៃបានដល់សុខភាពរបស់ពួកគេ ដោយឈរលើមូលដ្ឋានស្មើភាពគ្នានៃការប្រព្រឹត្តចំពោះប្រជាពលរដ្ឋរបស់រដ្ឋសាមី ។ ការថែទាំសុខភាពបន្ទាន់បែបនេះរបស់ពួកគេមិនត្រូវបានបដិសេធ ដោយសារមូលហេតុនៃភាពមិនស្របច្បាប់ណាមួយដែលពាក់ព័ន្ធនឹងការស្នាក់នៅ ឬការងាររបស់ពួកគេឡើយ ។

## មាត្រា ២៩

កុមារគ្រប់រូបរបស់ពលករទេសន្តរប្រវេសន៍ ត្រូវមានសិទ្ធិទទួលបានឈ្មោះ ការចុះសំបុត្រកំណើត និងសញ្ជាតិ ។

## មាត្រា ៣០

កុមារគ្រប់រូបរបស់ពលករទេសន្តរប្រវេសន៍ ត្រូវមានសិទ្ធិជាមូលដ្ឋានទទួលបានការអប់រំ ដោយឈរលើមូលដ្ឋានសមភាពនៃការប្រព្រឹត្តលើដូចប្រជាពលរដ្ឋរបស់រដ្ឋសាមី ។ មិនត្រូវបានបដិសេធ ឬដាក់កំហិតលើការចូលរៀននៅក្នុងស្ថាប័ន អប់រំកុមារតមត្តេយ្យសិក្សារបស់រដ្ឋ ឬសាលារៀនរបស់រដ្ឋដោយសារតែមូលហេតុនៃស្ថានភាពមិនស្របច្បាប់ ដែលពាក់ព័ន្ធនឹងការស្នាក់នៅ ឬការងាររបស់ឪពុក ឬម្តាយ ឬដោយសារតែមូលហេតុនៃភាពមិនស្របច្បាប់នៃការស្នាក់នៅរបស់កុមារនៅក្នុងរដ្ឋដែលទទួលឱ្យធ្វើការឡើយ។

## មាត្រា ៣១

១-រដ្ឋភាគី ត្រូវធានាឱ្យមានការគោរពអត្តសញ្ញាណវប្បធមិរបស់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ហើយមិនត្រូវរារាំងពួកគេ មិនឱ្យរក្សាទំនាក់ទំនងផ្នែកវប្បធមិជាមួយនឹងរដ្ឋកំណើត របស់ពួកគេឡើយ ។

២-រដ្ឋភាគី អាចចាត់វិធានការសមស្រប ដើម្បីជួយ និងលើកទឹកចិត្ត ឱ្យមានកិច្ចខិតខំប្រឹងប្រែងបែបនេះ។

## មាត្រា ៣២

បន្ទាប់ពីបញ្ចប់ការស្នាក់នៅក្នុងរដ្ឋដែលទទួលឱ្យធ្វើការ ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ត្រូវមានសិទ្ធិផ្ទេរចំណូល និងប្រាក់សន្សំរបស់ពួកគេ ក៏ដូចជាទ្រព្យសម្បត្តិ និងរបស់របរផ្ទាល់ខ្លួន ដោយអនុលោមទៅតាមច្បាប់ដែលនៅជាធរមានរបស់រដ្ឋដែលពាក់ព័ន្ធ។

## មាត្រា ៣៣

១-ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ត្រូវមានសិទ្ធិទទួលបានព័ត៌មានពីរដ្ឋកំណើត រដ្ឋដែលទទួលឱ្យធ្វើការ ឬរដ្ឋឆ្លងកាត់ អំពីករណីដែលអាចពាក់ព័ន្ធនឹង ៖

(ក) សិទ្ធិរបស់ពួកគេ ដែលមានចែងនៅក្នុងអនុសញ្ញានេះ។

(ខ) លក្ខខណ្ឌនៃការទទួលយកពួកគេ សិទ្ធិនិងកាតព្វកិច្ចរបស់ពួកគេតាមច្បាប់ និងការអនុវត្តរបស់រដ្ឋដែលពាក់ព័ន្ធ និងបញ្ហាផ្សេងទៀតដែលផ្តល់លទ្ធភាពឱ្យពួកគេអាចអនុវត្តទៅតាមបែបបទរដ្ឋបាល ឬបែបបទផ្សេងទៀត នៅក្នុងរដ្ឋនោះ។

២-រដ្ឋភាគី ត្រូវចាត់វិធានការគ្រប់បែបយ៉ាង ដែលខ្លួនចាត់ទុកថាសមស្រប ដើម្បីផ្សព្វផ្សាយពីព័ត៌មានខាងលើនេះ ឬដើម្បីធានាយ៉ាងណាឱ្យមានការផ្តល់ព័ត៌មានទាំងនេះ ដោយនិយោជក សហជីព ឬអង្គភាព ឬស្ថាប័នសមស្របដទៃទៀត។ តាមការសមស្រប រដ្ឋភាគីត្រូវសហការជាមួយនឹងរដ្ឋដែលពាក់ព័ន្ធដទៃទៀត។

៣-ព័ត៌មានគ្រប់ជ្រុងជ្រោយ ត្រូវផ្តល់ទៅឱ្យតាមការស្នើសុំដល់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ដោយមិនគិតថ្លៃ និងតាមលទ្ធភាពដែលអាចធ្វើបាន ក្នុងភាសាមួយដែលពួកគេអាចយល់បាន ។

## មាត្រា ៣៤

ពុំមានចំណុចណាមួយនៅក្នុងអនុសញ្ញានេះ ធ្វើឱ្យពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ រួចផុតពីកាតព្វកិច្ច ស្របតាមច្បាប់ និងបទបញ្ជាផ្សេងៗរបស់រដ្ឋឆ្លងកាត់ និងរដ្ឋដែលទទួលឱ្យធ្វើការ ឬកាតព្វកិច្ចគោរពអត្តសញ្ញាណវប្បធម៌របស់ប្រជាពលរដ្ឋ នៅក្នុងរដ្ឋទាំងនេះឡើយ ។

## មាត្រា ៣៥

ពុំមានចំណុចណាមួយនៅក្នុងអនុសញ្ញានេះ ត្រូវបានបកស្រាយថា ជាការធ្វើឱ្យស្របច្បាប់នៃស្ថានភាពរបស់ពលករទេសន្តរប្រវេសន៍ ឬសមាជិកគ្រួសាររបស់ពួកគេដែលពុំមានឯកសារត្រឹមត្រូវ ឬស្ថិតនៅក្នុងស្ថានភាពមិនស្របច្បាប់ឡើយ ឬថាជាសិទ្ធិណាមួយចំពោះការធ្វើឱ្យស្របច្បាប់បែបនេះនៃស្ថានភាពរបស់ពួកគេឡើយ ឬធ្វើឱ្យប៉ះពាល់ដល់វិធានការនានាដែលមានចេតនាធានាឱ្យមានលក្ខខណ្ឌល្អប្រសើរ និងប្រកបដោយសមធម៌សម្រាប់ការធ្វើទេសន្តរប្រវេសន៍អន្តរជាតិ ដូចចែងនៅក្នុងផ្នែកទី៦ នៃអនុសញ្ញានេះឡើយ ។

# ផ្នែកទី៤:
# សិទ្ធិដទៃទៀតរបស់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ដែលមានឯកសារត្រឹមត្រូវ ឬស្ថិតនៅក្នុងស្ថានភាពស្របច្បាប់

## មាត្រា ៣៦

ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ដែលមានឯកសារត្រឹមត្រូវ ឬស្ថិតនៅក្នុងស្ថានភាពស្របច្បាប់ នៅក្នុងរដ្ឋដែលទទួលឱ្យធ្វើការ ត្រូវទទួលបានសិទ្ធិ ដូចមានចែងនៅក្នុងផ្នែកនេះនៃអនុសញ្ញានេះ បន្ថែមលើសិទ្ធិនានា ដែលមានចែងនៅក្នុងផ្នែកទី៣។

## មាត្រា ៣៧

មុនពេលចេញដំណើររបស់ពួកគេ ឬយ៉ាងយូរបំផុត នៅពេលដែលពួកគេ ត្រូវបានអនុញ្ញាតឱ្យចូលទៅក្នុងរដ្ឋដែលទទួលឱ្យធ្វើការ ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ត្រូវមានសិទ្ធិទទួលបានព័ត៌មានពេញលេញពីរដ្ឋកំណើត ឬរដ្ឋដែលទទួលឱ្យធ្វើការ តាមការសមស្របពីលក្ខខណ្ឌទាំងអស់ដែលអាចអនុវត្តបានចំពោះការចូលរបស់ពួកគេ និងជាពិសេសលក្ខខណ្ឌទាំងឡាយណាដែលពាក់ព័ន្ធនឹងការស្នាក់នៅ និងសកម្មភាពបានកម្រៃដែលពួកគេចូលរួមធ្វើ ព្រមទាំងលក្ខខណ្ឌតម្រូវដែលពួកគេត្រូវបំពេញនៅក្នុងរដ្ឋដែលទទួលឱ្យធ្វើការ និងអាជ្ញាធរដែលពួកគេត្រូវជូនដំណឹង អំពីការផ្លាស់ប្តូរណាមួយនៃលក្ខខណ្ឌទាំងនេះ។

## មាត្រា ៣៨

១-រដ្ឋដែលទទួលឱ្យធ្វើការ ត្រូវខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង ដើម្បីអនុញ្ញាតឱ្យពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ អាចអវត្តមានជាបណ្តោះអាសន្នបាន ដោយពុំមានផលប៉ះពាល់ទៅលើការអនុញ្ញាតឱ្យពួកគេស្នាក់នៅ ឬធ្វើការឡើយ ដោយសារតែករណីនេះអាចកើតមាន។ នៅពេលផ្តល់ការអនុញ្ញាតបែបនេះ រដ្ឋដែលទទួលឱ្យធ្វើការត្រូវពិចារណាពីតម្រូវការ និងកាតព្វកិច្ចពិសេសរបស់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ជាពិសេស តម្រូវការ និងកាតព្វកិច្ច ដែលពួកគេមាននៅក្នុងរដ្ឋកំណើត។

២-ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ត្រូវមានសិទ្ធិទទួលបានព័ត៌មានពេញលេញអំពីលក្ខខណ្ឌនៃការអនុញ្ញាតឱ្យមានអវត្តមានជាបណ្តោះអាសន្នបែបនេះ។

## មាត្រា ៣៩

១-ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ត្រូវមានសិទ្ធិមានសេរីភាព ក្នុងការធ្វើដំណើរនៅក្នុងដែនដីរបស់រដ្ឋ ដែលទទួលឱ្យធ្វើការ និងសេរីភាពក្នុងការជ្រើសរើសកន្លែងស្នាក់នៅរបស់ពួកគេ នៅក្នុងរដ្ឋនោះ។

២-សិទ្ធិដែលបានលើកឡើងនៅក្នុងកថាខណ្ឌទី១នៃមាត្រានេះ មិនត្រូវទទួលរងការដាក់កំហិតអ្វីទាំងអស់ លើកលែងតែការដាក់កំហិតទាំងឡាយណាដែលកំណត់ដោយច្បាប់ដែលចាំបាច់ ដើម្បីការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ, សុខភាព ឬសីលធម៌សាធារណៈ ឬសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ និងស្របជាមួយនឹងសិទ្ធិដទៃទៀត ដែលត្រូវបានទទួលស្គាល់នៅក្នុងអនុសញ្ញានេះ។

## មាត្រា ៤០

១-ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ត្រូវមានសិទ្ធិបង្កើតសមាគម និងសហជីព នៅក្នុងរដ្ឋដែលទទួលឱ្យធ្វើការ ដើម្បីលើកកម្ពស់ និងការពារផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងផលប្រយោជន៍ដទៃទៀត របស់ពួកគេ។

២-ពុំមានការដាក់កំហិតណាមួយ អាចត្រូវបានធ្វើលើការអនុវត្តសិទ្ធិនេះឡើយ ក្រៅតែពីការដាក់កំហិតដែលកំណត់ដោយច្បាប់ និងដែលចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ ដើម្បីជាប្រយោជន៍ដល់សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ ឬការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃទៀត។

## មាត្រា ៤១

១-ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ត្រូវមានសិទ្ធិចូលរួមនៅក្នុងកិច្ចការសាធារណៈនៃរដ្ឋកំណើតរបស់ពួកគេ និងមានសិទ្ធិបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោតនៅក្នុងរដ្ឋនោះ ដោយអនុលោមទៅតាមច្បាប់របស់រដ្ឋនោះ។

២-រដ្ឋដែលពាក់ព័ន្ធ ត្រូវសម្រួលដល់ការអនុវត្តសិទ្ធិទាំងនេះ ទៅតាមការសមស្រប និងអនុលោមទៅតាមច្បាប់របស់ខ្លួន។

## មាត្រា ៤២

១-រដ្ឋភាគី ត្រូវពិចារណាលើការបង្កើតនីតិវិធី ឬស្ថាប័ន ទាំងនៅក្នុងរដ្ឋកំណើត ទាំងនៅក្នុងរដ្ឋដែលទទួលឱ្យធ្វើការដែលតាមរយៈនេះ អាចយកមកពិចារណាអំពីតម្រូវការ បំណងប្រាថ្នា និងកាតព្វកិច្ចពិសេសរបស់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ និងត្រូវពិចារណាតាមការសមស្របអំពីលទ្ធភាពឱ្យពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ មានតំណាងដែលពួកគេជ្រើសរើសដោយសេរី នៅក្នុងស្ថាប័នទាំងនោះ។

២-រដ្ឋដែលទទួលឱ្យធ្វើការ ត្រូវសម្រួលឱ្យមានការពិគ្រោះយោបល់ ឬការចូលរួមរបស់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ នៅក្នុងការធ្វើសេចក្តីសម្រេចពាក់ព័ន្ធនឹងអាយុជីវិតនិងការគ្រប់គ្រងរដ្ឋបាលរបស់សហគមន៍មូលដ្ឋាន ស្របទៅតាមច្បាប់ជាតិរបស់រដ្ឋនោះ។

៣-ពលករទេសន្តរប្រវេសន៍ អាចទទួលបានសិទ្ធិនយោបាយ នៅក្នុងរដ្ឋដែលទទួលឱ្យធ្វើការ ប្រសិនបើរដ្ឋនោះ ផ្តល់ឱ្យពួកគេ នូវសិទ្ធិបែបនេះ ក្នុងការអនុវត្តអធិបតេយ្យភាពរបស់ខ្លួន។

## មាត្រា ៤៣

១-ពលករទេសន្តរប្រវេសន៍ ត្រូវទទួលបានការប្រព្រឹត្តដោយស្មើភាពគ្នាដូចប្រជាពលរដ្ឋរបស់រដ្ឋដែលទទួលឱ្យធ្វើការដែរ ពាក់ព័ន្ធជាមួយនឹង :

(ក) ការប្រើប្រាស់ស្ថាប័ន និងសេវាកម្មអប់រំ ដោយពួកគេត្រូវបំពេញទៅតាមលក្ខខណ្ឌតម្រូវនៃការចុះឈ្មោះ និងបទបញ្ជាដទៃទៀតរបស់ស្ថាប័ន និងសេវាកម្មដែលពាក់ព័ន្ធ។

(ខ) ការទទួលបានគោលការណ៍ណែនាំវិជ្ជាជីវៈនិងសេវាកម្មធ្វើកម្មសិក្សា

(គ) ការប្រើប្រាស់ស្ថាប័ន និងសំភារៈសំរាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការបណ្តុះបណ្តាលឡើងវិញ។

(ឃ) ការទទួលបានលំនៅដ្ឋាន ដូចជា តាមរយៈកម្មវិធីលំនៅដ្ឋានសង្គម និងការការពារប្រឆាំងនឹងការកេងប្រវ័ញ្ច ដែលពាក់ព័ន្ធជាមួយនឹងការជួលផ្ទះ។

(ង) ការទទួលបានសេវាកម្មសង្គម និងសុខភាព នៅក្នុងករណីដែលពួកគេ អាចបំពេញបាន ទៅតាមលក្ខខណ្ឌតម្រូវ ដើម្បីចូលរួមក្នុងកម្មវិធីទាំងនោះបាន។

(ច) ការចូលរួមក្នុងសហគ្រាសស្វ័យគ្រប់គ្រង និងសហការ ដែលមិនត្រូវមានន័យថា ជាការផ្លាស់ប្តូរឋានៈនៃការធ្វើទេសន្តរប្រវេសន៍របស់ពួកគេទេ ហើយត្រូវនៅក្រោមវិធាន និងបទបញ្ជារបស់ស្ថាប័នដែលពាក់ព័ន្ធ ។

(ឆ) ការទទួលបាន និងការចូលរួមក្នុងជីវភាពវប្បធម៌ ។

២-រដ្ឋភាគី ត្រូវលើកកម្ពស់លក្ខខណ្ឌ ដើម្បីធានាឱ្យមានប្រសិទ្ធភាពនូវការប្រព្រឹត្តប្រកបដោយសមភាព ដើម្បីផ្តល់លទ្ធភាពឱ្យពលករទេសន្តរប្រវេសន៍អាចទទួលបានសិទ្ធិ ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ នៅពេលដែលលក្ខខណ្ឌនៃការស្នាក់នៅរបស់ពួកគេ បំពេញបានតាមលក្ខខណ្ឌតម្រូវសមស្រប ដូចដែលបានអនុញ្ញាតដោយរដ្ឋដែលទទួលឱ្យធ្វើការ ។

៣-រដ្ឋដែលទទួលឱ្យធ្វើការ មិនត្រូវរារាំងនិយោជករបស់ពលករទេសន្តរប្រវេសន៍ បង្កើតទីកន្លែង លំនៅដ្ឋាន ឬសង្គម ឬវប្បធម៌ សម្រាប់ពួកគេឡើយ ។ អនុលោមតាមមាត្រា៧០នៃអនុសញ្ញានេះ រដ្ឋដែលទទួលឱ្យធ្វើការអាចបង្កើតទីកន្លែងទាំងនេះ ឱ្យស្ថិតនៅក្រោមលក្ខខណ្ឌតម្រូវ ដែលអនុវត្តជាទូទៅ នៅក្នុងរដ្ឋនោះ អំពីការតំឡើងទីកន្លែងទាំងនេះ ។

## មាត្រា ៤៤

១-ដោយទទួលស្គាល់ថា គ្រួសារគឺជាកោសិកាគ្រឹះ និងពីធម្មជាតិរបស់សង្គម ហើយមានសិទ្ធិទទួលបានការការពារពីសង្គមនិងរដ្ឋ រដ្ឋភាគី ត្រូវចាត់វិធានការសមស្រប ដើម្បីធានាឱ្យមានការការពារឯកភាពរបស់គ្រួសារពលករទេសន្តរប្រវេសន៍ ។

២-រដ្ឋភាគីត្រូវចាត់វិធានការដែលខ្លួនយល់ថាសមស្រប និងស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន ដើម្បីសម្របសម្រួលឱ្យមានការជួបជុំគ្នាឡើងវិញរវាងពលករទេសន្តរប្រវេសន៍ និងសហព័ទ្ធរបស់ពួកគេ ឬជនដែលមានទំនាក់ទំនងសមមូលទៅនឹងចំណងអាពាហ៍ពិពាហ៍ ស្របតាមច្បាប់ជាធរមាន ព្រមទាំងជាមួយកូនៗជាអនីតិជន មិនទាន់រៀបការ ដែលស្ថិតនៅក្រោមបន្ទុករបស់ពួកគេ ។

៣-ផ្អែកទៅតាមគោលការណ៍មនុស្សធម៌ រដ្ឋដែលទទួលឱ្យធ្វើការ ត្រូវពិចារណាដោយពេញចិត្ត ផ្តល់ការប្រព្រឹត្តស្មើគ្នា ដល់សមាជិកគ្រួសារដទៃទៀតរបស់ពលករទេសន្តរប្រវេសន៍ ដូចមានចែងនៅក្នុងកថាខណ្ឌទី២ នៃមាត្រានេះ ។

## មាត្រា ៤៥

១-នៅក្នុងរដ្ឋដែលទទួលឱ្យធ្វើការ សមាជិកគ្រួសាររបស់ពលករទេសន្តរប្រវេសន៍ ត្រូវទទួលបានការប្រព្រឹត្តលើប្រកបដោយសមភាព ដូចគ្នានឹងប្រជាពលរដ្ឋក្នុងរដ្ឋនោះដែរ ពាក់ព័ន្ធជាមួយនឹង :

(ក) ការប្រើប្រាស់ស្ថាប័ន និងសេវាកម្មអប់រំ ដោយពួកគេត្រូវបំពេញទៅតាមលក្ខខណ្ឌតម្រូវនៃការចុះឈ្មោះ និងបទបញ្ជាដទៃទៀតរបស់ស្ថាប័ននិងសេវាកម្មដែលពាក់ព័ន្ធ ។

(ខ) ការទទួលបានគោលការណ៍ណែនាំវិជ្ជាជីវៈ និងការប្រើប្រាស់ស្ថាប័ន និងសេវាកម្មបណ្តុះបណ្តាល នៅក្នុងករណីដែលពួក គេអាចបំពេញបានទៅតាមលក្ខខណ្ឌតម្រូវសម្រាប់ការចូលរួម ។

(គ) ការទទួលបានសេវាកម្មសង្គម និងសុខភាពនៅក្នុងករណីដែលពួកគេអាចបំពេញបានទៅតាមលក្ខខណ្ឌតម្រូវ ដើម្បីចូលរួមក្នុងកម្មវិធីទាំងនោះបាន ។

(ឃ) ការទទួលបាន និងការចូលរួមក្នុងជីវភាពវប្បធម៌ ។

២-រដ្ឋដែលទទួលឱ្យធ្វើការ ត្រូវដាក់ចេញនូវគោលនយោបាយតាមការសមស្រប ដោយសហការជាមួយនឹងរដ្ឋកំណើតរបស់ពួកគេ សំដៅឱ្យមានការសម្របសម្រួលដល់ការធ្វើសមាហរណកម្មកូនរបស់ពលករទេសន្តរប្រវេសន៍ទៅក្នុងប្រព័ន្ធសាលារៀននៅមូលដ្ឋាន ជាពិសេស ពាក់ព័ន្ធនឹងការបង្រៀនពួកគេដោយប្រើប្រាស់ភាសាក្នុងស្រុក ។

៣-រដ្ឋដែលទទួលឱ្យធ្វើការ ត្រូវខិតខំខ្នែងជួយសម្រួលដល់ការបង្រៀនកូនរបស់ពលករទេសន្តរប្រវេសន៍ ពីភាសាកំណើត និងវប្បធម៌របស់ពួកគេ ហើយក្នុងករណីនេះ រដ្ឋកំណើតត្រូវសហការ នៅពេលណាសមស្រប ។

៤-រដ្ឋដែលទទួលឱ្យធ្វើការ អាចរៀបចំឱ្យមានកម្មវិធីអប់រំពិសេស ដោយប្រើភាសាកំណើតរបស់កូនពលករទេសន្តរប្រវេសន៍ ដោយសហការជាមួយនឹងរដ្ឋកំណើត ប្រសិនបើចាំបាច់ ។

## មាត្រា ៤៦

អាស្រ័យទៅតាមច្បាប់ជាធរមានរបស់រដ្ឋពាក់ព័ន្ធ ព្រមទាំងកិច្ចព្រមព្រៀងអន្តរជាតិដែលពាក់ព័ន្ធ និងកាតព្វកិច្ចរបស់រដ្ឋពាក់ព័ន្ធ ដែលកើតចេញពីការចូលរួមរបស់រដ្ឋទាំងនោះនៅក្នុងសហព័ន្ធគយ ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ត្រូវទទួលបានការលើកលែងពន្ធ និងអាករនាំចូល និងនាំចេញ ពាក់ព័ន្ធនឹងទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងរបស់គ្រួសារ ក៏ដូចជាសម្ភារៈចាំបាច់ ដើម្បីឱ្យពួកគេអាចចូលរួមក្នុងសកម្មភាពបានកម្រៃដែលពួកគេបានទទួលការអនុញ្ញាតឱ្យធ្វើ នៅក្នុងរដ្ឋដែលទទួលឱ្យធ្វើការ ៖

(ក) បន្ទាប់ពីពួកគេចាកចេញពីរដ្ឋកំណើត ឬរដ្ឋដែលពួកគេមានទីលំនៅអចិន្ត្រៃយ៍ ។

(ខ) បន្ទាប់ពីទទួលបានការអនុញ្ញាតជាបឋមឱ្យចូលក្នុងរដ្ឋដែលទទួលឱ្យធ្វើការ ។

(គ) បន្ទាប់ពីពួកគេចាកចេញចុងក្រោយពីរដ្ឋដែលទទួលឱ្យធ្វើការ ។

(ឃ) បន្ទាប់ពីពួកគេត្រលប់មកជាចុងក្រោយ ដល់រដ្ឋកំណើត ឬរដ្ឋដែលពួកគេមានទីលំនៅអចិន្ត្រៃយ៍ ។

## មាត្រា ៤៧

ពលករទេសន្តរប្រវេសន៍ត្រូវមានសិទ្ធិផ្ទេរចំណូល និងប្រាក់សន្សំរបស់ពួកគេ ជាពិសេស ប្រាក់ដែលចាំបាច់សម្រាប់ទ្រទ្រង់ជីវភាពគ្រួសាររបស់ពួកគេ ចេញពីរដ្ឋដែលទទួលឱ្យធ្វើការ ទៅកាន់រដ្ឋកំណើត ឬរដ្ឋដទៃទៀត។ ការផ្ទេរប្រាក់ទាំងនេះត្រូវធ្វើឡើង ស្របទៅតាមនីតិវិធីដែលត្រូវបានកំណត់ដោយច្បាប់ដែលនៅជាធរមានរបស់រដ្ឋពាក់ព័ន្ធ និងស្របទៅតាមកិច្ចព្រមព្រៀងអន្តរជាតិ ដែលនៅចូលជាធរមាន។

២-រដ្ឋពាក់ព័ន្ធ ត្រូវចាត់វិធានការសមស្រប ដើម្បីសម្រួលដល់ការផ្ទេរប្រាក់ទាំងនេះ ។

## មាត្រា ៤៨

១-ដោយមិនធ្វើឱ្យប៉ះពាល់ដល់កិច្ចព្រមព្រៀងដែលនៅជាធរមាន អំពីការគិតពន្ធទ្វេដង លើបញ្ហាប្រាក់ចំណូល នៅក្នុងរដ្ឋដែលទទួលឱ្យធ្វើការ ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ :

(ក) មិនត្រូវជាប់កាតព្វកិច្ចបង់ពន្ធ អាករ ឬតម្លៃសេវានានា ដែលមានកម្រិតខ្ពស់ ឬធ្ងន់ធ្ងរជាងកម្រិតដែលអនុវត្តចំពោះប្រជាពលរដ្ឋរបស់រដ្ឋនោះនៅក្នុងស្ថានភាពស្រដៀងគ្នានេះឡើយ ។

(ខ) ត្រូវមានសិទ្ធិទទួលបានការកាត់ ឬការលើកលែងពីការបង់ពន្ធគ្រប់បែបយ៉ាង និងចំពោះការអនុគ្រោះពន្ធនានា ដែលអនុវត្តចំពោះប្រជាពលរដ្ឋរបស់រដ្ឋនោះ នៅក្នុងស្ថានភាពស្រដៀងគ្នានេះឡើយ រួមទាំងការអនុគ្រោះពន្ធសម្រាប់សមាជិកគ្រួសារ ក្រោមបន្ទុករបស់ពួកគេផងដែរ ។

២-រដ្ឋភាគី ត្រូវខិតខំខ្មែងអនុម័តវិធានការសមស្រប ដើម្បីជៀសវាងពីការយកពន្ធទ្វេដងលើប្រាក់ចំណូល និងប្រាក់សន្សំរបស់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ។

## មាត្រា ៤៩

១-នៅក្នុងករណីដែលច្បាប់ជាតិ តម្រូវឱ្យមានលិខិតអនុញ្ញាតដោយឡែកសម្រាប់ការស្នាក់នៅ និងការបំពេញការងារ រដ្ឋដែលទទួលឱ្យធ្វើការត្រូវផ្ដល់ឱ្យពលករទេសន្តរប្រវេសន៍នូវលិខិតអនុញ្ញាតសម្រាប់ការស្នាក់នៅ រយៈពេលយ៉ាងហោចណាស់ ក៏ស្មើនឹងរយៈពេលនៃលិខិតអនុញ្ញាតសម្រាប់ការចូលរួមក្នុងសកម្មភាពបានកម្រៃដែរ ។

២-ពលករទេសន្តរប្រវេសន៍ ដែលត្រូវបានអនុញ្ញាតឱ្យជ្រើសរើសការងាររកកម្រៃដោយសេរី នៅក្នុងរដ្ឋដែលទទួលឱ្យធ្វើការ មិនត្រូវបានចាត់ទុកថាជាពលករទេសន្តរប្រវេសន៍ ដែលស្ថិតនៅក្នុងស្ថានភាពមិនស្របច្បាប់ឬបាត់បង់ការអនុញ្ញាតឱ្យស្នាក់នៅ ដោយគ្រាន់តែសំអាងលើការបញ្ចប់សកម្មភាពរកកម្រៃរបស់ពួកគេ មុនពេលផុតកំណត់នៃលិខិតអនុញ្ញាតការងារ ឬលិខិតអនុញ្ញាតស្រដៀងៗគ្នានេះរបស់ពួកគេឡើយ ។

៣-ដើម្បីផ្ដល់លទ្ធភាពឱ្យពលករទេសន្តរប្រវេសន៍ ដែលត្រូវបានលើកឡើងនៅក្នុងកថាខណ្ឌទី២ នៃមាត្រានេះ មានពេលវេលាគ្រប់គ្រាន់ ដើម្បីស្វែងរកសកម្មភាពបានកម្រៃដទៃទៀតធ្វើ លិខិតអនុញ្ញាតឱ្យស្នាក់នៅ មិនគួរត្រូវបានដកហូតឡើយ យ៉ាងហោចណាស់សម្រាប់រយៈពេលមួយ ដែលពួកគេអាចមានសិទ្ធិទទួលបានប្រយោជន៍ពីការគ្មានការងារធ្វើ ។

## មាត្រា ៥០

១-នៅក្នុងករណីពលករទេសន្តរប្រវេសន៍ទទួលមរណភាព ឬមានការរំលាយចំណងអាពាហ៍ពិពាហ៍ រដ្ឋដែលទទួលឱ្យធ្វើការ ត្រូវពិចារណាដោយពេញចិត្ត ក្នុងការផ្តល់លិខិតអនុញ្ញាតឱ្យស្នាក់នៅ ដល់សមាជិកគ្រួសាររបស់ពលករទេសន្តរប្រវេសន៍រូបនោះ ដែលកំពុងរស់នៅក្នុងរដ្ឋនោះ ដោយផ្អែកលើមូលដ្ឋាននៃការរស់នៅជួបជុំគ្រួសារ ។ រដ្ឋដែលទទួលឱ្យធ្វើការ ត្រូវពិចារណាលើថិរវេលា ដែលពួកគេបានស្នាក់នៅក្នុងរដ្ឋនោះកន្លងមក ។

២-សមាជិកគ្រួសារដែលមិនបានទទួលលិខិតអនុញ្ញាតបែបនេះ ត្រូវបានអនុញ្ញាតឱ្យមានពេលវេលាសមស្រប ដើម្បីឱ្យពួកគេអាចដោះស្រាយបញ្ហាដែលនៅសេសសល់នៅក្នុងរដ្ឋដែលទទួលឱ្យធ្វើការមុនពេលពួកគេចាកចេញពីរដ្ឋនោះ ។

៣-បទប្បញ្ញត្តិនៅក្នុងកថាខណ្ឌទី១ និងទី២ នៃមាត្រានេះ មិនអាចត្រូវបានបកស្រាយថាមានផលប៉ះពាល់ជាអវិជ្ជមានដល់សិទ្ធិរស់នៅ និងសិទ្ធិធ្វើការនោះឡើយ បើពុំដូច្នេះទេ ត្រូវផ្តល់ដល់សមាជិកគ្រួសាររបស់ពួកគេដោយច្បាប់របស់រដ្ឋដែលទទួលឱ្យធ្វើការ ឬដោយអនុសញ្ញាទ្វេភាគី និងពហុភាគី ដែលនៅជាធរមានចំពោះរដ្ឋនោះ ។

## មាត្រា ៥១

ពលករទេសន្តរប្រវេសន៍ដែលមិនត្រូវបានអនុញ្ញាតឱ្យជ្រើសរើសសកម្មភាពបានកម្រៃដោយសេរី នៅក្នុងរដ្ឋដែលទទួលឱ្យធ្វើការ មិនត្រូវបានចាត់ទុកថាជាពលករទេសន្តរប្រវេសន៍ ដែលស្ថិតនៅក្នុងស្ថានភាពមិនស្របច្បាប់ឡើយ ហើយពួកគេក៏មិនត្រូវបាត់បង់ការអនុញ្ញាតឱ្យស្នាក់នៅ ដោយគ្រាន់តែការបញ្ចប់សកម្មភាពបានកម្រៃរបស់ពួកគេ មុនការផុតកំណត់នៃលិខិត

អនុញ្ញាតការងាររបស់ពួកគេនោះឡើយ លើកលែងតែការអនុញ្ញាតឱ្យស្នាក់នៅនេះ ត្រូវពឹងផ្អែកយ៉ាងពិតប្រាកដទៅលើសកម្មភាពបានកម្រៃជាក់លាក់ដែលពួកគេត្រូវបានអនុញ្ញាតឱ្យបំពេញ។ ពលករទេសន្តរប្រវេសន៍ទាំងនេះត្រូវមានសិទ្ធិស្វែងរកការងារផ្សេងទៀត ការចូលរួមក្នុងកម្មវិធីសាធារណការ និងការបណ្ដុះបណ្ដាលឡើងវិញ នៅក្នុងរយៈពេលដែលនៅសល់ ទៅតាមលិខិតអនុញ្ញាតឱ្យធ្វើការរបស់ពួកគេ អាស្រ័យទៅតាមលក្ខខណ្ឌ និងដែនកំណត់ ដូចមានចែងនៅក្នុងលិខិតអនុញ្ញាតឱ្យធ្វើការនោះ។

## មាត្រា ៥២

១-ពលករទេសន្តរប្រវេសន៍ ត្រូវមានសិទ្ធិជ្រើសរើសសកម្មភាពបានកម្រៃដោយសេរី នៅក្នុងរដ្ឋដែលទទួលឱ្យធ្វើការ ប៉ុន្តែត្រូវស្ថិតនៅក្រោមលក្ខខណ្ឌ ឬការដាក់កំហិតដូចខាងក្រោម។

២-សម្រាប់ពលករទេសន្តរប្រវេសន៍ណាក៏ដោយ រដ្ឋដែលទទួលឱ្យធ្វើការ អាច ៖

(ក) ដាក់កំហិតលើប្រភេទកំណត់មួយចំនួននៃការងារ មុខងារ សេវាកម្ម ឬសកម្មភាពនានា ដែលការដាក់កំហិតនេះ គឺជាការចាំបាច់ ជាប្រយោជន៍របស់រដ្ឋនោះ និងដែលត្រូវបានចែងនៅក្នុងច្បាប់ជាតិ។

(ខ) ដាក់កំហិតលើការជ្រើសរើសសកម្មភាពបានកម្រៃដោយសេរី ដោយអនុលោមទៅតាមច្បាប់របស់ខ្លួន ដែលពាក់ព័ន្ធនឹងការទទួលស្គាល់លក្ខណៈសម្បត្តិការងារ ដែលទទួលបានពីខាងក្រៅដែនដីរបស់ខ្លួន។ ប៉ុន្តែ រដ្ឋភាគីដែលពាក់ព័ន្ធត្រូវខិតខំខ្នែងផ្តល់ការទទួលស្គាល់ដល់លក្ខណៈសម្បត្តិបែបនេះ។

៣-សម្រាប់ពលករទេសន្តរប្រវេសន៍ ដែលលិខិតអនុញ្ញាតការងាររបស់ពួកគេ មានកំរិតរយៈពេល រដ្ឋដែលទទួលឱ្យធ្វើការ អាច ៖

(ក) ដាក់សិទ្ធិជ្រើសរើសសកម្មភាពបានកម្រៃដោយសេរីរបស់ពួកគេ ឱ្យស្ថិតក្រោមលក្ខខណ្ឌដែលពលករទេសន្តរប្រវេសន៍ បានរស់នៅដោយស្របច្បាប់នៅក្នុងដែនដីរបស់ខ្លួនដើម្បីបំពេញសកម្មភាពបានកម្រៃក្នុងរយៈពេលមួយមានកំណត់នៅក្នុងច្បាប់ជាតិដែលមិនគួរលើសពីរយៈពេល២ឆ្នាំឡើយ។

(ខ) ដាក់កំរិតឱ្យពលករទេសន្តរប្រវេសន៍ក្នុងសកម្មភាពបានកម្រៃ ដោយអនុលោមទៅតាមគោលនយោបាយ ដែលផ្តល់អាទិភាពដល់ប្រជាពលរដ្ឋរបស់ខ្លួន ឬដល់បុគ្គលដែលមានឋានៈប្រហាក់ប្រហែលនឹងប្រជាពលរដ្ឋទាំងនោះ សម្រាប់គោលបំណងអាស្រ័យទៅតាមច្បាប់ ឬកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគី។ ការដាក់កំរិតបែបនេះ ត្រូវឈប់អនុវត្តចំពោះពលករទេសន្តរប្រវេសន៍ ដែលបានស្នាក់នៅដោយស្របច្បាប់ នៅក្នុងដែនដីរបស់រដ្ឋនេះ ដើម្បីបំពេញសកម្មភាពបានកម្រៃ ក្នុងរយៈពេលមួយ ដែលត្រូវបានកំណត់ដោយច្បាប់ជាតិ ដែលមិនគួរលើសពីរយៈពេល ៥ឆ្នាំ។

៤-រដ្ឋដែលទទួលឱ្យធ្វើការ ត្រូវកំណត់ពីលក្ខខណ្ឌដើម្បីអនុញ្ញាតឱ្យពលករទេសន្តរប្រវេសន៍ដែលត្រូវបានទទួលឱ្យធ្វើការ អាចចូលរួមបំពេញការងារដោយខ្លួនឯងបាន។ ត្រូវមានការពិចារណាពីរយៈពេលស្នាក់នៅស្របច្បាប់របស់ពលកររូបនេះ នៅក្នុងរដ្ឋដែលទទួលឱ្យធ្វើការ។

## មាត្រា ៥៣

១-សមាជិកគ្រួសារពលករទេសន្តរប្រវេសន៍ ដែលមានលិខិតអនុញ្ញាតឱ្យស្នាក់នៅ ឬលិខិតអនុញ្ញាតឱ្យចូលដោយគ្មានកំណត់ពេលវេលា ឬក៏លិខិតអនុញ្ញាតដែលអាចបន្តបានដោយស្វ័យប្រវត្តិ ត្រូវបានអនុញ្ញាតឱ្យជ្រើសរើសសកម្មភាពបានកម្រៃរបស់ខ្លួនដោយសេរី ក្រោមលក្ខខណ្ឌដូចគ្នានឹងលក្ខខណ្ឌដែលត្រូវបានអនុវត្តចំពោះពលករទេសន្តរប្រវេសន៍ ដែលអនុលោមតាមមាត្រា៥២ នៃអនុសញ្ញានេះ។

២-ពាក់ព័ន្ធនឹងសមាជិកគ្រួសារពលករទេសន្តរប្រវេសន៍ ដែលមិនត្រូវបានអនុញ្ញាតឱ្យជ្រើសរើសសកម្មភាពបានកម្រៃរបស់ខ្លួនដោយសេរី រដ្ឋភាគីត្រូវពិចារណាដោយពេញចិត្ត ផ្តល់ឱ្យពួកគេនូវអាទិភាព ក្នុងការទទួលបានការអនុញ្ញាតឱ្យចូលរួម នៅក្នុងសកម្មភាពបានកម្រៃ ជាងពលករដទៃទៀត ដែលស្នើសុំការអនុញ្ញាតពីរដ្ឋដែលទទួលឱ្យធ្វើការ អាស្រ័យទៅតាមកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី ដែលនៅជាធរមាន។

## មាត្រា ៥៤

១-ដោយមិនធ្វើឱ្យប៉ះពាល់ដល់ប្រការនានានៃលិខិតអនុញ្ញាតឱ្យស្នាក់នៅ ឬលិខិតអនុញ្ញាតឱ្យធ្វើការ និងសិទ្ធិនានាដូចមានចែងនៅក្នុងមាត្រា២៥ និង២៧នៃអនុសញ្ញានេះ ពលករទេសន្តរប្រវេសន៍ត្រូវទទួលបានការប្រព្រឹត្តលើដោយសមភាព ដូចគ្នានឹងប្រជាពលរដ្ឋនៃរដ្ឋដែលទទួលឱ្យធ្វើការដែរ ពាក់ព័ន្ធនឹង :

(ក) ការការពារប្រឆាំងនឹងការបណ្តេញចេញ។

(ខ) អត្ថប្រយោជន៍ពីភាពគ្មានការងារធ្វើ។

(គ) ចូលរួមក្នុងកម្មវិធីសាធារណការ ដែលមានបំណងប្រយុទ្ធនឹងភាពគ្មានការងារធ្វើ។

(ឃ) ការទទួលបានការងារតាមជម្រើសផ្សេង នៅក្នុងករណីដែលពួកគេ បាត់បង់ការងារ ឬត្រូវបានបញ្ឈប់ពីសកម្មភាពបានកម្រៃផ្សេងទៀត ដោយអនុលោមទៅតាមមាត្រា៥២ នៃអនុសញ្ញានេះ។

២-ប្រសិនបើពលករទេសន្តរប្រវេសន៍អះអាងថា ប្រការនានានៃកិច្ចសន្យាការងាររបស់ពួកគេត្រូវបានបំពានដោយនិយោជករបស់ពួកគេ ពលករទេសន្តរប្រវេសន៍រូបនេះ ត្រូវមានសិទ្ធិប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋដែលទទួលឱ្យធ្វើការ ទៅតាមលក្ខខណ្ឌ ដែលមានចែងនៅក្នុងកថាខណ្ឌទី១ មាត្រា១៨ នៃអនុសញ្ញានេះ។

## មាត្រា ៥៥

ពលករទេសន្តរប្រវេសន៍ ដែលត្រូវបានផ្តល់ការអនុញ្ញាតឱ្យចូលរួមនៅក្នុងសកម្មភាពបានកម្រៃ អាស្រ័យទៅតាមលក្ខខណ្ឌដែលភ្ជាប់ជាមួយនឹងការអនុញ្ញាតនេះ ត្រូវមានសិទ្ធិទទួលបានការប្រព្រឹត្តលើដោយសមភាព ដូចគ្នានឹងប្រជាពលរដ្ឋនៃរដ្ឋដែលទទួលឱ្យធ្វើការដែរ នៅពេលដែលពួកគេបំពេញសកម្មភាពបានកម្រៃនេះ។

## មាត្រា ៥៦

១-ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេដែលត្រូវបានលើកឡើងនៅក្នុងផ្នែកនេះនៃអនុសញ្ញានេះ អាចមិនត្រូវបានគេបណ្តេញចេញពីរដ្ឋដែលទទួលឱ្យធ្វើការឡើយ លើកលែងតែមានមូលហេតុដូចបានកំណត់នៅក្នុងច្បាប់ជាតិរបស់រដ្ឋនោះ ហើយពួកគេត្រូវទទួលបានការការពារ ដូចមានចែងនៅក្នុងផ្នែកទី ៣។

២-ការបណ្តេញចេញ មិនត្រូវបានប្រើប្រាស់ សម្រាប់ជាគោលបំណងនៃការដកហូតសិទ្ធិដែលកើតចេញពីលិខិតអនុញ្ញាតឱ្យស្នាក់នៅ និងលិខិតអនុញ្ញាតការងាររបស់ពលករទេសន្តរប្រវេសន៍ ឬសមាជិកគ្រួសាររបស់ពួកគេណាម្នាក់ឡើយ។

៣-នៅពេលពិចារណាថា តើត្រូវបណ្តេញពលករទេសន្តរប្រវេសន៍ ឬសមាជិកគ្រួសាររបស់ពួកគេណាម្នាក់ចេញ គួរមានការពិចារណាលើកត្តាមនុស្សធម៌ និងរយៈពេលដែលសាមីជននោះ បានស្នាក់នៅរួចទៅហើយ នៅក្នុងរដ្ឋដែលទទួលឱ្យធ្វើការ។

# ផ្នែកទី៥:
# បទប្បញ្ញត្តិដែលអាចអនុវត្តចំពោះប្រភេទដោយឡែកមួយចំនួន នៃពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ

## មាត្រា ៥៧

ប្រភេទដោយឡែកមួយចំនួននៃពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ដូចបានបញ្ជាក់នៅក្នុងផ្នែកនេះ នៃអនុសញ្ញា ដែលមានឯកសារត្រឹមត្រូវ ឬដែលស្ថិតនៅក្នុងស្ថានភាពស្របច្បាប់ ត្រូវទទួលបានសិទ្ធិ ដូចមានចែងនៅក្នុងផ្នែកទី៣ និងសិទ្ធិ ដូចមានចែងនៅក្នុងផ្នែកទី៤ លើកលែងតែមានការកែសម្រួលមួយចំនួនដូចខាងក្រោម ។

## មាត្រា ៥៨

១-ពលករតាមព្រំដែន ដូចបានកំណត់និយមន័យនៅក្នុងកថាខណ្ឌទី២ (ក) មាត្រា២នៃអនុសញ្ញានេះ ត្រូវទទួលបានសិទ្ធិដូចមានចែងនៅក្នុងផ្នែកទី៤ ដែលអាចយកមកអនុវត្តបានចំពោះពួកគេ ដោយសារវត្តមាន និងការងាររបស់ពួកគេ នៅក្នុងដែនដីនៃរដ្ឋដែលទទួលឱ្យធ្វើការ ដោយធ្វើការយកចិត្តទុកដាក់ថា ពួកគេពុំមានទីលំនៅអចិន្ត្រៃយ៍នៅក្នុងរដ្ឋនោះទេ ។

២-រដ្ឋដែលទទួលឱ្យធ្វើការត្រូវពិចារណាដោយពេញចិត្ត ផ្តល់ឱ្យពលករតាមព្រំដែននូវសិទ្ធិដើម្បីជ្រើសរើសសកម្មភាព បានកម្រៃរបស់ពួកគេដោយសេរី ក្រោយរយៈពេលកំណត់ណាមួយ ។ ការផ្តល់សិទ្ធិនេះ មិនត្រូវប៉ះពាល់ដល់ឋានៈជាពលករតាមព្រំដែនរបស់ពួកគេឡើយ ។

## មាត្រា ៥៩

១-ពលករតាមរដូវ ដូចបានកំណត់និយមន័យនៅក្នុងកថាខណ្ឌទី២(ខ) មាត្រា២ នៃអនុសញ្ញានេះ ត្រូវទទួលបានសិទ្ធិ ដូចមានចែងនៅក្នុងផ្នែកទី៤ ដែលអាចយកមកអនុវត្តចំពោះពួកគេបាន ដោយសារតែវត្តមាន និងការងាររបស់ពួកគេ នៅក្នុងដែនដីនៃរដ្ឋដែលទទួលឱ្យធ្វើការ ហើយដែលស្រប នឹងឋានៈជាពលករតាមរដូវរបស់ពួកគេនៅក្នុងរដ្ឋនោះ ដោយធ្វើការយកចិត្តទុកដាក់ថា ពួកគេមានវត្តមាននៅក្នុងរដ្ឋនោះ សំរាប់តែរយៈពេលមួយផ្នែកណាមួយនៃឆ្នាំតែប៉ុណ្ណោះ។

២-អាស្រ័យទៅតាមកថាខណ្ឌទី១នៃមាត្រានេះ រដ្ឋដែលទទួលឱ្យធ្វើការត្រូវពិចារណាផ្តល់ឱ្យពលករតាមរដូវ ដែលត្រូវបានជួលឱ្យធ្វើការនៅក្នុងដែនដីរបស់ខ្លួន សំរាប់រយៈពេលមួយជាក់លាក់ នូវលទ្ធភាពចាប់យកសកម្មភាពបានកម្រៃផ្សេងទៀត និងផ្តល់អាទិភាពឱ្យពួកគេជាងពលករដទៃទៀត ដែលសុំការអនុញ្ញាតចូលមកបំពេញការងារនៅក្នុងរដ្ឋនោះ អាស្រ័យទៅតាមកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី ដែលនៅជាធរមាន។

## មាត្រា ៦០

ពលករត្រាច់ចរ ដូចបានកំណត់និយមន័យនៅក្នុងកថាខណ្ឌទី២(ង) មាត្រា២ នៃអនុសញ្ញានេះ ត្រូវទទួលបានសិទ្ធិ ដូចមានចែងនៅក្នុងផ្នែកទី៤ ដែលអាចផ្តល់ដល់ពួកគេបាន ដោយសារតែវត្តមាន និងការងាររបស់ពួកគេនៅក្នុងដែនដីនៃរដ្ឋដែលទទួលឱ្យធ្វើការ ហើយដែលស្របនឹងឋានៈជាពលករត្រាច់ចររបស់ពួកគេនៅក្នុងរដ្ឋនោះ។

## មាត្រា ៦១

១-ពលករធ្វើការតាមគម្រោង ដូចបានកំណត់និយមន័យនៅក្នុងកថាខណ្ឌទី២(ច) មាត្រា២ នៃអនុសញ្ញានេះ និងសមាជិកគ្រួសាររបស់ពួកគេ ត្រូវទទួលបានសិទ្ធិដូចមានចែងនៅក្នុងផ្នែកទី៤ លើកលែងតែបទប្បញ្ញត្តិនៃមាត្រា៤៣ កថាខណ្ឌទី១(ខ) និង(គ) មាត្រា៤៣ កថាខណ្ឌទី១(ឃ) ដោយសារតែមាត្រានេះពាក់ព័ន្ធនឹងកម្មវិធីលំនៅដ្ឋានសង្គម មាត្រា៤៥ កថាខណ្ឌទី១(ខ) និងមាត្រា៥២ ដល់មាត្រា៥៥។

២-ប្រសិនបើពលករធ្វើការតាមគម្រោងម្នាក់អះអាងថា ប្រការនានានៃកិច្ចសន្យាការងាររបស់ខ្លួន ត្រូវបានបំពានដោយនិយោជករបស់ខ្លួន ពលកររូបនោះ ត្រូវមានសិទ្ធិប្ដឹងទៅអាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋដែលមានយុត្តាធិការលើនិយោជករូបនោះ ទៅតាមលក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា១៨ កថាខណ្ឌទី១ នៃអនុសញ្ញានេះ។

៣-អាស្រ័យទៅតាមកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគីដែលកំពុងចូលជាធរមាន រដ្ឋភាគីដែលពាក់ព័ន្ធត្រូវខិតខំខ្មែងផ្ដល់លទ្ធភាពឱ្យពលករធ្វើការតាមគម្រោង បន្តទទួលបានការការពារគ្រប់គ្រាន់ ពីប្រព័ន្ធសន្តិសុខសង្គមរបស់រដ្ឋកំណើត ឬរដ្ឋដែលពួកគេមានទីលំនៅអចិន្ត្រៃយ៍ នៅកំឡុងពេលដែលពួកគេកំពុងចូលរួមនៅក្នុងគម្រោង។ រដ្ឋភាគីដែលពាក់ព័ន្ធ ត្រូវចាត់វិធានការសមស្រប ក្នុងគោលដៅបញ្ចៀសមិនឱ្យមានការបដិសេធនូវសិទ្ធិណាមួយ ឬការបង់ថ្លៃពីរដងដល់ប្រព័ន្ធសន្តិសុខសង្គម។

៤-ដោយមិនធ្វើឱ្យប៉ះពាល់ដល់បទប្បញ្ញតិមាត្រា៤៧ នៃអនុសញ្ញានេះ និងដល់កិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគីដែលពាក់ព័ន្ធ រដ្ឋភាគី ត្រូវអនុញ្ញាតឱ្យពលករធ្វើការតាមគម្រោង បង់ថ្លៃដល់ប្រព័ន្ធសន្តិសុខសង្គមពីប្រាក់ចំណូលរបស់ពួកគេនៅក្នុងរដ្ឋកំណើតឬរដ្ឋដែលពួកគេមានទីលំនៅអចិន្ត្រៃយ៍។

## មាត្រា ៦២

១-ពលករតាមការងារជាក់លាក់ ដូចបានកំណត់និយមន័យនៅក្នុងកថាខណ្ឌទី២(ឆ) មាត្រា២ នៃអនុសញ្ញានេះ ត្រូវទទួលបានសិទ្ធិ ដូចមានចែងនៅក្នុងផ្នែកទី៤ លើកលែងតែបទប្បញ្ញត្តិនៃមាត្រា៤៣ កថាខណ្ឌ១(ខ) និង(គ) មាត្រា៤៣ កថាខណ្ឌ១(ឃ) ដោយសារតែមាត្រានេះពាក់ព័ន្ធនឹងកម្មវិធីលំនៅដ្ឋានសង្គម មាត្រា៥២ និងមាត្រា៥៤ កថាខណ្ឌ១ (ឃ) ។

២-សមាជិកគ្រួសាររបស់ពលករតាមការងារជាក់លាក់ ត្រូវទទួលបានសិទ្ធិនានាពាក់ព័ន្ធនឹងសមាជិកគ្រួសាររបស់ពលករទេសន្តរប្រវេសន៍ ដូចមានចែងនៅក្នុងផ្នែកទី៤នៃអនុសញ្ញានេះ លើកលែងតែបទប្បញ្ញត្តិនៃមាត្រា៥៣ចេញ ។

## មាត្រា ៦៣

១-ពលករស្វ័យបម្រើការងារ ដូចបានកំណត់និយមន័យនៅក្នុងកថាខណ្ឌទី២(ជ) មាត្រា២នៃអនុសញ្ញានេះ ត្រូវទទួលបានសិទ្ធិដូចមានចែងនៅក្នុងផ្នែកទី៤ លើកលែងតែសិទ្ធិទាំងឡាយណា ដែលអនុវត្តដាច់មុខចំពោះតែពលករដែលមានកិច្ចសន្យាការងារ ។

២-ដោយមិនធ្វើឱ្យប៉ះពាល់ដល់មាត្រា៥២ និង៧៩ នៃអនុសញ្ញានេះ ការបញ្ឈប់សកម្មភាពសេដ្ឋកិច្ចរបស់ពលករស្វ័យបម្រើការងារ មិនត្រូវមានន័យថាជា ការដកហូតលិខិតអនុញ្ញាតឱ្យស្នាក់នៅ ឬចូលរួមនៅក្នុងសកម្មភាពបានកម្រៃ នៅក្នុងរដ្ឋដែលទទួលឱ្យធ្វើការពីពួកគេ ឬពីសមាជិកគ្រួសាររបស់ពួកគេឡើយ លើកលែងតែក្នុងករណីដែលលិខិតអនុញ្ញាតឱ្យស្នាក់នៅនេះ ត្រូវអាស្រ័យទាំងស្រុងទៅលើសកម្មភាពបានកម្រៃជាក់លាក់ ដែលពួកគេ ត្រូវបានអនុញ្ញាតឱ្យធ្វើនោះ ។

# ផ្នែកទី៦:
# ការលើកកម្ពស់លក្ខខណ្ឌសមស្រប សមធម៌ មនុស្សធម៌ និងស្របច្បាប់ ពាក់ព័ន្ធនឹងការធ្វើទេសន្តរប្រវេសន៍អន្តរជាតិរបស់ពលករ និងសមាជិកគ្រួសាររបស់ពួកគេ

## មាត្រា ៦៤

១-ដោយមិនធ្វើឱ្យប៉ះពាល់ដល់មាត្រា៧៩ នៃអនុសញ្ញានេះ រដ្ឋភាគីដែលពាក់ព័ន្ធ ត្រូវពិគ្រោះយោបល់និងសហការគ្នា តាមការសមស្រប ដើម្បីលើកកម្ពស់លក្ខខណ្ឌសមស្រប សមធមិ និងមនុស្សធមិ ពាក់ព័ន្ធនឹងការធ្វើទេសន្តរប្រវេសន៍អន្តរជាតិ របស់ពលករ និងសមាជិកគ្រួសាររបស់ពួកគេ។

២-ពាក់ព័ន្ធនឹងចំណុចនេះ ត្រូវមានការពិចារណាត្រឹមត្រូវ មិនត្រឹមតែលើតម្រូវការ និងធនធានកម្លាំងពលកម្មប៉ុណ្ណោះទេ ថែមទាំងលើតម្រូវការផ្នែកសង្គមកិច្ច សេដ្ឋកិច្ច វប្បធមិ និងតម្រូវការផ្សេងទៀតរបស់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេដែលពាក់ព័ន្ធ ក៏ដូចជាអំពីផលវិបាកនៃការធ្វើទេសន្តរប្រវេសន៍បែបនេះ មកលើសហគមន៍ដែលពាក់ព័ន្ធនានា។

## មាត្រា ៦៥

១-រដ្ឋភាគីត្រូវរក្សាសេវាសមស្រប ដើម្បីដោះស្រាយបញ្ហានានា ដែលពាក់ព័ន្ធនឹងការធ្វើទេសន្តរប្រវេសន៍អន្តរជាតិរបស់ពលករ និងសមាជិកគ្រួសាររបស់ពួកគេ។ មុខងាររបស់រដ្ឋទាំងនេះ រួមមាន :

(ក) ការបង្កើតនិងការអនុវត្តគោលនយោបាយពាក់ព័ន្ធនឹងការធ្វើទេសន្តរប្រវេសន៍បែបនេះ។

(ខ) ការផ្លាស់ប្តូរព័ត៌មាន ការពិគ្រោះយោបល់ និងការសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋភាគីដទៃទៀត ដែលពាក់ព័ន្ធនឹងការធ្វើទេសន្តរប្រវេសន៍បែបនេះ។

(គ) ការផ្តល់ព័ត៌មានសមស្រប ជាពិសេស ដល់និយោជក កម្មករនិយោជិត និងស្ថាប័នរបស់ពួកគេ អំពីគោលនយោបាយ ច្បាប់ និងបទបញ្ញាពាក់ព័ន្ធនឹងការធ្វើទេសន្តរប្រវេសន៍និងការងារអំពីកិច្ចព្រមព្រៀង ដែលត្រូវបានបង្កើតឡើងជាមួយរដ្ឋភាគីផ្សេងទៀត ពាក់ព័ន្ធនឹងការធ្វើទេសន្តរប្រវេសន៍ និងអំពីបញ្ហាពាក់ព័ន្ធដទៃទៀត។

(ឃ) ការផ្តល់ព័ត៌មាន និងការជួយឧបត្ថម្ភសមស្រប ដល់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ពាក់ព័ន្ធនឹងការអនុញ្ញាត និងបែបបទចាំបាច់ និងការរៀបចំសម្រាប់ការចេញដំណើរ ការធ្វើដំណើរ ការមកដល់ ការស្នាក់នៅ សកម្មភាពបានកម្រៃ ការចាកចេញវិញ និងការវិលត្រលប់ ព្រមទាំងអំពីលក្ខខណ្ឌការងារ និងជីវិត នៅក្នុងរដ្ឋដែលទទួលឱ្យធ្វើការ និងអំពីទំនៀមទម្លាប់ រូបិយប័ណ្ណ ពន្ធ និងច្បាប់និងបទបញ្ញាដែលពាក់ព័ន្ធដទៃទៀត។

២-រដ្ឋភាគីត្រូវសម្រួលតាមការសមស្រប ដល់ការផ្តល់សេវាកុងស៊ុល និងសេវាដទៃទៀតឱ្យបានសមរម្យ ដែលចាំបាច់ដើម្បីបំពេញតម្រូវការផ្នែកសង្គមកិច្ច វប្បធម៌ និងតម្រូវការដទៃទៀតរបស់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ។

## មាត្រា ៦៦

១-អាស្រ័យទៅតាមកថាខណ្ឌទី២ នៃមាត្រានេះ សិទ្ធិធ្វើប្រតិបត្តិការពាក់ព័ន្ធនឹងការជ្រើសរើសពលករឱ្យទៅបំពេញការងារ នៅក្នុងរដ្ឋមួយទៀតត្រូវដាក់កំហិតត្រឹម ៖

(ក) សេវាសាធារណៈ ឬស្ថាប័នរបស់រដ្ឋដែលមានប្រតិបត្តិការបែបនេះ។

(ខ) សេវាសាធារណៈ ឬស្ថាប័នរបស់រដ្ឋដែលទទួលឱ្យធ្វើការ ដោយផ្អែកលើកិច្ចព្រមព្រៀងរវាងរដ្ឋដែលពាក់ព័ន្ធ។

(គ) ស្ថាប័ន ដែលត្រូវបានបង្កើតឡើងតាមស្មារតីនៃកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគី។

២-អាស្រ័យទៅតាមការអនុញ្ញាត ការឯកភាព និងការត្រួតពិនិត្យដោយអាជ្ញាធរសាធារណៈរបស់រដ្ឋភាគីដែលពាក់ព័ន្ធ ដូចដែលត្រូវបានកំណត់នៅក្នុងច្បាប់ និងការអនុវត្តរបស់រដ្ឋ ទីភ្នាក់ងារ និយោជក ឬបុគ្គលទាំងឡាយណាដែលធ្វើការងារ ក្នុងនាមតំណាងឱ្យពួកគេ អាចត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការខាងលើ។

## មាត្រា ៦៧

១-រដ្ឋភាគីដែលពាក់ព័ន្ធត្រូវសហការគ្នាតាមការសមស្រប ក្នុងការអនុម័តវិធានការនានាដែលពាក់ព័ន្ធនឹងការវិលត្រលប់មកវិញជាបន្តបន្ទាប់របស់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេមកកាន់រដ្ឋកំណើតនៅពេលដែលពួកគេ សម្រេចចិត្តថា នឹងវិលត្រលប់មកវិញ ឬនៅពេលដែលលិខិតអនុញ្ញាតឱ្យស្នាក់នៅ ឬបំពេញការងាររបស់ពួកគេ ត្រូវផុតកាលកំណត់ ឬនៅពេលដែលពួកគេស្ថិតក្នុងស្ថានភាពមិនស្របច្បាប់ នៅក្នុងរដ្ឋដែលទទួលឱ្យធ្វើការ។

២-ពាក់ព័ន្ធនឹងពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ដែលស្ថិតក្នុងស្ថានភាពស្របច្បាប់ រដ្ឋភាគីដែលពាក់ព័ន្ធ ត្រូវសហការគ្នាឱ្យបានសមស្របតាមការសមស្រប ដោយផ្អែកលើលក្ខខណ្ឌដែលបានព្រមព្រៀងគ្នាដោយរដ្ឋទាំងនោះ ដើម្បីលើកកម្ពស់លក្ខខណ្ឌសេដ្ឋកិច្ចឱ្យបានសមរម្យ សម្រាប់ការតាំងទីលំនៅជាថ្មីរបស់ពួកគេ និងដើម្បីសម្រួលដល់ការធ្វើសមាហរណកម្មជាថ្មីឱ្យបានរឹងមាំខាងផ្នែកសង្គមកិច្ច និងវប្បធម៌ នៅក្នុងរដ្ឋកំណើតរបស់ពួកគេ។

## មាត្រា ៦៨

១-រដ្ឋភាគី រាប់បញ្ចូលទាំងរដ្ឋឆ្លងកាត់ផង ត្រូវសហការគ្នាដើម្បីបង្ការទប់ស្កាត់ និងលុបបំបាត់ចលនាខុសច្បាប់ ឬលួចលាក់ និងការជួលពលករទេសន្តរប្រវេសន៍ ក្នុងស្ថានភាពមិនស្របច្បាប់។ ដើម្បីគោលបំណងនេះ វិធានការដែលត្រូវអនុវត្តនៅ ក្នុងយុត្តាធិការរបស់រដ្ឋភាគីពាក់ព័ន្ធនីមួយៗ ត្រូវរួមមាន៖

(ក) វិធានការសមស្រប ប្រឆាំងនឹងការផ្សព្វផ្សាយព័ត៌មានដែលធ្វើឱ្យមានការភាន់ច្រឡំ ពាក់ព័ន្ធនឹងនិរប្រវេសន្ត និងអន្តោប្រវេសន៍។

(ខ) វិធានការដើម្បីរកឱ្យឃើញ និងលុបបំបាត់ចលនាខុសច្បាប់ ឬដោយលួចលាក់នៃពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ និងដាក់ទោសទណ្ឌដ៏មានប្រសិទ្ធភាពដល់បុគ្គល ក្រុម ឬអង្គភាពដែលរៀបចំប្រតិបត្តិ ឬជួយដល់ការរៀបចំ ឬការប្រតិបត្តិចលនាបែបនេះ។

(គ) វិធានការដើម្បីដាក់ទោសទណ្ឌដ៏មានប្រសិទ្ធភាពដល់បុគ្គល ក្រុម ឬអង្គភាពដែលប្រើប្រាស់អំពើហិង្សា ការគំរាមកំហែង ឬការបំភិតបំភ័យដល់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ដែលស្ថិតនៅក្នុងស្ថានភាពមិនស្របច្បាប់។

២-រដ្ឋដែលទទួលឱ្យធ្វើការ ត្រូវចាត់វិធានការសមស្រប និងមានប្រសិទ្ធភាពគ្រប់បែបយ៉ាង ដើម្បីលុបបំបាត់ ការផ្តល់ការងារដល់ពលករទេសន្តរប្រវេសន៍ក្នុងស្ថានភាពមិនស្របច្បាប់ នៅក្នុងដែនដីរបស់ខ្លួន ដូចជាការដាក់ទោសទណ្ឌដល់និយោជករបស់ពលករទាំងនេះ តាមជាក់ស្តែងជាដើម។ សិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ចំពោះនិយោជករបស់ពួកគេដែលកើតចេញពីការងារបែបនេះ មិនត្រូវរងផលប៉ះពាល់ ដោយសារវិធានការទាំងនេះឡើយ។

## មាត្រា ៦៩

១-នៅពេលមានពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេដែលស្ថិតក្នុងស្ថានភាពមិនស្របច្បាប់ នៅក្នុងដែនដីរបស់ខ្លួន រដ្ឋភាគីត្រូវចាត់វិធានការសមស្រប ដើម្បីធានាថា ស្ថានភាពបែបនេះនឹងមិនបន្តមានទៀត។

២-នៅពេលដែលរដ្ឋភាគីពាក់ព័ន្ធ ពិចារណាពីលទ្ធភាពនៃការធ្វើឱ្យស្របច្បាប់ដល់ស្ថានភាពរបស់បុគ្គលខាងលើ ដោយអនុលោមទៅតាមច្បាប់ជាតិ និងកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគីដែលនៅជាធរមាន រដ្ឋនោះត្រូវពិចារណាឱ្យបានសមស្រប ពីកាលៈទេសៈនៃការចូលរបស់បុគ្គលទាំងនោះ រយៈពេលនៃការស្នាក់នៅរបស់ពួកគេ នៅក្នុងរដ្ឋដែលទទួលឱ្យធ្វើការ និងកត្តាដែលពាក់ព័ន្ធដទៃទៀត ជាពិសេស កត្តានានាដែលពាក់ព័ន្ធនឹងស្ថានភាពគ្រួសាររបស់ពួកគេ។

## មាត្រា ៧០

រដ្ឋភាគី ត្រូវចាត់វិធានការ មិនទាបជាងវិធានការដែលអនុវត្តចំពោះប្រជាពលរដ្ឋរបស់ខ្លួនឡើយ ដើម្បីធានាថាលក្ខខណ្ឌការងារ និងជីវភាពរស់នៅរបស់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ដែលស្ថិតក្នុងស្ថានភាពស្របច្បាប់ ត្រូវរក្សាទៅតាមស្តង់ដានៃភាពស័ក្តិសមសុវត្ថិភាព សុខភាព និងគោលការណ៍នៃសេចក្តីថ្លៃថ្នូររបស់មនុស្ស ។

## មាត្រា ៧១

១-នៅពេលចាំបាច់ រដ្ឋភាគីត្រូវសម្រួលដល់ការធ្វើមាតុភូមិនិវត្តន៍មកកាន់រដ្ឋកំណើតវិញ នៃសាកសពរបស់ពលករទេសន្តរប្រវេសន៍ ឬសមាជិកគ្រួសាររបស់ពួកគេ ដែលបានបាត់ជីវិត ។

២-អំពីបញ្ហាសំណងជំងឺចិត្ត ដែលទាក់ទិននឹងការស្លាប់របស់ពលករទេសន្តរប្រវេសន៍ ឬសមាជិកគ្រួសាររបស់ពួកគេ រដ្ឋភាគី ត្រូវផ្តល់ជំនួយដល់បុគ្គលសាមី តាមការសមស្រប ដើម្បីដោះស្រាយជាបន្ទាន់នូវបញ្ហាសំណងជំងឺចិត្តនេះ ។ ការដោះស្រាយបញ្ហានេះ ត្រូវធ្វើឡើង ដោយផ្អែកទៅតាមច្បាប់ជាតិដែលនៅជាធរមាន អនុលោមទៅតាមបទប្បញ្ញត្តិនៃអនុសញ្ញានេះ និងទៅតាមកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគីនានាដែលពាក់ព័ន្ធ ។

# ផ្នែកទី៧: ការអនុវត្តអនុសញ្ញានេះ

## មាត្រា ៧២

១-(ក) សម្រាប់គោលបំណងនៃការពិនិត្យឡើងវិញ លើការអនុវត្តអនុសញ្ញានេះ គណៈកម្មាធិការសម្រាប់ការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេមួយ ត្រូវបានបង្កើតឡើង (ចាប់ពីពេលនេះទៅត្រូវបាន ហៅថា "គណៈកម្មាធិការ") ។

(ខ) នៅពេលដែលអនុសញ្ញានេះចូលជាធរមាន គណៈកម្មាធិការនេះត្រូវមានសមាជិកចំនួន ១០រូប ហើយក្រោយពេលដែលមានរដ្ឋចំនួន៤១ ចូលជាភាគីនៃអនុសញ្ញានេះ គណៈកម្មាធិការនេះ ត្រូវមានសមាជិកជាអ្នកជំនាញចំនួន ១៨រូប ដែលសុទ្ធសឹងជាអ្នកដែលមានសីលធម៌ខ្ពស់ មានភាពមិនលំអៀង និងមានសមត្ថភាពដែលត្រូវបានទទួលស្គាល់ក្នុងវិស័យដែលគ្របដណ្តប់ ដោយអនុសញ្ញានេះ ។

២-(ក) សមាជិកគណៈកម្មាធិការនេះ ត្រូវជ្រើសរើសឡើង តាមរយៈការបោះឆ្នោតសម្ងាត់ដោយរដ្ឋភាគី ពីបញ្ជីឈ្មោះបេក្ខជនដែលត្រូវបានតែងតាំងដោយរដ្ឋភាគី ដោយការពិចារណាយ៉ាងត្រឹមត្រូវអំពីរបាយភូមិសាស្ត្រប្រកបដោយសមធម៌ រាប់ទាំងរដ្ឋកំណើត និងរដ្ឋដែលទទួលឱ្យធ្វើការផង និងអំពីភាពជាតំណាងឱ្យប្រព័ន្ធច្បាប់សំខាន់ៗ។ រដ្ឋភាគីនីមួយៗ អាចតែងតាំងបេក្ខជនម្នាក់ ពីក្នុងចំណោមប្រជាពលរដ្ឋរបស់ខ្លួន។

(ខ)សមាជិកត្រូវជ្រើសរើសតាមការបោះឆ្នោតហើយត្រូវបំពេញការងារឱ្យគណៈកម្មាធិការ ក្នុងសមត្ថភាពជាបុគ្គល។

៣-ការបោះឆ្នោតដំបូង ត្រូវរៀបចំឡើងមិនឱ្យយូរជាង ៦ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការចូលជាធរមានរបស់អនុសញ្ញានេះ ហើយការបោះឆ្នោតជាបន្តបន្ទាប់ ត្រូវធ្វើឡើងរៀងរាល់២ឆ្នាំម្តង។ យ៉ាងហោចណាស់ក៏ក្នុងរយៈពេល៤ខែ មុនកាលបរិច្ឆេទនៃការបោះឆ្នោតនីមួយៗ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវផ្ញើលិខិតមួយច្បាប់ដល់រដ្ឋភាគីទាំងអស់ ដោយអញ្ជើញពួកគេ ឱ្យផ្ញើឈ្មោះបេក្ខជនដែលពួកគេតែងតាំងមក មិនឱ្យលើសពីរយៈពេល ២ខែ។ អគ្គលេខាធិការ ត្រូវរៀបចំបញ្ជីឈ្មោះបេក្ខជនទាំងនោះ ទៅតាមលំដាប់នៃតួអក្សរ ដោយចង្អុលបង្ហាញពីរដ្ឋភាគី ដែលបានតែងតាំងពួក

គេ ហើយត្រូវផ្ញើបញ្ជីឈ្មោះនេះ រួមជាមួយប្រវត្តិរូបសង្ខេបរបស់បេក្ខជនដែលត្រូវបានតែងតាំងផងទៅកាន់រដ្ឋភាគី មិនឱ្យយឺតជាងមួយខែមុន កាលបរិច្ឆេទនៃការបោះឆ្នោត ។

៤-ការបោះឆ្នោតជ្រើសរើសសមាជិករបស់គណៈកម្មាធិការនេះត្រូវធ្វើឡើងនៅក្នុងសម័យប្រជុំរបស់រដ្ឋភាគីដែលកោះប្រជុំ ដោយអគ្គលេខាធិការនៅទីស្នាក់ការកណ្ដាលរបស់អង្គការសហប្រជាជាតិ។ នៅក្នុងសម័យប្រជុំនោះ ចំនួនកូរ៉ុមសំរាប់ការប្រជុំ គឺពីរភាគបីនៃរដ្ឋភាគី ហើយបេក្ខជនដែលជាប់ឆ្នោតជាសមាជិកគណៈកម្មាធិការ ត្រូវតែជាបេក្ខជនដែលទទួលបានសម្លេងឆ្នោតច្រើនជាងគេ និងសំលេងភាគច្រើនដាច់ខាតពីរដ្ឋភាគីដែលមានវត្តមាន និងធ្វើការបោះឆ្នោត។

៥-(ក) សមាជិកគណៈកម្មាធិការ ត្រូវមានអណត្តិរយៈពេល ៤ឆ្នាំ។ ប៉ុន្តែអណត្តិរបស់សមាជិក ៥រូប ក្នុងចំណោម សមាជិកដែលជាប់ឆ្នោតក្នុងការបោះឆ្នោតលើកទី១ ត្រូវផុតកំណត់នៅចុងរយៈពេល ២ឆ្នាំ។ ភ្លាម១បន្ទាប់ពីការបោះឆ្នោតលើកទី១ ឈ្មោះសមាជិកទាំង៥រូបនេះត្រូវបានជ្រើសរើសដោយការចាប់ឆ្នោត ដោយប្រធានកិច្ចប្រជុំរបស់រដ្ឋភាគី។

(ខ) ការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការ៤រូបបន្ថែមទៀតត្រូវរៀបចំឡើង ដោយអនុលោមទៅតាមកថាខណ្ឌទី២, ៣ និង៤ នៃមាត្រានេះ ក្រោយពីមានរដ្ឋចំនួន៤១ បានចូលជាភាគីនៃអនុសញ្ញានេះ។ អណត្តិរបស់សមាជិកបន្ថែម២នាក់ ដែលជាប់ឆ្នោតក្នុងឱកាសបោះឆ្នោតនេះត្រូវផុតកំណត់នៅចុងរយៈពេល ២ឆ្នាំ។ ឈ្មោះរបស់សមាជិកទាំង២ រូបនេះត្រូវជ្រើសរើសដោយការចាប់ឆ្នោត ដោយប្រធានកិច្ចប្រជុំរបស់រដ្ឋភាគី។

(គ) សមាជិកគណៈកម្មាធិការនេះ ត្រូវមានសិទ្ធិឈរឈ្មោះនៅក្នុងការបោះឆ្នោតជាថ្មី ប្រសិនបើពួកគេត្រូវបានតែងតាំងជាថ្មី ដោយរដ្ឋរបស់គេ។

៦-ប្រសិនបើសមាជិកគណៈកម្មាធិការណាម្នាក់ ទទួលមរណភាព ឬលាលែង ឬប្រកាសថា ដោយសារមូលហេតុផ្សេងទៀត គាត់លែងអាចបំពេញភារកិច្ចឱ្យគណៈកម្មាធិការបានទៀតហើយ រដ្ឋភាគីដែលតែងតាំងអ្នកជំនាញរូបនេះ ត្រូវតែងតាំងអ្នកជំនាញមួយរូបទៀត ពីក្នុងចំណោមប្រជាពលរដ្ឋរបស់ខ្លួន សម្រាប់រយៈពេលដែលនៅសល់នៃអណត្តិ។ ការតែងតាំងថ្មីនេះ ត្រូវទទួលបានការឯកភាពពីគណៈកម្មាធិការនេះ។

៧-អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវផ្តល់បុគ្គលិក និងមធ្យោបាយចាំបាច់ ដើម្បីឱ្យគណៈកម្មាធិការនេះ អាចបំពេញមុខងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

៨-សមាជិកគណៈកម្មាធិការនេះត្រូវទទួលបានផលកំរៃពីធនធានរបស់អង្គការសហប្រជាជាតិ អាស្រ័យទៅតាមខ្លឹមសារ និងលក្ខខណ្ឌ ដូចដែលមហាសន្និបាតអង្គការសហប្រជាជាតិ អាចធ្វើការសម្រេច។

៩-សមាជិកគណៈកម្មាធិការនេះ ត្រូវមានសិទ្ធិទទួលបានមធ្យោបាយរូបវ័ន្ត បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិនៃអ្នកជំនាញការ នៅពេលដែលពួកគេបំពេញបេសកកម្មឱ្យអង្គការសហប្រជាជាតិ ដូចដែលមានចែងនៅក្នុងផ្នែកពាក់ព័ន្ធនៃអនុសញ្ញាស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់អង្គការសហប្រជាជាតិ។

## មាត្រា ៧៣

១-រដ្ឋភាគីត្រូវផ្ញើរបាយការណ៍របស់ខ្លួនអំពីវិធានការច្បាប់ វិធានការតុលាការ វិធានការរដ្ឋបាលនិងវិធានការដទៃទៀត ដែលខ្លួនបានធ្វើ ដើម្បីធ្វើឱ្យបទប្បញ្ញត្តិនៃអនុសញ្ញានេះមានប្រសិទ្ធភាព ទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិ ធ្វើការពិចារណាលើរបាយការណ៍នេះ ដោយគណៈកម្មាធិការ ៖

(ក) មិនឱ្យលើសពីរយៈពេល១ឆ្នាំ បន្ទាប់ពីអនុសញ្ញានេះ ចូលជាធរមាន សម្រាប់រដ្ឋភាគីសាមី ។

(ខ) រៀងរាល់៥ឆ្នាំម្តងនិងនៅពេលដែលមានការស្នើសុំពីគណៈកម្មាធិការនេះ ។

២-របាយការណ៍ ដែលរៀបចំឡើងតាមមាត្រានេះ ត្រូវបង្ហាញផងដែរ ពីកត្តា និងការលំបាកនានា ប្រសិនបើមាន ដែលប៉ះពាល់ដល់ការអនុវត្តអនុសញ្ញានេះ ហើយត្រូវដាក់បញ្ចូលព័ត៌មានអំពីលក្ខណៈចរិកនៃលំហូរទេសន្តរប្រវេសន៍ ដែលក្នុងនោះ មានពាក់ព័ន្ធនឹងរដ្ឋភាគីសាមី ។

៣-គណៈកម្មាធិការនេះ ត្រូវសម្រេចអំពីគោលការណ៍ណែនាំបន្ថែមទៀត ដែលអាចអនុវត្តបាន ដល់ខ្លឹមសារនៃរបាយការណ៍ទាំងនេះ ។

៤-រដ្ឋភាគី ត្រូវផ្សព្វផ្សាយរបាយការណ៍នេះ ឱ្យបានទូលំទូលាយ ដល់សាធារណជន នៅក្នុងប្រទេសរបស់ពួកគេ ។

## មាត្រា ៧៤

១-គណៈកម្មាធិការនេះត្រូវពិនិត្យរបាយការណ៍ ដែលផ្ញើដោយរដ្ឋភាគីនីមួយៗ ហើយត្រូវផ្ញើយោបល់ដែលខ្លួនចាត់ទុក ថាសមស្រប ទៅរដ្ឋភាគីដែលពាក់ព័ន្ធវិញ ។ រដ្ឋភាគីនេះ អាចឆ្លើយតបទៅសេចក្តីអង្កេតរបស់គណៈកម្មាធិការ លើយោបល់ណាមួយវិញបាន ដោយអនុលោមទៅតាមមាត្រានេះ ។ គណៈកម្មាធិការនេះ អាចស្នើសុំព័ត៌មានបន្ថែមពីរដ្ឋភាគី នៅពេលដែលខ្លួន កំពុងធ្វើការពិចារណាលើរបាយការណ៍ទាំងនេះ ។

២-មុនពេលបើកសម័យប្រជុំទៀងទាត់នីមួយៗ របស់គណៈកម្មាធិការនេះ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនរបាយការណ៍ដែលរដ្ឋភាគីពាក់ព័ន្ធផ្ញើមក និងព័ត៌មាននានា ដែលពាក់ព័ន្ធនឹងការពិចារណាលើរបាយការណ៍ទាំងនេះ ទៅអគ្គនាយកការិយាល័យពលកម្មអន្តរជាតិ ដើម្បីផ្តល់លទ្ធភាពឱ្យការិយាល័យរបស់គាត់អាចជួយដល់គណៈកម្មាធិការជាមួយនឹងជំនាញឯកទេសដែលការិយាល័យនេះមាន ពាក់ព័ន្ធនឹងបញ្ហានានាដែលត្រូវដោះស្រាយដោយអនុសញ្ញានេះ ដែលត្រូវស្ថិតនៅ ក្រោមសមត្ថកិច្ចរបស់អង្គការពលកម្មអន្តរជាតិ។ គណៈកម្មាធិការនេះ ត្រូវពិចារណានៅក្នុងកិច្ចពិភាក្សារបស់ខ្លួន ពីយោបល់ និងឯកសារនានា ដូចដែលការិយាល័យនេះអាចផ្តល់ឱ្យ។

៣-បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយ គណៈកម្មាធិការនេះ រួចមកអគ្គលេខាធិការអង្គការសហប្រជាជាតិក៏អាចបញ្ជូន ទៅឱ្យទីភ្នាក់ងារឯកទេសផ្សេងទៀត ព្រមទាំងអង្គការអន្តររដ្ឋាភិបាលមួយចំនួន នូវផ្នែកខ្លះនៃរបាយការណ៍ទាំងនេះ ដូចដែលអាចស្ថិតក្រោមសមត្ថកិច្ចរបស់ពួកគេ ។

៤-គណៈកម្មាធិការនេះអាចអញ្ជើញទីភ្នាក់ងារឯកទេស និងស្ថាប័ននានារបស់អង្គការសហប្រជាជាតិ ក៏ដូចជា អង្គការអន្តររដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធដទៃទៀតឱ្យផ្ញើព័ត៌មានជាលាយល័ក្ខណ៍អក្សរអំពីបញ្ហានានានៅក្នុងអនុសញ្ញានេះ ដែលស្ថិតក្រោមវិសាលភាពនៃសកម្មភាពរបស់ពួកគេមកគណៈកម្មាធិការនេះ ដើម្បីធ្វើការពិចារណា។

៥-គណៈកម្មាធិការនេះត្រូវអញ្ជើញការិយាល័យពលកម្មអន្តរជាតិ ឱ្យតែងតាំងតំណាង ចូលរួមក្នុងនាមជាអ្នកផ្តល់ការពិគ្រោះយោបល់ នៅក្នុងសម័យប្រជុំរបស់គណៈកម្មាធិការនេះ។

៦-គណៈកម្មាធិការនេះ អាចអញ្ជើញតំណាងរបស់ទីភ្នាក់ងារឯកទេស និងទីភ្នាក់ងារដទៃទៀតរបស់អង្គការសហប្រជាជាតិ និងអង្គការអន្តររដ្ឋាភិបាល ឱ្យមានវត្តមាន និងចូលរួមស្តាប់ក្នុងកិច្ចប្រជុំរបស់ខ្លួន នៅពេលដែលមានការពិចារណាលើបញ្ហា ដែលស្ថិតក្នុងវិស័យក្រោមសមត្ថកិច្ចរបស់ពួកគេ។

៧-គណៈកម្មាធិការនេះ ត្រូវបង្ហាញរបាយការណ៍ប្រចាំឆ្នាំ ទៅមហាសន្និបាតអង្គការសហប្រជាជាតិ អំពីការអនុវត្តអនុសញ្ញានេះ ដោយមានដាក់បញ្ចូលនូវការពិចារណា និងអនុសាសន៍នានារបស់ខ្លួន ជាពិសេស ដោយផ្អែកលើមូលដ្ឋាននៃការពិនិត្យលើរបាយការណ៍ និងការសង្កេតផ្សេងទៀត ដែលដាក់បង្ហាញដោយរដ្ឋភាគី ។

៨-អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវផ្ញើរបាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មាធិការនេះ ទៅគ្រប់រដ្ឋភាគីនៃអនុសញ្ញានេះ ទៅក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ អគ្គនាយកនៃការិយាល័យពលកម្មអន្តរជាតិនិងអង្គការពាក់ព័ន្ធដទៃទៀត។

## មាត្រា ៧៥

១-គណៈកម្មាធិការ ត្រូវអនុម័តវិធាននីតិវិធីរបស់ខ្លួន ។

២-គណៈកម្មាធិការ បោះឆ្នោតជ្រើសរើសមន្ត្រីរបស់ខ្លួនសម្រាប់អណត្តិ ដែលមានរយៈពេល ២ឆ្នាំ។

៣-ជាធម្មតា គណៈកម្មាធិការ ត្រូវជួបប្រជុំគ្នាជាប្រចាំឆ្នាំ ។

៤-ជាធម្មតា សម័យប្រជុំរបស់គណៈកម្មាធិការ ត្រូវធ្វើឡើងនៅទីស្នាក់ការកណ្តាលរបស់អង្គការសហប្រជាជាតិ ។

## មាត្រា ៧៦

១-រដ្ឋភាគីនៃអនុសញ្ញានេះ អាចប្រកាសនៅពេលណាក៏បាន តាមមាត្រានេះ ថាខ្លួនទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការនេះ ក្នុងការទទួល និងពិចារណាលើបណ្តឹង ដែលរដ្ឋភាគីមួយអះអាងថា រដ្ឋភាគីមួយទៀតមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនក្រោមអនុសញ្ញានេះ។ តាមមាត្រានេះ បណ្តឹងអាចត្រូវបានទទួល និងយកមកពិចារណា តែនៅក្នុងករណីដែលបណ្តឹងនេះ ត្រូវបានផ្ញើដោយរដ្ឋភាគី ដែលបានប្រកាសទទួលស្គាល់ពីសមត្ថកិច្ចរបស់គណៈកម្មាធិការនេះតែប៉ុណ្ណោះ។ គណៈកម្មាធិការ នឹងមិនទទួលបណ្តឹង ដែលពាក់ព័ន្ធនឹងរដ្ឋភាគី ដែលមិនបានធ្វើការប្រកាសដូចខាងលើនេះឡើយ។ បណ្តឹងដែលទទួលបានតាមមាត្រានេះ ត្រូវយកមកដោះស្រាយស្របទៅតាមនីតិវិធីដូចខាងក្រោម ៖

(ក) ប្រសិនបើរដ្ឋភាគីមួយនៃអនុសញ្ញានេះ ពិចារណាឃើញថា រដ្ឋភាគីមួយទៀត មិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន ក្រោមអនុសញ្ញានេះទេ រដ្ឋភាគីនេះ អាចលើកយកបញ្ហានេះ តាមរយៈបណ្តឹងជាលាយលក្ខណ៍អក្សរទៅពិភាក្សាជាមួយរដ្ឋភាគីនោះ។ រដ្ឋភាគីនេះ ក៏អាចជូនដំណឹងដល់គណៈកម្មាធិការ អំពីបញ្ហានេះផងដែរ។ ក្នុងរយៈពេលមិនលើសពី ៣ខែ បន្ទាប់ពីបានទទួលបណ្តឹងនេះហើយ រដ្ឋដែលទទួលបណ្តឹងនេះ ត្រូវផ្តល់ដល់រដ្ឋដែលដាក់បណ្តឹងនូវការពន្យល់ ឬសេចក្តីថ្លែងជាលាយលក្ខណ៍អក្សរផ្សេងទៀតបំភ្លឺឱ្យបានសមហេតុផលនិងតាមលទ្ធភាពដែលអាចធ្វើបានពីបញ្ហាដែលបានលើកឡើងនេះ យោងតាមនីតិវិធី និងដំណោះស្រាយក្នុងស្រុក ដែលមាន ឬអាចអនុវត្តបានចំពោះបញ្ហានេះ។

(ខ) ប្រសិនបើបញ្ហានេះមិនត្រូវបានកែសម្រួល ដើម្បីឱ្យមានការពេញចិត្តពីសំណាក់រដ្ឋភាគីទាំងសងខាង ក្នុងរយៈពេលមិនលើសពី ៦ខែ ក្រោយពីរដ្ឋទទួលបណ្តឹង បានទទួលបណ្តឹងដំបូងនោះទេ នោះរដ្ឋភាគីណាមួយក្នុងចំណោមរដ្ឋភាគីទាំង២នេះ មានសិទ្ធិបញ្ជូនបញ្ហានេះ ទៅគណៈកម្មាធិការដោយធ្វើការជូនដំណឹងដល់គណៈកម្មាធិការ និងដល់រដ្ឋភាគីមួយទៀត ។

(គ) គណៈកម្មាធិការ ត្រូវដោះស្រាយបញ្ហាដែលត្រូវបានបញ្ជូនមកខ្លួន តែក្រោយពេលដែលគណៈកម្មាធិការ បានបញ្ជាក់ថា គ្រប់ដំណោះស្រាយក្នុងស្រុក ត្រូវបានសំអាង និងអនុវត្តអស់ ដោយអនុលោមទៅតាមគោលការណ៍នៃច្បាប់អន្តរជាតិដែលត្រូវបានទទួលស្គាល់ជាទូទៅ។ បើតាមការយល់ឃើញរបស់គណៈកម្មាធិការ វាមិនមែនជាវិធានទេ បើការអនុវត្តដំណោះស្រាយទាំងនេះ ត្រូវបានពន្យារពេលដោយពុំមានហេតុផលសមរម្យ ។

(ឃ) អាស្រ័យទៅតាមបទប្បញ្ញត្តិក្នុងអនុកថាខណ្ឌ(គ) នៃកថាខណ្ឌនេះ គណៈកម្មាធិការត្រូវផ្តល់ការអនុវត្តល្អៗដល់រដ្ឋភាគីពាក់ព័ន្ធ តាមទស្សនៈមួយនៃការដោះស្រាយបញ្ហាជាមិត្តភាព ដោយឈរលើមូលដ្ឋាននៃការគោរពតាមកាតព្វកិច្ច ដូចមានចែងនៅក្នុងអនុសញ្ញានេះ។

(ង) គណៈកម្មាធិការ ត្រូវរៀបចំកិច្ចប្រជុំបិទទ្វារ នៅពេលពិចារណាលើបណ្តឹងនានា ដែលផ្ញើមកតាមមាត្រានេះ។

(ច) ពាក់ព័ន្ធនឹងបញ្ហានានាដែលបញ្ជូនមកខ្លួន ស្របតាមអនុកថាខណ្ឌ(ខ) នៃកថាខណ្ឌនេះ គណៈកម្មាធិការ អាចស្នើដល់រដ្ឋភាគីដែលពាក់ព័ន្ធ ផ្តល់ឱ្យខ្លួននូវព័ត៌មាននានាដែលពាក់ព័ន្ធ ដូចបានលើកឡើងនៅក្នុងអនុកថាខណ្ឌ(ខ)

(ឆ) រដ្ឋភាគីដែលពាក់ព័ន្ធ ដូចបានលើកឡើងនៅក្នុងអនុកថាខណ្ឌ(ខ) នៃកថាខណ្ឌនេះ ត្រូវមានសិទ្ធិមានតំណាង នៅពេលដែលបញ្ហាខាងលើនេះត្រូវបានគណៈកម្មាធិការ លើកយកមកពិចារណា និងមានសិទ្ធិធ្វើសេចក្តីថ្លែងរបស់ខ្លួនបានដោយផ្ទាល់មាត់ និង/ឬជាលាយល័ក្ខណ៍អក្សរ ។

(ជ) ក្នុងរយៈពេលមិនលើសពី ១២ខែ បន្ទាប់ពីបានទទួលការជូនដំណឹង ក្រោមអនុកថាខណ្ឌ(ខ)នៃកថាខណ្ឌនេះ គណៈកម្មាធិការ ត្រូវផ្ញើរបាយការណ៏ ដូចខាងក្រោម :

(i) ប្រសិនបើមានការឈានដល់ដំណោះស្រាយ តាមលក្ខខណ្ឌដូចក្នុងអនុកថាខណ្ឌ(ឃ)នៃកថាខណ្ឌនេះ គណៈកម្មាធិការ ត្រូវសង្ខេបរបាយការណ៏របស់ខ្លួន អំពីអង្គហេតុ និងដំណោះស្រាយដែលបានព្រមព្រៀង។

(ii) ប្រសិនបើមិនអាចឈានដល់ដំណោះស្រាយតាមលក្ខខណ្ឌដូចក្នុងអនុកថាខណ្ឌ(ឃ)ទេនោះ នៅក្នុងរបាយការណ៏របស់ខ្លួន គណៈកម្មាធិការ ត្រូវដាក់ចេញនូវអង្គហេតុដែលពាក់ព័ន្ធជាមួយនឹងបញ្ហារវាងរដ្ឋភាគីពាក់ព័ន្ធ។ ចម្លើយជាលាយល័ក្ខណ៏អក្សរ និងកំណត់ត្រាអំពីចម្លើយផ្ទាល់មាត់ដែលផ្តល់ដោយរដ្ឋភាគីពាក់ព័ន្ធ ត្រូវភ្ជាប់ជាមួយនឹងរបាយការណ៏នេះ។ គណៈកម្មាធិការ ក៏អាចផ្ញើឱ្យរដ្ឋភាគីដែលពាក់ព័ន្ធ នូវទស្សនៈដែលខ្លួនចាត់ទុកថា ពាក់ព័ន្ធនឹងបញ្ហារវាងរដ្ឋភាគីទាំង២នេះ។

នៅគ្រប់បញ្ហា របាយការណ៏ ត្រូវផ្ញើឱ្យរដ្ឋភាគីដែលពាក់ព័ន្ធ។

២-បទប្បញ្ញត្តិនៃមាត្រានេះ ត្រូវចូលជាធរមាន នៅពេលដែលមានរដ្ឋភាគីចំនួន១០ នៃអនុសញ្ញានេះ បានធ្វើសេចក្តីប្រកាសតាមកថាខណ្ឌទី១នៃមាត្រានេះ។ រដ្ឋភាគីត្រូវតំកល់សេចក្តីប្រកាសនេះ នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលជាអ្នកត្រូវផ្ញើច្បាប់ចម្លងនៃសេចក្តីប្រកាសនេះទៅរដ្ឋភាគីដទៃទៀត។ សេចក្តីប្រកាសនេះ អាចត្រូវបានដកវិញនៅពេលណាក៏បាន តាមរយៈការជូនដំណឹងទៅអគ្គលេខាធិការ។ ការដកវិញនេះមិនត្រូវប៉ះពាល់ដល់ការពិចារណាលើបញ្ហានានា ដែលជាកម្មវត្ថុនៃបណ្តឹង ដែល

ត្រូវបានផ្ញើរួចមកហើយ ក្រោមមាត្រានេះនោះទេ។ នៅក្នុងករណីដែលអគ្គលេខាធិការ បានទទួលសេចក្តីជូនដំណឹងពីការដកវិញនៃសេចក្តីប្រកាសរបស់រដ្ឋភាគីណាមួយហើយ គ្មានបណ្តឹងផ្សេងទៀតរបស់រដ្ឋភាគីនោះ ត្រូវបានទទួលយកមកពិនិត្យឡើយ លើកលែងតែនៅក្នុងករណីដែលរដ្ឋភាគីនោះចេញសេចក្តីប្រកាសថ្មី។

## មាត្រា ៧៧

១-រដ្ឋភាគីនៃអនុសញ្ញានេះ អាចប្រកាសនៅពេលណាក៏បាន តាមមាត្រានេះ ថាខ្លួនទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការ ក្នុងការទទួល និងពិចារណាលើបណ្តឹងនានាពីឯកត្តបុគ្គល ឬពីតំណាងបុគ្គល ក្រោមយុត្តាធិការរបស់ខ្លួន ដែលអះអាងថា សិទ្ធិឯកត្តបុគ្គលរបស់ពួកគេ ដូចមានចែងក្នុងអនុសញ្ញានេះ ត្រូវបានរដ្ឋភាគីនោះ រំលោភបំពាន។ គ្មានបណ្តឹងណាមួយត្រូវបានគណៈកម្មាធិការទទួលយកមកពិនិត្យឡើយ ប្រសិនបើបណ្តឹងនេះពាក់ព័ន្ធនឹងរដ្ឋភាគីដែលមិនបានធ្វើសេចក្តីប្រកាសបែបនេះ។

២-តាមមាត្រានេះ គណៈកម្មាធិការត្រូវចាត់ទុកថាមិនអាចទទួលយកមកពិនិត្យបាន ចំពោះបណ្តឹងណាដែលអនាមិក ឬបណ្តឹងណាដែលគណៈកម្មាធិការ យល់ឃើញថា បានបំពានលើសិទ្ធិនៃការដាក់បណ្តឹង ឬបណ្តឹងណាដែលមិនស្របតាមបទប្បញ្ញត្តិនៃអនុសញ្ញានេះ។

៣-តាមមាត្រានេះ គណៈកម្មាធិការ មិនត្រូវពិចារណាលើបណ្តឹងណាដែលដាក់ដោយបុគ្គលម្នាក់ឡើយ លុះត្រាតែបណ្តឹងនេះ បានបញ្ជាក់ថា:

(ក) បញ្ហាដូចគ្នានេះមិនធ្លាប់ត្រូវបាន និងមិនកំពុងត្រូវបានពិនិត្យដោយនីតិវិធីនៃការស៊ើបអង្កេតឬការដោះស្រាយជាអន្តរជាតិមួយផ្សេងទៀតឡើយ

(ខ) បុគ្គលរូបនេះបានប្រើប្រាស់អស់នូវមធ្យោបាយដោះស្រាយក្នុងស្រុកដែលមាន។ តាមការយល់ឃើញរបស់គណៈកម្មាធិការ វាមិនមែនជាវិធានទេ បើការអនុវត្តដំណោះស្រាយទាំងនេះ ត្រូវបានពន្យារពេល ដោយពុំមានហេតុផលសមរម្យ ឬមិនទំនងជាផ្តល់នូវដំណោះស្រាយប្រកបដោយប្រសិទ្ធភាពសម្រាប់បុគ្គលនោះទេ។

៤-អាស្រ័យទៅតាមបទប្បញ្ញត្តិកថាខ័ណ្ឌទី២ នៃមាត្រានេះ គណៈកម្មាធិការ ត្រូវយកបណ្តឹងណាដែលផ្ញើមកខ្លួនតាមមាត្រានេះ ទៅឱ្យរដ្ឋភាគីនៃអនុសញ្ញានេះ ដែលបានធ្វើសេចក្តីប្រកាសតាមកថាខណ្ឌទី១ និងដែលត្រូវរងការចោទប្រកាន់ថា បានបំពានទៅលើបទប្បញ្ញត្តិនៃអនុសញ្ញានេះ។ ក្នុងរយៈពេលមិនលើសពី៦ខែ រដ្ឋដែលទទួលបណ្តឹងនេះ ត្រូវផ្ញើឱ្យគណៈកម្មាធិការនូវការពន្យល់ ឬសេចក្តីថ្លែងជាលាយល័ក្ខណ៍អក្សរ បំភ្លឺពីបញ្ហា និងដំណោះស្រាយដែលខ្លួនបានដាក់ចេញ ប្រសិនបើមាន។

៥-គណៈកម្មាធិការ ត្រូវពិចារណាលើបណ្តឹងដែលខ្លួនទទួល តាមមាត្រានេះ ដោយផ្អែកលើព័ត៌មានទាំងអស់ដែលខ្លួនមាន ទទួលបានពីបុគ្គល ឬពីតំណាងបុគ្គលនោះ និងពីរដ្ឋភាគីដែលពាក់ព័ន្ធ ។

៦-គណៈកម្មាធិការ ត្រូវរៀបចំកិច្ចប្រជុំបិទទ្វារមួយ នៅពេលពិនិត្យលើបណ្តឹង តាមមាត្រានេះ ។

៧-គណៈកម្មាធិការ ត្រូវបញ្ជូនទស្សនៈរបស់ខ្លួន ទៅរដ្ឋភាគីដែលពាក់ព័ន្ធ និងទៅបុគ្គលនោះ ។

៨-បទប្បញ្ញត្តិនៃមាត្រានេះ ត្រូវចូលជាធរមាន នៅពេលដែលមានរដ្ឋភាគីចំនួន១០នៃអនុសញ្ញានេះ បានធ្វើសេចក្តីប្រកាសតាមកថាខណ្ឌទី១ នៃមាត្រានេះ។ រដ្ឋភាគី ត្រូវតំកល់សេចក្តីប្រកាសនេះ នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលជាអ្នកត្រូវផ្ញើច្បាប់ចម្លងនៃសេចក្តីប្រកាសនេះទៅរដ្ឋភាគីដទៃទៀត។ សេចក្តីប្រកាសនេះ អាចត្រូវបានដកវិញនៅពេលណាក៏បាន តាមរយៈការជូនដំណឹងទៅអគ្គលេខាធិការ។ ការដកវិញនេះមិនត្រូវប៉ះពាល់ដល់ការពិចារណាលើបញ្ហានានា ដែលជាកម្មវត្ថុនៃបណ្តឹង ដែលត្រូវបានផ្ញើរួចមកហើយ ក្រោមមាត្រានេះនោះទេ។ នៅក្នុងករណីដែលអគ្គលេខាធិការ បានទទួលសេចក្តីជូនដំណឹងពីការដកវិញនៃសេចក្តីប្រកាសរបស់រដ្ឋភាគីណាមួយហើយ គ្មានបណ្តឹងផ្សេងទៀតរបស់រដ្ឋភាគីនោះ ត្រូវបានទទួលយកមកពិនិត្យឡើយ លើកលែងតែនៅក្នុងករណីដែលរដ្ឋភាគីនោះចេញសេចក្តីប្រកាសថ្មី។

## មាត្រា ៧៨

បទប្បញ្ញត្តិមាត្រា៧៦ នៃអនុសញ្ញានេះ ត្រូវយកមកអនុវត្ត ដោយមិនប៉ះពាល់ដល់នីតិវិធីណាមួយសម្រាប់ការដោះស្រាយវិវាទ ឬបណ្តឹងនៅក្នុងវិស័យដែលគ្របដណ្តប់ដោយអនុសញ្ញានេះ ដែលត្រូវបានកំណត់នៅក្នុងលិខិតុបករណ៍ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ និងទីភ្នាក់ងារឯកទេសនានា ឬក្នុងអនុសញ្ញានានា ដែលត្រូវបានអនុម័តដោយអង្គការសហប្រជាជាតិ និងទីភ្នាក់ងារឯកទេសនានា ហើយមិនត្រូវរារាំងរដ្ឋភាគីពីការអនុវត្តនីតិវិធីណាមួយសម្រាប់ការដោះស្រាយវិវាទ ដោយអនុលោមទៅតាមកិច្ចព្រមព្រៀងអន្តរជាតិ ដែលនៅជាធរមានរវាងរដ្ឋភាគីទាំងនោះឡើយ ។

# ផ្នែកទី៨: បទប្បញ្ញត្តិទូទៅ

## មាត្រា ៧៩

គ្មានចំណុចណាមួយនៅក្នុងអនុសញ្ញានេះ ប៉ះពាល់ដល់សិទ្ធិនៃរដ្ឋភាគីនីមួយៗ នៅក្នុងការកំណត់ពីលក្ខណៈវិនិច្ឆ័យ សម្រាប់ទទួលយកពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេទេ។ ពាក់ព័ន្ធនឹងបញ្ហាផ្សេងទៀតដែលទាក់ទិនទៅនឹងការគ្រប់គ្រង និងស្ថានភាពផ្លូវច្បាប់របស់ពួកគេ ជាពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ រដ្ឋភាគីត្រូវស្ថិតនៅក្រោមការដាក់កំហិត ដែលមានចែងនៅក្នុងអនុសញ្ញានេះ។

## មាត្រា ៨០

គ្មានចំណុចណាមួយនៅក្នុងអនុសញ្ញានេះ ត្រូវបានបកស្រាយថា ជាការប៉ះពាល់ដល់បទប្បញ្ញត្តិនៃធម្មនុញ្ញអង្គការសហប្រជាជាតិ និងធម្មនុញ្ញរបស់ទីភ្នាក់ងារឯកទេសនានា ដែលកំណត់ពីការទទួលខុសត្រូវរៀងៗខ្លួននៃស្ថាប័នផ្សេងៗរបស់អង្គការសហប្រជាជាតិ និងរបស់ទីភ្នាក់ងារឯកទេសពាក់ព័ន្ធនឹងបញ្ហាដែលត្រូវដោះស្រាយនៅក្នុងអនុសញ្ញានេះ។

## មាត្រា ៨១

១-គ្មានចំណុចណាមួយនៅក្នុងអនុសញ្ញានេះ ប៉ះពាល់សិទ្ធិឬសេរីភាពដែលមានភាពល្អប្រសើរជាងសិទ្ធិ ឬសេរីភាពដែលផ្ដល់ឱ្យពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ នៅក្នុងអនុសញ្ញានេះទេ ដោយអាស្រ័យទៅតាមស្មារតីនៃ :

(ក) ច្បាប់ ឬការអនុវត្តរបស់រដ្ឋភាគី ឬ

(ខ) សន្ធិសញ្ញាទ្វេភាគី ឬពហុភាគីណាដែលនៅជាធរមានសម្រាប់រដ្ឋភាគីពាក់ព័ន្ធ ។

២-គ្មានចំណុចណាមួយនៅក្នុងអនុសញ្ញានេះអាចត្រូវបានបកស្រាយថា រដ្ឋណាមួយ ក្រុមណាមួយ ឬបុគ្គលណាម្នាក់ មានសិទ្ធិអ្វីមួយ ចូលរួមក្នុងសកម្មភាពណាមួយ ឬធ្វើអំពើអ្វីមួយ ដែលប៉ះពាល់ដល់សិទ្ធិ និងសេរីភាព ដូចមានចែងនៅក្នុងអនុសញ្ញានេះឡើយ ។

## មាត្រា ៨២

សិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ដែលមានចែងនៅក្នុងអនុសញ្ញានេះ មិនអាចត្រូវបានលុបចោលឡើយ ។ មិនត្រូវបានអនុញ្ញាតឱ្យមានឡើយ ដល់ការដាក់សម្ពាធតាមទម្រង់ណាក៏ដោយ លើពលករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសាររបស់ពួកគេ ក្នុងគោលបំណងលុបចោល ឬបំបិទសិទ្ធិណាមួយដូចមានខាងលើរបស់ពួកគេ ។ នេះជាប្រការមិនអាចធ្វើបាន ក្នុងការព្យួរសិទ្ធិនានា ដែលត្រូវបានទទួលស្គាល់នៅក្នុងអនុសញ្ញានេះ ដោយកិច្ចសន្យាឡើយ ។ រដ្ឋភាគី ត្រូវចាត់វិធានការសមស្រប ដើម្បីធានាថា គោលការណ៍ទាំងនេះ ត្រូវបានគោរព ។

## មាត្រា ៨៣

រដ្ឋភាគីនីមួយៗ នៃអនុសញ្ញានេះ ត្រូវ ៖

(ក) ធានាថា បុគ្គលណាក៏ដោយដែលសិទ្ធិឬសេរីភាពរបស់ពួកគេ ដូចត្រូវបានទទួលស្គាល់នៅក្នុងអនុសញ្ញានេះត្រូវបានបំពាន ត្រូវទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព ទោះបីជាការរំលោភបំពាននេះ ត្រូវបានប្រព្រឹត្តដោយបុគ្គល ដែលធ្វើសកម្មភាពក្នុងនាមជាមន្ត្រីផ្លូវការក៏ដោយ ។

(ខ) ធានាថា បុគ្គលណាក៏ដោយ ដែលស្វែងរកដំណោះស្រាយបែបនេះ ត្រូវទទួលបានការពិនិត្យ និងការសំរេចលើបណ្តឹងរបស់ពួកគេ ដោយអាជ្ញាធរច្បាប់ រដ្ឋបាល ឬតុលាការមានសមត្ថកិច្ច ឬដោយអាជ្ញាធរមានសមត្ថកិច្ចដទៃទៀតដែលត្រូវបានកំណត់ដោយប្រព័ន្ធច្បាប់របស់រដ្ឋនេះ និងត្រូវបង្កើតឱ្យមានលទ្ធភាពរកដំណោះស្រាយតាមផ្លូវតុលាការ ។

(គ) ធានាថាអាជ្ញាធរមានសមត្ថកិច្ច ត្រូវអនុវត្តតាមដំណោះស្រាយទាំងនេះ នៅពេលដែលមានការសំរេច ។

### មាត្រា ៨៤

រដ្ឋភាគីនីមួយៗ ត្រូវអនុម័តវិធានការច្បាប់ និងវិធានការដទៃទៀតដែលចាំបាច់ ដើម្បីអនុវត្តបទប្បញ្ញត្តិនៃអនុ សញ្ញានេះ ។

## ផ្នែកទី៩: អវសានប្បញ្ញត្តិ

### មាត្រា ៨៥

អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបានចាត់តាំងជាអ្នករក្សាទុកអនុសញ្ញានេះ ។

### មាត្រា ៨៦

១-អនុសញ្ញានេះ ត្រូវបើកចំហឱ្យរដ្ឋទាំងអស់ ចុះហត្ថលេខា។ អនុសញ្ញានេះ ជាកម្មវត្ថុនៃការផ្តល់សច្ចាប័ន ។

២-អនុសញ្ញានេះត្រូវបើកចំហ ឱ្យរដ្ឋនានាចូលជាភាគី ។

៣-លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការចូលជាភាគី ត្រូវតំកល់ទុកនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

## មាត្រា ៨៧

១-អនុសញ្ញានេះត្រូវចូលជាធរមាន នៅថ្ងៃទីមួយនៃខែ បន្ទាប់ពីរយៈពេល៣ខែ ចាប់គិតពីកាលបរិច្ឆេទនៃការតំកល់ លិខិតុបករណ៍ទី២០ នៃការផ្តល់សច្ចាប័ន ឬការចូលជាភាគីនៃអនុសញ្ញា។

២-សម្រាប់រដ្ឋនីមួយៗ ដែលផ្តល់សច្ចាប័ន ឬអនុម័តលើអនុសញ្ញានេះ បន្ទាប់ពីការចូលជាធរមានរបស់អនុសញ្ញានេះ អនុសញ្ញានេះត្រូវចូលជាធរមាននៅថ្ងៃទី១នៃខែ បន្ទាប់ពីរយៈពេល៣ខែ ចាប់គិតពីកាលបរិច្ឆេទនៃការដាក់លិខិតុបករណ៍ផ្តល់សច្ចាប័ន ឬអនុម័តរបស់រដ្ឋនេះ។

## មាត្រា ៨៨

រដ្ឋដែលផ្តល់សច្ចាប័ន ឬចូលជាភាគីនៃអនុសញ្ញានេះ មិនអាចផាត់ចោលនូវការអនុវត្តផ្នែកណាមួយនៃអនុសញ្ញានេះឡើយ ឬដោយមិនធ្វើឱ្យប៉ះពាល់ដល់មាត្រា៣ ផាត់ចោលនូវប្រភេទដោយឡែកណាមួយនៃពលករទេសន្តរប្រវេសន៍ ចេញពីការអនុវត្តអនុសញ្ញានេះឡើយ។

## មាត្រា ៨៩

១-រដ្ឋភាគីណាក៏ដោយអាចប្រកាសបដិសេធអនុសញ្ញានេះ មិនឱ្យឆាប់ជាងរយៈពេល៥ឆ្នាំ ក្រោយពីអនុសញ្ញានេះ បានចូលជាធរមានសម្រាប់រដ្ឋនោះឡើយ តាមរយៈការជូនដំណឹងជាលាយល័ក្ខណ៍អក្សរទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិ។

២-ការប្រកាសបដិសេធបែបនេះ ត្រូវមានប្រសិទ្ធភាព នៅថ្ងៃទី១ នៃខែ ក្រោយពីការផុតកំណត់រយៈពេល១២ខែ ចាប់គិតពីកាលបរិច្ឆេទ ដែលអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបានសេចក្តីជូនដំណឹងនេះ។

៣-ការប្រកាសបដិសេធបែបនេះ គ្មានប្រសិទ្ធភាពធ្វើឱ្យរដ្ឋភាគីមួយនេះរួចផុតពីកាតព្វកិច្ចរបស់ខ្លួន ក្រោមអនុសញ្ញានេះ ចំពោះអំពើសកម្ម ឬអកម្មណាមួយដែលកើតឡើងមុនកាលបរិច្ឆេទនៃការប្រកាសបដិសេធនេះ ចូលជាធរមានឡើយ ហើយការប្រកាសបដិសេធនេះមិនប៉ះពាល់ដល់ការពិចារណាលើបញ្ហាណាមួយដែលកំពុងស្ថិតនៅក្នុងការពិចារណារួចទៅហើយរបស់គណៈកម្មាធិការ មុនកាលបរិច្ឆេទនៃការប្រកាសបដិសេធនេះចូលជាធរមានឡើយ ។

៤-បន្ទាប់ពីកាលបរិច្ឆេទនៃការប្រកាសបដិសេធរបស់រដ្ឋភាគីមួយ ចូលជាធរមាន គណៈកម្មាធិការនេះ មិនត្រូវចាប់ផ្តើមពិចារណាលើបញ្ហាថ្មីណាមួយ ដែលពាក់ព័ន្ធនឹងរដ្ឋនោះឡើយ ។

## មាត្រា ៩០

១-ប្រាំឆ្នាំក្រោយពីពេលដែលអនុសញ្ញានេះចូលជាធរមាន រដ្ឋភាគីណាក៏ដោយ អាចស្នើសុំឱ្យមានការកែសម្រួលអនុសញ្ញានេះ នៅពេលណាក៏បាន ដោយផ្ញើសេចក្តីជូនដំណឹងជាលាយល័ក្ខណ៍អក្សរ ទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិ ។ បន្ទាប់មក អគ្គលេខាធិការត្រូវផ្ញើលិខិតអំពីសំណើសុំធ្វើវិសោធនកម្មនេះ ទៅកាន់រដ្ឋភាគី ដោយស្នើសុំឱ្យរដ្ឋភាគីទាំងនោះ ជូនដំណឹងមកគាត់វិញ ថាតើពួកគេគាំទ្រឱ្យមានសន្និសីទនៃរដ្ឋភាគី សំរាប់គោលបំណងពិចារណា និងបោះឆ្នោតលើសំណើនេះ ។ នៅក្នុងករណីដែលក្នុងរយៈពេល៤ខែ គិតចាប់ពីថ្ងៃផ្ញើលិខិតនេះ មានរដ្ឋភាគីយ៉ាងហោចណាស់ មួយភាគបី គាំទ្រឱ្យមានសន្និសីទបែបនេះ អគ្គលេខាធិការត្រូវកោះប្រជុំសន្និសីទនេះក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ ។ វិសោធនកម្មណាដែលត្រូវបានអនុម័តដោយសំលេងភាគច្រើននៃរដ្ឋភាគីដែលមានវត្តមាននិងបោះឆ្នោត ត្រូវដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិ ដើម្បីអនុម័ត ។

២-វិសោធនកម្មនានា ត្រូវចូលជាធរមាន នៅពេលដែលទទួលបានការអនុម័តពីមហាសន្និបាតអង្គការសហប្រជាជាតិ និងទទួលយកដោយសម្លេងភាគច្រើនពីរភាគបីនៃរដ្ឋភាគី ដោយអនុលោមទៅតាមនីតិវិធីរដ្ឋធម្មនុញ្ញនីមួយៗរបស់ពួកគេ។

៣-នៅពេលដែលវិសោធនកម្មទាំងនេះចូលជាធរមាន វិសោធនកម្មទាំងនេះត្រូវចងកាតព្វកិច្ចលើរដ្ឋភាគីទាំងឡាយដែលបានទទួលយកវិសោធនកម្មទាំងនេះ។ រដ្ឋភាគីដទៃទៀត នៅតែជាប់កាតព្វកិច្ចនឹងបទប្បញ្ញត្តិនៃអនុសញ្ញានេះ និងវិសោធនកម្មមុនៗ ដែលរដ្ឋភាគីបានទទួលយក។

## មាត្រា ៩១

១-អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវទទួល និងផ្សព្វផ្សាយទៅកាន់រដ្ឋទាំងអស់ នូវអត្ថបទនៃខលក្ខខណ្ឌទាំងឡាយរបស់រដ្ឋនានា នៅពេលចុះហត្ថលេខា ផ្តល់សច្ចាប័ន ឬចូលជារដ្ឋភាគីនៃអនុសញ្ញានេះ។

២-ខលក្ខខណ្ឌ ដែលមិនស្របនឹងកម្មវត្ថុ និងគោលបំណងនៃអនុសញ្ញានេះ មិនត្រូវបានអនុញ្ញាតឡើយ។

៣-ខលក្ខខណ្ឌនានា អាចត្រូវបានដកវិញនៅពេលណាក៏បាន ដោយការជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលបន្ទាប់មក ត្រូវជូនដំណឹងដល់រដ្ឋទាំងអស់។ ការជូនដំណឹងបែបនេះ ត្រូវមានប្រសិទ្ធភាពនៅកាលបរិច្ឆេទ ដែលទទួលបានសេចក្តីជូនដំណឹងនេះ។

## មាត្រា ៩២

១-វិវាទទាំងឡាយ រវាងរដ្ឋភាគីចំនួន២ ឬច្រើន ពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តអនុសញ្ញានេះ ដែលមិនអាចដោះស្រាយបាន តាមរយៈការចរចា ត្រូវបញ្ជូនទៅកាន់មជ្ឈត្តកម្ម ទៅតាមការស្នើសុំរបស់រដ្ឋភាគីណាមួយ ក្នុងចំណោមរដ្ឋភាគីទាំងនេះ។ ប្រសិនបើនៅក្នុងរយៈពេល ៦ខែ ចាប់

ពីថ្ងៃដាក់សំណើឱ្យមានមជ្ឈត្តកម្មមក រដ្ឋភាគី មិនអាចឯកភាពគ្នាលើការរៀបចំមជ្ឈត្តកម្មនេះបាន ភាគីណាមួយក្នុងចំណោមភាគីទាំងនេះអាចបញ្ជូនវិវាទនេះ ទៅកាន់តុលាការយុត្តិធម៌អន្តរជាតិ តាមការស្នើសុំ ស្របតាមលក្ខន្តិកៈរបស់តុលាការនេះ ។

២-នៅពេលចុះហត្ថលេខា ឬផ្តល់សច្ចាប័ន ឬចូលជារដ្ឋភាគីនៃអនុសញ្ញានេះ រដ្ឋភាគីនីមួយៗអាចប្រកាសថា ខ្លួនមិនទទួលស្គាល់កាតព្វកិច្ចតាមកថាខណ្ឌទីមួយ នៃមាត្រានេះទេ ។ រដ្ឋភាគីដទៃទៀត មិនត្រូវជាប់កាតព្វកិច្ចដោយសារកថាខណ្ឌនេះ ពាក់ព័ន្ធនឹងរដ្ឋភាគីណាដែលបានធ្វើសេចក្តីប្រកាសបែបនេះឡើយ ។

៣-រដ្ឋភាគីណាដែលបានធ្វើសេចក្តីប្រកាស ស្របតាមកថាខណ្ឌទី២ នៃមាត្រានេះ អាចដកសេចក្តីប្រកាសនេះចេញ នៅពេលណាក៏បាន ដោយការជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

## មាត្រា ៩៣

១-អនុសញ្ញានេះដែលមានអត្ថបទជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញដែលមានតំលៃស្មើគ្នាត្រូវបានតំកល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

២-អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវធ្វើច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវនៃអនុសញ្ញានេះ ទៅកាន់រដ្ឋទាំងអស់ ។

ជាបន្ទាល់នៃអនុសញ្ញានេះ បុណ្ណទូតដែលមានហត្ថលេខាខាងក្រោម ហើយដែលបានទទួលនូវការអនុញ្ញាតយ៉ាងត្រឹមត្រូវពីរដ្ឋាភិបាលរបស់ខ្លួន បានចុះហត្ថលេខាលើអនុសញ្ញានេះ ។

# អនុសញ្ញាអន្តរជាតិ

# ស្តីពី

# ការការពារជនគ្រប់រូប

# ពីការបាត់ខ្លួនដោយបង្ខំ

# ១៥. អនុសញ្ញាអន្តរជាតិស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ

ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិកាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៦
ចូលជាធរមាននៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១០ តាមមាត្រា៣៩(១)
កម្ពុជាបានចូលជារដ្ឋភាគីនៅថ្ងៃទី២៧ មិថុនា ឆ្នាំ២០១៣

## បុព្វកថា

### *រដ្ឋភាគីនៃអនុសញ្ញានេះ*

*ដោយពិចារណាអំពី*កាតព្វកិច្ចរបស់រដ្ឋភាគី តាមធម្មនុញ្ញសហប្រជាជាតិ ដើម្បីលើកស្ទួយការគោរពជាសកល និងការប្រតិបត្តិសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ។

*ដោយយកចិត្តទុកដាក់ចំពោះ* សេចក្តីប្រកាសជាសកល ស្តីពីសិទ្ធិមនុស្ស ។

*រំលឹកឡើងវិញ*អំពីកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម-កិច្ច និងវប្បធម៌ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងលិខិតុបករណ៍អន្តរជាតិដែលពាក់ព័ន្ធដទៃទៀត នៅក្នុងវិស័យសិទ្ធិមនុស្ស ច្បាប់មនុស្សធម៌ និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។

*រំលឹកឡើងវិញផងដែរ* អំពីសេចក្តីប្រកាសស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ ដែលបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅក្នុងសេចក្តីសំរេចចិត្តរបស់ខ្លួនលេខ៤៧/១៣៣ ចុះថ្ងៃ ១៨ ខែធ្នូ ឆ្នាំ១៩៩២ ។

*ដោយដឹងអំពី* ភាពធ្ងន់ធ្ងរបំផុតនៃការបាត់ខ្លួនដោយបង្ខំ ដែល-បង្កើតបានជាបទឧក្រិដ្ឋមួយ និងជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុង-កាលៈទេសៈមួយចំនួនដែលបានកំណត់ក្នុងច្បាប់អន្តរជាតិ ។

*ដោយបានប្ដេជ្ញាចិត្ត* ដើម្បីបង្ការការបាត់ខ្លួនដោយបង្ខំ និងដើម្បីប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាពចំពោះឧក្រិដ្ឋកម្ម នៃការបាត់ខ្លួនដោយបង្ខំ។

*ដោយពិចារណាអំពី* សិទ្ធិបុគ្គលគ្រប់រូប ដែលមិនត្រូវស្ថិតក្រោមការបាត់ខ្លួនដោយបង្ខំ សិទ្ធិជនរងគ្រោះក្នុងការទាមទារយុត្តិធម៌ និងសំណងជម្ងឺចិត្ត។

*បញ្ជាក់អំពី* សិទ្ធិជនរងគ្រោះ ត្រូវដឹងការពិតពីកាលៈទេសៈនៃការបាត់ខ្លួនដោយបង្ខំ និងអំពីជោគវាសនានៃជនបាត់ខ្លួន និងសិទ្ធិមានសេរីភាពស្វែងរក ទទួល និងចែករំលែកព័ត៌មានក្នុងគោលបំណងនេះ។

*បានព្រមព្រៀងលើមាត្រាទាំងឡាយដូចខាងក្រោមនេះ :*

## ភាគ ១

### *មាត្រា ១ :*

គ្មានជនណាម្នាក់ ត្រូវស្ថិតក្រោមការបាត់ខ្លួនដោយបង្ខំឡើយ។

គ្មានករណីលើកលែង ទោះជាក្នុងករណីណាក៏ដោយ ទោះជាក្នុងស្ថានភាពសង្គ្រាម ឬការគំរាមកំហែងដោយសង្គ្រាម អស្ថិរភាពនយោបាយផ្ទៃក្នុង ឬភាពអាសន្នជាសាធារណៈណាក៏ដោយ មិនអាចយកជាយុត្តិកម្មចំពោះការបាត់ខ្លួនដោយបង្ខំឡើយ។

**មាត្រា ២ :**

សំរាប់គោលបំណងនៃអនុសញ្ញានេះ "ការបាត់ខ្លួនដោយបង្ខំ"សំដៅដល់ការចាប់ខ្លួន ការឃុំខ្លួន ការចាប់ពង្រត់ ឬទម្រង់ផ្សេងទៀតនៃការដកហូតសិទ្ធិ ធ្វើឡើងដោយភ្នាក់ងាររដ្ឋ ឬដោយបុគ្គល ឬដោយក្រុមបុគ្គលដែលមានការអនុញ្ញាត ការគាំទ្រឬការយល់ព្រមពីរដ្ឋ លុះក្រោយមកបានបដិសេធមិនទទួលស្គាល់ពីការដកហូតសេរីភាព ឬដោយមានការលាក់បំបាំងពីជោគវាសនា ឬទីកន្លែងជនបាត់ខ្លួន ដោយដាក់ជននោះឱ្យស្ថិតនៅក្រៅការការពារពីច្បាប់ ។

**មាត្រា ៣ :**

រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការសមស្របដើម្បីស៊ើបអង្កេតអំពើល្មើសដែលមានចែងក្នុងមាត្រា២ ដែលបានប្រព្រឹត្តដោយបុគ្គល ឬដោយក្រុមបុគ្គលដែលគ្មានការអនុញ្ញាត ការគាំទ្រ ឬការយល់ព្រមពីរដ្ឋ ហើយត្រូវនាំខ្លួនជនដែលទទួលខុសត្រូវទៅតុលាការ ដើម្បីផ្តន្ទាទោសតាមច្បាប់ ។

**មាត្រា ៤ :**

រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការចាំបាច់ដើម្បីធានាថា ការបាត់ខ្លួនដោយបង្ខំ គឺជាបទល្មើសមួយតាមច្បាប់ព្រហ្មទណ្ឌរបស់ខ្លួន ។

**មាត្រា ៥ :**

ការរីកដាល ឬការអនុវត្តន៏ជាប្រព័ន្ធនៃការបាត់ខ្លួនដោយបង្ខំ គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចមានចែងក្នុងច្បាប់អន្តរជាតិ ដែលកំពុងអនុវត្ត និងត្រូវមានវិបាកដូចមានចែងក្នុងច្បាប់អន្តរជាតិជាធរមាន ។

## មាត្រា ៦ ៖

១. រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការចាំបាច់ ដើម្បីចាប់ឱ្យទទួលខុសត្រូវព្រហ្មទណ្ឌ យ៉ាងហោចណាស់ចំពោះ:

(ក).ជនណាក៏ដោយដែលប្រព្រឹត្តបញ្ជាស្នើសុំ ឬញុះញុងឱ្យប្រព្រឹត្ត ប៉ុនប៉ង់ប្រព្រឹត្ត គឺជាអ្នកសមគំនិត ឬចូលរួមក្នុងការបាត់ខ្លួនដោយបង្ខំ។

(ខ). អ្នកគ្រប់គ្រងដែល ៖

(i). បានដឹង ឬមានចេតនាមិនអើពើចំពោះព័ត៌មានដែលបានបញ្ជាក់ច្បាស់លាស់ថា អ្នកក្រោមបង្គាប់ ដែលស្ថិតក្រោមអំណាច និងការគ្រប់គ្រងដ៏មានប្រសិទ្ធភាពរបស់ខ្លួន កំពុងប្រព្រឹត្ត ឬហៀបនឹងប្រព្រឹត្តបទឧក្រិដ្ឋ នៃការបាត់ខ្លួនដោយបង្ខំ

(ii). បានអនុវត្តការទទួលខុសត្រូវ និងការគ្រប់គ្រង ដ៏មានប្រសិទ្ធភាព ចំពោះសកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនៃការបាត់ខ្លួនដោយបង្ខំ និង

(iii). មិនបានចាត់វាល់វិធានការចាំបាច់ និងសមហេតុផល ក្នុងដែនអំណាចរបស់ខ្លួន ដើម្បីបង្ការ ឬបង្ក្រាបការប្រព្រឹត្តបទឧក្រិដ្ឋនៃការបាត់ខ្លួនដោយបង្ខំ ឬបញ្ជូនបញ្ហានេះ ទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីធ្វើការស៊ើបអង្កេត និងផ្តន្ទាទោស

(គ).អនុកថាខ័ណ្ឌ(ខ)ខាងលើ មិនធ្វើឱ្យប៉ះពាល់ដល់ក៏រិតនៃការទទួលខុសត្រូវខ្ពស់ជាង ដែលកំពុងអនុវត្តក្រោមច្បាប់អន្តរជាតិ ចំពោះមេបញ្ជាការយោធា ឬចំពោះបុគ្គលដែលកំពុងដើរតួនាទី យ៉ាងមានប្រសិទ្ធភាពដូចជាមេបញ្ជាការយោធានោះទេ។

(២) គ្មានបញ្ជា ឬការណែនាំពីអាជ្ញាធរសាធារណៈណាមួយ ជនស៊ីវិល យោធា ឬអ្នកដទៃទៀតអាចត្រូវបានលើកមកធ្វើការដោះសារ ដើម្បីធ្វើយុត្តិកម្មពីបទល្មើសនៃការបាត់ខ្លួនដោយបង្ខំឡើយ ។

## មាត្រា ៧ :

រដ្ឋភាគីនីមួយៗ ត្រូវដាក់បទល្មើសនៃការបាត់ខ្លួនដោយបង្ខំ អោយមានការផ្តន្ទាទោសដោយទោសបញ្ញត្តិ សមស្រប ដោយពិចារណាទៅតាមភាពធ្ងន់ធ្ងរនៃបទល្មើស ។

រដ្ឋភាគីនីមួយៗ អាចបង្កើត :

(ក) ស្ថានសំរាលទោសបាន ជាពិសេសចំពោះជនដែលត្រូវធ្វើឱ្យមានការពាក់ព័ន្ធនឹងការប្រព្រឹត្តបទឧក្រិដ្ឋ នៃការបាត់ខ្លួនដោយបង្ខំ ហើយដែលរួមវិភាគទានដ៏មានប្រសិទ្ធភាពក្នុងការនាំខ្លួនជនបាត់ខ្លួនឱ្យរស់រានមានជីវិត ឬផ្តល់លទ្ធភាពដល់ការបំភ្លឺករណី នៃការបាត់ខ្លួនដោយបង្ខំ ឬដើម្បីកំណត់អត្តសញ្ញាណជនល្មើសនៃការបាត់ខ្លួនដោយបង្ខំ ។

(ខ) ស្ថានទម្ងន់ទោសដោយមិនធ្វើឱ្យខូចខាតដល់នីតិវិធីព្រហ្មទណ្ឌដទៃទៀត ជាពិសេសក្នុងករណីនៃការស្លាប់របស់ជនបាត់ខ្លួន ឬការប្រព្រឹត្តបទល្មើសនៃការបាត់ខ្លួនដោយបង្ខំ ចំពោះស្ត្រីមានផ្ទៃពោះ អនីតិជន ជនពិការ ឬក៏ជនដែលងាយរងគ្រោះជាពិសេសផ្សេងទៀត ។

## មាត្រា ៨ :

ដោយមិនធ្វើឱ្យខូចខាតដល់មាត្រា៥ :

រដ្ឋភាគីនីមួយៗ ដែលអនុវត្តអាជ្ញាយុកាលចំពោះការបាត់ខ្លួន ដោយបង្ខំ ត្រូវចាត់វិធានការចាំបាច់ ដើម្បីធានាថា រយៈពេលអាជ្ញាយុកាល សំរាប់នីតិវិធីព្រហ្មទណ្ឌត្រូវ :

(ក). មានរយៈពេលវែង និងមានសមាមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃបទល្មើសនោះ

(ខ). គិតចាប់ពីពេលដែលបទល្មើសនៃការបាត់ខ្លួនដោយបង្ខំ បានបញ្ចប់ ដោយធ្វើការពិចារណាអំពីចរិតបន្តរបស់វា។

រដ្ឋភាគីនីមួយៗ ត្រូវធានាការពារសិទ្ធិជនរងគ្រោះ ដោយការបាត់ខ្លួនដោយបង្ខំ ដើម្បីដោះស្រាយប្រកបដោយប្រសិទ្ធភាព នៅក្នុងអំឡុងពេលនៃអាជ្ញាយុកាលនេះ។

## *មាត្រា ៩ :*

១. រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការចាំបាច់ ដើម្បីកំណត់ពីសមត្ថកិច្ចរបស់ខ្លួន ក្នុងការអនុវត្តន៍យុត្តាធិការលើបទល្មើសនៃការបាត់ខ្លួន ដោយបង្ខំ :

(ក) នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តនៅលើទឹកដីណាមួយក្រោមយុត្តាធិការរបស់ខ្លួន ឬនៅលើនាវា ឬយន្តហោះដែលបានចុះបញ្ជី ក្នុងរដ្ឋនោះ

(ខ) នៅពេលដែលជនល្មើសដែលជាប់ចោទ គឺជាជនជាតិរបស់ខ្លួន

(គ) នៅពេលដែលជនបាត់ខ្លួន គឺជាជនជាតិរបស់ខ្លួន ហើយរដ្ឋភាគី យល់ថា វាជាការសមស្រប។

២. រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការដូចគ្នានេះដែរតាមការចាំបាច់ ដើម្បីកំណត់សមត្ថកិច្ចរបស់ខ្លួន ក្នុងការអនុវត្តន៍យុត្តាធិការលើបទល្មើស នៃការបាត់ខ្លួនដោយបង្ខំ នៅពេលជនល្មើសដែលជាប់ចោទ មានវត្តមាននៅលើទឹកដីណាមួយ ក្រោមយុត្តាធិការរបស់ខ្លួន បើពុំនោះទេ រដ្ឋភាគីនោះត្រូវធ្វើបត្យាប័ន ឬប្រគល់ជនល្មើសនោះទៅឱ្យរដ្ឋមួយទៀត ស្របតាមកាតព្វកិច្ចអន្តរជាតិរបស់ខ្លួន ឬប្រគល់ជនល្មើសនោះឱ្យតុលាការព្រហ្មទណ្ឌអន្តរជាតិដែលរដ្ឋនោះបានទទួលស្គាល់ពីយុត្តាធិការតុលាការនេះ។

៣. អនុសញ្ញានេះ មិនបានផាត់ចោលយុត្តាធិការព្រហ្មទណ្ឌបន្ថែមណាមួយ ដែលបានអនុវត្តស្របតាមច្បាប់ជាតិឡើយ។

### *មាត្រា ១០ :*

១. បន្ទាប់ពីយល់ថាគ្រប់គ្រាន់ល្មមហើយនោះ ក្រោយពីការពិនិត្យព័ត៌មានដែលរដ្ឋនោះមាន ថាករណីនេះជាការចាំបាច់ រដ្ឋភាគីណាក៏ដោយនៅលើទឹកដីរបស់ខ្លួន ត្រូវចាប់ឃុំជនដែលត្រូវសង្ស័យថាបានប្រព្រឹត្តបទល្មើសនៃការបាត់ខ្លួនដោយបង្ខំ ឬចាត់វិធានការតាមផ្លូវច្បាប់តាមការចាំបាច់ ដើម្បីអះអាងពីវត្តមានជននោះ។ ការឃុំខ្លួន និងវិធានការតាមផ្លូវច្បាប់ដទៃទៀតត្រូវតែអនុវត្តដូចមានចែងក្នុងច្បាប់របស់រដ្ឋភាគីនោះ ប៉ុន្តែអាចឃុំខ្លួនបានក្នុងរយៈពេលមួយចាំបាច់តែប៉ុណ្ណោះ ដើម្បីធានាវត្តមានជនសង្ស័យតាមនីតិវិធីព្រហ្មទណ្ឌ ការប្រគល់ ឬការធ្វើបត្យាប័ន។

២. រដ្ឋភាគីដែលបានចាត់វិធានការ ដូចមានចែងក្នុងកថាខណ្ឌ១ នៃមាត្រានេះ ត្រូវធ្វើការសាកសួរ ឬការស៊ើបអង្កេតជាបឋមភ្លាមៗ ដើម្បីកំណត់អង្គហេតុ។ រដ្ឋភាគីនេះ ត្រូវជូនដំណឹងទៅរដ្ឋភាគីដទៃទៀត ដូចមានចែងក្នុងមាត្រា៩ កថាខណ្ឌ១ អំពីការចាត់វិធានការរបស់ខ្លួន ស្របតាមកថាខណ្ឌ១ នៃមាត្រានេះ រួមទាំងការឃុំខ្លួន និងករណីដែលតម្រូវឱ្យមានការឃុំខ្លួន និងរបាយការណ៍ស្ដីពីការសាកសួរ ឬការស៊ើបអង្កេតបឋមរបស់ខ្លួន ដោយបញ្ជាក់ថាតើ ខ្លួនមានបំណងអនុវត្តយុត្តាធិការរបស់ខ្លួនឬទេ។

៣. ជនជាប់ឃុំឃាំង ស្របតាមកថាខណ្ឌ១នៃមាត្រានេះ អាចទាក់ទងភ្លាមៗ ជាមួយតំណាងសមស្របដែលនៅជិតបំផុតនៃរដ្ឋដែលខ្លួនជាជន-ជាតិ ឬប្រសិនជាជននោះជាជនគ្មានសញ្ជាតិ គាត់អាចទាក់ទងជាមួយតំណាងរដ្ឋ ដែលខ្លួនរស់នៅជាធម្មតា។

## *មាត្រា ១១ :*

១. រដ្ឋភាគីដែលលើទឹកដីក្រោមយុត្តាធិការរបស់ខ្លួន មានជនណាម្នាក់ ត្រូវគេចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើសនៃការបាត់ខ្លួនដោយបង្ខំ បើខ្លួនមិនធ្វើបត្យាប័ន ឬប្រគល់ជននោះទៅឱ្យរដ្ឋណាមួយ ស្របតាមកាតព្វកិច្ចអន្តរជាតិរបស់ខ្លួន ឬមិនប្រគល់ជននោះឱ្យតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលខ្លួនបានទទួលស្គាល់សមត្ថកិច្ចតុលាការនោះទេ ត្រូវបញ្ជូនករណីនេះទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីផ្ដន្ទាទោសទៅតាមច្បាប់។

២. អាជ្ញាធរទាំងនេះ ត្រូវធ្វើការសំរេចរបស់ខ្លួន ក្នុងលក្ខណៈដូចគ្នាទៅនឹងករណីនៃបទល្មើសធម្មតា ដែលមានចរិតធ្ងន់ធ្ងរ ក្រោមច្បាប់រដ្ឋភាគីនោះ។ ក្នុងករណីដូចមានចែងក្នុងមាត្រា៩ កឋាខ័ណ្ឌ២ បទដ្ឋាននៃភស្តុតាងដែលតម្រូវឱ្យមាន សំរាប់ការចោទប្រកាន់ និងការផ្តន្ទាទោស មិនត្រូវឱ្យស្រាលជាង បទដ្ឋាននៃភស្តុតាងដែលអនុវត្តក្នុងករណីទាំងឡាយដែលមាន-ចែងក្នុងមាត្រា៩ កឋាខ័ណ្ឌ១ ឡើយ។

៣. ជនណាម្នាក់ដែលត្រូវគេចាត់នីតិវិធីប្រឆាំងមកលើខ្លួន ពាក់ព័ន្ធនឹងបទល្មើសនៃការបាត់ខ្លួនដោយបង្ខំ ត្រូវបានធានាការពារឱ្យមានការប្រព្រឹត្តមកលើខ្លួនឱ្យបានត្រឹមត្រូវ នៅគ្រប់ដំណាក់កាលនៃនីតិវិធី។ ជនណាម្នាក់ ដែលត្រូវបានជំនុំជំរះ ក្នុងបទល្មើសនៃការបាត់ខ្លួនដោយបង្ខំ ត្រូវទទួលបានអត្ថប្រយោជន៍ពីការជំនុំជំរះដោយយុត្តិធម៌នៅចំពោះមុខសាលាជំរះក្តីមួយដែលមានសមត្ថភាព ឯករាជ្យ និងមិនលំអៀង ឬតុលាការដែលបានបង្កើតឡើងដោយច្បាប់។

### *មាត្រា ១២ :*

១. រដ្ឋភាគីនីមួយៗ ត្រូវធានាថា ជនណាក៏ដោយដែលចោទថា ជនណាម្នាក់ ត្រូវបានស្ថិតក្រោមការបាត់ខ្លួនដោយបង្ខំ មានសិទ្ធិរាយការណ៍អំពីអង្គហេតុនោះ ទៅអាជ្ញាធរមានសមត្ថកិច្ច ដែលត្រូវពិនិត្យលើការចោទប្រកាន់នោះជាបន្ទាន់ និងដោយមិនលំអៀង ហើយប្រសិនជាចាំបាច់ ត្រូវធ្វើការស៊ើបអង្កេតទាំងស្រុង និងមិនលំអៀងមួយ ដោយគ្មានការពន្យាពេល។ ត្រូវចាត់វិធានការសមស្របប្រសិនជាចាំបាច់ ដើម្បីធានាថាដើមចោទ សាក្សី

សាច់ញាតិជនបាត់ខ្លួនដោយបង្ខំ និងមេធាវីរបស់គេ ព្រមទាំងបុគ្គលទាំងឡាយដែលចូលរួមក្នុងការស៊ើបអង្កេត ត្រូវបានការពារ ប្រឆាំងនឹងរាល់ការព្យាបាទ ឬការបំភិតបំភ័យ ដោយសារតែការប្ដឹង ឬការផ្ដល់ភស្ដុតាងណាមួយឡើយ ។

២. ប្រសិនជាមានហេតុផលសមស្របអាចជឿថា បុគ្គលម្នាក់ កំពុងស្ថិតក្នុងការបាត់ខ្លួនដោយបង្ខំ អាជ្ញាធរ ដែលមានចែងក្នុងកឋាខ័ណ្ឌ១ នៃ-មាត្រានេះ ត្រូវធ្វើការស៊ើបអង្កេត បើទោះជាមិនមានបណ្ដឹងជាផ្លូវការក៏ដោយ ។

រដ្ឋភាគីនីមួយៗ ត្រូវធានាថា អាជ្ញាធរទាំងឡាយដែលមានចែងក្នុងកឋាខ័ណ្ឌ១ នៃមាត្រានេះ ត្រូវ :

（ក） មានអំណាច និងធនធានចាំបាច់ ដើម្បីធ្វើការស៊ើបអង្កេតអោយមានប្រសិទ្ធភាព រួមទាំងសិទ្ធិប្រើប្រាស់សំណុំឯកសារ និងព័ត៌មានផ្សេងៗ ពាក់ព័ន្ធនឹងការស៊ើបអង្កេតរបស់ខ្លួន ។

（ខ） ប្រសិនជាចាំបាច់ ដោយមានការអនុញ្ញាតជាមុន ពីអាជ្ញាធរតុលាការ ដែលត្រូវសំរេចពីបញ្ហានេះជាបន្ទាន់ មានសិទ្ធិចូលទៅទីកន្លែងឃុំឃាំង ឬកន្លែងដទៃណាក៏ដោយ ដែលមានហេតុផលសមស្របអោយជឿបានថា ជនបាត់ខ្លួនមានវត្តមាននៅទីនោះ ។

៤. រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការចាំបាច់ ដើម្បីបង្ការ និងដាក់ទណ្ឌកម្មទង្វើទាំងឡាយ ដែលបង្កឧបសគ្គ ដល់ដំណើរការស៊ើបអង្កេត ។ រដ្ឋភាគីត្រូវធានាជាពិសេសថាជនសង្ស័យដែលបានប្រព្រឹត្តបទល្មើសនៃការបាត់

ខ្លួនដោយបង្ខំ មិនមានតួនាទីជ្រៀតជ្រែក ដល់កិច្ចដំណើរការស៊ើបអង្កេត ដោយមធ្យោបាយគាបសង្កត់ ឬការបំភិតបំភ័យ ឬការសងសឹកចំពោះដើមចោទ សាក្សី សាច់ញាតិជនបាត់ខ្លួន ឬមេធាវីរបស់ខ្លួន ឬចំពោះបុគ្គលដែលចូលរួមក្នុងការស៊ើបអង្កេត ។

***មាត្រា ១៣ :***

១.សំរាប់គោលបំណងនៃការធ្វើបត្យាប័នរវាងរដ្ឋភាគី បទល្មើសនៃការបាត់ខ្លួនដោយបង្ខំ មិនត្រូវចាត់ទុកថាជាបទល្មើសនយោបាយឬបទល្មើសពាក់ព័ន្ធនឹងរឿងនយោបាយ ឬបទល្មើសណាមួយ ដែលបានឃុបឃិតក្នុងគោលបំណងនយោបាយ ។ អាស្រ័យហេតុនេះការស្នើធ្វើបត្យាប័នដោយផ្អែកលើបទល្មើសបែបនេះ មិនអាចត្រូវបានបដិសេធ ដោយផ្អែកតែលើមូលហេតុនេះមួយមុខបានឡើយ ។

២. បទល្មើសនៃការបាត់ខ្លួនដោយបង្ខំ ត្រូវចាត់ថា បានរាប់បញ្ចូលជាបទល្មើសដែលអាចធ្វើបត្យាប័នបាន នៅក្នុងសន្ធិសញ្ញាបត្យាប័នណាមួយរវាងរដ្ឋភាគី នៅមុនការចូលជាធរមាននៃអនុសញ្ញានេះ ។

៣. រដ្ឋភាគីត្រូវបញ្ចូលបទល្មើសនៃការបាត់ខ្លួនដោយបង្ខំ ថាជាបទល្មើសមួយ ដែលអាចធ្វើបត្យាប័នបាន នៅក្នុងសន្ធិសញ្ញាបត្យាប័នណាមួយដែលក្រោយមក ត្រូវបានធ្វើឡើងរវាងរដ្ឋភាគីទាំងនោះ ។

៤.ប្រសិនបើរដ្ឋភាគីមួយដែលកំណត់លក្ខខណ្ឌបត្យាប័នលើអត្ថិភាពនៃសន្ធិសញ្ញាមួយ ទទួលការស្នើសុំធ្វើបត្យាប័នពីរដ្ឋភាគីមួយទៀត ដែលមិន

មានសន្ធិសញ្ញាបត្យាប័ន រដ្ឋនោះអាចចាត់ទុកអនុសញ្ញានេះថាជាមូលដ្ឋានគតិយុត្តិចាំបាច់សំរាប់ការធ្វើបត្យាប័នចំពោះបទល្មើសនៃការបាត់ខ្លួនដោយបង្ខំ ។

៥. រដ្ឋភាគីដែលមិនកំណត់លក្ខខណ្ឌបត្យាប័ន លើអត្ថិភាពនៃសន្ធិសញ្ញាមួយ ត្រូវទទួលស្គាល់បទល្មើសនៃការបាត់ខ្លួនដោយបង្ខំថាជាបទល្មើសមួយដែលអាចធ្វើបត្យាប័នបានរវាងរដ្ឋភាគី ។

៦. នៅគ្រប់ករណីទាំងអស់ ការធ្វើបត្យាប័នត្រូវស្ថិតក្រោមលក្ខខណ្ឌ ដែលមានចែងដោយច្បាប់របស់រដ្ឋភាគី ដែលបានស្នើសុំធ្វើបត្យាប័ន ឬដោយសន្ធិសញ្ញាបត្យាប័ននានាដែលកំពុងអនុវត្ត ជាពិសេសរួមទាំងលក្ខខណ្ឌទាក់ទងនឹងការទាមទារទោសបញ្ញត្តិជាអប្បបរមា សំរាប់ការធ្វើបត្យាប័ននិងមូលហេតុរដ្ឋភាគីដែលបានស្នើសុំធ្វើបត្យាប័ន អាចបដិសេធការធ្វើបត្យាប័ន ឬកំណត់ឱ្យវាស្ថិតក្រោមលក្ខខណ្ឌមួយចំនួន ។

៧. គ្មានបញ្ញត្តិណាមួយក្នុងអនុសញ្ញានេះ ត្រូវបានធ្វើការបកស្រាយថា ជាការកំណត់កាតព្វកិច្ចចំពោះការធ្វើបត្យាប័នឡើយ ប្រសិនបើរដ្ឋភាគីដែលស្នើសុំធ្វើបត្យាប័ន មានហេតុផលរឹងមាំដែលអាចជឿថាការស្នើសុំនោះបានធ្វើឡើងក្នុងគោលបំណងធ្វើការចោទប្រកាន់ ឬផ្តន្ទាទោសជនណាម្នាក់ដោយមូលហេតុនៃភេទ ពូជសាសន៍ សាសនា សញ្ជាតិ ដើមកំណើតជាតិ មតិនយោបាយ ឬសមាជិកភាពនៃក្រុមសង្គមណាមួយ ឬថាការអនុវត្តន៍តាមការស្នើសុំ អាចនឹងបង្កអន្តរាយដល់ជននោះចំពោះហេតុផលណាមួយក្នុងចំណោមហេតុផលទាំងនោះ ។

***មាត្រា ១៤ :***

១. រដ្ឋភាគី ត្រូវផ្ដល់ឱ្យគ្នាទៅវិញទៅមក នូវវិធានការមានប្រសិទ្ធភាពបំផុត តាមជំនួយផ្លូវច្បាប់ពាក់ព័ន្ធនឹងចំណាត់ការព្រហ្មទណ្ឌ ចំពោះបទល្មើសនៃការបាត់ខ្លួនដោយបង្ខំដោយរួមទាំងការផ្ដល់ភស្តុតាងគ្រប់បែបយ៉ាងដែលចាំបាច់ តាមធនធានរបស់ខ្លួន សំរាប់ដំណើរការនីតិវិធី ។

២. ការជួយគ្នាទៅវិញទៅមក តាមផ្លូវច្បាប់នេះ ត្រូវស្ថិតក្រោមលក្ខខណ្ឌដែលមានចែងដោយច្បាប់ក្នុងស្រុក នៃរដ្ឋភាគីដែលបានស្នើសុំធ្វើបត្យាប័ន ឬដោយសន្ធិសញ្ញានានាស្ដីពីជំនួយផ្នែកច្បាប់ដែលកំពុងអនុវត្ត ជាពិសេសរួម ទាំងលក្ខខណ្ឌទាក់ទងនឹងមូលហេតុ ដែលរដ្ឋភាគីស្នើសុំធ្វើបត្យាប័នអាចបដិសេធមិនផ្ដល់ជំនួយតាមផ្លូវច្បាប់ ឬអាចកំណត់លក្ខខណ្ឌផ្សេងៗ។

***មាត្រា ១៥ :***

១. រដ្ឋភាគី ត្រូវសហការគ្នា ហើយត្រូវផ្ដល់ឱ្យគ្នាទៅវិញទៅមកនូវវិធានការមានប្រសិទ្ធភាពបំផុត ក្នុងការជួយគ្នាទៅវិញទៅមក ក្នុងគោលបំណងជួយជនរងគ្រោះ ដោយការបាត់ខ្លួនដោយបង្ខំ និងក្នុងការស្វែងរកការកំណត់ទីកន្លែង និងការដោះលែងជនបាត់ខ្លួន ហើយក្នុងករណីជនរងគ្រោះទទួលមរណៈភាព ត្រូវគាស់សាកសព និងកំណត់អត្តសញ្ញាណ ហើយត្រូវបញ្ជូនធាតុទៅប្រទេសរបស់គេវិញ ។

## *មាត្រា ១៦ :*

១. គ្មានរដ្ឋភាគីណាមួយ ត្រូវនិរទេស បញ្ជូនត្រឡប់មកវិញ ("refouler") ប្រគល់ ឬធ្វើបត្យាប័នជនណាម្នាក់ ទៅឱ្យរដ្ឋណាមួយទៀត ដែលមានហេតុផលរឹងមាំអាចជឿថា ជននោះនឹងត្រូវប្រឈមមុខនឹងគ្រោះថ្នាក់ដោយការបាត់ខ្លួនដោយបង្ខំឡើយ ។

២. សំរាប់គោលបំណងនៃការកំណត់ពីហេតុផលទាំងនេះ អាជ្ញាធរមានសមត្ថកិច្ច ត្រូវពិចារណាអំពីករណីពាក់ព័ន្ធ ប្រសិនជាអាចធ្វើទៅបាន រួមទាំងអំពីអត្ថិភាពក្នុងរដ្ឋសាមី នូវលំនាំពាក់ព័ន្ធនៃការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរជាក់ស្តែង ឬទ្រង់ទ្រាយធំ ឬអំពីការរំលោភធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ។

## *មាត្រា ១៧ :*

គ្មានជនណាម្នាក់ត្រូវបានគេឃុំខ្លួនក្នុងមន្ទីរឃុំឃាំងសំងាត់ឡើយ ។

ដោយមិនធ្វើឱ្យប៉ះពាល់ដល់ កាតព្វកិច្ចអន្តរជាតិដទៃទៀត នៃរដ្ឋភាគី ចំពោះការដកហូតសេរីភាព រដ្ឋភាគីនីមួយៗ ត្រូវចែងក្នុងច្បាប់របស់ខ្លួន នូវការ :

(ក) បង្កើតលក្ខខណ្ឌ ដែលតាមរយៈនោះ អាចចេញបញ្ជាឱ្យដកហូតសេរីភាព

(ខ) បញ្ជាក់ថា អាជ្ញាធរទាំងនោះ ត្រូវបានអនុញ្ញាតឱ្យចេញបញ្ជាដកហូតសេរីភាព

(គ) ធានាថា ជនដែលត្រូវគេដកហូតសេរីភាព ត្រូវបានឃុំខ្លួន តែនៅក្នុងកន្លែងដកហូតសេរីភាព ដែលមានការគ្រប់គ្រង និងទទួលស្គាល់ជាផ្លូវការប៉ុណ្ណោះ ។

(ឃ) ធានាថា ជនដែលត្រូវគេដកហូតសេរីភាព ត្រូវបានអនុញ្ញាតឱ្យធ្វើការទាក់ទងជាមួយ និងត្រូវបានទទួលការសួរសុខទុក្ខពីគ្រួសារ មេធាវីឬអ្នកដទៃទៀត តាមការជ្រើសរើសរបស់ខ្លួន អនុលោមតាមលក្ខខណ្ឌដែលច្បាប់កំណត់ ឬប្រសិនបើជននោះ ជាជនបរទេស អាចទាក់ទងជាមួយអាជ្ញាធរកុងស៊ុលរបស់ខ្លួន ស្របតាមច្បាប់អន្តរជាតិ ជាធរមាន ។

(ង) ធានាថា អាជ្ញាធរ និងស្ថាប័នមានសមត្ថកិច្ចស្របច្បាប់ ដែលមានការអនុញ្ញាត អាចចូលទៅដល់កន្លែងដាក់ជនដែលត្រូវគេដកហូតសេរីភាព ប្រសិនជាចាំបាច់ ដោយមានការអនុញ្ញាតជាមុនពីអាជ្ញាធរតុលាការ ។

(ច) ធានាថាជនដែលត្រូវគេដកហូតសេរីភាព ឬក្នុងករណីសង្ស័យថាមានការបាត់ខ្លួនដោយបង្ខំ ដោយសារជនដែលត្រូវគេដកហូតសេរីភាពមិនអាចប្រើប្រាស់សិទ្ធិនេះ ជនដែលមានផលប្រយោជន៍ស្របច្បាប់ ដូចជាសាច់ញាតិ នៃជនដែលត្រូវគេដកហូតសេរីភាព តំណាង ឬមេធាវីរបស់ខ្លួននៅគ្រប់ករណីទាំងអស់ ត្រូវមានសិទ្ធិធ្វើចំណាត់ការតាមផ្លូវច្បាប់ នៅចំពោះមុខតុលាការ ដើម្បីឱ្យតុលាការសំរេចដោយមិនមានការពន្យាពេល អំពីភាពស្របច្បាប់ នៃការដកហូតសេរីភាព និងដើម្បីធ្វើការដោះលែងជននោះប្រសិនបើការដកហូតសេរីភាពនេះ ខុសច្បាប់ ។

៣. រដ្ឋភាគីនីមួយៗ ត្រូវធានាពីការចងក្រង និងការរក្សាបញ្ជីផ្លូវការមួយ ឬច្រើន ដែលបានធ្វើបច្ចុប្បន្នភាព និង/ឬកំណត់ហេតុជន ដែលត្រូវបានដកហូតសេរីភាព ដែលត្រូវរកអោយបានភ្លាមៗ តាមការស្នើសុំ ដល់អាជ្ញាធរ ឬស្ថាប័នតុលាការមានសមត្ថកិច្ចដទៃទៀត ដែលបានអនុញ្ញាតសំរាប់គោលបំណងនោះ ដោយច្បាប់នៃរដ្ឋភាគីសាមុី ឬដោយលិខិតុបករណ៏គតិយុត្តិអន្តរជាតិណាមួយពាក់ព័ន្ធ ដែលរដ្ឋសាមុីជាភាគី។ ព័តិមាននៅក្នុងនោះ ត្រូវមានជាអប្ប បរមានូវ ៖

(ក) អត្តសញ្ញាណរបស់ជនដែលត្រូវគេដកហូតសេរីភាព។

(ខ) កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងដែលជននោះត្រូវគេដកហូតសេរីភាព និងអត្តសញ្ញាណអាជ្ញាធរដែលបានដកហូតសេរីភាពជននោះ។

(គ) អាជ្ញាធរដែលបានបញ្ជាឱ្យដកហូតសេរីភាព និងមូលហេតុ នៃការដកហូតសេរីភាព។

(ឃ) អាជ្ញាធរទទួលខុសត្រូវគ្រប់គ្រងការដកហូតសេរីភាព។

(ង) កន្លែងដកហូតសេរីភាព កាលបរិច្ឆេទ និងពេលវេលានៃការ-ដាក់ចូលកន្លែងដកហូតសេរីភាព និងអាជ្ញាធរ ទទួលខុសត្រូវកន្លែងដកហូតសេរីភាព។

(ច) សមាសធាតុទាក់ទងនឹងស្ថានភាពសុខភាព របស់ជនដែលត្រូវគេដកហូតសេរីភាព។

(ឆ) ក្នុងករណីមរណៈភាព ក្នុងអំឡុងពេលនៃការដកហូតសេរីភាព ត្រូវបញ្ជាក់ពីកាលៈទេសៈ និងមូលហេតុនៃការស្លាប់ និងទីកន្លែងដែលបញ្ជូនសាកសពទៅ ។

(ជ) កាលបរិច្ឆេទ និងពេលវេលានៃការដោះលែង ឬការផ្ទេរទៅមន្ទីរឃុំឃាំងមួយទៀត គោលដៅ និងអាជ្ញាធរទទួលខុសត្រូវចំពោះការផ្ទេរនោះ ។

## *មាត្រា ១៨ :*

ស្របតាមមាត្រា១៩និងមាត្រា២០រដ្ឋភាគីនីមួយៗត្រូវធានាចំពោះជនដែលមានប្រយោជន៍ស្របច្បាប់ក្នុងព័ត៌មាននេះ ដូចជា សាច់ញាតិជនដែលត្រូវគេដកហូតសេរីភាព តំណាង ឬមេធាវីរបស់គេ អាចទទួលបានយ៉ាងហោចណាស់នូវព័ត៌មាន ដូចខាងក្រោមនេះ :

(ក) អាជ្ញាធរដែលបានបញ្ជាឱ្យធ្វើការដកហូតសេរីភាព ។

(ខ) កាលបរិច្ឆេទ ពេលវេលា និងទីកន្លែង ដែលជននោះត្រូវបានដកហូតសេរីភាព និងត្រូវបានទទួលឱ្យចូលក្នុងកន្លែងដកហូតសេរីភាព ។

(គ) អាជ្ញាធរទទួលខុសត្រូវគ្រប់គ្រងការដកហូតសេរីភាព ។

(ឃ) ទីកន្លែងនៃជនដែលត្រូវគេដកហូតសេរីភាព រួមទាំងក្នុងករណីនៃការផ្ទេរទៅកន្លែងដកហូតសេរីភាពមួយទៀត គោលដៅ និងអាជ្ញាធរទទួលខុសត្រូវចំពោះការផ្ទេរនោះ ។

(ង) កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងដោះលែង ។

(ច) សមាសធាតុទាក់ទងនឹងស្ថានភាពសុខភាព របស់ជនដែលត្រូវគេដកហូតសេរីភាព

(ឆ) ក្នុងករណីមរណៈភាពក្នុងអំឡុងពេលនៃការដកហូតសេរីភាព ត្រូវបញ្ជាក់ពីកាលៈទេសៈ និងមូលហេតុនៃការស្លាប់ និងទីកន្លែងដែលបញ្ជូនសាកសពទៅ ។

២. ត្រូវចាត់វិធានការសមស្រប ប្រសិនបើចាំបាច់ ដើម្បីការពារជនទាំងឡាយ ដែលមានចែងក្នុងកថាខណ្ឌ១ នៃមាត្រានេះ ក៏ដូចជាជនទាំងឡាយ ដែលចូលរួមក្នុងការស៊ើបអង្កេត ពីការតាមព្យាបាទ ការបំភិតបំភ័យ ឬការដាក់ទណ្ឌកម្ម ដោយសារតែការស្វែងរកព័ត៌មានពាក់ព័ន្ធ នឹងជនដែលត្រូវគេដកហូតសេរីភាព ។

## មាត្រា ១៩ :

ព័ត៌មានផ្ទាល់ខ្លួន រួមទាំងទិន្នន័យវិជ្ជសាស្ត្រ និងហ្សែន ដែលប្រមូលបាន និង/ឬបានបញ្ជូនក្នុងក្របខ័ណ្ឌនៃការស្វែងរកជនបាត់ខ្លួនណាម្នាក់ មិនត្រូវបានប្រើប្រាស់ ឬអោយប្រយោជន៍សំរាប់គោលបំណងណាផ្សេង ក្រៅពីការស្វែងរកជនបាត់ខ្លួននោះឡើយ ។ ការនេះមិនត្រូវឱ្យប៉ះពាល់ ដល់ការប្រើប្រាស់ព័ត៌មានបែបនេះ ក្នុងចំណាត់ការព្រហ្មទណ្ឌ ស្ដីពីបទល្មើសនៃការបាត់ខ្លួនដោយបង្ខំ ឬការអនុវត្តន៍សិទ្ធិទាមទារសំណងជំងឺចិត្តឡើយ ។

ការប្រមូល ការចាត់ការ ការប្រើប្រាស់ និងការរក្សាទុកព័ត៌មានផ្ទាល់ខ្លួន រួមទាំងទិន្នន័យវិជ្ជសាស្ត្រ និងហ្សែន មិនត្រូវរំលោភ ឬមានឥទ្ធិពលនៃការរំលោភសិទ្ធិមនុស្ស សេរីភាពជាមូលដ្ឋាន ឬសេចក្ដីថ្លៃថ្នូរជាមនុស្សនៃបុគ្គលណាមួយឡើយ ។

**មាត្រា ២០ :**

១. ក្នុងករណីដែលជនណាម្នាក់ត្រូវបានការពារដោយច្បាប់ ហើយការដកហូតសេរីភាព ស្ថិតក្រោមការត្រួតពិនិត្យដោយតុលាការ សិទ្ធិទទួលព័ត៌មានដែលមានចែងក្នុងមាត្រា១៨ អាចត្រូវបានរិតត្បិត ផ្អែកលើករណីពិសេស ប្រសិនបើចាំបាច់បំផុត និងមានចែងដោយច្បាប់ ហើយប្រសិនបើ-ការបញ្ជូនព័ត៌មាន អាចប៉ះពាល់ជាអវិជ្ជមានដល់សិទ្ធិឯកជន ឬសុវត្ថិភាពបុគ្គល បង្កឧបសគ្គដល់ការស៊ើបអង្កេតផ្នែកព្រហ្មទណ្ឌ ឬចំពោះហេតុផលស្រដៀងគ្នាដទៃទៀត អនុលោមតាមច្បាប់ និងស្របតាមច្បាប់អន្តរជាតិ ជាធរមាន ហើយស្របតាមគោលដៅនៃអនុសញ្ញានេះ។ ទោះជាក្នុងករណីណាក៏ដោយ មិនត្រូវធ្វើការរិតត្បិតសិទ្ធិទទួលព័ត៌មានដែលមានចែងក្នុងមាត្រា ១៨ ដែលបង្កើតបានជាទង្វើដែលមានចែងក្នុងមាត្រា២ ឬរំលោភលើមាត្រា ១៧ កថាខណ្ឌ១ ឡើយ។

២. ដោយមិនធ្វើឱ្យប៉ះពាល់ដល់ការគិតគូរពីភាពស្របច្បាប់នៃការដកហូតសេរីភាពបុគ្គល រដ្ឋភាគី ត្រូវធានាការពារជនទាំងឡាយដែលមាន-ចែងក្នុងមាត្រា១៨ កថាខ័ណ្ឌ១ នូវសិទ្ធិទទួលបានការដោះស្រាយតាមផ្លូវតុលាការភ្លាមៗ និងមានប្រសិទ្ធភាព ជាមធ្យោបាយក្នុងការទទួលបានព័ត៌មាន ដែលមានចែងក្នុងមាត្រា១៨ កថាខ័ណ្ឌ១ ដោយមិនមានការពន្យាពេល។ សិទ្ធិទទួលបានការដោះស្រាយនេះ មិនអាចត្រូវបានព្យួរ ឬរិតត្បិតទោះជាក្នុងករណីណាក៏ដោយ។

### មាត្រា ២១ :

រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការចាំបាច់ ដើម្បីធានាថា ជនដែលគេដកហូតសេរីភាព ត្រូវបានដោះលែងក្នុងលក្ខណៈមួយដែលអនុញ្ញាតឱ្យមានការពិនិត្យផ្ទៀងផ្ទាត់ ដែលអាចជឿបានថា ពួកគេពិតជាត្រូវបានដោះលែងប្រាកដមែន។ រដ្ឋភាគីនីមួយៗ ក៏ត្រូវចាត់វិធានការចាំបាច់ ដើម្បីធានាបូរណភាពរូបកាយរបស់បុគ្គលទាំងនេះ និងលទ្ធភាពក្នុងការអនុវត្តន៏សិទ្ធិរបស់ពួកគេយ៉ាងពេញលេញ នៅពេលដោះលែងឱ្យមានសេរីភាព ដោយមិនធ្វើឱ្យប៉ះពាល់ដល់កាតព្វកិច្ចណាមួយ ដែលជនទាំងនេះ អាចស្ថិតក្រោមច្បាប់ជាតិ។

### មាត្រា ២២ :

ដោយមិនធ្វើឱ្យប៉ះពាល់ដល់មាត្រា៦ រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការចាំបាច់ ដើម្បីបង្ការ និងដាក់ទណ្ឌកម្ម ចំពោះទង្វើដូចខាងក្រោមនេះ :

(ក) ការពន្យារពេល ឬការរំខានដល់ការដោះស្រាយដែលមានចែងក្នុងមាត្រា១៧ កឋាខ័ណ្ឌ២(ច) និងមាត្រា២០ កថាខ័ណ្ឌ២។

(ខ) ការខកខាន មិនបានកត់ត្រា អំពីការដកហូតសេរីភាពបុគ្គលណាម្នាក់ ឬការកត់ត្រាព័តិមានណាមួយ ដែលមន្ត្រីទទួលខុសត្រូវចំពោះបញ្ជីផ្លូវការ បានដឹង ឬគួរតែបានដឹងថាមិនពិត។

(គ) ការបដិសេធមិនព្រមផ្តល់ព័តិមាន អំពីការដកហូតសេរីភាព-បុគ្គលណាម្នាក់ ឬការផ្តល់ព័តិមានមិនពិត ទោះជាបានបំពេញសេចក្តីតម្រូវតាមផ្លូវច្បាប់ឱ្យផ្តល់ព័តិមាននោះក៏ដោយ។

**មាត្រា ២៣ ៖**

១. រដ្ឋភាគីនីមួយៗ ត្រូវធានាឱ្យមានការបណ្ដុះបណ្ដាលបុគ្គលិកប្រតិបត្តិច្បាប់ បុគ្គលិកស៊ីវិល ឬយោធា បុគ្គលិកពេទ្យ មន្ត្រីសាធារណៈ និងអ្នកដទៃទៀត ដែលអាចចូលរួមក្នុងការឃុំគ្រង ឬការប្រព្រឹត្តទៅលើជនណាម្នាក់ ដែលត្រូវគេដកហូតសេរីភាព រួមទាំងការអប់រំ និងព័ត៌មានចាំបាច់អំពីបទបញ្ញត្តិពាក់ព័ន្ធ នៃអនុសញ្ញានេះ ដើម្បី ៖

(ក) បង្ការការជាប់ពាក់ព័ន្ធនៃមន្ត្រីទាំងនេះក្នុងការបាត់ខ្លួន ដោយបង្ខំ ។

(ខ) បញ្ជាក់ពីសារសំខាន់នៃការបង្ការ និងការស៊ើបអង្កេតករណីនៃការបាត់ខ្លួនដោយបង្ខំ ។

(គ) ធានាថាសេចក្ដីត្រូវការជាបន្ទាន់ដើម្បីដោះស្រាយករណីនៃការបាត់ខ្លួនដោយបង្ខំត្រូវបានទទួលស្គាល់ ។

២. រដ្ឋភាគីនីមួយៗ ត្រូវធានាថា បញ្ជា ឬសេចក្ដីណែនាំដែលបានចេញ អនុញ្ញាត ឬជំរុញឱ្យមានការបាត់ខ្លួនដោយបង្ខំ ត្រូវបានហាមឃាត់ ។ រដ្ឋភាគីនីមួយៗត្រូវធានាថា ជនណាម្នាក់ដែលបដិសេធមិនគោរពតាមបញ្ជានេះ មិនត្រូវបានផ្ដន្ទាទោសឡើយ ។

៣. រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការចាំបាច់ ដើម្បីធានាថា ជនទាំងឡាយដែលមានចែងក្នុងកថាខ័ណ្ឌ១ នៃមាត្រានេះ ដែលមានហេតុផលអាចជឿបានថា ការបាត់ខ្លួនដោយបង្ខំបានកើតឡើង ឬបានគ្រោងរាយការណ៍អំពីបញ្ហានេះ ទៅថ្នាក់លើរបស់ខ្លួន ហើយបើសិនជាចាំបាច់ ទៅអាជ្ញាធរ ឬស្ថាប័នសមស្របដែលត្រូវបានប្រគល់អំណាចឱ្យពិនិត្យ ឬដោះស្រាយករណីនេះ ។

***មាត្រា ២៤ ៖***

១. សំរាប់គោលបំណងនៃអនុសញ្ញានេះ " ជនរងគ្រោះ " សំដៅដល់ជនបាត់ខ្លួន និងបុគ្គលណាម្នាក់ដែលរងការឈឺចាប់ដោយផ្ទាល់ពីការបាត់ខ្លួនដោយបង្ខំនេះ ។

២. ជនរងគ្រោះម្នាក់ៗ មានសិទ្ធិដឹងការពិតអំពីកាលៈទេសៈនៃការបាត់ខ្លួនដោយបង្ខំ ភាពជឿនលឿន និងលទ្ធផលនៃការស៊ើបអង្កេត និងជោគវាសនារបស់ជនបាត់ខ្លួន ។ រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការសមស្របចំពោះករណីនេះ ។

៣. រដ្ឋភាគីត្រូវចាត់រាល់វិធានការសមស្រប ដើម្បីស្វែងរកកំណត់ទីកន្លែងនិងដោះលែងជនបាត់ខ្លួន ហើយក្នុងករណីមរណៈភាព ត្រូវតំកល់សពការគោរព និងការបញ្ជូនសាកសពទៅប្រទេសខ្លួនវិញ ។

៤. រដ្ឋភាគីនីមួយៗ ត្រូវធានានៅក្នុងប្រព័ន្ធច្បាប់របស់ខ្លួនថា ជនរងគ្រោះដោយការបាត់ខ្លួនដោយបង្ខំ មានសិទ្ធិទទួលបានសំណងជម្ងឺចិត្ត និងសំណងការខូតខាតគ្រប់គ្រាន់ ត្រឹមត្រូវ និងភ្លាមៗ ។

៥. សិទ្ធិទទួលបានសំណងជម្ងឺចិត្ត មានចែងក្នុងកថាខ័ណ្ឌ៤នៃមាត្រានេះ រួមទាំងការខូចខាតខាងសំភារៈ និងស្មារតី ហើយប្រសិនជាសមស្របទម្រង់ផ្សេងៗ នៃការជួសជុលការខូចខាតដូចជា ៖

(ក) បដិទាន

(ខ) ការស្តារសម្បទា

(គ) ការធ្វើឱ្យពេញចិត្ត រួមមានការស្តារកិត្តិយស និងសេចក្តីថ្លៃថ្នូរ

(ឃ) ការធានាមិនឱ្យកើតមានជាថ្មី

៦. ដោយមិនធ្វើឱ្យប៉ះពាល់ដល់កាតព្វកិច្ច ដើម្បីបន្តការស៊ើបអង្កេតរហូតដល់បញ្ជាក់ច្បាស់ពីជោគវាសនាជនបាត់ខ្លួន រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការសមស្រប ពាក់ព័ន្ធនឹងស្ថានភាពផ្លូវច្បាប់នៃជនបាត់ខ្លួនដែលគេមិនទាន់បានបញ្ជាក់ច្បាស់ពីជោគវាសនា និងគ្រួសាររបស់ខ្លួន នៅក្នុងវិស័យមួយចំនួន ដូចជាសុខមាលភាពសង្គម បញ្ហាហិរញ្ញវត្ថុ ច្បាប់គ្រួសារ និងសិទ្ធិលើទ្រព្យសម្បត្តិ ។

៧. រដ្ឋភាគីនីមួយៗ ត្រូវធានាការពារសិទ្ធិបង្កើត និងចូលរួមដោយសេរីក្នុងអង្គការ និងសមាគមពាក់ព័ន្ធដោយការព្យាយាមបង្កើតកាលៈទេសៈនៃការបាត់ខ្លួនដោយបង្ខំ និងជោគវាសនារបស់ជនបាត់ខ្លួន និងដើម្បីជួយជនរងគ្រោះដោយការបាត់ខ្លួនដោយបង្ខំ ។

## *មាត្រា ២៥ :*

១. រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការចាំបាច់ ដើម្បីបង្ការ និងផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌរបស់ខ្លួនចំពោះ:

(ក) ការដកចេញដោយខុសច្បាប់ នូវកុមារទាំងឡាយ ដែលស្ថិតក្រោមការបាត់ខ្លួនដោយបង្ខំ កុមារដែលឪពុក ម្តាយ ឬអាណាព្យាបាលស្របច្បាប់របស់គេ ស្ថិតក្នុងការបាត់ខ្លួនដោយបង្ខំ ឬកុមារដែលកើតនៅក្នុងអំឡុងពេលនៃការចាប់ខ្លួនម្តាយ ក្រោមការបាត់ខ្លួនដោយបង្ខំ ។

(ខ) ការក្លែងបន្លំ ការលាក់បាំង ឬការបំផ្លិចបំផ្លាញឯកសារ ដែលបង្ហាញពីអត្តសញ្ញាណពិតប្រាកដរបស់កុមារ ដូចមានចែងក្នុងអនុកឋាខ័ណ្ឌ (ក) ខាងលើ ។

២. រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការចាំបាច់ ដើម្បីស្វែងរក និងកំណត់អត្តសញ្ញាណកុមារដែលមានចែងក្នុងកឋាខ័ណ្ឌ១ (ក) នៃមាត្រានេះ ហើយត្រូវបញ្ជូនកុមារទាំងនោះ ទៅឱ្យគ្រួសារដើមរបស់គេវិញ ស្របតាម-នីតិវិធីច្បាប់ និងកិច្ចព្រមព្រៀងអន្តរជាតិជាធរមាន។

៣. រដ្ឋភាគី ត្រូវជួយគ្នាក្នុងការស្វែងរកការកំណត់អត្តសញ្ញាណ និងទីកន្លែងកុមារ ដូចមានចែងក្នុងកឋាខ័ណ្ឌ១ (ក) នៃមាត្រានេះ។

៤. ដោយសារតែសេចក្តីត្រូវការការពារឧត្តមប្រយោជន៍កុមារ ដូចមានចែងក្នុងកថាខ័ណ្ឌ១(ក) នៃមាត្រានេះ និងសិទ្ធិកុមារក្នុងការរក្សា ឬដើម្បីកំណត់ជាថ្មីនូវអត្តសញ្ញាណ រួមទាំងសញ្ជាតិ ឈ្មោះ និងទំនាក់ទំនងគ្រួសាររបស់គេ ដូចបានទទួលស្គាល់ដោយច្បាប់ រដ្ឋភាគីដែលទទួលស្គាល់ប្រព័ន្ធសុំកូន ឬទម្រង់ផ្សេងទៀតនៃការឃុំគ្រងកុមារ ត្រូវតែមាននីតិវិធីច្បាប់ជាស្រេច ដើម្បីពិនិត្យលើនីតិវិធីសុំកុមារ ឬនីតិវិធីឃុំគ្រងកុមារ ហើយប្រសិនជាសមស្រប ត្រូវធ្វើមោឃភាពការសុំ ឬការឃុំគ្រងកុមារដែលមានប្រភពមកពីការបាត់ខ្លួនដោយបង្ខំ។

៥. នៅគ្រប់ករណីទាំងអស់ ហើយជាពិសេស នៅរាល់បញ្ហាដែលទាក់ទងនឹងមាត្រានេះ ត្រូវគិតគូរមុនគេបង្អស់ អំពីឧត្តមប្រយោជន៍របស់កុមារ និងកុមារដែលអាចបង្កើតគំនិតផ្ទាល់ខ្លួន ត្រូវមានសិទ្ធិសំដែងមតិយោបល់ទាំងនោះដោយសេរី មតិយោបល់ដែលកុមារសំដែង ត្រូវធ្វើការថ្លឹងថ្លែង ទៅតាមអាយុ និងភាពចាស់ទុំរបស់កុមារនោះ។

# ភាគ ២

## មាត្រា ២៦ :

១. គណៈកម្មាធិការទទួលបន្ទុកការបាត់ខ្លួនដោយបង្ខំ (ដែលនៅក្នុងឯកសារនេះហៅថា " គណៈកម្មាធិការ " ត្រូវបានបង្កើតឡើង ដើម្បីបំពេញមុខងារដែលមានចែងក្នុងអនុសញ្ញានេះ។ គណៈកម្មាធិការនេះ ត្រូវមានអ្នកជំនាញការដប់រូប ដែលមានសីលធមិខ្ពស់ និងសមត្ថភាពដែលគេទទួលស្គាល់ក្នុងវិស័យសិទ្ធិមនុស្ស ដែលត្រូវបំរើការក្នុងសមត្ថភាពរបស់ខ្លួនផ្ទាល់ដោយឯករាជ្យ និងមិនលំអៀង។ សមាជិកគណៈកម្មាធិការ ត្រូវបានជ្រើសរើសដោយរដ្ឋភាគី ស្របតាមការបែងចែកតាមភូមិសាស្ត្រ ប្រកបដោយសមធមិ។ ត្រូវពិចារណាយ៉ាងត្រឹមត្រូវអំពីអត្ថប្រយោជន៍ នៃការចូលរួម ក្នុងការងាររបស់គណៈកម្មាធិការនៃជនដែលមានបទពិសោធន៍ ផ្នែកច្បាប់ពាក់ព័ន្ធ និងតំណាងតុល្យភាពយេនឌ័រ។

២. សមាជិកគណៈកម្មាធិការ ត្រូវបានបោះឆ្នោតជ្រើសតាំង ជាសំងាត់ ពីក្នុងបញ្ជីបេក្ខជនឈរឈ្មោះដែលតែងតាំងដោយរដ្ឋភាគី ពីក្នុងចំណោមជនជាតិរបស់ខ្លួន ក្នុងសម័យប្រជុំរាល់ពីរឆ្នាំម្តងរបស់រដ្ឋភាគី ដែលកោះប្រជុំដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ សំរាប់គោលបំណងនេះ។ នៅក្នុងសម័យប្រជុំទាំងនោះ ចំនួនកូរ៉ុមគឺស្មើនឹងពីរភាគបី នៃរដ្ឋភាគីបេក្ខជនដែលត្រូវបានជ្រើសរើសជាសមាជិកគណៈកម្មាធិការ គឺជាបេក្ខជនដែលបានទទួលសំលេងឆ្នោតច្រើនជាងគេ និងសំលេងគាំទ្រភាគច្រើនដាច់ខាតពីតំណាងរដ្ឋភាគីទាំងឡាយ ដែលមានវត្តមាន និងបានបោះឆ្នោត។

៣. ការបោះឆ្នោតលើកដំបូង នឹងត្រូវបានរៀបចំធ្វើមិនឱ្យលើស ពីប្រាំមួយខែ បន្ទាប់ពីកាលបរិច្ឆេទនៃការចូលជាធរមាននៃអនុសញ្ញានេះ។ បួនខែមុនកាលបរិច្ឆេទនៃការបោះឆ្នោតនីមួយៗ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវផ្ញើលិខិតមួយច្បាប់ទៅរដ្ឋភាគី ដើម្បីអញ្ជើញរដ្ឋភាគីទាំងនេះ ឱ្យតែងតាំងឈ្មោះបេក្ខជនរបស់ខ្លួនក្នុងរយៈពេលបីខែ។ អគ្គលេខាធិការ ត្រូវរៀបចំបញ្ជីមួយ តាមលំដាប់តួអក្ខរក្រមនៃបេក្ខជនឈរឈ្មោះទាំងអស់ ដោយបញ្ជាក់ប្រាប់ពីរដ្ឋភាគីដែលបានតែងតាំង ហើយត្រូវបញ្ជូនបញ្ជីឈ្មោះនេះ ទៅរដ្ឋភាគីទាំងអស់។

៤. សមាជិកគណៈកម្មាធិការ ត្រូវបានបោះឆ្នោតជ្រើសតាំង សំរាប់អាណត្តិមួយ ដែលមានរយៈពេលបួនឆ្នាំ។ សមាជិកទាំងនោះ ត្រូវមានសិទ្ធិឈរឈ្មោះអោយគេបោះឆ្នោតជាថ្មីបានម្តងទៀត។ទោះជាយ៉ាងណាក៏ដោយ អាណត្តិរបស់សមាជិកប្រាំរូប ដែលជាប់ឆ្នោតក្នុងការបោះឆ្នោតលើកទីមួយ ត្រូវបញ្ចប់នៅខាងចុងឆ្នាំទីពីរ។ ភ្លាមៗបន្ទាប់ពីការបោះឆ្នោតលើកទីមួយ ឈ្មោះបេក្ខជនទាំងប្រាំរូបនេះ ត្រូវបានជ្រើសរើសដោយប្រធានអង្គប្រជុំ ដូចមានចែងក្នុងកថាខ័ណ្ឌ២ នៃមាត្រានេះ។

៥.ប្រសិនជាសមាជិកណាម្នាក់នៃគណៈកម្មាធិការនេះ ទទួលមរណៈភាព ឬលាឈប់ពីការងារ ឬដោយមូលហេតុដទៃទៀតដែលមិនអាចបំពេញការងារឱ្យគណៈកម្មាធិការបានតទៅទៀត រដ្ឋភាគីដែលបានបញ្ជូនឈ្មោះបេក្ខជននោះ ស្របតាមលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងកថាខ័ណ្ឌ១ នៃ-

មាត្រានេះ ត្រូវចាត់តាំងបេក្ខជនម្នាក់ផ្សេងទៀត ពីក្នុងចំណោមជនជាតិរបស់ខ្លួន ដើម្បីបំពេញអាណត្តិរបស់ខ្លួន ដោយមានការយល់ព្រម ពីចំនួន-ភាគច្រើននៃរដ្ឋភាគី។ ការយល់ព្រមនេះ ត្រូវបានចាត់ទុកថាបានទទួល បើពុំនោះទេ ត្រូវមានចំនួនពាក់កណ្តាល ឬច្រើនជាងពាក់កណ្តាលនៃរដ្ឋភាគីឆ្លើយបដិសេធក្នុងរយៈពេលប្រាំមួយសប្តាហ៍ចាប់ ពីថ្ងៃដែលអគ្គលេខាធិការអង្គការសហប្រជាជាតិជូនដំណឹង ពីការស្នើសុំឱ្យធ្វើការចាត់តាំងបេក្ខជនថ្មី។

៦. គណៈកម្មាធិការនេះ ត្រូវបង្កើតបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

៧. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវផ្តល់ឱ្យគណៈកម្មាធិការនេះ នូវមធ្យោបាយចាំបាច់ ដូចជា បុគ្គលិក មធ្យោបាយ សំរាប់បំពេញមុខងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវកោះប្រជុំលើកដំបូងនៃគណៈកម្មាធិការនេះ។

៨.សមាជិកគណៈកម្មាធិការនេះត្រូវមានសិទ្ធិប្រើប្រាស់មធ្យោបាយបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិជាអ្នកជំនាញការ បំពេញបេសកកម្មសំរាប់អង្គការសហប្រជាជាតិ ដូចមានចែងក្នុងផ្នែកពាក់ព័ន្ធនៃអនុសញ្ញាស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់អង្គការសហប្រជាជាតិ។

៩. រដ្ឋភាគីនីមួយៗ ត្រូវសហការជាមួយគណៈកម្មាធិការនេះ និង-ជួយសមាជិករបស់គណៈកម្មាធិការ ក្នុងការបំពេញអាណត្តិរបស់ខ្លួន ទៅ-តាមទំហំការងាររបស់គណៈកម្មាធិការ ដែលរដ្ឋភាគីបានយល់ព្រម។

## មាត្រា ២៧ :

សន្និសីទរបស់រដ្ឋភាគី នឹងត្រូវប្រារព្ធធ្វើយ៉ាងឆាប់បំផុត បួនឆ្នាំ ហើយយ៉ាងយូរបំផុតប្រាំមួយឆ្នាំ បន្ទាប់ពីការចូលជាធរមាននៃអនុសញ្ញានេះ ដើម្បីវាយតំលៃលើការងាររបស់គណៈកម្មាធិការ និងដើម្បីសំរេច ដោយអនុលោមតាមនីតិវិធីដែលមានចែងក្នុងមាត្រា៤៤ កឋាខ័ណ្ឌ២ ថាតើសមស្រប ត្រូវបញ្ជូនទៅស្ថាប័នមួយផ្សេងទៀត-ដោយមិនផាត់ចោលលទ្ធភាពណាមួយ - ដើម្បីឃ្លាំមើលអនុសញ្ញានេះ ស្របតាមមុខងារដែលបានកំណត់ក្នុងមាត្រា២៨ ដល់មាត្រា៣៦ ។

## មាត្រា ២៨ :

១. នៅក្នុងក្របខ័ណ្ឌសមត្ថកិច្ចដែលបានផ្ដល់ឱ្យដោយអនុសញ្ញានេះ គណៈកម្មាធិការ ត្រូវសហការជាមួយគ្រប់អង្គការ ការិយាល័យ ទីភ្នាក់ងារឯកទេសដែលពាក់ព័ន្ធ និងមូលនីធិអង្គការសហប្រជាជាតិ ជាមួយស្ថាប័នសន្ធិសញ្ញា ដែលបង្កើតឡើងដោយលិខិតុបករណ៍អន្តរជាតិ ជាមួយនីតិវិធីពិសេសរបស់អង្គការសហប្រជាជាតិ និងជាមួយអង្គការ ឬស្ថាប័នអន្តររដ្ឋាភិបាល ក្នុងតំបន់ដែលពាក់ព័ន្ធ ក៏ដូចជា ជាមួយស្ថាប័ន ទីភ្នាក់ងារ ឬការិយាល័យរដ្ឋទាំងអស់ដែលពាក់ព័ន្ធ ដែលធ្វើការដើម្បីការពារជនគ្រប់រូប ប្រឆាំងនឹងការបាត់ខ្លួនដោយបង្ខំ ។

២.នៅពេលបំពេញអាណត្តិរបស់ខ្លួន គណៈកម្មាធិការ ត្រូវពិគ្រោះយោបល់ជាមួយស្ថាប័នសន្ធិសញ្ញាដទៃទៀត ដែលបានបង្កើតឡើងដោយលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិដែលពាក់ព័ន្ធ ជាពិសេស គណៈកម្មាធិការ

សិទ្ធិមនុស្ស ដែលបង្កើតឡើងដោយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក្នុងគោលបំណងធានា ភាពស៊ីសង្វាក់គ្នានៃការសង្កេត និងការផ្តល់អនុសាសន៍របស់ខ្លួន ។

## ***មាត្រា ២៩ :***

១. រដ្ឋភាគីនីមួយៗ ត្រូវបញ្ជូនទៅគណៈកម្មាធិការនេះ តាមរយៈអគ្គលេខាធិការអង្គការសហប្រជាជាតិ នូវរបាយការណ៍មួយ ស្តីពីការចាត់វិធានការរបស់ខ្លួន ដើម្បីអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្រោមអនុសញ្ញានេះ ក្នុងរយៈពេលពីរឆ្នាំ បន្ទាប់ពីការចូលជាធរមាននៃអនុសញ្ញានេះ សំរាប់រដ្ឋភាគីពាក់ព័ន្ធ ។

២. អគ្គលេខាធិការអង្គការអង្គការសហប្រជាជាតិ ត្រូវផ្ញើរបាយការណ៍នេះ ទៅរដ្ឋភាគីទាំងអស់ ។

៣. របាយការណ៍នីមួយៗ ត្រូវបានពិចារណាដោយគណៈកម្មាធិការនេះ ដែលត្រូវធ្វើការផ្តល់មតិ ការសង្កេត ឬអនុសាសន៍ តាមការសមស្រប ។ ការផ្តល់មតិ ការសង្កេត ឬអនុសាសន៍ ត្រូវបានបញ្ជូនទៅរដ្ឋភាគីពាក់ព័ន្ធ ដែលរដ្ឋភាគីនោះ ត្រូវឆ្លើយតបវិញតាមគំនិតផ្តួចផ្តើមរបស់ខ្លួន ឬតាមការស្នើសុំរបស់គណៈកម្មាធិការ ។

៤. គណៈកម្មាធិការ ក៏អាចស្នើសុំទៅរដ្ឋភាគីនានា ឱ្យផ្តល់ព័ត៌មានបន្ថែមស្តីពីការអនុវត្តន៍សន្ធិសញ្ញានេះ ។

***មាត្រា ៣០ ៖***

១. ការស្នើសុំឱ្យស្វែងរកជនបាត់ខ្លួន អាចត្រូវបានបញ្ជូនទៅគណៈកម្មាធិការនេះ ជាបញ្ហាបន្ទាន់ ដោយសាច់ញាតិជនបាត់ខ្លួន ឬតំណាងស្របច្បាប់ មេធាវីរបស់គេ ឬជនណាម្នាក់ ដែលទទួលបានការអនុញ្ញាតពីសាច់ញាតិ ជនបាត់ខ្លួន ក៏ដូចជា ដោយជនណាម្នាក់ផ្សេងទៀតដែលមានផលប្រយោជន៍ស្របច្បាប់ ។

២. ប្រសិនបើគណៈកម្មាធិការនេះយល់ថា ការស្នើឱ្យចាត់វិធានការបន្ទាន់ ត្រូវបានបញ្ជូនមកស្របតាមកថាខ័ណ្ឌ១ នៃមាត្រានេះ ៖

(ក) មិនបង្ហាញថា គ្មានមូលហេតុត្រឹមត្រូវ

(ខ) មិនមានការរំលោភលើសិទ្ធិនៃការដាក់ពាក្យសុំនេះ

(គ) បានបង្ហាញយ៉ាងត្រឹមត្រូវហើយដល់ស្ថាប័នមានសមត្ថកិច្ច នៃរដ្ឋភាគីពាក់ព័ន្ធ ដូចជាស្ថាប័នដែលបានអនុញ្ញាតឱ្យធ្វើការស៊ើបអង្កេត ដែលលទ្ធភាពបែបនេះអាចមាន ។

(ឃ) មិនមានវិសមិតភាពជាមួយបទបញ្ញត្តិនៃអនុសញ្ញានេះ ហើយ

(ង) បញ្ហាដដែលនេះ មិនត្រូវបានពិនិត្យ ក្រោមនីតិវិធីមួយផ្សេងទៀតនៃការស៊ើបអង្កេត ឬការដោះស្រាយជាអន្តរជាតិ ដែលមានចរិតលក្ខណៈដូចគ្នា ។

គណៈកម្មាធិការ ត្រូវស្នើទៅរដ្ឋភាគីពាក់ព័ន្ធ ឱ្យផ្តល់ឱ្យខ្លួន នូវព័ត៌មានស្តីពីស្ថានភាពជនដែលគេស្វែងរក នៅក្នុងអំឡុងពេលមួយ ដែលគណៈកម្មាធិការបានកំណត់ ។

៣. ចំពោះព័ត៌មានដែលបានផ្តល់ដោយរដ្ឋភាគីពាក់ព័ន្ធ ស្របតាម-កថាខ័ណ្ឌ២នៃមាត្រានេះ គណៈកម្មាធិការ អាចបញ្ជូនអនុសាសន៍ ទៅរដ្ឋភាគីនោះ រួមទាំងការស្នើឱ្យរដ្ឋភាគីនោះ ចាត់វាល់វិធានការចាំបាច់ រួមទាំងវិធានការបណ្តោះអាសន្ន ដើម្បីកំណត់កន្លែង និងការពារសាមីជន ស្របតាមអនុសញ្ញានេះ ហើយត្រូវជូនដំណឹងទៅគណៈកម្មាធិការ នៅក្នុងអំឡុងពេលមួយដែលបានកំណត់អំពីវិធានការដែលបានធ្វើ ដោយគិតគូរពីភាពបន្ទាន់ នៃស្ថានការណ៍។ គណៈកម្មាធិការនេះ ត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យសុំចាត់វិធានការបន្ទាន់ អំពីអនុសាសន៍របស់ខ្លួន និងអំពីព័ត៌មាន ដែលបានផ្តល់ឱ្យគណៈកម្មាធិការ ដោយរដ្ឋភាគី នៅពេលដែលខ្លួនបានទទួល។

៤. គណៈកម្មាធិការ ត្រូវបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីធ្វើការជាមួយរដ្ឋភាគីពាក់ព័ន្ធ រហូតដល់ដរាបណាដែលគេមិនទាន់បញ្ជាក់ច្បាស់អំពីជោគវាសនារបស់ជនដែលគេស្វែងរក។ គណៈកម្មាធិការ ត្រូវបន្តជូនដំណឹង ទៅអ្នកដាក់ពាក្យសុំ។

### *មាត្រា ៣១ :*

១. នៅពេលផ្តល់សច្ចាប័ន ឬនៅពេលណា ក្រោយពីការផ្តល់សច្ចាប័នលើអនុសញ្ញានេះក៏ដោយ រដ្ឋភាគី អាចប្រកាសថា ខ្លួនទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការ ក្នុងការទទួល និងពិចារណាលើពាក្យបណ្តឹង របស់បុគ្គល ឬក្នុងនាមបុគ្គល ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដែលអះអាងថា ជាជនរងគ្រោះដោយការរំលោភពីរដ្ឋភាគីនេះ លើបទបញ្ញត្តិនៃអនុសញ្ញានេះ។ គណៈកម្មាធិការនេះ មិនត្រូវទទួលយកពាក្យបណ្តឹងណាដែលពាក់ព័ន្ធនឹងរដ្ឋភាគីដែលមិនបានធ្វើការប្រកាសនេះឡើយ។

២. គណៈកម្មាធិការ ត្រូវចាត់ទុកបណ្តឹងនេះ ថាមិនអាចទទួលយកបាន ប្រសិនជា ៈ

(ក) បណ្តឹងអាណាមិក

(ខ) បណ្តឹងបង្កើតឱ្យមានការរំលោភសិទ្ធិនៃការដាក់ពាក្យបណ្តឹង ឬមិនស្របនឹងបទបញ្ញត្តិនៃអនុសញ្ញានេះ

(គ) បញ្ហាដដែលនេះ កំពុងពិនិត្យក្រោមនីតិវិធីមួយផ្សេងទៀតនៃការស៊ើបអង្កេត ឬការដោះស្រាយជាអន្តរជាតិដែលមានចរិតលក្ខណៈដូចគ្នា ឬប្រសិនបើ

(ឃ) មិនទាន់ប្រើអស់ដំណោះស្រាយដែលមាន ប្រសិទ្ធភាពក្នុងស្រុក។ មិនត្រូវយកវិធាននេះមកប្រើទេ ប្រសិនបើការប្រើដំណោះស្រាយ-នេះ ត្រូវបានអូសបន្លាយពេលយូរ ដោយមិនសមហេតុផល។

៣. ប្រសិនបើគណៈកម្មាធិការយល់ឃើញថា បណ្តឹងនេះបំពេញតាមតម្រូវការដូចមានចែងក្នុងកឋាខ័ណ្ឌ២ នៃមាត្រានេះ គណៈកម្មាធិការត្រូវបញ្ជូនពាក្យបណ្តឹងនេះ ទៅរដ្ឋភាគីពាក់ព័ន្ធ ដើម្បីស្នើឱ្យរដ្ឋភាគីនោះផ្តល់សេចក្តីសង្កេត និងការផ្តល់មតិ ក្នុងរយៈពេលមួយដែលគណៈកម្មាធិការនេះបានកំណត់។

៤. នៅគ្រប់ពេល បន្ទាប់ពីទទួលពាក្យបណ្តឹង និងនៅមុនឈានដល់ការសំរេចលើអង្គសេចក្តី គណៈកម្មាធិការ អាចបញ្ជូនទៅរដ្ឋភាគីពាក់ព័ន្ធដើម្បីធ្វើការពិចារណាជាបន្ទាន់លើការស្នើសុំឱ្យរដ្ឋភាគីចាត់វិធានការបណ្តោះ

អាសន្ន តាមការចាំបាច់ ដើម្បីបញ្ចៀសលទ្ធភាពនៃការមិនចេញសំណងការខូចខាតទៅជនរងគ្រោះដោយការរំលោភបំពាន។ ប្រសិនបើគណៈកម្មាធិការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ការនេះមិនចាត់ទុកថា ជាការសំរេចទទួលយក ឬសំរេចលើអង្គសេចក្តីនៃបណ្តឹងឡើយ ។

៥. គណៈកម្មាធិការ ត្រូវប្រជុំជាសំងាត់ នៅពេលពិនិត្យពាក្យបណ្តឹង ក្រោមមាត្រានេះ។ គណៈកម្មាធិការ ត្រូវជូនដំណឹងទៅម្ចាស់បណ្តឹងអំពីចំលើយដែលរដ្ឋភាគីពាក់ព័ន្ធបានផ្តល់ឱ្យ ។នៅពេលដែលគណៈកម្មាធិការសំរេចបញ្ចប់នីតិវិធី គណៈកម្មាធិការ ត្រូវបញ្ជូនការយល់ឃើញរបស់ខ្លួនទៅរដ្ឋភាគី និងទៅម្ចាស់បណ្តឹង ។

## ***មាត្រា ៣២ :***

រដ្ឋភាគីនៃអនុសញ្ញានេះ អាចប្រកាសគ្រប់ពេលវេលាថា ខ្លួនទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការ ដើម្បីទទួល និងពិចារណាបណ្តឹងដែលក្នុងនោះ រដ្ឋភាគីអះអាងថា រដ្ឋភាគីមួយទៀត មិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន ក្រោមអនុសញ្ញានេះទេ។ គណៈកម្មាធិការ មិនទទួលពាក្យបណ្តឹងទាំងឡាយណា ដែលពាក់ព័ន្ធនឹងរដ្ឋភាគី ដែលមិនបានធ្វើការប្រកាសនេះ ឬពាក្យបណ្តឹងពីរដ្ឋភាគីដែលមិនបានធ្វើការប្រកាសនេះឡើយ ។

## ***មាត្រា ៣៣ :***

១. ប្រសិនបើគណៈកម្មាធិការ ទទួលព័ត៌មានដែលអាចទុកចិត្តបានបញ្ជាក់ថា រដ្ឋភាគីមួយកំពុងរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញានេះ ក្រោយពីបានពិគ្រោះយោបល់ជាមួយរដ្ឋភាគីពាក់ព័ន្ធ ហើយគណៈកម្មាធិការ អាច

ស្នើឱ្យសមាជិករបស់ខ្លួនម្នាក់ ឬច្រើននាក់ ទៅធ្វើទស្សនកិច្ច ហើយរាយការណ៍មកគណៈកម្មាធិការវិញ ដោយមិនមានការពន្យាពេល ។

២. គណៈកម្មាធិការត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅរដ្ឋភាគីពាក់ព័ន្ធ អំពីចេតនារបស់ខ្លួន ដើម្បីរៀបចំធ្វើទស្សនកិច្ច ដោយបញ្ជាក់ប្រាប់អំពីសមាសភាពគណៈប្រតិភូនិងអំពីគោលបំណងនៃការធ្វើទស្សនកិច្ចនោះ។ រដ្ឋភាគីត្រូវឆ្លើយតបមកគណៈកម្មាធិការវិញក្នុងអំឡុងពេលមួយសមស្រប។

៣. នៅពេលមានការស្នើសុំពីរដ្ឋភាគី ដោយបញ្ជាក់ហេតុផលត្រឹមត្រូវ គណៈកម្មាធិការអាចសំរេចលើកពេល ឬលប់ចោលការធ្វើទស្សនកិច្ចរបស់ខ្លួន ។

៤. ប្រសិនបើរដ្ឋភាគីយល់ព្រមចំពោះការធ្វើទស្សនកិច្ចនេះ គណៈកម្មាធិការ និងរដ្ឋភាគីពាក់ព័ន្ធត្រូវធ្វើការរួមគ្នា ដើម្បីកំណត់របៀបនៃការធ្វើទស្សនកិច្ច ហើយរដ្ឋភាគីត្រូវផ្តល់ឱ្យគណៈកម្មាធិការ នូវគ្រប់មធ្យោបាយចាំបាច់ សំរាប់ឱ្យការបំពេញទស្សនកិច្ចនេះបានជោគជ័យ ។

៥. ក្រោយពីបានបំពេញទស្សនកិច្ចរួច គណៈកម្មាធិការត្រូវបញ្ជូនទៅរដ្ឋភាគីពាក់ព័ន្ធ នូវសេចក្តីសង្កេត និងអនុសាសន៍របស់ខ្លួន ។

## *មាត្រា ៣៤ :*

ប្រសិនបើគណៈកម្មាធិការ ទទួលព័ត៌មាន ដែលខ្លួនយល់ថា មានតម្រុយច្បាស់លាស់ ថាការបាត់ខ្លួនដោយបង្ខំ បាននឹងកំពុងកើតមានជាទូទៅ ឬជាប្រព័ន្ធនៅលើទឹកដីស្ថិតក្រោមយុត្តាធិការរបស់រដ្ឋភាគីមួយ បន្ទាប់ពី

ស្វែងរកព័ត៌មានពាក់ព័ន្ធពីរដ្ឋភាគីសាមីអំពីស្ថានការណ៍នោះហើយ គណៈកម្មាធិការ អាចលើកយកបញ្ហានេះជាបន្ទាន់ប្រាប់ដល់មហាសន្និបាតអង្គការសហប្រជាជាតិ តាមរយៈអគ្គលេខាអង្គការសហប្រជាជាតិ។

## *មាត្រា ៣៥ :*

១. គណៈកម្មាធិការ ត្រូវមានសមត្ថកិច្ចដាច់មុខ ចំពោះការបាត់ខ្លួនដោយបង្ខំ ដែលបានចាប់ផ្តើមអនុវត្ត បន្ទាប់ពីការចូលជាធរមាននៃអនុសញ្ញានេះ។

២. ប្រសិនបើរដ្ឋមួយក្លាយជាភាគីនៃអនុសញ្ញានេះ បន្ទាប់ពីការចូលជាធរមាននៃអនុសញ្ញានេះ កាតព្វកិច្ចរបស់រដ្ឋនោះ ចំពោះគណៈកម្មាធិការត្រូវទាក់ទងតែចំពោះការបាត់ខ្លួនដោយបង្ខំ ដែលបានចាប់ផ្តើម បន្ទាប់ពីការចូលជាធរមាននៃអនុសញ្ញានេះ សំរាប់រដ្ឋសាមីនោះ។

## *មាត្រា ៣៦ :*

១. គណៈកម្មាធិការ ត្រូវដាក់ជូនរបាយការណ៍ប្រចាំឆ្នាំ ស្តីពីសកម្មភាពរបស់ខ្លួនតាមអនុសញ្ញានេះ ទៅរដ្ឋភាគីនានា និងទៅមហាសន្និបាតអង្គការ សហប្រជាជាតិ។

២. មុននឹងសេចក្តីសង្កេតលើរដ្ឋភាគីមួយ ត្រូវបានបោះពុម្ពផ្សាយនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ រដ្ឋភាគីសាមីនោះ ត្រូវបានជូនដំណឹងជាមុនហើយត្រូវទុកពេលវេលាមួយសមស្របសំរាប់ធ្វើការឆ្លើយតបវិញ។ រដ្ឋភាគីនេះ អាចស្នើឱ្យបោះពុម្ពផ្សាយសេចក្តីផ្តល់មតិ ឬការសង្កេតនៅក្នុងរបាយការណ៍នេះបាន។

# ភាគ ៣

## មាត្រា ៣៧ :

គ្មានបញ្ញត្តិណាមួយក្នុងអនុសញ្ញានេះប៉ះពាល់ដល់បញ្ញត្តិទាំងឡាយណា ដែលនាំឱ្យមានការការពារជនគ្រប់រូប ពីការបាត់ខ្លួនដោយបង្ខំឡើយ ហើយបញ្ញត្តិទាំងនេះ អាចមានចែងក្នុង :

(ក) ច្បាប់របស់រដ្ឋភាគី

(ខ) ច្បាប់អន្តរជាតិដែលនៅមានជាធរមានសំរាប់រដ្ឋនោះ

## មាត្រា ៣៨ :

១. អនុសញ្ញានេះ ត្រូវបើកចំហឱ្យចុះហត្ថលេខា ដោយរដ្ឋសមាជិកទាំងអស់របស់អង្គការសហប្រជាជាតិ ។

២. អនុសញ្ញានេះ ជាកម្មវត្ថុនៃការផ្តល់សច្ចាប័ន ដោយរដ្ឋសមាជិកសហប្រជាជាតិទាំងអស់ ។ លិខិតុបករណ៍ផ្តល់សច្ចាប័ន ត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៣. អនុសញ្ញានេះ ត្រូវបើកចំហឱ្យចូលជាសមាជិក ដល់រដ្ឋសមាជិកទាំងអស់របស់សហប្រជាជាតិ ។ ការចូលជាសមាជិក នឹងមានប្រសិទ្ធភាពទៅបាន ដោយការតំកល់លិខិតុបករណ៍សុំចូលជាសមាជិក នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

## មាត្រា ៣៩ :

១. អនុសញ្ញានេះ ត្រូវចូលជាធរមាននៅថ្ងៃទីសាមសិប បន្ទាប់ពីកាលបរិច្ឆេទនៃការតំកល់លិខិតុបករណ៍ នៅនឹងអគ្គលេខាធិការអង្គការសហ

ប្រជាជាតិ នៃលិខិតុបករណ៍ផ្តល់សច្ចាប័ន ឬលិខិតុបករណ៍សុំចូលជាសមាជិកទីម្ភៃ។

២. ចំពោះរដ្ឋនីមួយៗដែលផ្តល់សច្ចាប័ន ឬសុំចូលជាសមាជិកនៃអនុសញ្ញានេះ បន្ទាប់ពីកាលបរិច្ឆេទនៃការតំកល់លិខិតុបករណ៍ផ្តល់សច្ចាប័ន ឬលិខិតុបករណ៍សុំចូលជាសមាជិកទី២០ អនុសញ្ញានេះនឹងចូលជាធរមាននៅថ្ងៃទី៣០ បន្ទាប់ពីកាលបរិច្ឆេទនៃការតំកល់លិខិតុបករណ៍ផ្តល់សច្ចាប័ន ឬលិខិតុបករណ៍សុំចូលជាសមាជិករបស់រដ្ឋនោះ។

### *មាត្រា ៤០ :*

អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវជូនដំណឹងទៅរដ្ឋសមាជិកទាំងអស់របស់ខ្លួន និងរដ្ឋទាំងអស់ដែលបានចុះហត្ថលេខា ឬចូលជាសមាជិកនៃអនុសញ្ញានេះ ដូចតទៅ :

(ក) ការចុះហត្ថលេខា ការផ្តល់សច្ចាប័ន និងការចូលជាសមាជិកតាមមាត្រា៣៨ ។

(ខ) កាលបរិច្ឆេទនៃការចូលជាធរមាននៃអនុសញ្ញានេះ តាមមាត្រា៣៩ ។

### *មាត្រា ៤១ :*

បទបញ្ញត្តិនៃកតិកាសញ្ញានេះ ត្រូវអនុវត្តលើគ្រប់ផ្នែកទាំងអស់នៃរដ្ឋសហព័ន្ធ ដោយគ្មានការកម្រិត ឬការលើកលែងណាមួយឡើយ។

## មាត្រា ៤២ :

១. ទំនាស់រវាងរដ្ឋភាគីពីរ ឬច្រើនជាងនេះដែលពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តន៍អនុសញ្ញានេះ ហើយដែលមិនអាចដោះស្រាយតាម-រយៈការចរចា ឬតាមនីតិវិធីដែលមានចែងច្បាស់លាស់ក្នុងអនុសញ្ញានេះបាន ត្រូវបញ្ជូនទៅដោះស្រាយតាមរយៈមជ្ឈតកម្ម តាមការស្នើសុំរបស់ភាគីទំនាស់ណាមួយ។ ប្រសិនជាក្នុងអំឡុងពេល៦ខែ ចាប់ពីកាលបរិច្ឆេទ នៃការស្នើសុំដោះស្រាយតាមរយៈមជ្ឈតកម្ម ភាគីទាំងអស់ មិនអាចព្រមព្រៀងគ្នាលើការរៀបចំមជ្ឈតកម្មទេ ត្រូវបញ្ជូនទៅតុលាការយុត្តិធម៌អន្តរជាតិ តាម-ការស្នើសុំរបស់ភាគីទំនាស់ណាមួយ ស្របតាមលក្ខន្តិកៈនៃតុលាការនេះ។

២. នៅពេលចុះហត្ថលេខា ឬផ្តល់សច្ចាប័ន ឬចូលជាសមាជិកនៃអនុសញ្ញានេះ រដ្ឋមួយ អាចប្រកាសថា ខ្លួនមិនចាត់ទុកថា ជាប់កាតព្វកិច្ចតាមកឋាខ័ណ្ឌ១ នៃមាត្រានេះទេ។ រដ្ឋភាគីដទៃទៀត ក៏មិនជាប់កាតព្វកិច្ច តាមកឋាខ័ណ្ឌ១ នៃមាត្រានេះដែរ ចំពោះរដ្ឋភាគីណាដែលបានធ្វើការប្រកាសបែបនេះ។

៣. រដ្ឋភាគីណាមួយដែលបានធ្វើការប្រកាស ស្របតាមបទបញ្ញត្តិកឋាខ័ណ្ឌ២នៃមាត្រានេះ អាចដកការប្រកាសរបស់ខ្លួនបានគ្រប់ពេល ដោយគ្រាន់តែជូនដំណឹងនេះ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។

### មាត្រា ៤៣ :

១. អនុសញ្ញានេះ មិនធ្វើឱ្យប៉ះពាល់ដល់បទបញ្ញត្តិនៃច្បាប់មនុស្សធម៌អន្តរជាតិ រួមទាំងកាតព្វកិច្ចរបស់រដ្ឋភាគីចំពោះអនុសញ្ញាទីក្រុងហ្សឺណែវទាំងបួន ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងពិធីសារបន្ថែមពីរនៃអនុសញ្ញាចុះថ្ងៃទី៨ខែមិថុនា ឆ្នាំ១៩៧៧ ឬប៉ះពាល់ដល់ឱកាសដែលមានសំរាប់រដ្ឋភាគីណាមួយ ដែលអនុញ្ញាតឱ្យគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ ទៅធ្វើទស្សនកិច្ច នៅកន្លែងឃុំឃាំងក្នុងស្ថានការណ៍ ដែលមិនស្ថិតក្រោមច្បាប់មនុស្សធម៌អន្តរជាតិ ។

### មាត្រា ៤៤ :

១. រដ្ឋភាគីណាមួយនៃអនុសញ្ញានេះ អាចស្នើធ្វើវិសោធនកម្ម និង-ដាក់សេចក្តីស្នើនោះជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនសេចក្តីស្នើវិសោធនកម្មនេះ ទៅរដ្ឋភាគីនៃអនុសញ្ញានេះ ដោយសុំឱ្យរដ្ឋភាគី បញ្ជាក់ថាតើ យល់ព្រមឱ្យមានសន្និសីទនៃរដ្ឋភាគីទាំងអស់ ដើម្បីពិនិត្យ និងបោះឆ្នោត លើសេចក្តីស្នើវិសោធនកម្មនេះឬទេ ។ ប្រសិនបើក្នុងអំឡុងពេលបួនខែ ចាប់ពីកាលបរិច្ឆេទនៃការបញ្ជូនសំណើនេះ មានសម្លេង ១ភាគ៣ យ៉ាងតិចនៃរដ្ឋភាគីទាំងអស់ប្រកាសយល់ព្រមឱ្យមានសន្និសីទនេះ អគ្គលេខាធិការអង្គការសហប្រជា-ជាតិ ត្រូវកោះប្រជុំសន្និសីទនេះ ក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ ។

២. គ្រប់វិសោធនកម្មដែលបានអនុម័តដោយមតិភាគច្រើន ពីរភាគបីនៃរដ្ឋភាគីវត្តមាន និងបោះឆ្នោតនៅឯសន្និសីទ ត្រូវបានអគ្គលេខាធិការអង្គការសហប្រជាជាតិ ដាក់ជូនរដ្ឋភាគីទាំងអស់ ដើម្បីសុំការយល់ព្រម ។

៣. វិសោធនកម្មដែលបានអនុម័តស្របតាមកថាខ័ណ្ឌ១ នៃមាត្រានេះ ត្រូវចូលជាធរមាន នៅពេលដែលចំនួនពីរភាគបីនៃរដ្ឋភាគីនៃអនុសញ្ញានេះ បានទទួលយល់ព្រមស្របតាមបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញរបស់រដ្ឋនីមួយៗ។

៤. នៅពេលដែលវិសោធនកម្មទាំងនោះ ចូលជាធរមានហើយ វិសោធនកម្មទាំងនោះ នឹងក្លាយជាកាតព្វកិច្ច សំរាប់រដ្ឋភាគីទាំងឡាយដែលបានទទួលយល់ព្រមយកវិសោធនកម្មទាំងនោះ ឯរដ្ឋភាគីផ្សេងទៀត-ដែលមិនបានទទួលយល់ព្រម ត្រូវស្ថិតនៅក្រោមបទបញ្ញត្តិនៃអនុសញ្ញានេះ និងវិសោធនកម្មមុនៗដែលខ្លួនបានទទួលយល់ព្រមហើយ ។

### *មាត្រា ៤៥ :*

១. អនុសញ្ញានេះដែលមានអត្ថបទជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ៉ុល មានតម្លៃយថាភូតស្មើគ្នា និងត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនច្បាប់ចម្លងនៃអនុសញ្ញានេះ ដោយមានបញ្ជាក់ពីការចម្លងតាមច្បាប់ដើម ជូនដល់រដ្ឋទាំងអស់ យោងតាមមាត្រា ៣៨ ។

# អនុសញ្ញាពាក់ព័ន្ធ
# ឋានៈនៃជនភៀសខ្លួន

# ១៦- អនុសញ្ញាពាក់ព័ន្ធឋានៈនៃជនភៀសខ្លួន

អនុសញ្ញាពាក់ព័ន្ធឋានៈនៃជនភៀសខ្លួនត្រូវបានអនុម័តថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥១
ដោយសន្និសីទនៃបុណ្ណទូតសហប្រជាជាតិស្តីពីឋានៈនៃជនភៀសខ្លួន និងនិរបេតិកជន កោះប្រជុំសន្និសីទ
ស្របតាមសេចក្តីសម្រេចចិត្តលេខ៤២៩(V) ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៥០
ចូលជាធរមានថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៥៤ យោងតាមមាត្រា៤៣
កម្ពុជាក្លាយជារដ្ឋភាគីនៃអនុសញ្ញានេះនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២

## បុព្វកថា

*ភាគីជាន់ខ្ពស់នៃអនុសញ្ញា*

*យល់ឃើញថា* ធម្មនុញ្ញអង្គការសហប្រជាជាតិ និងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សដែលត្រូវបានអនុម័តនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ ដោយមហាសន្និបាតអង្គការសហប្រជាជាតិ បានបញ្ជាក់លើគោលការណ៍ដែលថា មនុស្សត្រូវអាស្រ័យផលសិទ្ធិ និងសេរីភាពមូលដ្ឋាន ដោយគ្មានការប្រកាន់រើសអើង។

*យល់ឃើញថា* អង្គការសហប្រជាជាតិ នៅក្នុងឱកាសផ្សេងៗ បានបង្ហាញនូវកង្វល់យ៉ាងខ្លាំងរបស់ខ្លួនចំពោះជនភៀសខ្លួន និងបានខិតខំធានាឱ្យជនភៀសខ្លួននូវការប្រើប្រាស់សិទ្ធិ និងសេរីភាពមូលដ្ឋានទាំងនេះ យ៉ាងទូលំទូលាយបំផុត តាមដែលអាចធ្វើទៅបាន ។

*យល់ឃើញថា* វាជាការគួរតែកែប្រែឱ្យបានត្រឹមត្រូវ និងចងក្រងជាក្រមនូវកិច្ចព្រមព្រៀងជាអន្តរជាតិ ដែលមានពីមុនមកពាក់ព័ន្ធនឹងឋានៈនៃជនភៀសខ្លួន និងពង្រីកទំហំ និងការការពារដែលផ្តល់ដោយលិខិតុបករណ៍ទាំងនោះ តាមកិច្ចព្រមព្រៀងថ្មីមួយ ។

*យល់ឃើញថា* ការផ្តល់សិទ្ធិជ្រកកោន អាចដាក់បន្ទុកដ៏ធ្ងន់ធ្ងរពេក ទៅលើប្រទេសមួយចំនួន និង *យល់ឃើញថា* ដំណោះស្រាយជាទីពេញចិត្តចំពោះបញ្ហាដែលអង្គការសហប្រជាជាតិ បានទទួលស្គាល់ថាមានទំហំ និងលក្ខណៈអន្តរជាតិ នឹងមិនអាចសម្រេចបានទេ បើពុំមានសហប្រតិបត្តិការជាអន្តរជាតិ ។

*សម្តែង* បំណងប្រាថ្នាសូមឱ្យរដ្ឋទាំងអស់ដែលទទួលស្គាល់នូវលក្ខណៈសង្គម និងមនុស្សធម៌នៃបញ្ហាជនភៀសខ្លួន ធ្វើអ្វីៗគ្រប់យ៉ាងក្នុងវង្វង់អំណាចរបស់ខ្លួន ដើម្បីទប់ស្កាត់កុំឱ្យបញ្ហានេះ ក្លាយជាបុព្វហេតុនៃភាពតានតឹងរវាងរដ្ឋ និងរដ្ឋ ។

*កត់សំគាល់ឃើញថា* ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ត្រូវទទួលបន្ទុកកិច្ចការត្រួតពិនិត្យអនុសញ្ញាអន្តរជាតិនានា ដែលផ្តល់នូវការការពារដល់ជនភៀសខ្លួន និង *ទទួលស្គាល់ថា* ការសម្របសម្រួលស័ក្តិសិទ្ធិនូវវិធានការ ដែលបានដាក់ចេញ ដើម្បីដោះស្រាយបញ្ហានេះ នឹងពឹងផ្អែកលើសហប្រតិបត្តិការរបស់រដ្ឋនានា ជាមួយឧត្តមស្នងការ ។

*បានព្រមព្រៀងគ្នាដូចតទៅ ៖*

# ជំពូក ១: បទបញ្ញត្តិទូទៅ

## មាត្រា ១: និយមន័យនៃពាក្យ "ជនភៀសខ្លួន"

ក. សម្រាប់គោលបំណងនៃអនុសញ្ញានេះ ពាក្យ "ជនភៀសខ្លួន" ត្រូវសំដៅដល់ជនទាំងឡាយណាដែល ៖

(១) ត្រូវបានចាត់ទុកជាជនភៀសខ្លួនរួចហើយ ស្របតាមកិច្ចព្រមព្រៀងមូលមាត់ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩២៦ និងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩២៨ ឬស្របតាមអនុសញ្ញាចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ ១៩៣៣ និងថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៣៨ ពិធីសារចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៣៩ ឬលក្ខន្តិកៈរបស់អង្គការអន្តរជាតិទទួលបន្ទុកជនភៀសខ្លួន ។

សេចក្តីសម្រេចស្តីពីភាពពុំមានសិទ្ធិទទួលបានឋានៈជាជនភៀសខ្លួន ដែលធ្វើឡើងដោយអង្គការអន្តរជាតិទទួលបន្ទុកជនភៀសខ្លួន នៅក្នុងអំឡុងពេលនៃអាណត្តិរបស់អង្គការនេះ មិនរារាំងដល់ឋានៈនៃជនភៀសខ្លួនរបស់បុគ្គល ដែលបំពេញតាមលក្ខខណ្ឌ ក្នុងកថាខណ្ឌ២ នៃផ្នែកនេះឡើយ ។

(២) ដោយសារព្រឹត្តិការណ៍ ដែលបានកើតឡើងមុនថ្ងៃទី១ ខែមករា ឆ្នាំ១៩៥១ និងអាស្រ័យដោយមានការភ័យខ្លាចមានមូលដ្ឋានច្បាស់លាស់ ចំពោះការធ្វើទុក្ខបុកម្នេញ ដោយហេតុផលពូជសាសន៍ សាសនា សញ្ជាតិ សមាជិកភាពនៃក្រុមសង្គមណាមួយ ឬដោយសារមតិនយោបាយនៅក្រៅប្រទេសដែលខ្លួនមានសញ្ជាតិ និងមិនអាច ឬដោយសារការភ័យខ្លាចនេះ មិនចង់ប្រើប្រាស់ការការពាររបស់ប្រទេសនោះ ឬជាជនដែលមិនមានសញ្ជាតិ និងកំពុងរស់នៅក្រៅប្រទេសដែលជាអតីតនិវេសនដ្ឋានប្រក្រតីរបស់ខ្លួន ដោយសារព្រឹត្តិការណ៍នេះ និងដែលមិនអាច ឬដោយការភ័យខ្លាចបែបនោះ មិនចង់វិលត្រឡប់ទៅកាន់ប្រទេសដើមរបស់ខ្លួនវិញ ។

ក្នុងករណីមនុស្សម្នាក់ មានសញ្ជាតិលើសពីមួយ នោះពាក្យថា "ប្រទេសដែលខ្លួនមានសញ្ជាតិ" ត្រូវនិយាយសំដៅដល់ប្រទេសនីមួយៗ ដែលជននោះមានសញ្ជាតិ ។ នឹងមិនត្រូវចាត់ទុកថាពុំមានការការពារពីប្រទេសសញ្ជាតិរបស់ខ្លួនឡើយ មនុស្សណាដែលមិនបានប្រើប្រាស់នូវការការពាររបស់ប្រទេសណាមួយ ក្នុងចំណោមប្រទេសដែលខ្លួនមានសញ្ជាតិទេនោះ ដោយពុំមានមូលហេតុបានការណាមួយដែលផ្អែកលើមូលដ្ឋាននៃការភ័យខ្លាចសមហេតុសមផល ។

ខ. (១) សម្រាប់គោលបំណងនៃអនុសញ្ញានេះ ពាក្យថា "ព្រឹត្តិការណ៍ដែលកើតឡើងមុនថ្ងៃទី១ ខែមករា ឆ្នាំ១៩៥១" ក្នុងមាត្រា១ ផ្នែក-ក និយាយសំដៅដល់ ឬមួយ (ក) "ព្រឹត្តិការណ៍ដែលកើតឡើងនៅអឺរ៉ុបមុនថ្ងៃទី១-មករា-១៩៥១" ឬមួយ (ខ) "ព្រឹត្តិការណ៍ដែលកើតឡើងនៅអឺរ៉ុប ឬនៅកន្លែងឯទៀត

មុនថ្ងៃទី១-មករា-១៩៥១” ហើយរដ្ឋភាគីនីមួយៗនៃអនុសញ្ញា ត្រូវធ្វើសេចក្តីប្រកាសមួយ នៅពេលចុះហត្ថលេខា ឬឱ្យសច្ចាប័ន ឬចូលជាសមាជិក ដោយកំណត់ឱ្យបានច្បាស់លាស់ ថាតើអត្ថន័យណាមួយដែលខ្លួនត្រូវយកមកអនុវត្ត សម្រាប់គោលបំណងនៃកាតព្វកិច្ចរបស់ខ្លួន ក្រោមអនុសញ្ញានេះ ។

(២) រដ្ឋភាគីណាមួយដែលបានអនុម័តយកនូវជម្រើស (ក) អាចពង្រីកកាតព្វកិច្ចរបស់ខ្លួន នៅពេលណាក៏បាន ដោយការអនុម័តនូវជម្រើស (ខ) ដោយការជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

គ. អនុសញ្ញានេះ ត្រូវមិនអនុវត្តចំពោះជនដែលស្ថិតក្រោមបទបញ្ញត្តិនៃផ្នែក (ក)ទេ បើ :

(១) ជននោះ ស្ម័គ្រចិត្តប្រើប្រាស់ឡើងវិញនូវការការពារនៃប្រទេសដែលខ្លួនមានសញ្ជាតិ ឬ

(២) ជននោះ ស្ម័គ្រចិត្តទទួលយកសញ្ជាតិដែលបានបាត់បង់នោះមកវិញ ឬ

(៣) ជននោះបានទទួលយកសញ្ជាតិមួយថ្មី និងមានការការពារពីប្រទេសនៃសញ្ជាតិថ្មីរបស់ខ្លួនឬ

(៤) ជននោះ បានស្ម័គ្រចិត្តកសាងជីវិតជាថ្មីនៅក្នុងប្រទេសដែលខ្លួនបានចាកចេញ ឬដែលខ្លួនទៅរស់នៅក្រៅ ដោយសារការភ័យខ្លាចការធ្វើទុក្ខបុកម្នេញ ឬ

(៥) ជននោះ មិនអាចបន្តបដិសេធតទៅទៀតបាន នូវការប្រើប្រាស់ការការពារពីប្រទេសនៃសញ្ជាតិរបស់ខ្លួន ដោយសារកាលៈទេសៈនៃការទទួលស្គាល់ឋានៈជាជនភៀសខ្លួនផុតរលត់ ។

ប៉ុន្តែកថាខណ្ឌនេះ មិនត្រូវយកទៅអនុវត្តលើជនភៀសខ្លួនដែលស្ថិតក្នុងផ្នែក-ក (១) នៃមាត្រានេះ ហើយដែលអាចបង្ហាញអំពីមូលហេតុពិតត្រូវទទួលយក ដែលកើតចេញពីការធ្វើទុកបុកម្នេញ កាលពីពេលមុនៗ សម្រាប់បដិសេធមិនប្រើប្រាស់នូវការការពារពីប្រទេសនៃសញ្ជាតិ ។

(៦) ដោយជាជនឥតមានសញ្ជាតិ ជននោះ អាចវិលត្រឡប់ទៅកាន់ប្រទេសជានិវេសនដ្ឋានដើមរបស់ខ្លួនវិញបាន ដោយសារកាលៈទេសៈនៃការទទួលស្គាល់ឋានៈជាជនភៀសខ្លួនផុតរលត់ ។

ប៉ុន្តែកថាខណ្ឌនេះ មិនត្រូវយកទៅអនុវត្តលើជនភៀសខ្លួនដែលស្ថិតក្នុងផ្នែក-ក (១)នៃមាត្រានេះ ហើយដែលអាចបង្ហាញអំពីមូលហេតុពិតត្រូវទទួលយក ដែលកើតចេញពីការធ្វើទុក្ខបុកម្នេញកាលពីពេលមុនៗ ដើម្បីបដិសេធការវិលត្រឡប់ទៅកាន់ប្រទេសជានិវេសនដ្ឋានដើមរបស់ខ្លួនវិញ ។

ឃ. អនុសញ្ញានេះ មិនអនុវត្តចំពោះជនទាំងឡាយណា ដែលបច្ចុប្បន្នកំពុងទទួលការការពារ ឬការឧបត្ថម្ភពីអង្គការ ឬទីភ្នាក់ងារនានារបស់អង្គការសហប្រជាជាតិ ក្រៅពីស្នងការជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនឡើយ ។

បើការការពារ ឬការឧបត្ថម្ភបែបនោះ ផុតរលត់ដោយប្រការណាមួយ ដោយពុំមានការដោះស្រាយចប់សព្វគ្រប់ ចំពោះស្ថានភាពរបស់ជនទាំងនោះ ស្របតាមសេចក្តីសំរេចចិត្ត ដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិទេ ជនទាំងនេះ ដោយផ្អែកតាមព្រឹត្តិការណ៍បែបហ្នឹង មានសិទ្ធិទទួលបាននូវផលប្រយោជន៍នៃអនុសញ្ញានេះ ។

ង. អនុសញ្ញានេះ មិនអនុវត្តចំពោះជនដែលត្រូវបានទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដែលជននោះបានតាំងនិវេសនដ្ឋាន ថាបានទទួលសិទ្ធិ និងមានកាតព្វកិច្ចដែលជាប់ជាមួយការមានសញ្ជាតិនៃប្រទេសនោះហើយ ។

ច. បទបញ្ញត្តិនៃអនុសញ្ញានេះ មិនអនុវត្តចំពោះជនណាដែលគេមានមូលហេតុធ្ងន់ធ្ងរ សម្រាប់ចាត់ទុកថា :

(១) ជននោះ បានប្រព្រឹត្តបទឧក្រិដ្ឋប្រឆាំងនឹងសន្តិភាព បទឧក្រិដ្ឋសង្គ្រាម ឬបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ដូចដែលមាននិយមន័យក្នុងលិខិតុបករណ៍អន្តរជាតិដែលតាក់តែងឡើងសម្រាប់ចែងឱ្យមាននូវបទបញ្ញត្តិអំពីបទឧក្រិដ្ឋបែបនេះ ។

(២) ជននោះ បានប្រព្រឹត្តបទឧក្រិដ្ឋមិនមែននយោបាយដ៏ធ្ងន់ធ្ងរ នៅក្រៅប្រទេសកំពុងជ្រកកោនមុនពេលទទួលបានការអនុញ្ញាតឱ្យចូលប្រទេសនោះ ក្នុងឋានៈជាជនភៀសខ្លួន ។

(៣) ជននោះ បានជាប់ពិរុទ្ធក្នុងបទប្រព្រឹត្តិអំពើផ្ទុយពីគោលដៅ និងគោលការណ៍របស់អង្គការសហប្រជាជាតិ ។

## មាត្រា ២: ភារកព្វកិច្ចទូទៅ

ជនភៀសខ្លួនម្នាក់ៗ មានករណីយកិច្ចចំពោះប្រទេសដែលខ្លួនកំពុងស្នាក់អាស្រ័យ ដែលតម្រូវជាពិសេសឱ្យជនភៀសខ្លួនគោរពតាមច្បាប់ និងបទបញ្ញាផ្សេងៗរបស់ប្រទេសនោះ ព្រមទាំងវិធានការនានាដែលបានដាក់ចេញសម្រាប់ការថែរក្សាសណ្តាប់ធ្នាប់សាធារណៈ ។

## មាត្រា ៣: ការមិនប្រកាន់រើសអើង

រដ្ឋភាគីនៃអនុសញ្ញា ត្រូវអនុវត្តតាមបទបញ្ញត្តិនៃអនុសញ្ញានេះ ចំពោះជនភៀសខ្លួនទាំងអស់ដោយគ្មានការប្រកាន់រើសអើង មានជាអាទិ៍ ពូជសាសន៍ សាសនា ឬប្រទេសដើមកំណើតឡើយ ។

## មាត្រា ៤: សាសនា

រដ្ឋភាគីនៃអនុសញ្ញានេះ ត្រូវយកចិត្តទុកដាក់ចំពោះជនភៀសខ្លួន ដែលស្ថិតនៅក្នុងទឹកដីរបស់ខ្លួនយ៉ាងហោចណាស់ ក៏អនុគ្រោះដល់ពួកគេ ឱ្យបានប្រហែលគ្នានឹងការយកចិត្តទុកដាក់ដែលខ្លួនបានផ្តល់ដល់ជនជាតិរបស់ខ្លួន ក្នុងវិស័យសេរីភាព ក្នុងការប្រតិបត្តិសាសនា និងសេរីភាពក្នុងការអប់រំខាងសាសនាដល់កូនចៅរបស់ពួកគេ ។

## មាត្រា ៥: សិទ្ធិដែលត្រូវផ្តល់ក្រៅពីអនុសញ្ញានេះ

គ្មានបទបញ្ញត្តិណាមួយក្នុងអនុសញ្ញានេះ ត្រូវបានចាត់ទុកជាការធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍ ដែលរដ្ឋភាគីនៃអនុសញ្ញានេះ ផ្តល់ឱ្យដល់ជនភៀសខ្លួន ក្រៅពីអនុសញ្ញានេះឡើយ ។

## មាត្រា ៦: ពាក្យថា "ក្នុងកាលៈទេសៈដូចគ្នា"

សម្រាប់គោលបំណងនៃអនុសញ្ញានេះ ពាក្យថា "ក្នុងកាលៈទេសៈដូចគ្នា" មានន័យថា គ្រប់តម្រូវការ (រួមទាំងតម្រូវការពាក់ព័ន្ធរយៈពេល និងលក្ខខណ្ឌនៃការស្នាក់អាស្រ័យបណ្តោះអាសន្ន ឬការតាំងនិវេសនដ្ឋាន) ដែលបុគ្គលម្នាក់ៗត្រូវបំពេញ ដើម្បីបានមកនូវសិទ្ធិដែលកំពុងនិយាយនេះ បើបុគ្គលនោះ មិនមែនជាជនភៀសខ្លួននោះវិញ ។ ត្រូវតែបំពេញដោយបុគ្គលនោះ លើកលែងតែតម្រូវការទាំងឡាយដែលជនភៀសខ្លួនមិនអាចបំពេញទៅបាន ដោយសារលក្ខណៈជាជនភៀសខ្លួន ។

## មាត្រា ៧: ការរួចខ្លួនពីបដិការ

១. លើកលែងកន្លែងដែលអនុសញ្ញានេះ មានបទបញ្ញត្តិអនុគ្រោះដល់ជនភៀសខ្លួនច្រើនជាងនេះចេញ រដ្ឋភាគីនៃអនុសញ្ញា ត្រូវផ្តល់ឱ្យជនភៀសខ្លួននូវការគិតគូរ ដូចដែលខ្លួនបានផ្តល់ឱ្យដល់ជនបរទេសជាទូទៅដែរ ។

២. បន្ទាប់ពីបានស្នាក់នៅអស់រយៈពេលបីឆ្នាំ ជនភៀសខ្លួនទាំងអស់ ត្រូវទទួលបាននូវការរួចខ្លួនពីបដិការខាងផ្នែកច្បាប់ ក្នុងទឹកដីនៃរដ្ឋភាគីនៃអនុសញ្ញានេះ ។

៣. រដ្ឋភាគីនីមួយៗនៃអនុសញ្ញា ត្រូវបន្តផ្តល់ឱ្យដល់ជនភៀសខ្លួន នូវសិទ្ធិ និងផលប្រយោជន៍ដែលពួកគេមានសិទ្ធិទទួលរួចស្រេចមកហើយ ដោយមិនមានបដិការនៅថ្ងៃដែលអនុសញ្ញានេះ ចូលជាធរមានសម្រាប់រដ្ឋនោះ ។

៤. រដ្ឋភាគនីមួយៗនៃអនុសញ្ញា ត្រូវពិចារណាដោយអនុគ្រោះដល់ជនភៀសខ្លួន ចំពោះលទ្ធភាពនៃការផ្តល់ឱ្យដល់ពួកគេ ដោយមិនមានបដិការនូវសិទ្ធិ និងផលប្រយោជន៍ ក្រៅពីសិទ្ធិនិង ផលប្រយោជន៍ដែលពួកគេមានសិទ្ធិទទួល ដូចមានចែងក្នុងកថាខណ្ឌ២ និង៣ និងចំពោះលទ្ធភាពក្នុងការពន្យារពេលឱ្យរួចខ្លួនពីបដិការដល់ជនភៀសខ្លួន ដែលមិនបានបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងកថាខណ្ឌ២ និង៣ ។

៥. បទបញ្ញត្តិក្នុងកថាខណ្ឌ២ និង៣ អនុវត្តបានទាំងចំពោះសិទ្ធិ និងផលប្រយោជន៍ ដូចមានចែងក្នុងមាត្រា១៣ មាត្រា១៨ មាត្រា១៩ មាត្រា២១ និងមាត្រា២២ នៃអនុសញ្ញានេះ ទាំងចំពោះសិទ្ធិ និងផលប្រយោជន៍ ដែលមិនមានចែងក្នុងអនុសញ្ញានេះ ។

## មាត្រា ៨: ការរួចខ្លួនពីវិធានការខុសប្រក្រតី

ចំពោះវិធានការខុសប្រក្រតី ដែលអាចដាក់ចេញទៅលើបុគ្គល ទ្រព្យសម្បត្តិ ឬផលប្រយោជន៍របស់ជនជាតិនៃរដ្ឋបរទេសណាមួយ រដ្ឋភាគីនៃអនុសញ្ញានេះមិនត្រូវអនុវត្តវិធានការបែបនោះទៅលើជនភៀសខ្លួនដែលជាផ្លូវការជាជនជាតិរបស់រដ្ឋបរទេសនោះ និងព្រោះតែមានសញ្ជាតិរបស់រដ្ឋបរទេសនោះឡើយ។ រដ្ឋភាគីនៃអនុសញ្ញានេះ ដែលនៅក្រោមច្បាប់របស់ខ្លួន ត្រូវបានរារាំងមិនឱ្យអនុវត្តគោលការណ៍ទូទៅដូចចែងក្នុងមាត្រានេះ ត្រូវផ្តល់ឱ្យមានការរួចខ្លួនតាមករណីសមស្របជាប្រយោជន៍ដល់ជនភៀសខ្លួនទាំងនោះ។

## មាត្រា ៩: វិធានការបណ្តោះអាសន្ន

គ្មានបទបញ្ញត្តិណាមួយនៃអនុសញ្ញានេះ រារាំងរដ្ឋភាគីណាមួយនៃអនុសញ្ញានេះ ក្នុងពេលមានសង្គ្រាម ឬក្នុងស្ថានភាពធ្ងន់ធ្ងរ និងខុសប្រក្រតីផ្សេងទៀត មិនឱ្យចាត់វិធានការបណ្តោះអាសន្នចំពោះជនណាម្នាក់ ដែលរដ្ឋនោះចាត់ទុកថាចាំបាច់ចំពោះសន្តិសុខជាតិ ទម្រាំរដ្ឋភាគីនៃអនុសញ្ញា ធ្វើសេចក្តីសម្រេចថា ជននោះពិតជាជនភៀសខ្លួន និងថាការបន្តអនុវត្តវិធានការនោះ គឺចាំបាច់ចំពោះជននោះ ដើម្បីផលប្រយោជន៍សន្តិសុខជាតិ ។

## មាត្រា ១០: ការបន្តការស្នាក់អាស្រ័យ

១. បើជនភៀសខ្លួន ត្រូវបានឱ្យផ្លាស់ទីកន្លែងដោយបង្ខំ ក្នុងអំឡុងសង្គ្រាមលោកលើកទីពីរ និងត្រូវបានឱ្យរើទៅកាន់ទឹកដីនៃរដ្ឋភាគី នៃអនុសញ្ញានេះ ហើយរស់នៅទីនោះ រយៈពេលនៃការស្នាក់នៅបណ្តោះអាសន្នដោយបង្ខំនោះ ត្រូវចាត់ទុកថាជាការស្នាក់អាស្រ័យនៅត្រឹមត្រូវតាមច្បាប់ នៅក្នុងទឹកដីនៃប្រទេសនោះ ។

២. បើជនភៀសខ្លួន ត្រូវបានផ្លាស់ប្តូរទីកន្លែងដោយបង្ខំ ក្នុងអំឡុងសង្គ្រាមលោកលើកទីពីរ ចេញពីទឹកដីរបស់រដ្ឋភាគីនៃអនុសញ្ញានេះ ហើយបានវិលត្រឡប់ទៅកាន់រដ្ឋនោះវិញ នៅមុនថ្ងៃដែលអនុសញ្ញានេះចូលធរមាន ក្នុងបំណងតាំងទីលំនៅចាស់ឡើងវិញ នោះរយៈពេលនៃការតាំងទីលំនៅមុន និងក្រោយការផ្លាស់ទីកន្លែងដោយបង្ខំនោះ ត្រូវចាត់ទុកថា ជាការតាំងទីលំនៅមិនដាច់រយៈពេល សម្រាប់គោលបំណងទាំងឡាយដែលតម្រូវឱ្យមានការស្នាក់នៅដោយមិនដាច់រយៈពេល ។

## មាត្រា ១១: កម្មករនាវាសមុទ្រជាជនភៀសខ្លួន

ក្នុងករណីជនភៀសខ្លួន បំរើការជាសមាជិកនាវិកជាប្រចាំនៅលើនាវាមួយដែលមានបង្គួតទង់ជាតិរបស់រដ្ឋភាគីនៃអនុសញ្ញានេះ រដ្ឋនោះត្រូវផ្តល់ការគិតគូរដោយករុណាធម៌ ឱ្យពួកគេស្នាក់អាស្រ័យលើទឹកដីរបស់ខ្លួន និងចេញលិខិតធ្វើដំណើរឱ្យពួកគេ ឬអនុញ្ញាតឱ្យគេបានចូលទៅក្នុងទឹកដីរបស់ខ្លួនជាបណ្តោះអាសន្ន ជាពិសេស ដើម្បីជួយសម្រួលដល់ការស្នាក់អាស្រ័យរបស់គេ ក្នុងប្រទេសមួយផ្សេងទៀត ។

## ជំពូក ២: ឋានៈតាមផ្លូវច្បាប់

### មាត្រា ១២: ឋានៈផ្ទាល់ខ្លួន

១. ឋានៈផ្ទាល់ខ្លួនរបស់ជនភៀសខ្លួន ត្រូវគ្រប់គ្រងដោយច្បាប់របស់ប្រទេសនៃលំនៅដ្ឋានរបស់ខ្លួន ឬបើជនភៀសខ្លួនពុំមានលំនៅដ្ឋានទេនោះ ជនភៀសខ្លួន ត្រូវស្ថិតនៅក្រោមច្បាប់គ្រប់គ្រងរបស់ប្រទេសដែលខ្លួនស្នាក់អាស្រ័យ ។

២. សិទ្ធិដែលជនភៀសខ្លួនបានទទួលពីពេលមុន ហើយអាស្រ័យនឹងឋានៈផ្ទាល់ខ្លួន ពិសេសជាងនេះទៀត គឺសិទ្ធិពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ ត្រូវបានគោរពដោយរដ្ឋភាគីនៃអនុសញ្ញានេះ អាស្រ័យតាមការគោរព បើចាំបាច់ នូវទម្រង់បែបបទដែលតម្រូវដោយច្បាប់របស់រដ្ឋនោះ ក្នុងលក្ខខណ្ឌដែលសិទ្ធិកំពុងនិយាយនេះ គឺជាសិទ្ធិដែលនឹងត្រូវបានទទួលស្គាល់ដោយច្បាប់របស់រដ្ឋនោះ បើឧបមាថា គេមិនទាន់បានក្លាយជាជនភៀសខ្លួន ។

### មាត្រា ១៣: ចលនទ្រព្យ និងអចលនទ្រព្យ

រដ្ឋភាគីនៃអនុសញ្ញានេះ ត្រូវផ្តល់ការយកចិត្តទុកដាក់ដល់ជនភៀសខ្លួនម្នាក់ៗ ដោយអនុគ្រោះតាមដែលអាចធ្វើទៅបាន ហើយទោះជាយ៉ាងណាក៏ដោយ ក៏មិនត្រូវយកចិត្តទុកដាក់តិចជាងការយកចិត្តទុកដាក់ ដែលបានផ្តល់ដល់ជនបរទេសជាទូទៅ ដែលស្ថិតនៅក្នុងស្ថានភាពដូចគ្នានោះឡើយ ចំពោះសិទ្ធិកាន់កាប់កម្មសិទ្ធិចលន និងអចលនទ្រព្យ និងសិទ្ធិផ្សេងៗទៀត ដែលជាប់ទាក់ទងនឹងសិទ្ធិនោះ ព្រមទាំងសិទ្ធិក្នុងការធ្វើកិច្ចសន្យាជួល និងកិច្ចសន្យាផ្សេងៗទៀតពាក់ព័ន្ធនឹងចលន និងអចលនទ្រព្យ ។

### មាត្រា ១៤: សិទ្ធិខាងវិចិត្រកម្ម និងទ្រព្យសម្បត្តិឧស្សាហកម្ម

ចំពោះទ្រព្យសម្បត្តិឧស្សាហកម្ម ដូចជាការច្នៃប្រឌិត ប្លង់រចនា ឬម៉ូតគំរូ សញ្ញា និងយីហោពាណិជ្ជកម្មជាដើម និងសិទ្ធិខាងស្នាដៃអក្សរសាស្ត្រ សិល្បៈ និងវិទ្យាសាស្ត្រ ជនភៀសខ្លួនម្នាក់ៗដែលមាននិវេសនដ្ឋានប្រក្រតីនៅក្នុងប្រទេសនោះ ត្រូវតែទទួលបាននូវការការពារដូចគ្នានឹងជនជាតិប្រទេសនោះ ។ នៅក្នុងទឹកដីរដ្ឋភាគីផ្សេងទៀតនៃអនុសញ្ញានេះ ជនភៀសខ្លួន ត្រូវទទួលបាននូវការការពារដូចគ្នានឹងជនជាតិរបស់ប្រទេស ដែលជនភៀសខ្លួនមាននិវេសនដ្ឋានប្រក្រតីដែរ ។

### មាត្រា ១៥: សិទ្ធិខាងសមាគម

ចំពោះសមាគមមិនមែននយោបាយនិងសមាគមមិនរកផលកម្រៃ និងសហជីព រដ្ឋភាគីនៃអនុសញ្ញានេះ ត្រូវផ្តល់ឱ្យដល់ជនភៀសខ្លួនដែលស្នាក់អាស្រ័យត្រឹមត្រូវតាមច្បាប់ក្នុងទឹកដីរបស់ខ្លួន នូវការគិតគូរដល់ពួកគេយ៉ាងអនុគ្រោះបំផុត ដូចដែលបានផ្តល់ដល់ជនជាតិនៃរដ្ឋបរទេស ក្នុងស្ថានភាពដូចគ្នានោះដែរ ។

### មាត្រា ១៦: សិទ្ធិចូលទៅកាន់តុលាការ

១. ជនភៀសខ្លួន ត្រូវមានសិទ្ធិប្រើប្រាស់តុលាការក្នុងទឹកដីរបស់រដ្ឋភាគីទាំងអស់នៃអនុសញ្ញានេះដោយសេរី ។

២. នៅក្នុងរដ្ឋភាគីនៃអនុសញ្ញានេះ ដែលជនភៀសខ្លួនតាំងនិវេសនដ្ឋានប្រក្រតី ជនភៀសខ្លួនត្រូវទទួលបាននូវការយកចិត្តទុកដាក់ដូចគ្នានឹងជនជាតិរបស់រដ្ឋនោះដែរ នៅក្នុងរឿងទាក់ទិនទៅនឹងសិទ្ធិប្រើប្រាស់តុលាការ រួមមានសិទ្ធិទទួលជំនួយខាងផ្លូវច្បាប់ និងសិទ្ធិរួចខ្លួនពីការបង់ប្រាក់ធានាក្តីនៅចំពោះមុខតុលាការផង ។

៣. ក្នុងបញ្ហាដូចបានចែងក្នុងកថាខណ្ឌ២ នៅក្នុងបណ្តាប្រទេសផ្សេងក្រៅពីប្រទេសដែលខ្លួនមាននិវេសនដ្ឋានប្រក្រតី ជនភៀសខ្លួនត្រូវមានសិទ្ធិទទួលបាននូវការគិតគូរ ដូចដែលផ្តល់ឱ្យដល់ជនជាតិប្រទេសដែលខ្លួនមាននិវេសនដ្ឋានប្រក្រតីនោះ ។

## ជំពូក ៣: ការផ្តល់ការងារដោយមានផលកម្រៃ

### មាត្រា ១៧: ការងារមានប្រាក់ឈ្នួល

១. រដ្ឋភាគីនៃអនុសញ្ញានេះ ត្រូវផ្តល់ដល់ជនភៀសខ្លួនដែលបានស្នាក់អាស្រ័យត្រឹមត្រូវតាមច្បាប់នៅលើទឹកដីរបស់ខ្លួន នូវការយកចិត្តទុកដាក់ដល់ពួកគេ ដោយអនុគ្រោះបំផុត ដូចដែលផ្តល់ឱ្យជនជាតិទាំងឡាយនៃរដ្ឋបរទេស ដែលស្ថិតក្នុងស្ថានភាពដូចគ្នានេះ ចំពោះសិទ្ធិចូលធ្វើការរកប្រាក់ឈ្នួល ។

២. តែយ៉ាងណាក៏ដោយ វិធានការរឹតត្បិតដែលដាក់បង្ខំទៅលើជនបរទេសឬការជួលជនបរទេសដើម្បីការពារទីផ្សារពលកម្មរបស់ជាតិ រដ្ឋភាគីនៃអនុសញ្ញានេះមិនត្រូវយកទៅអនុវត្តលើជនភៀសខ្លួនដែលត្រូវបានអនុញ្ញាតឱ្យរួចផុតពីវិធានការទាំងនោះរួចហើយនោះឡើយ ចាប់ពីកាលបរិច្ឆេទដែលអនុសញ្ញានេះចូលជាធរមានសម្រាប់រដ្ឋភាគីពាក់ព័ន្ធឬសម្រាប់ជនភៀសខ្លួនដែលបំពេញលក្ខខណ្ឌណាមួយខាងក្រោមនេះ

(ក) ជាអ្នកបានស្នាក់នៅគ្រប់រយៈពេល៣ឆ្នាំក្នុងប្រទេសនោះ ។

(ខ) ជាអ្នកមានប្តី ឬប្រពន្ធដែលមានសញ្ជាតិរបស់ប្រទេសដែលខ្លួនស្នាក់នៅ ។ ជនភៀសខ្លួនមិនអាចយកប្រយោជន៍នៃបទបញ្ញត្តិនេះ មកប្រើប្រាស់ជាសំអាងបានឡើយ ប្រសិនបើខ្លួនបានបោះបង់ប្តីឬប្រពន្ធរបស់ខ្លួន ។

(គ) មានកូនមួយ ឬច្រើនជាងនេះ ដែលមានសញ្ជាតិរបស់ប្រទេសដែលខ្លួនស្នាក់នៅ ។

៣. រដ្ឋភាគីនៃអនុសញ្ញានេះ ត្រូវផ្តល់ការប្រព្រឹត្តទៅលើពួកគេ ដោយករុណាធម៌ ក្នុងការធ្វើសមានកម្មនៃសិទ្ធិជនភៀសខ្លួន ក្នុងការងារមានប្រាក់ឈ្នួល ឱ្យដូចជាសិទ្ធិរបស់ជនជាតិខ្លួន និងជាពិសេសសិទ្ធិជនភៀសខ្លួនដែលបានចូលក្នុងទឹកដីរបស់ខ្លួន ស្របតាមកម្មវិធីជ្រើសរើសកម្លាំងពលករ ឬតាមផែនការអន្តោប្រវេសន៍ ។

## មាត្រា ១៨: ស្វ័យការងារ

រដ្ឋភាគីនៃអនុសញ្ញានេះ ត្រូវផ្តល់ដល់ជនភៀសខ្លួន ដែលស្នាក់នៅស្របច្បាប់នៅលើទឹកដីរបស់ខ្លួន នូវការប្រព្រឹត្តទៅលើពួកគេយ៉ាងអនុគ្រោះ តាមដែលអាចធ្វើទៅបាន និងទោះជាយ៉ាងណាក៏ដោយ ក៏ការប្រព្រឹត្តទៅលើពួកគេនេះ មិនត្រូវឱ្យតិចជាងការយកចិត្តទុកដាក់ដូចផ្តល់ដល់ជនបរទេសជាទូទៅដែលស្ថិតក្នុងស្ថានភាពដូចគ្នានេះឡើយ ចំពោះសិទ្ធិក្នុងការចូលរួមដោយខ្លួនឯងផ្ទាល់ នៅក្នុងវិស័យកសិកម្ម ឧស្សាហកម្ម សិប្បកម្ម និងពាណិជ្ជកម្ម ព្រមទាំងសិទ្ធិក្នុងការបង្កើតក្រុមហ៊ុនពាណិជ្ជកម្ម និងឧស្សាហកម្ម ។

## មាត្រា ១៩: វិជ្ជាជីវៈសេរី

១. រដ្ឋភាគីនៃអនុសញ្ញានីមួយៗ ត្រូវផ្តល់ដល់ជនភៀសខ្លួនដែលបានស្នាក់នៅត្រឹមត្រូវតាមច្បាប់ នៅលើទឹកដីរបស់ខ្លួន ដែលមានសញ្ញាប័ត្រទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋនោះ និងដែលមានបំណងចង់ប្រកបវិជ្ជាជីវៈសេរី នូវការយកចិត្តទុកដាក់ដល់ពួកគេយ៉ាងអនុគ្រោះ តាមដែលអាចធ្វើទៅបាន និងទោះជាយ៉ាងណាក៏ដោយ ក៏ការយកចិត្តទុកដាក់នេះ មិនត្រូវឱ្យទាបជាងការយកចិត្តទុកដាក់ ដែលផ្តល់ឱ្យដល់ជនបរទេសជាទូទៅ ដែលស្ថិតក្នុងស្ថានភាពដូចគ្នានេះឡើយ ។

២. រដ្ឋភាគីនៃអនុសញ្ញានេះ ត្រូវប្រើប្រាស់កិច្ចប្រឹងប្រែងរបស់ខ្លួនឱ្យអស់ពីលទ្ធភាព ស្របតាមច្បាប់ និងរដ្ឋធម្មនុញ្ញរបស់ខ្លួន ដើម្បីធានាការតាំងទីលំនៅរបស់ជនភៀសខ្លួនទាំងនោះ ក្នុងទឹកដីរបស់ខ្លួន ក្រៅពីទឹកដីទាំងឡាយ ដែលខ្លួនទទួលខុសត្រូវសម្រាប់ទំនាក់ទំនងអន្តរជាតិ ក្រៅពីទឹកដីរបស់ខ្លួនផ្ទាល់ ។

# ជំពូក ៤: សុខុមាលភាព

## មាត្រា ២០: ការកំណត់ម្ហូបអាហារ

ក្នុងករណីប្រព័ន្ធកំណត់ម្ហូបអាហារមានស្រាប់ ដែលអនុវត្តចំពោះប្រជាជនជាទូទៅ និងមានការដាក់កម្រិតចែកចាយជាទូទៅនូវផលិតផលដែលខ្វះខាតនោះ ជនភៀសខ្លួនក៏ត្រូវបានទទួលនូវការគិតគូរដូចគ្នានឹងជនជាតិនៅទីនោះដែរ ។

## មាត្រា ២១: លំនៅដ្ឋាន

ពាក់ព័ន្ធនឹងលំនៅដ្ឋាន ឱ្យតែបញ្ហានេះត្រូវបានកំណត់ដោយច្បាប់ ឬបទបញ្ញត្តិ ឬស្ថិតក្រោមការត្រួតត្រារបស់អាជ្ញាធរសាធារណៈ រដ្ឋភាគីនៃអនុសញ្ញានេះ ត្រូវផ្តល់ដល់ជនភៀសខ្លួនដែលបានស្នាក់នៅត្រឹមត្រូវតាមច្បាប់នៅលើទឹកដីរបស់ខ្លួន នូវការយកចិត្តទុកដាក់ដល់ពួកគេយ៉ាងអនុគ្រោះ តាមដែលអាចធ្វើទៅបាន និងទោះជាយ៉ាងណាក៏ដោយ ក៏ការយកចិត្តទុកដាក់នេះ មិនត្រូវទាបជាងការយកចិត្តទុកដាក់ដែលផ្តល់ឱ្យដល់ជនបរទេសជាទូទៅ ដែលស្ថិតក្នុងស្ថានភាពដូចគ្នានោះឡើយ ។

## មាត្រា ២២: ការអប់រំសាធារណៈ

១. រដ្ឋភាគីនៃអនុសញ្ញានេះ ត្រូវផ្តល់ដល់ជនភៀសខ្លួននូវការយកចិត្តទុកដាក់ដល់ពួកគេដូចគ្នានឹងការយកចិត្តទុកដាក់ដែលផ្តល់ដល់ជនបរទេស ចំពោះការអប់រំកម្រិតបឋមសិក្សា ។

២. រដ្ឋភាគីនៃអនុសញ្ញានេះ ត្រូវផ្តល់ដល់ជនភៀសខ្លួននូវការយកចិត្តទុកដាក់យ៉ាងអនុគ្រោះតាមដែលអាចធ្វើទៅបាន និងទោះយ៉ាងណាក៏ដោយ ក៏មិនទាបជាងការយកចិត្តទុកដាក់ ដែលផ្តល់ដល់ជនបរទេសជាទូទៅដែលស្ថិតក្នុងស្ថានភាពដូចគ្នា ចំពោះការអប់រំក្រៅពីការអប់រំកម្រិតបឋមសិក្សាជាពិសេសចំពោះការទទួលបាននូវការសិក្សា ការទទួលស្គាល់នូវវិញ្ញាបនប័ត្រ សញ្ញាប័ត្រ និងបរិញ្ញាប័ត្រពីសាលាបរទេស និងការបន្ធូរបន្ថយការបង់ថ្លៃ និងការយកថ្លៃឈ្នួលសិក្សា និងការចែករង្វាន់អាហារូបករណ៍ ។

## មាត្រា ២៣: ជំនួយសង្គ្រោះសាធារណៈ

រដ្ឋភាគីនៃអនុសញ្ញានេះ ត្រូវផ្តល់ដល់ជនភៀសខ្លួនដែលស្នាក់នៅត្រឹមត្រូវតាមច្បាប់នៅលើទឹកដីរបស់ខ្លួន នូវការយកចិត្តទុកដាក់ចំពោះជំនួយសង្គ្រោះ និងការឧបត្ថម្ភសាធារណៈ ដូចគ្នានឹងការយកចិត្តទុកដាក់ដែលខ្លួនផ្តល់ដល់ជនជាតិរបស់ខ្លួនដែរ ។

## មាត្រា ២៤: ច្បាប់ការងារ និងសន្តិសុខសង្គម

១. រដ្ឋភាគីនៃអនុសញ្ញានេះ ត្រូវផ្តល់ដល់ជនភៀសខ្លួនដែលស្នាក់នៅត្រឹមត្រូវតាមច្បាប់នៅលើទឹកដីរបស់ខ្លួននូវការយកចិត្តទុកដាក់ដូចគ្នានឹងការយកចិត្តទុកដាក់ដែលផ្តល់ដល់ជនជាតិខ្លួនចំពោះកិច្ចការដូចខាងក្រោមនេះ :

(ក) ឱ្យតែកិច្ចការទាំងនោះ ត្រូវបានគ្រប់គ្រងដោយច្បាប់ ឬបទបញ្ញត្តិ ឬស្ថិតក្រោមការត្រួតត្រារបស់អាជ្ញាធររដ្ឋបាលដូចជា: ប្រាក់បំណាច់រួម ប្រាក់ឧបត្ថម្ភសម្រាប់គ្រួសារក្នុងករណី ប្រាក់ឧបត្ថម្ភនេះ ជាផ្នែកមួយនៃប្រាក់បំណាច់ផង ចំនួនម៉ោងធ្វើការងារ ចំនួនម៉ោងធ្វើការបន្ថែម វិស្សមកាលដោយមានប្រាក់បៀវត្សរ៍ ការរឹតត្បិតលើការងារនៅផ្ទះ អាយុអប្បបរមានៃការធ្វើការងារ ការហ្វឹកហាត់ការងារ និងការបណ្តុះបណ្តាលការងាររបស់ស្ត្រី និងការងាររបស់យុវវ័យ ព្រមទាំងការទទួលបាននូវផលប្រយោជន៍ បានមកពីកិច្ចចរចាព្រមព្រៀងសមូហភាព ។

(ខ) សន្តិសុខសង្គម (បទបញ្ញត្តិចំពោះគ្រោះថ្នាក់ក្នុងការងារ ការមានជំងឺដោយការងារមាតុភាព ការឈឺថ្កាត់ ការបាត់បង់សមត្ថភាពពលកម្ម វ័យចាស់ជរា មរណភាព ភាពអត់ការងារធ្វើ និង ការទទួលខុសត្រូវចំពោះគ្រួសារ ព្រមទាំងព្រឹត្តិការណ៍ផ្សេងទៀត ស្របតាមច្បាប់ ឬបទបញ្ញត្តិជាតិ ត្រូវបានធានាដោយផែនការសន្តិសុខសង្គម) ដោយស្ថិតក្រោមលក្ខខណ្ឌដូចខាងក្រោមនេះ :

(i) វាអាចមានការរៀបចំសមស្រប ដើម្បីរក្សាសិទ្ធិ ដែលទទួលបានស្រេចហើយ និងសិទ្ធិដែលកំពុងតែរៀបចំឱ្យទទួលបាន ។

(ii) ច្បាប់ ឬបទបញ្ញត្តិជាតិរបស់ប្រទេសនៃលំនៅដ្ឋាន អាចដាក់បញ្ញត្តិឱ្យមានការរៀបចំពិសេស អំពីប្រាក់កម្រៃ ឬផ្នែកខ្លះនៃប្រាក់កម្រៃដែលផ្តល់ទាំងស្រុងចេញពីមូលនិធិសាធារណៈ និងអំពីប្រាក់ឧបត្ថម្ភ សម្រាប់ជនដែលពុំបានបំពេញលក្ខខណ្ឌនៃការបង់វិភាគទាន ដែលកំណត់ឡើងសម្រាប់ជាប្រាក់សោធនិវត្តន៍ធម្មតា ។

២. សិទ្ធិទទួលបានប្រាក់សំណង ចំពោះមរណភាពនៃជនភៀសខ្លួន ដែលបណ្តាលមកពីរងរបួស ដោយការងារ ឬមានជំងឺដោយការងារ មិនត្រូវរងផលប៉ះពាល់ ដោយសារចាលំនៅដ្ឋាននៃអ្នកទទួលផលនោះ នៅក្រៅទឹកដីរបស់រដ្ឋភាគីនៃអនុសញ្ញានោះឡើយ ។

៣. រដ្ឋភាគីនៃអនុសញ្ញា ត្រូវផ្តល់ឱ្យដល់ជនភៀសខ្លួននូវផលប្រយោជន៍នៃកិច្ចព្រមព្រៀងដែលបានព្រមព្រៀងរវាងគ្នារួចហើយ ឬដែលអាចនឹងព្រមព្រៀងរវាងគ្នាក្នុងពេលអនាគតស្តីពីការរក្សាសិទ្ធិដែលបានមកស្រេចហើយ និងសិទ្ធិដែលកំពុងតែរៀបចំឱ្យបានទទួលពាក់ព័ន្ធនឹងសន្តិសុខសង្គម ស្របតាមលក្ខខណ្ឌអនុវត្តចំពោះជនជាតិនៃរដ្ឋភាគីហត្ថលេខីនៃកិច្ចព្រមព្រៀង ដែលកំពុងតែនិយាយនេះតែប៉ុណ្ណោះ ។

៤. រដ្ឋភាគីនៃអនុសញ្ញានេះ នឹងផ្តល់ការគិតគូរដល់ជនភៀសខ្លួនដោយករុណាធម៌ តាមការពង្រីកដល់ជនភៀសខ្លួន នូវផលប្រយោជន៍ឱ្យបានច្រើនតាមដែលអាចធ្វើទៅបាននៃកិច្ចព្រមព្រៀងស្រដៀងគ្នាដែលអាចចូលជាធរមាន នៅពេលណាមួយរវាងរដ្ឋភាគី និងរដ្ឋមិនមែនជាភាគីនៃអនុសញ្ញានេះ ។

## ជំពូក ៥: វិធានការរដ្ឋបាល

### មាត្រា ២៥: ជំនួយផ្នែករដ្ឋបាល

១. បើការប្រើប្រាស់សិទ្ធិដោយជនភៀសខ្លួនជាធម្មតា ត្រូវការនូវជំនួយពីអាជ្ញាធរនៃរដ្ឋបរទេស ដែលជនភៀសខ្លួនមិនអាចពឹងផ្អែកបាន រដ្ឋភាគីនៃអនុសញ្ញាដែលទឹកដីរបស់ខ្លួនមានជនភៀសខ្លួនកំពុងស្នាក់នៅ ត្រូវរៀបចំផ្តល់ជំនួយបែបនោះដល់ជនភៀសខ្លួនដោយអាជ្ញាធររបស់ខ្លួន ឬដោយអាជ្ញាធរអន្តរជាតិ។

២. អាជ្ញាធរដូចមានចែងក្នុងកថាខណ្ឌ១ ត្រូវប្រគល់ ឬបង្កលក្ខណៈឱ្យមានការប្រគល់ ក្រោមការត្រួតពិនិត្យមើលរបស់ខ្លួន ឱ្យទៅជនភៀសខ្លួននូវឯកសារ ឬលិខិតបញ្ជាក់ទាំងឡាយ ដែលជាធម្មតាត្រូវប្រគល់ឱ្យទៅជនបរទេស ដោយ ឬតាមរយៈអាជ្ញាធរជាតិរបស់ខ្លួន ។

៣. ឯកសារ ឬលិខិតបញ្ជាក់ ដែលប្រគល់ឱ្យទៅជនភៀសខ្លួនបែបនេះ ត្រូវមានតម្លៃប្រើប្រាស់ជំនួសលិខិតុបករណ៍ផ្លូវការទាំងអស់ ដែលត្រូវប្រគល់ឱ្យទៅជនបរទេសដោយ ឬតាមរយៈអាជ្ញាធរជាតិរបស់ខ្លួន និងត្រូវមានតម្លៃអាចទុកចិត្តបាន ក្នុងករណីគ្មានភស្តុតាងផ្ទុយពីនេះ ។

៤. ស្របតាមការគិតគូរពិសេសដែលអាចផ្តល់ដល់ជនទីទ័លក្រ ថ្លៃឈ្នួលអាចនឹងត្រូវបង់សម្រាប់សេវាកម្មដែលមានចែងនៅទីនេះ ប៉ុន្តែថ្លៃឈ្នួលត្រូវតែសមល្មម និងប្រហាក់ប្រហែលនឹងថ្លៃឈ្នួលដែលបង់ដោយជនជាតិសម្រាប់សេវាកម្មស្រដៀងគ្នានោះ ។

៥. បទបញ្ញត្តិនៃមាត្រានេះ មិនមានប៉ះពាល់ដល់មាត្រា២៧ និង២៨ឡើយ ។

## មាត្រា ២៦: សេរីភាពក្នុងការធ្វើដំណើរ

រដ្ឋភាគីនៃអនុសញ្ញា ត្រូវផ្តល់ដល់ជនភៀសខ្លួនដែលស្នាក់នៅស្របច្បាប់លើទឹកដីរបស់ខ្លួន នូវសិទ្ធិជ្រើសរើសទីស្នាក់អាស្រ័យ និងធ្វើដំណើរដោយសេរីលើទឹកដីរបស់ខ្លួន ស្របតាមបញ្ញត្តិដែលអនុវត្តចំពោះជនបរទេសជាទូទៅក្នុងកាលៈទេសៈដូចគ្នានេះ ។

## មាត្រា ២៧: លិខិតសំគាល់អត្តសញ្ញាណ

រដ្ឋភាគីនៃអនុសញ្ញា ត្រូវចេញលិខិតសំគាល់អត្តសញ្ញាណដល់ជនភៀសខ្លួនដែលនៅលើទឹកដីរបស់ខ្លួន និងមិនមានឯកសារធ្វើដំណើរមានសុពលភាព ។

## មាត្រា ២៨: ឯកសារធ្វើដំណើរ

១. រដ្ឋភាគីនៃអនុសញ្ញា ត្រូវចេញឱ្យដល់ជនភៀសខ្លួនដែលកំពុងស្នាក់នៅត្រឹមត្រូវតាមច្បាប់នៅលើទឹកដីរបស់ខ្លួន នូវឯកសារធ្វើដំណើរ ដើម្បីដើរហើរចេញក្រៅពីទឹកដីរបស់ខ្លួន បើពុំមានហេតុផលត្រូវទទួលយកអំពីសន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈតម្រូវផ្សេង ហើយឯកសារលំអិតជាប់ជាមួយអនុសញ្ញានេះ ត្រូវអនុវត្តចំពោះឯកសារបែបនោះ ។ រដ្ឋភាគីនៃអនុសញ្ញា អាចចេញឯកសារធ្វើដំណើរបែបនោះ ទៅឱ្យជនភៀសខ្លួនផ្សេងទៀតនៅលើទឹកដីរបស់ខ្លួន ។ រដ្ឋភាគី ត្រូវផ្តល់ជាពិសេសនូវការគិតគូរដោយករុណាធម៌ ចំពោះការចេញឯកសារធ្វើដំណើរបែបនោះ ទៅឱ្យជនភៀសខ្លួននៅលើទឹកដីរបស់ខ្លួនដែលមិនអាចទទួលបាននូវឯកសារធ្វើដំណើរពីប្រទេស ដែលពួកគេមានលំនៅដ្ឋានត្រឹមត្រូវតាមច្បាប់ ។

២. ឯកសារធ្វើដំណើរ ដែលបានចេញឱ្យទៅជនភៀសខ្លួន ក្រោមកិច្ចព្រមព្រៀងអន្តរជាតិមុនៗដោយភាគីនៃកិច្ចព្រមព្រៀងទាំងនោះ ត្រូវបានទទួលស្គាល់ និងចាត់ទុកដោយរដ្ឋភាគីនៃអនុសញ្ញាថាដូចជាបានចេញតាមមាត្រានេះ ។

## មាត្រា ២៩: បន្ទុកសារពើពន្ធ

១. រដ្ឋភាគីនៃអនុសញ្ញា មិនត្រូវដាក់បន្ទុំលើជនភៀសខ្លួននូវពន្ធគយ ការបង់ថ្លៃ ឬពន្ធអាករក្នុងប្រភេទណាក៏ដោយ ក្រៅអំពី ឬខ្ពស់ជាងការបង់ថ្លៃ ឬពន្ធដែលដកហូត ឬអាចដកហូតពីជនជាតិរបស់ខ្លួន នៅក្នុងស្ថានភាពប្រហាក់ប្រហែលគ្នានេះឡើយ ។

២. គ្មានបទបញ្ញត្តិណាមួយនៅក្នុងកថាខណ្ឌខាងលើនេះ រារាំងដល់ការអនុវត្តន៍ចំពោះជនភៀសខ្លួន នូវច្បាប់ និងបទបញ្ញត្តិទាំងឡាយពាក់ព័ន្ធនឹងការបង់ថ្លៃចំពោះការចេញឯកសារខាងរដ្ឋបាល រួមមានលិខិតសំគាល់អត្តសញ្ញាណផងដល់ជនបរទេសនោះឡើយ ។

## មាត្រា ៣០: ការផ្ទេរទ្រព្យសម្បត្តិ

១. រដ្ឋភាគីនៃអនុសញ្ញា ស្របតាមច្បាប់ និងបទបញ្ញត្តិផ្សេងៗរបស់ខ្លួន ត្រូវអនុញ្ញាតឱ្យជនភៀសខ្លួនផ្ទេរសម្បត្តិទ្រព្យដែលពួកគេបាននាំចូលក្នុងដែនដីរបស់ខ្លួន ទៅប្រទេសមួយទៀតដែលពួកគេបានការអនុញ្ញាតឱ្យចូលដើម្បីតាំងទីលំនៅថ្មី ។

២. រដ្ឋភាគីនៃអនុសញ្ញា ត្រូវផ្តល់ការគិតគូរដោយករុណាធម៌ ចំពោះពាក្យសុំការអនុញ្ញាតរបស់ជនភៀសខ្លួន ដើម្បីផ្ទេរទ្រព្យសម្បត្តិដែលអាចមាន នៅទីណាក៏ដោយ និងដែលជាចាំបាច់ សម្រាប់តាំងទីលំនៅជាថ្មីរបស់ពួកគេ នៅក្នុងប្រទេសមួយទៀតដែលពួកគេទទួលបានការអនុញ្ញាតឱ្យចូលហើយ ។

## មាត្រា ៣១: ជនភៀសខ្លួននៅមិនស្របច្បាប់ក្នុងប្រទេសដែលខ្លួនជ្រកកោន

១. រដ្ឋភាគីនៃអនុសញ្ញា មិនត្រូវបង្ខំដាក់ទណ្ឌកម្ម ដោយសារការចូល ឬមានវត្តមានខុសច្បាប់ ទៅលើជនភៀសខ្លួនដែលមកពីទឹកដីដែលជីវិត និងសេរីភាពរបស់ពួកគេ រងការគំរាមកំហែង ស្របតាមន័យនៃមាត្រា១ ហើយចូល ឬមានវត្តមានលើទឹកដីនៃរដ្ឋភាគី ដោយពុំមានការអនុញ្ញាត បើពួកគេបានបង្ហាញខ្លួនភ្លាមៗនៅចំពោះមុខអាជ្ញាធរ និងបានបង្ហាញបុព្វហេតុត្រឹមត្រូវនៃការចូល ឬការមានវត្តមានដោយខុសច្បាប់របស់ពួកគេ ។

២. រដ្ឋភាគីនៃអនុសញ្ញាមិនត្រូវដាក់ការរឹតត្បិតលើការដើរហើររបស់ជនភៀសខ្លួនបែបនោះឡើយ លើកលែងតែការរឹតត្បិតនោះចាំបាច់ ហើយការរឹតត្បិតបែបនោះ អាចយកមកអនុវត្តបាន ទម្រាំដល់ពេលដែលឋានៈរបស់ពួកគេ នៅក្នុងប្រទេសនោះ ត្រូវបានធ្វើត្រឹមត្រូវស្របតាមច្បាប់ ឬពួកគេទទួលបានការអនុញ្ញាតឱ្យចូលទៅក្នុងប្រទេសមួយទៀតតែប៉ុណ្ណោះ ។ រដ្ឋភាគីនៃអនុសញ្ញា ត្រូវអនុញ្ញាតឱ្យជនភៀសខ្លួនបែបនោះ នូវរយៈពេលសមស្រប និងសម្ភារៈរូបវ័ន្តចាំបាច់ ដើម្បីទទួលបានការអនុញ្ញាតឱ្យចូលទៅក្នុងប្រទេសមួយផ្សេងទៀត ។

## មាត្រា ៣២: ការបណ្តេញចេញ

១. រដ្ឋភាគីនៃអនុសញ្ញា មិនត្រូវបណ្តេញជនភៀសខ្លួនណាម្នាក់ដែលនៅលើទឹកដីរបស់ខ្លួនត្រឹមត្រូវតាមច្បាប់ លើកលែងតែមានហេតុផលខាងសន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ ។

២. ការបណ្តេញចេញនូវជនភៀសខ្លួនបែបនោះ អាចធ្វើទៅបាន លុះត្រាតែអនុលោមតាមសេចក្តីសម្រេចដែលធ្វើឡើងស្របតាមនីតិវិធីច្បាប់តែប៉ុណ្ណោះ ។ លើកលែងតែនៅពេលណាដែលមានហេតុផលត្រូវទទួលយកខាងសន្តិសុខជាតិ តម្រូវឱ្យធ្វើផ្សេងពីនេះ ជនភៀសខ្លួនត្រូវតែបានការអនុញ្ញាតឱ្យដាក់ភស្តុតាង ដើម្បីបង្ហាញថាខ្លួនគ្មានទោសពៃរ៍ និងធ្វើឧទ្ធរណ៍ និងសុំឱ្យមានអ្នកតំណាងខ្លួនក្នុងកិច្ចការនេះ នៅចំពោះមុខអាជ្ញាធរមានសមត្ថកិច្ច ឬនៅចំពោះមនុស្សម្នាក់ ឬច្រើននាក់ដែលតែងតាំងជាពិសេសដោយអាជ្ញាធរមានសមត្ថកិច្ច ។

៣. រដ្ឋភាគីនៃអនុសញ្ញា ត្រូវអនុញ្ញាតឱ្យជនភៀសខ្លួននោះ នូវរយៈពេលសមស្របមួយ ដើម្បីស្វែងរកការអនុញ្ញាតចូលក្នុងដែនដីនៃរដ្ឋមួយទៀតស្របតាមច្បាប់ ។ ក្នុងន័យនេះ រដ្ឋភាគីនៃអនុសញ្ញារក្សាសិទ្ធិអនុវត្តវិធានការផ្ទៃក្នុង ដែលរដ្ឋភាគីអាចចាត់ទុកថាជាការចាំបាច់ ។

### មាត្រា ៣៣: ការហាមឃាត់ការបណ្តេញចេញ ឬការបញ្ជូនត្រឡប់វិញ "បញ្ជូនចេញដោយបង្ខំ"

១. គ្មានរដ្ឋភាគីនៃអនុសញ្ញាណាមួយ ត្រូវបណ្តេញចេញ ឬបញ្ជូនត្រឡប់វិញ នូវជនភៀសខ្លួនទោះតាមលក្ខណៈបែបណាក៏ដោយ ឱ្យទៅកាន់ព្រំដែននៃទឹកដី ដែលជីវិត និងសេរីភាពរបស់គេរងការគំរាមកំហែង ដោយសារតែជាតិសាសន៍ សាសនា សញ្ជាតិ សមាជិកភាពនៃក្រុមសង្គមណាមួយ ឬមតិនយោបាយ ។

២. ក៏ប៉ុន្តែ ផលប្រយោជន៍នៃបទបញ្ញត្តិនេះ មិនអាចយកមកសំអាងដោយជនភៀសខ្លួនដែលគេមានមូលហេតុសមហេតុផលថា ជននោះអាចជាគ្រោះថ្នាក់ដល់សន្តិសុខរបស់ប្រទេសដែលជននោះមកនៅ ឬដែលត្រូវបានតុលាការចេញសាលក្រមស្ថាពរ ឱ្យជាប់ទោសពីបទឧក្រិដ្ឋធ្ងន់ធ្ងរណាមួយ ដែលចាត់ជាគ្រោះថ្នាក់ដល់សហគមន៍នៃប្រទេសនោះ ។

### មាត្រា ៣៤: សញ្ជាតូបនីយកម្ម

រដ្ឋភាគីនៃអនុសញ្ញា ត្រូវជួយសម្របសម្រួលឱ្យបានច្រើនតាមអាចធ្វើទៅបាន នូវការរួមបញ្ចូលគ្នា និងការធ្វើសញ្ជាតូបនីយកម្មនៃជនភៀសខ្លួន ។ ជាពិសេស រដ្ឋទាំងនោះ ត្រូវធ្វើការប្រឹងប្រែងគ្រប់យ៉ាង ដើម្បីធ្វើឱ្យនីតិវិធីសញ្ជាតូបនីយកម្មបានឆាប់រហ័ស និងដើម្បីកាត់បន្ថយឱ្យបានច្រើនតាមដែលអាចធ្វើបាននូវការបង់ថ្លៃ និងថ្លៃនីតិវិធីនេះ ។

## ជំពូក ៦: បទបញ្ញត្តិប្រតិបត្តិ និងអន្តរកាល

### មាត្រា ៣៥: សហប្រតិបត្តិការនៃអាជ្ញាធរជាតិជាមួយអង្គការសហប្រជាជាតិ

១. រដ្ឋភាគីនៃអនុសញ្ញា សន្យាធ្វើសហប្រតិបត្តិការជាមួយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ឬជាមួយភ្នាក់ងារដទៃទៀតនៃអង្គការសហប្រជាជាតិ ដែលអាចបន្តកាតព្វកិច្ចពីការិយាល័យនេះ ក្នុងការអនុវត្តន៍មុខងាររបស់ឧត្តមស្នងការ ហើយជាពិសេស ត្រូវជួយសម្រួលករណីយកិច្ចត្រួតពិនិត្យរបស់ការិយាល័យ លើការអនុវត្តន៍បទបញ្ញត្តិនៃអនុសញ្ញានេះ ។

២. ដើម្បីឱ្យការិយាល័យឧត្តមស្នងការ ឬភ្នាក់ងារដទៃទៀតនៃអង្គការសហប្រជាជាតិ ដែលអាចបន្តកាតព្វកិច្ចនេះ អាចធ្វើរបាយការណ៍ជូនទៅអង្គការមានសមត្ថកិច្ចនានានៃអង្គការសហប្រជាជាតិ រដ្ឋភាគីនៃអនុសញ្ញានេះ សន្យាផ្តល់ជូនការិយាល័យ ឬភ្នាក់ងារនោះ តាមទម្រង់បែបបទសមស្របនូវព័ត៌មាន និងទិន្នន័យស្ថិតិដែលស្នើសុំទាក់ទិនទៅនឹង :

(ក) ស្ថានភាពរបស់ជនភៀសខ្លួន

(ខ) ការអនុវត្តន៍នៃអនុសញ្ញានេះ, និង

(គ) ច្បាប់ បទបញ្ញត្តិ និងក្រឹត្យនានាដែលនៅជាធរមាន ឬអាចចូលជាធរមាន បន្ទាប់ពីនេះទៅ នឹងប្រើប្រាស់ ហើយដែលទាក់ទិនទៅនឹងជនភៀសខ្លួន ។

## មាត្រា ៣៦: ព័ត៌មានស្តីពីច្បាប់ និងបទបញ្ញត្តិជាតិ

រដ្ឋភាគីនៃអនុសញ្ញានេះ ត្រូវជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ អំពីច្បាប់ និងបទបញ្ញត្តិនានាដែលខ្លួនអាចអនុម័ត ដើម្បីធានាដល់ការអនុវត្តន៍នៃអនុសញ្ញានេះ ។

## មាត្រា ៣៧: ទំនាក់ទំនងជាមួយអនុសញ្ញាមុនៗ

ដោយមិនធ្វើឱ្យប៉ះពាល់ដល់មាត្រា២៨ កថាខណ្ឌ២ នៃអនុសញ្ញានេះ អនុសញ្ញានេះត្រូវប្រើរវាងរដ្ឋភាគីនៃអនុសញ្ញានេះ ជំនួសឱ្យកិច្ចព្រមព្រៀងថ្ងៃទី៥ ខែកក្កដា ឆ្នាំ១៩២២ កិច្ចព្រមព្រៀងថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩២៤ កិច្ចព្រមព្រៀងថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩២៦ កិច្ចព្រមព្រៀងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩២៨ និងកិច្ចព្រមព្រៀងថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៣៥ និងជំនួសឱ្យអនុសញ្ញាថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៣៣ និងអនុសញ្ញាថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៣៨ ពិធីសារថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៣៩ និងកិច្ចព្រមព្រៀងថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៤៦ ។

# ជំពូក ៧: អវសានប្បញ្ញត្តិ

## មាត្រា ៣៨: ការដោះស្រាយវិវាទ

វិវាទណាមួយរវាងភាគីនៃអនុសញ្ញានេះ ដែលពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តន៍អនុសញ្ញា ហើយដែលមិនអាចផ្សះផ្សា តាមមធ្យោបាយផ្សេងទៀតបាន ត្រូវបញ្ជូនទៅតុលាការយុត្តិធម៌អន្តរជាតិ តាមសេចក្តីសុំរបស់ភាគីណាមួយនៃភាគីក្នុងវិវាទ ។

## មាត្រា ៣៩: ការចុះហត្ថលេខា ការឱ្យសច្ចាប័ន និងការចូលជាសមាជិក

១. អនុសញ្ញានេះ ត្រូវបើកចំហឱ្យចុះហត្ថលេខានៅទីក្រុងហ្សឺណែវ នៅថ្ងៃទី២៨-កក្កដា-១៩៥១ និងបន្ទាប់មកត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ អនុសញ្ញានេះ ត្រូវបើកចំហឱ្យចុះហត្ថលេខា នៅការិយាល័យអង្គការសហប្រជាជាតិប្រចាំទ្វីបអឺរ៉ុប ចាប់តាំងពីថ្ងៃទី២៨ ខែកក្កដា ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៥១ និងត្រូវគេបើកពិធីចុះហត្ថលេខាម្តងទៀតនៅទីស្នាក់ការអង្គការសហប្រជាជាតិ ចាប់តាំងពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៥១ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៥២ ។

២. អនុសញ្ញានេះ ត្រូវបើកចំហឱ្យចុះហត្ថលេខា តាងនាមឱ្យរដ្ឋសមាជិកទាំងអស់នៃអង្គការសហប្រជាជាតិ និងតាងនាមឱ្យរដ្ឋផ្សេងទៀតដែលត្រូវបានអញ្ជើញឱ្យចូលរួមនៅក្នុងមហាសន្និបាតពេញអង្គស្តីពីឋានៈនៃជនភៀសខ្លួន និងនិបេតិកជន ឬដែលមហាសន្និបាតអង្គការសហប្រជាជាតិបានអញ្ជើញឱ្យចុះហត្ថលេខាលើអនុសញ្ញានេះ ។ អនុសញ្ញានេះ ត្រូវបានដាក់ឱ្យផ្តល់សច្ចាប័ន ហើយលិខិតុបករណ៍ឱ្យសច្ចាប័នត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៣. អនុសញ្ញានេះ ត្រូវបើកចំហឱ្យរដ្ឋចូលជាសមាជិក ចាប់ពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥១ យោងតាមកថាខណ្ឌ២ នៃមាត្រានេះ ។ ការចូលជាសមាជិក មានអានុភាពដោយការដាក់តំកល់លិខិតុបករណ៍សុំចូលជាសមាជិក នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

## មាត្រា ៤០: បទបញ្ញត្តិសម្រាប់ការអនុវត្តន៍តាមដែនដី

១. រដ្ឋណាមួយក៏បាន នៅពេលចុះហត្ថលេខា ឱ្យសច្ចាប័ន ឬចូលជាសមាជិកអាចប្រកាសថា អនុសញ្ញានេះ ត្រូវពង្រីកការអនុវត្តន៍ទៅលើទឹកដីទាំងអស់ ឬលើទឹកដីណាមួយដែលនៅក្រោមការទទួលខុសត្រូវរបស់ខ្លួន សម្រាប់ទំនាក់ទំនងអន្តរជាតិ ។ ការប្រកាសនេះ ត្រូវមានអានុភាពនៅពេលដែលអនុសញ្ញាចូលជាធរមាន សម្រាប់ប្រទេសពាក់ព័ន្ធ ។

២. នៅពេលណាក៏ដោយ បន្ទាប់ពីនោះ ការពង្រីកនោះត្រូវធ្វើឡើង ដោយជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយការពង្រីកនោះចាប់មានអានុភាពនៅថ្ងៃទី៩០ បន្ទាប់ពីថ្ងៃដែលអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបានសេចក្តីជូនដំណឹងនេះ ឬចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃអនុសញ្ញានេះ សម្រាប់រដ្ឋពាក់ព័ន្ធ ដោយយកជាការនូវកាលបរិច្ឆេទណាមួយដែលក្រោយគេ ។

៣. ចំពោះទឹកដីណាដែលអនុសញ្ញានេះមិនទាន់បានពង្រីកដល់ នៅពេលចុះហត្ថលេខាឱ្យសច្ចាប័ន ឬចូលជាសមាជិក រដ្ឋពាក់ព័ន្ធនីមួយៗ ត្រូវពិចារណាអំពីលទ្ធភាពក្នុងការចាត់វិធានការចាំបាច់ជាជំហានៗ ដើម្បីពង្រីកការអនុវត្តន៍អនុសញ្ញានេះ លើទឹកដីទាំងនោះ ស្របតាមការយល់ព្រមពីរដ្ឋាភិបាលនៃទឹកដីនោះ ក្នុងករណីចាំបាច់ សម្រាប់ហេតុផលត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ។

## មាត្រា ៤១: បទបញ្ញត្តិពាក់ព័ន្ធនឹងរដ្ឋសហព័ន្ធ

ក្នុងករណីនៃរដ្ឋសហពន្ធ័ ឬរដ្ឋមិនមែនឯកត្តរដ្ឋ បទបញ្ញត្តិខាងក្រោម ត្រូវអនុវត្ត :

(ក) ចំពោះមាត្រាទាំងឡាយនៃអនុសញ្ញានេះ ដែលស្ថិតក្នុងដែនសមត្ថកិច្ចច្បាប់របស់អាជ្ញាធរខាងនីតិបញ្ញត្តិនៃរដ្ឋសហពន្ធ័ កាតព្វកិច្ចរបស់រដ្ឋាភិបាលសហព័ន្ធចំពោះវិសាលភាពនេះត្រូវដូចគ្នានឹងកាតព្វកិច្ចរបស់រដ្ឋភាគីដែលមិនមែនជារដ្ឋសហព័ន្ធ ។

(ខ) ចំពោះមាត្រាទាំងឡាយនៃអនុសញ្ញានេះដែលស្ថិតក្នុងដែនសមត្ថកិច្ចច្បាប់នៃរដ្ឋ ខេត្ត ឬស្រុក ដែលជាផ្នែកៗនៃរដ្ឋសហព័ន្ធ ហើយដែលជាប់កាតព្វកិច្ចចាត់វិធានការខាងនីតិបញ្ញត្តិ ក្រោមប្រព័ន្ធរដ្ឋធម្មនុញ្ញ នោះរដ្ឋាភិបាលសហព័ន្ធ ត្រូវនាំយកមាត្រាទាំងនោះ ដោយផ្តល់នូវអនុសាសន៍អនុគ្រោះមួយទៅជូនដំណឹងដល់អាជ្ញាធរទទួលមុខនាទីនៃរដ្ឋ ខេត្ត ឬស្រុកក្នុងរយៈពេលយ៉ាងឆាប់បំផុត តាមដែលអាចធ្វើទៅបាន ។

(គ) រដ្ឋសហព័ន្ធជាភាគីនៃអនុសញ្ញានេះ នៅពេលមានសំណើពីរដ្ឋភាគីផ្សេងទៀតនៃអនុសញ្ញានេះ ដែលបញ្ជូនតាមរយៈអគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវផ្តល់សេចក្តីថ្លែងការណ៍អំពីច្បាប់ និងការអនុវត្តន៍របស់សហព័ន្ធ និងអង្គភាពជាផ្នែកៗរបស់សហព័ន្ធ ចំពោះបទបញ្ញត្តិណាមួយ នៃអនុសញ្ញាដោយបង្ហាញអំពីវិសាលភាពនៃការផ្តល់អានុភាពដល់បទបញ្ញត្តិនោះ តាមរយៈវិធានការនីតិកម្ម ឬវិធានការផ្សេងទៀត ។

## មាត្រា ៤២: លក្ខខណ្ឌរក្សាទុក

១. នៅពេលចុះហត្ថលេខា ឱ្យសច្ចាប័ន ឬចូលជាសមាជិក រដ្ឋនីមួយៗ អាចដាក់លក្ខខណ្ឌចំពោះមាត្រាទាំងឡាយនៃអនុសញ្ញានេះ លើកលែងតែពីមាត្រា១ មាត្រា៣ មាត្រា៤ មាត្រា១៦ (១) មាត្រា៣៣ មាត្រា៣៦ ដល់មាត្រា៤៦ ចេញ ។

២. រដ្ឋណាដែលដាក់លក្ខខណ្ឌ ស្របតាមកថាខណ្ឌ១ នៃមាត្រានេះ អាចដកលក្ខខណ្ឌចេញវិញនៅពេលណាក៏បាន ដោយការជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

## មាត្រា ៤៣: ការចូលជាធរមាន

១. អនុសញ្ញានេះ ត្រូវចូលជាធរមាននៅថ្ងៃទី៩០ បន្ទាប់ពីថ្ងៃដាក់តំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬចូលជាសមាជិកទី៦ ។

២. ចំពោះរដ្ឋនីមួយៗដែលបានឱ្យសច្ចាប័ន ឬចូលជាសមាជិកនៃអនុសញ្ញានេះ ក្រោយការដាក់តំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬចូលជាសមាជិកទី៦ អនុសញ្ញានេះ ត្រូវចូលជាធរមាននៅថ្ងៃទី៩០ សម្រាប់រដ្ឋនោះ បន្ទាប់ពីកាលបរិច្ឆេទដែលរដ្ឋនេះដាក់តំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬចូលជាសមាជិករបស់ខ្លួន ។

## មាត្រា ៤៤: ការប្រកាសដកខ្លួន

១. រដ្ឋភាគីនៃអនុសញ្ញា អាចប្រកាសដកខ្លួនចេញពីអនុសញ្ញានេះ នៅពេលណាមួយក៏បាន ដោយការជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

២. ការប្រកាសដកខ្លួន ត្រូវមានអានុភាពចំពោះរដ្ឋភាគីនៃអនុសញ្ញាដែលពាក់ព័ន្ធរយៈពេល១ឆ្នាំចាប់ពីកាលបរិច្ឆេទ ដែលអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបានសេចក្តីប្រកាសនោះ ។

៣. រដ្ឋណាដែលបានធ្វើសេចក្តីប្រកាស ឬការជូនដំណឹងស្របតាមមាត្រា៤០ នៅពេលណាមួយ បន្ទាប់ពីនោះ ដោយការជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ អាចប្រកាសថា អនុសញ្ញានេះ ឈប់ពង្រីកដល់ទឹកដីនោះទៀតហើយ ក្នុងរយៈពេល១ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទដែលអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបានសេចក្តីជូនដំណឹង ។

## មាត្រា ៤៥: ការពិនិត្យឡើងវិញ

១. រដ្ឋភាគីណាមួយនៃអនុសញ្ញាអាចសុំពិនិត្យសើរើឡើងវិញនូវអនុសញ្ញានេះនៅពេលណាក៏បាន ដោយការជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

២. មហាសន្និបាតអង្គការសហប្រជាជាតិ ត្រូវផ្តល់អនុសាសន៍ ប្រសិនបើមាន អំពីវិធានការដែលត្រូវដាក់ចេញចំពោះសេចក្តីស្នើសុំនោះ ។

## មាត្រា ៤៦: ការជូនដំណឹងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ

អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវជូនដំណឹងដល់សមាជិកទាំងអស់នៃអង្គការសហប្រជាជាតិ និងរដ្ឋមិនមែនសមាជិក ដូចមានចែងក្នុងមាត្រា៣៩ អំពី :

(ក) សេចក្តីប្រកាស និងការជូនដំណឹងស្របតាមផ្នែក (ខ) នៃមាត្រា១ ។

(ខ) ការចុះហត្ថលេខា ការឱ្យសច្ចាប័ន និងការចូលជាសមាជិក ស្របតាមមាត្រា៣៩ ។

(គ) សេចក្តីប្រកាស និងការជូនដំណឹង ស្របតាមមាត្រា៤០ ។

(ឃ) លក្ខខណ្ឌ និងការដកចេញ ស្របតាមមាត្រា៤២ ។

(ង) កាលបរិច្ឆេទដែលអនុសញ្ញានេះនឹងចូលជាធរមាន ស្របតាមមាត្រា៤៣ ។

(ច) ការប្រកាសដកខ្លួនចេញ និងការជូនដំណឹង ស្របតាមមាត្រា៤៤ ។

(ឆ) សេចក្តីស្នើសុំពិនិត្យសើរើឡើងវិញ ស្របតាមមាត្រា៤៥ ។

ដោយមានជំនឿទៅលើអនុសញ្ញានេះ ភាគីចុះហត្ថលេខាខាងក្រោម ដោយមានការអនុញ្ញាតយ៉ាងត្រឹមត្រូវ បានចុះហត្ថលេខាលើអនុសញ្ញានេះ តំណាងឱ្យរដ្ឋាភិបាលរៀងៗខ្លួន ។

ធ្វើនៅទីក្រុងហ្សឺណែវ ថ្ងៃទីម្ភៃប្រាំបី ខែកក្កដា ឆ្នាំមួយពាន់ប្រាំបួនរយហាសិបមួយ ជាច្បាប់តែមួយគត់ ដែលមានអត្ថបទជាភាសាអង់គ្លេស និងបារាំង ត្រឹមត្រូវតាមច្បាប់ដូចគ្នា និងត្រូវរក្សាទុកនៅបណ្ណសារដ្ឋាននៃអង្គការសហប្រជាជាតិ ហើយច្បាប់ចម្លង ដែលមានបញ្ជាក់ត្រឹមត្រូវពិតតាមច្បាប់ដើម ត្រូវប្រគល់ជូនសមាជិកទាំងអស់ របស់អង្គការសហប្រជាជាតិ និងរដ្ឋមិនមែនជាសមាជិក ដូចចែងក្នុងមាត្រា៣៩ ។

## ១៦-គ. ពិធីសារពាក់ព័ន្ធឋានៈជនភៀសខ្លួន

ពិធីសារនេះ បានទទួលការកត់សំគាល់ ដោយមានការអនុម័តយល់ព្រមពីក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម តាមសេចក្តីសម្រេចចិត្តលេខ១១៨៦(XLI) ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៦៦ និងបានទទួលការកត់សំគាល់ ដោយមហាសន្និបាតតាមសេចក្តីសម្រេចចិត្តលេខ(XXI) ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ។
តាមសេចក្តីសម្រេចចិត្តដដែលនោះ មហាសន្និបាតបានស្នើសុំអគ្គលេខាធិការ បញ្ជូនអត្ថបទពិធីសារ ទៅរដ្ឋទាំងឡាយដូចបានចែងក្នុងមាត្រា៥ ដើម្បីឱ្យរដ្ឋទាំងនោះ អាចចូលជាសមាជិកនៃពិធីសារ ។
ចូលជាធរមាននៅថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៦៧ ដោយអនុលោមតាមមាត្រា៨
កម្ពុជាក្លាយជារដ្ឋភាគីនៃអនុសញ្ញានេះនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២

## រដ្ឋភាគីនៃពិធីសារនេះ

*យល់ឃើញថា* អនុសញ្ញាពាក់ព័ន្ធឋានៈជនភៀសខ្លួន អនុម័តនៅទីក្រុងហ្សឺណែវ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៥១ (ចាប់ពីនេះតទៅហៅត្រឹមថា អនុសញ្ញា) អនុវត្តតែចំពោះជនទាំងឡាយដែលបានក្លាយជាជនភៀសខ្លួន ដោយសារព្រឹត្តិការណ៍កើតឡើងនៅមុនថ្ងៃទី១ ខែមករា ឆ្នាំ១៩៥១ ។

*យល់ឃើញថា* ស្ថានភាពថ្មីៗនៃជនភៀសខ្លួន បានកើតឡើងចាប់តាំងពីអនុសញ្ញានេះ ត្រូវបានអនុម័ត និង*យល់ឃើញថា* ជនភៀសខ្លួនពាក់ព័ន្ធទាំងនោះ អាចនឹងមិនស្ថិតនៅក្នុងក្របខ័ណ្ឌនៃអនុសញ្ញា។

*យល់ឃើញថា* ជាសេចក្តីប្រាថ្នាចង់បានណាស់ដែលថា ជនភៀសខ្លួនទាំងអស់ត្រូវទទួលបានឋានៈស្មើៗគ្នា តាមការឱ្យនិយមន័យក្នុងអនុសញ្ញា ដោយមិនគិតអំពីកាលបរិច្ឆេទកំណត់ថ្ងៃទី១-មករា-១៩៥១ ។

*បានព្រមព្រៀងគ្នាដូចតទៅ :*

### មាត្រា ១: បទបញ្ញត្តិទូទៅ

១. រដ្ឋភាគីនៃពិធីសារនេះ សន្យាអនុវត្តអនុសញ្ញា ចាប់តាំងពីមាត្រា២ រហូតដល់មាត្រា៣៤ នៃអនុសញ្ញាពាក់ព័ន្ធឋានៈនៃជនភៀស ដូចមាននិយមន័យចែងនៅក្នុងនោះ ចាប់ពីពេលនេះតទៅ ។

២. សម្រាប់គោលបំណងនៃពិធីសារនេះ ពាក្យថា “ជនភៀសខ្លួន” លើកលែងតែចំពោះការអនុវត្តន៏ ដូចមានចែងក្នុងកថាខណ្ឌ៣ នៃមាត្រានេះចេញ និយាយសំដៅដល់ជនណាមួយ ដែលស្ថិតក្នុងនិយមន័យនៃមាត្រា១ នៃអនុសញ្ញា ដែលហាក់ដូចពាក្យ “ដោយសារព្រឹត្តិការណ៍ដែលបានកើតឡើងមុនថ្ងៃទី១-មករា-១៩៥១ និង...” និងពាក្យ “...ដោយសារព្រឹត្តិការណ៍បែបនេះ” ដែលចែងក្នុងមាត្រា១ ក (២) ត្រូវបានលុបចោល ។

៣. ពិធីសារនេះ ត្រូវអនុវត្តតាម ដោយរដ្ឋភាគី ដោយពុំមានកំណត់ភូមិសាស្ត្រណាមួយឡើយ លើកលែងតែថា សេចក្តីប្រកាសដែលមានស្រាប់ ធ្វើឡើងដោយរដ្ឋ ដែលជាភាគីនៃអនុសញ្ញាខាងដើម ស្របតាមមាត្រា១-ខ (១) (ក)នៃអនុសញ្ញា បើមិនបានពង្រីកការអនុវត្តន៍ស្របតាមមាត្រា១-ខ (២)ទេ ត្រូវតែអនុវត្តឱ្យស្របតាមពិធីសារនេះ ។

## មាត្រា ២: សហប្រតិបត្តិការនៃអាជ្ញាធរជាតិជាមួយអង្គការសហប្រជាជាតិ

១. រដ្ឋភាគីនៃពិធីសារនេះ សន្យាធ្វើសហប្រតិបត្តិការជាមួយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ឬជាមួយទីភ្នាក់ងារផ្សេងៗទៀត របស់អង្គការសហប្រជាជាតិ ដែលអាចបន្តកាតព្វកិច្ចពីការិយាល័យនេះ ក្នុងការអនុវត្តន៍ការងាររបស់ឧត្តមស្នងការ និងជាពិសេសជួយសម្រួលដល់ករណីយកិច្ចត្រួតពិនិត្យនៃការិយាល័យ លើការអនុវត្តន៍បទបញ្ញត្តិ នៃពិធីសារនេះ ។

២. ដើម្បីឱ្យការិយាល័យរបស់ឧត្តមស្នងការ ឬទីភ្នាក់ងាផ្សេងទៀតរបស់អង្គការសហប្រជាជាតិ ដែលអាចទទួលបន្តកាតព្វកិច្ចពីការិយាល័យនេះ អាចធ្វើរបាយការណ៍ជូនទៅស្ថាប័ន មានសមត្ថកិច្ចរបស់អង្គការសហប្រជាជាតិ រដ្ឋភាគីនៃពិធីសារនេះ សន្យាផ្តល់ជូនការិយាល័យឧត្តមស្នងការ ឬទីភ្នាក់ងារនោះ នូវព័ត៌មាននិងទិន្នន័យស្ថិតិ ដែលបានស្នើសុំទាក់ទងទៅនឹង:

(ក) ស្ថានភាពជនភៀសខ្លួន ។

(ខ) ការអនុវត្តពិធីសារនេះ ។

(គ) ច្បាប់ បទបញ្ញត្តិ និងក្រឹត្យទាំងឡាយដែលនៅជាធរមាន ឬអាចចូលជាធរមាន ចាប់ពីពេលនេះទៅ ហើយដែលទាក់ទិននឹងជនភៀសខ្លួន ។

## មាត្រា ៣: ព័ត៌មានស្តីពីនីតិគម្ពជាតិ

រដ្ឋភាគីនៃពិធីសារនេះ ត្រូវជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ អំពីច្បាប់ និងបទបញ្ញត្តិ ដែលរដ្ឋភាគីអាចអនុម័ត ដើម្បីធានាដល់ការអនុវត្តន៍ពិធីសារនេះ ។

## មាត្រា ៤: ការផ្សះផ្សារវិវាទ

វិវាទណាមួយរវាងរដ្ឋភាគីនៃពិធីសានេះ ពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តន៍ និងមិនអាចផ្សះផ្សារតាមមធ្យោបាយផ្សេងទៀតបាន ត្រូវបញ្ជូនទៅតុលាការយុត្តិធម៌អន្តរជាតិ តាមសេចក្តីស្នើសុំនៃភាគីណាមួយនៃភាគីវិវាទ ។

## មាត្រា ៥: ការចូលជាសមាជិក

ពិធីសារនេះ ត្រូវបើកឱ្យចូលជាសមាជិក ក្នុងនាមរដ្ឋភាគីទាំងអស់ នៃអនុសញ្ញា និងក្នុងនាមរដ្ឋសមាជិកផ្សេងទៀតនៃអង្គការសហប្រជាជាតិ ឬសមាជិកនៃស្ថាប័នឯកទេស ឬរដ្ឋ និងស្ថាប័នដែលមហាសន្និបាតអង្គការសហប្រជាជាតិ អាចអញ្ជើញឱ្យចូលជាសមាជិក ។ ការចូលជាសមាជិក មានប្រសិទ្ធភាព ដោយការតំកល់លិខិតុបករណ៍សុំចូលជាសមាជិកជាមួយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

## មាត្រា ៦: បទបញ្ញត្តិស្តីពីសហព័ន្ធ

ក្នុងករណីមានរដ្ឋសហព័ន្ធ ឬរដ្ឋមិនមែនឯកត្តរដ្ឋ បទបញ្ញត្តិខាងក្រោម ត្រូវអនុវត្ត :

(ក) ចំពោះមាត្រាទាំងឡាយនៃអនុសញ្ញាដែលត្រូវអនុវត្តឱ្យស្របតាមមាត្រា១ កថាខណ្ឌ១នៃពិធីសារនេះ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចច្បាប់នៃអំណាចខាងនីតិបញ្ញត្តិរបស់រដ្ឋសហព័ន្ធ កាតព្វកិច្ចរបស់រដ្ឋាភិបាលសហព័ន្ធចំពោះវិសាលភាពនេះ ត្រូវដូចគ្នានឹងកាតព្វកិច្ចរបស់រដ្ឋភាគីដែលមិនមែនជារដ្ឋសហពន្ធ័។

(ខ) ចំពោះមាត្រាទាំងឡាយនៃអនុសញ្ញាដែលត្រូវអនុវត្តឱ្យស្របតាមមាត្រា១ កថាខណ្ឌ១នៃពិធីសារនេះ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចច្បាប់របស់រដ្ឋ ខេត្ត ឬស្រុក សមាសភាគដែលមិនជាប់កាតព្វកិច្ចក្នុងការចាត់វិធានការច្បាប់ ក្រោមក្របខ័ណ្ឌធម្មនុញ្ញសហព័ន្ធ រដ្ឋាភិបាលសហព័ន្ធ ត្រូវយកមាត្រាទាំងនោះ ជាមួយអនុសាសន៍សមស្របមួយ ជូនជាដំណឹងដល់អាជ្ញាធររដ្ឋ ខេត្ត ឬស្រុក យ៉ាងឆាប់បំផុតតាមដែលអាចធ្វើបាន ។

(គ) រដ្ឋសហព័ន្ធ ដែលជាភាគីនៃពិធីសារនេះ ពេលមានសំណើពីរដ្ឋភាគីផ្សេងណាមួយ ដែលបញ្ជូនតាមរយៈអគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវផ្តល់សេចក្តីថ្លែងការណ៍មួយអំពីច្បាប់ និងការអនុវត្តន៍របស់សហព័ន្ធ ព្រមទាំងផ្នែកសំខាន់ៗ ក្នុងសេចក្តីថ្លែងការណ៍ពាក់ព័ន្ធនឹងបទបញ្ញត្តិជាក់លាក់ណាមួយនៃអនុសញ្ញា ដែលត្រូវបានអនុវត្តស្របតាមមាត្រា១ កថាខណ្ឌ១ នៃពិធីសារនេះ ដោយបង្ហាញនូវវិសាលភាពក្នុងការផ្តល់ប្រសិទ្ធភាពដល់បទបញ្ញត្តិនោះ តាមរយៈនីតិបញ្ញត្តិ ឬសកម្មភាពផ្សេងទៀត ។

## មាត្រា ៧: លក្ខខណ្ឌ និងសេចក្តីប្រកាស

១. នៅពេលសុំចូលជាសមាជិក រដ្ឋនីមួយៗ អាចធ្វើលក្ខខណ្ឌចំពោះមាត្រា៤ នៃពិធីសារនេះ និងចំពោះការអនុវត្តន៍ស្របតាមមាត្រា១ នៃពិធីសារនេះ នូវបទបញ្ញត្តិមួយចំនួននៃអនុសញ្ញា លើកលែងតែបទបញ្ញត្តិដែលមានចែងក្នុងមាត្រា១ មាត្រា៣ មាត្រា៤ មាត្រា១៦ (១) និងមាត្រា៣៣ នៃអនុសញ្ញា ឱ្យតែករណីដែលរដ្ឋភាគីមួយនៃអនុសញ្ញា ដែលធ្វើលក្ខខណ្ឌស្របតាមមាត្រានេះ មិនរាប់បញ្ចូលជនភៀសខ្លួន ដែលអនុសញ្ញាអនុវត្តចំពោះពួកគេ ។

២. លក្ខខណ្ឌធ្វើឡើងដោយរដ្ឋភាគីនៃអនុសញ្ញាស្របតាមមាត្រា៤២នៃអនុសញ្ញានោះ បើមិនបានដកចេញទេ អាចអនុវត្តចំពោះកាតព្វកិច្ចរបស់រដ្ឋភាគី ស្របតាមពិធីសារនេះ ។

៣. រដ្ឋណាដែលធ្វើលក្ខខណ្ឌស្របតាមកថាខណ្ឌ១ នៃមាត្រានេះ អាចដកលក្ខខណ្ឌនោះចេញវិញ នៅពេលណាក៏បាន ដោយជូនដំណឹងអំពីការដកនោះ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៤. សេចក្ដីប្រកាសដែលធ្វើស្របតាមមាត្រា៤០ កថាខណ្ឌ១ និង២ នៃអនុសញ្ញា ដោយរដ្ឋភាគី នៃអនុសញ្ញា ដែលសុំចូលជាសមាជិកនៃពិធីសារនេះ ត្រូវចាត់ទុកថាអនុវត្តតាមពិធីសារនេះ បើនៅពេល សុំចូលជាសមាជិក រដ្ឋភាគីពាក់ព័ន្ធពុំមានការជូនដំណឹងផ្ទុយពីនេះ ជូនអគ្គលេខាធិការអង្គការសហប្រជា ជាតិទេនោះ ។ បទបញ្ញត្តិនៃមាត្រា៤០ កថាខណ្ឌ២ និង៣ និងមាត្រា៤៤ កថាខណ្ឌ៣នៃអនុសញ្ញា ត្រូវ ចាត់ទុកថាអនុវត្តតាមពិធីសារនេះ ក្រោយពីបានពិចារណាល្អិតល្អន់ និងកែសម្រួលជាចាំបាច់រួចហើយ ។

## មាត្រា ៨: ការចូលជាធរមាន

១. ពិធីសារនេះ ត្រូវចូលជាធរមាន នៅថ្ងៃតំកល់ទុកលិខិតុបករណ៍សុំចូលជាសមាជិកទី៦០ ។

២. ចំពោះរដ្ឋនីមួយៗ ដែលសុំចូលជាសមាជិកនៃពិធីសារ ក្រោយការតំកល់ទុកលិខិតុបករណ៍សុំ ចូលជាសមាជិកទី៦០ ពិធីសារនេះ ចូលជាធរមាន នៅថ្ងៃតំកល់ទុកលខិតុបករណ៍សុំចូលជាសមាជិក ដោយរដ្ឋនោះ ។

## មាត្រា ៩: ការប្រកាសដកខ្លួនចេញ

១. រដ្ឋភាគីណាមួយនៃពិធីសារ អាចប្រកាសដកខ្លួនចេញពីពិធីសារនេះ នៅពេលណាក៏បាន ដោយការជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

២. ការប្រកាសដកខ្លួនចេញបែបនេះ នឹងមានប្រសិទ្ធភាពចំពោះរដ្ឋពាក់ព័ន្ធមួយឆ្នាំក្រោយពីថ្ងៃ ដែលអគ្គលេខាធិការអង្គការសហប្រជាជាតិ បានទទួលសេចក្ដីប្រកាសនោះ ។

## មាត្រា ១០: ការជូនដំណឹងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ

អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវជូនដំណឹងដល់រដ្ឋទាំងឡាយ ដូចចែងក្នុងមាត្រា៥ ខាង លើ អំពីកាលបរិច្ឆេទចូលជាធរមាន ការសុំចូលជាសមាជិក លក្ខខណ្ឌ និងការដកចេញនូវលក្ខខណ្ឌ និងការ ប្រកាសដកខ្លួនចេញពីពិធីសារនេះ ព្រមទាំងសេចក្ដីប្រកាស និងសេចក្ដីជូនដំណឹងទាំងឡាយដែលពាក់ព័ន្ធ។

## មាត្រា ១១: ការតំកល់ទុកក្នុងបណ្ណសារដ្ឋាននៃលេខាធិការដ្ឋានអង្គការសហប្រជាជាតិ

ឯកសារមួយច្បាប់នៃពិធីសារនេះដែលមានអត្ថបទសរសេរជាភាសាចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ មានតម្លៃត្រឹមត្រូវតាមច្បាប់ដូចគ្នា មានចុះហត្ថលេខារបស់ប្រធានមហាសន្និបាត និងអគ្គ លេខាធិការអង្គការសហប្រជាជាតិ ត្រូវដាក់តំកល់ទុកក្នុងបណ្ណសារដ្ឋាន នៃលេខាធិការដ្ឋានអង្គការសហ ប្រជាជាតិ ។ អគ្គលេខាធិការ ត្រូវបញ្ជូនច្បាប់ចម្លងមានបញ្ជាក់ត្រឹមត្រូវតាមច្បាប់ដើម នៃពិធីសារនេះ ទៅជូនរដ្ឋសមាជិកទាំងអស់នៃអង្គការសហប្រជាជាតិ និងរដ្ឋដទៃទៀត ដូចចែងក្នុងមាត្រា៥ ខាងលើ ។

# អនុសញ្ញា

# ស្តីពី

# ការបង្ការ   និងការផ្តន្ទាទោស

# ចំពោះ

# ឧក្រិដ្ឋកម្ម

# ប្រល័យពូជសាសន៍

## ១៩- អនុសញ្ញាស្តីពីការបង្ការ និងការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៤៨
និងចូលជាធរមាននៅថ្ងៃទី១២ ខែមករា ឆ្នាំ១៩៥១ ស្របតាមបទបញ្ញត្តិនៃមាត្រា១៣
កម្ពុជាក្លាយជារដ្ឋភាគីនៃអនុសញ្ញានេះនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៥០

រដ្ឋភាគីនៃអនុសញ្ញានេះ :

*យល់ឃើញថា* សេចក្តីប្រកាសដែលបានធ្វើឡើងដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅក្នុងសេចក្តីសំរេចចិត្តរបស់ខ្លួនលេខ៩៦ (I) ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៤៦ ថែងថា អំពើប្រល័យពូជសាសន៍ គឺជាបទឧក្រិដ្ឋមួយដែលបានកំណត់ក្នុងច្បាប់អន្តរជាតិ អំពើនេះផ្ទុយទៅនឹងស្មារតី និងបំណងប្រាថ្នារបស់អង្គការសហប្រជាជាតិ ហើយត្រូវផ្តន្ទាទោសដោយពិភពនៃអារ្យប្រទេស

*ទទួលស្គាល់ថា* នៅគ្រប់សម័យកាលនៃប្រវត្តិសាស្ត្រ អំពើប្រល័យពូជសាសន៍ បានបង្កឱ្យមានការបាត់បង់ដ៏ធំធេងដល់ជីវិតមនុស្សជាតិ ហើយ

*ជឿជាក់ថា* ដើម្បីរំដោះមនុស្សជាតិឱ្យរួចផុតពីមហាភ័យដ៏គួរឱ្យស្អប់ខ្ពើមនេះ គឺតម្រូវឱ្យមានកិច្ចសហប្រតិបត្តិការអន្តរជាតិ

ព្រមព្រៀងលើមាត្រាទាំងឡាយដូចតទៅ :

### មាត្រា ១

រដ្ឋភាគីទាំងអស់ បញ្ជាក់អះអាងថា អំពើប្រល័យពូជសាសន៍ ទោះជាបានប្រព្រឹត្តនៅក្នុងពេលមានសន្តិភាព ឬនៅពេលមានសង្គ្រាមក្តី គឺជាឧក្រិដ្ឋកម្មមួយដែលបានកំណត់ក្នុងច្បាប់អន្តរជាតិ ហើយរដ្ឋភាគីទាំងអស់មានភារកិច្ចធ្វើការទប់ស្កាត់ និងផ្តន្ទាទោស ។

### មាត្រា ២

នៅក្នុងអនុសញ្ញានេះ អំពើប្រល័យពូជសាសន៍ សំដៅដល់អំពើមួយក្នុងចំណោមអំពើទាំងឡាយខាងក្រោមនេះ ដែលបានប្រព្រឹត្តក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកដល់ប្រជាជាតិមួយ ក្រុមជាតិពន្ធុមួយ ឬក្រុមជាតិសាសន៍មួយ ឬក្រុមសាសនាមួយ ដូចជា :

(ក)- ការសំលាប់សមាជិកទាំងឡាយនៅក្នុងក្រុម

(ខ)- ការធ្វើឱ្យឈឺចាប់ និងខូចខាតធ្ងន់ធ្ងរដល់រាងកាយ ឬបញ្ញាស្មារតីរបស់សមាជិកទាំងឡាយនៅក្នុងក្រុម ។

(គ)- ការបង្កមហន្តរាយដោយចេតនាដល់ស្ថានភាពរស់នៅរបស់ក្រុមមនុស្សដែលនាំឱ្យពួកគេទទួលរងការខូចខាតទាំងស្រុង ឬមួយផ្នែក ។

(ឃ)- ការចាត់វិធានការផ្សេងៗ ក្នុងគោលបំណងទប់ស្កាត់ ការផ្តល់កំណើតដល់ទារកនៅក្នុងក្រុម ។

(ង)- ការយកកុមារពីក្រុមមួយ ទៅដាក់នៅក្នុងក្រុមមួយទៀត ដោយបង្ខិតបង្ខំ ។

## មាត្រា ៣

អំពើទាំងឡាយខាងក្រោមនេះ នឹងត្រូវផ្តន្ទាទោស :

(ក)- ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

(ខ)- ការឃុបឃិតប្រព្រឹត្តបទឧក្រិដ្ឋប្រល័យពូជសាសន៍

(គ)- ការញុះញង់ដោយផ្ទាល់ និងជាសាធារណៈឱ្យប្រព្រឹត្តបទឧក្រិដ្ឋប្រល័យពូជសាសន៍ ។

(ឃ)- ការប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋប្រល័យពូជសាសន៍

(ង)- ការសមគំនិតក្នុងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

## មាត្រា ៤

ជនណាដែលប្រព្រឹត្តបទឧក្រិដ្ឋប្រល័យពូជសាសន៍ ឬបទឧក្រិដ្ឋផ្សេងទៀតដែលមានចែងក្នុងមាត្រា ៣ ត្រូវផ្តន្ទាទោស ទោះបីជនទោះជាអ្នកដឹកនាំដែលមានការទទួលខុសត្រូវស្របតាមរដ្ឋធម្មនុញ្ញក្តី ជាមន្ត្រីរាជការក្តី ឬជាបុគ្គលឯកជនក្តី ។

## មាត្រា ៥

រដ្ឋភាគីទាំងអស់ មានភារកិច្ចអនុម័ត ស្របតាមរដ្ឋធម្មនុញ្ញនៃប្រទេសរៀងៗខ្លួន នូវច្បាប់ចាំបាច់ដើម្បីអនុវត្តបទបញ្ញត្តិនៃអនុសញ្ញានេះ ឱ្យមានប្រសិទ្ធភាព ហើយជាពិសេស ត្រូវកំណត់ទោសបញ្ញត្តិជាធរមានចំពោះជនដែលមានពិរុទ្ធភាព ពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ ឬបទឧក្រិដ្ឋដទៃទៀតដែលមានចែងក្នុងមាត្រា៣ ។

## មាត្រា ៦

ជនជាប់ចោទពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ ឬបទឧក្រិដ្ឋដទៃទៀត ដែលមានចែងក្នុងមាត្រា៣ ត្រូវបានកាត់សេចក្តីដោយតុលាការមានសមត្ថកិច្ចរបស់រដ្ឋដែលបទល្មើសបានកើតឡើងលើទឹកដីខ្លួន ឬដោយតុលាការព្រហ្មទណ្ឌអន្តរជាតិដែលអាចមានយុត្តាធិការ ដោយសាររដ្ឋភាគីទាំងនោះទទួលស្គាល់សមត្ថកិច្ចរបស់តុលាការនេះ ។

### មាត្រា ៧

ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មដទៃទៀតដែលមានចែងក្នុងមាត្រា៣ មិនត្រូវចាត់ទុកជាឧក្រិដ្ឋកម្មនយោបាយសំរាប់គោលបំណងនៃការធ្វើបត្យាប័នឡើយ ។

រដ្ឋភាគីទាំងអស់សន្យាថា ក្នុងករណីនេះ ត្រូវធ្វើបត្យាប័នស្របតាមច្បាប់ និងសន្ធិសញ្ញារបស់ខ្លួនដែលកំពុងអនុវត្ត ។

### មាត្រា ៨

រដ្ឋភាគីអាចស្នើទៅស្ថាប័នមានសមត្ថកិច្ចរបស់អង្គការសហប្រជាជាតិ ឱ្យចាត់វិធានការស្របតាមធម្មនុញ្ញសហប្រជាជាតិ តាមដែលខ្លួនយល់ថាជាការគួរ ដើម្បីធ្វើការទប់ស្កាត់ និងបង្ក្រាបអំពើប្រល័យពូជសាសន៍ ឬអំពើដទៃទៀតដែលមានចែងក្នុងមាត្រា៣ ។

### មាត្រា ៩

ជំលោះរវាងរដ្ឋ និងរដ្ឋ ពាក់ព័ន្ធនឹងការបកស្រាយការអនុវត្តន៍ ឬការគោរពតាមអនុសញ្ញានេះ ដោយរួមទាំងជំលោះទាក់ទងនឹងការទទួលខុសត្រូវរបស់រដ្ឋមួយចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឬឧក្រិដ្ឋកម្មដទៃទៀតដែលមានចែងក្នុងមាត្រា៣ ត្រូវបញ្ជូនទៅតុលាការយុត្តិធម៌អន្តរជាតិ តាមការស្នើសុំរបស់ភាគីជំលោះណាមួយ ។

### មាត្រា ១០

អនុសញ្ញានេះមានអត្ថបទជាភាសាចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ មានតំលៃគតិយុត្តិដូចគ្នា ហើយត្រូវមានកាលបរិច្ឆេទថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៤៨ ។

### មាត្រា ១១

អនុសញ្ញានេះ ត្រូវបើកចំហរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៤៩ សំរាប់ចុះហត្ថលេខាដោយរដ្ឋជាសមាជិកអង្គការសហប្រជាជាតិ និងដោយរដ្ឋឯទៀត ដែលមិនមែនជាសមាជិក ដែលត្រូវបានមហាសន្និបាតអញ្ជើញឱ្យចុះហត្ថលេខា ។

អនុសញ្ញានេះ នឹងត្រូវបានផ្តល់សច្ចាប័ន ហើយឯកសារនៃការផ្តល់សច្ចាប័ននេះនឹងត្រូវបានតំកល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

បន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៥០ អនុសញ្ញានេះ នឹងត្រូវដាក់ឱ្យសុំចូលជាសមាជិកដោយសមាជិកអង្គការសហប្រជាជាតិ និងដោយរដ្ឋឯទៀត ដែលមិនមែនជាសមាជិក ដែលបានទទួលការអញ្ជើញដូចខាងលើ ។

លិខិតុបករណ៍សុំចូលជាសមាជិកនេះ នឹងត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

## មាត្រា ១២

នៅពេលណាក៏បាន រដ្ឋភាគីទាំងឡាយអាចជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ អំពីការពង្រីកវិសាលភាពអនុវត្តអនុសញ្ញានេះទៅលើទឹកដីទាំងមូល ឬមួយផ្នែកដែលរដ្ឋភាគីនោះទទួលខុសត្រូវក្នុងការធ្វើទំនាក់ទំនងបរទេស ។

## មាត្រា ១៣

នៅថ្ងៃដែលលិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការសុំចូលជាសមាជិកចំនួនម្ភៃដំបូងគេត្រូវបានតំកល់ អគ្គលេខាធិការត្រូវធ្វើកំណត់ហេតុផ្លូវការ ហើយបញ្ជូនអត្ថបទចម្លងនៃកំណត់ហេតុនោះ ទៅគ្រប់សមាជិកអង្គការសហប្រជាជាតិ និងគ្រប់រដ្ឋដែលមិនមែនជាសមាជិកដូចមានចែងនៅក្នុងមាត្រា៦ ។

អនុសញ្ញានេះ ត្រូវចូលជាធរមាននៅថ្ងៃទី៩០ បន្ទាប់ពីកាលបរិច្ឆេទតំកល់លិខិតុបករណ៍ទីម្ភៃនៃការផ្តល់សច្ចាប័ន ឬការសុំចូលជាសមាជិក ។

ការផ្តល់សច្ចាប័ន ឬការសុំចូលជាសមាជិកណាមួយ ធ្វើឡើងបន្ទាប់ពីកាលបរិច្ឆេទនេះ ត្រូវចូលជាធរមាននៅថ្ងៃទី៩០ ក្រោយពីការដំកល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការសុំចូលជាសមាជិក ។

## មាត្រា ១៤

អនុសញ្ញានេះមានប្រសិទ្ធភាពអនុវត្តរយៈពេលដប់ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែលអនុសញ្ញានេះចូលជាធរមាន ។

បន្ទាប់ពីនោះ អនុសញ្ញានេះនឹងមានប្រសិទ្ធភាពអនុវត្តរយៈពេលប្រាំឆ្នាំទៀត សំរាប់រដ្ឋភាគីទាំងឡាយណាដែលមិនប្រកាសឈប់ទទួលស្គាល់អនុសញ្ញានេះ យ៉ាងតិចចំនួនប្រាំមួយខែមុនថ្ងៃផុតកំណត់នៃអនុសញ្ញានេះ ។

ការប្រកាសឈប់ទទួលស្គាល់អនុសញ្ញានេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ផ្ញើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

## មាត្រា ១៥

ចំពោះការប្រកាសឈប់ទទួលស្គាល់អនុសញ្ញានេះ បើរដ្ឋភាគីនៃអនុសញ្ញានេះនៅមានចំនួនតិចជាងដប់ប្រាំមួយ អនុសញ្ញានេះលែងមានប្រសិទ្ធភាពអនុវត្ត ចាប់ពីកាលបរិច្ឆេទនៃប្រកាសឈប់ទទួលស្គាល់ចុងក្រោយបំផុតចូលជាធរមាន ។

## មាត្រា ១៦

ការស្នើសុំសើរើពិនិត្យអនុសញ្ញានេះ អាចធ្វើបានគ្រប់ពេលវេលាដោយភាគីណាមួយ តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអគ្គលេខាធិការ ។

ប្រសិនជាមានករណីនេះ មហាសន្និបាតត្រូវកំណត់អំពីវិធានការដែលត្រូវចាត់ទៅលើសំណើនេះ ។

## មាត្រា ១៧

អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅគ្រប់រដ្ឋជាសមាជិកអង្គការសហប្រជាជាតិ និងទៅរដ្ឋឯទៀតដែលមិនមែនជាសមាជិក អំពីចំណុចមួយចំនួនដូចខាងក្រោមនេះ :

(ក)- ការចុះហត្ថលេខា ការផ្តល់សច្ចាប័ន និងការចូលជាសមាជិកដែលបានទទួល ស្របតាមមាត្រា១១

(ខ)- ការជូនដំណឹងជាលាយលក្ខណ៍អក្សរដែលបានទទួល ស្របតាមមាត្រា១២

(គ)- កាលបរិច្ឆេទដែលអនុសញ្ញានេះចូលជាធរមាន ស្របតាមមាត្រា១៣

(ឃ)- ការប្រកាសឈប់ទទួលស្គាល់ដែលបានទទួល ស្របតាមមាត្រា១៤

(ង)- ការទុកជាមោឃៈនៃអនុសញ្ញានេះ ស្របតាមមាត្រា១៥

(ច)- ការជូនដំណឹងជាលាយលក្ខណ៍អក្សរដែលបានទទួលស្គាល់ ស្របតាមមាត្រា១៦

## មាត្រា ១៨

ច្បាប់ដើមនៃអនុសញ្ញានេះ ត្រូវបានដំកល់ទុកនៅបណ្ណសារដ្ឋាននៃអង្គការសហប្រជាជាតិ ។

អត្ថបទចំលងត្រឹមត្រូវតាមច្បាប់ដើមមួយច្បាប់ៗ នឹងត្រូវបញ្ជូនទៅគ្រប់រដ្ឋជាសមាជិកអង្គការសហប្រជាជាតិ និងរដ្ឋឯទៀតដែលមិនមែនជាសមាជិក ដូចមានចែងក្នុងមាត្រា១១ ។

## មាត្រា ១៩

អនុសញ្ញានេះ ត្រូវបានចុះបញ្ជីដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ នៅកាលបរិច្ឆេទដែលអនុសញ្ញានេះចូលជាធរមាន ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ :១៣១ /00៣ /២00៧

ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២00៧

**សេចក្តីសម្រេច**

លេខ :0៩២/00៣/២00៧ កបធ.ច

ចុះថ្ងៃទី ១0 ខែ កក្កដា ឆ្នាំ ២00៧

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/0៤៩៨/0៦ ចុះថ្ងៃទី 0៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/0១0៧/00៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២00៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជសារ ចុះថ្ងៃទី ២0 ខែ មិថុនា ឆ្នាំ ២00៧ របស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពមាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២00៧ វេលាម៉ោង ១៤ និង ៣0 នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា ព្រះរាជសាររបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២0 ខែ មិថុនា ឆ្នាំ ២00៧ បានធ្វើឡើងត្រឹមត្រូវតាមមាត្រា ១៤១ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៨ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។
- យល់ឃើញថា មាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋបានចែងថា " ចំពោះបទឧក្រិដ្ឋ និង បទឧក្រិដ្ឋតម្រូវឱ្យធ្វើការ ចៅក្រមមិនត្រូវគិតពីស្ថានត្រាប្រណីទោស ឬបន្ធូរបន្ថយទោសក្រោមអប្បបរមា ឬព្យួរទោសបានឡើយ ។ ចំពោះបទមជ្ឈិមដែលមិនប៉ះពាល់ដល់របៀបរៀបរយសាធារណៈធ្ងន់ធ្ងរទេ អាចត្រូវព្យួរទោសទាំងមូល ឬមួយផ្នែកបាន ។ ក្នុងករណីនេះ ជនដែលបានប្រព្រឹត្តបទល្មើស មិនត្រូវទទួលរង

ទណ្ឌកម្មចប់ចុងចប់ដើមទេ ប្រសិនបើខ្លួនមិនបានប្រព្រឹត្តបទល្មើសមួយផ្សេងទៀតដែលមានចែងក្នុងបណ្តាមាត្រាមុនៗក្នុងរយៈពេល ៥ ឆ្នាំក្រោយពីការកាត់ទោសរបស់ខ្លួន ” ។

- យល់ឃើញថា មាត្រា ៨ នេះ កែប្រែតែមាត្រា ៧០ នៃបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល **ពុំមានប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍កុមារឡើយ** ។ បទបញ្ញត្តិនៃមាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋខាងលើនេះ ពុំមានអធម្មនុញ្ញភាពទេ ។
- យល់ឃើញថា ជាគោលការណ៍ ក្នុងការជំនុំជម្រះក្តី ចៅក្រមពុំមែនគ្រាន់តែផ្អែកទៅលើមាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋតែមួយនេះទេដើម្បីផ្តន្ទាទោសលើឧក្រិដ្ឋជន ប៉ុន្តែចៅក្រមត្រូវផ្អែកលើច្បាប់ ។ ពាក្យថាច្បាប់ខាងលើនេះ មានន័យថា ច្បាប់ជាតិ រួមមានរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលច្បាប់ទាំងឡាយដែលនៅជាធរមាន ហើយនិងច្បាប់អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់រួចមកហើយ ជាពិសេសអនុសញ្ញាស្តីពីសិទ្ធិកុមារ ។

## សម្រេច

**មាត្រា ១.-** មាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០១០២/០០៤ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ឯក សំអុល

សេចក្ដីប្រកាស
ជាសកល
ស្ដីពីសិទ្ធិមនុស្ស
១៩៤៨-២០០៨

**សេចក្ដីថ្លៃថ្នូរ និង**
**យុត្តិធម៌សំរាប់ទាំងអស់គ្នា**

នេះគឺជាការបោះពុម្ពផ្សាយដោយការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងឱកាសខួបលើកទី៦០នៃការអនុម័តសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្សកាលពីឆ្នាំ១៩៤៨ និងខួបលើកទី១៥ នៃការអនុម័តរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា កាលពីឆ្នាំ១៩៩៣។

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
*កម្ពុជា*

*OHCHR*
*00000000019*

ចងក្រងដោយការិយាល័យនៃឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា
ខែកញ្ញា ឆ្នាំ ២០១២

ចែកជូនដោយឥតគិតថ្លៃ